

# ការទុកចិត្ត តីតរផ្ដើ !

ចូរស្វែងរកអំណាពីការទុកចិត្តព្រះជាម្ចាស់
គ្រប់ពេល ក្នុងគ្រប់ការទាំងអស់

ចយស៍ ម៉ៃយ័រ

#1 *NEW YORK TIMES* BESTSELLING AUTHOR

# ការទុកចិត្ត

# សតវទថ្មី!

# ការទុកចិត្ត ឥតរង្គើ!

ចូរស្វែងរកអំណរពីការទុកចិត្តព្រះជាម្ចាស់

គ្រប់ពេល ក្នុងគ្រប់ការទាំងអស់


**ចយស៍ ម៉ៃយ័រ**



JOYCE MEYER MINISTRIES

P.O. Box 548 Phnom Penh,

CAMBODIA



Copyright © 2017 by Joyce Meyer

Cover design by Amber Majors, author photograph by Chad spickler.
Cover copyright @ 2017 by Hachette Book Group, Inc.

Hachette Book Group supports the right to free expression and the value of copyright. The purpose of copyright is to encourage writers and artists to produce the creative works that enrich our culture.

The scanning, uploading, and distribution of this bookwithout permission is a theft of the author’s intellectual property. If you would like permission to use materiel from the book (other than for review purpose), please contact permissions@hbgusa.com. Thank you for your support of the author’s right.

FaithWords
Hachette Book Group
1290 Avenue of the Americas, New York, NY 10104
Faithwords.com
Twitter.com/faithwords

First Edition: September 2017

Faithwords is a division of Hachette Book Group, Inc. The Faithwords name Logo are trademarks of Hachette Book Group, Inc.

The publisher is not responsible for website (or their content) that are not owned by the publisher.

The Hachette Speakers Bureau provides a wide range of authors for speaking events. To find out more, go to www.hachettespeakersbureau.com or call (866) 376-6591.

ព្រះបន្ទូលនៅក្នុងសៀវភៅនេះត្រូវបានដកស្រង់ចេញពីព្រះគម្ពីរបរិសុទ្ធ
និងព្រះគម្ពីរភាសាខ្មែរបច្ចុប្បន្ន។

រក្សាសិទ្ធិគ្រប់យ៉ាង© 2019ដោយព័ន្ធកិច្ច ចយស៍ ម៉ៃយ័រ

**ការទុកចិត្តឥតរង្គើ**!
ចូរស្វែងរកអំណរពីការទុកចិត្តព្រះជាម្ចាស់
គ្រប់ពេល ក្នុងគ្រប់ការទាំងអស់

ISBNs:978-1-4555-6006-6 (hardcover), 978-1-4555-6005-9 (ebook), 978-1-4555-6007-3 (large print)

*PRINTED IN CAMBODIA.*

# មាតិកា


| | | |
|---|---|---|
| អារម្ភកថា | | vii |
| ជំពូក ១ : | តើអ្វីជាសេចក្តីពិត? | ១ |
| ជំពូក ២ : | ទំនុកចិត្តនាំមកនូវការសំរាក | ៩ |
| ជំពូក ៣ : | តើខ្ញុំអាចទុកចិត្តអ្នកណា? | ១៨ |
| ជំពូក ៤ : | ភាពល្ងីល្ងើក្នុងការពឹងផ្អែកលើខ្លួនឯង | ២៨ |
| ជំពូក ៥ : | ចូរទុកចិត្តព្រះជាម្ចាស់និងធ្វើការល្អ (ភាគ ១) | ៣៨ |
| ជំពូក ៦ : | ចូរទុកចិត្តព្រះជាម្ចាស់និងធ្វើការល្អ (ភាគ ២) | ៤៧ |
| ជំពូក ៧ : | នៅគ្រប់ពេលទាំងអស់ | ៥៩ |
| ជំពូក ៨ : | បើព្រះជាម្ចាស់ទ្រង់ល្អមែន ហេតុអ្វីមនុស្សទទួលរងទុក្ខ? | ៧០ |
| ជំពូក ៩ : | តើព្រះជាម្ចាស់ "អនុញ្ញាត" ឲ្យមានទុក្ខវេទនា? | ៨០ |
| ជំពូក ១០: | ហេតុផលនាំឲ្យយើងរងទុក្ខ (ភាគ ១) | ៩០ |
| ជំពូក ១១: | ហេតុផលនាំឲ្យយើងរងទុក្ខ (ភាគ ២) | ១០១ |
| ជំពូក ១២: | មួយផ្នែកទៀតនៃការរងទុក្ខវេទនា | ១១១ |
| ជំពូក ១៣: | ពីមួយថ្ងៃទៅមួយថ្ងៃ | ១២២ |
| ជំពូក ១៤: | ការមិនយល់ដឹង | ១៣០ |
| ជំពូក ១៥: | នៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ (ភាគ ១) | ១៣៨ |
| ជំពូក ១៦: | នៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ (ភាគ ២) | ១៤៦ |
| ជំពូក ១៧: | នៅពេលព្រះជាម្ចាស់ស្ងៀមស្ងាត់ | ១៥៤ |
| ជំពូក ១៨: | ការទុកចិត្តព្រះជាម្ចាស់អំឡុងពេលនៃការផ្លាស់ប្តូរ | ១៦៣ |
| ជំពូក ១៩: | ខ្ញុំពិតជាចង់ផ្លាស់ប្តូរមែន | ១៧២ |
| ជំពូក ២០: | ការទុកចិត្តព្រះជាម្ចាស់ដើម្បីផ្លាស់ប្តូរមនុស្ស | ១៨២ |
| ជំពូក ២១: | ការដោះស្រាយជាមួយការសង្ស័យ | ១៩០ |
| ជំពូក ២២: | តើអ្នកមានបទពិសោធន៍ប៉ុន្មាន? | ១៩៩ |
| ជំពូក ២៣: | ការប្តូរផ្តាច់គ្រប់យ៉ាងថ្វាយព្រះជាម្ចាស់ | ២០៧ |

# សេចក្ដីផ្ដើម

ខ្ញុំមិនអាចគិតប្រធានបទណាផ្សេងទៀត ដែលសំខាន់ជាងដើម្បីសរសេរក្រៅពីការទុកចិត្តព្រះជាម្ចាស់ទេ។ នេះគឺជាប្រធានបទដ៏សំខាន់ ពីព្រោះ ម្ដងយើងជ្រើសរើសការទុកចិត្តព្រះជាម្ចាស់ នោះមានប្រយោជន៍ដ៏ច្រើនរាប់មិនអស់និងការអស្ចារ្យទៀត។ ការទុកចិត្តព្រះជាម្ចាស់គឺជាផ្លូវដ៏អស្ចារ្យបំផុតមួយដើម្បីផ្ដល់ កិត្តិយសដល់ទ្រង់។

តាំងពីដំបូងនៅក្នុងសៀវភៅនេះខ្ញុំចង់សង្កត់ថា ការទុកចិត្តមិនមែនជា ការតព្វកិច្ចដែលយើងជំពាក់ព្រះទេ ការទុកចិត្តគឺជាអភ័យឯកសិទ្ធដែលទ្រង់ប្រទានឲ្យយើង។ យើងត្រូវបានអញ្ជើញដើម្បីឲ្យទុកចិត្តព្រះជាម្ចាស់ ហើយដើម្បីធ្វើការនោះបាន យើងត្រូវបើកទ្វារជីវិតនៃក្ដីសុខសាន្ត អំណរ និងផលផ្លែដ៏បរិបូរ

នៅពេលណាយើងលាយបញ្ចូលចំណែកដែលមានសុខភាពនៃការទុកចិត្តព្រះជាម្ចាស់ទៅក្នុងកិច្ចការដែលយើងធ្វើ នោះវានឹងធ្វើឲ្យយើងរស់នៅដោយ គ្មានទុក្ខព្រួយ គ្មានកង្វល់ គ្មានការភ័យខ្លាច គ្មានហេតុផល ថយភាពស្មុគស្មាញ។ ឧទាហរណ៍ៈ ខ្ញុំកំពុងតែទុកចិត្តព្រះជាម្ចាស់ដើម្បីជួយខ្ញុំសរសេរសៀវភៅនេះ។ នោះមានន័យថា ខ្ញុំដឹងថា ខ្ញុំអត់ដឹងអ្វីៗដែលខ្ញុំត្រូវដឹងក្នុងការទុកចិត្តព្រះហើយខ្ញុំត្រូវបានបញ្ចុះបញ្ចូលថាគ្មានទ្រង់ នោះសៀវភៅនឹងសរសេរមិនបានល្អនោះទេ។ ព្រះជាម្ចាស់ចង់ឲ្យយើងពឹងផ្អែកលើទ្រង់គ្រប់ពេលនិងគ្រប់កិច្ចការទាំងអស់។ គ្មានអ្វីតូចពេកសំរាប់ព្រះជាម្ចាស់ចំពោះការចូលរួម នៅក្នុងទីកន្លែងដែលកូនរបស់ព្រះអង្គមានកង្វល់នោះទេ។

ចាប់តាំងពីម្នាក់ៗមានទំនោរពឹងផ្អែកលើខ្លួនឯងនិងឯករាជ្យមក វាជាធម្មតាធ្វើឲ្យយើងចំណាយពេលច្រើនបន្តិច ដើម្បីរៀនទុកចិត្តព្រះជាម្ចាស់យ៉ាងដូចម្ដេច។ ផ្នែកមួយនៃការលំបាកបណ្ដាលមកពី យើងជួបប្រទះជាមួយរឿងដែលយើងមិនសប្បាយចិត្តដែលធ្វើឲ្យយើងគិតថាមនុស្សទាំងអស់គឺមិនអាចទុកចិត្តបាន។ ប៉ុន្តែផ្លូវរបស់ព្រះជាម្ចាស់ គឺខុសពីផ្លូវរបស់មនុស្ស ហើយព្រះបន្ទូលរបស់ព្រះអង្គបង្រៀនយើងថាព្រះអង្គមិនដែលកុហក និងមិនដែលបោកប្រាស់ឡើយ។

នៅក្នុងសៀវភៅនេះ ខ្ញុំសង្ឃឹមថា អ្វីដែលខ្ញុំចែកចាយជាមួយលោកអ្នក លោកអ្នកអាចរៀនទុកចិត្តព្រះដោយគ្មានបន្ទុក និងមានជំនឿដោយគ្មានហេតុផល។ សរុបមកវិញ ការទុកចិត្តព្រះជាម្ចាស់ទាំងស្រុងគឺជាគោលបំណងរបស់យើង មិនមែនគ្រាន់តែជាការគោរពព្រះអង្គប៉ុណ្ណោះទេ តែក៏ជាប្រយោជន៍ដ៏លើសលប់សំរាប់យើងដែរ។

នៅពេលណាយើងទុកចិត្តព្រះជាម្ចាស់ គឺធ្វើឲ្យទ្រង់សព្វព្រះហឫទ័យ។ ហេព្រើរ ១១:៦ ចែងថា «បើឥតមានសេចក្ដីជំនឿទេ នោះមិនអាចនឹងគាប់ដល់ព្រះហឫទ័យព្រះបានឡើយ»។ សេចក្ដីជំនឿនិងការទុកចិត្ត គឺស្រដៀងគ្នាណាស់ យើងមិនអាចបំបែកបានឡើយ។ ជំនឿគឺជាសារធាតុម្យ៉ាងអញ្ជើញព្រះជាម្ចាស់ ចូលក្នុងជីវិតរបស់យើង។ជំនឿរក្សាព្រះវត្តមានរបស់ព្រះនៅក្នុងជីវិតរបស់យើង ហើយភ្ជាប់យើងជាមួយទ្រង់ក្នុងផ្លូវដែលពេញដោយអំណាចចេស្ដា។

យើងមានសត្រូវ មារសាតាំង ដែលព្យាយាមបំបែកយើងពីទំនាក់ទំនងដ៏រីករាយជាមួយព្រះជាម្ចាស់និងជីវិតដែលទ្រង់ប្រទានដល់យើង។ សាតាំងល្បួងយើងដោយការភ័យខ្លាច ព្រួយបារម្ភ ថប់បារម្ភ ដោះសារ ស្មុគស្មាញ សង្ស័យ ហើយនិងការជាច្រើនទៀតដែលយកគំនិតយើងចេញពីព្រះជាម្ចាស់ ហើយធ្វើឲ្យយើងដឹកនាំជីវិត ខ្លួនឯងក្នុងផ្លូវមួយដែលយើងខំប្រឹងថៃ ទាំងខ្លួនរបស់យើងយ៉ាងត្រដាបត្រដួស។

មានថ្នាំបន្សាបតែមួយគត់សំរាប់ភាពវេទនានេះគឺទុកចិត្តដល់ព្រះជាម្ចាស់។ ខ្ញុំសូមអធិស្ឋាន ពេលអ្នកអានសៀវភៅនេះលោកអ្នកនឹងទទួលព្រះគុណ ក្នុងការរំដោះលោកអ្នកឲ្យរួចមួយរយភាគរយ និងអ្វីដែលធ្វើឲ្យអ្នកព្រួយបារម្ភ ចូរផ្ទេរថ្វាយព្រះក្នុងគ្រប់ស្ថានការណ៍ទាំងអស់ និងគ្រប់ពេលវេលា។

ពេលអ្នកអាន និងសិក្សាសៀវភៅនេះ ចូរទុកព្រះបន្ទូលនៅក្នុងគំនិតៈ មានពរហើយ អ្នកណាដែលជឿដល់ទ្រង់ ទីពឹងដល់ទ្រង់ សង្ឃឹមលើទ្រង់ ហើយទុកចិត្តដល់ទ្រង់។

យេរេមា ១៧:៧

# ការទុកចិត្ត

## ឥតរង្គើ

# ជំពូក ១

## តើអ្វីទៅជាការទុកចិត្ត?

....

*ការចាប់ផ្តើមនៃការថប់បារម្ភ គឺជាចុងបញ្ចប់នៃសេចក្តីជំនឿ ហើយការចាប់ផ្តើមនៃសេចក្តីជំនឿ គឺជាទីបញ្ចប់នៃការថប់បារម្ភ។*

George Mueller

នៅពេលណា យើងទុកចិត្តអ្នកណាម្នាក់ ឬទុកចិត្តអ្វីមួយ ដែលបង្ហាញគួរឲ្យជឿជាក់ នោះជាការបិទបញ្ចប់ការថប់បារម្ភ។ ដូច្នេះ វាមានសារៈសំខាន់ខ្លាំងដើម្បីរៀន តើអ្វីជាការទុកចិត្ត និងការជឿទុកចិត្តយ៉ាងដូចម្តេច។ ជាពិសេស យើងចង់រៀនដើម្បីទុកចិត្តដល់ព្រះជាម្ចាស់។

វចនានុក្រមណូអេ វេបស្ទ័រ ១៨២៨ ឲ្យនិយមន័យពាក្យ ទុកចិត្តថា 'សេចក្តីទុកចិត្ត, សេចក្តីសង្ឃឹមលើ ឬការសំរាកនៃគំនិតចំពោះសេចក្តីសុចរិត, យុត្តិធម៌, មិត្តភាព ឬន័យចំបងម្យ៉ាងទៀតចំពោះអ្នកណាម្នាក់'។ តែអ្នកណាដែលទុកចិត្ត ដល់ព្រះយេហូវ៉ាពិត នោះនឹងបានសុខវិញ (មើលសុភាសិត ២៩:២៥)។

*ការទុកចិត្ត ធ្វើឲ្យយើងមិនអាចរស់នៅដោយគ្មានទម្ងន់, បន្ទុក, ឬការយកចិត្តទុកដាក់។*

ការទុកចិត្តធ្វើឲ្យយើងមិនអាចរស់នៅដោយគ្មានទម្ងន់, បន្ទុក ឬការយកចិត្តទុកដាក់ ពីព្រោះយើងមានទំនុកចិត្តផ្សេងទៀតដែល នឹងធ្វើការជាមួយការនោះសម្រាប់យើង។ ជំនួសឲ្យការមានអារម្មណ៍បែបនោះ គឺយើងកំពុងបន្តផ្ទុកទម្ងន់ដ៏ធ្ងន់នេះ យើងក៏អាចរីករាយនឹងពន្លឺដែលកំពុងតែជះនៅក្នុងព្រលឹងរបស់យើង។

ការដាក់ការទុកចិត្តរបស់យើងទៅលើព្រះជាម្ចាស់ ហើយនិងការបោះបង់ ការយកចិត្តទុកដាក់របស់យើងទៅលើទ្រង់ គឺទាមទារឲ្យយើងធ្វើការសម្រេចចិត្តធ្វើវា។ ទំនុកចម្រៀងរបស់ស្តេចដាវីឌច្រៀងជារើយៗអំពីការទុកចិត្តរបស់ទ្រង់ទៅលើព្រះជាម្ចាស់។ ពាក្យថា 'ទុក' គឺជាសកម្មភាពនៃពាក្យដែលយើងឃើញក្នុងព្រះបន្ទូលទ្រង់ជា

រើយៗ នៅពេលដែលទ្រង់ផ្ដល់ការបង្រៀននូវអ្វីដែលត្រូវធ្វើ ដូចជាទុកក្ដីស្រឡាញ់, ទុកលើបុរសថ្មីម្នាក់, ទុកលើស្បែកជើងនៃក្ដីសុខសាន្ត ក៏ដូចជាទុក ទំនុកចិត្តរបស់អ្នកទៅលើព្រះជាម្ចាស់។ (កូឡូស ៣:១៤, អេភេសូរ ៤:២៤, អេភេសូរ ៦:១៥, សុភាសិត ៣:៥)។

ព្រះគម្ពីរចែងថា 'ចូរផ្ទេរបន្ទុករបស់អ្នកទៅលើព្រះយេហូវ៉ា នោះទ្រង់នឹងជួយទប់ទល់អ្នក... (ទំនុកដំកើង ៥៥:២២)។ ខ្ញុំចូលចិត្តគំនិតថា ចូរផ្ទេរទម្ងន់នៃបន្ទុកចេញ។ ជារឿយៗយើងរស់នៅជាមួយដួងចិត្តដ៏ធ្ងន់ ហើយគំនិតបន្ទុក ប៉ុន្តែព្រះជាម្ចាស់គឺកំពុងតែនាំយើងទៅរកជីវិតដែល មានគុណភាពប្រសើរជាងនេះ ដែលមានតែបទពិសោធន៍មួយគត់គឺការទុកទំនុកចិត្តរបស់យើងទៅលើទ្រង់។ លោកណូអេវេបស្ទ័របាននិយាយថា ការទុកចិត្តគឺជាការសំរាកនៃគំនិត។ លោកសាវកប៉ុលក៏បានបញ្ជាក់ការនេះនៅពេលដែលលោក និយាយថា តែយើងរាល់គ្នាដែលជឿ (ទុកចិត្ត) យើងចូលក្នុងសេចក្ដីសំរាកនោះ វិញ (មើល ហេព្រើរ ៤:៣)។

មានតែវិធីមួយគត់ដែលយើងអាចដឹងបានថា យើងពិតជាមានទំនុចិត្តទៅលើព្រះជាម្ចាស់ ជាជាងព្យាយាមទុកចិត្តទ្រង់ គឺទោះជាមិនមែន ឬ មិនមែនជាព្រលឹងរបស់យើងកំពុងសំរាកក្នុងសេចក្ដីស្មោះត្រង់របស់ព្រះជាម្ចាស់។ ប្រសិនបើខ្ញុំនិយាយថា ខ្ញុំទុកចិត្តទ្រង់ ប៉ុន្តែខ្ញុំនៅតែស្ពាយបន្ទុកដ៏ធ្ងន់ដោយការព្រួយបារម្ភ និង ដោយការថប់បារម្ភ នោះអ្នកមិនបានផ្ទេរបន្ទុកថ្វាយព្រះជាម្ចាស់ឡើយ។ ប្រហែល ជាខ្ញុំចង់ផ្ទេរ ប្រហែលជាខ្ញុំព្យាយាម តែខ្ញុំមិនទាន់បានធ្វើវានៅឡើយ។

ការយល់ពីការនេះបានធ្វើឲ្យខ្ញុំរៀនពីការទុកចិត្តព្រះយ៉ាងដូចម្ដេច? វាលើសពីការនិយាយ វាគឺជាការផ្ទេរបន្ទុករបស់ខ្ញុំ សកម្មភាពនៃការសម្រេចចិត្ត ដែលនាំការសំរាកមកក្នុងព្រលឹងរបស់ខ្ញុំ (គំនិត, ឆន្ទៈ, ដួងចិត្ត)។ គ្រាន់តែស្រម៉ៃ ថា អ្នកកំពុងតែស្ពាយសំពាយដែលមានសុទ្ធតែថ្មទៅគ្រប់កន្លែងដែលអ្នកទៅ។ អ្នកស្ពាយវាទៅធ្វើការ ទៅផ្សារ ទៅវិហារ ហើយវាគឺជាបន្ទុកដ៏ធ្ងន់ តែអ្នកនៅតែ ស្ពាយវា។ ឥឡូវចូរស្រម៉ៃថា អ្នកសម្រេចចិត្តទំលាក់វាចោល ហើយគិតមើលថា តើ អ្នកមានអារម្មណ៍ស្រាលប៉ុណ្ណា ហើយអ្វីៗគ្រប់យ៉ាងនឹងស្រួលជាងប៉ុណ្ណា។

*អ្នកអាចសម្រេចចិត្តទំលាក់បន្ទុករបស់អ្នកចោលនៅថ្ងៃនេះ។*

នោះគឺជាផ្លូវនៅពេលដែលយើងព្រួយហើយស្ពាយបន្ទុក ដ៏ធ្ងន់ជាមួយយើងជំនួសប្រគល់វាឲ្យទៅព្រះជាម្ចាស់។ យើងបន្ត ការនេះហើយធ្វើអ្វីដែលយើងត្រូវការធ្វើ ប៉ុន្តែបន្ទុកដ៏ធ្ងន់បានផ្ទុកភាពស្មុគស្មាញដ៏ធំនៅក្នុងយើងនិងឲ្យជីវិតរបស់ យើងជួបការពិបាក។ អ្នកអាចសម្រេចចិត្តទម្លាក់បន្ទុករបស់អ្នកដោយ

ការទុកចិត្តលើព្រះជាម្ចាស់ ប្រសិនបើអ្នករើស នោះអ្នកនឹងរីករាយដែលអ្នកបានធ្វើការនេះ។

ខ្ញុំបានជួបប្រទះមនុស្សជាច្រើនដែលប្រាប់ខ្ញុំយ៉ាងលឿនថា ពួកគេទុកចិត្តព្រះក្នុងការដោះស្រាយបញ្ហារបស់ពួកគេ មិនទាន់បានអ្វីផង ពួកគេប្រាប់ខ្ញុំថា ពួកគេខ្លាចព្រួយបារម្ភ ហើយព្យាយាមយ៉ាងខ្លាំងរកមូលហេតុអ្វីដែលពួកគេគួរធ្វើ។ ការនេះប្រាប់ខ្ញុំថា ពួកគេជឿ ពួកគេគួរទុកចិត្តព្រះ ហើយពួកគេចង់ទុកចិត្តព្រះ ប៉ុន្តែពួកគេមិនទាន់បានធ្វើបែបនេះទេ។ ពួកគេនិយាយថា ពួកគេទុកចិត្តព្រះ តែពួកគេត្រូវ បានស្ពាយបន្ទុកដ៏ធ្ងន់ជាច្រើន។

ខ្ញុំធ្លាប់បានរៀនថា វិធីដ៏ប្រសើរបំផុតក្នុងដំណើរការទំនាក់ទំនងរបស់យើងជាមួយព្រះជាម្ចាស់ គឺការទុកចិត្តទាំងស្រុងលើទ្រង់។ ទ្រង់ជ្រាបពីសេចក្ដីពិត តែការនោះនឹងជួយយើងឲ្យប្រឈមនឹងវា។ ខ្ញុំបានចំណាយពេលអត់ប្រយោជន៍ជាច្រើនឆ្នាំអះអាងថាខ្ញុំបានទុកចិត្តព្រះពេលដែលខ្ញុំព្រួយ ហើយជួបទុក្ខលំបាក ហើយវាក៏ពិតជាបានជួយខ្ញុំឲ្យស្គាល់ថា ការទុកចិត្តពិតប្រាកដមានផលផ្លែល្អ។ វាបង្កើតសន្តិភាព ជាសន្តិភាពដែលមានការយល់ច្បាស់។

ប្រសិនបើមនុស្សម្នាក់មិនទាន់បានយល់ពីចំណុចដែលអាចទុកចិត្តព្រះទាំងស្រុង វាគឺជាការមួយពិសេសណាស់ក្នុងការស្មោះត្រង់ជាមួយព្រះអំពីការនេះ។ ក្នុងកណ្ឌគម្ពីរលូកា៩ មានរឿងល្អមួយ អំពីឪពុកដែលស្វែងរកការប្រោសឲ្យជាចំពោះកូនប្រុសរបស់ខ្លួន។ គាត់បានប្រាប់ព្រះយេស៊ូថា គាត់បានជឿ ប៉ុន្តែគាត់ត្រូវការជំនួយជួយគាត់ក្នុងការដែលគាត់មិនជឿ (មើលលូកា៩:២៤)។ ខ្ញុំតែងតែចូលចិត្តសេចក្ដីទៀងត្រង់ នេះ ហើយជាដំណឹងល្អ គឺថាគាត់បានទទួលការអស្ចារ្យរបស់គាត់។ យើងគ្រប់គ្នាមានការសង្ស័យលាយជាមួយជំនឿរបស់យើងគ្រប់ពេល។ សង្ឃឹមថា យើងកំពុងលូតលាស់ ហើយកំពុងរៀនទុកចិត្តព្រះជាម្ចាស់ថែមទៀត គ្រប់ពេលវេលា តែការលូតលាស់គឺត្រូវការពេល ហើយគ្មានហេតុផលណាមួយជាលេសទេ បើអ្នកទុកចិត្តព្រះជាម្ចាស់ គឺមិនឥតខ្ចោះនោះទេ។

ខ្ញុំបានបង្រៀនព្រះបន្ទូលរបស់ព្រះជាងសែសិបឆ្នាំ ហើយខ្ញុំក៏បានរៀនទុក ចិត្តព្រះជាច្រើនដែរប៉ុន្មានឆ្នាំនេះ។ ខ្ញុំស្រម៉ៃយ៉ាងមុតមាំថា ខ្ញុំនឹងរៀនថែមទៀតនៅ ពេលខ្ញុំកំពុងរៀន នឹងកំពុងស្រាវជ្រាវសម្រាប់សៀវភៅនេះ។

## *បុគ្គលិកលក្ខណៈនៃព្រះជាម្ចាស់*

ក្នុងវចនានុក្រម Merriam-Webster.com ឲ្យនិយមន័យការទុកចិត្តថាៈ 'ជឿថានរណាម្នាក់ ឬ ជឿថាអ្វីមួយគឺអាចទុកចិត្តបាន ល្អ ស្មោះត្រង់ មានឥទ្ធិពល ។ល។' ការទុកចិត្តគឺអាស្រ័យទៅលើអ្វីដែលយើងដឹងអំពីបុគ្គលិកលក្ខណៈនៃអ្នក ដែលយើងទុកចិត្តនោះ។ បើយើងមិនអាចជឿថា អ្នកនោះល្អ ចិត្តល្អ មានក្តីស្រឡាញ់និងពេញទៅដោយទំនុកចិត្ត នោះយើងមិនអាចដាក់ទំនុកចិត្តរបស់យើង ទៅលើគេបានទេ។

ខ្ញុំបានរកឃើញថា ការសិក្សាលើបុគ្គលិកលក្ខណៈរបស់ព្រះ បានជួយខ្ញុំ សម្បើមណាស់ក្នុងការរៀនពីរបៀបទុកដាក់ទំនុកចិត្តលើព្រះជាម្ចាស់ទាំងស្រុង។ ឧទាហរណ៍ៈ មានចំណុចបុគ្គលិកលក្ខណៈរបស់ព្រះជាម្ចាស់មួយដែលប្រទាន ភាពធូរស្រាលជាច្រើនឲ្យដល់ខ្ញុំ។ នោះមានន័យថា ទ្រង់នឹងតែងតែធ្វើការខុសអោយក្លាយទៅជាត្រូវ។

ខ្ញុំធ្លាប់ទទួលយុត្តិធម៌របស់ទ្រង់ជាច្រើនដងហើយ នៅក្នុងជីវិតរបស់ខ្ញុំ រាល់ពេលហើយនៅពេលដែលខ្ញុំអត់ធ្មត់នឹងអ្វីៗដែលហាក់បីដូច ជាមិនយុត្តិធម៌ ឬមិនស្មើភាពចំពោះខ្ញុំ នោះខ្ញុំអាចទុកចិត្តព្រះក្នុងការដែលធ្វើឲ្យការខុសនោះទៅ ជាត្រូវវិញក្នុងផ្លូវនិងក្នុងពេលរបស់ទ្រង់។ ជីវិតមិនមែនតែងតែស្មើភាពគ្នា ប៉ុន្តែព្រះជាម្ចាស់ទ្រង់យុតិធម៌ ហើយនៅពេលយើងទុកទំនុកចិត្តរបស់យើងលើទ្រង់ នោះទ្រង់នឹង ដោះបន្ទុករបស់យើងចេញ ដ្បិតទ្រង់ធ្វើការតាមយើង ហើយនាំភាពយុត្តិ ធម៌មកក្នុងស្ថានភាពរបស់យើង។

ការទុកចិត្តលើព្រះជាម្ចាស់ក្នុងការនាំមកនូវភាពយុត្តិធម៌ ដោះខ្ញុំពីការងារដែលខ្ញុំព្យាយាមធ្វើដោយខ្លួនឯង។ ព្រះជាម្ចាស់បានបញ្ជាក់ក្នុងព្រះបន្ទូលរបស់ ទ្រង់យ៉ាងច្បាស់ថា ការសងសឹកជារបស់ផងទ្រង់ ទ្រង់នឹងសងគេ ហើយទ្រង់នឹងជំ រុំជំរះរាស្ត្ររបស់ទ្រង់ៈ

> *ដ្បិតយើងស្គាល់ព្រះអង្គដែលទ្រង់មានព្រះបន្ទូលថា «សេចក្តីសងសឹកជារបស់ផងអញ អញនឹងសងគេ នេះជាព្រះបន្ទូលនៃព្រះអម្ចាស់» ហើយ១ទៀតថា «ព្រះ អម្ចាស់ទ្រង់នឹងជំនុំជំរះរាស្ត្រទ្រង់។»*
>
> ហេព្រើរ ១០:៣០

ដើម្បីភ្លក្សបទពិសោធន៍ភាពយុត្តិធម៌របស់ព្រះជាម្ចាស់ យើងត្រូវតែមានឆន្ទៈក្នុងការ បង្វែរស្ថានការណ៍ទៅព្រះជាម្ចាស់ ហើយបដិសេធន៍ក្នុងការព្យាយាមយកការងារមកធ្វើដោយពឹងខ្លួនឯង។ នេះគឺជាផ្នែកមួយដ៏ពិបាក! ហើយខ្ញុំគិតថា ពួកយើងភាគច្រើន គឺតែងតែយកខ្លួនយើងទៅព្យាយាមធ្វើកិច្ចការដោយខ្លួនឯង ដោយគ្មានជោគជ័យ រហូតទាល់តែចុងក្រោយទើបយើងមានឆន្ទៈផ្តល់ការទុកចិត្តលើព្រះជាម្ចាស់។ ពេលមួយ យើងធ្វើបែបនោះ យើងនឹងចាប់ផ្តើមមានបទពិសោធន៍ជា មួយភាពស្មោះត្រង់របស់ព្រះជាម្ចាស់ ការនោះនឹងកាន់តែងាយស្រួលក្នុងទុកចិត្តទ្រង់ម្តងហើយម្តងទៀត។ មានហេតុផលមួយ ពីការទុកចិត្តព្រះជាម្ចាស់អាចជាការលំបាក គឺពីព្រោះទ្រង់មិនបានប្រទានឲ្យយើងភ្លាមៗនូវអ្វីដែលយើងសុំ។ យើងទទួលពីព្រះជាម្ចាស់តាមរយៈសេចក្តីជំនឿហើយនិងការអត់ធ្មត់។ ជាធម្មតា ផ្នែកនៃការរង់ចាំគឺជាការសាកល្បងដែលទាញយឺតសេចក្តីជំនឿរបស់យើងទៅកំរិតថ្មីមួយទៀត។

ព្រះអង្គល្អ ពេញដោយក្តីមេត្តា បរិសុទ្ធ និងសប្បុរស។ ទ្រង់ គឺជាក្តីករុណា ទ្រង់ជាក្តីស្មោះត្រង់ និងជាក្តីពិត។ ព្រះគឺជាក្តីស្រឡាញ់! គ្រប់ពេលវេលា ទ្រង់នៅតែដដែល ហើយយើងអាចពឹងផ្អែកលើទ្រង់តាមព្រះបន្ទូលរបស់ទ្រង់។

វាជាការងាយក្នុងការដាក់ទំទុកចិត្តរបស់យើងទៅលើអ្នកណាម្នាក់ យើងជឿថាគេស្រឡាញ់យើង ហើយមិនត្រឹមតែមានឫទ្ធិអំណាចជួយយើងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានចិត្តចង់ជួយយើងទៀតផង! ព្រះជាម្ចាស់កំពុងតែរង់ចាំជួយអ្នក ហើយនិងខ្ញុំ ហើយរាល់អ្វីដែលយើងត្រូវការធ្វើគឺគ្រាន់តែទុកចិត្តលើទ្រង់ដើម្បីធ្វើការនោះប៉ុណ្ណោះ។ តាមតែខ្ញុំមើលពីជីវិតរបស់ខ្ញុំកាលពីមុន ខ្ញុំអាចនិយាយយ៉ាងប្រាកដថាព្រះជាម្ចាស់គឺពិតជាស្មោះត្រង់។ ទ្រង់តែងតែនៅចាំជួយយើង ទោះបីជាយើងមិនបាន ឃើញទ្រង់ក៏ដោយ។ ដរាបណាយើងជឿថាទ្រង់កំពុងធ្វើការ នោះទ្រង់នឹងបង្ហាញហើយបើកសម្តែង ពីភ័ស្តុតាងនៃកិច្ចការរបស់ទ្រង់នៅក្នុងពេលដ៏ត្រឹមត្រូវមួយ។ ចូរ កុំបោះបង់ទោះបីជាពេលរង់ចាំហាក់បីជាយូរបន្តិចក្តី ចូរបន្តការទុកចិត្តលើព្រះជាម្ចាស់!

គ្រប់ពេលដែលខ្ញុំជួបការលំបាកក្នុងការទុកចិត្តព្រះ ខ្ញុំនឹកចាំពីការដែល ទ្រង់បានធ្វើសម្រាប់ខ្ញុំកាលពីមុន ហើយខ្ញុំប្រាកដថា ទ្រង់នឹងធ្វើវាម្តងទៀត។ ខ្ញុំបានបន្តធ្វើបែបនេះ៤០ឆ្នាំហើយ ហើយខ្ញុំបានឆ្លងកាត់ការថ្មីមួយពីឆ្នាំ១៩៧០ ពេលនោះខ្ញុំបានសុំព្រះជាម្ចាស់ឲ្យប្រទានកន្សែងថ្មីជូតចានមួយឡូដល់ខ្ញុំ។ បងដេវនិងខ្ញុំគ្មានប្រាក់ទិញកន្សែង នោះទេ ហើយតាំងពីខ្ញុំចាប់ផ្តើមដំណើររបស់ខ្ញុំក្នុងការទុកចិត្តព្រះមក ខ្ញុំបានទទូចសុំកន្សែងនោះពីទ្រង់ដូចជាកូនក្មេងអ៊ីចឹង។ សូមស្រម៉ៃមើលក្តីរីករាយរបស់ខ្ញុំប៉ុន្មានសប្តាហ៍ក្រោយមក ស្ត្រីម្នាក់ដែលខ្ញុំទើបស្គាល់ បានបង្ហាញខ្លួននៅមាត់

ទ្វារផ្ទះរបស់ខ្ញុំហើយនិយាយថា «ខ្ញុំសង្ឃឹមថា អ្នកស្រីនឹងមិនគិតថាខ្ញុំឆ្កួតទេ ប៉ុន្តែខ្ញុំបានមានអារម្មណ៍ថា ព្រះជាម្ចាស់ចង់ឲ្យខ្ញុំយកកន្សែងជូតចានថ្មីមួយចំនួនមកជូនអ្នកស្រី!» ខ្ញុំបានរំភើបជាខ្លាំងនូវទង្វើរបស់នាងរហូតដល់ខ្ញុំពន្យល់នាងថា ខ្ញុំបានទូលសុំព្រះជាម្ចាស់នូវកន្សែងជូតចានទាំងនោះ។

នោះគឺជាបទពិសោធន៍ដ៏ប្រាកដមួយរបស់ខ្ញុំជាមួយភាពស្មោះត្រង់របស់ព្រះជាម្ចាស់ ហើយក៏មានការជាច្រើនទៀតកើតឡើងជាហូរហែរ។

នៅក្នុងព្រះគម្ពីរប៊ីបដែលយើងបានអាន នៅពេលដាវីឌចង់ទៅសម្លាប់យក្ស កូលីយ៉ាត គ្រប់គ្នាបានបំបាក់ទឹកចិត្តរបស់គាត់ ហើយប្រាប់គាត់ថាគាត់នឹងចាញ់ គាត់បាននឹកចាំពីសត្វសិង្ហ និង ខ្លាឃ្មុំដែលបានគាត់បានសម្លាប់កាលពីមុនដោយសារក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ជួយ។ ជំនឿរបស់គាត់បានកើនឡើង ហើយគាត់បានសម្លាប់កូលីយ៉ាត។ (១សាំយូអែល ១៧:៣៤-៣៦)។

ខ្ញុំចង់លើកទឹកចិត្តលោកអ្នកឲ្យចំណាយពេល ប្រហែលជាពេលឥឡូវនេះ សរសេរនូវពេលវេលាមួយចំនួន ដែលលោកអ្នកធ្លាប់មានបទពិសោធន៍ ជាមួយការស្មោះត្រង់របស់ព្រះជាម្ចាស់នៅក្នុងជីវិតផ្ទាល់ខ្លួនរបស់លោកអ្នក។ ខ្ញុំអាចប្រាកដជាមួយលោកអ្នកថា ការនេះនឹងស៊ីជាមួយសេចក្តីជំនឿរបស់លោកអ្នក ហើយអាចធ្វើឲ្យអ្នកទុកចិត្តលើព្រះជាម្ចាស់បានយ៉ាងងាយនូវអ្វីដែលអ្នកត្រូវការនៅក្នុងជីវិត របស់លោកអ្នកនាពេលបច្ចុប្បន្ននេះ។

ខ្ញុំធ្លាប់បានឮពាក្រ 'ស្មោះត្រង់' មានន័យថា «ទុកចិត្តលើ ឬពឹងផ្អែកលើ»។ យើងអាចពឹងលើព្រះជាម្ចាស់! យើងក៏អាចផ្អែកលើទ្រង់។ ទ្រង់បានសន្យាថា មិនចាកចេញពីយើង ឬ បោះបង់យើងចោលឡើយ ប៉ុន្តែតែងតែគង់នៅជាមួយយើង។ (មើលក្នុងកណ្ឌគម្ពីរម៉ាថាយ ២៨:២០)។

នៅពេលណាយើងត្រូវការអ្វីមួយចាំបាច់ យើងអាចទុកចិត្តទ្រង់គង់ជាមួយយើង និងជួយយើង។ (មើលក្នុងកណ្ឌគម្ពីរហេព្រើរ១៣:៥)។ ពេលណា យើងឆ្លងកាត់បទពិសោធន៍នេះ ទ្រង់គង់នៅជាមួយយើង ហើយតែងតែជួយយើង (សូមមើល១កូរិនថូស ១០:១៣)។ ហើយបើគេគ្រប់គ្នាបោះបង់យើង ក៏ទ្រង់នៅតែគង់ជាមួយយើង ហើយទ្រង់នៅតែស្មោះត្រង់ (មើល ២ធីម៉ូថេ ៤:១៦-១៧)។

ការសិក្សាដ៏ច្បាស់លាស់នៃចំណុចនិមួយៗ នៃលក្ខណៈរបស់ព្រះជាម្ចាស់ គឺជាប្រយោជន៍យ៉ាងខ្លាំងមួយក្នុងការជួយយើងឲ្យរៀនទុកចិត្តទ្រង់។ ខ្ញុំនឹងបញ្ជាក់ បន្ថែមទៀតពីលក្ខណៈរបស់ទ្រង់តាមរយៈសៀវភៅនេះ ប៉ុន្តែខ្ញុំក៏សូមលើកទឹកចិត្ត លោកអ្នកឲ្យស្វែងរកធនធានបន្ថែមទៀតពីប្រធានបទនេះ ហើយសិក្សាដោយខ្លួន ឯង។

## ទំនុកចិត្ត

ទុកចិត្តគឺនិយាយពីទំនុកចិត្ត! យើងទាំងអស់គ្នាដឹងថាជីវិតងាយស្រួល គឺពេលណាយើងមានទំនុកចិត្ត។ ការជឿជាក់ថាយើងអាចធ្វើបាន ជួយឲ្យយើងរស់នៅ ដោយភាពក្លាហានជាមួយនឹងអំណរ ហើយការរំពឹងទុកក៏វិជ្ជមានដែរ។ក្នុងនាមជាអ្នកជឿព្រះយេស៊ូ ទំនុកចិត្តរបស់យើងត្រូវនៅលើទ្រង់។ យើងគ្រប់គ្នាមានទំនុកចិត្តកន្លែងខ្លះៗ ប៉ុន្តែយើងអាចប្រាកដច្បាស់គ្រប់ទាំងអស់នៃជីវិត តាមរយៈការទុកចិត្តលើព្រះជាម្ចាស់។ ឧទាហរណ៍ ដូចជាពេលខ្លះ ខ្ញុំមានអារម្មណ៍ ថា ប្រាកដច្បាស់ពេលដែលខ្ញុំកំពុងបង្រៀនក្នុងមហាសន្និបាត ប៉ុន្តែក៏មានពេលខ្លះខ្ញុំអត់ប្រាកដច្បាស់ដែរ។ គ្រប់ពេលទាំងនោះ ខ្ញុំអាចជ្រើសរើសយកការប្រាកដច្បាស់បានដរាបណា ទំនុកចិត្តរបស់ខ្ញុំនៅលើព្រះគ្រីស្ទ មិនមែនខ្លួនរបស់ខ្ញុំ ឬ ខ្ញុំមានអារម្មណ៍បែបណា។

លោកសាវកប៉ុលបានបញ្ជាក់យ៉ាងច្បាស់ថា គាត់មិនបានទុកចិត្តលើសាច់ឈាមឡើយ។ ទោះបីជាលោកមានផលប្រយោជន៍ជាច្រើនពីកំណើតមកក្តី ក៏លោកមិនបានដាក់ការទុកចិត្តរបស់លោកលើរបស់ក្រៅខ្លួនទាំងនោះដែរ។ លោកបាននិយាយដោយចេញពីចិត្តថា ទំនុកចិត្តរបស់យើងគឺនៅក្នុងព្រះគ្រីស្ទ(មើលកណ្ឌគម្ពីរ ភីលីព ៣:៣)។

ការទុកចិត្ត គឺជាទំនុកចិត្តលើអ្នកណាម្នាក់ ដែលត្រូវបានគេទុកចិត្តលើ ហើយទំនុកចិត្តលើព្រះគ្រីស្ទធ្វើឲ្យយើងមានភាពងាយស្រួល!វាធ្វើឲ្យយើងធ្វើកិច្ចការដោយស្រួលពីព្រោះយើងជឿថាយើងអាចធ្វើបាននូវអ្វីដែលយើងចង់ធ្វើឲ្យរួចរាល់។ការទុកចិត្តប្រាកដច្បាស់ដកអស់ភាពស្មុគស្មាញ សំពាធ ទុក្ខព្រួយ ហើយនិងការភ័យខ្លាច។

> *ទុកចិត្ត គឺជាទំនុកចិត្តលើអ្នកណាម្នាក់ដែលត្រូវបានគេទុកចិត្តលើ។*

ខ្ញុំនិយាយថា យើង«មាន»ទំនុកចិត្ត សូម្បីតែយើងគ្មាន«អារម្មណ៍»ទុកចិត្តក៏ដោយ ហើយនេះជាចំណុចដ៏សំខាន់។ អារម្មណ៍រេរា វាអាចផ្លាស់ប្តូរ គ្រប់ពេលបាន មិនអាចកំណត់បានទេ។ ដូច្នេះការដាក់ទំនុកចិត្តរបស់យើងលើអារម្មណ៍ គឺជារឿងមិនឆ្លាតទេ

អ្នកប្រហែលជាដាក់ពាក្យទៅធ្វើការនៅកន្លែងមួយហើយអ្នកចាប់ផ្តើម មានទំនុកចិត្តដោយសារអ្នកជឿថាអ្នកមានជំនាញដែលគេត្រូវការ។ ប៉ុន្តែ នៅពាក់កណ្តាលផ្លូវទៅសម្ភាសន៍ អ្នកចាប់ផ្តើមមានអារម្មណ៍ថា អ្នកដែលសម្ភាសន៍ អ្នកមិនចូលចិត្តអ្នកសោះ ហើយរំពេចនោះ គំនិតនោះ (អាចមិនមែនជាការពិត) បានធ្វើឲ្យអ្នកបាត់បង់

ទំនុកចិត្ត។ យ៉ាងណាក្តី ប្រសិនបើ អ្នកមានទំនុកចិត្តលើព្រះ អ្នកអាចទុកចិត្តលើព្រះអង្គក្នុងការផ្តល់ព្រះគុណដល់អ្នក ហើយអ្នកអាចបន្ត ការសម្ភាសន៍របស់អ្នកជាមួយនឹងទំនុកចិត្តនោះ បើសិនការងារនោះសាកសមជាមួយអ្នក អ្នកនឹងបានទទួលការងារនោះ។

សាតាំងមិនចង់ឲ្យយើងមានទំនុកចិត្ត ដោយសារវាដឹងថា បើគ្មានទំនុកចិត្តទេ យើងនឹងមិនមានភាពជោគជ័យនៅក្នុងជីវិតប៉ុន្មានទេ។ សូម្បីតែមនុស្សដែលមានទេពកោសល្យ ឆ្លាតវ័យនិងមានសមត្ថភាពក្តី ពួកគេត្រូវការទំនុកចិត្ត។

ទំនុកចិត្តសម្រាប់យើង ប្រេងសម្រាប់យន្តហោះ ៖ យន្តហោះត្រូវការប្រេង ដើម្បីអាចហោះហើរបាន បើគ្មានប្រេងទេ វាមិនអាចហោះបានទេ។

វាមិនអាចទៅរួចទេ ក្នុងការមានទំនុកចិត្តទាំងស្រុង ប្រសិនបើ ដាក់ទំនុក ចិត្តខុសកន្លែង នៅលើមនុស្ស ឬសម្ភារៈ ព្រោះរបស់ទាំងនោះអាចផ្លាស់ប្រែបាន ប៉ុន្តែ ព្រះអង្គមិនប្រែប្រួលឡើយ ហើយទ្រង់ក៏មិនកុហកដែរ! ព្រះអង្គជាថ្មដា ដែលយើងឈរលើនៅក្នុងលោកីយ៍ដែលមិនដូចជារលកសមុទ្រដែលប្រែប្រួលទេ។

# ជំពូក ២

## ទំនុកចិត្តនាំមកនូវការសំរាក

*អស់អ្នកដែលនឿយហត់និងមានបន្ទុកធ្ងន់អើយ! ចូរមករកខ្ញុំ ខ្ញុំនឹងអោយអ្នករាល់គ្នាបានសំរាក...*

*(ម៉ាថាយ ១១៖២៨) (KHOV)*

និយមន័យនៃការទុកចិត្តនៅក្នុងវេបស្ទើណូអេ លោកបានសន្មតថា វាជាការសម្រាកនៃគំនិតលើអាកប្បកិរិយាល្អរបស់អ្នកណាម្នាក់ផ្សេងទៀត។ ខ្ញុំមានអារម្មណ៍ថាវាសំខាន់ណាស់ដើម្បីកំណត់និយមន័យជំពូកក្នុងសៀវភៅនេះទៅកាន់គំនិតនៃការសំរាករបស់ចិត្តគំនិត។ នេះគឺជាអ្វីដែលទាំងអស់គ្នាត្រូវការយ៉ាងខ្លាំង ហើយមនុស្សភាគច្រើនបំផុតចង់បានវា។ មានរឿងជាច្រើនក្នុងជីវិតរបស់យើងដែលត្រូវយកចិត្តទុកដាក់ដើម្បីគិតអំពីពួកវាដោយមិនមានអារម្មណ៍រំជើបរំជួល។ ព្រះជាម្ចាស់ចង់ជួយយើង ប៉ុន្តែស្របពេលជាមួយគ្នា យើងត្រូវព្យាយាមបន្តធ្វើវាទាំងអស់ដោយខ្លួនរបស់យើង ទ្រង់នឹងមិនចង់បង្ខំការជួយរបស់ទ្រង់លើយើងទាំងស្រុងទេ។

ជាញឹកញាប់ព្រះជាម្ចាស់ផ្តល់ជំនួយដល់យើងដោយបញ្ជូនមនុស្សដទៃដើម្បីជួយចែករំលែកបន្ទុករបស់យើងនៅក្នុងជិវិត។ ដេវ និងខ្ញុំ យើងមានកូនប្រុសពីរនាក់ដែលធ្វើការជាមួយយើងនៅក្នុងព័ន្ធកិច្ច ហើយព្រះជាម្ចាស់បានបញ្ជូនពួកគេមកជួយយើងដោយចែករំលែកបន្ទុកនៃការគ្រប់គ្រងព័ន្ធកិច្ចដ៏ធំនេះ។ វាពិតជាពិបាកនៅគ្រាដំបូងសម្រាប់យើងក្នុងការប្រលែងកិច្ចការដែលយើងធ្លាប់ទទួលខុសត្រូវពីមុន ហើយប្រគល់ពួកវាទៅអោយកូនប្រុសៗរបស់យើង។ វាជាការសម្រេចចិត្តដែលយើងបានធ្វើ ហើយការធ្វើដូច្នេះបានផ្តល់អោយយើងនូវការសម្រាកដ៏អស្ចារ្យនៃគំនិត និងព្រលឹងរបស់យើង។

មានកិច្ចការនិងស្ថានភាពជាច្រើនដែលយើងមិនមានបន្តទៀត ដើម្បីគិតអំពីវាពីព្រោះកូនៗរបស់យើងបានមើលថៃពួកវាសម្រាប់យើង។ ខ្ញុំមានពេលទំនេរដើម្បីបង្រៀន និពន្ធ អធិស្ឋាន សិក្សា នឹងសម្រាប់ការធ្វើបទបង្ហាញតាមទូរទស្សន៍របស់ខ្ញុំ។ ដូចដែលខ្ញុំអង្គុយនៅទីនេះ ហើយសរសេរ មានកិច្ចការជាច្រើនដែលដំណើរការទៅ

នៅក្នុងព័ន្ធកិច្ចដែលខ្ញុំមិនបានដឹងពីវា។ ខ្ញុំឃើញលទ្ធផលហើយវាគឺតែងតែល្អ ប៉ុន្តែខ្ញុំទុកចិត្តកូនៗរបស់ខ្ញុំ ដើម្បីគ្រប់គ្រងគ្រប់ទិដ្ឋភាពទាំងអស់នៃការនាំយើងទៅរកលទ្ធផលនោះ។ កូនប្រុសរបស់ខ្ញុំ ដាន ទើបតែប្រាប់ខ្ញុំម្សិលមិញនេះថា កម្មវិធីទូរទស្សន៍របស់យើងឥឡូវនេះមាននៅលើ ណែតវ្លិក ហើយខ្ញុំពិតជាមានការរំភើបដោយការភ្ញាក់ផ្អើលយ៉ាងខ្លាំង។ នោះគឺជាឱកាសដ៏អស្ចារ្យដើម្បីទៅដល់មនុស្សជាច្រើន ហើយទាំងអស់នេះបានកើតឡើងដោយមិនមានការជាប់ទាក់ទងរបស់ខ្ញុំនោះទេ ព្រោះខ្ញុំបានប្រគល់ផ្នែកនៃការគ្រប់គ្រងនៃព័ន្ធកិច្ចនោះទៅអ្នកណាម្នាក់ផ្សេងទៀត។

កូនប្រុសរបស់ខ្ញុំ ដាវីឌ បានធ្វើអោយខ្ញុំភ្ញាក់ផ្អើល នៅពេលដែលគេបានបង្ហាញខ្ញុំនូវរូបភាពនៃគំរោងនៅ *តានស្សានីអា* ដែលយើងបានឧបត្ថមនិងមើលខុសត្រូវ។ ខ្ញុំទទួលបានអំណរនៃការចែករំលែកនៅក្នុង ការសាទរនៃការជួយដល់មនុស្សជាច្រើន ប៉ុន្តែខ្ញុំមិនមានក្តីបារម្ភសូម្បីតែម្តងអំពីសេចក្តីលំអិតរាប់ពាន់ ដែលបានចូលទៅក្នុងការធ្វើអោយគំរោងទទួលបានជោគជ័យ។

កូនប្រុសៗរបស់ពួកយើងគឺជាដៃគូររបស់យើងនៅក្នុងព័ន្ធកិច្ច ហើយទោះបីជាយើងនៅតែធ្វើការធ្ងន់ តែយើងក៏មិនមានភារៈនិងបន្ទុកធ្ងន់ហួសពេកនោះដែរ។ យើងមិនត្រូវបានសង្កត់សង្កិនដោយក្តីបារម្ភនិងភាពខ្វល់ខ្វាយទេ។ គំនិតរបស់យើងគឺបានសំរាក!

ព្រះជាម្ចាស់មានសេចក្តីអំណរក្នុងការធ្វើអោយយើងភ្ញាក់ផ្អើល ហើយនឹងធ្វើដូច្នេះជារឿយៗ ប្រសិនបើយើងដាក់បញ្ហានានានិងការការពារទៅក្នុងព្រះហស្តរបស់ទ្រង់។ ទ្រង់ចង់ធ្វើជាដៃគូរជាមួយយើងក្នុងជីវិតរបស់យើង ហើយនៅពេលដែលយើងយល់ព្រមអោយព្រះអង្គធ្វើដូច្នេះ ចិត្តរបស់យើងនឹងអាចសំរាកបាន។ យោងតាមខគម្ពីរ យើងត្រូវបានត្រាស់ហៅទៅក្នុងភាពជាមិត្តសម្លាញ់និង ការប្រកបជាមួយនឹងព្រះជាម្ចាស់។ ១កូរិនថូស ១៖៩(KHSV) បាននិយាយរបៀបនេះ៖

> *ព្រះជាម្ចាស់មានព្រះទ័យស្មោះត្រង់ គួរទុកចិត្ត អាចទុកចិត្តបាន) ដូច្នេះ ហើយព្រះបន្ទូលសន្យារបស់ទ្រង់គឺតែងតែពិត ហើយយើងអាចពឹងផ្អែកលើទ្រង់បាន ព្រះអង្គបានត្រាស់ហៅបងប្អូនអោយរួមរស់ជាមួយព្រះបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូគ្រិស្តជាព្រះអម្ចាស់នៃយើង។*

ទំនាក់ទំនងជាមួយព្រះជាម្ចាស់ គឺច្រើនជាងការអានខគម្ពីរមួយថ្ងៃៗ ច្រើនជាងការទៅព្រះវិហាររៀងរាល់សប្តាហ៍ ច្រើនជាងការថ្វាយតង្វាយ ហើយប្រហែលជាការធ្វើរឿងល្អមួយចំនួន។ នោះគឺគ្រាន់តែជាបែបផែនសាសនាប៉ុណ្ណោះ ប៉ុន្តែទំនាក់ទំនង

*ចូរទុកចិត្តព្រះថាទ្រង់ជួយអ្នកអោយធ្វើបានល្អបំផុត ហើយទុកចិត្តទ្រង់ធ្វើអោយសំរាក*

ដែលបរិបូណ៌ និង ដ៏អស្ចារ្យគឺយើងថ្វាយតាមរយៈ សេចក្ដីជំនឿក្នុងព្រះគ្រីស្ទជាដៃគូរ។ ទ្រង់ប្រទានអោយយើងនូវលទ្ធភាពហើយ ថាយើងប្រើប្រាស់វាគ្រប់កាលៈទេសទាំងអស់យើងជឿលើទ្រង់។ ទ្រង់ក៏រួចរាល់ផងដែរក្នុងការដោះស្រាយគ្រប់ទាំងបញ្ហាទាំងអស់ដែលយើងមិនអាចដោះស្រាយបាន។ ខ្ញុំចង់និយាយថា *ចូរទុកចិត្តព្រះថាទ្រង់ជួយអ្នកឱ្យធ្វើបានល្អបំផុតហើយទុកចិត្តទ្រង់ធ្វើឱ្យសំរាក។*

## *ក្ដីសុខសាន្តនៃចិត្តគំនិត*

ព្រះជាម្ចាស់ប្រទានអោយយើងនូវក្ដីសុខសាន្តនៃផ្លូវចិត្តនៅពេលដែលយើងដាក់សេចក្ដីទុកចិត្តក្នុងទ្រង់។ ជាទូទៅនៅថ្ងៃបន្ទាប់មានគំនិជាច្រើនចូលមកក្នុងចិត្ត ដែលបណ្ដាលអោយមានក្ដីបារម្ភនិងភាពខ្វល់ខ្វាយ។ ព្រឹកនេះខ្ញុំបាននៅជាមួយមនុស្សម្នាក់ដែលស្ទៀមស្ងាត់បំផុត ហើយក៏មិនចាប់អារម្មណ៍ក្នុងការសន្ទនាជាមួយខ្ញុំដែរ ហើយគំនិតរបស់ខ្ញុំបានគិតទៅដល់រឿងមួយនេះ៖ *ខ្ញុំមិនគិតថានាងចូលចិត្តខ្ញុំខ្លាំងនោះទេ។* ខណៈដែលខ្ញុំគិតដូចនោះ ខ្ញុំចាប់ផ្ដើមមានអារម្មណ៍ថាខ្ញុំត្រូវ «ធ្វើអ្វីមួយ» ដើម្បីផ្លាស់ប្ដូរស្ថានភាព តែខ្ញុំនៅមិនទាន់មានគំនិតណាមួយថាគួរនឹងធ្វើអ្វីនោះទេ។

នៅពេលដែលយើងព្យាយាមធ្វើអ្វីមួយដែលយើងមិនទាន់មានគំនិតថាតើគួរធ្វើវាយ៉ាងដូចម្ដេច វាតែងតែបង្កើតភាពស្មុកស្មាញ បន្ទុក កង្វល់ ហើយពេលខ្លះមានភាពភ័យខ្លាច។ តើនៅក្នុងជីវិតរបស់អ្នកមានរឿងដែលអ្នកមានអារម្មណ៍ថាការទទួលខុសត្រូវដើម្បី «ដោះស្រាយ» ប៉ុន្ដែអ្នកមិនមានគំនិតអ្វីដើម្បីធ្វើពួកវា? ប្រសិនបើដូច្នេះ អ្នកអាចធ្វើអ្វីដែលខ្ញុំបានធ្វើនៅព្រឹកនេះហើយអធិស្ឋាន ការថ្វាយស្ថានភាពទៅព្រះជាម្ចាស់ហើយទុកចិត្តទ្រង់ដើម្បី «ដោះស្រាយវា។» ខ្ញុំបានអធិស្ឋានតាមគំរូការអធិស្ឋានដោយនិយាយថា «ព្រះបិតា ទូលបង្គំដាក់ទំនាក់ទំនងរបស់ទូលបង្គំជាមួយ ................ក្នុងព្រះហស្តរបស់ទ្រង់។ ទូលបង្គំថ្វាយវាទៅទ្រង់ ហើយសូមទ្រង់ធ្វើនូវអ្វីដែលទ្រង់សព្វព្រះហឫទ័យ។» ភ្លាមៗដែលខ្ញុំបានធ្វើដូច្នោះ ក្ដីសុខសាន្តនៃគំនិតរបស់ខ្ញុំបានត្រឡប់មកវិញ។

បន្ទាប់មកមិនយូរប៉ុន្មាន ខ្ញុំបានឮពីកូនម្នាក់ក្នុងចំណោមកូនៗរបស់ខ្ញុំ ហើយខ្ញុំអាចប្រាប់បានថាពួកគេមិនមានអារម្មណ៍ល្អនោះទេ។ ខ្ញុំបានសុំ ប្រសិនបើខ្ញុំអាចជួយក្នុងមធ្យោបាយណាមួយ ប៉ុន្ដែពួកគេបាននិយាយថា ទេ ហើយភ្លាមៗនោះគំនិតរបស់ខ្ញុំគឺ *ខ្ញុំឆ្ងល់ថាមានអ្វីខុស? តើពួកគេឈ្លោះប្រកែកជាមួយអ្នកណាឬ? តើពួកគេមាន*

*បញ្ហាផ្លូវចិត្តឬ? តើមានអ្វីកើតឡើង?* ខ្ញុំមានកាតាបស្ពាយដែលមានបន្ទុកធ្ងន់របស់ខ្ញុំ ហើយខ្ញុំរួចរាល់ជាស្រេចដើម្បីស្ពាយវាពេញមួយថ្ងៃ ពេលដែលខ្ញុំចងចាំថាខ្ញុំអាចលះបង់វាទៅព្រះជាម្ចាស់ ដែលទ្រង់តែម្នាក់គត់ដែលបានដឹងពីអ្វីដែលខុសនិងអ្វីដែលត្រូវធ្វើអំពីវា។

ខ្ញុំបានអធិស្ឋានថា «ព្រះបិតាអើយ សូមជួយ.....................សម្រេចចិត្តដើម្បីមានថ្ងៃល្អ។ សូមសម្តែងអោយពួកគេបានឃើញថា តើពួកគេមានពរយ៉ាងណា ហើយជំនួសអោយភាពទុក្ខសោកដោយការអរព្រះគុណ។» ក្នុងរយះពេលដ៏ខ្លីបន្ទាប់ពីការអធិស្ឋាននោះ ខ្ញុំបានទទួលឃ្លានេះ «ខ្ញុំមានអារម្មណ៍ប្រសើរច្រើនណាស់ឥឡូវនេះ។ ខ្ញុំស្រលាញ់អ្នក!»

យើងអាចមានបទពិសោធន៍ក្នុងរឿងជាច្រើនដូចជាក្នុងប៉ុន្មានថ្ងៃនេះ។ វាមិនគួរអោយឆ្ងល់នោះទេដែលមនុស្សចាកចេញពីភាពស្មុកស្មាញ នៅពេលដែលពួកគេដឹងថា ត្រូវទុក ចិត្ត ហើយចោលភាពកង្វល់របស់គេទៅថ្វាយព្រះជាម្ចាស់យ៉ាងដូចម្តេច។ ខ្ញុំក៏ធ្លាប់ជាមនុស្សម្នាក់ ក្នុងចំណោមមនុស្សជាច្រើនស្ទើរតែពាក់កណ្តាលជីវិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំពិតជាអរព្រះគុណដែលបានដឹងនូវអ្វីដែលត្រូវដោះស្រាយជាមួយខ្ញុំ។

សូមអោយព្រះជាម្ចាស់ចែករំលែកថ្ងៃរបស់អ្នក ដោយនិយាយជាមួយទ្រង់ពីរឿងគ្រប់យ៉ាង។ ការអធិស្ឋានជាការនិយាយគ្នាដ៏សាមញ្ញជាមួយព្រះជាម្ចាស់ ដូច្នេះខ្ញុំសូម កុំអោយអ្នកមើលទៅវាដូចជាករណីកិច្ចដែលត្រូវរៀបចំនោះឡើយ។ ការអធិស្ឋានគឺជាវិធីរបស់យើងដែលអនុញ្ញាតអោយព្រះជាម្ចាស់ចូលមកក្នុងជីវិតរបស់យើងតាមគ្រប់ទិដ្ឋភាពទាំងអស់ រាប់បញ្ចូលទាំងម្នាក់ដែលព្យាយាមលួចក្តីសុខសាន្តរបស់យើងនឹងនាំអោយយើងថប់បារម្ភ។

សូមកុំអនុញ្ញាតអោយការបោកបញ្ឆោតចូលទៅក្នុងសេចក្តីជំនឿ ដែលអ្នកមិនមានជំរើសនូវអ្វីដែលអ្នកបានគិតនោះឡើយ។ ប្រសិនបើគំនិតដែលមាននៅក្នុងចិត្តរបស់អ្នកជាសេចក្តីព្រួយបារម្ភឬជាទុក្ខកង្វល់ នោះអ្នកអាចជ្រើសរើសគិតពីអ្វីផ្សេងបាន។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់បង្រៀនយើងដើម្បីបណ្តេញការគិតខុស ដោយនាំការទាំងអស់ដែលមាននៅក្នុងគំនិតអោយទៅក្នុងការស្តាប់បង្គាប់ព្រះគ្រិស្ទវិញ ខ្ញុំរកឃើញ (២កូរិនថូស១០) ខ្ញុំរកឃើញថាការនិយាយទៅកាន់ព្រះយេស៊ូពីគ្រប់រឿងទាំងអស់ពេញមួយថ្ងៃ អំពីអ្វីទាំងអស់ដែលខ្ញុំបានធ្វើ ហើយនឹងការព្រួយបារម្ភដែលខ្ញុំមានជាវិធីមួយក្នុងចំណោមវិធីដ៏ល្អបំផុតដែលស្ថិតនៅក្នុងការប្រកបជាមួយនឹងទ្រង់

តើព្រះយេស៊ូគិតអ្វីនៅពេលដែលទ្រង់មានស្ថានភាពដែលគួរនឹងចាត់ទុកថាជា «បញ្ហា»? យើងមានឧទាហរណ៍មួយចំនួននៅក្នុងព្រះគម្ពីរអំពីរបៀបដែលព្រះអង្គដោះ

ស្រាយស្ថានការណ៍ទាំងនោះ នឹងក្នុងករណីដទៃទៀតព្រះអង្គបានធ្វើការសម្រេចចិត្ត ដោយទុកចិត្តលើព្រះបិតារបស់ទ្រង់ដែលនៅស្ថានសួគ៌។ សូម្បីតែនៅពេលដែលព្រះអង្គជាប់នៅលើឈើឆ្កាងហើយទ្រង់មានអារម្មណ៍ថា ព្រះអង្គត្រូវបានបោះបង់ចោល ទ្រង់មានបន្ទូលថា «ព្រះបិតាអើយ ទូលបង្គំប្រគល់វិញ្ញាណរបស់ទូលបង្គំដាក់ក្នុងព្រះហស្តរបស់ព្រះអង្គវិញ» (លូកា ៤៦៖២៣)(KHSV)។ នេះគឺជាពេលវេលាដ៏ពិបាកបំផុតនៅក្នុងជិវិតរបស់ទ្រង់ ហើយនៅពាក់កណ្តាលនៃការឈឺចាប់ដ៏គួរអោយភ័យខ្លាចនិងការរងទុក្ខវេទនា ទ្រង់បានទុកចិត្តព្រះជាម្ចាស់!

ព្រះគម្ពីរក៏បានផ្តល់អោយយើងនូវករណីរបស់ព្រះយេស៊ូដែលនៅក្នុងទូក ពេលដែលព្យុះដ៏ធំមួយបានកើតឡើង។ សិស្សដែលនៅជាមួយទ្រង់បានជ្រួលច្របល់ ហើយភិតភ័យ ប៉ុន្តែទ្រង់នៅឯកន្សៃទូកហើយផ្ទុំលក់។ នៅពេលដែលពួកគេដាស់ព្រះអង្គហើយបង្ហាញពីភាពភ័យខ្លាចរបស់ពួកគេ ព្រះអង្គបានមានបន្ទូលថា *«ហេតុអ្វីបានជាអ្នករាល់គ្នាភិតភ័យដូច្នេះ? អ្នករាល់គ្នាមិនទាន់មានជំនឿទេឬអី* (មិនមានការជឿជាក់លើការទុកចិត្ត ?)» (ម៉ាកុស ៤៖៤០) (KHSV)

ព្រះជាម្ចាស់រំពឹងថាយើងទុកចិត្តទ្រង់!ទ្រង់អោយយើងនូវជំរើសនោះ ហើយយើងទាំងអស់គ្នានឹងមានប្រាជ្ញា បើយើងរៀនជ្រើសរើសវានៅពេលណាដែលយើងត្រូវបានល្បួងឱ្យព្រួយបារម្ភ។ ហេតុអ្វីបានជាមានការលំបាកនៅពេលយើងមិនធ្វើវា?

## *តើមានអ្វីកើតឡើងប្រសិនបើខ្ញុំមិនបាននូវអ្វីដែលខ្ញុំចង់បាន?*

ខ្ញុំគិតថាការភ័យខ្លាចពីការមិនទទួលបានអ្វីដែលយើងចង់បាន ជាឫសគល់នៃការពិបាកដែលយើងមានក្នុងការសិក្សាពីរបៀបទុកចិត្តព្រះ។ ភាគច្រើននៃយើងរាល់គ្នាជឿជាក់ថា វិធីតែមួយគត់ដែលយើងអាចធានាបាននូវអ្វីដែលយើងចង់បានគឺប្រសិនបើយើងយកចិត្តទុកដាក់ពីខ្លួនឯង។ ភាពភ័យខ្លាចនេះបង្ខាំងយើងពីការទុកចិត្តទាំងស្រុងលើអ្នកណាម្នាក់។

ពីព្រោះខ្ញុំត្រូវបានចិញ្ចឹមបីបាច់ដោយឪពុកនិងម្តាយដែលអាត្មានិយម និងរំលោភបំពាន ខ្ញុំមានអារម្មណ៍ប្រាកដថាគ្មាននរណាម្នាក់ មានការចាប់អារម្មណ៍ល្អបំផុតពិតប្រាកដចំពោះខ្ញុំទេ។ ឥរិយាបថរបស់ខ្ញុំគឺ *ប្រសិនបើខ្ញុំមិនយកចិត្តទុកដាក់ពីខ្លួនរបស់ខ្ញុំទេ នឹងមិនមាននរណាម្នាក់ទេ!* ប្រហែលជាអ្នកទទួលស្គាល់អាកប្បកិរិយានោះ ហើយវាធ្វើអោយអ្នកវេទនាដូចជាវាបានធ្វើជាមួយខ្ញុំ។

ព្រះជាម្ចាស់តែងតែមានអត្ថប្រយោជន៍ល្អបំផុតរបស់យើងក្នុងគំនិតរបស់ទ្រង់និងផែនការសម្រាប់យើង។

ដេវ ធ្លាប់ទទួលការឈឺចាប់ដោយសារអារម្មណ៍មិនមានការទុកចិត្តរបស់ខ្ញុំចំពោះ

គាត់ ប៉ុន្តែ ខ្ញុំមិនប្រាកដចិត្តទេថាគាត់នឹងមិនធ្វើការសម្រេចចិត្តដោយអាត្មានិយម ដែលគាត់ទទួលប្រយោជន៍តែឯងនោះ។ ខ្ញុំជឿថាគាត់ស្រឡាញ់ខ្ញុំ តែឪពុកម្តាយរបស់ខ្ញុំក៏ធ្លាប់ប្រាប់ដែរថាពួកគាត់ស្រឡាញ់ខ្ញុំ ហើយខ្ញុំក៏បានឃើញថាវាមានអ្វីកើតឡើង។ ខ្ញុំអាចនឹងមិនរៀនទុកចិត្តនរណាម្នាក់រហូតដល់ខ្ញុំបានជឿលើក្តីស្រឡាញ់ដែលគ្មានល័ក្ខខ័ណ្ឌរបស់ព្រះ ហើយទោះជាមនុស្សបានធ្វើអោយខ្ញុំឈឺចាប់ ព្រះនឹងព្យាបាលហើយសម្រាលទុក្ខខ្ញុំ។ ព្រះជាម្ចាស់តែងតែមានអត្ថប្រយោជន៍ល្អបំផុតសំរាប់យើង ក្នុងគំនិតរបស់ទ្រង់និងផែនការសម្រាប់យើង ហើយពេលដែលយើងជឿដូច្នេះ យើងអាចទុកចិត្តទ្រង់ហើយរៀនទុកចិត្តអ្នកដទៃទៀត។

ការទុកចិត្តព្រះ មិនមានការធានាថាយើងនឹងទទួលបាននូវអ្វីដែលយើងចង់បានរហូតនោះទេ។ ទោះជាយ៉ាងណាក៏ដោយ បើយើងមិនបានទទួលអ្វីដែលយើងចង់បាន វាក៏ព្រោះថា ព្រះមានអ្វីដែលប្រសើរជាងក្នុងព្រះទ័យសម្រាប់យើង។ ជាច្រើនដងក្នុងជីវិតរបស់ខ្ញុំ ខ្ញុំធ្លាប់ចង់បាន និងបានសូមទ្រង់សម្រាប់អ្វីដែលខ្ញុំមិនបានទទួលវា តែខ្ញុំដឹងនៅពេលក្រោយថាប្រសិនបើព្រះប្រទានមកអោយខ្ញុំនូវអ្វីដែលខ្ញុំចង់បានក្នុងពេលនោះ វានឹងមិនល្អសម្រាប់ខ្ញុំនោះទេ។ ដូចដែលយើងរៀនដើម្បីចង់បានអ្វីដែលព្រះសព្វព្រះទ័យសម្រាប់យើងច្រើនជាងអ្វីដែលយើងចង់បាន យើងអាចមានក្តីសុខសាន្តនៃគំនិតក្នុងគ្រប់ស្ថានភាពទាំងអស់។

ព្រះយេស៊ូបានប្រទានអោយយើងនូវឧទាហរណ៍ដ៏ល្អឥតខ្ចោះ អំពីប្រភេទនៃឥរិយាបថនេះ ពេលដែលទ្រង់បានអធិស្ថានក្នុងសួនកេតសាម៉ានីមុនសេចក្តីរងទុក្ខវេទនានៃសេចក្តីស្លាប់របស់ទ្រង់។ ទ្រង់បានមានបន្ទូលថា:

> *...ព្រះបិតាអើយ ប្រសិនបើព្រះអង្គសព្វព្រះហឫទ័យ សូមដកយកពែងនៃទុក្ខលំបាកនេះ ចេញឱ្យឆ្ងាយពីទូលបង្គំទៅ។ ប៉ុន្តែសូមកុំអោយសម្រេចតាមចិត្តរបស់ទូលបង្គំឡើយ គឺអោយសម្រេចតាមព្រះហឫទ័យព្រះអង្គវិញ។*
>
> លូកា ២២៖៤២(KHSV)

ក្តីសុខសាន្តនៃចិត្តគំនិតរបស់យើងសម្រាក អាស្រ័យថា តើយើងនឹងទុកចិត្តឬអត់ថាព្រះហឫទ័យព្រះគឺប្រសើរជាងរបស់យើង ប្រសិនបើយើងមិនយល់អំពីវា។ ពីព្រោះយើងបានបង្កើតជាមួយនឹងបំណងដែលមានសេរីភាព យើងមានជំរើសនៃការព្យាយាមដើម្បីដំណើរការជីវិតផ្ទាល់របស់យើង ហើយរស់នៅសម្រាប់អ្វីដែលយើងប្រាថ្នា ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ យើងមានជំរើសដទៃទៀត ហើយនោះគឺដើម្បីទុកចិត្ត

ក្នុងសេចក្តីល្អនិងអធិបតេយ្យរបស់ព្រះ។ ហោរ៉ាអេសាយបាននិយាយយ៉ាងនេះ: «...ព្រះអង្គនឹងធ្វើអោយនគររបស់ព្រះអង្គមានសេចក្តីសុខសាន្តរហូតតទៅ...» (អេសាយ ៩៖៧)។ យើងអនុញ្ញាតអោយទ្រង់ដឹកនាំជីវិតរបស់យើងច្រើនប៉ុណ្ណាយើងក៏រីករាយនឹងក្តីសុខសាន្តច្រើនប៉ណ្ណោះដែរ!

## *តើអ្នកណានៅក្នុងកន្លែងអ្នកបើកបរនៃជីវិតរបស់អ្នក?*

នៅពេលជីវិតដំណើរការទៅមិនដូចជាអ្វីដែលយើងចង់បាន ហើយយើងមិនទុកចិត្តព្រះ វាងាយស្រួលដើម្បីព្យាយាមនឹងដណ្តើមយកចង្កូតពីទ្រង់ ដើម្បីដឹកនាំទ្រង់ហើយព្យាយាមបង្ខំទ្រង់ធ្វើអ្វីៗតាមវិធីរបស់យើង។ គួរអោយសោកស្តាយ នេះនឹងធ្លាក់ចុះសូម្បីតែមនុស្សដ៏ល្អបំផុតក្នុងអារម្មណ៍និងវិញ្ញាណ។ ហេតុអ្វីបានជាមិនជំនួសអោយព្រះជាម្ចាស់ដឹកនាំជីវិតរបស់អ្នក?

ថ្មីៗនេះខ្ញុំបានឮរឿងអំពីយុវតីពីរនាក់ដែលបានចំណាយពេលពេញមួយថ្ងៃជាមួយគ្នា។ មានម្នាក់ដែលជាយុវតីដែលធ្វើអ្វីដោយមិនខ្វល់ពីអ្នកណា ដែលតែងតែធ្វើអ្វីៗដោយមិនគិតពីការពីភាក្សាគ្នា។ នាងសម្រេចចិត្តភ្លាមៗនៅពេលដែលចង់បានកន្លែងជាមួយក្មេងស្រីដែលកំពុងបើកបរឡានហើយនាងបានព្យាយាមធ្វើ ហើយធ្វើដូច្នេះខណះពេលដែលរថយន្តកំពុងមានចលនា។ ទោះបីអ្នកបើករថយន្តបានទប់ទល់ពីដំបូង តែនៅទីបញ្ចប់នាងបានរួមចំណែកក្នុងបទពិសោធន៍មួយ ហើយភ្លាមៗពួកគេបានធ្លាក់ទៅក្នុងប្រឡាយជាមួយនឹងឧបទ្ទវហេតុរថយន្ត។

ខ្ញុំសូមផ្តល់យោបល់ អនុញ្ញាតអោយព្រះធ្វើការបើកបរ។ កុំព្យាយាមយកចង្កូតពីទ្រង់ខណៈពេល ដែលទ្រង់កំពុងនាំអ្នកទៅកាន់កន្លែងដែលទ្រង់ចង់អោយអ្នកទៅ។ អនុញ្ញាតអោយទ្រង់ដឹកនាំ ហើយរៀនតាមទ្រង់។ នេះគឺជាភាពវៃឆ្លាតបំផុត សុវត្ថិភាពបំផុត ហើយជាវិធីបំពេញល្អបំផុតដើម្បីរស់នៅ។

នេះជាកន្លែងល្អមួយដើម្បីឈប់អានពីរបីនាទីហើយគិតពីសំណួរមួយចំនួនៈ

- អ្នកណានៅក្នុងកន្លែងអ្នកបើកបរក្នុងជីវិតរបស់អ្នក?
- តើអ្នកមានអំណរនឹងសេចក្តីសុខសាន្តនៃចិត្តគំនិតកំរិតណា?
- តើញឹកញាប់ប៉ុណ្ណាដែលអ្នកបានខ្ជះខ្ជាយពេលពេញមួយថ្ងៃក្នុងការព្រួយបារម្ភអំពីអ្វីមួយដែលលួចសេចក្តីសុខសាន្តរបស់អ្នក?
- តើការភ័យខ្លាចនៃការមិនទទួលអ្វីដែលអ្នកចង់បានរារាំងអ្នកពីការទុកចិត្តព្រះឬទេ?

- តើអ្នកស្រេកឃ្លានសេចក្តីសុខសាន្តនៃចិត្តគំនិតបន្ថែមទៀតឬទេ?
- តើអ្នកចង់សប្បាយរីករាយបន្ថែមក្នុងជីវិតរបស់អ្នកឬទេ?

ជាការឆ្លើយសំណួរទាំងនេះ ដោយស្មោះត្រង់អាចជួយអ្នកស្គាល់កំរិតនៃសេចក្តីទុកចិត្តរបស់អ្នក។ ប្រសិនបើអ្នករកឃើញថា អ្នកមិនមានទំនុកចិត្តលើព្រះដូចដែលអ្នកគួរតែមាន នោះមិនមានហេតុផលអ្វីដែលត្រូវថ្កោលទោសនោះទេ។ គ្រាន់តែចាប់ផ្តើមពីឥឡូវនេះដោយជ្រើសរើសយកការទុកចិត្តពីលើភាពព្រួយបារម្ភ។ ចូរពិចារណាខគម្ពីរនេះ៖

*ឯអ្នកណាដែលមានគំនិតជាប់តាមទ្រង់ នោះទ្រង់នឹងថែរក្សាអ្នកនោះអោយមានសេចក្តីសុខពេញខ្នាត ដោយព្រោះគេទុកចិត្តនឹងទ្រង់ (ទាំងភាពលំអៀងនឹងចរិតលក្ខណៈរបស់វា)។*

*អេសាយ ២៦៖៣(KHSV)*

សូមអនុញ្ញាតអោយខ្ញុំផ្តល់ការណែនាំរបៀបថ្មីដល់អ្នកដើម្បីអធិស្ថាន។ ជំនួសអោយការទូលទៅព្រះពីអ្វីដែលអ្នកចង់បាន ប៉ុន្តែចូរបន្ថែមប្រយោគនេះ៖ «ប៉ុន្តែ ឱព្រះអង្គអើយ បើនេះមិនមែនជាអ្វីដែលត្រឹមត្រូវសម្រាប់ទូលបង្គំ ដូច្នេះសូមកុំប្រទានវាមកទូលបង្គំអី!»

មានជាច្រើនដងនៅក្នុងជីវិតរបស់ខ្ញុំ(ហើយប្រហែលជាក្នុងជីវិតរបស់អ្នកដូចគ្នា) ពេលដែលខ្ញុំធ្វើគ្រប់យ៉ាងដើម្បីបានអ្វីដែលខ្ញុំចង់បានប៉ុន្តែខ្ញុំបានឃើញថាវាមិនបានបំពេញនិងធ្វើអោយខ្ញុំពេញចិត្តទេ ហើយវាថែមទាំងធ្វើឱ្យស្ថានភាពរបស់ខ្ញុំកាន់តែអាក្រក់ទៅៗ។ ភាគច្រើននៃពួកយើងនៅពេលខ្លះបានទិញអ្វីដែលយើងចង់បានប៉ុន្តែនៅក្នុងការពិតមិនអាចមានលទ្ធភាព ហើយធ្លាក់ទៅក្នុងសម្ពាធផ្លូវចិត្តដោយសារតែបំណុល។ ឬក៏យើងអាចចាប់ផ្តើមការប្រកែកជាមួយប្តីឬប្រពន្ធរបស់យើងនៅពេលដែលមានមតិខុសគ្នា ប៉ុន្តែបន្ទាប់ពីបានទទួលអ្វីដែលយើងគិតថាយើងចង់បាន យើងបានដឹងថាការទទួលយកផ្លូវផ្ទាល់របស់យើង គឺមិនមានតម្លៃចំពោះទុក្ខវេទនាផ្លូវចិត្តនិងអារម្មណ៍ដែលយើងធ្លាប់មានឡើយ។

> បើយើងមិនអាចមានអ្វីដែលយើងចង់បានជាមួយក្តីសុខនៃចិត្តគំនិតទេ នោះ ដូច្នេះវាប្រហែលជាសក្តិសមនឹងមាននោះទេ។

ខ្ញុំបានរៀនថា ប្រសិនបើយើងមិនអាចមានអ្វីដែលយើងចង់បានជាមួយក្តីសុខសាន្តនៃចិត្តគំនិតទេនោះ ដូច្នេះវាប្រហែលជាសក្តិសមនឹងមាននោះទេ។

យើងត្រូវបានជម្រុញដោយព្រះគម្ពីរ ដើម្បីឱ្យសន្តិភាពក្លាយជាអ្នកសំរេចក្នុងជីវិតរបស់យើង ធ្វើការសម្រេចចិត្តចុងក្រោយទាំងអស់ (កូឡូស ៣:១៥)។ ជាច្រើនឆ្នាំក្រោយពីភាពរឹករវរផ្លូវចិត្តនិងអារម្មណ៍ ខ្ញុំបានរៀនថាសេចក្ដីសុខសាន្តគឺជាទំនិញដ៏មានតំលៃ ហើយយើងគួរតែធ្វើអ្វីដែលវាត្រូវការដើម្បីមានវា។

ពេលអ្នករកឃើញថាអ្នកកំពុងមានពេលវេលាដ៏លំបាកក្នុងការទុកចិត្តព្រះ ចូរសួរខ្លួនឯងថាៈ «តើវាពីព្រោះតែខ្ញុំភ័យខ្លាចថាប្រសិនបើខ្ញុំទុកចិត្តទ្រង់ ខ្ញុំនឹងមិនទទួលបាននូវអ្វីដែលខ្ញុំចង់បានឬ?» ប្រសិនបើចម្លើយនោះគឺ *ពិតមែន* ដូច្នេះអ្នករកឃើញមូលហេតុនៃការខ្វះទំនុកចិត្តនិងសេចក្ដីសុខសាន្តរបស់អ្នក។

ការទទួលបានវិធីផ្ទាល់ខ្លួនរបស់យើងគឺការវាយតំលៃដ៏មានកំរិតខ្ពស់បំផុត។ វាពិតជាអស្ចារ្យណាស់ ថាតើជីវិតរបស់យើងបានខ្ជះខ្ជាយលើការស្វែងរកការបំពេញចិត្តខ្លួនឯង ដោយរកឃើញនៅទីបញ្ចប់ថាយើងមិនបានពេញចិត្តបន្ទាប់ពីទាំងអស់នោះ។

មានតែព្រះហឫទ័យព្រះតែប៉ុណ្ណោះ ដែលមានសមត្ថភាពដើម្បបំពេញចិត្តយើងជាចុងក្រោយបំផុត។ យើងត្រូវបានបង្កើតមកសម្រាប់ទ្រង់ហើយសម្រាប់គោលបំណងរបស់ទ្រង់ ហើយអ្វីតិចជាងនោះគឺការមិនអាចនាំមកបានទាំងស្រុងនៃសេចក្ដីរីករាយដ៏យូរអង្វែង។ នៅពេលដែលយើងនៅក្មេង យើងអាចគិតថាការទទួលអ្វីដែលយើងចង់បានគឺជាអ្វីដែលសំខាន់បំផុតក្នុងជីវិត ប៉ុន្តែកន្លងទៅជាច្រើនឆ្នាំ ដោយក្ដីសង្ឃឹមយើងរៀនហើយមានបទពិសោធន៍គ្រប់គ្រាន់ដើម្បីរួចរាល់នឹងនិយាយថា «ខ្ញុំចង់បានអ្វីដែលព្រះសព្វព្រះទ័យច្រើនជាងខ្ញុំចង់បានចំណង់ផ្ទាល់ខ្លួនរបស់ខ្ញុំ។» មិនមានកន្លែងណាប្រសើរជាងនៅក្នុងព្រះហឫទ័យដ៏ឥតខ្ចោះរបស់ព្រះនោះទេ!

# ជំពូក ៣

## តើខ្ញុំអាចទុកចិត្តអ្នកណា?

*...ត្រូវបណ្តាសាហើយអ្នកណាដែលទីពឹងដល់មនុស្ស ហើយយកសាច់ឈាមជាដៃរបស់ខ្លួនជាអ្នកដែលមានចិត្តដកថយចេញពីព្រះយេហូវ៉ា។*
*(យេរេមា ១៧៖៥) (KHOV)*

នេះជាការសន្និដ្ឋានមួយ«អ្នកមិនអាចទុកចិត្តលើមនុស្សណាម្នាក់បានទេសព្វថ្ងៃនេះ» ជាទូទៅ ហើយក៏ជាចំណូលចិត្តមួយដែលយើងបង្កើតវាពីពេលមួយទៅពេលមួយ។ ទោះជាយ៉ាងណាក៏ដោយវាមិនមែនជាសេចក្តីពិតនោះទេថា អ្នកណាម្នាក់មិនសក្តិសមនឹងគោរពនោះ ហើយវាក៏ជាគ្រោះថ្នាក់ ដែលនាំអោយក្លាយជាមនុស្សសម្លឹងលើផ្លូវអាក្រក់ ហើយនឹងគិតទៅរកផ្លូវនោះ។

ខ្ញុំសូមសារភាពថាការស្វែងរកមនុស្សដែលអាចទុកចិត្តបានសព្វថ្ងៃនេះ គឺពិបាកជាងពេលណាៗទាំងអស់ដែលខ្ញុំចាំបាននៅក្នុងជីវិតរបស់ខ្ញុំ ប៉ុន្តែខ្ញុំបានបដិសេធការរស់នៅជាមួយនឹងដួងចិត្តដែលពេញទៅដោយសេចក្តីមិនទុកចិត្តនិងសេចក្តីសង្ស័យនេះ។ ខ្ញុំបានសម្រេចចិត្តជឿជាក់យ៉ាងល្អនិងទុកចិត្តលើមនុស្ស តែនៅទីបំផុតពួកគេបានផ្តល់អោយខ្ញុំនូវហេតុផលច្បាស់លាស់មួយដែលមិនដូចការជឿជាក់របស់ខ្ញុំ។ ហើយការសម្រេចចិត្តនេះគឺមិនបានបង្កើតដោយផ្អែកទៅលើបទពិសោធន៍របស់ខ្ញុំជាមួយនឹងមនុស្សនោះទេ។

ខ្ញុំបានដឹងតាំងតែពីខ្ញុំមានអាយុប្រាំពីរឆ្នាំម្ល៉េះថា ខ្ញុំមិនអាចទុកចិត្តលើឪពុកម្តាយរបស់ខ្ញុំបានទេ ព្រោះពួកគាត់ជាមនុស្សដែលយកតែចិត្តខ្លួនឯងនិងរំលោភបំពានយ៉ាងខ្លាំង។ ខ្ញុំមិនអាចទុកចិត្តអ្នកផ្សេងទៀតដែលខ្ញុំបានសូមអោយគេជួយខ្ញុំបានទេ ព្រោះពួកគេបានបដិសេធដោយធ្វើដូច្នេះ គឺប្រើការសូមអភ័យទោសដ៏ងាយថា «ខ្ញុំមិនចង់រួមចំណែកទេ! វាមិនមែនជាកិច្ចការរបស់ខ្ញុំ!»

ខ្ញុំបានធំឡើងជាក្មេងជំទង់នឹងជាយុវវ័យ ខ្ញុំមានបទពិសោធន៍ដែលក្រៀមក្រំដទៃទៀត ដែលវាបានផ្តល់ជាសារថា «អ្នកមិនអាចទុកចិត្តលើមនុស្សណាម្នាក់បានទេ!» ខ្ញុំបានរៀបការកាលពីខ្ញុំមានអាយុដប់ប្រាំបីឆ្នាំ ជាមួយនឹងបុរសម្នាក់ដែលមិនមានសេចក្តីស្មោះត្រង់ លើសពីនេះ គាត់បានក្លាយទៅជាចោរដែលបានបញ្ចប់វានៅក្នុងគុក ។ ខ្ញុំធ្លាប់ជឿជាក់ថា ខ្ញុំបានជួបនឹងមនុស្សដែលអាចជឿជាក់បាន ប៉ុន្តែខ្ញុំខឹងយ៉ាង

ខ្លាំងជាមួយនឹងមនុស្សដែលបានធ្វើអោយខ្ញុំឈឺចាប់ និងខកបំណងចំពោះអ្វីដែលខ្ញុំផ្តោតចិត្តជឿជាក់ទៅលើនោះ។

ខ្ញុំបានរៀបការជាមួយដេវ នៅពេលដែលខ្ញុំមានអាយុម្ភៃបីឆ្នាំ ហើយចាប់ពីពេលនោះមកខ្ញុំបានមានវត្តមានយ៉ាងទៀងទាត់នៅក្នុងព្រះវិហារ។ ខ្ញុំបានសន្មតថា ដោយសារតែខ្ញុំបានចូលរួមជាមួយ «សមាជិកក្រុមជំនុំ» ខ្ញុំអាចទុកចិត្តពួកគេ ហើយនឹងមិនទទួលការឈឺចាប់នោះទេ ប៉ុន្តែអ្វីដែលចេញមកនោះគឺមិនត្រឹមត្រូវទាំងអស់នោះទេ។ ជាការពិតណាស់ មានខ្ញុំមានបទពិសោធន៍នៅក្នុងជីវិតរបស់ខ្ញុំមកពីគ្រីស្ទាន។ (ខ្ញុំស្ទើរតែបានឮអ្នកអានទាំងអស់និយាយថា«អាម៉ែន!»)អ្នកក៏អាចមានបទពិសោធន៍នឹងរឿងដូចគ្នា ហើយខ្ញុំក៏ប្រាកដដែរថាអ្នកក៏មានរឿងរំខានចិត្តជាច្រើនមកនិយាយពីអ្វីដែលមនុស្សបានធ្វើជាមួយអ្នក។

មនុស្សរួមទាំងខ្លួនយើងផងដែរមានកំហុស ហើយយើងកំពុងរៀបចំខ្លួនយើងសម្រាប់ការខកបំណងដ៏ឈឺចាប់ ប្រសិនបើយើងគិតថា បើវានឹងមិនដូច្នេះទេ។ ព្រះយេស៊ូបានមកសម្រាប់អ្នកទន់ខ្សោយ មិនមែនសម្រាប់អ្នកខ្លាំងនោះទេ ហើយខ្ញុំអរព្រះគុណទ្រង់សម្រាប់អ្វីដែលទ្រង់បានធ្វើ។ ខ្ញុំត្រូវការព្រះគុណនឹងការអត់ទោសជាទៀងទាត់ ហើយនោះមានន័យថាខ្ញុំក៏ត្រូវត្រៀមលក្ខណៈសម្រាប់ការផ្តល់អោយពួកគេនូវសេចក្តីសប្បុរសដែរ។

ប្រធានបទនៃសេចក្តីជំនឿ _ រឺក៏កង្វះខាតនៃសេចក្តីជំនឿ _ ជាការបំពេញចំណងជើងបច្ចុប្បន្ននេះ។ ការចោទប្រកាន់នៃការរំលោភបំពានផ្លូវភេទដោយពួកសង្ឃ(បូជាចារ្យ) វាហាក់ដូចជាត្រូវបានរាយការណ៍ជាញឹកញាប់។ យើងធ្លាប់បានឮពីរឿងអាស្រូវរបស់អេនរ៉ូន ដែលក្នុងចំណោមមនុស្សរាប់ពាន់នាក់ត្រូវបានចាញ់បោកពីការសង្គ្រោះជីវិតរបស់ពួកគេ។ យើងបានបោះឆ្នោតសម្រាប់អ្នកនយោបាយដែលយើងគិតថាយើងអាចទុកចិត្តគេបាន ប៉ុន្តែពួកគេបានធ្វើអោយយើងខកចិត្ត ដោយពួកគេមិនបានធ្វើនូវអ្វីដែលពួកគេបានសន្យានោះទេ។

តើយើងនិយាយពីមនុស្សអាក្រក់ថាជាមនុស្សល្អបានដោយរបៀបណា។ តើយើងដឹងដោយរបៀបណាថាអ្នកណាមិនគួរនឹងជឿជាក់ ហើយតើអ្នកណាគួរអោយជឿជាក់? តើយើងដឹងដោយរបៀបណាថាអ្នកណាដែលយើងអាចទុកចិត្តបាន? ទាំងនេះវាមិនមែនជាការឆ្លើយតបដ៏ងាយនោះទេ ហើយពេលខ្លះយើងក៏មិនអាចជឿជាក់លើអ្នកទាំងឡាយដែលបានប្តូរផ្តាច់ក្នុងការចិញ្ចឹមបីបាច់និងថែរក្សាយើងបានដែរ។

គ្រាន់តែសួរទៅនារីវ័យក្មេងម្នាក់ដែលត្រូវបានរំលោភដោយឪពុករបស់នាង ដែលជាអ្នកបម្រើដ៏គួរអោយគោរពម្នាក់ក្នុងព្រះវិហាររបស់នាង។ គ្រប់គ្នាទាំងអស់ ដែលរួមទាំងក្រុមគ្រួសាររបស់នាងផង ពួកគេជឿថាគាត់គឺជាមនុស្សដែលសុចរិត និងគួរអោ

យទុកចិត្តបាន។ ប៉ុន្តែនៅទីបញ្ចប់បានបង្ហាញថា គាត់ជាមនុស្សបោកប្រាស់និងអាក្រក់បំផុត។

នៅក្នុងអត្ថបទបានដាក់ចំណងជើងថា «តើអ្នកណាដែលយើងអាចជឿជាកបាន?» វេជ្ជ.អ៊ែរវីន វ.ឡុតស្សែរ៍ បាននិយាយថា៖

> ហេតុអ្វីបានជាមនុស្សមិនគួរអោយទុកចិត្ត? ទោះបីជាយើងចង់គិតថា យើងត្រូវបានជំរុញដោយសភាវគតិដ៏សមហេតុផល ការពិតគឺថាយើងត្រូវបានជំរុញដោយចំណង់នៃភាពអាត្មានិយមរបស់យើងប៉ុណ្ណោះ។ ហើយដោយសារយើងចង់បានគំនិតដែលជាក់ច្បាស់ វាគឺងាយស្រួលសម្រាប់យើងក្នុងការចំណាយការយកចិត្តទុកដាក់ទៅលើបុគ្គលិកលក្ខណៈ ខាងក្រៅរបស់យើង ខណៈពេលដែលយើងមិនយកចិត្តទុកដាក់ទាំងស្រុងទៅលើសេចក្តីសុចរិតនៃដួងចិត្តរបស់យើង។ តាមការពិត មនុស្សមួយចំនួនមិនបានបញ្ឆោតដោយអ្នកដទៃនោះទេ ប៉ុន្តែជាការពិតនោះគឺគេធ្លាក់ទៅក្នុងការបោកបញ្ឆោតរបស់ខ្លួនពួកគេផ្ទាល់។ នៅពេលដែលការបោកបញ្ឆោតខ្លួនឯងរបស់យើងបានបំពេញ យើងអាចក្លាយទៅជាមនុស្សឃោរឃៅ ដែលបំផ្លាញមនុស្សជុំវិញខ្លួនរបស់យើង ដើម្បីការពារជំងឺអារម្មណ៍របស់យើង។

ពិតមែន ពិបាកដឹងណាស់ថា អ្នកណាដែលត្រូវទុកចិត្ត។ ការភិតក្បត់កើតឡើងគ្រប់ពេលទាំងអស់។ សិស្សវិទ្យាល័យជាច្រើនពួកគេលួចចំម្លងនៅពេលប្រឡង។ និយោជិតលួចពីនិយោជក។ ហើយនៅមានបន្តបន្ទាប់ទៀត។ លើសមាសភាគដ៏តិចតួច ប៉ុន្តែកំរិតនៃភាពតានតឹងក្នុងការស្វែងរកអ្នកដែលមានទឹកដៃមានស្មើគ្នា នៅគ្រប់ពេលទាំងអស់។ សូម្បីការដ៏សាមញ្ញ ចំពោះការចាប់ផ្តើមទុកចិត្តមនុស្សអោយរក្សាការណាត់ជួបអោយទាន់ពេលវេលានោះក៏ពិបាកទទួលបានដែរ។តើយើងធ្វើអ្វីបាន?

តើយើងត្រូវប្រកាន់យកអាកប្បកិរិយាជូរចត់និងការមិនទុកចិត្ត ហើយនិយាយទៅកាន់ម្នាក់ទៀតថា «អ្នកមិនអាចទុកចិត្តនរណាម្នាក់បានទេសព្វថ្ងៃនេះ?»ឬក៏យើងគួរតែសម្រេចចិត្តទុកចិត្តមនុស្សគ្រប់គ្នា លុះត្រាតែពួកគេផ្តល់អោយយើងនូវហេតុផលគ្រប់គ្រាន់? ខ្ញុំជ្រើសរើសយកការទុកចិត្តមនុស្ស ជាធម្មតា ពីព្រោះខ្ញុំបដិសេធរស់នៅជាមួយឥរិយាបទដែលមានមន្ទិលសង្ស័យ ដែលធ្វើអោយខ្ញុំពិបាកដោយគ្រាន់តែមនុស្សមួយចំនួនអាចធ្វើអោយខ្ញុំខកចិត្ត។

## *ចូរទុកចិត្តជាមួយភ្នែកដែលបើកចំហរបស់អ្នក*

យើងអាចទុកចិត្តមនុស្សដោយមិនដាក់ការទុកចិត្តក្នុងពួកគេ ជាសេចក្តីពិត ការទុកចិត្តជាកម្មសិទ្ធិជារបស់ព្រះជាម្ចាស់តែមួយអង្គគត់។ ព្រះយេស៊ូបានមានព្រះបន្ទូលពី

ការនេះហើយសាវ័កយ៉ូហានបានកត់សេចក្ដីនេះ៖

*តែព្រះយេស៊ូទ្រង់មិនទុកចិត្តនឹងគេទេ ពីព្រោះទ្រង់ស្គាល់ដល់គ្រប់ទាំងមនុស្ស*

យ៉ូហាន ២៖២៤(KHOV)

ខនេះមិនបាននិយាយថាព្រះយេស៊ូមិនទុកចិត្តអ្នកណាម្នាក់នោះទេ។ ជំនួសមកវិញ គឺបាននិយាយថាទ្រង់មិនទុកចិត្តអង្គទ្រង់ទៅនឹងពួកគេទេ។ តើមានន័យថាដូចម្ដេច? ព្រះអង្គមិនបានផ្ដល់អោយអង្គទ្រង់នូវគំនិតដែលថាមនុស្សនឹងធ្វើអោយទ្រង់ខកព្រះទ័យនោះទេ។ ទ្រង់មិនបានដាក់អង្គទ្រង់ទាំងស្រុងទៅក្នុងដៃរបស់ពួកគេសម្រាប់ការការពារនោះទេ។

*ហើយទ្រង់មិនត្រូវការ អោយអ្នកណាធ្វើបន្ទាល់ពីមនុស្សណាទេ ដ្បិតទ្រង់ជ្រាបហើយ ពីសេចក្ដីដែលមាននៅក្នុងមនុស្សទាំងឡាយ។*

យ៉ូហាន ២៖២៥(KHOV)

ព្រះយេស៊ូបានផ្ដល់ព័តមានយ៉ាងល្អអំពីធម្មជាតិរបស់មនុស្ស ហើយនិងភាពខ្សោយដែលមាន។ ទ្រង់បានយាងមកដើម្បីចំរើនកំលាំងមនុស្សក្នុងភាពទន់ខ្សោយរបស់ពួកគេ ហើយអត់ទោសរាល់កំហុសនិងអំពើបាបរបស់ពួកគេ។ ប្រសិនបើយើងចង់បានសេចក្ដីសុខសាន្ដនៅក្នុងជីវិតរបស់យើង យើងត្រូវធ្វើរឿងដូចគ្នា។

មិនមានអ្នកណាម្នាក់ក្នុងចំណោមយើង ដែលនិយាយថា យើងមិនបានធ្វើអោយអ្នកណាម្នាក់ឈឺចាប់ឬខកបំណងទេ ឬថាយើងមិនធ្លាប់បានឈឺចាប់ឬខកបំណងនោះទេ។ យើងមានបទពិសោធន៍ពីភាពទន់ខ្សោយនៃធម្មជាតិរបស់មនុស្ស។ ខ្ញុំមិនដែលមានចេតនាចង់ធ្វើអោយអ្នកណាម្នាក់ឈឺចាប់ទេ ប៉ុន្តែពេលខ្លះខ្ញុំធ្វើវា។ ផ្នែកមួយនៃការចាប់ផ្ដើមក្នុងទំនាក់ទំនងទាមទារអោយមានឆន្ទៈនឹងទទួលការខកបំណងនិងនៅតែជាវិធីដ៏ល្អមួយដើម្បីបន្តកសាងទំនុកចិត្ត ជាជាងការបោះបង់ចោល។

> មានភាពខុសគ្នារវាងការខកចិត្តរបស់ខ្ញុំនិងព្រះធ្វើឲ្យខ្ញុំខកចិត្ត។

ដូច្នេះខ្ញុំបានសម្រេចចិត្តទុកចិត្តដោយភ្នែកដែលបើកចំហរបស់ខ្ញុំ ហើយនោះបានន័យថាខ្ញុំមិនរំពឹងលើនរណាម្នាក់ (លើកលែងតែព្រះជាម្ចាស់) ដែលមិនធ្វើអោយខ្ញុំខកចិត្ត។ សូម្បីតែជាមួយព្រះ ក៏ខ្ញុំមានការខកចិត្តពីដំបូង នៅពេលដែលអ្វីៗមិនបានចេញមកតាមរបៀបដែលខ្ញុំបានសង្ឃឹមថាវានឹងកើតឡើង។ ទោះជាយ៉ាងណាក៏ដោយ មានភាពខុសគ្នារវាងការខកចិត្តរបស់ខ្ញុំនឹងព្រះធ្វើអោយខ្ញុំខកចិត្ត។ ការរំពឹងទុកផ្ទាល់ខ្លួនរបស់ខ្ញុំគឺជាប្រភពនៃការខកចិត្តរបស់ខ្ញុំ មិនមែនជាព្រះនោះទេ ពីព្រោះខគម្ពីរបង្រៀនថា ប្រសិនបើយើងដាក់ក្ដីសង្ឃឹមរបស់យើងក្នុងទ្រង់ ទ្រង់នឹងមិនដែលធ្វើអោយយើងខកចិត្តឡើយ (រ៉ូម ៥:៥)។

## *ការរំពឹងទុកខុសឆ្គង*

តើយើងមានការខកចិត្តប៉ុណ្ណាចំពោះកំហុសរបស់អ្នកដទៃហើយប៉ុណ្ណាចំពោះកំហុសរបស់ខ្លួនឯង? ខ្ញុំគិតថានោះជាសំនួរដ៏គួរអោយចាប់អារម្មណ៍។ ខ្ញុំកត់សំគាល់ថា ព្រះមិនដែលធ្វើឲ្យខកចិត្តនោះទេ។ យើងអាចមានអារម្មណ៍ខកចិត្តជាមួយរឿងខ្លះដែលទ្រង់ធ្វើនឹងមិនបានធ្វើ ប៉ុន្តែវាព្រោះតែការរំពឹងទុករបស់យើងមិនត្រឹមត្រូវ។ ជំនួសឲ្យការចង់បានអ្វីដែលព្រះសព្វព្រះទ័យ យើងបានចង់បាននូវអ្វីដែលយើងចង់បាន។

ការរំពឹងទុកថាមនុស្សម្នាក់មិនធ្វើឲ្យអ្នកឈឺចាប់ឬខកចិត្ត ជាការរំពឹងទុកខុសឆ្គងជារឿងសាមញ្ញ ព្រោះធម្មជាតិមនុស្សគឺមិនមានសមត្ថភាពដល់ភាពដែលឥតខ្ចោះនោះទេ។ យើងចង់ឲ្យមនុស្សដឹងថាយើងចង់បានអ្វីឬមានអារម្មណ៍យ៉ាងណា ហើយនៅពេលដែលពួកគេមិនដឹង យើងក៏មានការខកចិត្ត។ យើងខកចិត្តដែលមនុស្សមិនយល់អំពីយើង ប៉ុន្តែហេតុអ្វីបានជាខ្ញុំបន្ទោស ដេវ សម្រាប់ការដែលគាត់មិនយល់ថាខ្ញុំមានអារម្មណ៍យ៉ាងណា បើនោះវាពិតជាមិនមែនជាធម្មជាតិរបស់គាត់ដែលត្រូវមានអារម្មណ៍របៀបនោះ? ចរិតលក្ខណៈរបស់គាត់គឺខុសពីខ្ញុំ ហើយរឿងខ្លះដែលពិតជាសំខាន់សំរាប់ខ្ញុំ មិនមានបញ្ហាអ្វីទេចំពោះគាត់ ហើយវាក៏ផ្ទុយមកវិញ។ ខ្ញុំអាចពន្យល់ទៅគាត់ពីអារម្មណ៍របស់ខ្ញុំហើយគាត់ក៏អាចបង្ហាញពីការយល់ចិត្ត ព្រោះគាត់ស្រលាញ់ខ្ញុំ ប៉ុន្តែគាត់នៅតែមិនដឹងដោយបទពិសោធន៍ថាខ្ញុំមានអារម្មណ៍បែបណា វាជាធម្មតាពីព្រោះគាត់មិនមានចំណុចនៃសេចក្តីបញ្ជាក់នោះទេ។

ប្រសិនបើស្ត្រីចង់មានការយល់ដឹងកាន់តែច្បាស់ គាត់និយាយល្អជាមួយស្ត្រីម្នាក់ទៀត ហើយដែលគួរឲ្យចូលចិត្តជាម្នាក់ដែលមានចរិតលក្ខណៈប្រហាក់ប្រហែលនឹងនាង។ ប្រសិនបើដេវចង់ពិភាក្សាអំពីកីឡាជាមួយអ្នកណាម្នាក់ ដែលជាអ្នកមានចំណាប់អារម្មណ៍យ៉ាងពិតប្រាកដ វាជាការឥតប្រយោជន៍ដែលនិយាយជាមួយខ្ញុំ។ ខ្ញុំអាចធ្វើពុតជាមានចំណាប់អារម្មណ៍ចេញមកដោយការគួរសម ប៉ុន្តែខ្ញុំមិនយល់ពីការរំជើបរំជួលរបស់គាត់នោះទេ ព្រោះថាខ្ញុំមិនធ្លាប់មានអារម្មណ៍ដូច្នោះ ហើយប្រហែលជានឹងមិនមាន។

ដូចដែលខ្ញុំសរសេរនេះ ដេវនិងខ្ញុំបានរៀបការអស់ពេលដប់ប្រាំឆ្នាំមកហើយ ហើយហេតុផលមួយដែលធ្វើឲ្យអាពាហ៍ពិពាហ៍របស់យើងទទួលបានជោគជ័យ គឺពីព្រោះយើងបានរៀនអស់រយៈពេលជាយូរមកហើយពីចំណុចសំខាន់នៃការមិនរំពឹងអ្វីពីម្នាក់ទៀតដែលយើងខ្វះសមត្ថភាពនឹងផ្តល់ឲ្យ។មានរឿងខ្លះយើងអាចរៀនពីរបៀបផ្តល់ឲ្យមនុស្សផ្សេង ដែលត្រូវការវាគ្រាន់តែសម្រាប់ប្រយោជន៍នៃសេចក្តីសប្បុរស ប៉ុន្តែក៏មានរឿងខ្លះ ដែលមិនអាចទៅរួច។ ដេវ ចង់ឲ្យខ្ញុំមានអំណរនឹងជីវិតរបស់ខ្ញុំ ហើយគាត់ដឹងថាខ្ញុំមិនអាចមានអំណរបានទេ លុះត្រាតែខ្ញុំមានសេរីភាពជាខ្លួនរបស់ខ្ញុំយ៉ាងពិតប្រាកដសិន ដូច្នេះគាត់អបអរសាទរដែលខ្ញុំជាខ្ញុំ ហើយមិនមែនជាអ្នក

ដែលគាត់ចង់ឲ្យក្លាយទៅជា។ខ្ញុំក៏ធ្វើរឿងដូចគ្នាទៅនឹងគាត់ដែរ។ យើងបានចំណាយពេលពីរបីឆ្នាំ ដើម្បីមកដល់ចំណុចនេះ ហើយរហូតដល់យើងបានធ្វើវា យើងទាំងពីរនាក់មានបទពិសោធន៍យ៉ាងច្រើនពីការឈឺចាប់ និងការខកចិត្តពីហេតុផលផ្សេងទៀតដោយការរំពឹងទុកខុស។

ព្រះយេស៊ូទ្រង់បានជ្រាបថា សិស្សរបស់ទ្រង់នឹងធ្វើឲ្យទ្រង់ខកព្រះទ័យ ដូច្នេះព្រះអង្គបានរៀបចំរួចជាស្រេចនៅពេលពួកគេបានធ្វើ និងមិនបានបំផ្លាញដោយទង្វើរបស់ពួកគេដែរ។ យ៉ូដាស បានបំផ្លាញទ្រង់ ពេត្រុសបានបដិសេធទ្រង់ ពួកគេបានដេកលក់កំឡុងពេលដ៏សំខាន់បំផុតរបស់ទ្រង់ ដែលត្រូវជំនួសដោយការអធិស្ឋានជាមួយទ្រង់ ដូចដែលទ្រង់បានសូម តែទ្រង់នៅតែបន្តក្តីស្រឡាញ់ទ យ៉ាងពេញលេញចំពោះពួកគេ។ ទ្រង់មិនបាននិយាយទៅកាន់ពួកគេដោយអាកប្បកិរិយាចំអកថា«អ្នកបានធ្វើឲ្យខ្ញុំឈឺចាប់ ដូច្នេះខ្ញុំនឹងមិនទុកចិត្តអ្នកទៀតទេ។» ទ្រង់មិនមានការរំពឹងទុកដែលខុសឆ្គងនោះទេ។

វាមិនជាខុសទេដែលរំពឹងថាមនុស្សនឹងធ្វើអ្វីដែលត្រឹមត្រូវ ហើយខិតខំប្រឹងប្រែងកុំឱ្យប៉ះពាល់ដល់យើង ប៉ុន្តែក្នុងពេលជាមួយគ្នាយើងមិនគួរនឹងរំពឹងថាពួកគេនឹងមិនធ្វើកំហុសនោះ។ ជាធម្មតាមនុស្សមិនមែនល្អឥតខ្ចោះនោះទេ!

ខ្ញុំបានចំណាយពេលជាច្រើនឆ្នាំខកចិត្តនិងក្រៀមក្រំភាគច្រើនបំផុត ព្រោះតែផែនការណ៍របស់ខ្ញុំមិនបានសម្រេចតាមអ្វីដែលខ្ញុំបានរំពឹងទុក រហូតទាល់តែខ្ញុំបានរៀនថា រៀងរាល់ពីរបីថ្ងៃម្តងខ្ញុំធ្វើវាឲ្យដូចខ្ញុំចង់ឲ្យវាកើតឡើង។ ឥឡូវនេះខ្ញុំបង្កើតគំរោងសម្រាប់កិច្ចការដែលមិនបានរៀបចំទុកជាមុន ហើយដែលអនុញ្ញាតឲ្យខ្ញុំរក្សាក្តីសុខសាន្តរបស់ខ្ញុំ។ ជានិច្ចជាកាលសូមចងចាំថា វាគឺជាប្រាជ្ញាដែលបង្កើតគំរោងសម្រាប់កិច្ចការដែលមិនបានរៀបចំទុកជាមុនរាល់ថ្ងៃ។

វាគឺជាប្រាជ្ញាដែលបង្កើតគំរោងសម្រាប់កិច្ចការដែលមិនបានរៀបចំទុកជាមុនរាល់ថ្ងៃ។

## ចូរមើលទៅផ្នែកនៃពន្លឺ

យើងបាននិយាយពីគ្រប់មនុស្សដែលមិនអាចទុកចិត្តបាន ប៉ុន្តែតើមានអ្វីកើតឡើងចំពោះមនុស្សដែលបញ្ជាក់ម្តងហើយម្តងទៀតថាពួកគេអាចទុកចិត្តបាន? ដូចដែលយើងបាននិយាយថា មិនមានអ្នកណាម្នាក់ឥតខ្ចោះនោះទេប៉ុន្តែក៏មានមនុស្សអស្ចារ្យដ៏គួរឲ្យភ្ញាក់ផ្អើលមួយចំនួននៅក្នុងលោកនេះដែរ ដែលពេញទៅដោយសេចក្តីសុចរិតនិងស្មោះត្រង់។ យើងអាចពឹងផ្អែកលើពួកគេដើម្បីរក្សាសំដីរបស់ពួកគេ ហើយមិនមែនដើម្បីជាគោលបំណងបំផ្លាញទំនុកចិត្តរបស់យើង។

ខ្ញុំមានឱកាសស្គាល់មនុស្សប្រភេទនេះមួយចំនួន ហើយក៏អរគុណសម្រាប់ពួកគេ។ នៅពេលដែលខ្ញុំបានទទួលការឈឺចាប់ហើយខ្ញុំត្រូវល្បួងដើម្បីអនុញ្ញាតអោយឥរិយាបទចាស់ថា «អ្នកមិនអាចទុកចិត្តអ្នកណាម្នាក់បានទេ» ភ្លាមត្រឡប់ចូលក្នុងចិត្តរបស់ខ្ញុំ ខ្ញុំចាំបានថាមនុស្សដ៏កំរទាំងនេះដែលបានបន្តផ្តល់ឲ្យខ្ញុំនូវក្តីសង្ឃឹម។

ជានិច្ចកាលវាប្រសើរដែលមើលទៅកាន់ពន្លឺជាផ្នែកវិជ្ជមាននៃបញ្ហាអ្វីមួយ ជាជាងភាពល្ងីងល្ងរចត់ដែលដែលអវិជ្ជមាន។ មួយឲ្យក្តីសុខសាន្តមកយើង មួយផ្សេងទៀតលួចយកក្តីសុខសាន្តពីយើង ដូច្នេះតើហេតុអ្វីបានជាមិនធ្វើអ្វីគ្រប់យ៉ាងដែលអ្នកអាចធ្វើបាន ដើម្បីឲ្យជីវិតរបស់អ្នកល្អដូចដែលអ្នកអាចធ្វើទៅបានដោយមើលទៅផ្នែកនៃពន្លឺ?

## *ការយល់ដឹង*

មានអំណោយទាននៃព្រះវិញ្ញាណបរិសុទ្ធដែលយើងអាចទទួលបាន ត្រូវបានហៅថាវិញ្ញាណនៃការយល់ដឹង (១កូរិនថូស១២:៤-១១)។ វាគឺជាអំណោយទានដែលលើសពីធម្មជាតិមកពីព្រះ ដែលអនុញ្ញាតឲ្យយើងជួនកាលមានសមត្ថភាពដើម្បីដឹងថាអ្នកណាអាក្រក់ ហើយអ្នកណាល្អ។ ខ្ញុំអធិស្ឋានជាញឹកញាប់សម្រាប់អំណោយទាននៃការយល់ដឹងនេះ។ ខ្ញុំដឹងថាព្រះជាម្ចាស់អាចបណ្តាលឲ្យខ្ញុំដឹងអ្វីដែលមិនល្អជាមួយមនុស្សម្នាក់ នៅពេលដែលវាមិនមែនជាការដឹងតាមបែបធម្មជាតិសម្រាប់ខ្ញុំដើម្បីដឹងវា។ ថ្មីៗនេះខ្ញុំមានអារម្មណ៍បែបនោះពីមនុស្សម្នាក់ ដែលខ្ញុំទើបនឹងបានជួប។ មានពេលមួយខ្ញុំបានឃើញពួកគេ ខ្ញុំបានគិតថា *ខ្ញុំមិនទុកចិត្តអ្នកទេ*។ វាគឺជាលើកទីមួយដែលខ្ញុំបានធ្វើទោសខ្លួនឯងសម្រាប់ការដែលមានមន្ទិលសង្ស័យ និងការវិនិច្ឆ័យនេះ ប៉ុន្តែនោះបន្ទាប់ពីមនុស្សពីរនាក់ផ្សេងគ្នាបានប្រាប់ខ្ញុំអំពីលក្ខណៈពីរដែលអាចបំបែកចេញពីគ្នាដែលមនុស្សម្នាក់នៅក្នុងសំណួរ មិនបានបង្ហាញពួកវាចេញមក ដែលគួរនឹងបែបនោះ។

ខ្ញុំក៏មានបទពិសោធន៍នៃអារម្មណ៍ថា មានអ្វីមួយមិនត្រឹមត្រូវជាមួយនឹងបុគ្គលិករបស់ខ្ញុំផងដែរ។ ខ្ញុំមិនបានដឹងថាមានអ្វីដែលបានកើតឡើងនោះទេ ប៉ុន្តែខ្ញុំបានមានអារម្មណ៍ថា ខ្ញុំមិនមានសេចក្តីសុខនៅពេលដែលខ្ញុំបាននៅជាមួយពួកគេ។ បន្ទាប់ពីនោះពីរបីខែ យើងបានរកឃើញថាពួកគេមិនបានធ្វើកិច្ចការរបស់ពួកគេដោយត្រឹមត្រូវ ហើយពួកគេបានលាក់បាំងនូវរឿងមួយចំនួនដែលពួកគេគួរនឹងបញ្ចេញពួកវាជាការបើកចំហ។ ពីព្រោះខ្ញុំពិតជាបានមានអារម្មណ៍អ្វីមួយដែលវាមិនត្រឹមត្រូវ ការខក

បំណងដែលខ្ញុំមានអារម្មណ៍ថាមិនខ្លាំង ដូចដែលវាត្រូវបានគេនាំខ្ញុំអោយភ្ញាក់ផ្អើលនោះទេ។ ការស្គាល់ខុសស្គាល់ត្រូវ អាចការពារយើងពីការទាក់ទងជាមួយមនុស្សដែលខុស ហើយវាក៏អាចជួយរៀបចំយើងសម្រាប់អ្វីៗមុនពេលដែលវាកើតឡើង។

នៅពេលដែលខ្ញុំមានអារម្មណ៍ថាអ្វីមួយមិនត្រឹមត្រូវឬខ្ញុំមិនមានសន្តិភាពជាមួយអ្នកណាម្នាក់ ខ្ញុំមិនពឹងផ្អែកលើតែអារម្មណ៍នោះទេ ព្រោះខ្ញុំដឹងថាខ្ញុំអាចនឹងខុស ហើយខ្ញុំមិនចង់វិនិច្ឆ័យអ្នកណាម្នាក់ ឬក៏បិទចិត្តរបស់ខ្ញុំចំពោះពួកគេដោយផ្អែកតែលើអារម្មណ៍ប៉ុណ្ណោះទេ។ ប៉ុន្តែវាបានធ្វើឲ្យខ្ញុំប្រុងប្រយ័ត្នកាន់តែច្រើនឡើង ហើយមើលកាន់តែជិតជាងមុន។ ខ្ញុំអធិស្ឋានថា ប្រសិនបើមានបញ្ហានានា សូមព្រះបញ្ចៀសវាហើយព្រះអង្គតែងតែធ្វើការនេះ។ ចូរអធិស្ឋានសម្រាប់ការស្គាល់ខុសស្គាល់ត្រូវ។ វានឹងរក្សាអ្នកពីការបោកបញ្ឆោត ឬក៏ការឈឺចាប់។

មនុស្សដើរដោយវិញ្ញាណយ៉ាងពិតប្រាកដ ជាមនុស្សដែលមានការវិនិច្ឆ័យល្អ:

> *រីឯមនុស្សដែលបានទទួលព្រះវិញ្ញាណ វិនិច្ឆ័យបានទាំងអស់ {គាត់ពិនិត្យស្វែងរកដោយខ្ជាប់ខ្ជួន ស៊ើបសួរ សួរ ហើយវិនិច្ឆ័យលើអ្វីៗទាំងអស់} ហើយគ្មានអ្នកណាវិនិច្ឆ័យអ្នកនោះបានទេ។*
>
> *(១កូរិនថូស ២៖១៥)(KHSV)*

## ចូរទុកចិត្តព្រះអម្ចាស់!

ទោះបីជាយើងមិនអាចទុកចិត្តមនុស្សបានគ្រប់ពេល តែយើងតែងតែអាចទុកចិត្តព្រះ! ព្រះបិតានៃស្ថានសួគ៌របស់យើងទ្រង់បានបញ្ជាក់ម្តងហើយម្តងទៀតថា ទ្រង់អាចជឿជាក់បាន លើអ្វីដែលយើងបានថ្វាយទៅទ្រង់។

ខ្ញុំដឹងថាមានសំណួរមួយចំនួនដែលយើងនឹងត្រូវឲ្យចំណាងជើង ដូចជា: ប្រសិនបើព្រះល្អ ហើយទ្រង់អព្យាក្រឹត្យ ដូច្នេះហេតុអ្វីបានជាទ្រង់មិនធ្វើអ្វីមួយជាមួយនឹងស្ថានភាពគួរឲ្យរន្ធត់ក្នុងជីវិតរបស់មនុស្ស? តើអាចឲ្យយើងទុកចិត្តមនុស្សម្នាក់ដែលអាចធ្វើឲ្យការឈឺចាប់របស់យើងឃ្លាតចេញទៅបាន តែគេនៅតែមិនធ្វើវាដោយរបៀបណា? សម្រាប់បញ្ហានោះគឺ ហេតុអ្វីបានជារឿងអាក្រក់ៗ កើតមានលើមនុស្សល្អ? ឪពុករបស់ខ្ញុំ ជាមនុស្សម្នាក់ដែលអាក្រក់បំផុត រស់នៅបានរហូតដល់អាយុ ប៉ែតសិបបីឆ្នាំ ហើយថ្មីៗនេះខ្ញុំបានចូលរួមពិធីបុណ្យសពនៃភរិយាជាគ្រិស្ទបរិស័ទរយៈពេល សាមសិបប្រាំពីរឆ្នាំ នឹងជាម្តាយនៃកុមារតូចៗពីរនាក់។ ហេតុអ្វីបានជាមនុស្សអាក្រក់រស់បានយូរ ខណៈពេលដែលមនុស្សល្អរស់នៅបានតែរយៈខ្លី?

មានចម្លើយមួយចំនួន ប៉ុន្តែចម្លើយតែមួយដែលយើងមាន អាចនឹងមិនគ្រប់គ្រាន់ដើម្បីបំពេញចិត្តអ្នករាល់គ្នាទេ។ ខ្ញុំនឹងបកស្រាយជាមួយនឹងប្រធានបទនេះឲ្យបានល្អ

បំផុតដោយសមត្ថភាពដែលនៅមានភាពខ្វះចន្លោះរបស់ខ្ញុំ នៅពេលក្រោយនៅក្នុងសៀវភៅនេះ ប៉ុន្តែសូមអនុញ្ញាតឲ្យខ្ញុំនិយាយម្តងទៀតថា ការទុកចិត្តព្រះតម្រូវឲ្យយើងនៅតែទុកចិត្តទ្រង់លើគ្រប់ផ្លូវទាំងអស់ ទោះជាមានសំណួរមួយចំនួនដែលមិនមានចម្លើយក៏ដោយ។ ផ្នែកមួយនៃការទុកចិត្តព្រះមិនមានព្រំដែននោះទេ នោះមានន័យថា យើងមិនឈប់ទុកចិត្តទ្រង់ទេ នៅពេលដែលយើងមានសំណួរដែលមិនមានចម្លើយ! យើងអាចមិនដឹងអំពីចម្លើយទាំងនោះ ប៉ុន្តែយើងអាចសម្រាកនៅក្នុងសេចក្តីជំនឿដែលថា ព្រះជាម្ចាស់ដឹងពីការទាំងនោះ។

ការទុកចិត្តព្រះជាម្ចាស់គឺជាអភ័យឯកសិទ្ធិ វាជាជំរើសដែលយើងអាចធ្វើបាន ប្រសិនបើយើងជ្រើសរើសធ្វើ។ បន្ទាប់មកជាច្រើនឆ្នាំនៃការសួរសំណួរនៃបញ្ហាជាច្រើន ខ្ញុំបានសម្រេចចិត្តទុកចិត្តព្រះ ពីព្រោះមិនមានផ្លូវណាផ្សេងសម្រាប់ខ្ញុំ ដែលធ្លាប់មានសុភមង្គលនោះទេ លុះត្រាតែខ្ញុំទុកចិត្តលើទ្រង់។ ខ្ញុំជឿថាទ្រង់ស័ក្តិសមនឹងសេចក្តីទុកចិត្តរបស់ខ្ញុំ។ ខ្ញុំមានបទពិសោធន៍ក្នុងការដាក់សេចក្តីទុកចិត្តរបស់ខ្ញុំលើអ្វីមួយ ឬនរណាម្នាក់ផ្សេងទៀត ហើយខ្ញុំក៏មិនបានរកឃើញថាវត្ថុអ្វីមួយនោះ ឬនរណាម្នាក់នោះ ដែលមានភាពឥតខ្ចោះគ្រប់គ្រាន់ស័ក្តិសមនឹងទទួលការទុកចិត្តទាំងនោះដែរ ដូច្នេះខ្ញុំថ្វាយវាទៅព្រះ។ ខ្ញុំបានព្យាយាមទុកចិត្តខ្លួនរបស់ខ្ញុំ តែនោះគឺជាមហន្តរាយ។ ខ្ញុំបានព្យាយាមទុកចិត្តលើមនុស្សដទៃទៀត ហើយទោះបីជាមួយចំនួននៃពួកគេពិតជាមនុស្សល្អ យើងបានឃើញហើយថាធម្មជាតិរបស់មនុស្សគឺមិនមានអ្នកណាឥតខ្ចោះនោះទេ។ រដ្ឋាភិបាលមិនជាជំរើសដ៏ល្អនោះទេ សូម្បីតែផ្សារភាគហ៊ុន ឬក៏ប្រាក់ចូលនិវត្តន៍របស់ខ្ញុំក៏ដោយ។ បន្ទាប់ពីការពិចារណាទៅលើជំរើសនានារបស់ខ្ញុំរួចមក ព្រះជាម្ចាស់ទទួលជ័យជំនះ ខ្ញុំទុកចិត្តទ្រង់!

វាគួរឲ្យចាប់អារម្មណ៍ នៅពេលដែលខ្ញុំបានសរសេរឃ្លាចុងក្រោយនេះ ខ្ញុំមានអារម្មណ៍ថាមានសេចក្តីអំណរនៅក្នុងព្រលឹងរបស់ខ្ញុំ! ដែលប្រាប់ខ្ញុំថា ព្រះមានអំណរនៅពេលដែលយើងទុកចិត្តទ្រង់។ ទ្រង់សព្វព្រះហឫទ័យនឹងវា ហើយទ្រង់ចាប់ផ្តើមគង់ក្នុងរាស្ត្ររបស់ទ្រង់ នៅពេលដែលទ្រង់មានអំណរយើងក៏មានអំណរដែរ។

ប្រសិនបើអ្នកធ្លាប់ឆ្ងល់ពីសេចក្តីអំណរដែលអ្នកមាន ចូរពិនិត្យមើលសេចក្តីជំនឿរបស់អ្នក។ លោក ប៉ុល បានប្រាប់នៅក្នុងព្រះគម្ពីររ៉ូមថា សេចក្តីអំណរនិងសេចក្តីសុខសាន្តរកឃើញនៅក្នុងសេចក្តីជំនឿ (រ៉ូម ១៥៖១៣)។ ខ្ញុំបានសាកល្បងគោលការណ៍នេះនៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំដឹងថាវាជាការពិត។ ពេលដែលខ្ញុំទុកចិត្តព្រះការជឿព្រះបន្ទូលនិងការសន្យារបស់ទ្រង់ ខ្ញុំមានសន្តិភាពនិងអំណរ ហើយខ្ញុំរីករាយនឹងជីវិត។ ប៉ុន្តែពេលដែលខ្ញុំមិនទុកចិត្តទ្រង់ ខ្ញុំពេញទៅដោយមន្ទិលសង្ស័យ ភាពភ័យខ្លាច ក្តីព្រួយបារម្ភ និងក្តីកង្វល់។ វាគឺជាភាពតប់ប្រមល់ដែលជំនួសមកនូវបន្ទុកយ៉ាងធ្ងន់លើខ្ញុំ ដែលខ្ញុំមិនចង់រែកពន់វា។

យើងមានជំរើសតែពីរប៉ុណ្ណោះគឺ ទុកចិត្តព្រះ ឬមិនទុកចិត្តទ្រង់។ នេះមិនមែនជាអ្វីដែលយើងអាចធ្វើតែពាក់កណ្តាលហើយទទួលបានផលពេញលេញនោះទេ! ប៉ុន្តែដូចដែលបានស្នើកន្លងមក លើអ្វីៗទាំងអស់ផ្សេងទៀត សូមស្មោះត្រង់ជាមួយព្រះ។ ជាមួយកាធ្វើពុត យើងមិនបានទទួលកន្លែងណាទាំងអស់ជាមួយព្រះ។ ប្រសិនបើអ្នកមានបញ្ហាក្នុងការទុកចិត្តព្រះ ប៉ុន្តែអ្នកចង់ទុកចិត្តទ្រង់ ដូច្នេះសូមអធិស្ឋាននូវការអធិស្ឋាននេះ «ឱព្រះបិតាអើយ ទូលបង្គំទុកចិត្តទ្រង់ដើម្បីជួយទូលបង្គំឲ្យរៀនទុកចិត្តព្រះអង្គ។»

«ព្រះបិតា ទូលបង្គំទុកចិត្តទ្រង់ដើម្បីជួយទូលបង្គំឲ្យចេះរៀនទុកចិត្តព្រះអង្គ។»

ព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងជួបអ្នកនៅគ្រប់ទីកន្លែងដែលអ្នកនៅ ហើយនឹងជួយអ្នកឲ្យអ្នកបានទៅដល់ទីកន្លែងដែលអ្នកចង់ទៅដល់។ នេះគឺជាព័តមានដ៏ល្អនៃ *ដំណឹងល្អ*!

# ជំពូក ៤

## ភាពល្ងីល្ងើក្នុងការពឹងផ្អែកលើខ្លួនឯង

*មិនមែនថា យើងខ្ញុំពូកែល្មមដោយខ្លួនឯង និងគិតស្មានថា មានអ្វីកើតពីខ្លួនយើងខ្ញុំនោះឡើយ តែដែលយើងខ្ញុំពូកែនោះមកតែពីព្រះទេ។*

២កូរិនថូស៣:៥

តើអ្នកត្រូវទុកចិត្តលើព្រះជាម្ចាស់ ឬត្រូវទុកចិត្តលើខ្លួនឯង? តាំងពីដើមរៀងមក ការលើកឡើងអំពីសំណួរនៃការសង្ឃឹមខាងវិញ្ញាណនេះ បានផ្លាស់ប្តូរជាច្រើនដង។ មនុស្សជាតិតែងតែប្រឆាំងយ៉ាងខ្លាំងអំពីគំនិតដែលត្រូវការព្រះជាម្ចាស់។

មនុស្សគ្រប់គ្នា ហើយតាមពិតទៅគឺគ្រិស្តបរិស័ទគ្រប់រូបតែម្តង គួរតែខិតខំយ៉ាងខ្លាំងក្នុងការប្រើប្រាស់ទេព្យកោសលរបស់ខ្លួនឲ្យអស់ពីសមត្ថភាព ហើយយើងក៏ត្រូវធ្វើការសម្រេចចិត្តផងដែរ។ ប៉ុន្តែព្រះជាម្ចាស់មិនបានត្រាស់ហៅយើងមកដើម្បីឲ្យយើងដឹកនាំជីវិតដោយខ្លួនឯងឡើយ ហើយធ្វើដូចជាយើងធ្វើឲ្យព្រះជាម្ចាស់សព្វព្រះទ័យ និងព្រងើយកន្តើយជាមួយព្រះអង្គរហូតដល់យើងមានរឿងបន្ទាន់ដែលមិនអាចដោះស្រាយបាន។

ការប៉ុនប៉ងក្នុងការរស់នៅដោយខ្លួនឯង ដោយទោរទន់ទៅរកការពឹងផ្អែកដោយខ្លួនឯងនឹងបញ្ចប់ដោយការអស់កំលាំងទាំងគំនិត អារម្មណ៍ និងរូបកាយ បូករួមទាំងមានការស្រងាកចិត្ត ការខកចិត្ត ឬអាចមានកំហឹង និងមានការភាន់ភាំងផង។

គម្ពីរយ៉ូស្វេ ២៤:១៥ យើងត្រូវតែបង្ហាញជម្រើសដែលយើងជ្រើសរើស ហើយវានៅតែជាជម្រើសដែលល្អបំផុត សម្រាប់អ្នកជឿគ្រប់រូប។

*តែបើសិនជាឯងរាល់គ្នាមិនគាប់ចិត្តនឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាទេ នោះចូររើសយកព្រះណា ដែលឯងចង់គោរពប្រតិបត្តិតាមនៅថ្ងៃនេះចុះ... តែឯអញ និងពួកគ្រួអញ យើងទាំងអស់គ្នានឹងគោរពប្រតិបត្តិដល់ព្រះយេហូវ៉ាតែមួយប៉ុណ្ណោះ។*

ការរំឮកមួយដែលសំខាន់បំផុតក្នុងចំណោមការរំលឹកដែលខ្ញុំអាចផ្តល់ឲ្យអ្នកនៅ

ថ្ងៃនេះ អាចថា «អ្នកត្រូវធ្វើការសម្រេចចិត្តដោយខ្លួនឯងថា តើអ្នកនឹងបម្រើព្រះជាម្ចាស់ឬអត់ ហើយកុំឲ្យពាក្យរបស់នរណាម្នាក់ ឬក៏នរណាម្នាក់សម្រេចចិត្តជំនួសអ្នកឡើយ»។

> តើនៅក្នុងជីវិតតែមួយគត់របស់អ្នកនេះ តើអ្នកនឹងទុកចិត្តលើអ្នកណា?

តើនៅក្នុងជីវិតតែមួយគត់របស់អ្នកនេះ តើអ្នកនឹងទុកចិត្តលើអ្នកណា? តើអ្នកនឹងទុកចិត្តលើអ្នកដែលជាដើមហើយជាចុង ជាអ្នកដែលជ្រាបទាំងការចាប់ផ្តើមនិងការបញ្ចប់ឬទេ? ឬអ្នកនឹងទុកចិត្តលើព្រះនៃប្រព័ន្ធលោកីយ៍នេះ និងទុកចិត្តលើវិញ្ញាណនៃការពឹងផ្អែកលើខ្លួនឯង?

## *តើអ្វីទៅជាការពឹងផ្អែកលើខ្លួនឯង?*

ការពឹងផ្អែកលើខ្លួនឯង គឺជាការប៉ុនប៉ងរបស់មនុស្ស ដើម្បីទទួលបានសុភមង្គលតាមរយៈរបស់ក្រៅខ្លួន ដូចជាលុយកាក់ តួនាទី អំណាច រូបរាងកាយ ទ្រព្យសម្បត្តិ និងអ្វីផ្សេងៗទៀត។ នៅពេលដែលយើងទទួលស្គាល់ថារបស់ទាំងនេះនឹងធ្វើឲ្យយើងរីករាយ យើងនឹងព្យាយាមដេញតាមរបស់ទាំងនោះ រហូតទាល់តែយើងមានបទពិសោធន៍ក្នុងការបាក់ទឹកចិត្តច្រើន នោះយើងនឹងដឹងថារបស់ទាំងនោះមិនអាចផ្តល់ឲ្យអ្វីដែលយើងគិតថាវាអាចផ្តល់ឲ្យយើងបានឡើយ។

មានពេលមួយខ្ញុំបានឮមនុស្សម្នាក់និយាយថា៖ «មនុស្សបានចំណាយពេលពេញមួយជីវិតរបស់ពួកគេព្យាយាមឡើងជណ្តើរជោគជ័យ រហូតដល់ពួកគេទៅដល់ទីខ្ពស់បំផុតទើបពួកគេបានដឹងថាជណ្តើររបស់ពួកគេផ្អែកទៅលើអគារខុស»។ ខ្ញុំឆ្ងល់ណាស់នៅពេលដែលអ្នកណាម្នាក់ជិតស្លាប់ទៅហើយបែរជាសួរសំណួរ អំពីលុយនៅក្នុងធនាគាទៅវិញ។ ពួកគេចង់នៅជាមួយគ្រួសារ មិត្តភ័ក្តរបស់ពួកគេ ហើយខ្ញុំសង្ឃឹមថាពួកគេចង់នៅជាមួយព្រះជាម្ចាស់។

ខ្ញុំដឹងច្បាស់ថាអ្នកក៏ធ្លាប់និយាយ ឬក៏ឮគេនិយាយថា៖ «ខ្ញុំមិនត្រូវការនរណាទាំងអស់។ ខ្ញុំអាចមើលថែខ្លួនឯងបាន»។ ខ្ញុំបាននិយាយដូច្នេះ ឬក៏និយាយពាក្យស្រដៀងនេះអស់រយៈពេលជាច្រើនឆ្នាំក្នុងជីវិតរបស់ខ្ញុំ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ ដែលខ្ញុំបានដឹងថាខ្ញុំពិតជាត្រូវការអ្នកដទៃ ហើយខ្ញុំពិតជាត្រូវការព្រះជាម្ចាស់។ មនុស្សដែលបាននិយាយពាក្យស្រដៀងគ្នានេះ ដោយសារគេធ្លាប់ទទួលការឈឺចាប់យ៉ាងខ្លាំងពីអ្នកដទៃ ហើយពួកគេមិនធ្លាប់បានទទួលការណែនាំឲ្យមានទំនាក់ទំនង

ពិតប្រាកដជាមួយព្រះជាម្ចាស់តាមរយៈព្រះយេស៊ូឡើយ។ ពួកគេមិនទុកចិត្តអ្នកណាម្នាក់ឡើយក្រៅពីខ្លួនគេផ្ទាល់ ហើយពួកគេមិនបានដឹងថាការពឹងផ្អែកលើខ្លួនឯងគឺជាជម្រើសមួយដែលអាក្រក់បំផុតឡើយ។ ពួកគេត្រូវការជួបជាមួយព្រះដ៏ពិត ដែលបានបង្កើតពួកគេមក និងជាព្រះដែលស្រឡាញ់ពួកគេដោយឥតលក្ខខ័ណ្ឌ។

មនុស្សម្នាក់អាចគិតថា ពួកគេមិនត្រូវការនរណាម្នាក់ឡើយ ប៉ុន្តែព្រះជាម្ចាស់បានបង្កើតយើងមកឲ្យត្រូវការគ្នាទៅវិញទៅមក ទោះបីជាយើងចូលចិត្ត ឬអត់ យើងមិនអាចពេញលក្ខណៈបានទេ រហូតដល់យើងរៀនពឹងផ្អែក និងចាប់ដៃគូជាមួយអ្នកដទៃនៅក្នុងជីវិត។ មនុស្សម្នាក់ៗមានទេព្យកោសល និងសមត្ថភាព ប៉ុន្តែគ្មាននណាម្នាក់ក្នុងចំណោមយើងមានគ្រប់យ៉ាងនោះទេ។ ព្រះជាម្ចាស់បានដាក់យើងនៅក្នុងទំនាក់ទំនងជាមួយអ្នកដទៃ ជាអ្នកដែលមានអ្វីដែលយើងគ្មាន ហើយយើងត្រូវរៀនក្នុងការធ្វើការជាមួយគ្នា យើងអាចទទួលបានរបស់អស្ចារ្យ ហើយយើងអាចរីករាយនឹងជីវិតរបស់យើងបាន។

គួរឲ្យស្តាយ ដែលយើងតែងតែចំណាយពេលឥតប្រយោជន៍ក្នុងការរិះគន់អ្នកដទៃ ដោយសារតែគេមិនបានធ្វើតាមរបៀបដូចដែលយើងធ្វើ ហើយយើងក៏បានបដិសេធពួកគេ ជាជាងទទួលយកពួកគេដែរ។ រឿងទាំងនេះបណ្តាលឲ្យយើងបាត់បង់នូវអ្វីដែលពួកគេអាចរួមចំណែកនៅក្នុងជីវិតរបស់យើង ហើយវាក៏បានលួចអ្វីដែលយើងអាចរួមចំណែកក្នុងជីវិតរបស់ពួកគេចេញពីពួកគេដែរ។ រឿងមួយក្នុងចំណោមរឿងសំខាន់ៗទាំងឡាយដែលយើងទាំងអស់គ្នាអាចរៀនបាន គឺត្រូវឲ្យតំលៃមនុស្សគ្រប់គ្នា។ ពួកគេក៏មិនគ្រប់លក្ខ័ណ៍ដូចជាយើងរាល់គ្នាដែរ ហើយយើងត្រូវធ្វើការ និងខិតខំប្រឹងប្រែង ដើម្បីកសាងទំនាក់ទំនងល្អជាមួយអ្នកដទៃ តែវាពិតជាមានតំលៃណាស់។

កុំឲ្យគិតថាគ្រប់គ្នានឹងធ្វើឲ្យអ្នកឈឺចាប់ ដោយសារមានមនុស្សម្នាក់បានធ្វើឲ្យអ្នកឈឺចាប់នោះឡើយ! ទោះបីជាយើងទុកចិត្តអ្នកដទៃហើយអាចទទួលការឈឺចាប់ដោយប្រការណាមួយក៏ដោយ ក៏វាប្រសើរជាងការកាត់ផ្តាច់ខ្លួនឯងពីអ្នកដទៃ ហើយបដិសេធមិនបើកចំហដួងចិត្តរបស់អ្នកចំពោះនរណាម្នាក់នោះដែរ។ ដោយសារតែខ្ញុំមានបទពិសោធន៍មិនល្អជាមួយអ្នកដទៃ ធ្វើឲ្យខ្ញុំបានសង់ជញ្ជាំងមួយជុំវិញដួងចិត្តរបស់ខ្ញុំ ហើយភ័យខ្លាចមិនឲ្យនរណាម្នាក់ចូលមកទេ។ ខ្ញុំធ្លាប់មានទំនាក់ទំនងខ្លះ ប៉ុន្តែមិនមែនជាទំនាក់ទំនងដែលល្អទេ ពីព្រោះខ្ញុំបានចំណាយពេលជាច្រើន ដើម្បីកុំឲ្យគេបដិសេធខ្ញុំ

> កុំឲ្យគិតថាគ្រប់គ្នានឹងធ្វើឲ្យអ្នកឈឺចាប់ ដោយសារមានមនុស្សម្នាក់បានធ្វើឲ្យអ្នកឈឺចាប់នោះឡើយ!

ជាជាងការកសាងទំនាក់ទំនងល្អជាមួយពួកគេ។ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់តាមរយៈទំនាក់ទំនងជាមួយព្រះអង្គ ព្រមទាំងបទពិសោធន៍តាមរយៈព្រះចេស្តារបស់ទ្រង់ ដែលធ្វើឲ្យខ្ញុំបានរៀនក្នុងការទុកចិត្តសារជាថ្មីម្តងទៀត។

ប្រសិនបើអ្នកធ្លាប់ទទួលការឈឺចាប់ ព្រះជាម្ចាស់រង់ចាំក្នុងការព្យាបាលព្រលឹងដែលមានរបួសរបស់អ្នក។ ព្រះអង្គនឹងព្យាបាលដួងចិត្តដែលប្រេះស្រាំ ហើយផ្តល់អំណរឲ្យពួកគេជាជំនួសឲ្យការឈឺចាប់ (អេសាយ ៦១:១-៧)។ ព្រះអង្គនឹងក្លាយជាជញ្ជាំងការពារជុំវិញអ្នក។ ព្រះជាម្ចាស់មិនបានធានាថាយើងនឹងមិនទទួលការឈឺចាប់នោះឡើយ ប៉ុន្តែព្រះអង្គពិតជាបានសន្យាថានឹងកំសាន្តចិត្ត ព្យាបាលហើយស្តារយើងឡើងវិញនៅពេលដែលយើងមានបញ្ហា។ សូមចំណាយពេលដើម្បីអានយឺតៗ ហើយពិចារណាលើខគម្ពីរខាងក្រោម។ វាបានជួយខ្ញុំយ៉ាងច្រើនក្នុងឆ្នាំដែលខ្ញុំរៀនក្នុងការពឹងផ្អែកព្រះជាម្ចាស់ជាជាងពឹងផ្អែកលើខ្លួនឯង។

> *សូមសរសើរដល់ព្រះដ៏ជាព្រះវរបិតានៃព្រះយេស៊ូវគ្រីស្ទ ជាអម្ចាស់នៃយើងរាល់គ្នា គឺជាព្រះវរបិតាដ៏មានសេចក្តីមេត្តាករុណា ជាព្រះដ៏កំសាន្តចិត្តគ្រប់ជំពូក ៤ ដែលទ្រង់កំសាន្តចិត្តយើងរាល់គ្នា ក្នុងគ្រប់ទាំងសេចក្តីវេទនា ប្រយោជន៍ឲ្យយើងអាចនឹងកំសាន្តចិត្តអ្នកឯទៀត ក្នុងអស់ទាំងសេចក្តីវេទនារបស់គេបានដែរ គឺដោយសារសេចក្តីក្សាន្តនោះឯង ដែលព្រះបានកំសាន្តចិត្តយើងស្រេចហើយ។*
>
> *២កូរិនថូស១:៣-៤*

បើខ្ញុំមិនបានអនុញ្ញាតឲ្យព្រះជាម្ចាស់ព្យាបាលព្រលឹងដែលមាន របួសរបស់ខ្ញុំទេ នោះខ្ញុំមិនអាចបង្រៀនអ្នកដទៃឲ្យទទួលជំនួយ និងទទួលការកំសាន្តចិត្តពីព្រះជាម្ចាស់បានឡើយ។ ព្រះជាម្ចាស់ក៏មានរឿងសំខាន់មួយចំនួនឲ្យអ្នកធ្វើ និងមានមនុស្សជាច្រើនឲ្យអ្នកជួយដែរ។ ប្រសិនបើអ្នកនៅក្នុងចំណោមអ្នកដែលមានរបួសនៅឡើយ ហើយជាប់នៅក្នុងការឈឺចាប់ពីអតីតកាល ខ្ញុំសូមអធិស្ឋានឲ្យអ្នកចាប់ផ្តើមទទួលការកំសាន្តចិត្ត និងការព្យាបាលពីព្រះជាម្ចាស់នៅថ្ងៃនេះ។ អ្នកអាចសុំពីព្រះជាម្ចាស់យ៉ាងសាមញ្ញ ដើម្បីឲ្យព្រះអង្គឲ្យព្យាបាលព្រលឹងនិងកំសាន្តចិត្តរបស់អ្នកនៅពេលដែលអ្នកឈឺចាប់ ។

> ព្រះជាម្ចាស់មិនត្រឹមតែព្យាបាលអ្នកទេ ព្រះអង្គនឹងស្តារពេលវេលាដែលបាត់បង់ក្នុងជីវិតរបស់អ្នកឡើងវិញ។

ព្រះជាម្ចាស់មិនត្រឹមតែព្យាបាលអ្នកទេ ព្រះអង្គនឹងស្តារពេលវេលាដែលបាត់បង់

ក្នុងជីវិតរបស់អ្នកឡើងវិញ។ ព្រះអង្គបានសន្យាថានឹងប្រទានព្រះពរទ្វេដងដល់យើង ជំនួសបញ្ហាពីមុនរបស់យើង ប្រសិនបើយើងដាក់ការទុកចិត្តលើព្រះអង្គ។ ទោះបីជាការទាំងអស់នោះមិនទាន់កើតឡើងក្នុងរយៈពេលមួយយប់ ក៏ដោយ តែវានឹងកើតឡើងបន្តិចម្តងៗនៅពេលដែលយើងនៅតែទុកចិត្តព្រះជាម្ចាស់ និងព្រមធ្វើការជាមួយព្រះវិញ្ញាណដើម្បីឲ្យមានការរួបរួម។ ដូចដែលមានចែងនៅក្នុងគម្ពីរ អេសាយ ៦១:៧ ថា៖

> *ឯងរាល់គ្នានឹងបានចំណែក១ជា២ជំនួសសេចក្តីខ្មាសរបស់ឯង ហើយនឹងមានសេចក្តីរីករាយ ដោយចំណែកដែលខ្លួនទទួលជំនួសសេចក្តីអាប់យស ដូច្នេះ ឯងនឹងបាន២ចំណែកនៅក្នុងស្រុករបស់ឯង ហើយនឹងមានសេចក្តីអំណរ ដ៏នៅអស់កល្បជានិច្ច។*

ការសន្យារបស់ព្រះជាម្ចាស់នេះបានកើតឡើយយ៉ាងពិតប្រាកដនៅក្នុងជីវិតរបស់ខ្ញុំ ក៏ដូចជានៅក្នុងជីវិតមនុស្សជាច្រើននាក់ទៀតដែលខ្ញុំបានស្គាល់។ ប្រសិនបើអ្នកគ្មានបទពិសោធន៍បែបនេះទេ អ្នកនឹងជួបមិនខាន។ ការទុកចិត្តលើព្រះជាម្ចាស់គឺជាគន្លឹះដើម្បីបើកបង្ហូរសេចក្តីសន្យានេះ និងសេចក្តីសន្យាផ្សេងៗទៀតដែរ។

## *មនុស្សល្ងីល្ងើ*

គម្ពីរសុភាសិត គឺជាគម្ពីរដែលចែកចាយពីគោលការណ៍នៃប្រាជ្ញា ហើយសាឡូមូនដែលជាអ្នកសរសេរគម្ពីរនេះ បានចំណាយពេលជាច្រើន ដើម្បីបង្ហាញទាំងផលនៃប្រាជ្ញា និងផលនៃភាពល្ងីល្ងើ។ មានព្រះបន្ទូលដែលថ្លែងពីមនុស្សមានប្រាជ្ញា និងមនុស្សល្ងីល្ងើ។ ព្រះពរតាមរយៈព្រះបន្ទូលសន្យាសម្រាប់អ្នកមានប្រាជ្ញាមានដូចជា៖ ការណែនាំ ការថែរក្សា អាយុវែង សុខភាពល្អ ភាពរុងរឿងសម្រាប់ខ្លួនឯង កិត្តិយស និងការគោរព ទាំងនេះគ្រាន់តែជាចំណុចខ្លះៗប៉ុណ្ណោះ។ ប៉ុន្តែមនុស្សល្ងីល្ងើរំពឹងនឹងបានអ្វីដែលផ្ទុយពីនេះប៉ុណ្ណោះ។

នៅក្នុងគម្ពីរសុភាសិតបានរៀបរាប់ថា មនុស្សល្ងីល្ងើជាអ្នកដែលមានទំនុកចិត្តលើខ្លួនឯង ឬជាមនុស្សដែលពឹងផ្អែកលើខ្លួនឯង។ សូមដឹងឲ្យច្បាស់ថាអ្នកដែលពឹងផ្អែកលើខ្លួនឯងគឺជាមនុស្សល្ងីល្ងើ ហើយផលនៃការជ្រើសរើសរបស់អ្នកនោះមិនដែលល្អឡើយ។ មនុស្សដែលពឹងផ្អែកលើខ្លួនឯង បដិសេធដំបូន្មានរបស់អ្នកដទៃ។ ពួកគេគិតថាផ្លូវរបស់គេតែងតែត្រឹមត្រូវ។ ការអាម៉ាស់គឺជាផលដែលអាក្រក់បំផុតដែលអាច

បង្ហាញពីផលរបស់មនុស្សល្ងីល្ងើ (មើលក្នុងគម្ពីរ សុភាសិត ៣:៣៥)។ មនុស្សល្ងីល្ងើនិយាយដោយមិនបានគិត ហើយយើងអាចចំណាំគេបានតាមរយៈរបៀបដែលគេនិយាយ។ ពួកគេជាមនុស្សចំអក និងឡកឡឺយដែលយកសេចក្តីពិតជាការលេងសើច ។ ពួកគេស្រឡាញ់ការអាក្រក់ ហើយស្អប់អ្វីដែលល្អ។ ចរិតលក្ខណៈមួយដែលអាក្រក់បំផុតរបស់មនុស្សល្ងីល្ងើ និងអ្នកដែលពឹងផ្អែកលើខ្លួនឯងគឺអំណួត។ ភាពអំណួតរបស់ពួកគេផ្ទាល់បានបំផ្លាញពួកគេ ហើយពួកគេបដិសេធមិនចង់ស្តាប់ព្រះជាម្ចាស់ឡើយ។

ខ្ញុំគិតថាវាគ្មានបញ្ហាទេ បើយើងនិយាយថាមានមនុស្សល្ងីល្ងើជាច្រើននៅក្នុងពិភពលោកនេះ ហើយពួកគេនឹងច្រូតពីផលនៃភាពល្ងីល្ងើរបស់ខ្លួនបើគេមិនផ្លាស់ប្តូរទេនោះ។ រឿងដែលរំភើបបំផុតដែលបានមកព្រះជាម្ចាស់ គឺថាព្រះអង្គបានប្រទានការចាប់ផ្តើមថ្មីនៅពេលណាដែលយើងត្រូវការ។ គ្មាននរណាម្នាក់នៅជាប់ក្នុងអតីតកាលរបស់ខ្លួនរហូតទេ លុះត្រាតែគេជ្រើសរើសធ្វើបែបនោះ។ ទោះបីជាខ្ញុំធ្លាប់ពឹងផ្អែកលើខ្លួនឯងអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែដោយសារជំនួយពីព្រះជាម្ចាស់ ខ្ញុំបានផ្លាស់ប្តូរ ខ្ញុំពិតជាដឹងថាខ្ញុំពិតជាត្រូវការព្រះជាម្ចាស់គ្រប់ពេលវេលា ហើយខ្ញុំក៏ត្រូវការអ្នកដទៃដែរ! ខ្ញុំទុកចិត្តថាព្រះជាម្ចាស់នឹងប្រទានមនុស្សត្រឹមត្រូវមកក្នុងជីវិតរបស់ខ្ញុំ ហើយបន្ទាប់មក បើយើងដាក់ការទុកចិត្តរបស់យើងជាមួយព្រះអង្គ ការអស្ចារ្យនឹងកើតឡើង។

ទោះបីជានរណាម្នាក់ពិតជាប្តូរផ្តាច់ក្នុងការក្លាយជាគ្រិស្តបរិស័ទក៏ដោយ ក៏ជួនកាលគេធ្វើរឿងល្ងីល្ងើដែរ។ យ៉ាងហោចណាស់ខ្ញុំដឹងថាខ្ញុំធ្លាប់ឆ្លងកាត់រឿងនេះ។ ពីរបីខែមុន ខ្ញុំបានធ្វើការប្តូរផ្តាច់រយៈពេលយូរដោយមិនបានគិតឲ្យបានល្អិតល្អន់ ហើយឥឡូវនេះខ្ញុំគិតថា បើខ្ញុំមិនបានធ្វើវានោះល្អជាង។ ខ្ញុំបានប្តូរផ្តាច់តាមអារម្មណ៍របស់ខ្ញុំ ជាជាងចំណាយពេលស្វែងរកប្រាជ្ញាពីព្រះជាម្ចាស់។ ខ្ញុំបានប្រែចិត្តហើយសុំឲ្យព្រះជាម្ចាស់ជួយឲ្យខ្ញុំរក្សាពាក្យសំដីរបស់ខ្ញុំ ព្រោះខ្ញុំដឹងថាបើខ្ញុំមិនធ្វើតាមពាក្យសំដីរបស់ខ្ញុំទេ នោះខ្ញុំនឹងល្ងីល្ងើជាងមុនទៀត ហើយខ្ញុំក៏បានរៀនពីកំហុសរបស់ខ្ញុំពីការវាយតម្លៃរបស់ខ្ញុំ។

អ្វីដែលខ្ញុំចង់និយាយ គឺមនុស្សគ្រប់គ្នាមានពេលដែលល្ងីល្ងើ ប៉ុន្តែបើយើងមានដួងចិត្តដែលត្រឹមត្រូវជាមួយព្រះជាម្ចាស់ នោះព្រះអង្គអាចនាំការល្អចេញពីកំហុសរបស់យើងបាន។ នៅពេលខ្លះការក្លាយជាមនុស្សល្ងីល្ងើ និងការធ្វើការសម្រេចចិត្តដោយខ្លួនឯង ដោយមិនបានប្រឹក្សាជាមួយព្រះជាម្ចាស់ គឺ មិនដូចនឹងភាពល្ងីល្ងើដោយយើងរស់នៅដោយពឹងផ្អែកលើខ្លួនឯងនោះទេ។

យើងរៀនបានថាមនុស្សល្ងីល្ងើដែលព្រះគម្ពីរបានលើកឡើង គឺជាប្រភេទមនុស្សដែលមានការទុកចិត្តលើខ្លួនឯង ឬជាមនុស្សដែលពឹងផ្អែកលើខ្លួនឯង ការនេះបានធ្វើឲ្យខ្ញុំភ្លឹកភ្លែក។ការពឹងផ្អែកលើខ្លួនឯងធ្វើឲ្យយើងមានបញ្ហាច្រើនជាងអ្វីដែលយើងអាចស្រមៃដល់ទៅទៀត។ វាពិតជាបានបិទទ្វាពីគ្រប់ជំនួយដែលព្រះជាម្ចាស់ចង់ផ្តល់ឲ្យយើង។ នៅពេលដែលយើងពឹងផ្អែក ឬទុកចិត្តលើខ្លួនឯង លទ្ធផលគឺបានតិចតួចមែនទែនបើប្រៀបធៀបនឹងលទ្ធផលដ៏អស្ចារ្យ ដែលយើងនឹងទទួលបាននៅពេលយើងទុកចិត្តព្រះជាម្ចាស់!

## អ្នកមិនត្រូវធ្វើរឿងគ្រប់យ៉ាងទេ

ការមិនទុកចិត្តអ្នកណាសោះ ប៉ុន្តែទុកចិត្តតែលើខ្លួនឯង គឺជាបន្ទុកមួយដ៏ធ្ងន់ដែលអ្នកត្រូវទទួល។ វាមានន័យថាអ្នកត្រូវធ្វើរឿងគ្រប់យ៉ាងទាំងអស់។ វ៉ាវ! គ្រាន់តែគិតអំពីរឿងនេះ ខ្ញុំអស់កំលាំងទៅហើយ ព្រោះខ្ញុំនឹកចាំពីពេលដែលខ្ញុំដើរតាមផ្លូវនេះ។ និយមន័យមួយនៃការទុកចិត្តគឺ «ការពឹងផ្អែក» ហើយវាមានន័យថា ការផ្តេកផ្តួលលើការផ្តល់ទំនុកចិត្តលើ ការអាស្រ័យលើ ឬក៏ការជឿជាក់។ នៅពេលដែលយើងពឹងផ្អែកគ្នាទៅវិញទៅមក រំពេចនោះយើងបានបន្ធូរបន្ថយបន្ទុកដែលយើងមាន។

បើអ្នកឮខ្លួនឯងនិយាយថា «ខ្ញុំមិនអាចបន្តធ្វើតាមរបៀបនេះបានទៀតទេ» វាប្រហែលជាមានន័យថា អ្នកព្យាយាមធ្វើលើសពីអ្វីដែលព្រះជាម្ចាស់បង្កើតអ្នកឲ្យមានសមត្ថភាពធ្វើហើយ។ មនុស្សយើងគ្រប់គ្នាមានដែនកំណត់។ យើងអាចចំណាំដែនកំណត់ទាំងនោះបាន ប្រសិនបើយើងចាប់អារម្មណ៍កំរិតនៃស្រ្តេសរបស់យើង។ នៅពេលដែលខ្ញុំស្ពាយបន្ទុកដ៏ធ្ងន់ដែលធ្វើឲ្យខ្ញុំអស់កំលាំងគ្រប់ពេល ធ្វើឲ្យខ្ញុំមានការតូញត្អែរស្ទើរតែគ្រប់ពេលវេល ហើយតែងតែមានការតូចចិត្ត និងគ្មានការអត់ធ្មត់ជាមួយមនុស្សជុំវិញខ្លួន នោះខ្ញុំបានឆ្លងហួសដែនកំណត់របស់ខ្ញុំហើយ។ ខ្ញុំពិតជាត្រូវការជំនួយ ហើយទោះបីជាជំនួយពីព្រះជាម្ចាស់ ឬពីអ្នកណាម្នាក់ដែលអាចជួយខ្ញុំបានក្តី។ ខ្ញុំត្រូវតែពឹងផ្អែកលើអ្នកដទៃ ប៉ុន្តែវាពិបាកនឹងទៅរួចណាស់បើខ្ញុំមិនទុកចិត្តអ្នកដទៃទេ។

តើយើងពិតជាត្រូវធ្វើអ្វីគ្រប់យ៉ាងដែលយើងធ្វើឬយ៉ាងណា? តើមានតែយើងម្នាក់ទេឬ ដែលអាចធ្វើអ្វីដែលយើងធ្វើបាន? ឬក៏យើងខ្លាចក្នុងការទុកចិត្តលើអ្នកដទៃ? តើយើងប្រហែលជាមានអត្តសញ្ញាណ (ភាពសាកសម និងតម្លៃ) ជា «ម្នាក់ដែលអាចធ្វើការគ្រប់យ៉ាងបានឬ»? ចូរឆ្លើយសំណួរទាំងនេះដោយភាពស្មោះត្រង់ចេញពីចិត្ត។

យើងពិតជាស្ទាត់ជំនាញក្នុងការលាក់បាំងខ្លួនឯងណាស់។ តើមានមនុស្សប៉ុន្មាននាក់ដែលពិតជាស្គាល់ខ្លួនឯង និងដឹងពីហេតុផលនៅពីក្រោយអ្វីដែលពួកគេធ្វើ? តើយើងពិតជាខ្លាចក្នុងការសួរខ្លួនឯងថាហេតុអ្វីយើងត្រូវធ្វើគ្រប់យ៉ាង ដោយសារតែយើងមិនពេញចិត្តនូវចម្លើយដែលយើងនឹងរកឃើញឬ?មានរឿងឈឺចាប់មួយដែលខ្ញុំធ្លាប់ជួប គឺនៅពេលដែលខ្ញុំមានអារម្មណ៍ថាខ្ញុំត្រូវធ្វើអ្វីៗគ្រប់យ៉ាង ដោយសារតែខ្ញុំជាមនុស្សមានអំណួត ដែលធ្លាប់បានគិតថាគ្មាននរណាម្នាក់អាចធ្វើអ្វីដែលខ្ញុំត្រូវធ្វើដូចជាខ្ញុំបានទេ។ អូ!

ពីអតីតកាលនៅក្នុងជីវិតរបស់ខ្ញុំមានឫសគល់នៃការបដិសេធ ហើយដោយសារតែរឿងនេះ ខ្ញុំស្ទាក់ស្ទើរក្នុងការសុំជំនួយ ព្រោះខ្ញុំបានគិតថាគេនឹងបដិសេធការស្នើសុំរបស់ខ្ញុំ។ វាមិនមែនជាការងាយស្រួលទេនៅពេលដែលយើងសុំ ជំនួយពីនរណាម្នាក់ហើយទទួលចម្លើយថា «ទេ» មកវិញ។ ខ្ញុំក៏ដូចជាមនុស្សផ្សេងទៀតដែរ ខ្ញុំធ្លាប់ភ័យក្លាចក្នុងការមើលឲ្យបានស៊ីជម្រៅហួសពីស្រទាប់ខាងលើនៃជីវិតរបស់ខ្ញុំ ដូច្នេះហើយបានជាខ្ញុំនៅតែបន្តធ្វើរហូតស្ទើរតែបរាជ័យទាំងស្រុង។ នៅពេលនោះហើយដែលខ្ញុំសុំជំនួយពីព្រះជាម្ចាស់។

បើអ្នកមានអារម្មណ៍ថាអ្នកនៅចុងបំផុតហើយ ចូរនៅឲ្យស្ងៀម និងត្រូវសុំជំនួយពីព្រះជាម្ចាស់។ នៅពេលដែលយើងសុំជំនួយពីព្រះអង្គ នោះទ្រង់នឹងប្រទានសេចក្តីពិតដ៏ធំមួយដែលយើងពិបាកទទួល។ សេចក្តីពិតនោះនឹងដោះយើងឲ្យរួច តែទាល់តែយើងទទួលយកជាមុន បើនិយាយឲ្យត្រង់ទៅវាតែងតែធ្វើឲ្យយើងឈឺចាប់។

វាមិនមែនជាការងាយស្រួលទេសម្រាប់ខ្ញុំ ដែលត្រូវទទួលស្គាល់ថាខ្ញុំធ្លាប់មានអំណួត ខ្ញុំជាមនុស្សដែលចេះគ្រប់គ្រងស្ថានការណ៍ ខ្ញុំក៏ធ្លាប់ជាមនុស្សដែលពឹងផ្អែកលើខ្លួនឯង ហើយខ្ញុំធ្លាប់មានឥរិយាបថថា «ខ្ញុំមិនត្រូវការអ្នកណាទាំងអស់» នេះសុទ្ធតែជាអ្វីដែលព្រះមិនសព្វព្រះទ័យ។ នៅពេលដែលព្រះជាម្ចាស់បើកសំដែងការនេះឲ្យខ្ញុំដឹង ខ្ញុំដូចជាមានអារម្មណ៍ថាព្រលឹងរបស់ខ្ញុំបានបើកចំហ និងផ្ទុះឡើង ដែលធ្វើឲ្យខ្ញុំគ្មានក្តីសុខទាល់តែសោះ ប៉ុន្តែសេចក្តីពិតបានដោះខ្ញុំឲ្យរួច។ ហើយវានឹងកើតឡើងដូចគ្នាចំពោះអ្នកណាដែលព្រមទទួល។

> ការទុកចិត្តលើព្រះជាម្ចាស់ គឺជាការចាប់ផ្តើមនៃការជាសះស្បើយគ្រប់យ៉ាង។

ឥឡូវនេះខ្ញុំមិនគ្រាន់តែមិនចង់ធ្វើការគ្រប់យ៉ាងតែម្នាក់ឯងទេ ប៉ុន្តែខ្ញុំពិតជាដឹងថាខ្ញុំមិនអាចធ្វើអ្វីៗទាំងអស់តែម្នាក់ឯងបានឡើយ!! តាមពិតទៅខ្ញុំក៏មិនអាចធ្វើបាន ហើយអ្នកក៏មិនអាចធ្វើបានគ្រប់យ៉ាងដែរ។ ការទុកចិត្តលើព្រះជាម្ចាស់ គឺជាការចាប់ផ្តើមនៃការជាសះស្បើយគ្រប់យ៉ាង។

យើងត្រូវតែទុកចិត្តផ្លូវរបស់ព្រះអង្គ ទោះបីជាយើងមើលទៅដូចជាពិបាកជាងមុនក៏ដោយ។ វាតែងតែពិបាកយល់ថាតើហេតុអ្វីបានជាការប្រោសឲ្យជាធ្វើឲ្យមានការឈឺចាប់ជាងជំងឺរបស់យើង។ ព្រលឹងរបស់ខ្ញុំធ្លាប់មានជំងឺ។ ខ្ញុំមិនធ្លាប់ទុកចិត្តលើអ្នកណាឡើយ។ ខ្ញុំបានរស់នៅក្នុងភាពភ័យខ្លាច។ វ៉ាលីស្ពាយរបស់ខ្ញុំពេញទៅដោយបន្ទុកដ៏ធ្ងន់ ហើយខ្ញុំបានស្ពាយវាជាបន្តបន្ទាប់។ តាមពិតទៅខ្ញុំពិតជាមានអំណរនៅពេលដែលខ្ញុំមានអតីតកាលដើម្បីប្រៀបធៀប ព្រោះវាបានជួយខ្ញុំឲ្យឃើញពីជីវិតដ៏អស្ចារ្យដែលខ្ញុំមាននៅពេលបច្ចុប្បន្ននេះ។ ពេលដែលខ្ញុំនឹកចាំពីសំពាធដែលខ្ញុំធ្លាប់មានពីមុនមក និងពីបន្ទុកដ៏ស្រាល និង សេរីភាពដែលខ្ញុំមានក្នុងពេលនេះ ខ្ញុំពិតជាមានការអស្ចារ្យនៅក្នុងចិត្តពីព្រះចេស្តា និងការល្អរបស់ព្រះជាម្ចាស់មែនទែន។

ខ្ញុំនិយាយពីផ្លូវដែលខ្ញុំធ្លាប់ដើរពីមុន ព្រោះខ្ញុំគិតថាមានមនុស្សជាច្រើនកំពុងជាប់នៅកន្លែងនោះនៅឡើយ។ ការអធិស្ឋានរបស់ខ្ញុំគឺថា នៅពេលដែលមនុស្សដឹងថាមាននរណាម្នាក់បានទទួលសេរីភាពដ៏ពិតប្រាកដ និងងផ្តល់ការលើកទឹកចិត្តដល់ព្រលឹងដែលមានបន្ទុកធ្ងន់ ហើយរឿងដូចគ្នានេះនឹងកើតឡើងក្នុងជីវិតរបស់ពួកគេបើពួកគេ «អនុញ្ញាតឲ្យវាកន្លងទៅ និងអនុញ្ញាតឲ្យព្រះជាម្ចាស់ធ្វើការ» នៅក្នុងជីវិតរបស់ពួកគេ។

ត្រូវយកព្រះជាម្ចាស់ជាបង្អែក និងពឹងផ្អែកលើព្រះអង្គ ឲ្យព្រះអង្គជួយ និងថែរក្សាអ្នក! ខ្ញុំពិតជារន្ធត់ក្នុងចិត្ត នៅពេលដែលខ្ញុំគិតពីមនុស្សដែលរស់នៅក្នុងលោកិយ៍នេះដែលគិតថាគេមិនត្រូវការព្រះជាម្ចាស់ទាល់តែសោះ។ បើខ្ញុំគ្មានព្រះជាម្ចាស់នៅក្នុងជីវិតរបស់ខ្ញុំគ្រប់ពេលទេ នោះខ្ញុំរស់នៅគ្មានន័យឡើយ។ ព្រះជាម្ចាស់បានបង្កើតយើងមកឲ្យយើងត្រូវការព្រះអង្គ ដូច្នោះហើយនៅពេលដែលយើងនៅឆ្ងាយពីព្រះអង្គ យើងនឹងមិនអាចធ្វើអ្វីគ្រប់យ៉ាងដោយប្រក្រតីបានឡើយ។ មានមនុស្សមួយចំនួនបានបោកប្រាស់ខ្លួនឯងដោយគិតថាពួកគេមានអ្វីៗគ្រប់យ៉ាងទាំងអស់ តែថ្ងៃដែលគេនឹងទទួលផលនឹងមកដល់។ ពួកគេនឹងដល់ទីបំផុតនៃជីវិតរបស់ពួកគេ ខ្ញុំសង្ឃឹមថាពួកគេនឹងបន្ទាបខ្លួនដើម្បីយាងព្រះជាម្ចាស់មកក្នុងជីវិតរបស់ពួកគេ។

ប្រសិនបើអ្នកមានការប៉ះពាល់ចិត្ត តាមរយៈសេចក្តីបង្រៀនអំពីការពឹងផ្អែកលើខ្លួនឯងនេះ ហើយអ្នកត្រូវការជំនួយសូមឲ្យអ្នករាល់គ្នាសុំជំនួយពីព្រះជាម្ចាស់! ព្រះអង្គគឺជាអ្នកជំនាញបំផុតក្នុងលោកនេះក្នុងការជួយមនុស្ស! ព្រះវិញ្ញាណរបស់ព្រះអង្គគង់នៅទីនេះជាមួយយើង ហើយព្រះអង្គមាននាមថាព្រះដ៏ជាជំនួយ(មើលក្នុងគម្ពីរយ៉ូហាន ១៤:២៦)។ ចូរស្រមៃថាៈអ្នកមានអ្នកជួយដ៏ល្អបំផុតដែលឈរនៅក្បែរអ្នកគ្រប់ពេលវេលា ចុះហេតុអ្វីមិនអនុញ្ញាតឲ្យព្រះអង្គធ្វើការខ្លះផង? អ្នកពិតជាមិនត្រូវ

ធ្វើការគ្រប់យ៉ាងឡើយ។ ការពិតព្រះយេស៊ូបានសម្រេចគ្រប់ការទាំងអស់រួចហើយ តាមរយៈការទុកចិត្ត ជំនឿ និងការជឿលើព្រះអង្គ អ្នកអាចដកដង្ហើមយ៉ាងស្រួល ហើយអនុញ្ញាតឲ្យបន្ទុករបស់អ្នកចេញឆ្ងាយពីអ្នកទៅ!

អ្នកអាចពឹងផ្អែកលើព្រះជាម្ចាស់ជាជាងការពឹងផ្អែកលើខ្លួនឯង។

# ជំពូក ៥

## ចូរទុកចិត្តព្រះជាម្ចាស់និងធ្វើការល្អ

(វគ្គ១)

*ចូរទុកចិត្តនឹងព្រះយេហូវ៉ា ហើយប្រព្រឹត្តការល្អចុះ យ៉ាងនោះអ្នកនឹងបាននៅក្នុងស្រុកហើយចំអែតខ្លួនដោយសេចក្តីពិត។*

ទំនុកដំកើង៣៧:៣

ព្រះគម្ពីរទំនុកតម្កើង ៣៧:៣ គឺជាព្រះបន្ទូលដែលមានសេចក្តីសន្យាថា បើយើងទុកចិត្តដល់ព្រះជាម្ចាស់ហើយធ្វើការល្អ នោះយើងនឹងទទួលការផ្គត់ផ្គង់ប៉ុន្តែត្រង់នេះមិនត្រឹមតែនិយាយអំពីការមានអាហារគ្រប់គ្រាន់ ដើម្បីធ្វើឲ្យយើងស្កប់ចិត្តប៉ុណ្ណោះទេ។ តែមានន័យថាយើងនឹងមានការអរសប្បាយ និងមានការស្កប់ចិត្តនៅក្នុងព្រលឹងរបស់យើង។ យើងប្រហែលជាចង់ឲ្យអ្វីមួយផ្លាស់ប្តូរ ប៉ុន្តែនៅក្នុងពេលដែលយើងកំពុងរង់ចាំនៅឡើយ យើងអាចមានព្រលឹងដែលស្កប់ស្កល់ក្នុងព្រះជាម្ចាស់។

ការទុកចិត្តលើព្រះជាម្ចាស់ជាប្រយោជន៍ដល់បុត្ររបស់ព្រះអង្គគ្រប់រូប។ ការនេះបានធ្វើឲ្យគាត់មានអំណរនៅក្នុងជិវិត ជាជាងគ្រាន់តែបានទទួលការសង្គ្រោះ។ ចូរចាំថាការទុកចិត្តលើព្រះជាម្ចាស់ជាជម្រើសរបស់យើង ហើយវាជាអភ័យឯកសិទ្ធិមួយដ៏វិសេស។ ប៉ុន្តែមានអ្វីផ្សេងទៀតដែលយើងត្រូវបន្ថែមលើការទុកចិត្ត ដើម្បីអាចឲ្យយើងទទួលប្រយោជន៍ពេញលេញពីការទុកចិត្តនេះ ហើយអ្វីដែលយើងត្រូវបន្ថែមនោះគឺ «ការធ្វើការល្អ»។

ជំពូកនេះប្រហែលអាចជាចំណុចដែលសំខាន់បំផុតសម្រាប់អ្នកនៅក្នុងសៀវភៅទាំងមូល។ គោលការណ៍នៅក្នុងព្រះគម្ពីរទំនុកតម្កើង ៣៧:៣ បានជួយខ្ញុំយ៉ាងច្រើននៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំជឿថាវាក៏សំខាន់សម្រាប់អ្នកដែរ។

ការទុកចិត្តលើព្រះជាម្ចាស់មានន័យថា យើងថ្វាយការខ្វល់ខ្វាយរបស់យើងទៅព្រះអង្គ ហើយមិនព្រួយអ្វីទាំងអស់ ឬក៏អន្ទះសារលើរឿងអ្វីមួយឡើយ ប៉ុន្តែមិនមានន័យថាយើងបោះបង់ចោលការទទួលខុសត្រូវរបស់យើងនោះទេ។ ជាញយដងមាន

សកម្មភាពដែលមានការជំរុញពីព្រះជាម្ចាស់ដែលយើងត្រូវធ្វើ ដើម្បីឲ្យយើងអាចទទួលបានអ្វីដែលយើងប្រាថ្នា។ អ្នកខ្លះគាត់មានគំនិតខុសឆ្គងថាការទុកចិត្ត ឬការរង់ចាំព្រះជាម្ចាស់ គឺជាការអសកម្ម ហើយមានន័យថាយើងមិនធ្វើអ្វីទាំងអស់នៅពេលដែលយើងរង់ចាំឲ្យព្រះអង្គធ្វើរឿងគ្រប់យ៉ាង ប៉ុន្តែវាមិនមែនជាការពិតឡើយ។ ឧទាហរណ៍ថា មានមនុស្សម្នាក់ទុកចិត្តថាព្រះជាម្ចាស់នឹងជួយគាត់ឲ្យមានការងារធ្វើ ប៉ុន្តែបើគាត់មិនបានយកចិត្តទុកដាក់រកការងារទេ វាប្រហែលជាមិនអាចទទួលបានផលល្អឡើយ។

លោក ប៉ុលបាននិយាយរឿងនេះយ៉ាងច្បាស់នៅក្នុងសំបុត្ររបស់លោកទៅកាន់ក្រុមជំនុំនៅអេភេសូរ។ លោកមានប្រសាសន៍ថាពួកគេត្រូវធ្វើរឿងគ្រប់យ៉ាងដើម្បីទប់ទល់នឹងការអាក្រក់ ហើយពួកគេឲ្យនៅតែឈរមាំមួននៅកន្លែងរបស់ពួកគេ(សូមមើលនៅក្នុងគម្ពីរអេភេសូរ៦:១៣)។ យើងបានឃើញពីគោលការណ៍នៃ «ការទុកចិត្តព្រះជាម្ចាស់និងការធ្វើការល្អ»នៅក្នុងគម្ពីរនេះ។ធ្វើអ្វីដែលអ្នកគួរធ្វើ ធ្វើអ្វីដែលអ្នកអាចធ្វើបាន ហើយទុកចិត្តព្រះជាម្ចាស់លើអ្វីដែលអ្នកមិនអាចធ្វើបាន ឬមិនគួរធ្វើវា។

ចំណុចដំបូងដែលយើងត្រូវតែធ្វើ គឺត្រូវទុកចិត្តលើព្រះជាម្ចាស់គ្រប់ផ្នែកទាំងអស់នៅក្នុងជីវិតរបស់យើង។ ចំណុចទី២ដែលយើងត្រូវធ្វើ គឺយើងត្រូវរួចរាល់ក្នុងការធ្វើរឿងគ្រប់យ៉ាងដែលព្រះជាម្ចាស់បង្ហាញប្រាប់យើងថាយើងត្រូវតែធ្វើ។ ខ្ញុំធ្លាប់បានទទួលការណែនាំអំពីការផ្លាស់ប្តូររបៀបនៃការអធិស្ឋាន នៅពេលដែលខ្ញុំមានតម្រូវការអ្វីមួយ។ ជំនួសដោយពាក្យនិយាយថា «ទូលបង្គំជឿលើព្រះអង្គក្នុងការធ្វើរឿងនេះសម្រាប់ខ្ញុំ» ឥឡូវនេះខ្ញុំនិយាយថា «ព្រះជាម្ចាស់អើយ ខ្ញុំទុកចិត្តព្រះអង្គក្នុងការជួយទូលបង្គំក្នុងស្ថានភាពនេះ ហើយបើមានអ្វីដែលទូលបង្គំត្រូវធ្វើ សូមបង្ហាញដល់ទូលបង្គំផងថាតើវាជាអ្វី»។ អ្នកអាចប្រាថ្នាក្នុងការផ្តោតទៅលើការធ្វើរឿងនេះ រហូតទាល់តែអ្នកបានធ្វើវារួចហើយ។ ខ្ញុំគិតថាវានឹងធ្វើឲ្យយើងដឹងថា ហេតុអ្វីយើងត្រូវស្តាប់ការណែនាំដែលព្រះជាម្ចាស់នឹងប្រទានដល់យើង។

នៅថ្ងៃទី ១ ខែមករា ឆ្នាំ ២០១៥ ខ្ញុំបានសរសេរនៅក្នុងកំណត់ត្រារបស់ខ្ញុំថា ខ្ញុំត្រូវការ ហើយពិតជាប្រាថ្នាចង់បានកំលាំងច្រើនជាងមុន។ បន្តិចក្រោយមកខ្ញុំមានគំនិតថា ខ្ញុំគួរតែចាប់ផ្តើមដើររៀងរាល់ថ្ងៃ។ ខ្ញុំធ្លាប់បានហ្វឹកហាត់ជាមួយគ្រូបង្វឹកបីថ្ងៃក្នុងមួយសប្តាហ៍ តែឥឡូវនេះខ្ញុំគិតថាខ្ញុំគួរតែដើរបន្ថែមទៀត។ ខ្ញុំពឹងផ្អែកលើព្រះជាម្ចាស់ជារៀងរាល់ថ្ងៃដើម្បីឲ្យព្រះអង្គប្រទានបំណងប្រាថ្នា និងសមត្ថភាពក្នុងការធ្វើនេះ។ អស់រយៈបីបួនខែ ខ្ញុំបានដើរ៨គីឡូម៉ែត្រក្នុងមួយថ្ងៃ ហើយធ្វើឲ្យខ្ញុំស្វាហាប់ជាងពេលណាៗទាំងអស់។ ខ្ញុំមានភាពអត់ធ្មត់ជាងមុន និងមានភាពក្លៀវក្លានៅក្នុង

ចិត្ត។ អ្វីដែលលើសពីនេះ ខ្ញុំក៏បានស្រកទំងន់ខ្លះដែរ ហើយទោះជាយ៉ាងណាក៏ដោយវាមិនមែនជាគោលដៅចំបងរបស់ខ្ញុំទេ តែខ្ញុំរំភើបចិត្តណាស់។ការធ្វើលំហាត់ប្រាណបន្ថែមក្លាយជាអ្វីដែលខ្លួនប្រាណរបស់ខ្ញុំត្រូវការ។

ខ្ញុំទុកចិត្តព្រះជាម្ចាស់ដែលប្រទានកំលាំង ហើយព្រះអង្គប្រទានកិច្ចការខ្លះទៀតឲ្យខ្ញុំធ្វើ ហើយព្រះអង្គក៏ប្រទានបំណងចិត្ត និងសមត្ថភាពក្នុងការធ្វើការទាំងអស់នេះដែរ។ បើអ្នកទុកចិត្តលើព្រះអង្គ ហើយពិតជារួចរាល់ក្នុងការធ្វើរឿងគ្រប់យ៉ាងដែលព្រះអង្គចង់ឲ្យយើងធ្វើមែន ខ្ញុំធានាថាអ្នកនឹងមានការអស្ចារ្យក្នុងសកម្មភាពដែលអ្នកបានធ្វើដើម្បីសម្រេចគោលដៅរបស់អ្នកមិនខាន។

> ខ្ញុំទុកចិត្តព្រះជាម្ចាស់ដែលប្រទានកំលាំង ហើយព្រះអង្គប្រទានកិច្ចការខ្លះទៀតឲ្យខ្ញុំធ្វើដែរ។

មានរឿងមួយទៀតដែលទើបតែកើតឡើងចំពោះខ្ញុំ គឺទាក់ទងនឹងភ្នែករបស់ខ្ញុំ។ ភ្នែករបស់ខ្ញុំប្រែជាស្ងួតមែនទែន មានពេលខ្លះវាមានការរលាក ហើយពេលខ្លះទៀតវាពិតជាមានការឈឺចាប់ខ្លាំងណាស់។ ខ្ញុំបានប្រើប្រាស់ថ្នាំបន្តក់ភ្នែកគ្រប់ប្រភេទដែលគ្រូពេទ្យបានណែនាំ ខ្ញុំបានដាក់ម៉ាស៊ីនបន្សើមនៅកន្លែងដែលខ្ញុំគេង ហើយទោះបីវាអាចជួយខ្ញុំបានខ្លះមែន ប៉ុន្តែខ្ញុំនៅតែមានការឈឺចាប់ដដែល។ ខ្ញុំពិតជាពិបាកខ្លាំងណាស់នៅពេលដែលខ្ញុំធ្វើដំណើរទៅកន្លែងដែលមានអាកាសធាតុស្ងួត គឺជាកន្លែងដែលខ្ញុំតែងតែមានចំណែកក្នុងការទទួលខុសត្រូវបម្រើក្នុងព័ន្ធកិច្ច។

ខ្ញុំបានអធិស្ឋានសម្រាប់ស្ថានភាពនេះ ដូចដែលខ្ញុំធ្លាប់មានបទពិសោធន៍ពីមុន នៅពេលនោះខ្ញុំមានអារម្មណ៍ថាព្រះជាម្ចាស់មានបន្ទូលមកខ្ញុំ ព្រះអង្គចង់ឲ្យខ្ញុំផឹកទឹកឲ្យបានច្រើនជាងពីមុន។ ខ្ញុំបានគិតថាពីមុនខ្ញុំក៏បានផឹកទឹកច្រើនដែរហើយ! មានមនុស្សមួយចំនួនបានប្រាប់ឲ្យខ្ញុំផឹកទឹកឲ្យបានច្រើនជាងមុន ប៉ុន្តែដោយសារខ្ញុំគិតថាខ្ញុំបានផឹកច្រើនរួចហើយ ធ្វើឲ្យខ្ញុំបដិសេធយោបល់ល្អរបស់ពួកគេ ដោយគិតថាវាគ្មានអ្វីទាក់ទងទៅនឹងបញ្ហារបស់ខ្ញុំទេ។ យើងត្រូវដឹងថាគំនិតដែលមានអំនួតរបស់យើងធ្វើឲ្យយើងមិនចាប់អារម្មណ៍ជាមួយយោបល់ល្អរបស់អ្នកដទៃ ដែលបានប្រាប់យើង។ ទោះជាយ៉ាងណាក្តីយើងគួរតែពិចារណាដំបូន្មានដែលយើងបានទទួលនៅចំពោះព្រះជាម្ចាស់ ហើយមើលថាតើវាស្របជាមួយវិញ្ញាណរបស់យើងដែរឬទេ។ ជារឿយៗព្រះជាម្ចាស់មានបន្ទូលមកកាន់យើងតាមរយៈមនុស្ស ហេតុនេះហើយបានជាយើងត្រូវតែស្តាប់ពួកគេដោយបន្ទាបខ្លួន។

> អរព្រះគុណព្រះជាម្ចាស់ ដែលព្រះអង្គមិនអស់ជំនឿលើយើង។

អរព្រះគុណព្រះជាម្ចាស់ ដែលព្រះអង្គមិនអស់ជំនឿលើយើងឡើយ ហើយទោះបីជាព្រះ

អង្គព្យាយាមប្រាប់ខ្ញុំតាមរយៈមនុស្សអំពីអ្វីខ្ញុំត្រូវធ្វើច្រើនយ៉ាងណាក៏ដោយ ក៏ឥឡូវនេះព្រះអង្គបានមានបន្ទូលមកកាន់ខ្ញុំដោយផ្ទាល់តាមរយៈព្រះគុណទ្រង់។ ខ្ញុំមានអារម្មណ៍ថាខ្ញុំគួរតែផឹកទឹកទ្វេដងលើសអ្វីដែលខ្ញុំធ្លាប់ផឹកពីមុន ជាពិសេសនៅពេលដែលខ្ញុំស្ថិតក្នុងតំបន់ដែលមានអាកាសធាតុស្ងួត។ ដើម្បីខ្ញុំអាចធ្វើដូច្នេះបាន ខ្ញុំត្រូវតែផឹកទឹកប្រាំបីដបធំក្នុងមួយថ្ងៃ! តាមពិតទៅខ្ញុំបានរៀបវានៅលើតុរបស់ខ្ញុំ ហើយចាប់ផ្តើមផឹកវា បន្ទាប់មកភ្នែករបស់ខ្ញុំក៏បានប្រសើរឡើង។ វាមិនបានដូចដើមទេ ប៉ុន្តែភ្នែកទាំងគូរបស់ខ្ញុំពិតជាបានប្រសើរឡើងច្រើនបើប្រៀបពីពេលមុន។ ការផឹកទឹកដ៏ច្រើននេះជាការប្រឈមមួយសម្រាប់ខ្ញុំ ហើយខ្ញុំមិនអាចធ្វើបានរាល់ថ្ងៃឡើយ ប៉ុន្តែជាបទពិសោធន៍ ខ្ញុំអាចធ្វើឲ្យវាក្លាយជាទម្លាប់ថ្មីរបស់ខ្ញុំ ហើយនៅពេលដែលខ្ញុំចេះតែបន្តធ្វើ អ្វីដែលជាការលំបាកកាលពីមុន បានក្លាយជាផ្នែកមួយនៃជីវិតរបស់ខ្ញុំនៅពេលនេះ។

មានពេលមួយទៀត ខ្ញុំគេងមិនលក់ ខ្ញុំបានប្រែចុះប្រែឡើងរហូតដល់ពេលព្រលឹម ខ្ញុំបានសួរព្រះជាម្ចាស់ថា តើមានរឿងអ្វី។ ព្រះអង្គបានឲ្យខ្ញុំចាប់អារម្មណ៍ភ្លាមៗពីហេតុការនៅក្នុងថ្ងៃនោះ គឺនៅពេលដែលខ្ញុំមានឥរិយាបថមិនសមរម្យនិងគ្មានចិត្តសប្បុរសចំពោះមនុស្សម្នាក់ នៅរំពេចនោះខ្ញុំបានដឹងថាខ្ញុំត្រូវសុំការអត់ទោសពីព្រះជាម្ចាស់ ហើយខ្ញុំក៏បានធ្វើនៅពេលនោះ។ ខ្ញុំក៏ត្រូវតែសុំទោសអ្នកដែលខ្ញុំបានមានឥរិយាបថមិនសមរម្យឲ្យបានលឿនបំផុតដែរ។ ក្រោយមកខ្ញុំបានចូលគេង!

គោលបំណងរបស់ខ្ញុំនៅក្នុងជីវិត គឺបន្តទុកចិត្តលើព្រះជាម្ចាស់ ហើយ «ធ្វើការល្អ»។ ធ្វើការល្អមានន័យថាយើងធ្វើការល្អដែលព្រះជាម្ចាស់នាំយើងឲ្យធ្វើ ហើយយើងស្តាប់បង្គាប់ព្រះអង្គយ៉ាងល្អនូវគ្រប់អ្វីដែលព្រះអង្គបានបើកសំដែងដល់យើង។ ខ្ញុំក៏មានគំនិតផ្សេងទៀតដែរអំពីការធ្វើការល្អដែលខ្ញុំចង់និយាយនៅក្នុងជំពូកបន្ទាប់ តែចូររៀនមេរៀនអំពីសារៈសំខាន់នៃការដើរតាមការដឹកនាំរបស់ព្រះវិញ្ញាណបរិសុទ្ធយ៉ាងទៀងទាត់។

## *ជំនួយរបស់យើង*

នៅពេលដែលព្រះយេស៊ូយាងត្រឡប់ទៅស្ថានសួគ៌វិញ ព្រះអង្គបានប្រទានព្រះដ៏ជាជំនួយ និងជាព្រះជួយកំសាន្តចិត្ត គឺព្រះវិញ្ញាណដ៏វិសុទ្ធ។ ព្រះអង្គបានមានព្រះបន្ទូលនៅក្នុងគម្ពីរ យ៉ូហាន ១៤:១៦ថាៈ

នោះខ្ញុំនឹងទូលសូមដល់ព្រះវរបិតា ហើយទ្រង់នឹងប្រទានព្រះដ៏ជាជំនួយ

១អង្គទៀត មកអ្នករាល់គ្នា ឲ្យបានគង់នៅជាមួយ នៅអស់កល្បរៀងទៅ។

ព្រះយេស៊ូបានប្រទានព្រះវិញ្ញាណរបស់ព្រះអង្គឲ្យគង់ជាមួយយើង និងនៅក្នុងយើងគ្រប់ពេលវេលា។ ព្រះវិញ្ញាណជាអ្នកបង្ហាញផ្លូវដល់យើង បើយោងតាមព្រះគម្ពីរ យ៉ូហាន ១៦:១៣។ ខ្ញុំស្រឡាញ់គំនិតដែលមានអ្នកជំនួយដ៏វិសុទ្ធដើរជាមួយខ្ញុំពេញមួយជីវិតរបស់ខ្ញុំ ហើយខ្ញុំសង្ឃឹមថាព្រះអង្គក៏ធ្វើឲ្យអ្នករីករាយផងដូចគ្នា។ យើងមិនមែនត្រូវដើរក្នុងជីវិតនេះតែម្នាក់ឯង ឬក៏ធ្វើអ្វីគ្រប់យ៉ាងដោយខ្លួនយើងផ្ទាល់ឡើយ ព្រោះព្រះដ៏ជាជំនួយគង់នៅទីនេះចាំជួយយើង។ ព្រះអង្គបង្ហាញដល់យើងនូវអ្វីដែលយើងត្រូវធ្វើ ហើយព្រះអង្គប្រទានកំលាំងឲ្យយើង និងអាចឲ្យយើងធ្វើវាបាន! ត្រូវប្រាកដថាអ្នកបានទុកចិត្តលើព្រះអង្គគ្រប់ពេលទាំងអស់ព្រោះការដែលដាច់ចេញពីព្រះអង្គយើងមិនអាចធ្វើអ្វីបានទាំងអស់ (សូមមើលនៅក្នុងគម្ពីរ យ៉ូហាន ១៥:៥)។ នៅពេលដែលយើងថ្វាយការទុកចិត្តរបស់យើងនៅក្នុងព្រះយេស៊ូ និងពឹងផ្អែកលើព្រះអង្គ នោះគ្រប់ទាំងភាពតានតឹងនឹងចេញពីយើងទៅ។

ប្រសិនបើព្រះជាម្ចាស់ចង់ឲ្យយើងធ្វើអ្វីមួយពិតប្រាកដ យើងត្រូវដឹងថាវាមិនកើតឡើងភ្លាមៗរហូតឡើយ។ ប៉ុន្តែនៅពេលដែលអ្នករង់ចាំព្រះអង្គយ៉ាងអត់ធ្មត់ និងរក្សាការទុកចិត្តលើព្រះអង្គ នោះព្រះអង្គនឹងសំដែងបំណងព្រះហឫទ័យរបស់ព្រះអង្គដល់យើង។ ធ្លាប់មានពេលមួយដែលខ្ញុំបានរង់ចាំព្រះជាម្ចាស់ឲ្យព្រះអង្គកែប្រែស្ថានភាពលំបាកមួយរបស់ខ្ញុំ ហើយខ្ញុំគិតថាអ្វីដែលខ្ញុំត្រូវធ្វើគឺនិយាយដោយវិជ្ជមានអំពីរឿងនេះ អរព្រះគុណព្រះជាម្ចាស់ដែលព្រះអង្គឲ្យខ្ញុំឆ្លងផុត។ ខ្ញុំចាំថាមានបីបួនដងនៅពេលដែលព្រះអង្គចង់ឲ្យយើងថ្វាយដង្វាយ មានពេលផ្សេងទៀតព្រះអង្គចង់ឲ្យយើងតមអត់ ហើយក៏មានពេលខ្លះទៀតព្រះអង្គបានណែនាំយើងឲ្យគ្រាន់តែថ្វាយបង្គំ និងរង់ចាំព្រះអង្គដែរ។ កុំឲ្យគិតទុកជាមុនអំពីរបៀបដែលព្រះជាម្ចាស់ធ្វើការ និងពីរបៀបដែលព្រះអង្គមានបន្ទូលមកកាន់យើងឡើយ ព្រោះផ្លូវរបស់ព្រះអង្គគ្មានទីបញ្ចប់ទេ!

នៅពេលដែលព្រះអង្គមានបន្ទូល (ដឹកនាំនិងបង្ហាញផ្លូវ) នោះយើងដឹងយ៉ាងច្បាស់នៅក្នុងចិត្តរបស់យើងអំពីផ្លូវដែលយើងត្រូវដើរ ឬយើងមានគំនិត ឬការគិតថាយើងមិនទៅណាឆ្ងាយឡើយ។ ព្រះជាម្ចាស់ដឹកនាំអ្នកណាដែលពិតជាចង់បានការដឹកនាំពីព្រះអង្គ! យើងពិតជាបានទទួលមេរៀនមួយតាមរយៈកំហុសរបស់យើង ដូច្នេះហើយបើយើងឈានជើងចេញដោយជំនឿ ហើយបានដឹងពីការភាន់ច្រឡំជាមួយនឹងអ្វីដែលអ្នកត្រូវធ្វើរួចហើយ នោះសូមកុំបោះបង់ចោល

ព្រះជាម្ចាស់ដឹកនាំអ្នកណាដែលពិតជាចង់បានការដឹកនាំពីព្រះអង្គ!

ឡើយ។ បើអារម្មណ៍នេះនៅតែមានទៀត ខ្ញុំមានបទពិសោធន៍ថា ខ្ញុំត្រូវតែដើរតាមទិសដៅផ្សេង ហើយខ្ញុំត្រូវតែរង់ចាំដើម្បីដឹងថាតើខ្ញុំត្រូវដើរតាមផ្លូវណាវិញ។

បើខ្ញុំធ្វើអ្វីដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំធ្វើ នោះខ្ញុំនឹងមានសន្តិភាព ពេញដោយព្រះគុណ និងមានអំណរផង។ តើអ្នកណាមានឥទ្ធិពលនៅក្នុងជីវិតរបស់អ្នក? បើជាព្រះជាម្ចាស់នោះ រឿងគ្រប់យ៉ាងនឹងទៅមុខយ៉ាងល្អ តែបើមិនមែនជាព្រះអង្គទេ រឿងគ្រប់យ៉ាងនឹងមិនទៅមុខយ៉ាងរលូនឡើយ។

## *អ្វីដែលព្រះអង្គមានបន្ទូលមកកាន់អ្នក ចូរធ្វើវាចុះ!*

ខ្ញុំតែងតែ និយាយរឿងក្មេងស្រីម្នាក់ មកជួបខ្ញុំនៅពេលចុងបញ្ចប់នៃកម្មវិធីសិក្ខាសាលា ហើយសុំនិយាយជាមួយខ្ញុំ។ នាងបានចំណាយពេលជាមួយស្ត្រីបីបួននាក់ផ្សេងទៀតនៅថ្ងៃចុងសប្តាហ៍ ពួកគេបានចែកចាយទីបន្ទាល់រៀងៗខ្លួនអំពីរបៀប និងពីអ្វីដែលព្រះជាម្ចាស់បានប្រាប់ឲ្យពួកគេធ្វើ។ ក្រោយពីបានធ្វើរឿងទាំងអស់នោះមក ពួកគេមានបទពិសោធន៍ថាពួកគេបានយកឈ្នះលើអ្វីៗទាំងអស់នោះ។ តែនាងបាននិយាយប្រាប់ខ្ញុំថា «ចយ័ អ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់ដឹកនាំឲ្យគេធ្វើ ព្រះអង្គក៏បង្ហាញទិសដៅដូចគ្នាឲ្យខ្ញុំដែរ។ ប៉ុន្តែអ្វីដែលជាភាពខុសគ្នារវាងខ្ញុំនិងពួកគេ គឺអ្វីដែលព្រះប្រាប់ឲ្យពួកគេធ្វើ ពួកគេតែងតែទទួលបានជ័យជំនះលើបញ្ហារបស់ពួកគេជានិច្ច តែខ្ញុំមិនដូចពួកគេទេ»! ការដើរតាមការណែនាំរបស់ព្រះវិញ្ញាណ គឺជាគន្លឹះក្នុងការធ្វើដំណើរទៅមុខក្នុងជីវិត និងយកឈ្នះការប្រឈមនៅក្នុងជីវិតរបស់យើង។

ខ្ញុំគ្មានអ្វីដែលច្បាស់ជាងនេះទៀតទេ! ឧទាហរណ៍ល្អដែលមាននៅក្នុងគម្ពីរ គឺនៅក្នុងគម្ពីរ យ៉ូហានជំពូក២។ ម្តាយរបស់ព្រះយេស៊ូចង់បានការអស្ចារ្យនៅពេលដែលអស់ស្រាទំពាំងបាយជូក្នុងពិធីមង្គលការនៅស្រុកកាណាន។ នៅក្នុងខ៥ នាងបាននិយាយទៅកាន់អ្នកបម្រើថា «អ្វីក៏ដោយដែលព្រះយេស៊ូឲ្យពួកគេធ្វើ ចូរធ្វើតាមព្រះអង្គចុះ»។ បើអ្នកមិនទាន់អនុញ្ញាតឲ្យព្រះជាម្ចាស់គ្រប់គ្រង់ជីវិតទាំងស្រុងរបស់អ្នកនៅឡើយ តើអ្នកមានបំណងឲ្យការនេះក្លាយជាគោលដៅថ្មីនៅក្នុងជីវិតរបស់អ្នកឬ? បើមានបំណងដូច្នេះមែន នោះអ្នកនឹងមិនស្តាយក្រោយឡើយ។

សូមសួរខ្លួនឯងយ៉ាងស្មោះត្រង់ថា «តើខ្ញុំពិតជាទុកចិត្តព្រះជាម្ចាស់ដែរឬទេ»? តើខ្ញុំពិតជាបានធ្វើអ្វីដែលព្រះអង្គចង់ឲ្យខ្ញុំធ្វើឬទេ ឬក៏ខ្ញុំលែងស្តាប់បង្គាប់ព្រះអង្គ ហើយនៅតែសង្ឃឹមថាខ្ញុំនឹងទទួលបានអ្វីដែលខ្ញុំចង់បានឬយ៉ាងណា»? តើអាចទៅរួចទេ បើអ្នកណាម្នាក់ទុកចិត្តព្រះជាម្ចាស់តែពួកគេមិនចង់ស្តាប់បង្គាប់ព្រះអង្គ? ខ្ញុំគិតថា

មិនអាចទៅរួចឡើយ! វាហាក់ដូចជាពិបាកស្តាប់បន្តិច តែខ្ញុំគិតថាវាជាការពិតដែលកើតឡើងមែន។ ការទុកចិត្តដល់ព្រះជាម្ចាស់គ្មានអ្វីក្រៅពីគំនិតខាងវិញ្ញាណនោះទេ រហូតដល់យើងអាចទុកចិត្តដល់ព្រះអង្គ ក្នុងការធ្វើអ្វី ដែលព្រះអង្គចង់ឲ្យយើងធ្វើ ហើយ ប្រហែលជាមិនធ្វើអ្វីទាំងអស់បើព្រះអង្គមិនឲ្យធ្វើ។

## *តើអ្វីដែលព្រះអង្គមិនឲ្យយើងធ្វើទាំងអស់?*

មានកិច្ចការដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើ ហើយក៏មានកិច្ចការខ្លះទៀតដែលព្រះអង្គចង់សុំឲ្យយើងឈប់ធ្វើដែរ។ មានពេលមួយដែលខ្ញុំចង់ឲ្យស្វាមីរបស់ខ្ញុំផ្លាស់ប្តូរ ប៉ុន្តែព្រះជាម្ចាស់បានឲ្យខ្ញុំឈប់ព្យាយាមផ្លាស់ប្តូរគាត់! ហើយមានពេលដែលខ្ញុំចង់ផ្លាស់ប្តូរខ្លួនឯង តែខ្ញុំមិនអាចធ្វើបានដោយការតស៊ូ និងប្រឹងប្រែងដោយខ្លួនឯងបានឡើយ ខ្ញុំត្រូវតែរង់ចាំព្រះជាម្ចាស់ដោយជឿថាព្រះអង្គនឹងបង្ហើយការល្អដែលព្រះអង្គបានចាប់ផ្តើមនៅក្នុងខ្ញុំ(សូមមើលក្នុងគម្ពីរភីលីព១:១៦)។ ខ្ញុំចង់រួមចំណែកយ៉ាងសកម្មក្នុងកិច្ចការ ដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំឈប់ធ្វើ ប៉ុន្តែវាមិនមែនជារឿងងាយស្រួលសម្រាប់ខ្ញុំឡើយ។

តើមានអ្វីមួយដែលព្រះជាម្ចាស់ឲ្យអ្នកឈប់ធ្វើដែរឬទេ? ព្រះអង្គពិតជាបានឲ្យខ្ញុំឈប់ធ្វើរឿងមួយចំនួនម្តងហើយម្តងទៀត។ ខ្ញុំនៅចាំពីពេលដែលខ្ញុំប្រកែកជាមួយស្វាមីខ្ញុំ ប៉ុន្តែព្រះជាម្ចាស់បានប្រាប់ឲ្យខ្ញុំឈប់និយាយ! ខ្ញុំចូលចិត្តបញ្ចេញយោបល់ ប៉ុន្តែជាញយដងព្រះវិញ្ញាណបានឲ្យភ្លើងក្រហមដល់ខ្ញុំ ទ្រង់ឲ្យសញ្ញាឲ្យខ្ញុំឈប់ ហើយរំឭកខ្ញុំឲ្យនៅស្ងៀមស្ងាត់។

ខ្ញុំមិនចង់ឲ្យអ្នកណាម្នាក់ធ្វើឲ្យខ្លួនឯងមានភាពតានតឹង ជាមួយនឹងការងារខាងសាច់ឈាម ដោយព្យាយាម «ធ្វើ» អ្វីដែលមិនអាចធ្វើបានដោយកំលាំង ឬសមត្ថភាពរបស់ខ្លួនផ្ទាល់នោះទេ។ ចូរចាំថាខ្ញុំកំពុងនិយាយពីការធ្វើអ្វីដែលព្រះជាម្ចាស់បង្ហាញឲ្យអ្នកធ្វើ ឬក៏អ្វីដែលព្រះអង្គបង្ហាញថាកុំឲ្យធ្វើ។

ខគម្ពីរមួយដែលខ្ញុំចូលចិត្ត នៅក្នុងគម្ពីរទំនុកតម្កើង៤៦:១០ ដែលបានចែងថា ចូរនៅស្ងៀមសិន ដើម្បីឲ្យដឹងថាព្រះអង្គគឺជាព្រះ។ សម្រាប់ខ្ញុំការដែលនៅស្ងៀម គឺពិបាកជាងការឲ្យខ្ញុំមានសកម្មភាព! ព្រះជាម្ចាស់ចង់ឲ្យយើងសកម្ម ប៉ុន្តែគឺសកម្មក្នុងការធ្វើតាមព្រះហឫទ័យព្រះអង្គ មិនមែនធ្វើតាមចិត្តរបស់យើងឡើយ។

ខណៈពេលដែលអ្នកទុកចិត្តព្រះជាម្ចាស់ដើម្បីឲ្យព្រះអង្គថែរក្សាស្ថានភាព ដែលអ្នកប្តូរផ្តាច់ថ្វាយទៅព្រះអង្គ អ្នកប្រហែលជាបានដឹងនៅក្នុងវិញ្ញាណរបស់អ្នកថាព្រះ

អង្គចង់ឲ្យអ្នកប្រើពេលអធិស្ឋានរបស់អ្នកដើម្បីអរព្រះគុណព្រះអង្គជាជាងការសុំ។ វាអាចកើតឡើងជាច្រើនដងនៅក្នុងជីវិត គឺមានពេលដែលអ្នកពិតជាមិនអាចធ្វើអ្វីបានទាំងអស់ក្រៅពីអធិស្ឋាននិងការរង់ចាំ។ ជាពិសេសវាកើតឡើងនៅពេលដែលអ្នកអធិស្ឋានទាក់ទងទៅនឹងអ្វីដែល អ្នកចង់បានសម្រាប់អ្នកដ៏ជាទីស្រឡាញ់របស់អ្នក។ ការអធិស្ឋានរបស់អ្នកបើកទ្វាឲ្យព្រះជាម្ចាស់ធ្វើការ ប៉ុន្តែមនុស្សដែលយើងអធិស្ឋានឲ្យនោះត្រូវតែអនុញ្ញាតឲ្យព្រះអង្គធ្វើការនៅក្នុងពួកគេដែរ។

មានពេលដែលខ្ញុំអធិស្ឋានសម្រាប់មនុស្សម្នាក់អស់រយៈពេលយ៉ាងយូរ បន្ទាប់មកខ្ញុំមានអារម្មណ៍ថាខ្ញុំមិនត្រូវទូលសូមព្រះអង្គឲ្យធ្វើអ្វីទៀតឡើយ ប៉ុន្តែត្រូវអរព្រះគុណព្រះអង្គវិញដែលព្រះអង្គកំពុងធ្វើការ!

## *អំណាចនៃការស្តាប់បង្គាប់*

ខ្ញុំបាននិយាយជាមួយមនុស្សជាញយដងយ៉ាងស្មោះត្រង់ ជាមួយអ្នកដែលមានការច្របូកច្របល់ថា ហេតុអ្វីបានជាជំនឿរបស់គេហាក់បីដូចមិនកើតផលអ្វីទាំងអស់។ ក្រោយពីបាននៅជាមួយពួកគេមួយរយៈមក ខ្ញុំអាចដឹងពីមូលហេតុទាំងនេះបាន។ ពួកគេត្អូញត្អែរ ពួកគេរិះគន់អ្នកដទៃ ហើយពួកគេមានគំនិតអវិជ្ជមាន! ឥរិយាបថបែបនេះមិនមែនជាការស្តាប់តាមការដឹកនាំរបស់ព្រះវិញ្ញាណឡើយ។ វាពិតជាសំខាន់ខ្លាំងណាស់សម្រាប់យើងម្នាក់ៗដែលមានឥរិយាបថស្តាប់បង្គាប់ព្រះជាម្ចាស់។

យើងមានអំណាចលើសត្រូវរបស់យើងគឺលើមាសាតាំង ប៉ុន្តែសិទ្ធិក្នុងការប្រើអំណាចនេះបានមកពីការស្តាប់បង្គាប់ព្រះជាម្ចាស់។ ព្រះយេស៊ូពិតជាពេញដោយព្រះចេស្តារ ប៉ុន្តែព្រះអង្គក៏ស្តាប់បង្គាប់ដែរ។ ព្រះគម្ពីរបានចែងថាព្រះអង្គស្តាប់បង្គាប់ខ្លាំងមែនទែន ទោះបីជារហូតដល់សុគត ហើយព្រះអង្គបានទទួលនាមលើអស់ទាំងនាម នៅពេលណាគេឮព្រះនាមព្រះអង្គ គ្រប់ជង្គង់នឹងលុតចុះ (មើលក្នុងគម្ពីរ ភីលីព ២:៨-១០)។

ឧបសគ្គដ៏ធំរបស់មនុស្សភាគច្រើន ដែលពួកគេបានមើលឃើញចំលើយនៃការអធិស្ឋានរបស់ពួកគេ ជាកំហឹង និងភាពល្វីងជូរចត់ គឺមកពីពួកគេមិនបានអនុញ្ញាតឲ្យការទាំងនេះវាចេញពីពួកគេឡើយ។ បើនិយាយអំពីគោលបំណងនៃការអត់ទោសដល់អស់អ្នកដែលបានធ្វើខុសចំពោះយើង និងដល់អ្នកដែលយើងគិតថាជា«សត្រូវ» គឺគ្មានអ្វីច្បាស់ជាងព្រះបន្ទូលរបស់ព្រះជាម្ចាស់ឡើយ។ ព្រះអង្គបានបញ្ជាក់យ៉ាងច្បាស់ថា នៅពេលដែលយើងអធិស្ឋាន យើងត្រូវតែអត់ទោសដល់មនុស្សទាំងអស់

ដែលបានធ្វើខុសចំពោះយើង(សូមមើលក្នុងគម្ពីរ ម៉ាកុស ១១:២៥)។ ដូច្នេះហើយបើនរណាម្នាក់គិតថាទោះបីយើងមិនចង់អត់ទោសក៏ដោយក៏ យើងនៅតែឃើញព្រះជាម្ចាស់ធ្វើការក្នុងជីវិតយើងដដែលនោះយើងគិតខុសហើយ។

ឥឡូវខ្ញុំចង់បញ្ជាក់ប្រាប់អ្នកថា ខ្ញុំមិនបាននិយាយថាយើងបានទទួលការសង្គ្រោះតាមរយៈការស្តាប់បង្គាប់របស់យើងឡើយ។ ប៉ុន្តែការស្តាប់បង្គាប់របស់ព្រះគ្រិស្តទេ ដែលផ្តល់ការសង្គ្រោះដល់យើងរាល់គ្នាវិញ។ យើងបានសង្គ្រោះដោយសារព្រះគុណរបស់ព្រះអង្គ មិនមែនមកពីការខិតខំប្រឹងប្រែងរបស់យើងផ្ទាល់ឡើយ!(សូមមើលនៅក្នុងគម្ពីរអេភេសូរ២:៨-៩)។ ខ្ញុំពិតជាជឿថាអ្នកណាដែលបានទទួលអំណោយនៃការសង្គ្រោះតាមរយៈព្រះគ្រិស្ត ពិតជាចង់លូតលាស់ក្នុងការស្តាប់បង្គាប់មិនខាន ព្រោះពួកគេស្រឡាញ់ព្រះអង្គ។

ឪពុកម្តាយរំពឹងថាកូនៗរបស់ពួកគេទុកចិត្ត និងស្តាប់បង្គាប់ពួកគេ ចុះតើហេតុអ្វីបានជាយើងគិតថាព្រះជាម្ចាស់រំពឹងតិចជាងនេះពីយើងរាល់គ្នា? ខ្ញុំចង់លើកទឹកចិត្តឲ្យអ្នកប្តូរគំនិត ហើយដើរក្នុងផ្លូវនៃការទុកចិត្តព្រះជាម្ចាស់គ្រប់ពេលទាំងអស់ ធ្វើអ្វីដែលព្រះអង្គឲ្យយើងធ្វើ និងមិនធ្វើអ្វីដែលព្រះអង្គមិនឲ្យយើងធ្វើ (សូមមើលកូឡូស៣:២)។ នេះមិនមែនជាអ្វីដែលយើងធ្វើយូរៗម្តង ដែលនាំជោគជ័យមកក្នុងជីវិតរបស់យើងនោះទេ ប៉ុន្តែជាអ្វីដែលយើងធ្វើដោយជាប់លាប់ និងដោយអស់ពីព្យាយាម។ ការស្តាប់បង្គាប់តិចតួចលាយជាមួយការមិនស្តាប់បង្គាប់ គឺស្មើនឹងជីវិតដែលមិនគាប់ព្រះទ័យព្រះជាម្ចាស់។

ការស្តាប់បង្គាប់តិចតួចលាយជាមួយការមិនស្តាប់បង្គាប់ គឺស្មើនឹងជីវិតដែលមិនគាប់ព្រះទ័យព្រះជាម្ចាស់។

តើអ្នកនឹងប្តូរផ្តាច់ដើម្បីឲ្យការស្តាប់បង្គាប់ព្រះជាម្ចាស់របស់អ្នកបានប្រសើរឡើយឬទេ? បើអ្នកមានការប្តូរផ្តាច់ ព្រះអង្គនឹងផ្តល់ព្រះគុណឲ្យអ្នកអាចធ្វើបាន។ តើមានចំណុចណាដែលអ្នកគិតថាត្រូវថ្វាយទៅព្រះជាម្ចាស់ឥឡូវនេះ គឺមិនត្រឹមតែការគិត និងការខ្វាយខ្វល់ប៉ុណ្ណោះទេ ប៉ុន្តែទាំងអាកប្បកិរិយាដែលមិនស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ផង? អ្នកអាចចាប់ផ្តើមសារជាថ្មី! ការបោះជំហានថ្មី! សូមឲ្យសំរែកនៃដួងចិត្តរបស់អ្នកនៅតែបន្តថា« បិតាអើយ សូមឲ្យបំណងព្រះហឫទ័យព្រះអង្គបានសម្រេច តែមិនមែនជាបំណងចិត្តរបស់កូនឡើយ»!

ឥឡូវនេះចូរយើងបន្តទៅវគ្គបន្ទាប់នៃការធ្វើការល្អ គឺជាអ្វីដែលពិតជាមានអំណរដែលធ្វើឲ្យខ្ញុំចង់តែចែកចាយរឿងនេះដល់អ្នកទាំងអស់គ្នា!

# ជំពូក ៦

## ទុកចិត្តព្រះជាម្ចាស់ ហើយធ្វើការល្អ

(វគ្គ២)

*យើងមិនត្រូវនឿយណាយនឹងប្រព្រឹត្តអំពើល្អឡើយ ដ្បិតប្រសិនបើយើងមិនបាក់ទឹកចិត្តទេនោះដល់ពេលកំណត់ យើងនឹងច្រូតបានផលជាមិនខាន។*
*កាឡាទី ៦:៩*

យើងបានរៀនថា ការដែលចុះចូលដល់ព្រះជាម្ចាស់ ហើយដើរតាមការដឹកនាំនៃព្រះវិញ្ញាណដ៏វិសុទ្ធ គឺជា"ទង្វើល្អ"។ ប៉ុន្តែនៅក្នុងជំពូកនេះ ខ្ញុំចង់ផ្តោតយ៉ាងខ្លាំងទៅលើការស្តាប់បង្គាប់ព្រះជាម្ចាស់ និងការធ្វើ កិច្ចការល្អៗដោយជួយដល់មនុស្សដែលត្រូវការជំនួយវិញ។

លោកសាវ័កប៉ូលបានប្រាប់ដល់អ្នកស្រុកកាឡាទីកុំឲ្យនឿយណាយនឹងធ្វើការល្អ (សូមមើលកាឡាទី៦:៩)។ លោកបាននែនាំពួកគេឲ្យធ្វើកិច្ចការល្អដល់មនុស្សទាំងអស់តាមពេលនិងតាមឱកាសដែលបានបើកឲ្យធ្វើ ហើយជាពិសេសនោះ ធ្វើចំពោះអស់អ្នកដែលរួមជំនឿ(កាឡាទី៦:១០)។យើងគួរតែជួយដល់មនុស្សផ្សេងទៀតដែលកំពុងត្រូវការជំនួយ នោះជាឱកាសដើម្បីធ្វើការល្អហើយ! វាគឺជា ឱកាសសំរាប់យើងរាល់គ្នាក្នុងការឲ្យពរដល់អ្នកដទៃដែរ ស្របពេលនោះយើងក៏បានពរខ្លួនឯងផងដែរ។ មនុស្សណាដែលផ្តោតលើការជួយអ្នកដទៃគឺជាមនុស្សដែលរីករាយ។

ខ្ញុំពិតជាជឿថា ការថ្វាយគឺបានចាក់ឫសក្នុងការទុកចិត្តព្រះជាម្ចាស់។ យើងធ្វើការដូច្នេះ ព្រោះ ព្រះជាម្ចាស់បានបង្គាប់ឲ្យយើងធ្វើ ហើយយើងក៏ជឿលើសេចក្តីសន្យារបស់ព្រះអង្គដែលនឹងបំពេញ សេចក្តីត្រូវការនៃហិរញ្ញវត្ថុរបស់យើងផងដែរ។ ការធ្វើទង្វើល្អៗ គឺជាការដ៏ប្រពៃចំពោះអស់អ្នកដែលព្យាយាមធ្វើវា។ ព្រះគម្ពីរ កិច្ចការ ២០:៣៥ ថ្លែងថា "...បើឲ្យ នោះនឹងបានសុភមង្គលច្រើនជាងទទួល"។ ការឲ្យខ្លួនឯង គឺបើកឲ្យមានអំណរចូលមកក្នុងការរស់នៅរបស់យើង ហើយធ្វើឲ្យយើងរីករាយខណៈយើងរង់ចាំការបំពេញសេចក្តីត្រូវការពីព្រះជាម្ចាស់។ ដូច្នេះ បើអ្នកឆ្ងល់ថា

"តើឲ្យខ្ញុំរីករាយខណៈខ្ញុំមានបញ្ហាដូចម្តេចកើត?" ចម្លើយគឺងាយទេ៖ ចូរបែរគំនិតអ្នកចេញពីខ្លួនអ្នកដោយផ្តោតទៅលើការធ្វើអ្វីៗដែលល្អសំរាប់អ្នកផ្សេងវិញ។ យើងមិនចាំបាច់ផ្តោតលើបញ្ហារបស់យើងរាល់ថ្ងៃ ដើម្បីឲ្យបានទទួលការឆ្លើយតបពីព្រះជាម្ចាស់ទេ។ ចូរទូលថ្វាយព្រះអង្គនូវអ្វីដែលអ្នកចង់បាន និងត្រូវការហើយទុកចិត្តលើព្រះអង្គថា ទ្រង់នឹងផ្តល់ឲ្យខណៈអ្នកផ្តោតលើកិច្ចការល្អៗចុះ។

ខគម្ពីរចំណង់ចំណូលចិត្តខ្ញុំមួយ គឺព្រះគម្ពីរកិច្ចការ ១០:៣៨ ថ្លែងថា ព្រះយេស៊ូត្រូវបានចាក់ប្រេងតាំង នឹងព្រះវិញ្ញាណបរិសុទ្ធហើយ "ព្រះអង្គបានយាងពីកន្លែងមួយទៅកន្លែងមួយទាំងប្រព្រឹត្តអំពើល្អ និង ប្រោសអស់អ្នកដែលត្រូវសង្កត់អារក្សសង្កិនឲ្យជា..."។ យើងត្រូវបានបង្រៀនឲ្យប្រព្រឹត្តតាមទង្វើរបស់ព្រះអង្គ ហើយដើរតាមគំរូរបស់ទ្រង់ នោះយើងគឺជាវិធីដ៏ល្អបំផុតមួយដែលយើងអាចធ្វើ។ ពិភពលោកនេះបានពេញដោយមនុស្សដែលមារសង្កត់សង្កិន ហើយយើងត្រូវបានចាក់ប្រេងតាំងដោយព្រះវិញ្ញាណបរិសុទ្ធ ដើម្បីជួយពួកគេដូចព្រះយេស៊ូបានធ្វើដូច្នោះដែរ។

គ្រប់ពេលដែលយើងធ្វើល្អ គឺយើងកំពុងសាបព្រោះគ្រាប់ពូជដែលផ្តល់ផលជាចំរូតដល់យើងវិញ។ ចូរកុំធ្វើឲ្យមានកំហុសដោយគិតថាអ្នកមានបញ្ហាខ្លួនឯងច្រើនពេក ដោយសារជួយមនុស្សដទៃ។ ការគិតបែបដូច្នោះ គឺវាធ្វើឲ្យអ្នកជាប់គាំងក្នុងបញ្ហាយ៉ាងពិត។

ចូរកុំធ្វើឲ្យមានកំហុសដោយគិតថាអ្នកមានបញ្ហាខ្លួនឯងច្រើនពេក ដោយសារជួយមនុស្សដទៃ។

ចុងសប្តាហ៍មួយ នៅពេលដែលខ្ញុំកំពុងបង្រៀនមេរៀននេះក្នុងសិក្ខាសាលារបស់ខ្ញុំ គឺការទុកចិត្តព្រះជាម្ចាស់ ហើយធ្វើការល្អ នេះ ចរន្តអគ្គិសនីបានដាច់នៅលើអាគារនៃវេទិការដែលនៅខាងក្នុង។ វាបានកើតឡើងប្រហែលមួយម៉ោងមុននឹងការចាប់ផ្តើមកម្មវិធី ដូច្នេះយើងត្រូវតែលុបចោល ហើយមើល មនុស្សរាប់ពាន់នាក់ដើរចេញ។ ចរន្តក៏បានមកវិញប្រហែលជា១០នាទីមុនការបង្រៀនត្រូវបញ្ចប់។ យើងត្រូវតែរង់ចាំ ហើយចាប់ផ្តើមសិក្ខាសាលានៅព្រឹកស្អែកវិញ។

ខ្ញុំត្រូវតែទុកចិត្តព្រះជាម្ចាស់ ខណៈខ្ញុំកំពុងព្យាយាមបង្រៀនក្នុងសិក្ខាសាលាអំពីការទុកចិត្តព្រះជាម្ចាស់នោះ! លើសពីអ្វីដែលយើងបានប្រឈមជាមួយនោះ អ្នកគ្រប់គ្រងអាគារនោះបានស្រវឹងនៅឯផ្ទាំងប៉ាណូខាងក្រៅទាំងមានសរសេរថា៖ "សិក្ខាសាលារបស់ចយស៍ ម៉េយ័រ ត្រូវបានលុបចោល"។ ពួកគេបានគិតថា ពួកគេកំពុងជួយ ប៉ុន្តែពួកគេបានភ្លេចនិយាយថា វាគ្រាន់តែលុបចោលតែយប់នោះ ប៉ុណ្ណោះ ហើយនឹងចាប់ផ្តើមវិញទៀតនៅព្រឹកបន្ទាប់នោះ។ ខ្ញុំបាននិមិត្តឃើញ នៅក្នុងអាគារដ៏ធំនោះ ខ្ញុំបង្រៀនចំពោះកៅអីទទេ។ ខ្ញុំបានទទួលអារម្មណ៍វិវក់នៅក្នុងព្រលឹងរបស់ខ្ញុំ ប៉ុន្តែខ្ញុំ

នៅតែនិយាយថា "ឱព្រះជាម្ចាស់អើយ ទូលបង្គំទុកចិត្តលើងព្រះអង្គហើយ" ហើយចុងក្រោយយើងធ្វើសិក្ខាសាលាយ៉ាងធំមួយវិញ។

អំឡុងពេលកំពុងតែបង្រៀននោះ ខ្ញុំបានប្រើគ្រឿងតាក់តែងដើម្បីជួយមនុស្សឲ្យយល់ពីសារៈសំខាន់ ស្នូលនៃការទុកចិត្តដល់ព្រះជាម្ចាស់ ហើយធ្វើការល្អ។ ក្រុមការងារសំណង់របស់យើងបានបង្កើតឲ្យមានថ្នាំពេទ្យពីរដប ដែលមានកំពស់០.៩ម៉ែត។ យើងបានដាក់វានៅលើតុ ហើយសរសេរលើវាថា "ទុកចិត្តព្រះជាម្ចាស់" ហើយម្ខាងទៀត "ធ្វើការល្អ"។ ដបនោះក៏បាននិយាយផងដែរថា ចាក់បំពេញវិញ គឺមិនមានកំណត់ឡើយ ហើយអ្នកជម្ងឺអាចយកវាញឹកញាប់តាមតែសេចក្ដីត្រូវការ។ វាជាការសំខាន់ណាស់ដែលប្រើឲ្យហួសកំរិតលើសម្ខាងទៀត។

ដូចខ្ញុំបានបង្រៀនអំពីរបៀបដោះស្រាយក្ដីទុក្ខវេទនា បញ្ហា និងសេចក្ដីវេទនាគ្រប់បែបគ្រប់យ៉ាង ខ្ញុំបាននិយាយដូច្នេះថា "នៅពេលដែលអាការៈកើតមាន ចូរទទួលទាន "ទុកចិត្តព្រះជាម្ចាស់" ឲ្យគ្រប់កំរិតភ្លាម រួចត្រូវយក"ការធ្វើកិច្ចការល្អ" តាមក្រោយឲ្យបានដល់កំរិតផងដែរ។ ឧទាហរណ៍បែបនេះ ហាក់ដូចជាជួយមនុស្សឲ្យយល់ខ្លាំងថា ការធ្វើកិច្ចការល្អសំរាប់អ្នកផ្សេងខណៈកំពុងទុកចិត្តព្រះ ជាម្ចាស់ដែលទ្រង់ល្អដល់យើង នោះគឺជាថ្នាំដែលយើងត្រូវការសំរាប់ព្រលឹងរបស់យើង។

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ ធ្វើការដូចជាថ្នាំសំរាប់ព្រលឹងរបស់យើង បើសិនជាយើងធ្វើតាម។ ថ្នាំមិនជួយអ្វីយើងទេ បើយើងមិនលេបវា ហើយព្រះបន្ទូលនៃព្រះជាម្ចាស់ក៏មិនជួយអ្វីយើងដែរ បើយើងគ្រាន់តែដឹង តែមិនធ្វើតាមនោះ។ ឧទាហរណ៍ បើសិនជាអ្នកប្រព្រឹត្តអំពើបាប អ្នកអាចធ្វើអ្វីដែលមនុស្សធម្មតាធ្វើដែរ ហើយតាំងមានអារម្មណ៍ថាខុស និងគួរស្ដីបន្ទោស ឬអ្នកអាចទទួល "ការអត់ទោសពីព្រះ ចំពោះខ្ញុំ" ទុកជាថ្នាំ ហើយវានឹងព្យាបាលព្រលឹងរបស់អ្នក។ បើមានអ្នកណាម្នាក់ធ្វើឲ្យអ្នកឈឺចាប់ ឬប្រមាថអ្នក ជំនួសដោយការខឹង និងគ្រាំចិត្តនោះ អ្នកអាចទទួលទាន "ខ្ញុំអត់ទោសដល់អ្នក" ទុកជាឱសថដ៏ល្អឲ្យគ្រប់គ្រាន់ ហើយរីករាយថ្ងៃនោះចុះ។ បើយើងមើលមកព្រះបន្ទូលនៃព្រះថាជាថ្នាំសំរាប់ព្រលឹងរបស់យើង នោះយើងរកឃើញជំនួយសំរាប់បញ្ហាទាំងអស់ដែលយើងប្រឈមនៅក្នុងជីវិតហើយ។

សូមឲ្យខ្ញុំនិយាយម្ដងទៀតថា ខ្ញុំជឿជាក់លើការទុកចិត្តលើព្រះជាម្ចាស់ ហើយធ្វើការល្អ នោះគឺជាឱសថសំរាប់ព្រលឹងរបស់យើង ហើយខ្ញុំពិតជាសូមណែនាំថា អ្នកអាចត្រូវការច្រើនប៉ុណ្ណាក៏បាន ហើយធ្វើច្រើនប៉ុណ្ណាតាមតែអ្នកត្រូវការ។ យ៉ាងណាមិញ ខ្ញុំគួរតែប្រាប់អ្នកថា វាមានផ្នែកដែលប៉ះពាល់! នោះគឺ សន្តិភាព អំណរ ស្មេរភាព ទំនុកចិត្ត និងរង្វាន់នៅឯស្ថានសួគ៌។

## *តើអ្វីដែលជាការល្អ?*

ការធ្វើទង្វើល្អអាចសាមញ្ញដូចជាការផ្តល់ភាពគោរព ឬការស្តាប់អ្នកណាម្នាក់ដែលកំពុងតែឈឺចាប់។ វាអាចមានទាំងការចំណាយពេលរបស់អ្នក ឬលុយកាក់ដើម្បីជួយបំពេញសេចក្តីត្រូវការរបស់គេផងដែរ។

ព្រះគម្ពីរពោរពេញទៅដោយព្រះបន្ទូលអំពីការជួយដល់អ្នកក្រីក្រ និងអ្នកដែលស្ថិតក្នុងសេចក្តីត្រូវការ ព្រមទាំងផ្តល់ការលើកទឹកចិត្តដល់អស់អ្នកដែលកំពុងឈឺចាប់ដែរ។ ជាក់ស្តែង ដូចជាថ្លែងថា យើងគួរតែ "ប្រឹងប្រែង" ធ្វើទង្វើល្អៗ ហើយប្រព្រឹត្តដោយសប្បុរសផង។ នោះហើយដែលមានន័យថា យើងរក មើលរបៀបក្នុងការជួយអ្នកដទៃ។

> ចូរប្រយ័ត្ន កុំឲ្យនរណាម្នាក់ប្រព្រឹត្តអំពើអាក្រក់តបនឹងអំពើអាក្រក់ឡើយ តែត្រូវសង្វាតធ្វើអំពើល្អជានិច្ចគឺធ្វើចំពោះបងប្អូនគ្នាឯង និងចំពោះមនុស្សទូទៅ។
>
> ១ថែស្សាឡូនិក ៥:១៥

តើអ្នកចង់ឲ្យខ្លួនឯងមានប្រយោជន៍នៅក្នុងពិភពលោកនេះ ហើយរស់នៅដោយបំណងស្កប់ស្កល់ឬទេ? លោកឆាលស៍ ឌីកយែន បានមានប្រសាសន៍ថា "គ្មាននរណាម្នាក់ដែលរស់នៅលើលោកនេះ ហើយ ដែលបានផ្តល់ពន្លឺដល់អ្នកដទៃ ជាមនុស្សអត់ប្រយោជន៍នោះទេ"។

ព្រះជាម្ចាស់ណែនាំយើងមិនគ្រាន់តែជួយដល់មនុស្សដែលកំពុងឈឺចាប់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងឲ្យពរដល់សត្រូវរបស់យើងថែមទៀតផង! ហេតុអ្វីបានជាយើងគួរធ្វើដូច្នោះ? ពីព្រោះយើងមាន ជ័យជំនះលើការអាក្រក់ដោយការប្រព្រឹត្តល្អ (ចូរមើលព្រះគម្ពីរ រ៉ូម១២:២១)។ យើងបានទទួលអាវុធដ៏ សម្ងាត់ដែលមានឥទ្ធិពលដូចជាការអស្ចារ្យនៅពេលបញ្ហាមកដល់ នៅពេលដែលមនុស្សធ្វើឲ្យយើងឈឺចាប់ ឬពេលណាយើងមានតម្រូវការផ្ទាល់ខ្លួន *ចូរធ្វើល្អចុះ*!

ការមួយដំបូងបង្អស់ដែលយើងគួរធ្វើ នៅពេលអ្នកណាម្នាក់ធ្វើឲ្យយើងឈឺចាប់ ឬប្រព្រឹត្តចំពោះយើងយ៉ាងអយុត្តិធម៌នោះ គឺអធិស្ឋានឲ្យពួកគេ។ តើយើងអធិស្ឋានយ៉ាងដូចម្តេច? ចូរទូលសុំព្រះជាម្ចាស់ ឲ្យព្រះអង្គអត់ទោសឲ្យពួកគេ ហើយបើកភ្នែករបស់ពួកគេ នោះគេមុខជាឃើញនូវអាកប្បកិរិយា របស់ពួកគេឆ្គាំឆ្គងយ៉ាងណាចំ

ពោះព្រះអង្គ។ បើគេមិនទាន់បានទទួលការសង្គ្រោះនៅឡើងទេ នោះចូរទូលសុំការសង្គ្រោះឲ្យពួកគេផង។ ដោយធ្វើទង្វើបែបដូច្នេះ អ្នកនឹងដោះខ្លួនពីភាពវេទនាដោយភាពក្រេវក្រោធនឹងពួកគេ ហើយទង្វើរបស់ពួកគេដែលបានធ្វើនឹងកន្លងផុតទៅយ៉ាងឆាប់រហ័ស។ អ្នកអាចនឹងមិនមានអារម្មណ៍អ្វីខុសប្លែកចំពោះពួកគេទេបន្តិចក្រោយមកនោះ ប៉ុន្តែវាពិបាកណាស់ដែលនៅតែ ខឹងនឹងអ្នកណាម្នាក់ដែលអ្នកអធិស្ឋានឲ្យគេជាប្រចាំនោះ។

យើងគួរតែឲ្យខ្លួនឯងធ្វើកិច្ចការល្អៗគ្រប់ពេលវេលា ប៉ុន្តែមានសេចក្ដីល្បួងម៉្យាងដែលបំប្រែខាងក្នុង ហើយបញ្ឈប់ការឈោងចាប់នៅពេលដែលយើងកំពុងឈឺចាប់។ នេះគឺជាកំហុសមួយដ៏ធំ។ ការប្រព្រឹត្តអំពើល្អ គឺតែងតែមានសារៈសំខាន់ ប៉ុន្តែវាពិសេសថែមទៀតនោះគឺ នៅពេលអ្នកមានបញ្ហាខ្លួនឯងវិញ។ ព្រះយេស៊ូបានប្រឈមសេចក្ដីស្លាប់ដ៏ឈឺចាប់មិនគួរឲ្យជឿឡើយ ហើយព្រះអង្គថែមទាំងនៅតែ ល្អចំពោះអ្នកដទៃដោយទូលសុំព្រះបិតារបស់ព្រះអង្គ ឲ្យអត់ទោសចំពោះអស់អ្នកដែលឆ្កាងព្រះអង្គ ហើយក៏បានលើកទឹកចិត្តឧក្រិដ្ឋជនដែលត្រូវបានគេឆ្កាងជាមួយព្រះអង្គដែលបានសុំព្រះអង្គឲ្យជួយថែមទៀតផង (ចូរមើលលូកា២៣:៣២-៤៣)។ ខ្ញុំមិនដឹងអំពីអ្នកទេ ប៉ុន្តែនៅពេលដែលខ្ញុំកំពុងមានបញ្ហាខ្លួនឯង ជាញឹកញយនោះ វាពិបាកក្នុងការទប់មិនឲ្យខ្លួនឯងអន់ចិត្តនឹងអ្នកដទៃឡើយ។ យ៉ាងណាក៏ដោយ ខ្ញុំបានរៀនជាច្រើនឆ្នាំហើយថា នេះគឺជាពេលដ៏ល្អបំផុតក្នុងការអនុវត្តភាពសប្បុរស និងប្រព្រឹត្តល្អ។ ពេលណាយើងគ្មានបញ្ហា ការប្រព្រឹត្តដោយសប្បុរសចំពោះអ្នកផ្សេង មិនតម្រូវឲ្យមានការអប់រំនោះទេ តែវាតម្រូវឲ្យការអប់រំដ៏ខ្លាំងក្លាមួយចំពោះការទុកចិត្តព្រះជាម្ចាស់ ហើយបន្តធ្វើតាមបំណង ព្រះហឫទ័យរបស់ព្រះអង្គខណៈយើងកំពុងតែឈឺចាប់វិញ។

ខ្ញុំពេញចិត្តនឹងព្រះគម្ពីរទំនុកតម្កើង៣៧ ហើយខ្ញុំក៏ឧស្សាហ៍អានដែរ។ ខ១-៥ ផ្ដល់ប្រាជ្ញាដល់យើង៖ កុំកើតទុក្ខ ឬកុំអន្ទះអន្ទែង ហើយកុំខ្វល់ខ្វាយអំពីអស់អ្នកដែលប្រព្រឹត្តទុច្ចរិតឡើយ ពីព្រោះព្រះជាម្ចាស់ នឹងចាត់ការជាមួយពួកគេក្នុងពេលរបស់ព្រះអង្គ។ គឺនៅពេលអ្នករង់ចាំ ហើយទុកចិត្តព្រះជាម្ចាស់ ទាំង ប្រព្រឹត្តអំពើល្អ។ ចូរស្វែងរកសុភមង្គលក្នុងព្រះអម្ចាស់ នោះព្រះអង្គនឹងប្រទាននូវអ្វីៗដែលចិត្តអ្នកប៉ងប្រាថ្នា។ ចូរផ្ញើជីវិតរបស់អ្នកទៅព្រះអង្គ នោះព្រះអង្គនឹងសម្រេចឲ្យមិនខាន។

នេះមិនមែនគ្រាន់តែជាក្រុមមួយនៃព្រះបន្ទូលដែលយើងអាចអាន ដើម្បីធ្វើឲ្យអារម្មណ៍យើងល្អប៉ុណ្ណោះទេ។ ខគម្ពីរទាំងនោះផ្ដល់ដំបូន្មានដល់យើងឲ្យកាន់តាម។ នៅពេលដែលយើងកាន់តាម នោះមិនគ្រាន់តែចុងបញ្ចប់ សេចក្ដីត្រូវការរបស់យើង

នឹងបានបំពេញប៉ុណ្ណោះទេ ប៉ុន្តែយើងថែមទាំងអាច ក្លាយទៅជាគំរូដល់អស់អ្នកដែល មិនស្គាល់ព្រះជាម្ចាស់ថែមទៀតផង។

លោកិយ៍ស្គាល់យើងគឺដោយសារការប្រព្រឹត្តអំពើល្អៗដែលលោកិយ៍ស្គាល់ថា យើងជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់ (ចូរមើល ១ពេត្រុស ២:១២)។

គឺដោយសារការប្រព្រឹត្តអំពើល្អៗ ដែលលោកិយ៍ស្គាល់ថា យើង ជាកម្មសិទ្ធិរបស់ព្រះជាម្ចាស់។

## *បញ្ញត្តិធំបំផុត*

ខណៈរាល់បញ្ញត្តទាំងអស់ដែលមកពីព្រះជាម្ចាស់ជាការអស្ចារ្យនិងសំខាន់ ព្រះយេស៊ូ ក៏បានមានព្រះបន្ទូលថា បញ្ញត្តបំផុត ឬសំខាន់បំផុតជាងគេទាំងអស់នោះគឺ យើងត្រូវដើរក្នុងសេចក្តីស្រឡាញ់ គឺយើងត្រូវស្រឡាញ់ព្រះជាម្ចាស់ និងស្រឡាញ់មនុស្សឲ្យដូចយើងស្រឡាញ់ខ្លួនឯង (ចូរមើល ម៉ាថាយ ២២:៣៦-៣៩)។ ព្រះអង្គក៏បានមានបន្ទូលដែរថា វាដោយសារសេចក្តីស្រឡាញ់នេះហើយ ដែលលោកិយ៍នឹង ដឹងថាយើងជាសិស្សរបស់ព្រះអង្គ៖

> *ខ្ញុំអោយបទបញ្ញាថ្មីដល់អ្នករាល់គ្នា គឺត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ អ្នករាល់គ្នាត្រូវស្រឡាញ់គ្នាទៅវិញទៅមក ដូចខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ បើអ្នកស្រឡាញ់គ្នាទៅវិញទៅមក មនុស្សទាំងអស់មុខជាដឹងថា អ្នករាល់គ្នាពិតជាសិស្សរបស់ខ្ញុំមែន [ព្រោះអ្នករាល់គ្នានៅតែ បន្តបង្ហាញសេចក្តីស្រឡាញ់ក្នុងចំណោះអ្នករាល់គ្នា]»។*
>
> *យ៉ូហាន ១៣:៣៤-៣៥*

យើងមិនអាចជជែកគ្នាអំពីសេចក្តីស្រឡាញ់ដោយមិន និយាយអំពីការប្រព្រឹត្តអំពើល្អៗនោះទេ ពីព្រោះនោះជារបៀបដែលយើងបានឃើញស្រាប់ហើយ។ សេចក្តីស្រឡាញ់មិនគ្រាន់តែជាទ្រឹស្តី ឬជាសេចក្តីបង្រៀនណាមួយដែលធ្វើឲ្យការបង្រៀននោះមានចលនាប៉ុណ្ណោះទេ តែគឺប្រាកដហើយសំខាន់មែន។ សេចក្តីស្រឡាញ់មើលឃើញ និងមានអារម្មណ៍ប្រាកដ ហើយវាមានអំណាចអស្ចារ្យ ដែលផ្លាស់ប្តូរជីវិតថែមទៀតផង។

សេចក្តីស្រឡាញ់ស្វែងរកផ្លូវយល់ស្រប វាមិនមែនរកការខ្វែងគំនិតគ្នានោះទេ។

លោកិយ៍មានមន្ទិលនឹងសេចក្តីបន្ទាល់ដ៏សាមញ្ញរបស់យើង ដោយសារតែមានការបាក់បែកក្នុងចំណោមយើងទាំងអស់នោះ។ បើក្រុមជំនុំអាចរួបរួមបាន នោះបន្ទាល់

របស់យើងនឹងមិនអាចបដិសេធបានឡើយ! សេចក្តីស្រឡាញ់ស្វែងរកផ្លូវយល់ស្រប គ្នា មិនមែនស្វែងរកការខ្វែងគំនិតគ្នានោះទេ។

គ្រួសារដែលមានការព្រមព្រៀងគ្នា នោះគឺជាអំណាច! បងដេវ និងខ្ញុំ បានយល់តាំងពីដំបូងថា ព័ន្ធកិច្ចរបស់យើងនឹងមិនបានជោគជ័យ បើមានការទាស់គ្នានៅក្នុងចិត្តរបស់យើង។ យើងបានធ្វើ ការយ៉ាងប្រឹងប្រែងបំផុតដើម្បីដកវាចេញពីជីវិតរបស់យើង និងបានឃើញបទពិសោធន៍ថា មានអំណាច ដែលនាំមកនូវសន្តិភាព និងការរួបរួម។

កុំរួមចំណែកក្នុងការខ្វែងគំនិតនៅក្នុងគ្រួសារ ក្នុងផ្ទះ នៅតំបន់អ្នករស់នៅ និងនៅព្រះវិហារ ឬក៏នៅកន្លែងធ្វើការរបស់អ្នកឡើយ។ អ្នកដែលគេចចេញពីការទាស់ទែងគ្នាហើយមិនមើលពីទោសពៃ នោះជាអ្នកគួរឲ្យគោរព(ចូរមើលសុភាសិត៩:១១)។ នៅពេលយើងគោរពព្រះជាម្ចាស់ ដោយដើរក្នុងផ្លូវរបស់ព្រះអង្គ នោះព្រះអង្គនឹងលើកមុខយើងឡើងជាចំហនៅក្នុងការរស់នៅរបស់យើងវិញដែរ។

> សេចក្តីស្រឡាញ់មិនមែនជាអារម្មណ៍យើងមានទេប៉ុន្តែជាជម្រើសដែលយើងធ្វើ ថាតើយើង នឹងប្រព្រឹត្តចំពោះមនុស្សដោយរបៀបណា។

ការដើរក្នុងសេចក្តីស្រឡាញ់នឹងតម្រូវយើងធ្វើនូវជម្រើសរៀងរាល់ថ្ងៃដែលវានឹងជួយយើងឲ្យរស់ នៅលើសពីផ្លូវអារម្មណ៍របស់យើងទៅទៀត។ យើងមិនអាចធ្វើអ្វីៗគ្រប់យ៉ាងតាម"អារម្មណ៍" យើងចង់ធ្វើ និងស្តាប់បង្គាប់បញ្ញត្តិនេះក្នុងពេលតែមួយបានទេ។យើងនឹងមិនតែងតែមាន"អារម្មណ៍" ចង់ចំណាយពេលធ្វើអ្វីសប្បុរសចំពោះអ្នកផ្សេងឡើយ ប៉ុន្តែពេលណាមួយដែលខ្ញុំធ្វើ គឺខ្ញុំកំពុងដើរនៅក្នុងសេចក្តីស្រឡាញ់ហើយ។ សេចក្តីស្រឡាញ់មិនមែនជាអារម្មណ៍ដែលយើងមានទេ ប៉ុន្តែគឺជាជម្រើស ដែលយើងធ្វើ ថាតើយើងនឹងប្រព្រឹត្តចំពោះមនុស្សដោយរបៀបណា។ ព្រះបន្ទូលមួយដែលជួយខ្ញុំឲ្យបន្តដើរក្នុងសេចក្តីក្តីស្រឡាញ់គឺ ម៉ាថាយ ៧:១២៖

> *ដូច្នេះ បើអ្នករាល់គ្នាចង់អោយអ្នកដទៃប្រព្រឹត្តចំពោះខ្លួនបែបណា ត្រូវប្រព្រឹត្តចំពោះគេបែបនោះដែរ។ គម្ពីរវិន័យ និងគម្ពីរព្យាការីមានចែងទុក [សរុប] មកដូច្នេះឯង។*

ការនេះងាយយល់ទេគឺថាបើយើងចង់ឲ្យគេប្រព្រឹត្តចំពោះយើងបែបណា យើងត្រូ ប្រព្រឹត្តបែប នោះដាក់គេជាមុនសិន នោះកិរិយាមាយាទរបស់យើងនឹងផ្លាស់ប្រែ។ វាជាការអប់រំដ៏សាមញ្ញមួយ និងក៏ ជាការមួយដែលយើងអាចធ្វើវាជាប្រចាំចំពោះការ

រស់នៅរបស់យើងផងដែរ។ នៅពេលស្ថានភាពមួយកើតឡើងដែល ពិបាកប្រព្រឹត្តល្អចំពោះអ្នកណាម្នាក់នោះ ចូរសួរខ្លួនឯងថា "តើខ្ញុំគួរចង់ឲ្យអ្នកនេះធ្វើអ្វីសំរាប់ខ្ញុំ បើខ្ញុំក៏ជាមនុស្សដែលត្រូវការសេចក្តីមេត្តាដែរនោះ?"

ជាញឹកញាប់ រៀងរាល់ថ្ងៃរបស់យើងបានប្រទះនឹងរឿងក្តៅក្រហាយបន្តិចបន្តួចដែរ។ យើងអាច នឹងត្រូវរង់ចាំកន្លែងដាក់លាក់ណាមួយសំរាប់ចតរថយន្តនៅឯផ្សារទំនើប ជាទីប្រជុំជន ហើយខណៈនោះ មានគេម្នាក់បានចូលចតយ៉ាងលឿនមុនយើងអាចចូលបាន។ យើងមានអារម្មណ៍ក្តៅក្រហាយមួយរំពេច ហើយប្រហែលពេលខ្លះបានបញ្ចេញភាពក្រេវក្រោធថា គេនឹងជាមនុស្សអសីលធម៌ក៏មាន។ យើងអាចស្រែក ឬស៊ីភ្លេ ឬក៏អាចធ្វើអ្វីដែលអាក្រក់ជាងនេះ ប៉ុន្តែទង្វើទាំងនេះពុំអាចជួយឲ្យយើងមានអារម្មណ៍ធូរស្រាលទេ ផ្ទុយទៅវិញវានាំមកនូវការបង្កើនកំដៅទៅវិញ។ ព្រះជាម្ចាស់នឹងប្រទានពរដល់អ្នកតាម របៀបផ្សេងៗបើសិនជាអ្នកទុកចិត្តព្រះអង្គ ហើយបន្តប្រព្រឹត្តអំពើល្អ!

ចូរចាប់ផ្តើមមើលភាពក្តៅក្រហាយ និងហេតុការណ៍ដែលមិនបានព្រៀងទុកទាំងនេះទុកដូចជា ឱកាសដើម្បីបង្ហាញសេចក្តីស្រឡាញ់ជំនួស ការដែលយើងអនុញ្ញាតពួកវាធ្វើឲ្យអ្នកខឹងវិញ។

យើងបានទទួលនិយមន័យនៃអាកប្បកិរិយាប្រកបដោយសេចក្តីស្រឡាញ់ នៅក្នុងព្រះគម្ពីរ១កូរិនថូស១៣:៤-៨។ សូមចំណាយពេលមើលចំណុចទាំងនេះ ហើយសួរខ្លួនអ្នកបើសិនជាអ្នកត្រូវការភាពលូតលាស់ក្នុងចំនុចទាំងនេះ៖

- សេចក្តីស្រឡាញ់ទ្រាំទ្រយូរអង្វែង ហើយថែមទាំងចេះអត់ធ្មត់ និងសប្បុរស
- សេចក្តីស្រឡាញ់ មិនដែលច្រណែន ក៏មែនពុះកញ្ជ្រោលជាមួយនឹងសេចក្តីឈ្នានីសដែរ។
- សេចក្តីស្រឡាញ់ មិនអំនួត ឬអួតបំប៉ោង ហើយក៏មិនវាយឫកខ្ពស់ដែរ។
- សេចក្តីស្រឡាញ់មិនប្រកាន់ខ្លួន (ក្រអឺតក្រទម និងបំប៉ោងដោយសេចក្តីអំនួត )។
- សេចក្តីស្រឡាញ់មិនព្រហើន (មិនឆ្មើងឆ្មៃ) ហើយមិនប្រព្រឹត្តបែបមិនសមគួរ
- សេចក្តីស្រឡាញ់ធ្វើតាមចិត្តរបស់ខ្លួន ព្រោះនោះគឺជាការរកប្រយោជន៍ផ្ទាល់ខ្លួន។
- សេចក្តីស្រឡាញ់ មានចិត្តធ្ងន់ មិនទាស់ទែង ហើយមិនថ្នាំងថ្នាក់ចិត្ត។
- សេចក្តីស្រឡាញ់ មិនគុំគួននឹងអ្នកដែលបានប្រព្រឹត្តអាក្រក់ ហើយមិនរាប់កំហុសអ្នកដទៃ។

- សេចក្តីស្រឡាញ់ មិនរីករាយនឹងភាពអយុត្តិធម៌ ប៉ុន្តែអរសប្បាយនឹងការទទួលបាននូវសេចក្តី យុត្តិធម៌ និងសេចក្តីពិតវិញ។
- សេចក្តីស្រឡាញ់ ទ្រាំទ្រទាំងអស់ ព្រមទាំងអ្វីដែលមកដល់ផងដែរ។
- សេចក្តីស្រឡាញ់ គឺតែងតែជឿជាក់លើភាពប្រសើរបំផុតនៃបុគ្គលម្នាក់ៗ។
- សេចក្តីស្រឡាញ់ មិនឈប់ មិនចុះចាញ់ វាតែងតែពេញដោយសេចក្តីសង្ឃឹមជានិច្ច ហើយទ្រាំទ្រគ្រប់យ៉ាងទាំងអស់ដោយមិនចុះខ្សោយឡើយ។
- សេចក្តីស្រឡាញ់ មិនដែលសាបសូនសោះឡើយ។

## *ការជួយអ្នកខ្វះខាត*

ព្រះគម្ពីរមានការផ្តោតខ្លាំងនិយាយអំពីការជួយដល់ជនក្រីក្រ ហើយក៏មានព្រះបន្ទូលសន្យាដ៏ប្រពៃ ខ្លះសំរាប់អស់អ្នកដែលជួយអ្នកទាំងនោះផងដែរ។ នេះជាព្រះបន្ទូលសន្យាមួយក្នុងចំណោមសេចក្តីសន្យាជាច្រើននោះ៖

> *អ្នកដែលចែកទានដល់ជនទុគ៌ត ទុកដូចជាអោយ**ព្រះអម្ចាស់**ខ្ចី ព្រះអង្គនឹងប្រទានរង្វាន់ដល់អ្នកនោះវិញ។*
>
> *សុភាសិត ១៩:១៧*

លោកសាវ័កយ៉ាកុបបានថ្លែងថា "រីឯសាសនាដ៏បរិសុទ្ធ ឥតខ្ចោះនៅចំពោះព្រះភក្ត្រព្រះបិតាជាម្ចាស់វិញ គឺស្ថិតនៅលើការទៅសួរសុខទុក្ខក្មេងកំព្រា និងស្ត្រីមេម៉ាយដែលមានទុក្ខលំបាក..."(យ៉ាកុប១:២៧)។ សាសនាពិតប្រាកដ តែងតែសំដែងចេញដោយការប្រព្រឹត្តមកខាងក្រៅ ពីព្រោះ គ្រិស្តបរិស័ទពិតមិនគ្រាន់តែមានការប៉ះពាល់ក្នុងចិត្តប៉ុណ្ណោះទេ គឺមានទាំងការប្រព្រឹត្តរបស់អ្នកនោះផងដែរ។ ព្រះជាម្ចាស់ ជាអ្នកប្រទានឲ្យ ហើយអស់អ្នកដែលមានទំនាក់ទំនងជាមួយព្រះអង្គ នឹងចងចែកចាយផងដែរ។ ព្រះវិញ្ញាណដ៏វិសុទ្ធ គឺជាព្រះដែលជួយ ហើយអស់អ្នកណាដែលពេញ ដោយព្រះវិញ្ញាណដ៏វិសុទ្ធ ក៏ជាអ្នកដែលជួយដែរ។

វាអាចជាការហ្វឹកហាត់ដែលប្រកបដោយផាសុកភាពដោយសួរខ្លួនយើងថា "តើខ្ញុំធ្វើអ្វីដើម្បីជួយអ្នកណាម្នាក់?" តើអ្នកអាចគិតដល់បុគ្គលចុងក្រោយបំផុតដែលអ្នកបានជួយបានឬទេ? មែនហើយ ជាធម្មតាយើងជួយគ្រួសាររបស់យើងរាល់ថ្ងៃ ឬយើង ឲ្យកាដូក្នុងរដូវណូអែល ក៏ប៉ុន្តែខ្ញុំកំ

> សេចក្តីរីករាយនិងជីវិតដ៏មានន័យមិនរកឃើញនៅក្នុងអ្វីដែលអ្នកទទួលបានទេ ប៉ុន្តែ ឃើញក្នុងអ្វីដែលអ្នកឲ្យវិញ។

ពុងនិយាយ អំពីទង្វើដែលលើសពីនោះ។ ខ្ញុំកំពុងនិយាយអំពីការរស់នៅដែលឲ្យ។ សេចក្តីរីករាយ និងជីវិតដ៏មានន័យមិនរកឃើញនៅក្នុងអ្វីដែលអ្នកទទួលបានទេ ប៉ុន្តែគឺវាឃើញក្នុងអ្វីដែលអ្នកឲ្យវិញ។ មានមនុស្សដែលស្ថិតក្នុងភាពត្រូវការប៉ុន្មាននាក់ដែលយើងដឹង ហើយយើងមិនអើពើថាជាបុគ្គល ដែលយើងគួរជួយគេនោះ? ពេលយើងចាប់ផ្តើមសួរសំណួរដ៏ពិបាកនេះ យើងអាចរកឃើញចម្លើយ របស់យើងទាំងខកចិត្ត។ យ៉ាងណាក៏ដោយ ពេលណាខ្ញុំខកចិត្តនឹងខ្លួនឯង ខ្ញុំតែងតែបានភាព "តាំងចិត្តជាថ្មី" ហើយចាប់ផ្តើមធ្វើកិច្ចការដែលល្អ។

ខ្ញុំចង់លើកទឹកចិត្តអ្នក ឲ្យជួយមនុស្សដែលត្រូវការជំនួយ ចេញពីបំណងពិត។ ចូរមើលពួកគេ ហើយស្វែងយល់ពីរបៀបជួយពួកគេ។ វាងាយទេ ក្នុងការដោះសារ ហើយមិនធ្វើអ្វីទាំងអស់ ប៉ុន្តែនោះមិនមែនជាទង្វើប្រក្រដីទេចំពោះគ្រិស្តបរិស័ទ។ ទាំងនេះគឺជា ការដោះសារខ្លះដែលខ្ញុំបាន ធ្វើកាលពីមុន ឬខ្ញុំបានធ្លាប់ឮពីមនុស្សខ្លះនិយាយ៖

- ខ្ញុំរវល់ខ្លាំងណាស់
- បញ្ហារបស់ពួកគេ គឺជាកំហុសរបស់ពួកគេ
- ខ្ញុំក៏មានបញ្ហាខ្លួនឯងដែរ
- ខ្ញុំមិនចង់ពាក់ព័ន្ធរឿងរបស់គេទេ
- ខ្ញុំមិនដឹងជាជួយដូចម្តេចទេ

ជួសឲ្យការខំរកហេតុផលថា ហេតុអ្វីយើងមិនអាចជួយបាននោះ ហេតុអ្វីបានជាយើងមិនទម្លុះ ទម្លាយរកវិធីណាដែលយើងអាចជួយបានវិញ? យើងអាចនឹងប្រទះអ្នកណាម្នាក់ដែលកំពុងត្រូវការជំនួយ តែអ្នកមិនអាចជួយតែម្នាក់ឯងបាន ប៉ុន្តែអ្នកអាចជាអ្នកដែលស្គាល់ក្រុមមនុស្សដែលធ្វើការរួមគ្នា ដើម្បីជួយបុគ្គលនោះបាន។ ការតូចបំផុតដែលយើងម្នាក់ៗអាចធ្វើបាននោះ គឺអធិស្ឋានឲ្យ ហើយសុំព្រះ បង្ហាញយើងនូវអ្វីដែលព្រះអង្គចង់ឲ្យយើងធ្វើដើម្បីជួយដល់មនុស្ស ដែលយើងស្គាល់ថាជាអ្នកកំពុងឈឺចាប់ និងត្រូវការជំនួយមែន។ មិនត្រូវភ្លេចថា ពេលណាមួយដែលអ្នកធ្វើកិច្ចការសប្បុរសសំរាប់អ្នកណាម្នាក់នោះ អ្នកក៏ជួយដល់ខ្លួនអ្នកដែរ។

ថ្មីៗនេះ មានស្ត្រីបីនាក់បានចូលរួមសិក្ខាសាលារបស់យើង ហើយបានឮខ្ញុំនិយាយអំពីសេចក្តីត្រូវការ ដែលជួយជីកអណ្តូងក្នុងប្រទេសមួយភាគបីនៃពិភពលោក ជាកន្លែងដែលមនុស្សមិនអាចមានទឹកទេ បើគេមិនធ្វើដំណើរទៅរកវារាប់ម៉ោងនោះ ហើយពេលខ្លះត្រូវចំណាយពេលដល់មួយថ្ងៃថែម ទៀតផងដើម្បីឲ្យបានទឹក រួចនៅ

ពេលគេទៅដល់ប្រភពទឹកនោះហើយក្តី ពួកគេជាធម្មតាទទួលបានទឹក មិនស្អាត និង ជាទឹកដែលឆ្លងរោគប៉ុណ្ណោះ។ យើងមានកិត្តិយសណាស់ដែលផ្តល់អណ្តូងចំនួនប្រាំពីររយ ហើយបានសង្កេតឃើញថាមានការផ្លាស់ប្តូរភូមិនោះទាំងមូលទៀតផង។

ស្ត្រីទាំងបីនាក់នោះចង់ធ្វើកិច្ចការខ្លះៗ ដូច្នេះពួកនាងបានគៀងគរម្ហូបមួយគ្រួសារ ហើយបានដាក់លក់រោងមួយយ៉ាងធំ។ នៅសិក្ខាសាលាបន្ទាប់ ពួកនាងបានចូលរួមទៀត ហើយបានថ្វាយដង្វាយជាងពីរពាន់ដុល្លា ដើម្បីជួយការជីកអណ្តូងមួយ និងសាងសង់វិហារមួយជាប់អណ្តូងនោះដែរ។ របៀបដូច្នោះហើយ ដែលយើងអាចផ្តល់ទាំងទឹកធម្មជាតិ ទាំងទឹកនៃព្រះបន្ទូល គឺទាំងពីរនេះហើយផ្តល់នូវ ជីវិត!

*ចូរធ្វើអំណោយដល់អ្នកដទៃ នោះព្រះជាម្ចាស់នឹងប្រទានអំណោយដល់អ្នករាល់គ្នាដែរ ទ្រង់នឹងប្រទានមកយ៉ាងបរិបូណ៌ហូរហៀរ។ ព្រះជាម្ចាស់នឹងវាល់អោយអ្នក តាមរង្វាល់ដែលអ្នកវាល់អោយអ្នកដទៃ។*

*លូកា ៦:៣៨*

ខ្ញុំមិនជឿថា បំណងរបស់យើង ដែលជំរុញការធ្វើទាននឹងគួរតែបានអ្វីខ្លះមកវិញនោះទេ។ យើងគួរឲ្យ(ធ្វើទាន) ពីព្រោះបំណងរបស់យើងគឺជួយអ្នកដទៃ ប៉ុន្តែព្រះបន្ទូលនៃព្រះជាម្ចាស់សន្យាថា ពេលណាយើងធ្វើដូច្នោះ នោះវានឹង ត្រឡប់មកយើងវិញពហុគុណក្នុងផ្លូវផ្សេងៗវិញ។

លោកយ៉ូប បានធ្វើសេចក្តីថ្លែងយ៉ាងពេញទី។ លោកបាននិយាយថា បើលោកមិនបានប្រើដៃ លោកជួយអ្នកក្រីក្រទេ ដៃនោះនឹងដាច់ចេញពីស្មា (ចូរមើលគម្ពីរ យ៉ូប ៣១:១៦-២២)។

ព្រះបន្ទូលដែលបានប៉ះពាល់ក្នុងជីវិតរបស់ខ្ញុំផ្ទាល់យ៉ាងខ្លាំងនោះ គឺខ្ញុំកំពុងនិយាយពេលនេះ ហើយខ្ញុំទូលសូម ឲ្យអ្នកនឹងចំណាយពេលអានពីរបីដង មុននឹងអ្នកបោះជំហាន។ អ្នកហើយនិងខ្ញុំ មានអំណាចបន្ទូរការឈឺចាប់ ហើយយើងមិនត្រូវបណ្តោយឲ្យឱកាសនោះរំលងពីយើងឡើយ។ លោក ចន ប៊ុននីយ៉ាន បានថ្លែងថា "អ្នកមិនមែនរស់នៅរហូតមកទល់ពេលនេះដោយមិនបានធ្វើអ្វីខ្លះសំរាប់អ្នក ដែលមិនអាចសងគុណអ្នកវិញទេ"។

## ចូរធ្វើឲ្យព្រះជាម្ចាស់ទ្រង់ញញឹម

វាអស្ចារ្យណាស់ ដែលគិតថាយើងអាចធ្វើឲ្យព្រះជាម្ចាស់ទ្រង់ញញឹមបាន ប៉ុន្តែព្រះ

បន្ទូលថ្លែងថា យើងអាច។ ស្តេចដាវីឌ បានទូលនូវសេចក្តីអធិស្ឋានបែបនេះថាៈ "សូមញញឹមដាក់ទូលបង្គំ ជាអ្នកបំរើរបស់ព្រះអង្គ ហើយសូមបង្រៀនទូលបង្គំនូវច្បាប់របស់ព្រះអង្គ" (ទំនុកតម្កើង ១១៩:១៣៥)។

ពេលយើងធ្វើតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ព្រះអង្គញញឹមមិនខាន! ខ្ញុំគិតថា ព្រះអង្គ ទ្រង់កាន់តែញញឹមធំជាងនេះទៅទៀត ពេលដែលការស្តាប់បង្គាប់របស់យើងនោះ មានពាក់ព័ន្ធនឹងការជួយដល់អ្នកដទៃ ពីព្រោះពេលយើងធ្វើដូច្នោះ គឺយើងកំពុងប្រព្រឹត្តតាមព្រះអង្គ។ ខ្ញុំបានឮកូនប្រុសរបស់ខ្ញុំ និយាយអំពីកូនៗថា "កូនៗឃើញខ្ញុំធ្វើការនោះ ហើយពួកគេក៏ចម្លងតាមខ្ញុំដែរ"។ នៅពេលកូនខ្ញុំប្រាប់ខ្ញុំ គឺគាត់តែងតែញញឹមផងដែរ។

ពេលណាអ្នកដាក់ស្នាមញញឹមចំពោះមុខអ្នកផ្សេង នោះខ្ញុំគិតថា ព្រះជាម្ចាស់ក៏ញញឹមដែរ!

# ជំពូក ៧

# នៅគ្រប់ពេលទាំងអស់

*....ជនទាំងឡាយអើយ ចូរទុកចិត្តនឹងទ្រង់ជានិច្ច ចូរអ្នករាល់គ្នាប្លុងចិត្តនៅចំពោះទ្រង់ ព្រះជាទីពឹងជ្រកសំរាប់យើងខ្ញុំ (ប៉មនិងបន្ទាយដ៏ខ្ពស់)។ បង្អង់(ឈប់សំកាំង និង ស្ងប់ស្ងាត់គិតអំពីការនោះ)*

*ទំនុកតម្កើង៦២៖៨(KHOV)*

មានចិតសិបមួយខនៅក្នុងព្រះគម្ពីរទំនុកតម្កើង និង បីខនៅក្នុងគម្ពីរហាបាគុ កន្លែងដែលមានពាក្យ «បង្អង់» បង្ហាញឡើង។ ចាប់តាំងពីខខាងលើអំពីការទុកចិត្តព្រះជាម្ចាស់ក្នុងគ្រប់ពេលទាំងអស់ គឺមួយនៅក្នុងចំណោមខគម្ពីរទាំងចិតសិបបួនខនៅក្នុងព្រះគម្ពីរ ដែលប្រើពាក្យនេះ ខ្ញុំគិតថាយើងគួរតែឈប់ អោយបានយូរគ្រប់គ្រាន់ដើម្បីដឹងថាព្រះជាម្ចាស់មានបន្ទូលថា: *ខនេះគឺមានតំលៃខ្លាំងណាស់ ហើយអ្នកគួរតែផ្អាកនិងគិតអំពីវា។*

នៅក្នុងប៉ុន្មានឆ្នាំដំបូងនៃការដើរក្នុងព្រះរបស់ខ្ញុំ ខ្ញុំបានផ្អែកលើការទុកចិត្តទ្រង់ដើម្បីជួយខ្ញុំក្នុងពេលនានាដែលខ្ញុំមានបញ្ហាហើយខ្ញុំមានអារម្មណ៍ថា ខ្ញុំមិនអាចដោះស្រាយវាបាន។ ប៉ុន្តែបន្ទាប់ពីរយៈពេលពីរបីឆ្នាំនោះមក ខ្ញុំចាប់ផ្តើមដឹងថា ខ្ញុំមិនមានសមត្ថភាពនឹងធ្វើការអស់ទាំងនោះដោយមិនមានទ្រង់នោះទេ ដូច្នេះឥឡូវនេះខ្ញុំផ្តោតលើការសិក្សាការទុកចិត្តទ្រង់ក្នុងគ្រប់ពេលទាំងអស់។ វិធីដែលខ្ញុំធ្វើនេះគឺដោយការរស់នៅជាមួយនឹងឥរិយាបថដែលព្រះជាម្ចាស់ជាអ្នកជំនួយរបស់ខ្ញុំ។ រយៈពេលប៉ុន្មានថ្ងៃនេះ វាមិនបានកន្លងទៅដោយខ្ញុំមិនបាននិយាយថា «ខ្ញុំទុកចិត្តទ្រង់ក្នុងគ្រប់ការណ៍ទាំងអស់» ពីរ ឬ បីដងក្នុងមួយថ្ងៃនោះទេ។ ការប្រកាសទំនុកចិត្តរបស់អ្នកលើព្រះជាម្ចាស់គឺជាទំរង់មួយនៃការអធិស្ឋាន។ ខ្ញុំទុកចិត្តព្រះជាម្ចាស់សំរាប់កិច្ចការដ៏ពិសេស ដែលខ្ញុំយល់ថាជាការនាំមកក្នុងជីវិតរបស់ខ្ញុំនិងមនុស្សដទៃទៀត ប៉ុន្តែខ្ញុំក៏ទុកចិត្តទ្រង់ផងដែរសំរាប់ «គ្រប់ការទាំងអស់» ដែលខ្ញុំមិនទាន់បានយល់នៅឡើយ។

វាជាភាពល្ងង់ខ្លៅដែលរង់ចាំអោយភាពអាសន្ននឹងបញ្ហាធ្ងន់ធ្ងរមកដល់ខ្លួនរបស់

យើង មុនពេលដែលយើងសម្រេចចិត្តទុកចិត្តព្រះជាម្ចាស់។ យើងអាចរស់ក្នុងអាកប្បកិរិយានៃសេចក្ដីទុកចិត្ត ហើយពេលដែលយើងធ្វើ យើងដើរដោយសេចក្ដីជំនឿ។ ទាំងនេះមិនធានានោះទេថា យើងនឹងមិនមានបញ្ហានៅក្នុងជីវិត ប៉ុន្តែវាបង្ហាញថា យើងពឹងផ្អែក លើព្រះជាម្ចាស់ដើម្បីជួយយើងអោយឆ្លងកាត់ការលំបាកទាំងឡាយរបស់យើង ទោះបីជាទ្រង់មិនបានជ្រើសយកការនាំយើងចេញពីទុក្ខលំបាកទាំងនោះក៏ដោយ។

ពេលដែលព្រះយេស៊ូនៅក្នុងសួនកេតសេម៉ានី ទ្រង់បានដឹងយ៉ាងច្បាស់ពីការលំបាក ភាពឈឺចាប់ ហើយនឹងការល្បួងដែលទ្រង់នឹងសិស្សរបស់ទ្រង់ប្រឈមមុខ។ ព្រះអង្គបានប្រាប់ពួកសិស្សរបស់ទ្រង់ថា «ចូរអធិស្ឋានទៅ ដើម្បីកុំអោយត្រូវសេចក្ដីល្បួងឡើយ!» (លូកា២២៖៤០)(KHOV) ប៉ុន្តែពួកគេចូលចិត្តដេក។ ខគម្ពីរនេះថ្លែងថាពួកគេបានគេងលក់ពីសេចក្ដីទុក្ខព្រួយ(លូកា៤៥៖២២)។ ប្រហែលជាពួកគេអស់កំលាំងដោយសារការព្រួយបារម្ភនិងការភ័យខ្លាច ឬប្រហែលការគេងជាវិធីរបស់ពួកគេក្នុងការគេចវេសពីបញ្ហា។ ប៉ុន្តែព្រះយេស៊ូបានចំណាយពេលរបស់ព្រះអង្គអធិស្ឋានយ៉ាងក្លៀវក្លា។ ទ្រង់បានទុកចិត្តព្រះបិតារបស់ទ្រង់ជាមុនដើម្បីដកយកការឈឺចាប់ ឬប្រទានកំលាំងអោយព្រះអង្គដើម្បីឆ្លងកាត់វាទៅបាន។

ព្រះយេស៊ូបានចាកចេញពីជំរើសជាមួយព្រះបិតា។ ជាជាងការសូមសម្រាប់បំណងប្រាថ្នារបស់ទ្រង់ ទ្រង់បានថ្លែងពីអ្វីដែលព្រះអង្គចង់បាន ប៉ុន្តែព្រះអង្គបានអធិស្ឋានយ៉ាងពេញលេញនូវពាក្យថា«សូមកុំអោយជាបំណងប្រាថ្នារបស់ទូលបង្គំឡើយ ប៉ុន្តែ (ជានិច្ចកាល) សូមអោយជាព្រះហឫទ័យរបស់ទ្រង់វិញ» (លូកា២២៖៤២)(KHOV) បន្ទាប់ពីព្រះអង្គធ្វើដូចនេះ ទេវតាបានបញ្ជូនពីស្ថានសួគ៌មកដើម្បីបន្ថែមកំលាំងខាងឯវិញ្ញាណដល់ទ្រង់(លូកា២២៖៤៣)។

ព្រះបិតានៃស្ថានសួគ៌របស់យើង មិនត្រឹមតែជាអ្នកប្រោសលោះ របស់យើង ប៉ុណ្ណោះទេ គឺទ្រង់ថែមទាំងជាអ្នកចម្រើនកំលាំងដល់យើង! ប្រសិនបើទ្រង់មិនប្រទានសេចក្ដីប្រោសលោះភ្លាមៗដល់អ្នកទេ ទ្រង់នឹងពង្រឹងអ្នកប្រសិនបើអ្នកជ្រើសរើសការអត់ធ្មត់ហើយបន្តជឿទុកចិត្តព្រះសំរាប់អ្វីដែលត្រឹមត្រូវ ក្នុងពេលដ៏ត្រឹមត្រូវ។

ប្រសិនបើមានកន្លែងនៅក្នុងជីវិតរបស់យើង ដែលយើងដឹងថាជាចំណុចខ្សោយសំរាប់យើង វាគួរនឹងជាប្រាជ្ញាដើម្បីទុកចិត្តព្រះដើម្បីជួយយើងគេចចេញពីការល្បួងនៅក្នុងផ្នែកទាំងនោះ ជាជាងការរង់ចាំរហូតដល់យើងទៅដល់ចំណុចកណ្ដាលនៃបញ្ហាទាំងនោះ។

ចំណុចខ្សោយរបស់ខ្ញុំសម្រាប់ពេលប៉ុន្មានឆ្នាំនេះ វាធ្លាប់ជាការនិយាយច្រើនពេក

របស់ខ្ញុំ វីជាការនិយាយរឿងដែលមិនគួរនិយាយចេញមកដោយមិនបានគិត។ ជាការពិតណាស់ នេះជាហេតុបង្កបញ្ហាដែលមានជាញឹកញាប់។ ខ្ញុំតែងអធិស្ឋាននៅពេលព្រឹកមុនពេលខ្ញុំចាប់ផ្តើមនិយាយជាមួយមនុស្សដទៃ ថាព្រះជាម្ចាស់នឹងជួយខ្ញុំ អោយជាអ្នកស្តាប់ដ៏ល្អ និងប្រើប្រាស់ប្រាជ្ញាក្នុងរាល់អ្វីដែលខ្ញុំនិយាយ។

ភាពវ៉យឆ្លាតមួយដែលយើងអាចធ្វើបាន គឺដឹងពីភាពខ្សោយរបស់យើង ហើយពឹងផ្អែកលើព្រះជាម្ចាស់ជួយផ្តល់ភាពខ្លាំងដល់យើងដើម្បីមិនអោយធ្លាក់ទៅក្នុងសេចក្តីល្បួងទាំងនោះ។

ដោយការធ្វើរបៀបនេះ ខ្ញុំមិនរង់ចាំរហូតដល់ ខ្ញុំបានបណ្តាលអោយមានបញ្ហាហើយ ត្រូវដោះស្រាយជាមួយបញ្ហានោះទេ។ខ្ញុំអធិស្ឋានថាសូមព្រះអង្គរក្សាទូលបង្គំចេញពីការនាំទៅអោយសេចក្តីល្បួងនៅពេលដែលវាមកដល់។ ភាពវ័យឆ្លាតមួយដែលយើងអាចធ្វើបាន គឺដឹងពីភាពខ្សោយរបស់យើង ហើយពឹងផ្អែកលើព្រះជាម្ចាស់ជួយផ្តល់ភាពខ្លាំងដល់យើងដើម្បីមិនអោយធ្លាក់ទៅក្នុងសេចក្តីល្បួងទាំងនោះ។ ពេត្រុសគាត់នឹងមានភាពប្រសើរឡើងប្រសិនបើគាត់មានប្រាជ្ញាដើម្បីធ្វើការនេះ។

ព្រះយេស៊ូបានព្រមានពេត្រុសដែលសាតាំងកំពុងនឹងល្បួងលោកយ៉ាងខ្លាំង ប៉ុន្តែជំនួសអោយការសូមអោយព្រះយេស៊ូជួយលោក លោកបានគិតថាលោកខ្លាំងគ្រប់គ្រាន់ ហើយវាមិនអាចទៅរួចទេដែលលោកនឹងចាញ់ការល្បួងនោះ។ សូមមើលខគម្ពីរនេះដោយការប្រុងប្រយ័ត្ន ហើយសូមប្រាកដពីអាកប្បកិរិយាដែលពេត្រុសមានវានឹងមិនកើតឡើងជាមួយយើងនោះទេ៖

*«ស៊ីម៉ូន ស៊ីម៉ូនអើយ (ពេត្រុស) មារសាតាំងបានទាមទារសុំរែងអ្នករាល់គ្នា ដូចគេរែងអង្ករ។*
*«ប៉ុន្តែ ខ្ញុំបានអង្វរព្រះជាម្ចាស់ សូមកុំអោយអ្នកបាត់ជំនឿឡើយ។ លុះដល់ពេលអ្នកប្រែចិត្តមកវិញ ចូរជួយបងប្អូនរបស់អ្នកអោយមានជំនឿមាំមួនផង» លោកពេត្រុសទូលព្រះអង្គថា៖«បពិត្រព្រះអម្ចាស់! ទូលបង្គំត្រៀមខ្លួនជាស្រេច ទោះបីត្រូវជាប់ឃុំឃាំងឬត្រូវស្លាប់ក៏ដោយ ទូលបង្គំសុខចិត្តទៅជាមួយព្រះអង្គរហូត»។*

*លូកា ២២៖៣១-៣៣ (KHOV)*

ពេត្រុសបានបដិសេធព្រះគ្រិស្ទចំនួនបីដង! (លូកា២២៖៥៥-៦២)។ ប្រហែលជាប្រសិនបើលោកបានដឹងអំពីភាពទន់ខ្សោយរបស់គាត់ ហើយបានសូមជំនួយពីព្រះ

យេស៊ូគាត់ពិតជាទទួលបាន គាត់នឹងរឹងមាំជាងនេះ។ ព្រះយេស៊ូមិនចង់នាំគាត់ចេញពីសេចក្ដីល្បួងនោះទេ ប៉ុន្តែទ្រង់មានព្រះទ័យចង់អោយគាត់បានឆ្លងកាត់វាទៅដោយជោគជ័យ ដូច្នេះគាត់អាចនឹងមានបទពិសោធន៍គ្រប់គ្រាន់សម្រាប់ជួយអ្នកដទៃទៀត។ប៉ុន្តែពេត្រុសពិតជាគិតថាគាត់អាចយកឈ្នះលើសេចក្ដីល្បួងនេះបាន ប៉ុន្តែពេត្រុសពិតជាបានគិតថាគាត់មានកំលាំងលើសការល្បួង។ នេះគឺជាកំហុសយ៉ាងធំ ហើយវាក៏ជាកំហុសសម្រាប់យើងរាល់គ្នាដែរ ដែលគិតរបៀបនោះ។ ការគិតខ្ពស់ហួសលើសពីភាពជាខ្លួនរបស់យើងគឺមិនមែនជាប្រាជ្ញានោះទេ ហើយវាបើកទ្វារសម្រាប់ការធ្លាក់ចុះរបស់យើង(រ៉ូម១២៖៣)។ ព្រះជាម្ចាស់ស្រលាញ់យើងខ្លាំងណាស់ មិនបានទាក់ទងជាមួយនឹងភាពអំនួតរបស់យើងទេ ដូច្នេះយើងអាចរៀនពឹងផ្អែកលើព្រះជាម្ចាស់ទាំងស្រុង។

ប៉ូលបង្រៀនយើងអោយអធិស្ឋានរាល់ពេលទាំងអស់ ក្នុងគ្រប់រដូវកាលទាំងអស់ (អេភេសូ ៦៖១៨)។ នៅពេលដែលយើងធ្វើដូច្នេះ វាបង្ហាញថាយើងមានសេចក្ដីជំនឿរបស់យើងនៅក្នុងទ្រង់គ្រប់ពេលទាំងអស់។

ចំណាយពេលដើម្បីដឹងថាអ្វីជាភាពខ្សោយរបស់អ្នក ហើយប្រាកដថាអ្នកទុកចិត្តលើព្រះជាម្ចាស់គ្រប់ពេលវេលាទាំងអស់ថា ព្រះជាម្ចាស់ប្រទានកំលាំងដល់អ្នកនៅក្នុងសេចក្ដីល្បួងទាំងនោះ។

> *នៅថ្ងៃដែលទូលបង្គំបានអំពាវនាវ នោះទ្រង់បានឆ្លើយតបមកទូលបង្គំ ទ្រង់បានកំឡាចិត្តទូលបង្គំ ដោយចំរើនកំលាំង (កំលាំងនិងការបត់បែនទៅនឹងសេចក្ដីល្បួង) នៃព្រលឹងទូលបង្គំ។*
>
> *(ទំនុកដំកើង ១៣៨៖៣)(KHOV)*

ប្រហែលជាអ្នកមានអារម្មណ៍ថាអ្នកបានអធិស្ឋានទៅព្រះ សូមអោយព្រះអង្គជួយអ្នក តទល់ការល្បួង ហើយអ្នកនៅតែត្រូវបានអោយទៅក្នុងការនោះ។ ពេលខ្លះខ្ញុំមានអារម្មណ៍បែបនេះ ប៉ុន្តែប្រសិនបើអ្នកជ្រើសរើសបន្តទុកចិត្តព្រះជាម្ចាស់ នោះអ្នកនឹងរឹងមាំឡើង រឹងមាំឡើងតាមពេលដែលវិវដ្តទៅ។ ចូរបូកបញ្ចូលគ្នានូវក្ដីជំនឿរបស់អ្នកជាមួយនឹងការសិក្សាព្រះបន្ទូលព្រះយ៉ាងហ្មត់ចត់របស់អ្នក ដើម្បីទទួលបាននូវលទ្ធផលយ៉ាងល្អបំផុត។ សាវក យ៉ាកុបបាននិយាយថា ព្រះបន្ទូលមានអំណាចនឹងសង្គ្រោះព្រលឹងរបស់យើង (យ៉ាកុប ១៖២១)។

នៅពេលដែលខ្ញុំអធិស្ឋាន សូមព្រះអោយទ្រង់ជួយខ្ញុំគ្រប់គ្រងពាក្យសំដីដែលខ្ញុំ

និយាយ ខ្ញុំក៏បានទាញយកព្រះបន្ទូលខុសៗគ្នានៃខគម្ពីរដែលខ្ញុំបានរៀន អំពីពាក្យសំដីនៃអណ្តាត។ សម្លេងនៃការអធិស្ឋានរបស់ខ្ញុំមានដូចយ៉ាងនេះ៖

*«ព្រះបិតាអើយ សូមជួយទូលបង្គំនៅថ្ងៃនេះ និយាយតែពាក្យដែលល្អឥតខ្ចោះ។ សូមជួយទូលបង្គំអោយក្លាយជាអ្នកស្តាប់ដ៏ល្អនិងគិតមុនពេលទូលបង្គំនិយាយ។ ទូលបង្គំចង់អោយពាក្យរបស់ទូលបង្គំបានថ្វាយសិរីល្អដល់ទ្រង់ ហើយនឹងមានពរដល់អស់អ្នកដែលស្តាប់ពាក្យទាំងនោះ។ ទូលបង្គំត្រូវការទ្រង់ ព្រះអង្គអើយ។ ទូលបង្គំមិនមានអ្វីទាំងអស់បើគ្មានទ្រង់។ សូមចម្រើនទូលបង្គំអោយបានខ្លាំងឡើងនៅក្នុងភាពកំសោយទាំងអស់របស់ទូលបង្គំ។»*

បន្ទាប់ពីខ្ញុំអធិស្ឋាននិងប្រកាសព្រះបន្ទូល ព្រោះការរំលឹកព្រះអំពីព្រះបន្ទូលរបស់ទ្រង់គឺជាអ្វីដែលហោរាអេសាយបាននិយាយថា យើងគួរនឹងធ្វើ (អេសាយ៤៣៖២៦)។ ជាការពិតណាស់ព្រះជាម្ចាស់មិនភ្លេចព្រះបន្ទូលរបស់ទ្រង់ឡើយ **ដូច្នេះ**ហេតុអ្វីបានជាយើងត្រូវរំលឹកទ្រង់អំពីពាក្យទាំងនោះ? ទីនេះជាហេតុផលមួយចំនួន៖

- ពេលដែលយើងរំលឹកទ្រង់ពីព្រះបន្ទូលរបស់ទ្រង់ វាបង្ហាញថាយើងដាក់សេចក្តីទុកចិត្តរបស់យើងទាំងស្រុងក្នុងទ្រង់និងនៅក្នុងសេចក្តីសន្យារបស់ទ្រង់
- ការនិយាយព្រះបន្ទូលរបស់ព្រះចេញមកឮៗ គឺជាការធ្វើកិច្ចការមួយដ៏ពេញដោយអំណាច ពីព្រោះវាជាដាវនៃព្រះវិញ្ញាណ ជាមួយក្នុងចំណោមអាវុធនៃសង្គ្រាមខាងឯវិញ្ញាណទាំងអស់របស់យើង (២កូរិនថូស ១០៖៤-៥, អេភេសូរ ៦៖១៧)
- ការនិយាយព្រះបន្ទូលរបស់ព្រះ ជួយបន្តដំណើរការនៃចិត្តគំនិតរបស់យើងអោយថ្មីឡើងៗ (រ៉ូម១២៖២)។ វាជាផ្នែកមួយនៃការប្រព្រឹត្តទៅនៃការគិតពិចារណាពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយនោះគឺជារឿងមួយដែលជាញឹកញាប់នៅក្នុងព្រះគម្ពីរជំរុញយើងអោយធ្វើ។

នៅទីនេះមានខគម្ពីរចំនួនបីដែលខ្ញុំចូលចិត្តទាក់ទងនឹងពាក្យដែលខ្ញុំនិយាយដែលខ្ញុំតែងតែដាក់ចូលទៅក្នុងការអធិស្ឋានរបស់ខ្ញុំ:

*ឱព្រះយេហូវ៉ាអើយ សូមទ្រង់ដាក់ការយាមនៅមាត់ទូលបង្គំ ហើយថែរក្សាទ្វានៃបបូរមាត់ទូលបង្គំផង។ (ទំនុកដំកើង ១៤១៖៣)(KHOV)*

*ឱព្រះយេហូវ៉ាជាថ្មដា ហើយជាអ្នកប្រោសលោះនៃទូលបង្គំអើយ សូមអោយពាក្យសំដីដែលចេញមកពីមាត់ទូលបង្គំនិងការរំពឹងគិតក្នុងចិត្តរបស់ទូលបង្គំ បានគួរគាប់នៅព្រះនេត្រទ្រង់។*

*(ទំនុកដំកើង ១៩៖១៤)(KHOV)*

*ដ្បិតទូលបង្គំបានកាន់តាមអស់ទាំងផ្លូវរបស់ព្រះយេហូវ៉ា ហើយមិនបានថយចេញពីព្រះនៃទូលបង្គំ ដោយប្រព្រឹត្តសេចក្តីអាក្រក់ឡើយ។*

*(ទំនុកដំកើង ១៨៖២១)(KHOV)*

អ្នកក៏អាចប្រើប្រាស់គំនិតនេះដូចគ្នាសម្រាប់ការអធិស្ឋាន និងការប្រកាសព្រះបន្ទូលរបស់ព្រះជាម្ចាស់នៅក្នុងគ្រប់ទីកន្លែងដែលអ្នកត្រូវការជំនួយ។ តើការខឹង ការបរិភោគច្រើន ភាពអាត្មានិយម ជាភាពទន់ខ្សោយរបស់អ្នកឬ? ទោះបីវាជាយ៉ាងនេះក្តី ខ្ញុំអាចសន្យានឹងអ្នកថា មានខគម្ពីរជាច្រើនដែលសន្យានៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលគ្របបាំងវា។ ប្រើប្រាស់កម្មវិធីព្រះគម្ពីរដែលអ្នកអាចស្វែងរកប្រើប្រាស់បានក្នុងបច្ចុប្បន្ននេះនៅលើប្រព័ន្ធអ៊ីនធឺណែតដែលបង្ក ភាពងាយស្រួលក្នុងការប្រើប្រាស់។ ដូចគ្នានេះដែរ ខ្ញុំសូមជំរុញអោយអ្នកចងចាំថា វាមិនមែនអ្វីដែលអ្នកធ្វើត្រឹមត្រូវម្តងរឺពីរដងនោះ នឹងនាំភាពជោគជ័យចូលក្នុងជីវិតរបស់អ្នកនោះទេ។ ត្រូវប្តេជ្ញាបន្តពឹងផ្អែកលើព្រះជាម្ចាស់និងព្រះបន្ទូលរបស់ទ្រង់ជាទីមួយ ហើយសំខាន់ *នៅគ្រប់ពេលទាំងអស់* ហើយអ្នកនឹងឃើញពីការផ្លាស់ប្តូរនៅក្នុងកំឡុងពេលនោះ។

## *ភាពស្កប់ស្កល់ជានិច្ច*

ប្រសិនបើយើងទុកចិត្តព្រះជាម្ចាស់គ្រប់ពេលទាំងអស់ ជាធម្មជាតិនោះមានន័យថា យើងទុកចិត្តព្រះក្នុងរឿងដែលយើងមិនយល់ ហើយនោះហាក់ដូចជាមិនពិតប្រាកដនូវរឿងជាច្រើនដែលយើងធ្វើនៅពេលផ្សេងទៀត។ វាជារឿងមួយដែលទុកចិត្តព្រះនៅពេលដែលយើងបានទទួលនូវអ្វីដែលយើងចង់បាន ប៉ុន្តែការពិតមួយផ្សេងទៀតដើម្បីទុកចិត្តទ្រង់នៅពេលដែលយើងមិនបានទទួលវា។ ខ្ញុំជឿថាគោលដៅរបស់យើង ក្នុងនាមជាគ្រិស្ទបរិស័ទគួរនឹងនិយាយជាមួយនឹងលោកសាវកប៉ុលថា «ដ្បិតខ្ញុំបានរៀនអោយចេះ

វាគឺជារឿងមួយដែលទុកចិត្តព្រះនៅពេលដែលយើងបានទទួលនូវអ្វីដែលចង់បាន ប៉ុន្តែការពិតមួយផ្សេងទៀតដើម្បីទុកចិត្តទ្រង់នៅពេលដែលយើងមិនបានទទួលវា។

ស្កប់ចិត្ត...ក្នុងគ្រប់កាលៈទេសៈ» (ភីលីព ៤៖១១)(KHSV)។ លោកសាវ៉ប៉ូលបាននិយាយថា គាត់បានរៀនអំពីរបៀបដើម្បីអោយបានស្កប់ចិត្ត គាត់មិនត្រូវបានរំខាននោះឡើយ ទោះបីជាពេលដែលគាត់មានច្រើនហូរហៀរ ឬ នៅក្នុងការខ្វះខាតក្តី (ភីលីព៤៖១១.១២)។

ភាពស្កប់ស្កល់មិនមែនមានន័យថាយើងនឹងមិនចង់ឃើញការផ្លាស់ប្តូរ ឬក៏យើងមិនមាននិមិត្តសម្រាប់អ្វីដែលល្អជាងនោះដែរ ប៉ុន្តែគឺវាមានន័យថា យើងមិនអនុញ្ញាតអោយវត្ថុដែលយើងចង់បានហើយមិនទាន់មាន មកលួចការសប្បាយរីករាយនៃអ្វីដែលយើងនឹងមានក្នុងពេលអនាគតនោះទេ។

អស់រយៈពេលពេញប៉ុន្មានឆ្នាំដែល ខ្ញុំបានពេញទៅដោយភាពសោកសង្រេង ហើយឫសគល់នៃបញ្ហានោះគឺបានកើតឡើងមកពីខ្ញុំមិនមានសេចក្តីរីករាយ ដែលខ្ញុំបាននៅលើផ្លូវជាកន្លែងដែលខ្ញុំកំពុងបានធ្វើដំណើរ។ ព្រះជាម្ចាស់គឺសម្រាប់ភាពរីកចំរើនទាំងអស់ និងការលូតលាស់ទាំងអស់ ប៉ុន្តែអ្វីដែលលើសពីនេះទៀតនោះគឺទ្រង់សម្រាប់សេចក្តីសុខសាន្ត។

សូមពិចារណាខគម្ពីរនេះដែលដកស្រង់ចេញពីសៀវភៅសាស្តា:

> *អ្វីៗដែលយើងមើលឃើញផ្ទាល់នឹងភ្នែក នោះប្រសើរជាងចិត្តស្រមើស្រមៃ។ សូម្បីតែត្រង់នេះទៀត ក៏ឥតបានការ (ភាពទទេស្អាត ក្លែងបន្លំ និងឥតប្រយោជន៍) ដូចដេញចាប់ខ្យល់។*
>
> *(សាស្តា ៦៖៩)(KHSV)*

អ្នកសរសេរ (ដែលជឿថាជា សាឡូម៉ូន) គឺនិយាយថា វាជាការឥតប្រយោជន៍ (គ្មានប្រយោជន៍ និង គ្មានន័យ) ដើម្បីសម្រេចចិត្តយ៉ាងមោះមុតនូវអ្វីដែលអ្នកមិនមាន ហើយវាបង្ខាំងអ្នកពីសេចក្តីរីករាយពីអ្វីដែលអ្នកធ្វើ។

លោកសាវ៉ប៉ូលបានរៀនអោយស្កប់ស្កល់ ទោះបីជាលោកបានទទួលអ្វីដែលលោកចង់បាន ឬមិនបានទទួលវាក្តី ហើយនេះត្រូវតែជាគោលដៅរបស់យើង។ នៅពេលដែលយើងបានទទួលវិធីផ្ទាល់ខ្លួនរបស់យើងដើម្បីការស្កប់ស្កល់ និងការអរព្រះគុណ គឺវាជាភាពក្មេងខ្ចីនិងមិនបានសម្តែងនូវភាពចាស់ទុំខាងឯវិញ្ញាណនោះទេ។ ដូចជាឪពុកម្តាយ យើងកែតម្រូវកូនៗរបស់យើងសម្រាប់ប្រភេទនៃឥរិយាបថដែលមិនទាន់ពេញវ័យនេះ។ ខ្ញុំរំលឹកពួកគេពីគ្រប់ទាំងព្រះពររបស់ពួកគេ ហើយប្រាប់ពួកគេអោយអរព្រះគុណសម្រាប់រាល់ទាំងអ្វីៗដែលពួកគេមាន។ ប្រហែលជាយើងត្រូវ

ការការចងចាំដើម្បីរៀបចំផងដែរនូវឧទាហរណ៍សម្រាប់ពួកគេដើរតាមនៅក្នុងរបៀបដែលយើងធ្វើនៅពេលដែលយើងមិនមានអ្វីដែលយើងចង់បាន។ ការទុកចិត្តព្រះជាម្ចាស់វាងាយស្រួលនៅពេលដែលអ្វីៗទៅតាមផ្លូវរបស់យើង, ទោះជាយ៉ាងណា សៀវភៅនេះគឺនិយាយអំពីការរៀនដើម្បីទុកចិត្តព្រះជាម្ចាស់ក្នុងគ្រប់ពេលទាំងអស់។

ធម្មជាតិនៃភាពស្អប់ស្អល់ គឺនៅពេលដែលជីវិតទទួលការឈឺចាប់ ឬ នៅពេលយើងត្រូវរង់ចាំហើយមិនយល់ថាហេតុអ្វី។ វាតម្រូវអោយជឿថាព្រះអង្គគឺល្អហើយផ្លូវរបស់ទ្រង់គឺខុសពីផ្លូវរបស់យើង។ អ្វីដែលខ្ញុំគួរនឹងធ្វើសម្រាប់ខ្លួនរបស់ខ្ញុំ អាចនឹងមិនល្អបំផុតសម្រាប់ខ្ញុំនោះទេ។ ខ្ញុំប្រាកដថាវានឹងមានអារម្មណ៍ល្អហើយហាក់ដូចជាល្អក្នុងពេលនោះ ប៉ុន្តែតើវានឹងជួយខ្ញុំរយៈពេលយូរឬទេ? តើខ្ញុំនឹងទទួលបានវិធីរបស់ខ្ញុំគ្រប់ពេលដែរឬទេ ដែលជួយខ្ញុំបោះបង់ភាពអាត្មានិយម បន្ថែមក្តីស្រលាញ់ បន្ថែមការយល់ដឹង ហើយបន្ថែមក្តីមេត្តាករុណាជាមួយមនុស្សដទៃទៀត នៅពេលដែលពួកគេឈឺចាប់? ទេ, វានឹងមិនអាចទេ! មធ្យោបាយតែមួយគត់ដើម្បីកំណត់អត្តសញ្ញាណពិតប្រាកដជាមួយអ្នកដទៃ គឺត្រូវមានបទពិសោធន៍ខ្លះទាក់ទងនឹងប្រភេទនៃអ្វីដែលពួកគេកំពុងដោះស្រាយ។ យើងមិនចាំបាច់ឆ្លងកាត់បទពិសោធន៍គ្រប់យ៉ាងដែលមនុស្សគ្រប់គ្នាមានដើម្បីជួយពួកគេនោះទេ ប៉ុន្តែយើងមិនអាចយល់ពីការខកចិត្ត ឬការឈឺចាប់ខាងផ្លូវចិត្ត ឬការឈឺចាប់ខាងរាង្គកាយ ឬការលំបាកផ្សេងៗប្រសិនបើយើងមិនបានជួបប្រទះវា។

យើងបែរទៅរកព្រះយេស៊ូនៅក្នុងការឈឺចាប់របស់យើង ពីព្រោះទ្រង់ជាមហាបូជាចារ្យដ៏ខ្ពស់បំផុត ដែលយល់ច្បាស់ពីភាពខ្សោយនិងពិការភាពរបស់យើង។ តើទ្រង់យល់បានយ៉ាងដូចម្តេច? ទ្រង់ជ្រាបពីព្រោះទ្រង់ធ្លាប់ទទួលការល្បួងនៅក្នុងគ្រប់ផ្នែកទាំងអស់ដែលយើងទទួល ហើយទ្រង់ក៏មិនបានប្រព្រឹត្តអំពើបាបដែរ (ហេព្រើ ១ ៖១៥)។ វាងាយស្រួលសម្រាប់យើងទៅរកព្រះយេស៊ូសម្រាប់ការជួយ ពីព្រោះយើងជឿថាទ្រង់យល់ពីយើង! ទ្រង់គឺស្គាល់ជំងឺនឹងទុក្ខព្រួយ សេចក្តីឈឺចាប់នឹងការបដិសេធ។ ដូចយើងអាច មករកព្រះយេស៊ូ យើងក៏គួរឱ្យវាងាយស្រួលសម្រាប់អ្នកដទៃមករកយើងដោយមានទំនុកចិត្តដូចគ្នា ជឿថាយើងនឹងយល់។

ដូចដែលយើងបានឆ្លងកាត់រឿងជាច្រើននៅក្នុងជីវិត បទពិសោធន៍ទាំងនោះបង្កើនសមត្ថភាពយើងអោយជាម្នាក់ដែលព្រះជាម្ចាស់ប្រើប្រាស់បាន ដើម្បីនាំយកភាពសុខស្រួលនិងការលើកទឹកចិត្តដល់មនុស្សដទៃទៀតដែលមានតម្រូវការ។ យើងប្រហែលជាមិន(ហើយប្រហែលជាមិនចង់) យល់ពីផ្លូវរបស់ព្រះជាម្ចាស់គ្រប់ពេលនោះទេ (អេសាយ៥៥៖៩) ប៉ុន្តែ យើងអាចស្មោះត្រង់ជាមួយទ្រង់ ដោយបន្តការជឿ

ទ្រង់គឺល្អនិងគ្រប់ទាំងផ្លូវរបស់ទ្រង់គឺត្រឹមត្រូវ!

## *ការទុកចិត្តទាមទារសេចក្តីអត់ធ្មត់*

ការទុកចិត្តព្រះជាម្ចាស់តែងតែទាមទារអោយមានសេចក្តីអត់ធ្មត់ ពីព្រោះព្រះជាម្ចាស់មិនធ្វើការនៅក្នុងពេលវេលារបស់យើងនោះទេ។ ការអត់ធ្មត់អនុញ្ញាតអោយយើងរីករាយនឹងជីវិតកំឡុងពេលដែលយើងរង់ចាំ! វាប្រហែលជាពិបាកសម្រាប់អោយយើងជឿថា ហេតុអ្វីបានជាព្រះជាម្ចាស់មិនធ្វើអ្វីមួយដែលយើងដឹងថាវាងាយស្រួលសម្រាប់ព្រះអង្គ ប្រសិនបើទ្រង់ជ្រើសរើសធ្វើវា ហើយនៅពេលដែលរឿងនេះកើតឡើង ជាការពិតណាស់ទ្រង់មានហេតុផលរបស់ទ្រង់។ វាអាចជាការសាកល្បងសេចក្តីជំនឿរបស់ ឬពន្លាតសេចក្តីជំនឿរបស់យើង ដូច្នេះសមត្ថភាពរបស់យើងរស់នៅដោយសេចក្តីជំនឿដែលរីកលូតលាស់។ វាអាចថា ព្រះជាម្ចាស់ចង់ធ្វើអ្វីមួយដែលប្រសើរជាងអ្វីដែលយើងចង់បាន ឬក្នុងពេលបច្ចុប្បន្នមានលទ្ធភាពដោះស្រាយ។ ហេតុផលទាំងអស់នេះ (និងហេតុផលដទៃទៀតជាច្រើន) ជាឱកាសសម្រាប់យើងដើម្បីរក្សាសន្តិភាពដោយទុកចិត្តលើអធិបតេយ្យភាពរបស់ព្រះជាម្ចាស់ ភាពល្អហើយនឹងប្រាជ្ញារបស់ទ្រង់។

> ការអត់ធ្មត់អនុញ្ញាតអោយជីវិតរីករាយ ខណៈពេលយើងរង់ចាំ។

ការអត់ធ្មត់ជាធម្មតាមិនមែនជាផលផ្លែនៃព្រះវិញ្ញាណ ដែលងាយស្រួលនឹងមានបរិបូរណ៍ក្នុងជីវិតរបស់នៅរបស់យើងនោះទេ។ ខ្ញុំរកឃើញថាមានកន្លែងខ្លះដែលខ្ញុំមានភាពអត់ធ្មត់ តែកន្លែងខ្លះទៀតគឺខ្ញុំមិនមាននោះទេ ហើយជាការពិតខ្ញុំនៅតែចម្រើនលូតលាស់ក្នុងការអត់ធ្មត់នេះ។ យើងទាំងអស់គ្នារង់ចាំសម្រាប់រឿងអ្វី ដូច្នេះការរង់ចាំមិនមែនជាជំរើសនោះទេ ប៉ុន្តែតើយើងមានទំលាប់និងឥរិយាបថយ៉ាងដូចម្តេចក្នុងកំឡុងពេលយើងរង់ចាំជំរើស។ ផលផ្លែនៃការអត់ធ្មត់គឺជានិយមន័យខ្លះនៅក្នុងទស្សនាវដ្តី *Vine's Expository* ដូចជាផលផ្លែនៃព្រះវិញ្ញាណដែលចំរើនលូតលាស់តែនៅក្រោមគន្លង។ វ៉ាវ! តើអ្នកមិនឆ្ងល់ទេឬ ថាវាបាននិយាយពីអ្វីមួយផ្សេង? ខ្ញុំដឹងខ្ញុំធ្វើ!

ខ្ញុំនឹងអធិស្ឋានសម្រាប់ការអត់ធ្មត់កាន់តែខ្លាំងឡើង ហើយនឹងមានព្រះទាញយកវាមកក្នុងខ្ញុំ ប៉ុន្តែវាមិនបានប្រព្រឹត្តតាមរបៀបនោះទេ។ យើងមានផលផ្លែនៃការអត់ធ្មត់នៅក្នុងយើងដូចជាកូនក្មេងនៃព្រះ ប៉ុន្តែវាត្រូវតែបានអភិវឌ្ឍន៍និងបានអនុញ្ញាតអោយវាប្រព្រឹត្តទៅតាមផ្លូវរបស់វាពីផ្នែកខាងក្នុងរបស់យើង ទៅផ្នែកខាងក្រៅរបស់

យើង។ វាត្រូវការច្រើនជាងទ្រឹស្តីខាងឯវិញ្ញាណឬគំនិត មុខងារពិតនៃការអត់ធ្មត់នៅក្នុងជីវិតប្រចាំថ្ងៃរបស់យើង ហើយនឹងស្ថានភាពនានា។ យើងត្រូវការភាពអត់ធ្មត់ជាពិសេសនៅពេលយើងត្រូវរង់ចាំរបស់អ្វីមួយដែលយើងចង់បានឥឡូវនេះ!

ទោះបីយើងកំពុងរង់ចាំក្នុងជួរនៅផ្សារ កុំពុងរង់ចាំក្នុងចរាចរ កំពុងរង់ចាំមនុស្សម្នាក់ដែលមកយឺតសម្រាប់ការណាត់ជួប ឬកំពុងរង់ចាំព្រះជាម្ចាស់ឆ្លើយតបនឹងការអធិស្ឋានរបស់យើង យើងពិតជាត្រូវការការអត់ធ្មត់ក្នុងជីវិតនេះប្រសិនបើយើងចង់មានសន្តិភាពនិងអំណរក្នុងការរស់នៅរបស់យើង។ សេនទ៍ អាហ្គូស្ទីន បាននិយាយថា «សេចក្តីអត់ធ្មត់គឺជាគូកននឹងបញ្ញា។»[6] សេចក្តីអត់ធ្មត់អាចនឹងហាក់ដូចជារស់ជាតិល្វីង និងជូរ ប៉ុន្តែផ្លែរបស់វាគឺផ្អែម។

ជាញឹកញាប់ហេតុផលព្រះជាម្ចាស់តម្រូវអោយយើងរង់ចាំគឺថា ទ្រង់កំពុងតែប្រើការលំបាករបស់យើងដើម្បីការអត់ធ្មត់ធ្វើការក្នុងយើង។ ការសិក្សាដើម្បីការអត់ធ្មត់គឺមានសារៈសំខាន់គ្រប់គ្រាន់ចំពោះព្រះ ដែលទ្រង់កំណត់អង្គទ្រង់ពីការប្រទានអោយកូនៗរបស់ទ្រង់នូវរបស់អ្វីដែលពួកគេត្រូវការភ្លាមៗ។ នេះគឺជារឿងដែលឪពុកម្តាយជាច្រើនត្រូវរៀន។ រឿងដ៏គួរអោយសោកស្តាយ! នៅលើលោកយើងនេះគឺពេញទៅដោយមនុស្សដែលមិនបានរៀន អំពីគោលការដ៏សំខាន់នេះនៅក្នុងជីវិតរបស់ពួកគេ ហើយពួកគេឥឡូវនេះទាមទារអោយមានការពេញចិត្តភ្លាមៗ។បំណងប្រាថ្នាសម្រាប់ការពេញចិត្តភ្លាម បណ្តាលអោយយើងធ្វើការសម្រេចចិត្តដែលមិនល្អជាច្រើន។ ឧទាហរណ៍៖ មនុស្សមួយចំនួនបានធ្លាក់ចូលទៅក្នុងបំណុលដែលបណ្តាលអោយគេមានភាពស្មុកស្មាញយ៉ាងខ្លាំងនៅក្នុងជីវិតរបស់ពួកគេ។ មនុស្សមួយចំនួនទៀតបានរៀបការជាមួយមនុស្សខុសសម្រាប់ពួកគេពីព្រោះពួកគេតាមចំណង់ដាច់បហ្មៀររបស់ពួកគេ។ ការជឿខុសថា យើងមានការបំពេញបំណងចិត្តភ្លាមៗផ្តល់ជីវិតដែលមិនសប្បាយនិងឥរិយាបថមិនល្អជាច្រើនដូចជាការជ្រើសរើសអាក្រក់។

ការដឹងពីធម្មជាតិនៃព្រះ ខ្ញុំសង្ស័យថាព្រះជាម្ចាស់រក្សាអ្នកណាម្នាក់អោយរង់ចាំលុះត្រាតែទ្រង់ដឹងថាវាជារបស់ដ៏ល្អបំផុតសម្រាប់ពួកគេ។ វាពិបាកសម្រាប់យើងដែលជឿថាការរង់ចាំគឺល្អសម្រាប់យើង ប៉ុន្តែនោះគឺដោយសារការបណ្តុះបណ្តាលដែលមិនត្រឹមត្រូវនិងជាធម្មជាតិនៃសាច់ឈាម។ ការរង់ចាំគឺល្អ - វាធ្វើអោយយើងអរព្រះគុណព្រះកាន់តែច្រើនឡើង នៅពេលដែលទីបញ្ចប់យើងបានទទួលនអ្វីដែលយើងប្រាថ្នា។

ការគ្មានភាពអត់ធ្មត់បន្ថែមសម្ពាធទៅលើជីវិតរបស់យើង ប៉ុន្តែការទុកចិត្តព្រះកំឡុងពេលដែលយើងរង់ចាំដកយកសម្ពាធទាំងនោះ ហើយអនុញ្ញាតអោយយើងរង់

ចាំជាមួយនឹងឥរិយាបថដែលថ្វាយសិរីរុងរឿងទ្រង់។ ផលប្រយោជន៍នៃការទុកចិត្តគឺពិតជាស្រស់ស្អាតខ្លាំងណាស់។ នៅពេលដែលយើងជឿថា ព្រះជាម្ចាស់កំពុងនឹងយកចិត្តទុកដាក់លើអ្វីដែលកំពុងធ្វើអោយយើងខ្វល់ខ្វាយ វាធ្វើអោយយើងមានសេរីភាពដោយផ្ដែកលើរបស់ផ្សេងទៀតដែលនឹងរំខានការទទួលផលល្អ។ វាជាជំនួយដល់ការមានសុខភាពល្អនិងមានអាយុយឺនយូរ ហើយខ្ញុំជឿថាវាក៏ជួយយើងអោយងាយស្រួលរស់នៅជាមួយគ្នាផងដែរ។ ទំនុកចិត្តបណ្ដេញភាពស្មុកស្មាញនិងភាពតានតឹងចេញពីជិវិតរបស់យើង ហើយទាំងនោះជាប្រភពចម្បងពីរនៃការម៉ួរម៉ៅនិងឆាប់ខឹងជាមួយនឹងអ្នកផ្សេង។ យើងពិតជាមិនមានបំណងធ្វើអោយអ្នកណាម្នាក់ឈឺចាប់ ឬ ប្រព្រឹត្តចំពោះពួកគេដោយមិនសប្បុរសនោះទេ ប៉ុន្តែនៅពេលដែលព្រលឹងរបស់យើងពេញទៅដោយភាពច្របូកច្របល់ ជាធម្មតាយើងផ្អែកលើថា*យើងមានអារម្មណ៍*យ៉ាងដូចម្ដេច។ ដូច្នេះនោះជារបៀបដែលយើងប្រព្រឹត្តចំពោះមនុស្សដទៃ។ ជារឿយៗយើងមិនដឹងថា តើយើងមានភាពតឹងរ៉ឹងនិងត្រគោះបោះបោកដែលយើងកំពុងតែធ្វើនោះទេ ប៉ុន្តែមនុស្សគឺមានអារម្មណ៍នេះ ហើយនៅទីបញ្ចប់ពួកគេនឹងបដិសេធយើងប្រសិនបើការបំពាននៅតែបន្ត។

ខ្ញុំប្រាកដណាស់ថាក្ដីស្រលាញ់មានឯកសិទ្ធិនៃការជឿទុកចិត្តព្រះជាម្ចាស់!ហើយខ្ញុំក៏ប្រាកដដែរថា ក្ដីសម្ពប់នាំមកនូវក្ដីព្រួយបារម្ភ ភាពភ័យខ្លាច ភាពស្មុកស្មាញ ហើយពោរពេញដោយភាពតានតឹង! ប្រសិនបើអ្នកធ្វើការសម្រេចចិត្តអំពីផ្លូវណាមួយទៅកាន់ស្ថានភាពរយៈពេលខ្លីរបស់អ្នក ហើយនឹងរបៀបទាក់ទងនឹងជីវិតរបស់អ្នក ខ្ញុំអាចធានាសម្រាប់អ្នកថាការជឿទុកចិត្តព្រះជាម្ចាស់ជាជំរើសដែលប្រសើរបំផុត។

# ជំពូក ៨

## បើព្រះជាម្ចាស់ល្អមែន ហេតុអ្វីមនុស្សឈឺចាប់?

*ខ្ញុំយល់ឃើញថា ទុក្ខលំបាកនាបច្ចុប្បន្នកាល ពុំអាចប្រៀបផ្ទឹមនឹងសិរីរុងរឿង ដែលព្រះជាម្ចាស់សំដែងអោយយើងឃើញ នៅអនាគតកាលនោះបានឡើយ។*

*រ៉ូម ៨:១៨*

ការឈឺចាប់ ជាមុខវិជ្ជាមួយដែលពិបាកបំផុតក្នុងការបង្រៀន ដូច្នេះខ្ញុំចាប់ចំណុចនេះដោយការអធិស្ឋានច្រើន ហើយចាប់ផ្តើមនិយាយពីការនោះ ទោះខ្ញុំមិនមានអារម្មណ៍ថាមិនមានចម្លើយក៏ដោយ។ យ៉ាងណាក៏ដោយ ខ្ញុំមិនអាចសរសេរសៀវភៅការទុកចិត្តព្រះជាម្ចាស់ បានទេ បើខ្ញុំមិននិយាយពីមុខវិជ្ជាដ៏ពិបាកនេះ ហើយវាក៏ដោយសារតែសំណួរមួយដែលតែងត្រូវបានសួរនោះថា "បើព្រះជាម្ចាស់ល្អមែន ហេតុអ្វីមនុស្សឈឺចាប់?"

គ្រិស្តបរិស័ទមិនសូវមានសំណួរថា ហេតុអ្វីអ្នកមិនជឿឈឺចាប់ទេ គឺបើអ្នកនោះមិនជឿលើព្រះ នោះប្រហែលយើងអាចយល់ហេតុផលនៃការឈឺចាប់របស់ពួកគេ។ ដូច្នេះ សំណួររបស់យើងត្រឡប់មកជា "ហេតុអ្វីគ្រិស្តបរិស័ទឈឺចាប់?" យើងបានរៀនឲ្យជឿថា ព្រះជាម្ចាស់ស្រឡាញ់យើង ហើយព្រះអង្គ ចង់ឲ្យយើងមានអំណរក្នុងជីវិតនិងសន្តិភាព ហើយព្រះអង្គពិតជាដូច្នេះមែន ប៉ុន្តែព្រះអង្គក៏បង្រៀនយើងផងដែរថា យើងអាចទទួលការនោះបានខណៈយើងស្ថិតនៅកណ្តាលនៃការឈឺចាប់។

ខ្ញុំឮសំនួរដូច្នេះថា៖

- តើព្រះជាម្ចាស់ធ្វើឲ្យមានការឈឺចាប់ឬ?
- តើព្រះជាម្ចាស់អនុញ្ញាតឲ្យមានការឈឺចាប់ឬ?
- បើព្រះជាម្ចាស់លើទាំងអស់ ហេតុអ្វីក៏ព្រះអង្គមិនបញ្ឈប់កុំឲ្យមានការឈឺចាប់ទៀត?
- ហេតុអ្វីព្រះជាម្ចាស់បណ្តោយឲ្យមាន ការអត់ឃ្លាន រំលោភបំពាន ជំងឺ និងការអាក្រក់ផ្សេងៗរាប់ ពាន់ដែលបង្កឲ្យមានការឈឺចាប់?

- ហេតុអ្វី ក្មេងៗ ពេលខ្លះឈឺចាប់ដោយសារជំងឺមហារីក?
- ហេតុអ្វីមនុស្សល្អខ្លះ បែរជាស្លាប់តាំងពីក្មេង?
- ហេតុអ្វីបានជាខ្ញុំបាត់បង់ការងារនិងការចូលនិវត្តន៍របស់ខ្ញុំ?
- ហេតុអ្វីព្រះជាម្ចាស់មិនធ្វើអ្វីម្យ៉ាងកុំឲ្យមានគ្រោះរាំងស្ងួត ឬការប្រល័យពូជសាសន៍?

> ខ្ញុំដឹងថា ព្រះជាម្ចាស់ទ្រង់ល្អ ដូច្នេះ ខ្ញុំសំរេចចិត្តផ្តោតតែលើការនេះ ប៉ុណ្ណោះ ជាជាងលើការអ្វីដែល ខ្ញុំមិនសូវយល់ច្បាស់។

"ហេតុអ្វី?" អាចស្ទើរតែរុញច្រានមនុស្សឲ្យធ្លាក់ចូលក្នុងភាពចង្អួត បើពួកគេមិនអាចយល់ នឹងខ្លឹមសាររបស់វា។ បើខ្ញុំបានឆ្លើយទៅនឹងសំណួរទាំងនោះ ខ្ញុំនឹងចាប់ផ្តើមដោយនិយាយយ៉ាង សាមញ្ញថា "ខ្ញុំអត់ដឹងដែរ។" ខ្ញុំដឹងថា ព្រះជាម្ចាស់ល្អ ដូច្នេះខ្ញុំសំរេចផ្តោតតែលើការនេះប៉ុណ្ណោះ ជាជាងលើការអ្វីដែលខ្ញុំមិនសូវយល់។ ខ្ញុំជឿលើ ការធានាដ៏ច្បាស់លាស់មួយនៃភាព ល្អរបស់ព្រះជាម្ចាស់ ដែលអនុញ្ញាតឲ្យយើងប្រឈមនឹងការឈឺចាប់ផ្ទាល់ខ្លួន និងការឈឺចាប់នៅជុំវិញយើង ដោយមិនឲ្យយើងធ្លាក់ជាប់ជុងនៃភាពភាន់ច្រឡំឡើយ។ បើចូលទៅក្នុង បន្ទប់មួយ ហើយស្រែកឡើងថា "ព្រះជាម្ចាស់ ហេតុអ្វី? ហេតុអ្វីបានជាវាកើតឡើងដូច្នេះ?" ហើយការនេះអាចជួយអ្នកបាន ដូច្នេះចូរទៅធ្វើបែបនឹងចុះ។ តែចូរត្រៀមខ្លួនឲ្យបានរួចរាល់ផង សំរាប់ការដែលគ្មានចម្លើយមកវិញ ហើយត្រូវនៅតែមានជំរើសដែលទុកចិត្តព្រះជាម្ចាស់ ឬមួយ ក៏ខកចិត្តនឹងខ្លួនឯងទ្រាំលែងបាន។

ខ្ញុំត្រូវតែព្រមទទួលយកថា ខ្ញុំបានចំណាយពេលពីរបីឆ្នាំដំបូងនៃការដើររបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់ដែលសួរថា "ហេតុអ្វី?" អំពីចំពោះអ្វីៗគ្រប់យ៉ាងដែលខ្ញុំមិនយល់ ក៏ប៉ុន្តែខ្ញុំក៏បានចំណាយពេលជាច្រើនដែរ ក្នុងភាពច្របូកច្របល់ និងការខកចិត្ត។ សំណួរដែលមិនទទួលបានចម្លើយរបស់ខ្ញុំទាំងប៉ុន្មាន បានបកមករកខ្ញុំ ធ្វើឲ្យប៉ះពាល់ដល់ទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះជាម្ចាស់។ ហេតុដូច្នេះ ជាចុងក្រោយ ខ្ញុំក៏បានឈប់ទាមទារនូវចម្លើយពីព្រះអង្គទៀត ហើយបានសំរេចចិត្ត ទុកចិត្តព្រះអង្គទាំងស្រុងវិញ ជាពិសេសនោះគឺនៅពេលខ្ញុំកំពុងឈឺចាប់ ឬមិនយល់នូវអ្វីដែលកំពុងកើតឡើងក្នុងជីវិតរបស់ខ្ញុំ។

បន្ទាប់ពីការឈឺចាប់យ៉ាងវេទនាអស់រយៈពេល១៥ឆ្នាំដោយការរំលោភបំពានផ្លូវភេទពីឪពុករបស់ខ្ញុំ ហើយ២៥ឆ្នាំឬលើសពីនោះពីផលប៉ះពាល់ដែលរំលោភបំពាននោះ ខ្ញុំអាចប្រាប់អ្នកបានថាខ្ញុំមានសំណួរច្រើនណាស់។ជាក្មេងម្នាក់ ខ្ញុំបានអធិស្ឋាន និងបានសុំព្រះជាម្ចាស់ឲ្យ យកខ្ញុំចេញពីកាលៈទេសៈដែលខ្ញុំបានស្ថិតនៅនោះ ប៉ុន្តែ

ព្រះអង្គពុំបានឆ្លើយតបវិញទេ។ ថ្វីបើព្រះអង្គពុំបានរំដោះខ្ញុំចេញ តែព្រះអង្គបានប្រទាននូវកម្លាំងមកខ្ញុំឲ្យឆ្លងកាត់ផុត ហើយប្រទាន ព្រះគុណឲ្យខ្ញុំជាស្បើយពីវា។ ជាញឹកញាប់ណាស់ មនុស្សទាំងអស់ គឺយើងមើលទៅលើអ្វីដែលព្រះជាម្ចាស់មិនបាន ធ្វើសំរាប់យើងជាជាងអ្វីៗដែលព្រះជាម្ចាស់បាន ធ្វើវិញ។ ខ្ញុំគិតថា នោះគឺជាកំហុសមួយដ៏ធំបំផុតដែលយើងធ្វើ! អ្នកអាចសំរេចចិត្តរីករាយនឹងអ្វីដែលអ្នក មាន ជាជាងសោកសៅនឹងអ្វីដែលមិនស្មើភាព ឬអ្វីដែលកើតក្នុងជីវិតរបស់អ្នក។ ចូរកុំបណ្តោយឲ្យអ្វីដែលអ្នកមិនយល់ធ្វើអោយខ្វាក់ភ្នែកមើលមិនឃើញការល្អរបស់ព្រះជាម្ចាស់ឲ្យសោះ។

ជាញឹកញាប់ណាស់ មនុស្សទាំងអស់ គឺយើងមើលទៅលើ អ្វីដែលព្រះជាម្ចាស់មិនបានធ្វើសំរាប់យើង ជាជាងអ្វីៗដែលព្រះជាម្ចាស់បានធ្វើវិញ។

ខ្ញុំមិនជឿថា ព្រះជាម្ចាស់តែងតែទុកយើងនៅទីងងឹតដោយខ្លាចហេតុអ្វីកើតឡើង ឬមិន កើតឡើងទេ ប៉ុន្តែមានការជាច្រើនច្បាស់ណាស់ត្រូវលាក់បាំងនៅក្នុងព្រះប្រាជ្ញាញាណនៃព្រះ ដែលមិនអាចវាស់ស្ទង់បាន ជារឿងហេតុដែលស្វែងរកកន្លងហើយ ហើយវានៅតែជាអាថ៌កំបាំង ចំពោះយើងរហូតដល់យើងទៅស្ថានសួគ៌វិញ។ ចូរផ្តោតលើខគម្ពីរខាងក្រោម៖

> *ព្រះហឫទ័យទូលាយរបស់ព្រះជាម្ចាស់ ជ្រៅពន់ពេកណាស់ ហើយព្រះប្រាជ្ញាញាណ និងព្រះតម្រិះរបស់ព្រះអង្គក៏ខ្ពង់ខ្ពស់ដែរ! គ្មាននរណាអាចយល់ការសំរេចរបស់ព្រះអង្គបានឡើយ ហើយក៏គ្មាននរណាអាចយល់មាគ៌ារបស់ព្រះអង្គបានដែរ!*
>
> *រ៉ូម ១១:៣៣*

ព្រះជាម្ចាស់សន្យាថា ឲ្យយើងមើលឃើញអាថ៌កំបាំងខាងក្នុង និងការសម្ងាត់ ដ៏រាបណាយើងស្វែងរកព្រះអង្គ (ចូរអានអេភេសូរ១:១៧) ហើយលោកសាវ័កប៉ូលក៏បានប្រាប់យើងផងដែរថា យើងគ្រាន់តែ ដឹងដោយផ្នែកប៉ុណ្ណោះ យើងមិនដឹងគ្រប់ទាំងអស់នោះទេ គឺរហូតទាល់តែយើងនៅជាមួយព្រះយេស៊ូ មុខផ្ទាល់នឹងមុខ (ចូរអាន ១កូរិនថូស ១៣:៩-១០)។

ខ្ញុំឧស្សាហ៍និយាយថា ការទុកចិត្តតម្រូវឲ្យគ្មានចម្លើយចំពោះសំណួរទាំងឡាយ។ ព្រះជាម្ចាស់សំដែងការជាច្រើនដល់យើង ហើយបានផ្តល់ឲ្យយើងនូវចម្លើយចំពោះបញ្ហាដ៏ស្មុគស្មាញ ក៏ប៉ុន្តែក៏មានពេលខ្លះយើងមិនអាច ទទួលចម្លើយចំពោះកាលៈទេសៈមួយទោះបើ

ការទុកចិត្តតម្រូវការគ្មានចម្លើយចំពោះសំណួរទាំងឡាយ។

ព្រះជាម្ចាស់បានផ្តល់ហើយក្តី។ ខ្ញុំមិនជឿថា ព្រំដែននៃគំនិតរបស់យើង អាចចាប់យកបាននូវអ្វីដែលមានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលជ្រាបនោះ។ ហើយខ្ញុំជឿថា ព្រះអង្គមុខជាបង្ហាញដល់យើងឲ្យដឹងនូវអ្វីដែលត្រូវសំរាប់យើង ហើយក៏លាក់ការខ្លះដែលមិនត្រូវនឹងយើងផងដែរ។

យើងរស់នៅជីវិតឆ្ពោះទៅមុខ ប៉ុន្តែជាញឹកញាប់យើងអាចយល់ពីវាបាននៅពេលយើងមើលត្រឡប់មកក្រោយវិញប៉ុណ្ណោះ។ មានការឈឺចាប់ជាច្រើនដែលខ្ញុំមិនយល់ នៅពេលពួកវាបានកើតឡើងចំពោះខ្ញុំ។ ប៉ុន្តែពេលខ្ញុំមើលទៅក្រោយវិញ ខ្ញុំឃើញវាប្លែកជាងកាលពីមុន ពីព្រោះខ្ញុំឃើញការ ល្អកើតមកពីការឈឺចាប់ដែលខ្ញុំបានឈរមាំពីមុន ឬដោយព្រោះខ្ញុំបានលូតលាស់ខាងវិញ្ញាណ។ ដាវីឌ ថ្លែងថា "ឱ **ព្រះអម្ចាស់**អើយ ទូលបង្គំគ្មានចិត្តអំណួត ឬវាយឫកខ្ពស់ទេ ទូលបង្គំមិនប្រាថ្នាចង់បានអ្វីដែលធំអស្ចារ្យហួសពីសមត្ថភាពរបស់ទូលបង្គំឡើយ"(ទំនុកតម្កើង ១៣១:១)

ខ្ញុំគិត ដាវីឌនិយាយយ៉ាងសាមញ្ញថា មានរឿងខ្លះដែលត្រូវបានបិទបាំងក្នុងភាពអាថ៌កំបាំងនៃព្រះជាម្ចាស់ដែលមនុស្សមិនអាចយល់បានឡើយ។ មើលទៅ យើងគួរតែចោទសួរសំណួរបន្តិចបន្តួច ហើយទុកចិត្តព្រះជាម្ចាស់ឲ្យច្រើនវិញ! ខ្ញុំធ្លាប់ឮការថ្លែងរបស់លោក លី ស្ត្រូបែល ថា "ចម្លើយចុង ក្រោយរបស់ព្រះជាម្ចាស់ចំពោះការឈឺចាប់នោះ មិនមែនជាការពន្យល់ទេ តែជាការចូលរួមទៅវិញទេ"។ ព្រះជាម្ចាស់បានចាត់ព្រះយេស៊ូឲ្យមករងទុក្ខ ហើយសុគតសំរាប់បាបរបស់យើង។ ព្រះអង្គបានសន្យាពីការប្រោសលោះដល់អស់អ្នកណាដែលទុកចិត្តព្រះអង្គ ប៉ុន្តែព្រះអង្គមិនដែលប្រាប់យើងឲ្យប្រាកដថា ពេលណា ឬដោយរបៀបណាដែលការប្រោសលោះនោះនឹងមកដល់ទេ។ ទម្រាំតែការនោះមកដល់ នោះយើងបានខ្ពស់មុខដោយការទុកចិត្តព្រះជាម្ចាស់ និងទទួលនូវការសម្រាលទុក្ខពីគ្រប់ភាពលំបាករបស់យើងទាំងអស់។

នៅពេលយើងឃើញអ្នកជាទីស្រឡាញ់ម្នាក់បានបាត់បង់ទៅ ដោយជម្ងឺទាំងនៅក្មេង នោះយើងអាចនឹងថា "ការប្រោសលោះរបស់អ្នកនេះ មិនបានមកទាន់ពេលសោះ តើឲ្យខ្ញុំជឿថា ព្រះជាម្ចាស់តែង រំដោះយើងដូចម្តេចទៅ? ខ្ញុំជឿច្បាស់ណាស់ថា ព្រះអង្គគឺតែងតែរំដោះអស់អ្នកដែលទុកចិត្តព្រះអង្គ។ វាមិនមែនតែងតែកើតឡើងនៅលើផែនដីនេះទេ ក៏ប៉ុន្តែនៅពេលណាមួយដែលយើងចូលរួមជាមួយនឹង ព្រះអង្គនៅឯស្ថានសួគ៌ ដែលជាទីគ្មានការឈឺចុកចាប់ មិនសំរក់ទឹកភ្នែក ឬការឈឺចាប់ពីអ្វីៗនោះទេ។

ពេលមួយខ្ញុំបានឮអំពីរឿងរាវដ៏មានឥទ្ធិពលរបស់ក្មេងប្រុសម្នាក់ដែលបានធ្លាក់ពីជណ្តើរយន្តហោះ ដូចទារក ហើយបាក់ឆ្អឹងខ្នង។ គាត់បានចេញចូលមន្ទីរពេទ្យពេញ

មួយជីវិត។ ពេលអាយុបាន ១៧ឆ្នាំ គាត់បានចំណាយពេលអស់១៣ឆ្នាំនៅក្នុងមន្ទីរពេទ្យ។ គាត់បាននិយាយថាគាត់ធ្លាប់បានគិតថា ព្រះជាម្ចាស់មានតម្លាភាព ហើយនៅពេលដែលគេសួរគាត់ថា "តើអ្នកគិតអញ្ចឹងទៅរួចកើត?" គាត់ក៏ បានឆ្លើយតបវិញថា "មែនហើយ ព្រះជាម្ចាស់មានភាពអស់កល្ប ដែលអាចធ្វើឲ្យវាកើតឡើងចំពោះខ្ញុំបាន"។

វាពិតជាពិបាកនឹងពន្យល់ឲ្យប្រាកដ ថានោះជាអ្វីដែលខ្ញុំមានអារម្មណ៍នៅក្នុងវិញ្ញាណរបស់ខ្ញុំ នៅពេលដែលខ្ញុំឮរឿងរ៉ាវបែបនេះ ឬក៏ជួបមនុស្សដែលបានឈរមាំនៅក្នុងការឈឺចាប់ដ៏រន្ធត់ ហើយគេនៅតែទុកចិត្តព្រះជាម្ចាស់បានទៀត។ អ្វីដែលខ្ញុំអាចនិយាយបាននោះគឺ ខ្ញុំយល់ដឹងពីសម្រស់នៃការទុកចិត្តរបស់គេនោះ ហើយមនុស្សបែបនោះគឺជាគំរូដល់អស់អ្នកដែលមានសេចក្តីជំនឿនឹងព្រះ ជាម្ចាស់គ្រប់ពេលទាំងអស់នៃជីវិតរបស់ពួកគេ។ នោះគឺជារឿងមួយដែលនរណាម្នាក់បានទុកចិត្តព្រះជាម្ចាស់នៅពេលដែលសេចក្តីអធិស្ឋានរបស់គេត្រូវបានឆ្លើយតបយ៉ាងលឿន ក៏ប៉ុន្តែរឿងមួយទៀតនោះ គឺថា ការទុកចិត្តព្រះជាម្ចាស់ខណៈពេលអ្នកកំពុងរងការឈឺចុកចាប់ ឬបានអធិស្ឋានហើយ ហើយសេចក្តីទូលសូមនោះក៏យូរដែរ តែអ្នកនៅតែរង់ចាំឲ្យការឆ្លើយតបនោះមកដល់។ គំនិតរបស់ខ្ញុំនោះគឺ ចុងក្រោយបំផុត វាតម្រូវឲ្យមានសេចក្តីជំនឿឲ្យខ្លាំងជាងនេះទៀត។

## *តើព្រះជាម្ចាស់ល្អមែនឬ?*

មែនហើយ ព្រះជាម្ចាស់ល្អ! និស្ស័យរបស់ព្រះអង្គ គឺល្អ ហើយព្រះអង្គអត់មានអ្វីផ្ទុយពីនឹងទេ។ មិនមែនដោយព្រោះតែរឿងវាកើតមកហាក់ដូចជាមិនល្អ ឬវាធ្វើឲ្យយើងមានអារម្មណ៍ល្អនោះ មានន័យថា ព្រះជាម្ចាស់មិនល្អនោះទេ។ មានខគម្ពីរប្រហែលជា៧០០ដង ដែលប្រាប់យើងថា ព្រះជាម្ចាស់ល្អ។ ខ្ញុំចូលចិត្តខនេះមួយនៅក្នុងគម្ពីរយ៉ាកុប៖

> *គ្រប់អំណោយដ៏ល្អវិសេស និងអ្វីៗទាំងប៉ុន្មានដ៏គ្រប់លក្ខណៈដែលយើងបានទទួល សុទ្ធតែមកពីស្ថានលើទាំងអស់ គឺមកពីព្រះបិតាដែលបង្កើតពន្លឺ។ ព្រះអង្គមិនចេះប្រែប្រួលឡាស់ទេ...*
>
> *យ៉ាកុប ១:១៧*

គ្រប់អ្វីៗដែលល្អសុទ្ធតែមកពីព្រះជាម្ចាស់ទាំងអស់ ត្រង់នេះហើយដែលពិតជាលក្ខណៈរបស់ព្រះអង្គ នោះហើយសេចក្តីពិតគ្មានការប្រែប្រួលទេ។ ខ្ញុំប្រាកដណាស់ពេលខ្ញុំនិយាយបែបនោះ ក៏មានអ្នកអានខ្លះអាចចង់និយាយបកមកខ្ញុំវិញថា "បើព្រះជាម្ចាស់តែងតែល្អមែន ចុះហេតុអ្វីមានមនុស្សរងទុក្ខ?" មានហេតុផលខ្លះៗថា ហេតុអ្វីយើងរងទុក្ខ ប៉ុន្តែគ្មានមួយណានៃការរងទុក្ខនោះ ដោយសារ ព្រះជាម្ចាស់បានរៀបចំវាឡើងនោះទេ។ ព្រះអង្គមិនមែនជាអ្នកនិពន្ធពីការរងទុក្ខទេ តែគឺសាតាំងវិញ! ទោះបីមានរឿងមួយដែលអាចនឹងមិនល្អខាងក្នុង និងគឺវាផ្ទាល់មិនល្អ ពីព្រោះព្រះជាម្ចាស់ល្អ ព្រះអង្គ អាចធ្វើរឿងល្អៗចេញពីកាលៈទេសៈនៃការរស់នៅ របស់យើងក៏បាន។ អ្នកអាចនឹងជួប ឬធ្លាប់បានដឹង ពីគ្រាមួយដែលសែនវេទនា ហើយវាធ្វើឲ្យអ្នកគិតថា *គ្មានផ្លូវរឿងល្អនឹងកើតឡើងបានទេ* ប៉ុន្តែគ្រប់ រឿងទាំងអស់គ្មានអ្វីពិបាកសំរាប់ព្រះជាម្ចាស់ឡើយ។

ខ្ញុំអាចនិយាយដោយគ្មានការញញើតថាព្រះជាម្ចាស់បានដកនូវការរំលោភបំពានដែលខ្ញុំបានរងទុក្ខកាលពីនៅក្មេង ហើយព្រះអង្គបានធ្វើវាឲ្យទៅជាល្អសំរាប់ខ្ញុំវិញ និងរឿងល្អៗជាច្រើនដែលខ្ញុំមានអភ័យឯកសិទ្ធិនៃសេចក្តីបង្រៀនរបស់ខ្ញុំ។ការយល់ដឹងបញ្ហានេះមិនបានកើតមានខណៈខ្ញុំស្ថិតក្នុងភាពជូរចត់ តែបែរជាចាក់បំពេញដោយការអណិតខ្លួនឯង និងគុំកួនចំពោះអស់អ្នកដែលរំលោភបំពានខ្ញុំទាំងឡាយ។ វាបានចាប់ផ្តើមកើតមានបន្តិចម្តងៗ ដូចខ្ញុំបានទុកចិត្តព្រះជាម្ចាស់ឲ្យដកការអាក្រក់ ហើយឲ្យការល្អកើតចេញជំនួសវិញ។ រឿងដូចគ្នានេះ អាចកើតមានឡើងដល់អ្នកដូចគ្នា។ ខ្ញុំសូមឲ្យអ្នកទុកចិត្តព្រះជាម្ចាស់គ្រប់ពេលចុះ ពីព្រោះខ្ញុំជឿថា នេះគឺជាជម្រើសតែមួយគត់ដែលធ្វើឲ្យមានជំនួយដែលត្រូវនឹងសេចក្តីត្រូវការរបស់អ្នក។ បើយើងមិនទុកចិត្តព្រះជាម្ចាស់ទេ យើងគ្មានអ្វីសល់ទេ ប៉ុន្តែមានតែការភាន់ភាំង និងភាពល្វីងជូរចត់លើអ្វីៗដែលយើងឃើញ ព្រមទាំងបទពិសោធនៅក្នុងជីវិតប៉ុណ្ណោះ។

ព្រះទ្រង់ល្អ ហើយអ្វីដែលព្រះអង្គធ្វើ គឺសុទ្ធតែល្អទាំងអស់ (សូមមើលទំនុកតម្កើង ១១៩:៦៨)។ ដូច្នេះតើវាអាចទៅរួចទេ ការរងទុក្ខអាចត្រឡប់ទៅជាល្អសំរាប់យើងវិញ? មានពេលមួយនោះ យើងបានតយុទ្ធជាមួយនឹងការរងទុក្ខវេទនា តើវាអាចទៅរួចឬទេដែលព្រះជាម្ចាស់ចំណាយ ពេលយូរដើម្បីរំដោះយើងជាជាងយើងចង់ឲ្យព្រះអង្គដកចេញឲ្យអស់ភ្លាមនោះ ហើយនោះដោយព្រោះ ព្រះអង្គចង់ប្រើរឿងអាក្រក់ឲ្យកើតការល្អនៅក្នុងយើង? មែនហើយ វាអាចទៅរួចណាស់ ហើយយើង ស្ទើរតែទាំងអស់គ្នាអាចធ្វើបន្ទាល់ពីការដ៏ប្រពៃដែលបានកើតឡើងក្នុងយើង ជាលទ្ធផលដែលយើងបានឆ្លងកាត់ ជារឿងរ៉ាវដែលយើងមិនចង់មានបទពិសោធជាជាង។ ការផ្តល់

ជម្រើស នាំឲ្យជៀសផុតពីការរងទុក្ខ ប៉ុន្តែយើងមិនតែងតែផ្តល់ជម្រើសនោះទេ យ៉ាងណាក៏ដោយ យើងនៅតែមានជម្រើសដដែល គឺ ថាយើងទុកចិត្តឬមិនទុកចិត្តព្រះជាម្ចាស់ធ្វើឲ្យមានការល្អកើតចេញមក។

ខ្ញុំចង់ជជែកពីរឿងនេះឲ្យកាន់តែក្បោះក្បាយនៅពេលក្រោយ ប៉ុន្តែមុនយើងអាចបន្តក្នុងការ ព្យាយាមចាប់យកអត្ថន័យយ៉ាងហោចណាស់នៃការរងទុក្ខរបស់យើងខ្លះៗនោះ យើងត្រូវតែមានគ្រឹះនៅ ក្នុងចិត្តរបស់យើងអំពីជំនឿដែលមិនអាចសួរបាន គឺ ព្រះជាម្ចាស់ទ្រង់ល្អ ហើយព្រះអង្គប្រព្រឹត្តល្អ។ ក្នុងគ្រាដំបូង គឺបន្ទាប់ពីព្រះអង្គបានសូនអ្វីៗដែលយើងរីករាយនាពេលនេះបាន ដែលព្រះអង្គបានទតមើលទាំងអស់ ហើយគម្ពីរលោកុប្បត្តិ១:៣១ ថ្លែងថា "ព្រះជាម្ចាស់ទតឃើញអ្វីៗទាំងអស់ ដែលព្រះអង្គបានបង្កើតមក ព្រះអង្គឈ្វេងយល់ថាល្អប្រសើរបំផុតហើយ។ ពេលនោះមានល្ងាច មានព្រឹក គឺជាថ្ងៃទីប្រាំមួយ"។

មានអ្នកខ្លះបានសួរសំណួរដូច្នេះថា "បើព្រះជាម្ចាស់ល្អមែន ហេតុអ្វីបានជាព្រះអង្គមិនបង្កើត ពិភពលោកមួយដែលគ្មានការរងទុក្ខ និងសោកនាដកម្ម?" ជាក់ស្តែងគឺព្រះអង្គបានធ្វើហើយ! អ្វីដែលយើងត្រូវធ្វើនោះ គឺមើលទៅសួនអេដែន និងផែនការដំបូងដែលព្រះជាម្ចាស់មានសំរាប់មនុស្ស ហើយយើងក៏អាចឃើញដែរថា គ្រប់យ៉ាងទាំងអស់គឺល្អ។ ទោះបែបនេះក្តី ព្រះជាម្ចាស់បានផ្តល់សេរីភាពដល់មនុស្ស តែគួរឲ្យស្តាយលទ្ធផលត្រូវបានឈឺចាប់។ ព្រះអង្គចង់ឲ្យយើងស្រឡាញ់ព្រះអង្គដោយគ្មានការបង្ខំ គឺមិនដូចកូនឆ្កែចិញ្ចឹមដែលគ្មានជម្រើសក្នុងការសម្រេចនោះទេ។ អាដាមនិងអេវ៉ាពុំបានជ្រើសរើស តាមព្រះហឫទ័យនៃព្រះជាម្ចាស់ឡើយ ហើយជាលទ្ធផលនោះគឺ ការឈឺចាប់បានចូលមកពិភពលោកនេះ។ ព្រះយេស៊ូបានយាងមកដើម្បីរំដោះយើងពីជម្រើសនៃសោកនាដសកម្មដែលអាដាមនិងអេវ៉ា បានសម្រេចធ្វើនេះ ប៉ុន្តែយើងនឹងមិនអាចឃើញលក្ខណៈដ៏ពេញលេញនៃការបង្កបង្កើតរបស់ព្រះអង្គទេ គឺលើកលែងតែយើងទៅឯស្ថានសួគ៌។ លោកប៉ូលបាននិយាយនៅក្នុងគម្ពីរអេភេសូរថា ព្រះវិញ្ញាណ ដ៏វិសុទ្ធដែលយើងបានទទួលគឺ "មកបញ្ជាំចិត្តយើងអោយដឹងថាយើងនឹងទទួលមត៌ក នៅពេលព្រះអង្គលោះប្រជារាស្ត្ររបស់ព្រះអង្គ ជាស្ថាពរ ដើម្បីអោយគេលើកតម្កើងសិរីរុងរឿងរបស់ព្រះអង្គ"។ (អេភេសូ ១:១៣)

> ព្រះជាម្ចាស់រំដោះយើងពីសត្រូវរបស់យើងបន្តិចម្តងៗ។

ខគម្ពីរនេះសំដែងឲ្យយើងដឹងច្រើនណាស់។ នៅពេលយើងទទួលព្រះយេស៊ូជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់របស់យើង នោះរឿងរ៉ាវក្នុងការរស់នៅរបស់យើងនឹងបានប្រសើរ។ហើយកាលណាយើងកាន់តែរៀនស្គាល់ព្រះអង្គនិងដើរដោយ

ការស្តាប់បង្គាប់តាមព្រះហឫទ័យរបស់ព្រះអង្គ រឿងរ៉ាវរបស់ យើងក៏កាន់តែប្រសើរឡើងយ៉ាងនោះដែរ។ ស្តេចសាឡូម៉ូនបានថ្លែងថា ផ្លូវរបស់មនុស្សសុចរិតនឹងកាន់តែភ្លឺឡើងៗរហូតដល់ថ្ងៃពេញកំដៅ (សូមមើលសុភាសិត ៤:១៨)។ គម្ពីរទុតិយកថា ៧:២២ ថ្លែងថា ព្រះជាម្ចាស់រំដោះយើងពីខ្មាំងរបស់យើងបន្តិចម្តងៗ។

សូម្បីតែផែនដីក៏ស្រែកថ្ងូរ រង់ចាំការរំដោះយ៉ាងពេញលេញចំពោះកូនៗរបស់ព្រះជាម្ចាស់ដែរ។ ខគម្ពីរខាងក្រោមនេះ នាំយកសេចក្តីពិតឲ្យលេចមកក្នុងរបៀបមួយដ៏អស្ចារ្យ៖

> *មិនត្រឹមតែពិភពលោកប៉ុណ្ណោះទេ សូម្បីតែយើង ដែលបានទទួលព្រះអំណោយទានដំបូងរបស់ព្រះវិញ្ញាណ ក៏ថ្ងូរក្នុងចិត្តទាំងទន្ទឹងរង់ចាំព្រះជាម្ចាស់ប្រោសយើងអោយទៅជាបុត្ររបស់ព្រះអង្គ និងលោះរូបកាយយើងទាំងស្រុងដែរ។*
>
> *រ៉ូម ៨:២៣*

ឥឡូវនេះយើងភ្លក្សការល្អនៃព្រះជាម្ចាស់ជាដំបូងហើយ ប៉ុន្តែថ្ងៃនោះនឹងមកដល់ជាពេលដែលយើងរីករាយពេញទី។ កាលណានៅតែមានភាពគ្រេកគ្រអាល នោះក៏នៅតែមានអំពើបាប ហើយកាលណានៅតែមានអំពើបាប នោះក៏នៅតែមានការរងទុក្ខឈឺចាប់ដែរ។ ព្រះជាម្ចាស់មិនដែលបានសន្យាជាមួយយើងថា នឹងរំដោះយើងពីគ្រប់ទាំងការឈឺចាប់នៅគ្រាដែលយើងស្ថិតនៅផែនដីនេះទេ ប៉ុន្តែព្រះអង្គបានសន្យាថា យើងអាចរីករាយនឹងអំណាចនៃការរស់ឡើងវិញរបស់ព្រះអង្គ ដែលលើកយើងឲ្យផុតពីការនោះ (សូមមើល ភីលីព៣:១០)។ បើនិយាយម្យ៉ាងទៀតគឺ ព្រះអង្គធ្វើឲ្យអាចទ្រាំទ្រនឹងវារួមជាមួយនឹងអំណរនិងការនឹងធឹង។ព្រះយេស៊ូបានប្រាប់យើងថា នៅក្នុងពិភពលោកនេះ យើងនឹងមានសេចក្តីវេទនា ប៉ុន្តែយើងគួរអរសប្បាយពីព្រោះព្រះអង្គបានឈ្នះលោកីយ៍នេះហើយ (សូមមើល យ៉ូហាន ១៦:៣៣)។

ខ្ញុំកំពុងរីករាយជាមួយនឹងការល្អរបស់ព្រះជាម្ចាស់ច្រើនតាមតែខ្ញុំអាចរីករាយបានខណៈខ្ញុំស្ថិតនៅលើផែនដីនេះ ហើយខ្ញុំសម្លឹងទៅមុខ ទៅកាន់អ្វីៗដែលប្រសើរនៅពេលខ្ញុំលែងស្ថិតនៅក្នុងរូបការរបស់ខ្ញុំ គឺស្ថិតនៅក្នុងដំណាក់ជាមួយព្រះអម្ចាស់។ ទំរាំថ្ងៃនោះមកដល់ខ្ញុំនឹងអធិស្ឋានដោយមិននិយាយអ្វីផ្សេងក្រៅពី "ព្រះជាម្ចាស់ល្អ!" មិនថាយើងរងទុក្ខលំបាកអ្វីទេ ឬយើងឃើញសោកនាដកម្មជាច្រើននៅ ផែនដីនេះទេ រឿងទាំងនោះមិនមែនជាកំហុសរបស់ព្រះជាម្ចាស់ទេ ដ្បិតព្រះជាម្ចាស់ល្អ!

## *សេចក្តីវេទនា មិនឋិតនៅរហូតទេ*

ការដំលើកទឹកចិត្តមួយដែលត្រូវចងចាំ គឺនៅពេលអ្នកកំពុងរងទុក្ខនោះ វានឹងមិនកើតឡើងរហូតនោះទេ។ យ៉ាងហោចណាស់ វានឹងមិនកើតចំពោះអស់អ្នកដែលជឿព្រះយេស៊ូ ពីព្រោះមិនថារឿងទាំងនោះអាក្រក់ប៉ុណ្ណានៅលើផែនដីនោះទេ យើងនៅតែអាចសម្លឹងទៅឯភាពអស់កល្បជានិច្ចនៃព្រះជាម្ចាស់ ដែលបានសន្យានឹងយើងថាគ្រានោះនឹងគ្មានការឈឺចាប់ទៀតឡើយ។

> *ព្រះអង្គនឹងជូតទឹកភ្នែកចេញអស់ពីភ្នែករបស់គេ សេចក្តីស្លាប់លែងមានទៀតហើយ ការកាន់ទុក្ខ ការសោកសង្រេង និងទុក្ខលំបាក ក៏លែងមានទៀតដែរ ដ្បិតអ្វីៗដែលកើតមានកាលពីមុននោះបាត់អស់ទៅហើយ»។*
>
> *វិវរណៈ ២១:៤*

បញ្ហាដែលឈឺចាប់ភាគច្រើនត្រូវបានដោះស្រាយមុននឹងយើងលាចាកលោកនេះ ហើយទៅនៅស្ថានសួគ៌ ប៉ុន្តែទោះបីយើងមើលទៅឯរយៈពេលនៃការឈឺចាប់ដ៏ខ្លាំងនោះក្តីក៏វានឹងមានពេលបញ្ចប់ដែរ ហើយនឹងបានជំនួសមកវិញនូវសេចក្តីអំណរដែលមិនអាចស្រមៃឃើញឡើយ។

*ការនេះក៏ត្រូវកន្លងផុតដែរ* គឺជារបៀបដែលខ្ញុំគិតនៅពេលខ្ញុំកំពុងឈឺចាប់ ពីព្រោះវាជួយអ្នកមិនឲ្យមានអារម្មណ៍ច្រើនលើសជ្រុល។ ថ្មីៗនេះ ខ្ញុំឈឺជំងឺរលាកខ្នង់ច្រមុះដែលបង្កឲ្យឈឺក្បាលវាកើតមាន៣៥ថ្ងៃ។ ខ្ញុំបាននិយាយជាញឹកញយថា "*ការនេះក៏ត្រូវកន្លងផុតដែរ*" ហើយវាក៏បាត់ទៅមែន។ ប៉ុន្តែនៅ ពេលយើងកំពុងឈឺចុកចាប់មួយគ្រានោះ យើងចាប់ផ្តើមគិតថា *វានឹងមិនចប់ទេ*។ ទេ តាមពិតគឺវាមានពេលចប់។ ការខូចចិត្តក៏ជាដែរ ឬយ៉ាងហោចណាស់ពួកគេមុខជាអាចជាបានបើយើងទុកឲ្យព្រះយេស៊ូធ្វើ ការក្នុងជីវិតរបស់យើង។ ទំនុកតម្កើង១៤៧:៣ ថ្លែងថា "ព្រះអង្គប្រោសអ្នកដែលមានចិត្តគ្រាំគ្រា ឲ្យបានធូរស្បើយ ព្រះអង្គរុំរបួសអោយគេ"។ របួសនឹងជា ការខកចិត្តត្រឡប់ទៅក្នុងសុបិន្តថ្មី ឯទីបញ្ចប់ នៃបញ្ហាមួយ បើកទ្វាសំរាប់ឲ្យកិច្ចការផ្សេងៗចាប់ផ្តើមឡើងដែរ។

របួសនឹងជា ការខកចិត្តត្រឡប់ទៅក្នុងសុបិន្តថ្មី ឯទីបញ្ចប់នៃបញ្ហាមួយ បើកទ្វាសំរាប់ឲ្យកិច្ចការផ្សេងៗចាប់ផ្តើមឡើង។

យើងរាល់គ្នាសម្លឹងបកទៅក្រោយមើលការរស់នៅរបស់យើង ហើយរំលឹកពីការឈឺចាប់តាមពេលនោះ ហើយរឿងរ៉ាវទាំងនោះត្រូវបានដោះស្រាយចប់សព្វគ្រប់

ហើយ ហើយយើងក៏មិនរងការឈឺចាប់ដោយសារវាទៀតដែរ។ អស់រយៈពេល ៣០ឆ្នាំដែលខ្ញុំមានការឈឺចាប់ដ៏រ៉ាំរ៉ៃនៅនឹងខ្នងរបស់ខ្ញុំ ដែលខ្ញុំធ្វើកិច្ចការមានកំរិត។ ២ឆ្នាំមុន ខ្ញុំបានជួបវេជ្ជបណ្ឌិតថ្មីម្នាក់ លោកឆ្លាតល្មមនឹងបញ្ជូនខ្ញុំឲ្យទៅធ្វើ តេស្ត៍ ដែលខ្ញុំមិនធ្លាប់ពីមុនសោះ។ វាត្រូវបានរកឃើញថា រោគនេះអាចនឹងកើតមានតាំងពីកំណើតដែល ប៉ះពាល់ឆ្អឹងត្រគាកខ្ញុំ ហើយវានាំឲ្យមានបញ្ហាដល់ខ្នងរបស់ខ្ញុំថែមទៀត។ តាមរយៈវិទ្យាសាស្ត្រដ៏ទំនើបសម័យនេះ ខ្ញុំបានប្តូរឆ្អឹងត្រគាក ហើយក៏លែងមានការឈឺចាប់ខ្នងទៀតដែរ។ ខ្ញុំអាចធ្វើអ្វីៗដែលកាល ពីមុនខ្ញុំមិនអាចធ្វើបាននោះ។ គេអាចនឹងមានបញ្ហាដូចគ្នានេះអស់រយៈពេល៣០ឆ្នាំ គេរាប់ថាកើតរហូត ប៉ុន្តែរឿងរបស់ខ្ញុំវិញវាមានទីបញ្ចប់ដែលបានធ្វើឲ្យខ្ញុំមានការចាប់ផ្តើមថ្មីមួយផ្សេងទៀត។

ខ្ញុំមិនគិតថា យើងមិនគួរបញ្ចប់សេចក្តីសង្ឃឹមរបស់យើងពីការជាសះស្បើយពីគ្រប់ការឈឺចាប់នោះទេ! ការវិវត្តន៍នៃសេចក្តីសង្ឃឹម នោះវាប្រសើរជាជាងការដែលអស់សង្ឃឹម! តើចិត្តរបស់អ្នកអាចជាសះស្បើយ ពីការបាត់បង់អ្នកដ៏ជាទីស្រឡាញ់បំផុតរបស់អ្នកភ្លាមៗបានដែរឬទេ? បាន ពីព្រោះព្រះជាម្ចាស់គឺជា ព្រះដែលលួងលោមចិត្ត ហើយគ្មានអ្វីដែលព្រះអង្គមិនធ្វើទៅរួចនោះទេ។

លោកសាវ័កប៉ុលបានជួបនឹងការឈឺចាប់លើស ពីយើងរាល់គ្នាធ្លាប់ជួបទៅទៀត តែលោកបាន រាប់វា ទុកជាពន្លឺមួយ និងជាបញ្ហាមួយភ្លែតតែប៉ុណ្ណោះ៖

> *ដ្បិតទុក្ខលំបាកបន្តិចបន្តួចដែលយើងជួបប្រទះម្តងម្កាលនោះ ធ្វើអោយយើងមានសិរីរុងរឿងដ៏ប្រសើរលើសលប់ ជាសិរីរុងរឿងនៅស្ថិតស្ថេរអស់កល្បជានិច្ច ដែលរកអ្វីមកប្រៀបផ្ទឹមពុំបាន។*
>
> *២កូរិនថូស ៤:១៧*

លោកប៉ុល មានអាកប្បកិរិយាដែលយើងអាចមានដើម្បីជ្រើសរើសផ្លូវទុកចិត្តព្រះជាម្ចាស់ដែរ។ លោកបានថ្លែងថា លោកមិនសម្លឹងមើលទៅអ្វីដែលលោកអាចមើលឃើញទេប៉ុន្តែមើលទៅអ្វីដែល លោកមិនអាចមើលឃើញវិញ (សូមមើល ២កូរិនថូស ៤:១៨)។ បើនិយាយម្យ៉ាងទៀតបានថា លោកប៉ុលបានសម្លឹងមកកាន់ជីវិត តាមវិញ្ញាណជាជាងសម្លឹងមើលរូបកាយ។ លោកបានជឿលើសេចក្តីល្អ របស់ព្រះជាម្ចាស់ សូម្បីតែខណៈពេលលោកកំពុងឈឺចាប់ក៏ដោយ លោកបានជឿដោយយោងតាមព្រះបន្ទូលនៃព្រះជាម្ចាស់ ថាលោកនឹងមានពេលស្ថិតនៅកន្លែងដែលប្រកបដោយសិរីរុងរឿងរហូត ជាកន្លែងដែលការឈឺចាប់របស់លោកនឹងបានត្រឡប់ទៅជាសេចក្តីរីករាយវិញ។

# ជំពូក ៩

## តើព្រះជាម្ចាស់«អនុញ្ញាត»ឲ្យមានទុក្ខវេទនា?

*ការអ្វីក៏ដោយ ដែលព្រះយេហូវ៉ាសព្វព្រះហឫទ័យចង់ធ្វើនោះក៏បានធ្វើទៅ ទាំងនៅលើមេឃ នៅផែនដីនៅក្នុងសមុទ្រហើយនៅទីជំរៅទាំងប៉ុន្មានផង។*

*ទំនុកតម្កើង ១៣៥:៦*

អាចមានម្នាក់និយាយថា៖ «ខ្ញុំមិនជឿថាព្រះជាម្ចាស់បណ្ដាលឲ្យមានការឈឺចាប់ និងទុក្ខវេទនាទេ។ ខ្ញុំមិនជឿថាព្រះអង្គជាអ្នកបង្កើតវាឡើយ ប៉ុន្តែតើព្រះអង្គអនុញ្ញាតឲ្យវាកើតឡើងដែរឬទេ? បើព្រះអង្គពិតជាអនុញ្ញាត តើព្រះអង្គមានគោលបំណងអ្វី ហើយតើអ្វីជាភាពខុសគ្នារវាងការដែលព្រះអង្គជាអ្នកអនុញ្ញាត និងការដែលព្រះអង្គបង្កើតវាឡើង? តើខ្ញុំអាចទុកចិត្តព្រះដែលប្រហែលជាអនុញ្ញាតឲ្យខ្ញុំមានការឈឺចាប់ និងទុក្ខវេទនាដែរឬទេ? ខ្ញុំដឹងថាសំណួរទាំងនេះពិតជាមាន ព្រោះមានមនុស្សជាច្រើនបានសួរសំណួរទាំងនេះមកខ្ញុំ។

ខ្ញុំក៏បានឮមនុស្សម្នាក់ទៀតនិយាយថា៖ «វាមិនពិតទេ ដែលមានអ្វីមួយធ្វើឲ្យខ្ញុំមិនជឿថាលើលោកនេះមានវិញ្ញាណដែលមានអំណាចលើអ្វីៗទាំងអស់ ដែលជាអ្នកកំណត់ទាំងទុក្ខវេទនា និងការអាក្រក់ទាំងអស់នៅក្នុងពិភពលោកនេះ»។ បុរសនេះមិនអស់ចិត្តជាមួយការអាក្រក់ដែលគាត់បានឃើញ ព្រមទាំងវត្តមានរបស់ព្រះជាម្ចាស់ដែលគ្រប់គ្នានិយាយថាព្រះអង្គល្អនោះទេ។ ក្នុងចំណោមពួកយើងខ្លះ ជំនឿធ្វើឲ្យយើងឆ្លងផុតសំណួរទាំងនេះ ប៉ុន្តែមានមនុស្សជាច្រើនផ្សេងទៀតត្រូវការចម្លើយដើម្បីឲ្យគេអាចជឿបាន។

ខ្ញុំមានបទពិសោធន៍ដ៏ឈឺចាប់ ដែលខ្ញុំមានឪពុកឃោរឃៅ តែបានធ្វើឲ្យខ្ញុំមានជំនឿក្នុងព្រះជាម្ចាស់។ ការឈឺចាប់ និងទុក្ខវេទនា គឺលើសពីអ្វីដែលខ្ញុំអាចទទួលយកបាន ហើយខ្ញុំបានរកឃើញសន្តិភាព សេចក្ដីសង្ឃឹម និងការប្រោសឲ្យជាតាមរយៈទំនាក់ទំនងជាមួយព្រះជាម្ចាស់។ ប្រយោជន៍ដែលខ្ញុំបានទទួលពីការស្គាល់ និងជឿលើព្រះជាម្ចាស់បានឲ្យខ្ញុំរួចពីសំណួរដែលខ្ញុំមាន ហើយឥឡូវនេះខ្ញុំអាចទុក

សំណួរទាំងនោះមួយកន្លែងរហូតដល់ថ្ងៃមួយដែលខ្ញុំអាចទទួលចម្លើយពីព្រះជាម្ចាស់ ឬនៅពេលដែលខ្ញុំទៅនៅជាមួយព្រះអង្គនៅឯនគរស្ថានសួគ៌ ជាកន្លែងដែលមានគ្រប់ទាំងចម្លើយសម្រាប់សំណួរទាំងអស់នេះ។

ទោះជាយ៉ាងណាក៏ដោយ ខ្ញុំយល់ពីសំណួរដែលមនុស្សទាំងឡាយបានសួរ ហើយខ្ញុំគិតថាវាមិនខុសទេដែលពួកគេសួរសំណួរទាំងនេះ។ ព្រះជាម្ចាស់មិនទាស់ព្រះទ័យដោយសារសំណួររបស់យើងទេ ប៉ុន្តែព្រះអង្គមិនឆ្លើយសំណួរទាំងនោះគ្រប់ពេលឡើយ។ មិនថាមានសំណួរប៉ុន្មាន ដែលមានចម្លើយសម្រាប់ពួកយើងទេ ប៉ុន្តែតែងតែមានសំណួរផ្សេងទៀតដែលតម្រូវឲ្យយើងសម្រេចចិត្តថា តើយើងនឹងទុកចិត្តព្រះជាម្ចាស់ឬអត់ នៅក្នុងកាលៈទេសៈដែលជីវិតហាក់បីដូចជាមិនទៅមុខ។

ខ្ញុំនឹងប្រឹងប្រែងឲ្យអស់ពីសមត្ថភាព ដើម្បីព្យាយាមឆ្លើយសំណួរដែលសួរថា តើព្រះជាម្ចាស់ «អនុញ្ញាត» ឲ្យមានទុក្ខវេទនា ឬអត់ ប៉ុន្តែខ្ញុំចង់ប្រាប់ជាមុនថាចម្លើយរបស់ខ្ញុំនឹងមិនគ្រប់ល័ក្ខណ៍ទេ ជាពិសេសសម្រាប់មនុស្សដែលរកការចោទប្រកាន់ដើម្បីមិនជឿលើព្រះជាម្ចាស់។ ពួកគេក៏នឹងមិនស្កប់ចិត្ត លើអ្នកដែលមានអារម្មណ៍ថាពួកគេអាចយល់រឿងទាំងអស់នេះតាមរយៈគំនិតរបស់ពួកគេដែរ។ ការដែលយើងស្វែងរកចំណេះដឹងជាការល្អ ប៉ុន្តែវាក៏អាចជាអំពើដែលនាំមកនូវសេចក្តីអន្តរាយដែរ បើការនោះនាំចូលទៅជ្រៅពេក។ ព្រះបន្ទូលពេញដោយជីវិតសម្រាប់ខ្ញុំ គឺនៅក្នុងគម្ពីរសុភាសិត៖

> *ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ ៦ ត្រូវឲ្យទទួលស្គាល់ទ្រង់នៅគ្រប់ទាំងផ្លូវឯងចុះ នោះទ្រង់នឹងដំរង់អស់ទាំងផ្លូវច្រករបស់ឯង ៧ កុំឲ្យមើលខ្លួនថាមានប្រាជ្ញាឡើយ ចូរកោតខ្លាចដល់ព្រះយេហូវ៉ាវិញ ហើយចៀសចេញពីសេចក្តីអាក្រក់ទៅ។*
>
> *សុភាសិត៣:៥-៧*

យើងមិនអាចរកឃើញសន្តិភាពដោយពឹងលើការយល់ឃើញរបស់យើងផ្ទាល់ឡើយ។ តើហេតុអ្វីបានជាការនេះ ឬ ក៏ការនោះកើតឡើង ហើយតើហេតុអ្វីបានជាវាកើតលើខ្លួនខ្ញុំ? វាជាគំនិតបោកប្រាស់របស់សត្រូវគឺសាតាំង វាព្យាយាមខ្សឹបដាក់ត្រចៀកយើង ដើម្បីឲ្យយើងបែកឆ្ងាយពីព្រះវត្តមានរបស់ព្រះជាម្ចាស់។ យើងអាចត្រឡប់ទៅកាន់សួនអេដែនវិញបាន ហើយអានពីរបៀបដែលវាខ្សឹបសំណួរទៅកាន់អេវ៉ា

> យើងមិនអាចរកឃើញសន្តិភាពដោយពឹងលើការយល់ឃើញរបស់យើងផ្ទាល់ឡើយ។

ដែលធ្វើឲ្យទាំងអ័ដាម និងនាងធ្លាក់ចូលទៅក្នុងអំពើបាប ដែលធ្វើឲ្យផ្លាស់ប្ដូរបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់សម្រាប់មនុស្ស។ សាតាំងបាននិយាយមកកាន់នាងថា «ឯពស់ជាសត្វចេះឧបាយកលលើសជាងអស់ទាំងសត្វព្រៃ ដែលព្រះយេហូវ៉ាដ៏ជាព្រះទ្រង់បានបង្កើត វានិយាយទៅកាន់ស្ត្រីថា តើព្រះមានព្រះបន្ទូលហាមមិនឲ្យអ្នកបរិភោគផ្លែឈើណានៅក្នុងសួនច្បារមែនឬ»? (លោកុប្បត្តិ ៣:១)។ សំណួរនេះបើកផ្លូវសម្រាប់សំណួរផ្សេងទៀត ដែលសាតាំងមិនទាំងបានសួរផង- បើសិនជាផ្លែឈើទាំងអស់នៅក្នុងសួនល្អ ហេតុអ្វីបានជាព្រះជាម្ចាស់ចង់រារាំងមិនឲ្យខ្ញុំបរិភោគពីដើមខ្លះទៅវិញ?ទោះបីជាក្រោយមកនាងចាប់ផ្ដើមរកមូលហេតុក៏ដោយក៏ហេតុផលរបស់នាងនាំនាងទៅរកការភាន់ច្រឡំ ដែលធ្វើឲ្យនាងមានបណ្ដាសានៅក្នុងជីវិត។

ព្រះជាម្ចាស់បានបង្កើតពិភពលោកដែលពីមុនគឺល្អឥតខ្ចោះ ដែលគ្មានការឈឺចាប់និងទុក្ខវេទនាឡើយ។ ព្រះអង្គចង់ឲ្យអ័ដាម និងអេវ៉ាមានពេញដោយអំណាចក្នុងការគ្រប់គ្រងផែនដី ប្រើប្រាស់ធនធានដ៏សម្បូរបែបក្នុងការបម្រើព្រះជាម្ចាស់ និងមនុស្ស (មើលក្នុងលោកុប្បត្តិ ១:២៨)។ មិនមែនព្រះជាម្ចាស់ជាអ្នកនាំទុក្ខវេទនាមកក្នុងពិភពលោកនេះឡើយ ប៉ុន្តែគឺបុរស និងស្ត្រីដែលព្រះអង្គបង្កើតវិញទេតើដែលធ្វើការនេះ។ ក្នុងវិនាទីដែលពួកគេឈប់ស្ដាប់ព្រះជាម្ចាស់ទៅស្ដាប់សាតាំងវិញនិងចាប់ផ្ដើមបរិភោគផ្លែឈើដែលព្រះជាម្ចាស់បានហាម ទុក្ខវេទនារបស់ពួកគេក៏ចាប់ផ្ដើមកើតឡើង។ ជាមួយនឹងការសម្រេចចិត្តមួយនេះ ពួកគេចេញពីការរស់នៅដោយសេរីភាព និងការរីករាយជាមួយនឹងសេចក្ដីស្រឡាញ់ និងការប្រកបជាមួយព្រះជាម្ចាស់ទៅជាការគេចខ្លួនពីព្រះអង្គដោយសេចក្ដីភ័យខ្លាច (មើលក្នុងលោកុប្បត្តិ ៣:៨)។

ព្រះជាម្ចាស់ជ្រាបគ្រប់ការទាំងអស់ ហើយតាមពិតទៅព្រះអង្គអាចធ្វើអ្វីបានគ្រប់យ៉ាង គ្រប់ពេលវេលា គ្រប់ទីកន្លែង និងទៅកាន់អ្នកណាក៏បានឲ្យតែព្រះអង្គចង់ធ្វើ។ យើងអធិស្ឋាន ហើយជ្រើសរើសសេចក្ដីអធិស្ឋានដែលពឹងលើការយល់ដឹងគ្រប់យ៉ាងរបស់ព្រះអង្គ។ យើងពឹងលើសេចក្ដីសន្យាដែលមានជាមួយព្រះជាម្ចាស់ គ្រប់អ្វីទាំងអស់អាចទៅរួច(មើលក្នុងម៉ាថាយ១៩:២៦)។ ទោះជាយ៉ាងណាក៏ដោយព្រះជាម្ចាស់បានផ្ដល់ជម្រើសមួយ គឺឲ្យមនុស្សមានសេរីភាពក្នុងការជ្រើសរើស ហើយការនេះបានផ្លាស់ប្ដូរថាយើងនឹងរងទុក្ខដោយសារការអាក្រក់។ តើយើងនឹងស្ដាប់បង្គាប់ព្រះជាម្ចាស់ឬទេ ឬក៏យើងដើរផ្លូវរបស់យើង?

ព្រះជាម្ចាស់ស្រឡាញ់យើង ហើយចង់ឲ្យយើងស្រឡាញ់ទ្រង់វិញ ប៉ុន្តែវាមិនមែនជាសេចក្ដីស្រឡាញ់ពិតឡើយបើមានការបង្ខំ។ វាត្រូវតែជាសេចក្ដីស្រឡាញ់ដែលចេញពីចិត្តទើបមានន័យ។ យើងតែងតែផ្ដល់សេរីភាពទៅកាន់អ្នកដែលយើងពិតជា

ស្រឡាញ់។ ខ្ញុំធ្លាប់ឮគេនិយាយថា៖ សេចក្តីស្រឡាញ់តម្រូវឲ្យមានការជ្រើសរើសដោយសេរី ហើយកន្លែងណាដែលមានសិទ្ធិក្នុងការជ្រើសរើស កន្លែងនោះក៏នឹងមានការអាក្រក់ដែរ ប៉ុន្តែកន្លែងណាមានការអាក្រក់ កន្លែងនោះក៏អាចមានអ្នកសង្គ្រោះ ហើយកន្លែងណាដែលមានអ្នកសង្គ្រោះ នឹងអាចមានការប្រោសលោះ ហើយកន្លែងណាមានការប្រោសលោះ ក៏នឹងមានការស្តារឡើងវិញដែរ។

ព្រះជាម្ចាស់បានផ្តល់សិទ្ធិក្នុងការជ្រើសរើសដល់មនុស្ស ជាមួយការដឹងជាមុនថា បើគាត់ជ្រើសរើសខុស ជម្រើសរបស់គាត់នឹងបើកទ្វាសម្រាប់ការឈឺចាប់ និងទុក្ខវេទនា ប៉ុន្តែព្រះអង្គនឹងមិនចាកចេញពីយើងដោយគ្មានជម្រើស និង ជំនួយនោះឡើយ ។ សម្រាប់ទស្សនៈនេះ ព្រះជាម្ចាស់បានអនុញ្ញាតឲ្យទុក្ខវេទនាចូលមកក្នុងពិភពលោកនេះ ប៉ុន្តែការនេះវាប្រសើរជាងបង្កើតមនុស្សដែលគ្មានជម្រើសថា តើពួកគេគួរស្រឡាញ់ ឬគួរមិនស្រឡាញ់ និងមានអាកប្បកិរិយាយ៉ាងដូចម្តេច។

ព្រះជាម្ចាស់មិនដែលមានបញ្ហាក្នុងករណីសំណួរគ្មានចម្លើយនោះទេ។ ការដឹងអ្វីដែលនឹងកើតឡើង គឺព្រះអង្គរៀបចំផែនការតាំងពីពេលដំបូងបំផុត ដើម្បីបញ្ជូនព្រះរាជបុត្រារបស់ព្រះអង្គ គឺព្រះយេស៊ូ ដើម្បីបង់ថ្លៃបាប និងបើកផ្លូវឲ្យព្រះជាម្ចាស់ក្នុងការមានទំនាក់ទំនងជាមួយបុត្ររបស់ព្រះអង្គសារជាថ្មី។ ព្រះជាម្ចាស់មិនបានផ្តល់ច្រករត់គេចពីទុក្ខវេទនាឡើយ ព្រោះអំពើបាបនៅមានក្នុងពិភពលោកនៅឡើយ ហើយដរាបណាបាបនៅតែមាន នោះទុក្ខវេទនាក៏កើតមានដែរ។ ប៉ុន្តែតាមរយៈព្រះយេស៊ូ ព្រះជាម្ចាស់បានផ្តល់ការអត់ទោសបាប ការកំសាន្តចិត្ត ព្រះគុណ កំលាំង និងជំនួយគ្រប់យ៉ាងដែលយើងត្រូវទ្រាំទ្រជាមួយទុក្ខវេទនាដោយអត់ធ្មត់ នៅពេលដែលយើងត្រូវតែធ្វើបែបនេះ។ ព្រះជាម្ចាស់ត្រូវតែធ្វើដូច្នេះតទៅទៀត ហើយមានបន្ទូលថា បើយើងទុកចិត្តព្រះអង្គ ទោះបីជាទុក្ខលំបាករបស់យើងធំយ៉ាងណាក៏ដោយ ក៏ព្រះអង្គអាចធ្វើឲ្យវាទៅជាការល្អសម្រាប់យើងដែរ៖

> *តែយើងដឹងថា គ្រប់ការទាំងអស់ផ្សំគ្នា សំរាប់សេចក្តីល្អដល់ពួកអ្នកដែលស្រឡាញ់ព្រះ គឺដល់ពួកអ្នកដែលទ្រង់ហៅមក តាមព្រះដំរិះទ្រង់។*
>
> *រ៉ូម ៨:១៨*

អ្វីមួយមិនមែនត្រូវតែជារឿងល្អ ដើម្បីឲ្យការល្អកើតឡើងពីវានោះទេ។ គឺថាដោយសារវា ជាភ័ស្តុតាងបញ្ជាក់ថា ព្រះជាម្ចាស់ទ្រង់ល្អ ហើយការល្អរបស់ព្រះអង្គអាចបិតបាំងឥទ្ធិពលអាក្រក់នៃភាពអយុត្តិធម៌

អ្វីមួយមិនមែនត្រូវតែជារឿងល្អដើម្បីឲ្យរឿងល្អកើតឡើងពីវានោះទេ។

និងការឈឺចាប់ផ្ទាល់ខ្លួនបាន។ បើគ្មានហេតុផលអ្វីផ្សេងក្រៅពីនេះ យើងត្រូវតែជ្រើសរើសទុកចិត្តព្រះជាម្ចាស់។ ជាមួយការមានឬគ្មានជំនឿក្នុងព្រះជាម្ចាស់ក៏ដោយក៏យើងនឹងមានបទពិសោធន៍ជាមួយទុក្ខលំបាកនៅក្នុងជីវិតនេះដូចគ្នា។ ព្រះយេស៊ូបានប្រាប់យើងថានៅក្នុងពិភពដែលយើងរស់នៅយើងនឹងមានទុក្ខព្រួយ ប៉ុន្តែព្រះអង្គក៏បង្ហាញសេចក្តីពិតតាមរយៈសេចក្តីសន្យាយ៉ាងអស្ចារ្យថា៖ ព្រះអង្គបានយកឈ្នះលោកកិយ៍ហើយ (មើលក្នុង យ៉ូហាន ១៦:៣៣)។ អំពើបាបបណ្តាលឲ្យមានទុក្ខព្រួយ ហើយព្រះជាម្ចាស់គឺជាចម្លើយ! ព្រះជាម្ចាស់នឹងមិនទុកយើងចោលដោយមិនជួយនោះឡើយ។

បើសិនជាយើងមានទុក្ខព្រួយដោយគ្មានព្រះជាម្ចាស់បាន ចុះហេតុអ្វីបានជាយើងមិនអាចរងទុក្ខជាមួយព្រះអង្គ ការទុកចិត្តព្រះអង្គថាព្រះអង្គនឹងអាចឲ្យយើងរួចពីទុក្ខព្រួយទាំងនេះនៅក្នុងពេលវេលាសមស្រប ឬក៏ឲ្យមានការល្អចេញពីវា? សម្រាប់ខ្ញុំការទុកចិត្តព្រះជាម្ចាស់គឺជារឿងត្រឹមត្រូវ។ ការទុកចិត្តព្រះជាម្ចាស់អាចឲ្យយើងអាចទទួលជំនួយរបស់យើងពីព្រះអង្គ ចំណែកឯការដែលមិនទុកចិត្ត ឬមិនជឿព្រះអង្គ នាំយើងទៅកាន់ទុក្ខព្រួយ ដោយគ្មានសេចក្តីសង្ឃឹមនៃការប្រោសលួស ឬការប្រោសឲ្យជាឡើយ។

ព្រះជាម្ចាស់ធ្វើការគ្រប់យ៉ាងដើម្បីឲ្យអ្នកដែលស្រឡាញ់ ទុកចិត្ត និងចង់បានបំណងប្រាថ្នារបស់ព្រះអង្គបានទទួលការល្អ! យើងកើតមកជាមួយសេរីភាពក្នុងការជ្រើសរើស ហើយនៅពេលដែលយើងរងទុក្ខយើងក៏អាចមានជម្រើសក្នុងការទុកចិត្ត ឬមិនទុកចិត្តព្រះជាម្ចាស់ដែរ។

## គ្រប់ទុក្ខព្រួយទាំងអស់សុទ្ធតែជាផលនៃអំពើបាប

បើគ្មានអំពើបាបទេ ក៏គ្មានទុក្ខព្រួយដែរ។ គ្រប់ទាំងទុក្ខព្រួយ ឬការអាក្រក់សុទ្ធតែជាលទ្ធផលនៃអំពើបាបទាំងអស់។ វាអាចជាលទ្ធផលរបស់អំពើបាបរបស់យើងផ្ទាល់ ឬជារបស់អ្នកណាម្នាក់ផ្សេងទៀត ឬក៏ជាលទ្ធផលមិនផ្ទាល់នៃការរស់នៅក្នុងពិភពលោកដែលរលួយនេះ។ សាតាំង គឺជាដើមហេតុនៃអំពើបាប, វាជាអ្នកពេញដោយកំហឹង និងជាអ្នកក្បត់ ដូច្នេះយើងអាចនិយាយឲ្យចំថាសាតាំង គឺជាប្រភពនៃបញ្ហារបស់យើង ប៉ុន្តែយើងក៏ត្រូវមានទំនួលខុសត្រូវខ្លះដោយដឹងថាអ្នកដែលយើងស្តាប់និងអ្នកដែលយើងដើរតាមនៅតែស្ថិតក្នុងសេរីភាពក្នុងការជ្រើសរើសរបស់យើង។ តើយើងនឹងជឿ និងស្តាប់បង្គាប់ការណែនាំរបស់ព្រះជាម្ចាស់សម្រាប់ជីវិតរបស់យើង ឬ

ក៏យើងអនុញ្ញាត ឲ្យបំណងប្រាថ្នាអាក្រក់គ្រប់គ្រងយើង តាមរយៈការកុហករបស់សាតាំង? សាតាំងផ្តល់អំណរបណ្តោះអាសន្នដល់យើង ដែលលួងលោមអារម្មណ៍របស់យើង គឺដូចអ្វីដែលវាបានធ្វើជាមួយអេវ៉ាដែរ ប៉ុន្តែព្រះជាម្ចាស់ផ្តល់ឲ្យយើងនូវជីវិតដែលលើសពីអំណរបណ្តោះអាសន្ននេះ។ ព្រះអង្គបានផ្តល់ដល់យើងនូវទំនាក់ទំនងពិតប្រាកដជាមួយព្រះអង្គ ផ្តល់ទាំងសន្តិភាព អំណរ និងជីវិតដ៏មានន័យដល់យើងតាមរយៈការចូលរួម និងការប្រកបជាមួយព្រះអង្គ។

សូមឲ្យខ្ញុំជាស់តឿនអ្នកថា កុំព្យាយាមភ្ជាប់ទុក្ខព្រួយរបស់អ្នកជាមួយនឹងអំពើបាបផ្ទាល់ខ្លួនខ្លាំងពេក។ មានអ្នកជំងឺជាច្រើនបង្កើនភាពវេទនារបស់ពួកគេដោយធ្លាក់ទៅក្នុងការដាក់កំហុសដល់ខ្លួនឯងលើអ្វីដែលពួកគេអាចធ្វើខុស ដែលបើទ្វារឲ្យពួកគេមានជម្ងឺ។ ទោះបីជាយើងប្រហែលជាអាចបើទ្វារសម្រាប់ជម្ងឺដោយសារអំពើបាផ្ទាល់ខ្លួនរបស់យើងក៏ដោយ វាក៏អាចទៅរួចដែរថាយើងមិនបានធ្វើអ្វីខុសដែលបណ្តាលឲ្យយើងមានបញ្ហាឡើយហើយជាសាមញ្ញវា គឺជាលទ្ធផលនៃការរស់នៅក្នុងពិភពលោកដែលពេញដោយអំពើបាប ដោយទាំងជម្ងឺ និងរោគា គឺជាលទ្ធផលនៃឥទ្ធិពលខ្លះៗរបស់វា។ កុំកាត់ទោសខ្លួនឯងជាមួយការទំលាក់កំហុសដល់ខ្លួនឯងនៅពេលដែលអ្នកបានរងទុក្ខពីស្ថានភាពខ្លោចផ្សារនិងឈឺចាប់ឡើយ។ ទោះបីជានៅពេលដែលព្រះជាម្ចាស់ជ្រើសរើសបង្ហាញយើងថាយើងបានធ្វើរឿងអ្វីមួយខុសឆ្គង ព្រះអង្គមិនធ្វើឲ្យយើងមានអារម្មណ៍ទៅជាការដាក់កំហុសខ្លួនឯងនៅក្នុងស្ថានភាពនេះទេ។ ព្រះអង្គណែនាំយើង ព្រះអង្គឲ្យយើងប្រែចិត្ត និងទទួលការអត់ទោសពីព្រះអង្គ។ ព្រះអង្គមិនកាត់ទោសយើងទេ ការកាត់ទោសនេះជាការងាររបស់វិញ្ញាណអាក្រក់វិញ។

ជាជាងការរង់ចាំដើម្បីដឹងថាហេតុអ្វីបានជាមនុស្សរងទុក្ខ និងថាហេតុអ្វីបានជាពិភពលោកនេះពេញដោយការអាក្រក់ មនុស្សត្រូវតែចង់ដឹងវិញថាអ្វីទៅជាគោលបំណងនៅក្នុងជីវិត។ ពួកគេចង់មានអារម្មណ៍ថាពួកគេមានតំលៃ។ បញ្ហារបស់មនុស្សមិនមែនទុក្ខព្រួយទេ ប៉ុន្តែជាអំណរហួសហេតុដែលគេមិនដែលស្កប់ចិត្តឡើយទោះបីដោយវិធីណាក៏ដោយ។ ឧទាហរណ៍ដូចជាប្រទេសឥណ្ឌាមានពេញទៅដោយទុក្ខព្រួយគ្រប់យ៉ាង ហើយពួកគេជាអ្នកកាន់សាសនាយ៉ាងជោគជាំ។ ទោះបីជាពួកគេមានពេញទៅដោយសាសនាខុសឆ្គងក៏ដោយ ក៏ប្រជាជនរបស់គេស្វែងរកព្រះដែរ។ ពួកគេជឿលើការថ្វាយបង្គំអ្វីមួយផ្សេងទៀតជាជាងខ្លួនឯង។ ប៉ុន្តែលោកខាងលិចដែលជាទីកំណើតនៃជំនឿដ៏អស្ចារ្យក្នុងព្រះជាម្ចាស់បានរីករាយនឹងអំណរគ្រប់យ៉ាងហើយវាហាក់បីដូចជាគេឃ្លាតឆ្ងាយទៅៗពីព្រះជាម្ចាស់ទៅវិញ។ តាមពិតទៅលោកខាងលិចបានប្រាប់ព្រះជាម្ចាស់ថាគេមិនស្វាគមន៍ព្រះអង្គទៀតឡើយ។ ប្រជាជាតិ

ដែលយើងបែរទៅរកមនុស្សនិយម គឺមនុស្សដែលគ្មានព្រះជាម្ចាស់។ នៅពេលដែលមានអំពើបាបកាន់តែច្រើន នោះទុក្ខព្រួយ និងការអាក្រក់ក៏មានកាន់តែច្រើនដែរ។ ប៉ុន្តែមិនថាប្រជាជាតិមួយបែរឆ្ងាយពីព្រះជាម្ចាស់យ៉ាងណាក៏ដោយ មនុស្សម្នាក់ៗដែលត្រឡប់ទៅរកព្រះអង្គ ដែលទុកចិត្តព្រះអង្គក្នុងគ្រប់រឿងទាំងអស់នឹងមានបទពិសោធន៍ក្នុងការទទួលជំនួយពីព្រះជាម្ចាស់នៅក្នុងពេលជួបទុក្ខលំបាក។ អ្នកនោះនឹងមានបទពិសោធន៍ជាមួយការប្រោសលោះ និងការការពារពីវិញ្ញាណអាក្រក់ ប៉ុន្តែព្រះគម្ពីរមិនដែលសន្យាថាយើងនឹងជៀសផុតពីការទាំងនោះឡើយ។ យើងនៅក្នុងលោកិយ៍ ហើយលោកិយ៍មានពេញដោយអំពើបាប ដូច្នេះយើងមិនអាចជៀសវៀងពីឥទ្ធិពលរបស់វាបានឡើយ។

ទុក្ខលំបាកអាចចែកចេញជាពីរក្រុម។ ទីមួយគឺទុក្ខវេទនាដែលជាផលនៃការសម្រេចចិត្តខាងសីលធម៌ ហើយទី២គឺជាទុក្ខវេនាពីធម្មជាតិ ដែលរួមទាំងគ្រោះធម្មជាតិដូចជាទឹកជំនន់ អគ្គីភ័យ ព្យុះ និងអ្វីផ្សេងទៀត។ តើគ្រោះធម្មជាតិទាំងអស់នេះមកពីព្រះជាម្ចាស់ ឬព្រះអង្គអនុញ្ញាត? មានទេវវិទូខ្លះគិតថាពិតជាដូច្នេះមែន ហើយមានអ្នកខ្លះទៀតគិតថាវាមិនដូច្នេះទេ។ ជាជាងការជជែកវែកញែកផ្នែកទេវវិទ្យា ខ្ញុំគិតថាគ្រោះធម្មជាតិជាការគ្ងូញគ្ងែររបស់ផែនដីក្រោមទំងន់របស់បាប។

តែងតែមានមនុស្សល្អ និងមនុស្សត្រឹមត្រូវដែលតក់ស្លុតព្រោះតែការបាត់បង់ និងទុក្ខលំបាកពីផលនៃគ្រោះធម្មជាតិទាំងអស់នេះ។ ខ្ញុំជ្រើសរើសព្យាយាម និងជួយអ្នកទាំងនោះ ជាជាងការវែកញែកពីមូលហេតុនៃគ្រោះមហន្តរាយដែលកើតឡើងនៅក្នុងកន្លែងដំបូងបំផុត។ មានមនុស្សដែលជឿ និងទុកចិត្តព្រះជាម្ចាស់ ហើយពួកគេរងឥទ្ធិពលមិនអំណោយផលពីគ្រោះធម្មជាតិដូចមនុស្សអាក្រក់ដែរ ហើយយើងមិនអាចពន្យល់រឿងទាំងអស់នេះបានទេ យ៉ាងហោចណាស់ខ្ញុំមិនអាចពន្យល់បានទេ។ ប៉ុន្តែអ្នកដែលទុកចិត្តព្រះជាម្ចាស់អាចមានសេចក្តីសង្ឃឹមអំពីជំនួយ និងការស្តារឡើងវិញ។ ក្តីមេត្តា និងចិត្តសប្បុរសយកឈ្នះលើការថ្កោលទោស។

## *តើសេចក្តីជំនួយមកដល់នៅពេលណា?*

វាហាក់បីដូចជាព្រះជាម្ចាស់ជួយខ្ញុំពេលខ្លះ ហើយពេលខ្លះទៀតព្រះអង្គមិនជួយ។ ទោះបីជាវាហាក់បីដូចជាកើតឡើងដូច្នេះចំពោះខ្ញុំវាមិនមែនជាករណីតែមួយឡើយ។ នៅពេលដែលព្រះជាម្ចាស់មិនផ្តល់ជំនួយដែលខ្ញុំចង់បាន របៀបដែលខ្ញុំចង់បាន ការស្គាល់អាកប្បកិរិយារបស់ព្រះជាម្ចាស់ជួយឲ្យខ្ញុំទុកចិត្តព្រះអង្គថាព្រះអង្គតែងតែជួយ

ខ្ញុំក្នុងផ្លូវដែលល្អបំផុតសម្រាប់ខ្ញុំនៅពេលដែលខ្ញុំសុំព្រះអង្គ។ យើងតែងតែមានចេតនាចង់បាននូវអ្វីដែលយើងប្រាថ្នា ដែលយើងអាចមានអារម្មណ៍ថា បើព្រះជាម្ចាស់មិនប្រទានឲ្យយើងទេ នោះព្រះអង្គមិនជួយយើងសោះនោះឡើយ។ ការកង្វល់ខ្លាំងពេកជាមួយនឹងបំណងខ្លួនឯង និងបណ្តាលឲ្យយើងមិនអាចឃើញអ្វីដែលព្រះជាម្ចាស់កំពុងតែជួយយើង។

បន្ទាប់មកយើងមានបញ្ហានៃពេលវេលា។ ពេលខ្លះយើងអធិស្ឋាន ហើយព្រះជាម្ចាស់ក៏ជួយ និងរំដោះយើងឲ្យរួច ប៉ុន្តែមានពេលខ្លះទៀតជំនួយរបស់ព្រះអង្គនៅលើកាលវិភាគដែលយើងមិនយល់។ បើខ្ញុំឆ្លងកាត់អ្វីមួយ ដែលធ្វើឲ្យខ្ញុំមានទុក្ខវេទនា ហើយព្រះជាម្ចាស់នឹងរំដោះខ្ញុំ ចុះហេតុអ្វីបានជាយើងរង់ចាំអស់ជាច្រើនខែ ឬអាចរាប់ឆ្នាំផងមុនពេលព្រះអង្គធ្វើការនោះ? ព្រះអង្គតែងតែមានហេតុផលរបស់ព្រះអង្គ ប៉ុន្តែព្រះអង្គកម្រប្រាប់ហេតុផលទាំងអស់នោះដល់យើងណាស់។ ព្រះអង្គប្រើទុក្ខវេទនារបស់យើងនៅពេលមួយ ដើម្បីធ្វើការអ្វីមួយនៅក្នុងយើង ដែលយើងមិនអនុញ្ញាតឲ្យព្រះអង្គធ្វើក្នុងពេលវេលាល្អរបស់យើង។

លោក ស៊ី អែស លូវីសបាននិយាយថា៖″ការឈឺចាប់កើតឡើងដោយការដែលយើងចង់ឈឺចាប់។ ព្រះជាម្ចាស់ខ្សឹបដាក់ត្រចៀកយើងនៅពេលយើងមានអំណរ មានបន្ទូលមកក្នុងមនសិការរបស់យើង ប៉ុន្តែព្រះអង្គស្រែកនៅក្នុងការឈឺចាប់របស់យើង។ វាគឺជាសំរែកដ៏លឺបំផុតរបស់ព្រះអង្គទៅកាន់ពិភពលោកដែលកំពុងតែថ្លង់នេះ″។

នៅពេលដែលយើងបានឮពីព្រះជាម្ចាស់ វាមិនប្រាកដថាព្រះអង្គមានបន្ទូលមកកាន់យើងជាលើកដំបូងឡើយ។ ខ្ញុំបានរកឃើញថានៅពេលខ្លះគំនិតរបស់ខ្ញុំផ្ទាល់ចំពោះរឿងអ្វីមួយ រារាំងខ្ញុំពីការទទួលបានគំនិតពីព្រះជាម្ចាស់ ដែលពិតជាខុសពីគំនិតរបស់ខ្ញុំខ្លាំងណាស់។ ខ្ញុំបានបញ្ជាក់មុននេះបន្តិចថាព្រះជាម្ចាស់បានឆ្លើយតមចំពោះភ្នែកស្ងួតរបស់ខ្ញុំ គឺឲ្យខ្ញុំផឹកទឹកឲ្យបានច្រើន ប៉ុន្តែតាំងពីពេលដែលខ្ញុំគិតថាខ្ញុំផឹកទឹកច្រើនមកខ្ញុំមិនបានទទួលចម្លើយរបស់ព្រះអង្គទេ។ ខ្ញុំក្រឡេកមើលក្រោយ ហើយដឹងថាព្រះអង្គបានប្រើមនុស្សពីរបីនាក់ឲ្យនិយាយថា៖«អ្នកប្រហែលជាត្រូវផឹកទឹកច្រើនជាងនេះ»។ ប៉ុន្តែខ្ញុំធ្លាប់ឆ្លើយយ៉ាងលឿនថា៖ «ខ្ញុំបានផឹកទឹកច្រើនហើយ ដែលនោះមិនមែនជាចម្លើយទេ»។

មានបុរសម្នាក់នៅក្នុងគម្ពីរ ២ពង្សាវតាក្សត្រជំពូក ៥ ឈ្មោះថា ណាម៉ាន។ គាត់ជានាយទាហ៊ានរបស់ទ័ពប្រទេសស៊ីរីជាមនុស្សដ៏ក្លាហាន ប៉ុន្តែលោកជាអ្នកកើតឃ្លង់។ គាត់បានទទួលដំណឹងតាមរយៈអ្នកបម្រើរបស់លោកថា លោកហោរាអេលីសេ

អាចប្រោសលោកឲ្យជាបាន។ ដូច្នេះគេក៏នាំ ណាម៉ានមកជួបលោកអេលីសេជាមួយសំបុត្ររបស់ស្ដេចស្រុកស៊ីរី ដែលសុំឲ្យលោកជួយមេទ័ពនោះផង។ នៅពេលដែលណាម៉ានមកដល់ អេលីសេមិនបាននិយាយដោយផ្ទាល់ជាមួយលោកទេ ប៉ុន្ដែផ្ញើសារទៅលោកថា លោកគួរតែទៅសំអាតខ្លួននៅក្នុងទន្លេយ័រដាន់៧ដង ហើយលោកនឹងបានជា។ ណាម៉ានខឹងយ៉ាងខ្លាំងហើយចេញទៅ ព្រោះលោក «គិត» ថាអ្នកបម្រើរបស់ព្រះជាម្ចាស់នឹងមកជួបលោកជាមួយនឹងពិធីយ៉ាងអធិកអធម៌ ហើយប្រោសលោកឲ្យបានជា។ វាហាក់បីដូចជាដោយសារតែលោកជានាយទាហ៊ាន ដោយសារតែលោកធ្លាប់តែគេទទួលស្វាគមន៍លោកជាផ្លូវការ ប៉ុន្ដែនៅពេលនេះវាមិនបានកើតឡើតដូច្នេះឡើយ។

ព្រះគម្ពីរបាននិយាយថាណាម៉ានបានចេញទៅទាំងកំហឹង ហើយនិយាយថា បើគាត់ពិតជាចង់លាងខ្លួននៅក្នុងទន្លេមែន គាត់មិនចាំបាច់ធ្វើដំណើរយ៉ាងឆ្ងាយ ដើម្បីធ្វើការនេះទេ ព្រោះនៅកន្លែងដែលគាត់រស់នៅមានទន្លេល្អជាងនេះទៅទៀត។ ប៉ុន្ដែមានអ្នកបម្រើម្នាក់ក្នុងចំណោមអ្នកបម្រើផ្សេងទៀតបាននិយាយទៅគាត់ថា៖ «លោកឪពុកអើយ បើលោកហោរាបានបង្គំលោកឲ្យធ្វើរឿងធំសម្បើម តើលោកមិនធ្វើទេឬអី»?(២ពង្សាវតាក្សត្រ៥:១៣)។ ព្រះជាម្ចាស់បានប្រើអ្នកបំរើដ៏ទន់ទាបម្នាក់មកបំបាក់អំណួតរបស់ណាម៉ាន ដែលជាអ្វីរារាំងលោកមិនឲ្យលោកទទួលការប្រោសឲ្យជាដែលលោកពិតជាត្រូវការមែនទែន។ តើជាញឹកញាប់យ៉ាងណាទៅដែលយើង «គិត» ថាអ្វីមួយគួរតែជាវិធីពិតប្រាកដ ហើយពេលដែលព្រះជាម្ចាស់ផ្ដល់វិធីផ្សេង (ផ្លូវរបស់ព្រះអង្គ) យើងបែរជាព្រងើយកន្តើយ ដោយសារតែយើងមិនយល់ពីវិធីនោះ ឬក៏យើងខកចិត្តព្រះតែវិធីនោះផង?

ព្រះបន្ទូលរបស់ព្រះជាម្ចាស់ថ្លែងថា«...ចូរឲ្យគ្រប់គ្នាបានឆាប់នឹងស្ដាប់ ក្រនឹងនិយាយ ហើយយឺតនឹងខឹងដែរ» យ៉ាកុប១:១៩។ ខ្ញុំគិតថាយើងអាចនឹងទទួលនូវចម្លើយដែលយើងត្រូវការ ប្រសិនបើយើងប្រឹងស្ដាប់ឲ្យបានប្រសើរជាងអ្វីដែលយើងធ្លាប់ធ្វើពីមុន។ យ៉ាងហោចណាស់ខ្ញុំដឹងវាពិតជាត្រូវចំពោះខ្ញុំ។

ខ្ញុំធ្លាប់ខកចិត្តដោយសារខ្លួនខ្ញុំផ្ទាល់នៅក្មេងខាងជំនឿ និងជាគ្រិស្ដបរិស័ទដែលមិនទាន់ពេញវ័យ ព្រោះខ្ញុំតែងតែចង់ដឹងពីសំណួរថា «ហេតុអ្វី» នៅពីក្រោយអ្វីៗទាំងអស់ដែលខ្ញុំមិនចូលចិត្ត ឬមិនយល់។ ព្រះអង្គអើយ ហេតុអ្វីមានជាចំណាយពេលយូរម្លេះដើម្បីឲ្យព័ន្ធកិច្ចរបស់កូនលូតលាស់? បិតាអើយ ទូលបង្គំកំពុងអធិស្ឋាន ចុះហេតុអ្វីបានជាព្រះអង្គមិនបានផ្លាស់ប្ដូរ បងដេវ និងកូនៗរបស់ទូលបង្គំដូច្នេះ? ឥឡូវនេះខ្ញុំបានទទួលចម្លើយច្បាស់លាស់ហើយថា៖ ព្រះអង្គមិនផ្លាស់ប្ដូរព័ន្ធកិច្ចរបស់ខ្ញុំទេ

ហើយក៏មិនផ្លាស់ប្តូរគ្រួសាររបស់ខ្ញុំដែរ ព្រោះខ្ញុំគឺជាម្នាក់ដែលត្រូវផ្លាស់ប្តូរ ពីមុនខ្ញុំមិនចាស់ទុំគ្រប់គ្រាន់ដើម្បីយល់ពីការផ្លាស់ប្តូរនេះ។បទពិសោធន៍ទាំងនេះបានបង្រៀនខ្ញុំថា ពេលខ្លះព្រះជាម្ចាស់រង់ចាំឆ្លើយ តែដោយសារយើងសួរសំណួរខុសទៅព្រះអង្គ ហើយនៅពេលខ្លះយើងមិនរួចរាល់ក្នុងការទទួលនូវអ្វីដែលយើងកំពុងសុំពីព្រះអង្គ។ បន្ទាត់ក្រោមបំផុតគឺ មិនថាយើងមានសំណួរអ្វីឡើយ ចម្លើយគឺតែងតែដូចគ្នាគឺថា៖ ត្រូវទុកចិត្តព្រះជាម្ចាស់ជានិច្ច!

ពេលខ្លះព្រះជាម្ចាស់រង់ចាំឆ្លើយ តែដោយសារយើងសួរសំណួរខុសទៅព្រះអង្គ។

# ជំពូក ១០

# ហេតុផលដែលនាំអោយយើងរងទុក្ខ

## (ផ្នែកទី ១)

*ចូរអរព្រះគុណព្រះជាម្ចាស់គ្រប់កាលៈទេសៈទាំងអស់ ដ្បិតព្រះអង្គសព្វ ព្រះហឫទ័យអោយបងប្អូន ដែលរួមជាមួយព្រះគ្រិស្តយេស៊ូធ្វើដូច្នេះឯង។*
១ថេស្សាឡូនិក ៥:១៨

ទោះបីយើងនឹងមិនអាចយល់ពីការឈឺចាប់ទាំងស្រុងមែន តែមានរឿងខ្លះដែលយើងអាចរៀនពីវាដែរ ហើយវាជាការឈ្លាសវៃណាស់ដែលធ្វើបែបនេះ។ នៅពេលយើងយល់ពីអ្វីមួយ នោះវាងាយជាងក្នុងការទ្រាំទ្រ ជាជាងយើងពិតជាបានភន្តច្រឡំដោយសារវា។ ពេលណាយើងមិនយល់ពីវា នោះ យើងអាចនឹងមានការពិបាកទ្វេដងក្នុងការទ្រាំទ្រនឹងវា។ ខ្ញុំបានរកឃើញជាច្រើននូវចម្លើយដែលថា ហេតុអ្វីការឈឺចាប់កើតមានដល់ខ្ញុំ តាមរយៈដំណាក់កាលនៃការលូតលាស់ខាងវិញ្ញាណ។ ឧទាហរណ៍ ខ្ញុំបានដឹងថា ការរងទុក្ខមួយចំនួនជាក់ស្តែង ជាប្រយោជន៍ដល់ខ្ញុំ។ ហើយខ្លះទៀត ខ្ញុំត្រូវឱបក្រសោប និងទុកឲ្យវាកើតឡើងតាមតែវាកើតនៅក្នុងខ្ញុំ ហើយក៏នៅមានខ្លះទៀតដែលខ្ញុំត្រូវឈរឲ្យមាំតទល់នឹងវា ពីព្រោះវាជាបំណងរបស់សាតាំងចង់បំផ្លាញខ្ញុំ។ ទៅថ្ងៃអនាគត់ ដូចខ្ញុំបន្តលូតលាស់នៅ ក្នុងព្រះជាម្ចាស់ ប្រហែលជាខ្ញុំយល់ដឹងពីវាថែមទៀត ក៏ប៉ុន្តែឥឡូវនេះ ខ្ញុំត្រូវចែករំលែកដល់អ្នករាល់គ្នា នូវអ្វីដែលខ្ញុំបានដឹង។

ការដឹងគុណសំរាប់ព្រះពរជាច្រើននៅក្នុងជីវិតរបស់យើង គឺដូចជាថ្នាំប៉ូវកម្លាំងឲ្យតយុទ្ធនឹងជីវិតដែលរងទុក្ខ។ យើងកាន់តែផ្តោតលើការរងទុក្ខរបស់យើងប៉ុណ្ណា យើងក៏កាន់តែរងទុក្ខប៉ុណ្ណោះដែរ ប៉ុន្តែដើម្បីរកអ្វីៗដែលត្រូវអរព្រះគុណ និងផ្តោតលើរឿងរ៉ាវនោះគឺមានប្រយោជន៍ជាង។ បើមានអ្នកជឿថា ព្រះជាម្ចាស់ល្អ នោះទោះបីជាគេស្ថិតនៅកណ្តាលនៃការរងទុក្ខដ៏អាក្រក់បំផុតក៏ដោយ ក៏គេនៅតែបង្ហាញទំនុកចិត្តក្នុងព្រះជាម្ចាស់ខ្លាំងដដែល ហើយឈរមាំគ្រប់រដូវកាលនៃជីវិតដែរ។ ពាក្យសំដី

ដែលប្រកបដោយការដឹងគុណរបស់យើងក្នុងពេលកំពុងប្រឈមនឹងទុក្ខលំបាក ជាពិសេសការឈឺចាប់ដោយរឿង អយុត្តិធម៌ នោះជាការបញ្ជាក់ដ៏មុតមាំនៃសេចក្តីទុកចិត្តរបស់យើងនៅក្នុងព្រះជាម្ចាស់ជាជាងអ្វីផ្សេងៗ ទៀតដែលខ្ញុំធ្លាប់ដឹង។

ការរងទុក្ខលំបាកគឺមានពិត ហើយវាឈឺចាប់ទៀតផង។ វាមានពេលខ្លះគួរឲ្យរន្ធត់ ហើយហាក់ដូចជាមិនអាចទ្រាំទ្រយកបានផង។ វាអាចជារូបកាយ វិញ្ញាណ គំនិត អារម្មណ៍ ហិរញ្ញវត្ថុ ឬទំនាក់ទំនងក៏មាន។ ព្រះយេស៊ូ បានរងទុក្ខលើសជាងយើងទាំងអស់ដែលធ្លាប់រងទុក្ខទៅទៀត ឯព្រះបន្ទូលនៃព្រះថ្លែងថា ព្រះអង្គបានរៀនស្តាប់បង្គាប់តាមរយៈអ្វីដែលព្រះអង្គបានរងឈឺចាប់ (សូមអានព្រះគម្ពីរហេប្រឺរ៥:៨)។ ព្រះយេស៊ូមិនដែលបានមិនស្តាប់បង្គាប់សោះឡើយ។ ព្រះអង្គនៅតែអរព្រះគុណ ហើយតែងតែបង្ហាញខ្លួនដោយកិរិយានៃក្តីស្រឡាញ់។ ប៉ុន្តែ តាមរយៈការឈឺចាប់របស់ព្រះអង្គ ទ្រង់បានស្រង់បទពិសោធពីអ្វីដែលហៅថា ការស្តាប់បង្គាប់ព្រះជាម្ចាស់ដែលតែងតែត្រូវបង់ថ្លៃ ហើយព្រះអង្គតែងរួចរាល់ នឹងបង់ថ្លៃដើម្បីឲ្យបានបំពាក់ខ្លួនរៀបចំបំរើ ជាកាន់អំណាច និងក៏ជាប្រភពនៃការសង្គ្រោះរបស់យើង (សូមមើលគម្ពីរហេប្រឺរ៥:៩ ១២:២)។ ព្រះអង្គគឺជា មហាបូជាចារ្យដែលយល់អំពីគ្រប់ការឈឺចាប់នៅក្នុងជីវិតរបស់យើង (សូមមើលគម្ពីរហេព្រើរ៤:១៥)។ ព្រះយេស៊ូមិនដែលឲ្យយើងទៅកន្លែងណាដែលព្រះអង្គមិនដែលធ្លាប់យាងទៅនោះទេ។ ការនេះលួងលោមខ្ញុំដោយដឹងថា ព្រះអង្គតែងតែយាងទៅមុនខ្ញុំ ហើយរៀបចំផ្លូវដែលខ្ញុំនឹងដើរទៅនោះ។

> ព្រះយេស៊ូមិនដែលសុំយើងទៅកន្លែងណាដែលព្រះអង្គមិនធ្លាប់យាងទៅទេ។

ដោយមានការខ្លះៗនៅក្នុងគំនិតរបស់យើង ទុកឲ្យខ្ញុំឲ្យការបីបួនយ៉ាងទៅអ្នកដើម្បីពិចារណានៅពេល ដោះស្រាយជាមួយនឹងការរងទុក្ខដែលយើងប្រឈមនៅក្នុងជីវិតនេះ។

## *អំពើបាបគឺជាឫសគល់គ្រប់ការរងទុក្ខ*

យើងទើបតែបានលើកឡើងថា បាបរបស់យើងផ្ទាល់ និងបាបរបស់អ្នកផ្សេង ឬ លទ្ធផលនៃការរស់នៅក្នុងអំពើបាប និងពិភពដែលអាក្រក់ គឺបង្កឲ្យមានការឈឺចាប់។ ក៏ប៉ុន្តែខ្ញុំចង់បើកបង្ហាញឲ្យឃើញ បន្ថិចថែមទៀត ធ្វើដូច្នេះយើងកាន់តែមានការយល់ដឹងបន្ថែមទៀត។ ព្រះហឫទ័យដ៏ពិតរបស់ព្រះជាម្ចាស់នោះគឺ ព្រះអង្គមិនចង់ឲ្យយើងរាល់គ្នាជួបនឹងទារុណកម្ម និងសង្គ្រៀតធ្មេញទេ ហើយនោះជា ការដែលមិនត្រូវ

ទេ ដែលមកបន្ទោសព្រះអង្គដោយសាររឿងអស់នោះ។

រឿងមួយដែលពេលខ្លះយើងភាគច្រើនរងទុក្ខនៅក្នុងជីវិតនោះគឺជម្ងឺ។ ពេលយើងឮថា បាប និង ជម្ងឺ គឺតែងតែផ្សារជាប់គ្នា វាងាយនឹងយកខ្លួនឯងមកធ្វើការព្យាយាមពិចារណា និងដាក់ខ្លួនឯងទៅនឹងបាបរបស់យើង។ ថ្វីបើការនោះពិតក៏ដោយដែលថា កិច្ចការខ្លះដែលខ្ញុំបានធ្វើ បានបង្កឲ្យមានជម្ងឺ តែវាក៏មិនបែបនេះរហូតដែរ ឬមិនសូម្បីតែជាធម្មតាផងរឿងបែបនេះ។

គ្មានឧទាហរណ៍នៅក្នុងគម្ពីរដែលព្រះយេស៊ូភ្ជាប់បាបមួយណាជាក់លាក់ទៅនឹងជម្ងឺ ឬ រោគាទេ។ ព្រះអង្គគឺជា អ្នកប្រោសអោយជារបស់យើង ហើយព្រះអង្គតែងតែបានប្រើវិធីប្រោសនេះ ដែលជារបៀបជំរុញ មនុស្សថា បើជឿថាព្រះអង្គអាចប្រោសមនុស្ស នោះព្រះអង្គក៏អាចអត់ទោសបាបបានដែរ (សូមមើលម៉ាកុស ២:៩-១១)។ តាមការសិក្សាព្រះបន្ទូលនៃព្រះជាម្ចាស់ឲ្យស៊ីជម្រៅ បង្ហាញឲ្យឃើញថា ការប្រោសអោយជាគឺល្អដូចជាការអត់ទោសបាបដែរ ដែលមានរួមនៅក្នុងយញ្ញបូជារបស់ព្រះគ្រិស្តហើយ(សូមមើលគម្ពីរអេសាយ៥៣:៤-៥)។ ព្រះជាម្ចាស់ មិនសាមញ្ញពេក ដូចជាអ្នកប្រោសរបស់យើងផង ជាបង្កឲ្យកើតមានជម្ងឺផងទេ។ ចូរយើងដោះស្រាយរឿងនេះពេលណាមួយ ហើយគ្រប់ទាំងអស់ដែលនៅក្នុង ចិត្តរបស់យើង គឺថា ព្រះជាម្ចាស់ល្អ ហើយមារគឺអាក្រក់។

នៅពេលរដូវត្រជាក់ និងគ្រុនផ្តាសាយចូលមកដល់រៀងរាល់ឆ្នាំ មនុស្សគ្រប់គ្នារងទុក្ខដោយប៉ះពាល់ ពីជម្ងឺទាំងនេះ ទាំងមនុស្សល្អ ទាំងអាក្រក់ ទាំងក្មេង និងទាំងចាស់ផងដែរ! វាហាក់ដូចជាដដែលៗ ហើយគួរឲ្យសង្ស័យណាស់ថា អ្នកដែលកើតគ្រុនផ្តាសាយនោះគឺជាមនុស្សបាប ហើយអស់អ្នកដែលមិនផ្តាសាយ គឺជាមនុស្សគ្មានបាប។ ទោះយ៉ាងណាក៏ដោយ ខ្ញុំគិតថា វាជារឿងដែលឆ្លាតវៃជាជាង នៅពេលយើងមានជម្ងឺ ដោយសួរព្រះជាម្ចាស់ ប្រហែលជាយើងបានបើកទ្វារដោយរបៀបណាមួយសំរាប់ឲ្យជម្ងឺចូលមក។ ជាញឹកញាប់ យើងមិនបានប្រតិកម្មដោយឈ្លាសវៃក្នុងរបៀបដែលយើងត្រូវការពារខ្លួនឯង ហើយវាបានធ្វើឲ្យប្រព័ន្ធកោសិការបស់យើងទៅជាខ្សោយ ដែលជាហេតុធ្វើឲ្យយើងងាយនឹងប្រឈមនឹងជម្ងឺ ជាជាងយើងគួរមានអាកប្បកិរិយាដែលប្លែក។ ថ្វីបើព្រះជាម្ចាស់អាចបង្ហាញយើងខ្លះថា យើង គួរជៀសវាងនៅពេលក្រោយ ហើយក៏មានពេលខ្លះដែលព្រះអង្គមិនបង្ហាញដែរ។ ពេលព្រះអង្គស្ងាត់ស្ងៀម ខ្ញុំទូលសូមយ៉ាងសាមញ្ញសំរាប់ការប្រោសឲ្យជា ហើយទុកចិត្តព្រះជាម្ចាស់ថា ព្រះអង្គមុខជាធ្វើឲ្យការល្អកើតឡើង។

ការនេះងាយយល់ទេ បើយើងនិយាយអំពីរឿងគ្រុនឬផ្តាសាយ ប៉ុន្តែវានឹងទៅជាពិ

បាក ពេលជម្ងឺនោះគឺជាមហារីក ឬអ្វីផ្សេងទៀតដែលបង្កការចុកចាប់ ជាពេលមួយដែលគំរាមគំហែងអាយុជីវិត។ ពេលដែលកាន់តែចុកចាប់ ក៏ជាពេលដែលយើងកាន់តែពិបាកនឹងយល់ពីវាដែរ។

ខ្ញុំមានជម្ងឺមហារីកដោះក្នុងឆ្នាំ១៩៨៩ ហើយថ្មីៗនេះខ្ញុំបានដឹងថា ខ្ញុំមុខជាអាចគេចផុតពីជម្ងឺនេះបានបើខ្ញុំថែទាំរាងកាយរបស់ខ្ញុំឲ្យឆ្លាតវៃជាងពេលនោះ។ ក្នុងជីវិតរបស់ខ្ញុំពេលនោះ ព័ន្ធកិច្ចរបស់ យើងកើតឡើងថ្មីទេ ហើយខ្ញុំក៏រស់នៅក្រោមភាពស្មុគស្មាញទៀត ពីព្រោះខ្ញុំមិនបានដឹងច្រើនអំពីការទុកចិត្តព្រះជាម្ចាស់ ហើយនិងការអត់ធ្មត់ទេ។ លើសពីនេះ ខ្ញុំក៏ព្យាយាមអភិវឌ្ឍន៍ព័ន្ធកិច្ចថែមទៀតផង ខ្ញុំបានដើរកាត់តាមដំណាក់កាលនៃការប្រោសឲ្យជា ជាមួយនឹងព្រះជាម្ចាស់ ហើយនោះជាការឈឺចាប់និងពិបាកណាស់។ ខ្ញុំពុំបានគេងលក់គ្រប់គ្រាន់ទេ ហើយក៏មិនបានហាត់ប្រាណទៀងទាត់ដែរ ឯការងារវិញក៏ច្រើន ខ្ញុំសំរាក់មិនគ្រប់ទេ ទទួលទានអាហារអន់ៗ រួចផឹកកាហ្វេច្រើន ចំណែកទឹកបន្តិចបន្តួចប៉ុណ្ណោះ ខ្ញុំឆាប់ខឹង ហើយព្រួយចិត្តច្រើន ទាំងខកចិត្តនិងល្ងើយទៅៗ។ ជាលទ្ធផលនោះគឺ ភាពស្មុគ ស្មាញបង្កឲ្យកោសិកាលូតលាស់មិនស្មើគ្នា ធ្វើឲ្យរដូវមកមិនទៀង ហើយខ្ញុំត្រូវទៅជួបនឹងគ្រូពេទ្យ ជាអ្នកណែនាំឲ្យខ្ញុំត្រូវវះកាត់យកស្បូនចេញ និងបណ្តុះកោសិកាបន្តពូជឡើងវិញ។ វាជួយបានបន្តិចបន្តួចដែរ តែចុងក្រោយ ខ្ញុំត្រូវទៅបាញ់ចេញរៀងរាល់១០ថ្ងៃម្តង។ មួយឆ្នាំក្រោយមក ខ្ញុំបានធ្វើការវិភាគជា មួយនឹងកោសិការបន្តពូជដែលឯករាជ្យនៃដុំសាច់ដោះ។ និយាយម្យ៉ាងទៀតថា វាបានបំពេញ និងបាន វិវត្តន៍នូវការលូតលាស់កោសិកា នេះជាលទ្ធផល។ មហារីកបែបនេះ បានលូតលាស់យ៉ាងលឿន ហើយគ្រោះថ្នាក់ផងដែរ ខ្ញុំត្រូវតែធ្វើការវះកាត់បន្ទាន់មួយ។

ព្រះជាម្ចាស់ពុំបានដាក់ទោសខ្ញុំក្នុងកាលៈទេសៈនេះ ឬស្តីបន្ទោសខ្ញុំដោយសារខ្ញុំមិនបានមើល ថែទាំរូបកាយរបស់ខ្លួនឯងមិនល្អនោះទេ។ ការវះកាត់បានជោគជ័យ ហើយខ្ញុំមិនចាំបាច់ត្រូវការការព្យាបាលទៀតទេ។ សំរាប់ខ្ញុំ ការនេះគឺជាការអស្ចារ្យ។ ប៉ុន្តែព្រះជាម្ចាស់បានប្រើឱកាសនោះ ដើម្បីចាប់ផ្តើមបង្រៀនខ្ញុំថា ការស្រឡាញ់រូបកាយរបស់ខ្ញុំជារឿងដ៏សំខាន់ ព្រោះរូបកាយនេះគឺជាដំណាក់របស់ព្រះអង្គ មកដល់ពេលនេះ ខ្ញុំធ្វើការសំរេចចិត្តធ្វើអ្វីដែលប្រសើរជាងមុនជាប្រចាំថ្ងៃចំពោះ សុខភាពរូបកាយរបស់ខ្ញុំ។ ខ្ញុំបានមកដល់ចំណុចមួយដែលជឿជាក់ថា យើងត្រូវបានលោះដោយការបង់ថ្លៃ ហើយក៏កម្មសិទ្ធិរបស់ព្រះជាម្ចាស់ដែរ រូបកាយរបស់យើងជាដំណាក់ (ផ្ទះ) របស់ព្រះជាម្ចាស់ ហើយកាលណាយើងមិនស្រឡាញ់ រួចមកបំពានរូបកាយរបស់ខ្លួននោះគឺជាអំពើបាប។ បើគំនិតនេះ វាលើសលប់ចំពោះអ្នក ដូច្នេះពេលនេះ ចូរដាក់វា

ទៅម្ខាងសិនចុះ ប៉ុន្តែខ្ញុំជំរុញឲ្យអ្នកឲ្យតម្លៃខ្លួនឯងឲ្យ បានគ្រប់គ្រាន់ ហើយមើលថែខ្លួនឯងឲ្យល្អជាងនេះទៀត។

ខ្ញុំបានរកឃើញ ពេលខ្ញុំនិយាយជាមួយមនុស្សជាច្រើន អាចភាគច្រើនផងដែរ ដែលមិនឲ្យតម្លៃរូបកាយរបស់ខ្លួន។ យើងរាល់គ្នាអាចមានការយល់ដឹងទាបអំពីគុណតម្លៃនៃការរស់នៅប្រកបដោយសុខភាពល្អ ដោយហេតុនេះហើយ យើងត្រូវស្វែងរកព្រះជាម្ចាស់ ស្វែងយល់អំពីប្រភពពិតនៃជម្ងឺផ្សេងៗដែលយើងមាន។ ខ្ញុំណែនាំឲ្យអ្នករាល់គ្នាចំណាយពេលអានសៀវភៅល្អមួយ និយាយពីរបៀបរស់នៅនៃវិញ្ញាណ ព្រលឹង និងរូបកាយដែលប្រកបដោយសុខភាពល្អ ហើយខ្ញុំពិតជាជឿជាក់ថា វានឹងបើកភ្នែក របស់លោកអ្នកឲ្យឃើញអ្វីៗជាច្រើនដែលពីមុនលោកអ្នកមើលមិនឃើញ។

ព្រះជាម្ចាស់មានមេត្តា និងពេញដោយព្រះគុណចំពោះខ្ញុំនៅពេលខ្ញុំមានមហារីក ហើយបើមើលពីខាងក្រៅ មិនគួរបានប្រសើរឡើយ។ ខ្ញុំចង់ចែកចាយបទពិសោធន៍របស់ខ្ញុំឲ្យបានច្បាស់ថា ខ្ញុំគ្មានផ្លូវណាផ្សេងទៀតក្រៅពីនិយាយថា អ្នកដែលមានមហារីកគឺគេមើលថែខ្លួនមិនបានត្រឹមត្រូវឡើយ។ ខ្ញុំមិនដឹងហេតុផលទាំងអស់ដែលនៅពីក្រោយជម្ងឺ និងរោគាក៏ពិតមែន ប៉ុន្តែខ្ញុំដឹងថា យើងគួរតែវិនិយោគក្នុងសុខភាព ហើយនៅឲ្យរឹងមាំតាមតែអាចធ្វើទៅបាន។ សាតាំងក្រវែលផែនដីរកមើលអ្នកដែលវាអាចចាប់ចងនិងលេបត្របាក់ ហើយខ្ញុំនឹងធ្វើគ្រប់បែបយ៉ាងតាមតែអាចធ្វើបាន ដើម្បីឲ្យច្បាស់ថា មិនមែនខ្ញុំទេ ជាគោលដៅរបស់វា។ ព្រះគម្ពីរ ១ពេត្រុស ៥:៨ "ត្រូវភ្ញាក់ខ្លួន ហើយប្រុងស្មារតីជានិច្ច! ដ្បិតមារ ជាសត្រូវនឹងបងប្អូន កំពុងតែក្រវែលជុំវិញបងប្អូនដូចសឹង្ហក្រវែលទាំងគ្រហឹមរកត្របាក់ស៊ីអ្នកណាម្នាក់"។ លោកពេត្រុសប្រាប់យើងឲ្យប្រុងស្មារតីឲ្យបានល្អ ដើម្បីរួចផុតពីការលេបត្របាក់។ ខ្ញុំពិតជាពុំបានប្រុងស្មារតីឡើយពេលខ្ញុំស្ថិតក្នុងជីវិតពេលនោះ។ យើងមិនអាចបំពានច្បាប់សុខភាពរបស់ព្រះជាម្ចាស់ ដែលមាននៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ ហើយរំពឹងថានឹងគ្មានជម្ងឺអ្វីប៉ះពាល់ឡើយ។ យ៉ាងហោចណាស់ យើងក៏នឹងអស់កម្លាំងដែរ បើយើងមិនមើលថែខ្លួនឲ្យល្អទេនោះ។

ថ្មីៗនេះ ខ្ញុំបានវះកាត់ប្តូរឆ្អឹងជំនី ដោយសារខះទឹកសន្លាក់ និងសន្លាក់នៃឆ្អឹងជំនីមិនត្រូវគ្នានៅក្នុងរាងកាយរបស់ខ្ញុំ។ ទោះជាយ៉ាងណា ខ្ញុំបានអស្ចារ្យក្នុងចិត្តដោយបានជាសះឡើងវិញល្អ ថ្វីដ្បិតខ្ញុំធ្លាប់ ចុកចាប់យ៉ាងខ្លាំងដោយសារលំហាត់ប្រាណដែលប៉ះពាល់ពីផ្នែកណាមួយនៃរាងកាយក្តី។ ការចុកចាប់នោះ គឺរបៀបដែលរាងកាយរបស់ខ្ញុំប្រាប់ខ្ញុំឲ្យបន្ថយល្បឿន បន្ថយសកម្មភាព ហើយអត់ធ្មត់ឲ្យបានច្រើន

ជាងនេះវិញ។ គ្រូពេទ្យរបស់ខ្ញុំក៏បានប្រាប់ខ្ញុំដែរថា ទុកឲ្យការចុកចាប់ជាអ្នកណែនាំអ្នកថា អ្វីដែលអ្នកគួរធ្វើ អ្វីដែលមិនគួរធ្វើ។ លោកបាននិយាយថា "បើអ្នកធ្វើកិច្ចការច្រើនថ្ងៃមួយ នោះអ្នកនឹងបង្កើនការ ឈឺចុកចាប់ច្រើននៅថ្ងៃបន្ទាប់ ដូច្នេះចូរបន្ថយសកម្មភាពរបស់អ្នក រួចទុកឲ្យការឈឺចុកចាប់ស្ងប់ទៅវិញចុះ"។

លោកប៉ូលបានសរសេរសំបុត្រផ្ញើទៅអ្នកអេភេសូថា "ហេតុនេះ ចូរបងប្អូនប្រើគ្រឿងសស្ត្រាវុធទាំងប៉ុន្មានរបស់ព្រះជាម្ចាស់ទៅ ដើម្បីអោយបងប្អូនអាចតទល់នៅថ្ងៃអពមង្គល ហើយមានជំហររឹងប៉ឹងដដែល ដោយបានប្រើគ្រប់មធ្យោបាយ" (មើលអេភេសូរ៦:១៣)។ នៅឲ្យជាប់នឹងព្រះគ្រិស្ត ឲ្យជាប់នឹងសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយទុកចិត្តព្រះអង្គឲ្យប្រោសអ្នកឲ្យជា។ ចូរធ្វើអ្វីដែលព្រះជាម្ចាស់ បង្គាញអ្នកឲ្យធ្វើ ហើយសំរាកក្នុងសេចក្តីស្រឡាញ់របស់ព្រះអង្គ រួចសង្ឃឹមលើការស្តារឡើងវិញរួមទាំងការប្រោសជម្ងឺឲ្យជាទាំងស្រុងផងដែរ។

## *មនុស្សឆ្លាតរងទុក្ខតិចជាងមនុស្សឆោតល្ងង់*

យ៉ាងណាក៏មនុស្សឆ្លាតវៃមិនអាចគេចផុតពីការឈឺចាប់ទាំងអស់បានដែរ គាត់អាចនឹងរួចផុតពីទុក្ខ លំបាកជាច្រើនដែលមនុស្សល្ងង់មិនអាចគេចផុត។ បើយោងតាមច្បាប់របស់ព្រះជាម្ចាស់ យើងនឹងច្រូតកាត់ពីអ្វីដែលយើងសាបព្រោះ (មើលកាឡាទី ៦:៧ ម៉ាថាយ ៧:១-២ លូកា ៦:៣១)។ ចំពោះខ្ញុំ វាជាការគិតដែលស្រគត់ស្រគំ ហើយជាការមួយដែលយើងគួរចងចាំរៀងរាល់ថ្ងៃ។

បើមនុស្សម្នាក់មិនបានស្មោះត្រង់នឹងភរិយារបស់ខ្លួនពីរបីដងហើយ នោះគាត់នឹងឈឺចាប់យ៉ាងដំណំដោយបាត់បង់ទំនាក់ទំនង។ នោះជាកំហុសរបស់គាត់ ហើយគាត់កំពុងច្រូតកាត់ពីអ្វីដែលគាត់បានសាបព្រោះប៉ុណ្ណោះ។ បើមានម្នាក់ចំណាយយ៉ាងហួសហេតុ ទាំងផ្លូវអារម្មណ៍ នោះចុងបញ្ចប់គឺនឹងមានសំពាធដោយបំណុល ហើយនោះជាកំហុសរបស់គាត់ផ្ទាល់ ដោយសារគាត់បានព្រោះភាពល្ងីល្ងើ រួចពេលនេះគឺជាលទ្ធផលច្រូតកាត់មកវិញហើយ។ ព្រះគម្ពីរសុភាសិតមានអំណះអំណាងយ៉ាងច្រើនអំពីរឿងល្ងីល្ងើដោយសម្តីដែលនឹងបង្ករឹកវរក្នុងជីវិតរបស់ខ្លួន។ ខាងក្រោមនេះជាឧទាហរណ៍មួយ៖

> សំដីរបស់មនុស្សខ្លៅបណ្តាលអោយមានការឈ្លោះប្រកែកគ្នា ពេលណាអ្នកនោះនិយាយរមែងធ្វើអោយមានការវាយតប់គ្នា។

> មាត់របស់មនុស្សខ្លៅរមែងធ្វើអោយខ្លួនវិនាស ហើយពាក្យសំដីរបស់អ្នកនោះ ជាអន្ទាក់សំរាប់ដាក់ខ្លួនឯង។
>
> សុភាសិត ១៨:៦-៧

ក៏មានព្រះបន្ទូលជាច្រើនទៀត ដែលបង្រៀនយើងអំពីផលនៃពាក្យសម្ដីរបស់មនុស្សឆ្លាតដែរ។ ខាងក្រោមនេះ គឺជាឧទាហរណ៍មួយៈ

> អ្នកដែលនិយាយប៉ប៉ាច់ប៉ប៉ោច តែងតែធ្វើអោយអ្នកដទៃរបួស ដូចចាក់មួយដាវ រីឯពាក្យសំដីរបស់មនុស្សមានប្រាជ្ញា ជាឱសថព្យាបាលមុខរបួស។
>
> សុភាសិត ១២:១៨

លើសពីនេះ ការខិតខំនិយាយពាក្យសម្ដីប្រកបដោយប្រាជ្ញា យើងក៏អាចជ្រើសរើសសកម្មភាពដ៏ឆ្លាតវៃដែរ។ ព្រះគម្ពីរសុភាសិតបង្រៀនយើងថា ប្រាជ្ញាគឺមានតម្លៃបំផុតដែលយើងអាចស្វែងរកតាម និង ប្រតិបត្តិក្នុងនោះ។ សេចក្ដីសន្យាបានធ្វើឡើងចំពោះមនុស្សឆ្លាត គឺមានច្រើនបរិបូរណ៍ និងគួរប្រាថ្នាដូចជា៖ ការគាប់ចិត្ត ភាពមានបាន អាយុវែង ការលើកកម្ពស់ ភាពច្បាស់លាស់ ការការពារ នៅមានច្រើនទៀត។

វាច្បាស់ណាស់ថា យើងមិនច្រូតកាត់ ឬជួបដោយផ្ទាល់ភ្លាមៗនូវផលដែលកើតចេញពីជម្រើសដ៏ល្ងីល្ងើដែលយើងបានធ្វើទេ បើដូច្នោះមែន នោះយើងនឹងជួបភាពរឹកររមិនខាន។ ប្រសើរណាស់ ដោយយើងអាចទទួលការអត់ទោស និងព្រះគុណ ពីព្រះជាម្ចាស់ ក៏ប៉ុន្តែបើយើងនៅតែទទឹង សាបព្រោះភាពល្ងីល្ងើទៀត នោះយើងនឹងច្រូតផល និងភ្លក្សនូវការឈឺចាប់ខ្លះមិនខាន។

យើងរស់នៅក្នុងពិភពលោកដែលបានសង់លើគ្រឹះនៃសីលធម៌ ហើយក៏មានផលសំរាប់កិរិយា អសីលធម៌ផងដែរ។ ឧទាហរណ៍៖ បើមានម្នាក់ទទួលទានសុរា ហើយបើករថយន្ត គេអាចនឹងត្រូវរបួស ឬក៏បង្ករបួសដល់អ្នកដទៃ។ បើមានម្នាក់មានកំហឹងជាញឹកញយ គេអាចនឹងគ្មាននរណារាប់រក។ បើមានគេសម្លាប់មនុស្ស គេអាចនឹងទទួលការអត់ទោស ប៉ុន្តែក៏ត្រូវចំណាយជីវិតរបស់គេនៅក្នុងគុកផងដែរ។ វាប្រហែលជាល្អ បើយើងចំណាយពេលនៃថ្ងៃនីមួយៗគិតអំពីរបៀបដែលយើងនិយាយ និងធ្វើសកម្មភាពដែលអាចមានផលប៉ះពាល់នោះ។ ធ្វើបែបនេះ អាចនាំឲ្យយើងធ្វើការសំរេចចិត្តឆ្លាតជាងសព្វដង។

លោកសាវ័កពេត្រុសនិយាយអំពីការឈឺចាប់ដែលយើងសមទទួល និង មិនសម

ទទួល។ លោក ថ្លែងថា ការដែលឈឺចាប់ពីភាពអយុត្តិធម៌ដោយបានធ្វើរឿងត្រឹមត្រូវ នោះប្រសើរជាងការឈឺចាប់ពីការ ដែលបានធ្វើរឿងមិនត្រឹមត្រូវ (មើល ១ពេត្រុស ២:១៩-២០ និង ៤:១៥-១៦)។

ខ្ញុំអាចនិយាយយ៉ាងច្បាស់ថា ខ្ញុំកាន់តែរៀនព្រះបន្ទូលព្រះ ខ្ញុំក៏កាន់តែទទួលបានប្រាជ្ញា ហើយកាន់តែអនុវត្តនៅក្នុងជីវិត នោះខ្ញុំក៏កាន់តែមានការឈឺចាប់តិចទៅៗដែរ។ ព្រះគម្ពីរ គឺជាការណែនាំសំរាប់ជីវិត! ហើយជួយយើងឲ្យមានការប្រុងប្រយ័ត្នរៀងរាល់ពេលយើងធ្វើការសំរេចចិត្ត ធ្វើអ្វីៗដែលសំខាន់ ពីព្រោះជម្រើសនីមួយៗក៏មាននូវលទ្ធផលរបស់វាផងដែរ។ អស់អ្នកណាដែលប្រព្រឹត្តតាមព្រះបន្ទូលរបស់ព្រះ នឹងមិនក្លាយជាជនរងគ្រោះទេ ពីព្រោះវាមិនគ្រាន់តែធ្វើឲ្យការសំរេចិត្តនោះជួយគេឲ្យឈ្នះប៉ុណ្ណោះទេ ប៉ុន្តែគេថែមទាំងអាចរៀនការនោះថែមទៀតផង។ ខ្ញុំធ្លាប់ជាទាសករនៃការរំលោភបំពានផ្លូវភេទមុនខ្ញុំបានរៀនព្រះបន្ទូលរបស់ព្រះទៅទៀត ប៉ុន្តែពេលនេះខ្ញុំមានសេរីភាពពីវាហើយ ពីព្រោះខ្ញុំបានធ្វើនូវជម្រើសដែលស្របនឹងផ្លូវរបស់ព្រះជាម្ចាស់។

## *យើងនឹងរងទុក្ខការបៀតបៀនដោយព្រោះ សេចក្ដីជំនឿរបស់យើងជាគ្រិស្តបរិស័ទ*

លោកសាវកប៉ូលបានសរសេរសំបុត្រផ្ញើទៅលោកធីម៉ូថេរដើម្បីរំលឹកគាត់ អស់អ្នកណាដែលព្យាយាមរស់នៅ ដោយគោរពកោតខ្លាចព្រះជាម្ចាស់ នឹងរងទុក្ខដោយការបៀតបៀន ពីព្រោះតែជំហររបស់ពួកគេ (មើលព្រះគម្ពីរ ២ធីម៉ូថេរ ៣:១២)។ លោកសាវកប៉ូលក៏ធ្លាប់បាននិយាយថា ថ្វីដ្បិតគាត់បានរងការបៀតបៀនជាច្រើនមែន តែព្រះជាម្ចាស់បានរំដោះគាត់ពីការនោះទាំងអស់ (មើលព្រះគម្ពីរ២ធីម៉ូថេរ ៣:១១)។ ខ្ញុំពិតជាមានសេចក្ដីដឹងគុណណាស់ ដោយគ្រប់ពេលនៃការឈឺចាប់ យើងមានសេចក្ដីសន្យាពីការសង្គ្រោះ ហើយមានអភ័យឯកសិទ្ធិទុកចិត្តព្រះសំរាប់ការសង្គ្រោះនោះផងដែរ។ យើងត្រូវតែមានការអត់ធ្មត់ និងរឹងមាំពេលការលំបាកមកដល់ ប៉ុន្តែព្រះជាម្ចាស់ស្មោះត្រង់ ព្រះអង្គរំដោះយើង ហើយថែមទាំងចំរើនកម្លាំងយើងឲ្យមានសមត្ថភាពតយុទ្ធនឹងភាពរឹករវជាមួយនឹងកិរិយាមាយាទល្អ បើយើងមានឆន្ទៈចង់ធ្វើមែននោះ។

មានពួកយើងតិចទេដែលបានឆ្លងកាត់ការបៀតបៀន។ ជាញឹកញយ ការបៀតបៀនមកក្នុងទម្រង់បដិសេធពីគ្រួសារនិងមិត្តភ័ក្រ។ បទពិសោធន៍ផ្ទាល់របស់ខ្ញុំត្រង់

ចំណុចនេះគឺជ្រាលជ្រៅគួរសមហើយឈឺចាប់ណាស់។ បន្ទាប់ពីនោះ មានការត្រាស់ហៅឲ្យខ្ញុំបង្រៀនព្រះបន្ទូលព្រះ ខ្ញុំធ្លាប់គេប្រាប់ឲ្យដើរចេញពីក្រុមជំនុំរបស់ខ្ញុំ ហើយរងការបដិសេធពីគ្រួសារ និងមិត្តភ័ក្ត្រថែមទៀតផង។ ជាមនុស្ស មិនស្រួលទេ ក្នុងការស្វែងរកភាពរួបរួមនៅក្នុងភាពបែកបាក់នោះ។ យើងចង់ឲ្យមនុស្សគ្រប់គ្នាដូចជាយើង បើមិនដូច្នោះទេ យើងមានអារម្មណ៍ថា ការគិត យោបល់ និងសកម្មភាពរបស់យើងនឹងរងការវាយប្រហារមិនខាន។

ខ្ញុំបានបោះជំហានចេញពីភាពធម្មតា និងបានទទួលយកតំណែងសំរាប់ស្ត្រីៗ ហើយខ្ញុំជឿជាក់ថា ខ្ញុំបានឮព្រះសូរសៀងពីព្រះជាម្ចាស់។ វាគ្រប់គ្រាន់ហើយ ដែលបញ្ជូនមនុស្សធ្លាក់ចូលក្នុងសេចក្ដីក្រោធ។ តើខ្ញុំបានគិតថា ខ្ញុំជានរណា? ខ្ញុំពុំបានទទួលការអប់រំគ្រប់គ្រាន់ទេ។ ខ្ញុំគ្រាន់តែជាស្ត្រីម្នាក់ប៉ុណ្ណោះ ឯស្ត្រីៗមិនធ្វើអ្វីធំដុំទេ ក្នុងចំណោមយើង។ ខ្ញុំពុំបានដឹងពីការនោះទេ ប៉ុន្ដែវាជាការប៉ុនប៉ង ដំបូងរបស់មារ ដែលព្យាយាមធ្វើឲ្យខ្ញុំបញ្ឈប់ ហើយទៅកន្លែងដដែលរបស់ខ្ញុំវិញ ជាកន្លែងវេទនា និងខ្វះខាត។

ពួកសាវ័កបានទទួលការព្រមានពីព្រះវិញ្ញាណដ៏វិសុទ្ធថា ពួកលោកនឹងរងការបៀតបៀន តែពួកលោកនៅតែបោះពួយទៅមុខយ៉ាងក្លាហានដដែល។ ព្រះយេស៊ូបង្រៀនយើងថា អស់អ្នកណាឮព្រះបន្ទូល "ហើយទទួលយកដោយអំណរ" ក្នុងរយៈពេលខ្លី តែពេលការបៀតបៀនចូលមកពាក់ព័ន្ធនឹងព្រះបន្ទូល ពួកគេបានការពារខ្លួនឯង ហើយក៏ដួលចុះទៅ (មើលព្រះគម្ពីរម៉ាកុស ៤:១៦-១៧)។

យើងទាំងអស់គ្នាចង់ឲ្យគេទទួលស្គាល់។ គ្មាននរណាម្នាក់រីករាយនឹងការឈឺចាប់ដោយគេបដិសេធនោះទេ ព្រោះវាជាការឈឺចាប់ផ្លូវអារម្មណ៍ ដែលធ្ងន់ធ្ងរខ្លាំងដែរ ឯឥទ្ធិពលរបស់វាអាចនៅជាប់នឹងយើងយូរផងដែរ។ ព្រះយេស៊ូត្រូវបានគេបដិសេធ និងរងការប្រមាថ (មើលអេសាយ៥៣:៣)។ ជាក់ស្ដែង ព្រះគម្ពីរ យ៉ូហាន ១៥:២៥ ក៏ថ្លែងថា គេស្អប់ព្រះអង្គដោយគ្មានហេតុផល។ តាមពិតព្រះអង្គល្អ ព្រះអង្គ មិនដែលបានធ្វើអ្វីខុសឡើយ តែព្រះអង្គត្រូវគេធ្វើទុក្ខ។ ព្រះអង្គប្រាប់យើងថា សិស្សនឹងមិនធំជាងគ្រូទេ (មើលលូកា ៦:៤០)។ បើព្រះអង្គរងទុក្ខ យើងក៏រំពឹងថា រងទុក្ខដូចគ្នា។

ខ្ញុំចង់ចែកចាយខគម្ពីរ២ខ អំពីការឈឺចាប់ដែលពិបាកសំរាប់ខ្ញុំ ក្នុងគ្រាដំបូងនៃជីវិតរបស់ខ្ញុំ៖

> បើមានបងប្អូនណាម្នាក់រងទុក្ខលំបាកដោយអយុត្តិធម៌ ហើយស៊ូទ្រាំ ព្រោះយល់ដល់ព្រះជាម្ចាស់ តោងចាត់ទុកថា ព្រះអង្គប្រណីសន្ដោស

ដល់បងប្អូននោះហើយ។
ព្រះអង្គត្រាស់ហៅបងប្អូនមក អោយរងទុក្ខលំបាកយ៉ាងនេះ ព្រោះព្រះគ្រិស្ត*ក៏បានរងទុក្ខលំបាកសំរាប់បងប្អូន ទុកជាគំរូអោយបងប្អូនដើរតាមគន្លងរបស់ព្រះអង្គដែរ។

១ពេត្រុស ២:១៩ និង២១

ខ្ញុំមិនអាចដឹងថា ហេតុអ្វីព្រះជាម្ចាស់គ្រាប់ព្រះហឫទ័យ ពេលខ្ញុំឈឺចាប់ ប៉ុន្តែចុងក្រោយខ្ញុំដឹងថា វាមិនមែនជាការឈឺចាប់ និងរងទុក្ខរបស់ខ្ញុំទេដែលព្រះអង្គគាប់ព្រះហឫទ័យ ការពិតនោះគឺ ខ្ញុំចង់ធ្វើវាដើម្បីព្រះអង្គទេតើ។ វាមិនមែនជាការឈឺចាប់របស់យើងទេ ដែលថ្វាយសិរីរុងរឿងល្អទៅព្រះជាម្ចាស់ តែគឺសមត្ថភាពរបស់យើងទេដែលឆ្លើយតបល្អក្នុងភាពឈឺចាប់។ ពេលណាយើងឈឺចាប់ក៏ដោយ ព្រះជាម្ចាស់ក៏ឈឺចាប់ជាមួយនឹងយើងដែរ គឺដូចយើងឈឺចាប់ពេលកូនៗរបស់យើងឈឺចាប់ដែរ។ គ្មានអ្វីអាចបំបែកយើងចេញសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់បានឡើយ ហើយព្រះអង្គក៏នឹងមិនបោះបង់យើងចោលដែរ គ្មានម្តងណាសោះឡើយ (មើលព្រះគម្ពីររ៉ូម៨:៣៨-៣៩ និងហេប្រឺ១៣:៥)។ ទោះជាយើងមាន*អារម្មណ៍*ថា ព្រះអង្គបោះបង់យើងចោល ដូចគ្រាព្រះយេស៊ូនៅលើឈើឆ្កាងក្តី ក៏ព្រះអង្គនឹងមិនធ្វើឡើយ។ មិនថាអ្នកប្រឈមនឹងអ្វីទេពេលនេះ ចូរដឹងថា ព្រះជាម្ចាស់គឺគង់នៅជាមួយអ្នក ហើយព្រះអង្គមានគំរោងរំដោះអ្នក និងប្រោស អ្នកឲ្យជាផងថែមទៀតផង។

*មិនថាអ្នកប្រឈមនឹងអ្វីទេពេលនេះ ចូរដឹងថា ព្រះជាម្ចាស់គឺគង់នៅជាមួយអ្នក ហើយព្រះអង្គមានគំរោងរំដោះអ្នក និងប្រោសអ្នកឲ្យជាផងថែមទៀតផង។*

ព្រះយេស៊ូបានថ្លែងថា យើងបានពរហើយ ពេលណាយើងត្រូវគេបៀតបៀនដោយសារសេចក្តីសុចរិត ហើយយើងនឹងទទួលរង្វាន់ដ៏អស្ចារ្យនៅស្ថានសួគ៌ (មើលព្រះគម្ពីរ ម៉ាថាយ៥:១០-១២)។ បើអ្នកដូចជាខ្ញុំ មិនចង់រង់ចាំទទួលរង្វាន់ពេលអ្នកទៅដល់ស្ថានសួគ៌ទេនោះ ព្រះយេស៊ូក៏បានថ្លែងដែរថា បើយើងចុះ ចាញ់ដោយសារព្រះអង្គ និងដោយសារតែដំណឹងល្អ នោះយើងនឹងច្រូតកាត់នៅក្នុងជីវិតបច្ចុប្បន្ន និងគ្រាបន្ទាប់ដែលនឹងមកដល់មិនខាន (មើលព្រះគម្ពីរម៉ាកុស១០:២៩-៣០)។ តាមរយៈខគម្ពីរ២ខខាងលើនេះ យើងឃើញសេចក្តីសន្យាអំពីរង្វាន់ទាំងនៅស្ថានសួគ៌ ទាំងនៅផែនដី។

រឿងមួយដែលជាញឹកញាប់ យើងបោះបង់ចោល ដើម្បីបំរើព្រះជាម្ចាស់ឲ្យអស់ពីចិត្តនោះគឺ កេរ្តិ៍ឈ្មោះ។ ព្រះយេស៊ូបានធ្វើឲ្យខ្លួនឯងអស់កេរ្តិ៍ឈ្មោះ (មើលព្រះគម្ពីរភីលីព២:៧) ហើយពេលនេះ វាងាយឲ្យ ខ្ញុំយល់ណាស់ថា ហេតុអ្វីពេលនេះ។ បើយើងខ្វល់ខ្វាយខ្លាំងថា តើមនុស្សគិតដូចម្តេចពីយើង នោះ យើងនឹងមិនដើរតាមព្រះគ្រិស្តពេញទំហឹងទេ។ ខ្ញុំបានលះបង់កេរ្តិ៍ឈ្មោះរបស់ខ្ញុំជាមួយអស់អ្នកមួយចំនួនដែលខ្ញុំបានស្គាល់ នៅពេលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំ ហើយពេលនេះ ព្រះអង្គបានឲ្យរង្វាន់ដល់ខ្ញុំហើយ។ ពេលនេះ ខ្ញុំមានមិត្តច្រើនជាងពេលខ្ញុំបោះបង់ចោលពីមុនណាស់។

ព្រះជាម្ចាស់ នឹងផ្តល់រង្វាន់ដល់អស់អ្នកឧស្សាហ៍ព្យាយាមស្វែងរកព្រះអង្គ (ចូរមើលព្រះគម្ពីរ ហេប្រឺ១១:៦)។ ពេលណាអ្នកកំពុងឈឺចាប់ពីការបៀតបៀន ចូរសម្លឹងទៅឯរង្វាន់ខាងមុខដែលព្រះជាម្ចាស់ បានគ្រោងទុកសំរាប់អ្នកចុះ! បើអ្នកឈឺចាប់ដោយបាត់បង់កេរ្តិ៍ឈ្មោះរបស់អ្នក ឬដោយត្រូវបានជំនុំជំរះ មិនបានស្មើភាព ហើយត្រូវគេរិះគន់ដោយសារសេចក្តីជំនឿក្នុងព្រះជាម្ចាស់នោះ ចូរកុំអស់សង្ឃឹម។ ចូរ បន្តទុកចិត្តព្រះជាម្ចាស់ ហើយមើលទៅឯរង្វាន់របស់អ្នកនៅខាងមុខវិញ។

# ជំពូក ១១

# ហេតុផលដែលនាំអោយយើងរងទុក្ខ
# (ផ្នែកទី ២)

នៅក្នុងជំពូកកន្លងមក ខ្ញុំបានបរិយាយជាមួយនឹងហេតុផលចំនួនបី ថាហេតុអ្វីយើងរងទុក្ខ។ ទីមួយនោះគឺអត្ថិភាពនៃអំពើបាប។ ទីពីរ ខ្ញុំបាននិយាយអំពីការរងទុក្ខដោយសារការបង្កើតជំរើសដែលមិនឆ្លាតវៃ។ ហើយទីបី ខ្ញុំបាននិយាយអំពីការរងទុក្ខវេទនាជាលទ្ធផលនៃការដែលត្រូវគេបៀតបៀនដោយសារសេចក្តីជំនឿរបស់យើងលើព្រះជាម្ចាស់។

នៅក្នុងជំពូកនេះ ខ្ញុំចង់បន្តបរិយាយជាមួយហេតុផលហេតុអ្វីយើងរងទុក្ខវេទនា ហើយខ្ញុំអធិស្ឋាន ដែលវានឹងមានប្រយោជន៍ដល់អ្នកក្នុងការដើររបស់អ្នកជាមួយព្រះជាម្ចាស់។

## *យើងរងទុក្ខអយុត្តិធម៌ដោយសារអំពើបាបរបស់មនុស្សដទៃ*

ប្រភេទនៃការរងទុក្ខនេះគឺពិបាកណាស់សម្រាប់យើងដើម្បីទ្រាំទ្រ ពីព្រោះយើងមានអារម្មណ៍ថាយើងមិនមានកំហុសទាល់តែសោះ ហើយយើងកំពុងរងទុក្ខវេទនាសម្រាប់អ្វីដែលនៅហួសពីការគ្រប់គ្រងរបស់យើង។ គំនិតទីមួយដែលយើងមានគឺ *នេះគឺមិនយុត្តិធម៌ទេ* ហើយវាជាក់ច្បាស់ណាស់គឺមិនមែន។ ប៉ុន្តែទោះបីជាជីវិតមិនមែនតែងតែយុត្តិធម៌ក្តី អ្នកទាំងឡាយណាដែលដាក់សេចក្តីជំនឿរបស់ពួកគេលើព្រះជាម្ចាស់អាចរំពឹងថានឹងឃើញសេចក្តីយុត្តិធម៌របស់ទ្រង់នៅក្នុងពេល និង ផ្លូវរបស់ទ្រង់ ។ ពីព្រោះព្រះអង្គស្រលាញ់សេចក្តីយុត្តិធម៌ ព្រះអង្គសព្វព្រះហឫទ័យធ្វើអ្វីដែលខុសអោយជាត្រូវ។ ទ្រង់គឺជាអ្នកកែតម្រូវរបស់យើង ហើយទ្រង់សងសឹកជួសយើងនៅពេលដែលយើងទទួលរងភាពអយុត្តិធម៌។

ទោះបីវាជាការរំលោភបំពានក្នុងវ័យកុមារក្តី ត្រូវបានឈ្លានពានដោយអយុត្តិធម៌ពីព្រោះតែពណ៌ស្បែករបស់ខ្ញុំ ភេទរបស់ខ្ញុំ សញ្ជាតិរបស់ខ្ញុំ រឺដោយសារហេតុផលរាប់ពាន់ផ្សេងទៀត ភាពអយុត្តិធម៌តែងតែធ្វើអោយការឈឺចាប់កប់ជ្រៅ ហើយប្រសិនបើ

យើងមិនដោះស្រាយវាអោយបានត្រឹមត្រូវទេនោះ យើងមិនអាចចាកចេញពីជំបៅដ៏ជ្រៅនោះបានទេ ហើយស្លាកស្នាមនៅក្នុងព្រលឹងរបស់យើងនោះមានឥទ្ធិពលដល់របៀបដែលយើងរស់នៅ។

លក្ខណៈមួយនៃលក្ខណៈរបស់ព្រះជាម្ចាស់ ដែលខ្ញុំទទួលបានសេចក្តីរំភើបបំផុតនោះ គឺថាទ្រង់គឺជាព្រះនៃសេចក្តីយុត្តិធម៌។ នៅទីនេះគឺមួយនៃសេចក្តីសន្យារបស់ទ្រង់ដែលយើងអាចដាក់សេចក្តីទុកចិត្តរបស់យើងទៅក្នុងទ្រង់:

> ដ្បិតយើងបានស្គាល់ព្រះជាម្ចាស់ដែលមានព្រះបន្ទូលថា «ការសងសឹកស្រេចតែនៅលើយើង គឺយើងទេតើដែលនឹងតបស្នងដល់គេ» ហើយ « ព្រះអម្ចាស់នឹងវិនិច្ឆ័យទោសប្រជារាស្ត្ររបស់ព្រះអង្គ»។
>
> ហេប្រឺ ១០៖៣០ (KHSV)

អស្ចារ្យ! នេះជាគម្ពីរដ៏អស្ចារ្យនិងលើកទឹកចិត្ត ហើយប្រសិនបើអ្នកកំពុងរងទុក្ខដោយសារភាពអយុត្តិធម៌មកពីមនុស្សណាម្នាក់ផ្សេង អ្នកគួរតែលាក់ខគម្ពីរនេះនៅក្នុងដួងចិត្តរបស់អ្នក ហើយទុកចិត្តព្រះជាម្ចាស់នាំយកការសន្យាមកដាក់នៅក្នុងជីវិតរបស់អ្នក។

ខ្ញុំមានបទពិសោធន៍ ជាមួយនឹងសេចក្តីយុត្តិធម៌របស់ទ្រង់នៅក្នុងជីវិតផ្ទាល់របស់ខ្ញុំលើកាលៈទេសៈជាច្រើន។ ខ្ញុំធ្លាប់បានរៀបរាប់អំពីការបដិសេធដែលខ្ញុំធ្លាប់មានបទពិសោធន៍នៅក្នុងព័ន្ធកិច្ចរបស់ខ្ញុំ ហើយទោះបីជាវាបានចំណាយពេលជាច្រើនឆ្នាំ មានមនុស្សពីរបីនាក់ដែលបានធ្វើអោយខ្ញុំឈឺចុកចាប់យ៉ាងខ្លាំង បានចាប់ផ្តើមសូមអភ័យទោស នឹងបាននិយាយថា វិធីដែលពួកគេបានប្រព្រឹត្តចំពោះខ្ញុំនោះគឺខុស។

ការសងសឹកចំពោះអំពើអយុត្តិធម៌នោះមានន័យថា អ្នកសងវាត្រឡប់ទៅវិញសម្រាប់អ្វីដែលបានកើតឡើងចំពោះអ្នក។ នៅទីនេះមិនមានអ្វីផ្អែមជាងការដែលមើលឃើញថាព្រះជាម្ចាស់ស្មោះត្រង់និងប្រទានពរអ្នក ពីព្រោះអ្នកណាម្នាក់បានប្រព្រឹត្តចំពោះអ្នកដោយអយុត្តិធម៌ ប៉ុន្តែយើងត្រូវតែបោះបង់ការព្យាយាមធ្វើអោយអ្នកផ្សេងសងត្រឡប់មកយើងសម្រាប់ភាពអយុត្តិធម៌ដែលយើងបានទ្រាំទ្រ ប្រសិនបើយើងចង់ឃើញព្រះជាម្ចាស់បង្ហាញយើង។

បន្ទាប់ពីការបំពានផ្លូវភេទដោយឪពុករបស់ខ្ញុំ និងត្រូវបានបោះបង់ចោលក្នុងស្ថានភាពនោះដោយម្តាយរបស់ខ្ញុំហើយមនុស្សដែលមានទំនាក់ទំនងដទៃទៀតមិនបានធ្វើអ្វីសោះដើម្បីជួយខ្ញុំ ខ្ញុំពិតជាមានឥរិយាបថពុលនឹងជីវិតរបស់ខ្ញុំ។ ខ្ញុំធ្លាប់ចង់

សងត្រឡប់ទៅមនុស្សដែលបានធ្វើអោយខ្ញុំឈឺចាប់វិញ ដូចគ្នាដែរសម្រាប់មនុស្សដែលមិនបានជួយខ្ញុំ។ ខ្ញុំធ្លាប់មានភាពជូរចត់ ដែលពោរពេញទៅដោយភាពតូចចិត្ត ហើយមានអារម្មណ៍ថាផែនដីជំពាក់អ្វីមួយខ្ញុំ។ ពិតណាស់គ្មានអាកប្បកិរិយាបែបណាមួយល្អសម្រាប់ខ្ញុំទេ។ ពួកវាមិនបានដោះស្រាយបញ្ហារបស់ខ្ញុំ ឬ ធ្វើអោយខ្ញុំមានអារម្មណ៍ប្រសើរឡើងនោះទេ ប៉ុន្តែពួកវាបានបន្តធ្វើអោយខ្ញុំលំបាក។ ខ្ញុំបានទទួលការរំលោភបំពាន ដែលវាអាក្រក់គ្រប់គ្រាន់ ប៉ុន្តែជាច្រើនឆ្នាំក្រោយមកខ្ញុំនៅតែជាជនរងគ្រោះហើយជាប់នៅក្នុងអ្វីដែលបានកើតឡើង។ ខ្ញុំពិតជាមានអារម្មណ៍ថាខ្ញុំនឹងមិនមានជីវិតធម្មតាឬមានសុខភាពផ្លូវចិត្តល្អនោះទេ។

ខ្ញុំបានជាគ្រិស្ទបរិស័ទ តែខ្ញុំពិតជាមិនបានស្គាល់ព្រះបន្ទូលរបស់ព្រះនោះទេ។ ខ្ញុំបានកើតជាថ្មី ប៉ុន្តែខ្ញុំនៅតែធ្វើអ្វីតាមផ្លូវរបស់ខ្ញុំជំនួសអោយការសិក្សានិងដើរតាមផ្លូវរបស់ព្រះ។ ពេលមួយខ្ញុំបានរៀន ដែលព្រះជាម្ចាស់ស្រលាញ់សេចក្តីយុត្តិធ៌មនិងចង់ដោះស្រាយបញ្ហាពីអតីតកាលរបស់ខ្ញុំ ជំនួសខ្ញុំដែលព្យាយាមធ្វើវាតាមផ្លូវរបស់ខ្ញុំ អ្វីៗគ្រប់យ៉ាងបានចាប់ផ្តើមផ្លាស់ប្តូរសម្រាប់ខ្ញុំ។ ខ្ញុំមិនចង់និយាយអ្វីដែលវាបានកើតឡើងពេញមួយយប់នោះទេ ប៉ុន្តែតាមលំដាប់លំដោយ ការបាក់បែករបស់ខ្ញុំវាបានសះស្បើយហើយ ហើយព្រះជាម្ចាស់ពិតជាបានដកយកការអាក្រក់ដែលបានកើតមានចំពោះខ្ញុំហើយបានធ្វើវាអោយចេញមកសម្រាប់ការល្អ។

ព្រះជាម្ចាស់តម្រូវអោយយើងបោះបង់អតីតកាលចោល ហើយបំភ្លេចសត្រូវរបស់យើងចោលទាំងស្រុង អធិស្ឋានសម្រាប់ពួកគេ ហើយសូម្បីការអោយពរដល់ពួកគេដូចដែលទ្រង់បានដឹកនាំយើងពីរបៀបធ្វើវា។ ទីបញ្ចប់ឪពុករបស់ខ្ញុំបានសូមការអភ័យទោសពីខ្ញុំហើយបានសម្រក់ទឹកភ្នែកដោយការស្តាយក្រោយ។ ខ្ញុំមានអភ័យឯកសិទ្ធិដើម្បីដឹកនាំគាត់ទៅរកព្រះជាម្ចាស់និងធ្វើពិធីជ្រមុជទឹកដល់គាត់។ គាត់បានប្រាប់ខ្ញុំថាតើគាត់មានមោទនភាពយ៉ាងណាចំពោះខ្ញុំ ហើយនឹងកិច្ចការដែលខ្ញុំបានអោយពរនៅក្នុងព័ន្ធកិច្ច។

ខ្ញុំគិតថាវាអាចនឹងមានសុវត្ថិភាព ដែលភាគច្រើនបំផុតនៃសេចក្តីរងទុក្ខក្នុងជីវិតរបស់យើងមកពីភាពអយុត្តិធ៌មដោយសារមនុស្សអាក្រក់ ប៉ុន្តែមួយផ្នែកនៃការរងទុក្ខវេទនាទាំងនោះគឺវាមកពីមនុស្សដែលគេនិយាយថាពួកគេស្រលាញ់យើង។នៅពេលដែលនោះជាករណីមួយរបួសគឺវាកាន់តែជ្រៅ។ ប៉ុន្តែវាមិនមានបញ្ហាថាវាជ្រៅយ៉ាងណា រឺក៏មានបញ្ហាខ្លាំងយ៉ាងណានោះទេ ព្រះជាម្ចាស់អាចទៅដល់វា ព្យាបាលវា ធ្វើវាអោយចេញមកយ៉ាងល្អ ហើយសងសឹកជួសអ្នកសម្រាប់ការឈឺចាប់ពីអតីតកាល។

ព្រះអង្គប្រទានអោយយើងមានសុភមង្គល ហើយអំណរជំនួសការកាន់ទុក្ខ (ព្រះ

គម្ពីរ អេសាយ ៦១៖១-៣) ហើយព្រះអង្គសន្យាថាសងត្រឡប់មកយើងវិញនូវអ្វីដែលយើងបាត់បង់។

> ព្រះអម្ចាស់ ជាព្រះរបស់អ្នកនឹងស្តារស្ថានភាពរបស់អ្នក ព្រះអង្គនឹងអាណិតអាសូរអ្នក ហើយប្រមូលអ្នកពីក្នុងចំណោមជាតិសាសន៍ទាំងប៉ុន្មាន ដែលព្រះអង្គកំចាត់កំចាយអ្នកទៅនោះ។
>
> ទុតិយកថា ៣០៖៣(KHSV)

មិនមានមនុស្សណាម្នាក់ចង់រងទុក្ខនិងឈឺចាប់នៅក្នុងជីវិតរបស់ពួកគេនោះទេ ប៉ុន្តែវាជាការល្អដែលដឹងថាអ្នកកំពុងឆ្លងកាត់វា ព្រះជាម្ចាស់រួចរាល់ជាស្រេចនឹងទូទាត់សងអ្នកប្រសិនបើអ្នកតាមផ្លូវរបស់ទ្រង់និងទុកចិត្តទ្រង់ដើម្បីធ្វើការដូច្នោះ។

## *យើងរងទុក្ខវេទនាពីព្រោះតែយើងព្យាយាមផ្លាស់ប្តូរអ្វីដែលមានតែព្រះជាម្ចាស់ប៉ុណ្ណោះអាចផ្លាស់ប្តូរវាបាន*

ខ្ញុំគិតថារឿងមួយក្នុងចំណោមរឿងដំបូងដែលខ្ញុំបានរៀននោះគឺការកាត់បន្ថយការរងទុក្ខវេទនាខាងផ្លូវអារម្មណ៍របស់ខ្ញុំ ដែលខ្ញុំមិននៅក្នុងការត្រួតត្រានៃលោកីយ៍នេះ។ ដោយការកើតមកជាមួយនិស្ស័យធម្មជាតិដ៏រឹងរូស និង ឈ្លានពាន អាកប្បកិរិយា «យកបន្ទុក» ខ្ញុំបានព្យាយាមគ្រប់គ្រងនិងផ្លាស់ប្តូរអ្វីៗជាច្រើនដែលខ្ញុំគ្មានអំណាចលើវា។ វាបាននាំយកការឈឺចាប់មកអោយខ្ញុំជាច្រើនឆ្នាំ ដើម្បីយល់ថាព្រះជាម្ចាស់បានចាប់អារម្មណ៍យ៉ាងខ្លាំងចំពោះការផ្លាស់ប្តូរខ្ញុំ ច្រើនជាងការផ្លាស់ប្តូរស្ថានភាពមិនល្អរបស់ខ្ញុំ។ ការពិតណាស់ ខ្ញុំក៏តស៊ូផងដែរជាមួយការព្យាយាមដើម្បីផ្លាស់ប្តូរមនុស្សក្នុងលោករបស់ខ្ញុំ ដូច្នេះពួកគេគួរតែធ្វើអោយខ្ញុំមានភាពរីករាយនិងកាន់តែប្រសើរឡើង ប៉ុន្តែខ្ញុំបានរៀនថា (ហើយវាមិនបានមកដោយស្រួលនិងឆាប់រហ័យនោះទេ) មានតែព្រះជាម្ចាស់ប៉ុណ្ណោះអាចផ្លាស់ប្តូរមនុស្សបាន ហើយទោះជាទ្រង់មិនសព្វព្រះទ័យធ្វើវាប្រសិនបើពួកគេមិនចង់បានជំនួយរបស់ទ្រង់។

ពេលមួយខ្ញុំបានរៀន ដើម្បីឲ្យតម្លៃមនុស្សដែលពួកគេបានជំនួសដោយទីកន្លែងដែលខ្ញុំចង់អោយដល់ពួកគេ (ហើយខ្ញុំនៅតែកំពុងរៀនសូត្ររាល់ថ្ងៃនេះ) ភាគច្រើនបំផុតនៃទុក្ខវេទនានិងភាពកំសត់របស់ខ្ញុំបានបញ្ចប់។ ខ្ញុំធ្លាប់នៅក្នុងក្តីអស់សង្ឃឹមដែលត្រូវការការបន្ទាបខ្លួន។ ទោះបីជាព្រះបានអញ្ជើញយើងដើម្បីអោយ «បន្ទាបខ្លួនរបស់យើង» មានចំនួនតិចតួចប៉ុណ្ណោះដែលមានបំណងនឹងធ្វើវា ដូច្នេះទ្រង់ធ្វើវា

សម្រាប់យើង។ ព្រះអង្គសម្រេចការនេះ ដោយដាក់យើងក្នុងស្ថានភាពនានាជាមួយមនុស្សដែលបង្កភាពធុញថប់និងតឹងតែងដល់យើង ហើយតាមរយៈការអស់សង្ឃឹមរបស់យើង ដើម្បីបញ្ចប់ក្តីឈឺចាប់ដោយសារពួកគេ នៅទីបញ្ចប់យើងដឹងថាព្រះជាម្ចាស់ប្រើប្រាស់ពួកគេដើម្បីទៅដល់បញ្ហាដ៏ជ្រៅដែលនៅក្នុងយើង។ ទ្រង់គឺជាព្រះប្រោសលោះរបស់យើង ហើយទោះជាទ្រង់អាចចំណាយពេលយូរជាងយើងចង់ឱ្យទ្រង់ធ្វើក៏ដោយ ជាញឹកញាប់ព្រះជាម្ចាស់ប្រើប្រាស់រឿងអាក្រក់នៅក្នុងជីវិតរបស់យើងដើម្បីធ្វើការល្អចេញមក!

តើអ្នកធ្លាប់បានពិចារណារឺទេថា*សកម្មភាពឆ្លើយតប* របស់អ្នកទៅនឹងបញ្ហារបស់អ្នក អាចជាបញ្ហាពិតប្រកដជំនួសអោយអ្វីដំបូងដែលអ្នកបានគិតថាវាជាបញ្ហានោះ? ខ្ញុំបានគិតជាច្រើនឆ្នាំថាខ្ញុំមិនសប្បាយចិត្ត ពីព្រោះ ដេវ មិនបានជួបនូវអ្វីដែលជាសេចក្តីត្រូវការរបស់ខ្ញុំ ប៉ុន្តែព្រះជាម្ចាស់បានបង្ហាញខ្ញុំថា ឥរិយាបថអាត្មានិយមរបស់ខ្ញុំគឺជាបញ្ហាពិតប្រាកដរបស់ខ្ញុំ។ ខ្ញុំនៅតែរក្សាការព្យាយាមផ្លាស់ប្តូរគាត់ ហើយគ្មានការខិតខំប្រឹងប្រែងរបស់ខ្ញុំណាដែលបានបង្កើតលទ្ធផលនោះទេ ពីព្រោះព្រះបានប្រើស្ថានភាពនេះដើម្បីទៅអោយដល់ឫសគល់នៃបញ្ហារបស់ខ្ញុំ។

ព្រះបន្ទូលព្រះប្រាប់យើងថាក្មេងប្រុសគង្វាលតូច ដាវីឌ បានទទួលការចាក់ប្រេងតាំងអោយក្លាយជាស្តេច។ ប៉ុន្តែរយៈពេលដ៏យូរមុនពេលលោកបានឡើងគ្រងរាជ្យ លោកធ្លាប់បានធ្វើការនៅក្រោមនិងដោះស្រាយជាមួយស្តេចដែលលេលានិងអាក្រក់ គាត់បានកំណត់ទិសដៅដើម្បីផ្លាស់ប្តូរ។ ដូច្នេះអ្វីៗដែលកើតឡើងជាច្រើនចំពោះដាវីឌ គឺនៅក្នុងដៃរបស់សូល ហាក់ដូចជាមិនយុត្តិធម៌ ហើយមិនទាន់មានគោលបំណងក្នុងវានៅឡើយ។

ពេលមួយខ្ញុំបានឮថា ព្រះជាម្ចាស់បានប្រើស្តេចសូល ដើម្បីនាំ«សូល»ចេញពី ដាវីឌ មុនពេលដែលគាត់បានមកជាស្តេចដូចជា ស្តេចសូល។ ខ្ញុំដឹងថាវានឹងក្លាយជាការពិតក្នុងជីវិតរបស់ខ្ញុំ។ ខ្ញុំអាចក្រឡេកក្រោយទៅកាន់ភាពសាហាវព្រៃផ្សៃដែលមាននៅក្នុអាកប្បកិរិយារបស់ឪពុកខ្ញុំ ហើយឥឡូវខ្ញុំទទួលស្គាល់ថាខ្ញុំបានរៀនយ៉ាងច្រើនអំពីលក្ខណៈរបស់គាត់ ប៉ុន្តែខ្ញុំមិនដឹងថាវានៅពេលណានោះទេ។ ខ្ញុំគឺជាស្ត្រីម្នាក់ដែលបានត្រាស់ហៅចូលទៅក្នុងព័ន្ធកិច្ច ប៉ុន្តែខ្ញុំធ្លាប់មានដួងចិត្តដែលរឹងរូសដោយសារការរំលោភបំពាន ខ្ញុំជាក្មេងដែលធ្លាប់រងទុក្ខវេទនា។ ផ្លូវរបស់ខ្ញុំវាធ្លាប់ពិបាកខ្លាំងណាស់ ហើយខ្ញុំពិតជាមាននីតិនិយមចំពោះ អ្វីដែលខ្ញុំបានគិត គឺមនុស្សពិតជាមិនគួរនឹងធ្វើនោះទេ។ ទំនាក់ទំនងសម្រាប់ខ្ញុំ គឺមានន័យថាការធ្វើតាមវិន័យរបស់ខ្ញុំ ហើយខ្ញុំបញ្ជាក់វិន័យ«របស់ខ្ញុំ» ខ្ញុំមានអំណោយទាន ប៉ុន្តែវាខ្វះនៅក្នុងតម្រូវ

ការអត្តចរិតជាគ្រិស្ទបរិស័ទសម្រាប់ការងារនៅចំពោះមុខរបស់ខ្ញុំ។ ខ្ញុំបានខ្វាក់នឹងអាកប្បកិរិយារបស់ខ្ញុំ ពីព្រោះវាគឺជាបុព្វហេតុនៃដំបៅហើយនិងស្លាកស្នាមនៅក្នុងព្រលឹងរបស់ខ្ញុំ ដែលត្រូវការធ្វើការដោះស្រាយជាមួយវា។ ការក្លាយជាគ្រិស្ទបរិស័ទមិនមែនមានន័យថា យើងចំណាយជីវិតរបស់យើងនៅក្នុងអាកប្បកិរិយាកែប្រែនោះទេ ប៉ុន្តែយើងត្រូវការបើកអោយព្រះយេស៊ូបំផ្លាស់បំប្រែរយើងពីផ្នែកខាងក្នុងនិងធ្វើឱ្យយើងចូលក្នុងរូបរបស់ទ្រង់។

ព្រះជាម្ចាស់បានប្រើអ្នកដឹកនាំខាងព្រលឹងវិញ្ញាណ និង មនុស្សមួយចំនួនផ្សេងទៀតដែលមិនបានប្រព្រឹត្តល្អចំពោះខ្ញុំ ដើម្បីជួយខ្ញុំអោយដឹងថាខ្ញុំមិនគួរនឹងប្រព្រឹត្តដាក់អ្នកដទៃជាមួយនឹងអ្វីដែលពួកគេធ្វើដាក់ខ្ញុំនោះទេ។ ព្រះជាម្ចាស់ពិតបានធ្វើឲ្យខ្ញុំអនុគ្រោះ ដោយដាក់ខ្ញុំទៅក្នុងទំនាក់ទំនងយ៉ាងជិតស្និតជាមួយមនុស្សទាំងនោះអស់ចំនួនប៉ុន្មានឆ្នាំ ហើយទោះបីជាវាមានការឈឺចាប់យ៉ាងណាក្តី វាបានជួយខ្ញុំយ៉ាងខ្លាំងហើយធ្វើអោយខ្ញុំក្លាយជាមនុស្សម្នាក់ដែលប្រសើរឡើង។ ខ្ញុំចង់និយាយថា ពេលខ្លះយើងត្រូវការអ្វីមួយដែលពិបាក និង មិនស្រណុកសុខស្រួលឲ្យកើតឡើងដើម្បីជួយយើងឲ្យមើលទៅសេចក្តីពិតរបស់ខ្លួនឯង ជំនួសឲ្យការដែលយើងគិតថាយើងជាអ្វី។ ការគិតរបស់យើងវាអាចងាយស្រួលនឹងមិនច្បាស់លាស់ដោយសារភាពអំណួត ការនាំយើងឲ្យវិនិច្ឆ័យរិះគន់អ្នកដទៃ ហើយបើទោះជាយើងអាចនឹងធ្វើរឿងខ្លះដូចគ្នាទៅនឹងអ្វីដែលយើងបានរិះគន់ពួកគេនោះ ក៏យើងមិនបានមើលឃើញវា(រ៉ូម ២៖១)។

ខ្ញុំឃើញថាលោកពេត្រុសគឺជាគំរូយ៉ាងល្អនៅក្នុងផ្នែកនេះ។ ពេត្រុសធ្លាប់ជាមនុស្សកំរោលនិងនិយាយច្រើន។ គាត់ត្រូវបានកំណត់សម្រាប់រឿងដ៏អស្ចារ្យ ប៉ុន្តែគាត់បានគិតថា គាត់មានសមត្ថភាពខ្ពស់ដែលវាលើសពីខ្លួនរបស់គាត់ដែលគួរនឹងមាន អាកប្បកិរិយារបស់គាត់គឺត្រូវការការដោះស្រាយសម្រាប់ផលប្រយោជន៍ផ្ទាល់របស់គាត់។ នៅពេលដែលព្រះយេស៊ូមានបន្ទូលប្រាប់គាត់ថាសាតាំងបានកំពុងនឹងសុំរែងគាត់ដូចជារែងស្រូវដែលពួកគេត្រូវឆ្លងកាត់ ប៉ុន្តែព្រះអង្គបានអធិស្ឋានសម្រាប់គាត់ដើម្បីកុំអោយសេចក្តីជំនឿរបស់គាត់ត្រូវធ្លាក់ចុះ លោកពេត្រុសបានឆ្លើយតបទៅវិញយ៉ាងលឿនថាគាត់បានរួចរាល់នឹងទៅគុគ ឬសូម្បីតែសេចក្តីស្លាប់ជាមួយនឹងព្រះអង្គក៏ដោយ ប្រសិនបើគាត់ត្រូវស្លាប់។ គាត់បានបដិសេធព្រះយេស៊ូចំនួនបីដងក្នុងថ្ងៃនោះ ពីព្រោះគាត់បានធ្លាក់ចុះនិងនៅទីបញ្ចប់បានបង្ហាញពីខ្លួនរបស់គាត់ ថាគាត់គឺយ៉ាងដូចម្តេច។ គាត់ជាមនុស្សដែលទន់ខ្សោយដែលត្រូវការការអត់ទោសនិងការជួយរបស់ព្រះ។ (លូកា ២២៖៣១-៣៤, ៥៥-៦២) នៅពេលដែលព្រះយេស៊ូបាន

ប្រាប់ទៅពេត្រុសថា ទ្រង់បានអធិស្ឋានសម្រាប់គាត់ ពេត្រុសគួរតែបានអរព្រះគុណទ្រង់និងព្រមទទួលថា គាត់ពិតជាត្រូវការជំនួយទាំងអស់ដែលគាត់អាចទទួលបាន។

បន្ទាប់ពីបដិសេធព្រះគ្រិស្ត ពេត្រុសបានប្រែចិត្ត ហើយយំដោយការសោកស្តាយ ហើយគាត់បានក្លាយទៅជាមនុស្សម្នាក់ដែលប្រសើរបំផុត ហើយជាសាវកដែលមានប្រសិទ្ធិភាពបំផុត។ វាមិនមែនភាពខ្សោយរបស់យើងដែលនាំបញ្ហាអោយយើងនោះទេ តែភាពស្ទាក់ស្ទើររបស់យើងដែលមានបញ្ហាជាមួយពួកវា។ យើងគួរតែមានប្រាជ្ញាសូមព្រះជាម្ចាស់ជារៀងរាល់ថ្ងៃដើម្បីជួយយើង ហើយបង្ហាញយើងនូវអ្វីមួយអំពីខ្លួនរបស់យើងដែលរារាំងទ្រង់ពីការធ្វើអ្វី ដែលទ្រង់សព្វព្រះហឫទ័យធ្វើជាមួយយើង។ ជានិច្ចកាលយើងគួរតែចង់បានអ្វី ដែលជាបំណងព្រះហឫទ័យរបស់ព្រះជាជាងអ្វីផ្សេងដែលយើងចង់បាន។

សាវកពេត្រុសបានដាស់តឿនយើងឲ្យបន្ទាបខ្លួនក្រោមព្រះហស្តដ៏ខ្លាំងពូកែរបស់ព្រះអង្គ ដែលក្នុងវេលាកំណត់ទ្រង់នឹងលើកយើងឡើង(១ពេត្រុស៥៖៦)។ ដើម្បីបន្ទាបខ្លួនគឺ ត្រូវស្ថិតនៅក្រោមអ្វីមួយជាជាងការតស៊ូដើម្បីទទួលមានសេរីភាពពីវាពីព្រោះវាជាការលំបាក។ យើងរាល់គ្នាមិនមានអ្នកណាម្នាក់ចង់រងទុក្ខនោះទេ ប៉ុន្តែយើងគួរតែជ្រើសរើសធ្វើដូច្នេះប្រសិនបើវាជាតម្រូវការសម្រាប់យើង។

ឧបមាថាស្ត្រីម្នាក់រៀបការជាមួយបុរសម្នាក់ដែលរំលោភបំពានលើរាងកាយរបស់នាងនិងកូនៗរបស់ពួកគេ។ ក្នុងស្ថានភាពនោះ ច្បាស់ណាស់ថានាងគួរតែមិនស្ថិតនៅក្រោមការរំលោភបំពាន។ នាងគួរតែចាកចេញពីបុរសម្នាក់នេះ។ ម្តាយរបស់ខ្ញុំបាននៅជាមួយឪពុករបស់ខ្ញុំ ទាំងដែលដឹងថាគាត់បានធ្វើអ្វីមកលើខ្ញុំ ហើយវាប្រហែលជាការពិតដែលជាកំហុសយ៉ាងធ្ងន់ធ្ងរដែលគាត់បានធ្វើក្នុងមួយជីវិតរបស់គាត់។ នាងត្រូវបានបដិសេធនិងលេងសើចដោយអ្នកធ្វើការដទៃទៀតជាច្រើនហើយទោះបីជាបានឆ្លងកាត់សម្រាប់ការផ្សព្វផ្សាយដែលនាងសមនឹងទទួលបានក៏ដោយ។ តើនាងចាកចេញព្រោះតែវាមិនមានសេចក្តីសុខសម្រាប់នាង ឬតើនាងអធិស្ឋានថាប្រសិនបើព្រះសព្វព្រះទ័យឲ្យនាងចាកចេញ ទ្រង់នឹងធ្វើឲ្យវាច្បាស់លាស់ ហើយប្រសិនបើទ្រង់មិនសព្វព្រះទ័យទេនោះ ព្រះទ័យរបស់ទ្រង់នឹងបានសម្រេច? ក្នុងឧទាហរណ៍នេះ ព្រះជាម្ចាស់អាចចង់ឲ្យនាងនៅក្រោមការលំបាកសម្រាប់ហេតុផលមួយពីព្រោះទ្រង់ត្រូវការឧបករណ៍មួយនៅទីនោះ ដែលទ្រង់អាចប្រើដើម្បីបង្ហាញពីអង្គទ្រង់។ ២ធីម៉ូថេ៤៖២ និយាយថាយើងគួរតែរួចរាល់ជាស្រេចដើម្បីបម្រើព្រះ «ចូរប្រកាសព្រះបន្ទូល ព្រមទាំងនិយាយហើយនិយាយទៀត ទោះមានឱកាសល្អក្តី មិនល្អក្តី ត្រូវពន្យល់គេឲ្យដឹងខុសត្រូវ ស្តីបន្ទោស ដាស់តឿន និងបង្រៀនគេ ដោយចិត្ត

អត់ធ្មត់គ្រប់ជំពូក។»

នៅពេលដែលស្ថានភាពមួយ ឬមនុស្សម្នាក់ជាបុព្វហេតុឲ្យយើងរងទុកវេទនា ជានិច្ចកាលយើងគួរតែស្វែងរកព្រះជាម្ចាស់អំពីរបៀបដែលយើងគួរនឹងដោះស្រាយវា។ វាមិនមែនជាការមានប្រាជ្ញាទេ ដែលយើងធ្វើការសម្រេចចិត្តដោយមិនមានការពិភាក្សាជាមួយព្រះវិញ្ញាណដ៏វិសុទ្ធសម្រាប់ការបង្ហាញផ្លូវកំឡុងពេលដែលយើងកំពុងឈឺចាប់។ សាវកប៉ូលបានប្រាប់ដល់អ្នកស្រុកកាឡាទីថា ប្រសិនបើពួកគេបានពេញដោយព្រះវិញ្ញាណនោះពួកគេគួរតែទ្រាំទ្រ(ដាក់ជាមួយ) កំហុសរបស់គ្នាទៅវិញទៅមក (កាឡាទី ៦៖២)។ គំនិតដំបូងរបស់ខ្ញុំនឹងត្រូវនិយាយថា «ខ្ញុំមិនចាំបាច់ទ្រាំទ្រនឹងរឿងនេះ ហើយខ្ញុំក៏មិនទៅដែរ» ប៉ុន្តែផ្ទុយទៅវិញ ព្រះយេស៊ូបានដាក់ការណ៍នេះជាមួយខ្ញុំ ហើយខ្ញុំរីករាយដែលទ្រង់ធ្វើដូច្នេះ។

> បំណាងព្រះហឫទ័យព្រះជាម្ចាស់តែងតែប្រទានព្រះគុណដល់យើងសម្រាប់ទីកន្លែងរបស់យើង។

ខ្ញុំបានដឹងថាបន្ទាប់ពីបានឆ្លងកាត់កិច្ចការលំបាកមួយចំនួននៅក្នុងជីវិតរបស់ខ្ញុំដែលព្រះជាម្ចាស់តែងតែប្រទានព្រះគុណដល់យើងសម្រាប់ទីកន្លែងរបស់យើង។ នៅក្នុងពាក្យផ្សេងទៀត ប្រសិនបើយើងនៅទីកន្លែងដែលព្រះចង់ឲ្យយើងនៅ នោះព្រះអង្គអាចប្រទានព្រះគុណមកគ្រប់គ្រាន់ល្មមសម្រាប់ឲ្យយើងមានអំណរយ៉ាងពិតប្រាកដ ជាមួយអ្វីដែលអាចធ្វើឲ្យមានកង្វល់។

នៅពេលដែលខ្ញុំក្រឡេកមើលក្រោយ ទៅកាន់ប៉ុន្មានឆ្នាំដំបូងនៃការដើរជាមួយព្រះរបស់ខ្ញុំវាហាក់ដូចជាខ្ញុំបានកំពុងនឹងតស៊ូជាមួយអ្វីមួយគ្រប់ពេលទាំងអស់។ ប្រសិនបើវាមិនមែនជារឿងមួយទេនោះវានឹងជាមួយផ្សេងទៀត។ អារម្មណ៍របស់ខ្ញុំត្រូវបានគ្រប់គ្រងស្ទើរតែទាំងស្រុងដោយកាលៈទេសៈរបស់ខ្ញុំ។ ឧទាហរណ៍ នៅពេលសន្និសីទរបស់ខ្ញុំត្រូវបានប្រព្រឹត្តយ៉ាងល្អ ខ្ញុំមានអំណរ ប៉ុន្តែនៅពេលវាប្រព្រឹត្តទៅមិនបានល្អ ខ្ញុំបានខូចចិត្តនិងនិយាយរឿងអវិជ្ជមានជាច្រើន។ ដូច្នេះយើងអាចធ្វើអ្វីគ្រប់យ៉ាងទៅបានដើម្បីបង្កើនការយកចិត្តទុកដាក់ ប៉ុន្តែនៅពេលដែលវានៅតែបន្តឡើងនិងចុះ នោះខ្ញុំបានមានអារម្មណ៍ឡើងចុះតាមវា។ ជាលទ្ធផលខ្ញុំបានទទួលស្គាល់ថាខ្ញុំបានព្យាយាមដើម្បីផ្លាស់ប្តូរអ្វីមួយចំនួនដែលខ្ញុំមិនអាចផ្លាស់ប្តូរបាន ប៉ុន្តែដែលព្រះអាច ហើយទ្រង់នឹងធ្វើនៅពេលដែលពេលវេលាត្រឹមត្រូវ។ ពិតណាស់ពេលវេលារបស់យើងនៅក្នុងព្រះហស្តរបស់ទ្រង់ (ទំនុកដម្កើង៣១៖១៥)។ ជាយថាហេតុខ្ញុំបានថ្វាយភាពខ្វល់ខ្វាយរបស់ខ្ញុំទៅព្រះ ហើយប្រាកដល្មម ក្តីសុខសាន្តបានមកដូចដែលបានសន្យាវានឹងមក (ភីលីព៤៖៦-៧)។

សិក្ខាសាលារបស់យើងទទួលការយកចិត្តទុកដាក់ប្រសើរជាងមុនឥឡូវនេះ ប៉ុន្តែម្តងម្កាលយើងនៅតែមានមួយដែលមិនមែនសម្រាប់ហេតុផលណាមួយទេ ហើយទោះបីជាខ្ញុំនៅតែមិនចូលចិត្តវាក៏ដោយ វាមិនបានធ្វើឲ្យរងទុក្ខដូចដែលវាធ្លាប់មានពីមុននោះទេ ពីព្រោះខ្ញុំមិនបានប្រយុទ្ធជាមួយវា។ ខ្ញុំបានឆ្លងកាត់វាហើយបន្តបន្ទាប់ទៀត។

ពេលបន្ទាប់អ្នករកឃើញខ្លួនរបស់អ្នកការឈឺចាប់ផ្លូវអារម្មណ៍និងស្មារតី ពីព្រោះអ្នកកំពុងព្យាយាមផ្លាស់ប្តូរអ្វីដែលអ្នកមិនចូលចិត្ត ចូរសួរខ្លួនឯង ប្រសិនបើអ្នកកំពុងព្យាយាមផ្លាស់ប្តូរអ្វីដែលមានតែព្រះអាចធ្វើបាន ហើយប្រសិនបើអ្នកពិតជាយ៉ាងនេះមែន ដូច្នេះខ្ញុំជំរុញអ្នកថា «លែងទៅហើយថ្វាយឲ្យព្រះ។»

## *យើងរងទុក្ខពីព្រោះយើងរស់នៅក្នុងពិភពលោកមិនឥតខ្ចោះ*

យើងហាក់ដូចជាថាយើងអាចរងទុក្ខដោយសារមនុស្សម្នាក់ធ្វើបាប ឬអំពើបាបរបស់មនុស្សដទៃ ប៉ុន្តែមួយនៃហេតុផលដ៏សំខាន់ហេតុអ្វីបានជាយើងរងទុក្ខគឺជាធម្មតាពីព្រោះយើងរស់នៅក្នុងពិភពលោក-ពិភពលោកមួយដែលពេញទៅដោយអំពើបាប-ហើយវាហាក់ដូចជានៅនឹងផែនដីជាយូរមកហើយ អំពើអាក្រក់បន្ថែមទៀតជាសមាសធាតុ។ ខ្ញុំគិតថា ក្នុងគ្រប់ទាំងជំនាន់របស់មនុស្សបានមានភាពស្មុគស្មាញដោយសាររឿងអាក្រក់ៗបានមានក្នុងលោកនេះ។ ខ្ញុំចាំបានថា នៅពេលដែលខ្ញុំនៅក្មេង ខ្ញុំបានឮមនុស្សធំនិយាយពីរឿងអាក្រក់ៗដែលបានមាន ហើយឥឡូវនេះយើងនិយាយអំពីថា តើយើងស្មុគស្មាញដូចម្តេចពីអ្វីដែលកំពុងកើតមានក្នុងលោកនេះ ហើយលុះត្រាតែព្រះអម្ចាស់ត្រឡប់មកវិញជាមុនសិន កូនៗរបស់យើងនឹងអង្គុយនៅជុំវិញហើយនិយាយគ្នាអំពីអ្វីដែលអាក្រក់ជាងនេះនៅជំនាន់របស់ពួកគេ ជាងពួកគេធ្លាប់ជួប។ អំពើអាក្រក់និងអំពើឃោរឃៅមានភាពចម្រើនឡើងជាលំដាប់ ពួកវាមិនស្ថិតនៅដដែលឡើយ ប៉ុន្តែពួកវារួមបញ្ចូលគ្នានិងពហុគុណ។ ដេវ គាត់ចាំថា នៅពេលដែលក្មេងប្រុសអ្នកកាសែតដំបូងត្រូវបានគេប្លន់នៅក្នុងទីក្រុងរបស់យើង ហើយនោះប្រហែលជានៅឆ្នាំ១៩៥០។ វាជារឿងគួរឱ្យតក់ស្លុតដល់មនុស្សហើយពួកគេមិនអាចព្យាករណ៍មើលថាមានអ្វីមួយដូចនោះកើតឡើងឡើយ។ ប្រសិនបើយើងមើលទៅអ្វីដែលកំពុងកើតឡើងសព្វថ្ងៃនេះ ក្មេងប្រុសអ្នកកាសែតដែលត្រូវគេប្លន់នឹងមិនធ្វើអោយយើងរន្ធត់ឬតក់ស្លុតនោះឡើយ។ វាកំពុងធ្វើឱ្យចលាចលដែលលក្ខខណ្ឌទាំងនោះគឺពួកវាដូចជាអាក្រក់ខ្លាំងណាស់ ហើយគួរអោយសោកស្តាយ

រឿងរ៉ាវអាក្រក់ក្លាយមកជាការឈឺចាប់កាន់តែច្រើនឡើង។ ទោះបីជាយើងមិនមានគ្រប់ទាំងចំលើយ តែយើងមានឯកសិទ្ធិនៃការទុកចិត្តព្រះ។

តើព្រះជាម្ចាស់ការពារអស់អ្នកដែលដាក់ការទុកចិត្តរបស់ពួកគេក្នុងទ្រង់ឬ? ខ្ញុំពិតជាជឿថាទ្រង់ការពារពួកគេ។ យើងតែងតែឮថាព្រះជាម្ចាស់បានការពារអ្នកណាម្នាក់យ៉ាងដូចម្តេច ហើយយើងមានរឿងរបស់យើងផ្ទាល់ខ្លួនដែរ។ ប៉ុន្តែតើមានអ្វីកើតឡើងនៅពេលដែលការការពាររបស់ទ្រង់ហាក់ដូចជាមិននៅទីនោះ ហើយយើងធ្លាក់ទៅក្នុងការឈឺចាប់អ្វីមួយដែលយើងមិនបានយល់? ចូរត្រឡប់ទៅកាន់យោបល់ដ៏ឈ្លាសវៃម្តងទៀតដែលខ្ញុំបានឮពី លី ស្រ្តបែល: «ចំលើយចុងក្រោយរបស់ព្រះជាម្ចាស់ការរងទុក្ខវេទនាគឺមិនមែនជាការពន្យល់នោះទេ: វាគឺជាការកើតជាថ្មី។» មិនមាននរណាម្នាក់អាចពន្យល់បានទេ ប៉ុន្តែព្រះយេស៊ូអាចលោះវាទាំងអស់។

ថ្មីៗនេះបុគ្គលិកម្នាក់របស់យើងបានបាត់បង់ផ្ទះរបស់នាង ហើយទាំងអស់នោះនៅក្នុងទឹកជំនន់ដែលយើងមាននៅក្នុងផ្លូវ ល្វីស។ នាងគឺជាអ្នកដឹកនាំបេសកកម្មវេជ្ជសាស្ត្ររបស់យើង ហើយនាងបានធ្វើការលះបង់ដ៏អស្ចារ្យធ្វើដំណើរទៅកាន់ប្រទេសនៃសង្គ្រាមលោកលើកទីបីហើយជួយមនុស្សទាំងនោះ។ នាងជាស្ត្រីជឿព្រះយ៉ាងល្អហើយចេញពីគ្រួសារដែលជឿព្រះដ៏ល្អ។ ហេតុអ្វីបានជាអាចកើតយ៉ាងនេះចំពោះនាង? ពេលខ្លះរឿងឈឺចាប់កើតឡើងដោយសារតែយើងរស់នៅក្នុងលោកីយ៍នេះ។ ដំណឹងល្អគឺថា ព្រះជាម្ចាស់គឺជាការប្រោសលោះស្ថានភាពទាំងស្រុងរបស់នាង។ មនុស្សហើយនឹងព័ន្ធកិច្ចផ្សេងៗទៀតជួយគ្រួសាររបស់នាងសាងសង់ឡើងវិញនិងចំណាយលើអ្វីដែលពួកគេត្រូវការ ហើយនៅពេលដែលវាបញ្ចប់ នាងមានផ្ទះនិងសង្ឃារឹមដែលប្រសើរជាងពីមុន។

ខ្ញុំស្គាល់គ្រីស្ទបរិស័ទដទៃទៀតដែលស្ទើរតែបាត់បង់ផ្ទះរបស់ពួកគេ តែមិនបានបាត់បង់។ ពួកគេមានអារម្មណ៍ថាព្រះបានការពារពួកគេ ហើយពេលដែលយើងឮទីបន្ទាល់របស់ពួកគេ យើងមានអំណរជាមួយពួកគេ។ ហេតុអ្វីបានជាអ្នកខ្លះគេចរួចហើយអ្នកខ្លះគេចមិនរួច? ម្តងទៀត យើងមិនគួរពឹងផ្អែកលើការស្វែងរកការពន្យល់នោះទេ សូមត្រឡប់ទៅកាន់ការកើតជាថ្មីហើយមើលថាព្រះប្រោសលោះហើយស្តារឡើងវិញការឈឺចាប់ហើយបង្វែរវាទៅជាការលូតលាស់។

# ជំពូក ១២

## មួយផ្នែកទៀតនៃការរងទុក្ខវេទនា

*ជើងគាត់ត្រូវរឹតរួតជាប់ដោយចំណង ហើយមានច្រវាក់ដែកជាប់នៅប្រាណ*

ទំនុកតំកើង ១០៥៖១៨(KHOV)

លោក យ៉ូសែប ធ្លាប់ជាយុវជនវ័យក្មេងម្នាក់ជាមួយនឹងក្តីសុបិន្តនៃការធ្វើកិច្ចការដ៏អស្ចារ្យ។ បងប្រុសៗរបស់គាត់បានស្អប់និងច្រណែនគាត់ ពីព្រោះគាត់ជាកូនប្រុសពៅនិងជាកូនសំណព្វរបស់លោកយ៉ាកុប។ ការស្អប់របស់ពួកគេបានជំនួសមកនូវការដែលពួកគេបានទុកគាត់ខាងក្រៅមួយថ្ងៃហើយក៏បានលក់គាត់អោយទៅជាទាសកររបស់ពួកឈ្មួញ ហើយពួកគេបាននាំយកជំរៀកអាវដែលប្រឡាក់ទៅដោយឈាមប្រឡប់ទៅវិញ ហើយកុហកឪពុករបស់ពួកគេ ដោយនិយាយថាលោកត្រូវបានសម្លាប់ដោយសត្វសាហាវ។

យ៉ូសែបឆ្លងកាត់សេចក្តីទុក្ខព្រួយអស់រយៈពេលជាច្រើនឆ្នាំ ស្ថានភាពអយុត្តិធម៌យ៉ាងធ្ងន់បណ្តាលឲ្យគាត់មានសេចក្តីឈឺចាប់យ៉ាងខ្លាំង ហើយគាត់នៅតែមានសេចក្តីជំនឿយ៉ាងពេញបរិបូណ៌ទៅលើព្រះជាម្ចាស់និងបន្តទុកចិត្តទ្រង់។ ព្រះជាម្ចាស់បានប្រទាននូវសេចក្តីមេត្តាករុណាដល់លោក នៅគ្រប់កន្លែងដែលលោកនៅ ហើយទីបញ្ចប់លោកត្រូវបានតែងតាំងជាមនុស្សក្នុងលំដាប់ទីពីរក្រោមផារ៉ោននៃរាជាធិរាជ្យអេស៊ីព្ទ។ ជាលទ្ធផល ព្រះជាម្ចាស់បានប្រើយ៉ូសែប ដើម្បីសង្គ្រោះមនុស្សជាច្រើន រួមទាំងគ្រួសាររបស់លោកដែរ ពីទុរភិក្សកំឡុងពេលលើផែនដីនេះមានភាពអត់ឃ្លានជាច្រើន។ វាជាការអស្ចារ្យណាស់ក្នុងការដែលមើលទៅការឆ្លើយតបរបស់លោកយ៉ូសែប ទៅកាន់បងប្រុសៗរបស់គាត់នៅពេលដែលពួកគេបានរកឃើញថាគាត់បាននៅក្នុងតួនាទីនៃអំណាច ហើយអាចនឹងសងត្រឡប់ទៅពួកគេវិញសម្រាប់គ្រប់ទាំងការឈឺចាប់ និងការរងទុក្ខវេទនា ដែលគាត់បានអត់ធ្មត់ដោយអយុត្តិធម៌ ពីព្រោះតែភាពឃោរឃៅរបស់ពួកគេចំពោះគាត់ជាច្រើនឆ្នាំកន្លងទៅ:

នោះបងប្រុសៗរបស់គាត់បានទៅហើយអោនក្រាបចុះនៅចំពោះមុខ

> របស់គាត់ និយាយថា មើល យើងជាអ្នកបំរើរបស់លោក (ទាសករ)! ហើយយ៉ូសែបនិយាយទៅកាន់ពួកគេថា កុំឲ្យខ្លាចអ្វីឡើយ ដ្បិតតើខ្ញុំជាព្រះឬអ្វី? {សេចក្តីសងសឹកជារបស់ទ្រង់ មិនមែនជារបស់ខ្ញុំនោះទេ} អ្នករាល់គ្នាបានគិតអាក្រក់ដល់ខ្ញុំ តែព្រះទ្រង់សំរេចជាការល្អវិញ ដើម្បីនឹងសង្គ្រោះដល់ជីវិតមនុស្សជាច្រើន ដូចជាបានកើតមានសព្វថ្ងៃនេះ។
>
> លោកុប្បត្តិ៥០៖១៨-២០(KHOV)

ខគម្ពីរទាំងនេះពេញដោយភាពអស្ចារ្យ ប្រសិនបើយើងគិតពិចារណាដោយយកចិត្តទុកដាក់។ បន្ទាប់ពីយ៉ូសែបបានឆ្លងកាត់រឿងទាំងអស់នោះ ជំនួសឲ្យភាពល្វីងជូរចត់ គាត់បានឃើញព្រះហស្តរបស់ព្រះជាម្ចាស់ដែលបានធ្វើកិច្ចការដ៏ល្អនៅគ្រប់ស្ថានភាពទាំងអស់។ ឥឡូវនេះជាជាងការល្វីងជូរចត់ គាត់បានរៀបចំជាស្រេចដើម្បីជួយដល់បងៗរបស់គាត់។ នេះគឺជាផ្នែកមួយនៃសំដីរបស់គាត់ៈ

> ឥឡូវនេះ សូមបងៗកុំព្រួយបារម្ភអ្វី ខ្ញុំនឹងជួយទំនុកបម្រុងបងៗ និងកូនចៅរបស់បងៗ។ លោកយ៉ូសែបលើកទឹកចិត្តបងៗ ដោយនិយាយជាមួយគេយ៉ាងស្និតស្នាល។
>
> លោកុប្បត្តិ ៥០៖២១(KHOV)

យ៉ូសែបជាវីរៈបុរសរបស់ខ្ញុំ នៅពេលដែលវាមកដល់អ្នកណាម្នាក់ដែលធ្លាប់មានបទពិសោធន៍នៃការដែលរងទុក្ខព្រួយយ៉ាងធ្ងន់ធ្ងរ ភាពអយុត្តិធម៌ ហើយបានដោះស្រាយវាយ៉ាងត្រឹមត្រូវតាមរបៀបដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើ។ មិនគួរឲ្យឆ្ងល់នោះទេ គាត់ជាមនុស្សដែលបានពេញដោយអំណាច។ គាត់បានរស់នៅមានអាយុមួយរយដប់ឆ្នាំ ហើយសេចក្តីអំណរបានកើតមាននៅក្នុងជីវិតរបស់គាត់យ៉ាងល្អជាច្រើនឆ្នាំជាង ពេលមួយដែលពួកគេបានធ្វើឲ្យគាត់ឈឺចាប់។ យ៉ូសែបបានសប្បាយរីករាយនឹងជ័យជំនះដ៏អស្ចារ្យលើផ្នែកដទៃទៀតនៃការសឺចាប់របស់គាត់។ យើងអាចនិយាយបានថា ការឈឺចាប់របស់គាត់បានជំរុញគាត់ទៅកាន់ជីវិតដែលប្រសើរឡើង។ ប្រសិនបើយើងនៅតែនឹងធឹងនិងបន្តទុកចិត្តព្រះជាម្ចាស់ ទោះបីជានៅក្នុងសេចក្តីឈឺចាប់របស់យើងក៏ដោយ នោះយើងបង្ហាញថាយើងជាប្រភេទមនុស្សដែលព្រះជាម្ចាស់អាចទុកចិត្តជាមួយទំនួលខុសត្រូវដ៏ធំសម្បើមនិងព្រះពរដ៏មហិមា។

នៅពេលដែលយើងមានអារម្មណ៍ អត់ទោសដល់អ្នកដែលធ្វើឲ្យយើងឈឺចាប់ យើងពិតជាធ្វើឲ្យខ្លួនយើងជាមនុស្សម្នាក់ដែលអនុគ្រោះ ពីព្រោះវាមិនអាចទៅរួចទេ

ដែលក្នុងពេលតែមួយមនុស្សមានអំណរនៃជីវិតហើយក៏ពេញទៅដោយភាពល្វីងជូរចត់នោះ។ នេះជាឧទាហរណ៍ដែលយើងឃើញពីជិវិតរបស់លោកយ៉ូសែបដែលយើងអាចនឹងយកជាគំរូបាន។

*នៅពេលដែលយើងមានអារម្មណ៍ថាបានបំភ្លេចអស់អ្នកដែលធ្វើឲ្យយើងឈឺចាប់ ជាការពិតគឺយើងបានធ្វើឲ្យខ្លួនយើងជាមនុស្សម្នាក់ដែលចេះអនុគ្រោះ។*

កុំឡុងពេលជាច្រើនឆ្នាំបន្ទាប់ពីយ៉ូសែបត្រូវបានលក់ទៅក្នុងភាពជាទាសករ គាត់ជាប់គុគអស់រយៈពេលដប់បីឆ្នាំសម្រាប់អ្វីដែលមិនមែនជាកំហុសរបស់គាត់។ គាត់បានជាប់ច្រវាក់ដែក ហើយនៅក្នុងសៀវភៅទំនុកដំកើង១០៥ ដែលខ្ញុំបានលើកយកមកខាងលើយើងបានប្រាប់ថា «ព្រលឹងរបស់គាត់ជាប់នៅក្នុងច្រវាក់ដែក។» តើវាមានន័យថាដូចម្ដេច? ប្រសិនបើយើងគិតអំពីវានៅក្នុងកម្រិតជាក់ស្ដែង វាហាក់ដូចជាខ្ញុំថា ប្រសិនព្រលឹងរបស់គាត់ជាប់ច្រវាក់ វាបានធ្វើឲ្យគាត់រឹងមាំឡើង។ ក្នុងន័យមួយផ្សេងទៀត ការរងទុក្ខរបស់គាត់បានធ្វើអោយគាត់ជាមនុស្សម្នាក់ដែលប្រសើរហើយជួយកសាងគាត់ដើម្បីដឹកនាំលើអេស៊ីព្ទ។

ជាញឹកញាប់យើងឮប្រយោគនេះ «បញ្ហារបស់យើងអាចធ្វើឲ្យយើងប្រសើរឬជូរចត់។ ការទុកចិត្តលើព្រះជាម្ចាស់គ្រប់វិធីតាមរយៈស្ថានភាពដ៏ឈឺចាប់ តែងតែនាំមកជាមួយនូវរង្វាន់និងភាគលាភនៅទីបញ្ចប់។មួយនៃរង្វាន់គឺថាវាធ្វើឲ្យអ្នករឹងមាំឡើង។

នៅក្នុងព្រះគម្ពីរអេសាយ យើងឃើញថាព្រះមានព្រះបន្ទូលតាមរយៈហោរាទៅកាន់មនុស្ស ហើយលើកទឹកចិត្តពួកគេមិនអោយខ្លាចនឹងអ្វីដែលពួកគេឆ្លងកាត់ ពីព្រោះទ្រង់បានឲ្យពួកគេរឹងមាំឡើងៈ

> កុំភ័យខ្លាចអ្វីយើងស្ថិតនៅជាមួយអ្នក កុំព្រួយបារម្ភអោយសោះ យើងជាព្រះរបស់អ្នក យើងនឹងអោយអ្នកមានកម្លាំងរឹងប៉ឹង យើងជួយអ្នក យើងគាំទ្រអ្នក យើងនឹងសំដែងបារមី រកយុត្តិធ៌មអោយអ្នក...
> យើងនឹងធ្វើអោយអ្នកប្រែទៅជារនាស់ថ្មី ដែលមានធ្មេញយ៉ាងមុត អ្នកនឹងវាក់កំទេចភ្នំតូចធំ អោយទៅជាធូលីដី។
>
> អេសាយ ៤១៖១០,១៥(KHSV)

នេះជាឧទាហរណ៍ផ្សេងទៀតដែលព្រះជាម្ចាស់សន្យាថា ប្រើប្រាស់នូវអ្វីដែលយើងឆ្លងកាត់ដើម្បីឲ្យយើងរឹងមាំឡើងនិងប្រសើរជាងយើងកាលពីមុន។ ប៉ុន្តែទាំងអស់នេះសុទ្ធតែអាស្រ័យលើថាតើយើងនឹងទុកចិត្តទាំងស្រុងលើព្រះអំពីរឿងឈឺចាប់

ដែលយើងជួបប្រទះក្នុងជីវិតឬទេ។ អ្វីដែលអ្នកអាចឆ្លងកាត់ឥឡូវនេះ សេចក្ដីសន្យានេះគឺសម្រាប់អ្នក។ សត្រូវរបស់អ្នកអាចមានគ្រោះថ្នាក់ដល់អ្នក ប៉ុន្តែព្រះជាម្ចាស់នឹងធ្វើការនេះឲ្យចេញមកយ៉ាងល្អ ហើយនៅក្នុងដំណើរការនេះ ទ្រង់នឹងធ្វើអោយអ្នកជាមនុស្សដែលប្រសើរឡើង។ នៅពេលដែលជីវិតក្នុងសេចក្ដីឈឺចាប់និងលំបាក ចូរចាំថាព្រះជាម្ចាស់ស្រលាញ់អ្នក ហើយដោយព្រះដូច្នេះអ្នកមិនត្រូវមានសេចក្ដីភ័យខ្លាចនោះទេ។ នៅទីនេះមានជារឿងខ្លីមួយដែលខ្ញុំធ្លាប់បានឮនៅពេលមួយ ដែលធ្វើឱ្យចំណុចនេះនៅក្នុងវិធីដ៏គួរឱ្យស្រឡាញ់:

បុរសម្នាក់ទើបនឹងរៀបការរួច ហើយបានត្រឡប់ទៅផ្ទះជាមួយនឹងភរិយារបស់គាត់។ ផ្នែកនៃដំណើររបស់ពួកគេតម្រូវឱ្យពួកគេឆ្លងកាត់បឹងជាមួយនឹងទូក។ ខណៈពេលដែលពួកគេកំពុងឆ្លង ព្យុះក៏បានបក់បោកមកដែលបណ្ដាលឲ្យទូកខ្ទាតយ៉ាងខ្លាំង ហើយស្ត្រីក៏មានការភ័យខ្លាច។ ស្វាមីរបស់នាង ទោះជាយ៉ាងនេះ គាត់ហាក់ដូចជាស្ងប់ស្ងាត់ ហើយនាងបានសួរប្ដីរបស់នាងថាហេតុអ្វីគាត់មិនភ័យខ្លាច។

គាត់(ប្ដី)បានញញឹមហើយបានដកយកកាំបិទពីស្រោមរបស់វា ហើយកាន់វាដើរទៅកាន់នាងហាក់ដូចជាគាត់កំពុងនឹងធ្វើបាបនាង។ នាងមិនបានគេចចេញពីវានោះទេហើយនៅពេលដែលគាត់សួរនាងថាហេតុអ្វីបានជានាងមិនខ្លាច នាងបាននិយាយថា «តើហេតុអ្វីបានជាខ្ញុំគួរនឹងខ្លាច? ខ្ញុំដឹងថាបងស្រលាញ់ខ្ញុំ ហើយវាមិនអាចទៅរួចទេដែលបងនឹងធ្វើបានខ្ញុំ។»

បុរសបាននិយាយថា «នោះជាហេតុផលដែលបងមិនខ្លាចនៅក្នុងព្យុះនេះ។ បងដឹងថាព្រះជាម្ចាស់ស្រលាញ់យើង ហើយគ្មានបញ្ហាទេថានឹងមានអ្វីកើតឡើង ទ្រង់នឹងធ្វើការនេះយ៉ាងល្អសម្រាប់យើង។»

មិនមានបញ្ហាទេថាមានព្យុះប៉ុន្មានដែលយើងជួបនៅក្នុងជីវិតនោះទេ យើងតែងតែមានសុវត្ថិភាពក្នុងព្រះហស្តនៃក្តីស្រលាញ់របស់ព្រះ។

## *ការអាណិតអាសូរនិងការយល់ចិត្ត*

ខ្ញុំបានរកឃើញថាការឈឺចាប់ផ្ទាល់ខ្លួនរបស់ខ្ញុំនៅក្នុងជីវិតបានជួយខ្ញុំ អោយមានការអាណិតអាសូរខ្លាំងជាង មុនសម្រាប់អស់អ្នកដែលទទួលរងការឈឺចាប់ តាមមធ្យោបាយមួយចំនួន។ ប្រសិនបើយើងមិនមានបទពិសោធន៍ការឈឺចាប់នៃការធ្វើបាបនិងការជួបការបាត់បង់ វាពិតពិបាកខ្លាំងណាស់ដើម្បីទាក់ទងទៅនឹងអ្វីដែលអ្នកដទៃកំពុងឆ្លងកាត់។

វាងាយស្រួលក្នុងការផ្តល់ដំបូន្មាន ប៉ុន្តែដោយសារការមិនមានបទពិសោធន៍ណាមួយ នោះអាកប្បកិរិយារបស់យើងអាចនឹងត្រូវប្រានចោល។ ចូរធ្វើដូចជាថា ខ្ញុំមានអាយុម្ភៃប្រាំឆ្នាំហើយជីវិតសម្រាប់ខ្ញុំវាស្រស់ស្អាតងាយស្រួលសម្រាប់ចំណុចនេះ។ ខ្ញុំមានឪពុកម្តាយដ៏អស្ចារ្យដែលតែងតែផ្គត់ផ្គង់ខ្ញុំ ហើយបានផ្តល់អោយខ្ញុំគ្រប់យ៉ាងសម្រាប់អ្វីដែលខ្ញុំត្រូវការ។ ខ្ញុំជាមនុស្សដែលឈ្លាសវៃ ដូច្នេះការទទួលនិទ្ទេសល្អវាបានមកដោយងាយសម្រាប់ខ្ញុំនៅក្នុងសាលា។ ឪពុករបស់ខ្ញុំបានរ៉ាប់រងការងារក្នុងក្តីសុបន្តិមួយសម្រាប់ខ្ញុំ ពីមួយនៃសហការីអាជីវកម្មរបស់គាត់តាំងតែមុនពេលដែលខ្ញុំបានបញ្ចប់សញ្ញាប័ត្រពីសាលាម្ល៉េះ។ជីវិតគឺល្អ! ឥឡូវនេះហការីម្នាក់នៅកន្លែងធ្វើការអ្នកដែលផ្តល់ឲ្យខ្ញុំបានដឹងច្បាស់ដូចជាការបានទទួលការលើកទឹកចិត្ត ហើយសូម្បីតែការធ្លាក់ទឹកចិត្ត ហើយខ្ញុំឆ្ងល់ថាតើមានអ្វីខុស ប៉ុន្តែខ្ញុំមិនរវល់នឹងសួរនោះទេ។ ជាការពិតណាស់ មិត្តរបស់ខ្ញុំបានព្យាយាមប្រាប់ខ្ញុំអំពីការតស៊ូនឹងបញ្ហាហិរញ្ញវត្ថុដ៏ធ្ងន់ធ្ងរមួយចំនួនដែលនាងបានជួប។ ខ្ញុំបានឲ្យយោបល់យ៉ាងលឿនថា ឲ្យនាងទូរស័ព្ទទៅឪពុកម្តាយរបស់នាងសូមពួកគេឲ្យជួយនាង ពីព្រោះវាជាអ្វីដែលខ្ញុំគួរនឹងធ្វើ។ នាងបានប្រាប់ខ្ញុំថា ឪពុកម្តាយរបស់នាងបានរំលោភបំពានលើនាងនៅពេលធំពេញវ័យ ដូច្នេះហើយទើបពួកគេឃ្លាតឆ្ងាយពីគ្នា។ នាងអះអាងប្រាប់ខ្ញុំថា ការទទួលជំនួយពីពួកគេវាមិនអាចទៅរួចនោះទេ។ ខ្ញុំមិនអាចនឹងប្រមើល៍មើលថាឪពុកម្តាយរំលោភបំពានកូនៗ ឬមិនជួយពួកគេនោះទេ ខ្ញុំប្រានចោលបញ្ហារបស់នាងជាមួយការមិនចាប់អារម្មណ៍នឹងស្ថានភាពអ្វីទាំងអស់។ ខ្ញុំបាននិយាយថា «កុំបារម្ភ, នឹងមានអ្វីមួយកើតឡើង» ហើយខ្ញុំបានដើរចេញទៅ។

មិត្តរបស់ខ្ញុំបានចាកចេញទៅទាំងអារម្មណ៍ទទេស្អាតនឹងឯកោ។ ផ្នែកមួយដែលគួរឲ្យក្រៀមក្រំនោះ គឺថាខ្ញុំបានទទួលព្រះពរផ្នែកហិរញ្ញវត្ថុយ៉ាងបរិបូណ៌ ដែលខ្ញុំអាចនឹងងាយស្រួលផ្តល់ជំនួយដល់នាងខ្លះដោយខ្លួនរបស់ខ្ញុំ ប៉ុន្តែកង្វះបទពិសោធន៍ជាមួយការឈឺចាប់របស់ខ្ញុំធ្វើឲ្យខ្ញុំមិនយល់ទៅដល់ទឹកចិត្ត អស់អ្នកដែលមានសេចក្តីឈឺចាប់។

មានមនុស្សរបៀបនេះជាច្រើននៅលើលោកនេះ។ ពួកគេមិនមែនជាមនុស្សអាក្រក់ទេ ប៉ុន្តែពួកគេមិនធ្លាប់មានបទពិសោធន៍។ ជាយថាហេតុពួកគេនឹងជួបប្រទះការលំបាកខ្លះៗក្នុងជីវិតនោះ ដោយមានក្តីសង្ឃឹម នឹងផ្លាស់ប្តូរពួកគេសម្រាប់ការដែលប្រសើរ។

ខ្ញុំមិនដូចជាមនុស្សអាយុម្ភៃប្រាំឆ្នាំម្នាក់ ដែលមានជីវិតងាយស្រួលនោះទេ។ ខ្ញុំមិនមានឪពុកម្តាយដែលស្រលាញ់ខ្ញុំយ៉ាងពិតប្រាកដ ឬក៏ជួយខ្ញុំក្នុងមធ្យោបាយផ្សេង

នោះទេក្នុងរយៈពេលនៃការធំធាត់របស់ខ្ញុំ ហើយពួកគេបានរំលោភបំពានលើខ្ញុំ។ កុមារភាពរបស់ខ្ញុំបានពេញទៅដោយភាពភ័យខ្លាច ការឈឺចាប់ និងភាពឯកោ។ ខ្ញុំអាចនិយាយបានថាខ្ញុំបានចេញពីកុមារភាពរបស់ខ្ញុំជាមួយនឹង សេចក្តីមេត្តាករុណាយ៉ាងច្រើនសម្រាប់អស់អ្នកដែលដែលកំពុងរងទុក្ខវេទនា ប៉ុន្តែជំនួសមកវិញខ្ញុំគ្រាន់តែមានដួងចិត្តដែលរឹងរូសប៉ុណ្ណោះ។ វាមានទំនាក់ទំនងយ៉ាងជ្រៅជាមួយនឹងព្រះគ្រីស្ទ ហើយរយៈពេលពីរបីឆ្នាំដែលពេញទៅដោយបទពិសោធន៍ជាច្រើនតាមរយៈសេចក្តីឈឺចាប់និងការរងទុក្ខវេទនាផ្ទាល់ខ្លួន មុនពេលដែលខ្ញុំបានទទួលការកែប្រែ។

នៅពេលដែលខ្ញុំមានជំងឺមហារីក ខ្ញុំបានពេញទៅដោយការអាណិតអាសូរសម្រាប់អស់អ្នកដែលទទួលបានរោគវិនិច្ឆ័យដែលធ្ងន់ធ្ងរនេះដែរ។ បន្ទាប់ពីខ្ញុំមានការឈឺក្បាលប្រកាំងអស់រយៈពេលដប់ឆ្នាំមក ឥឡូវនេះខ្ញុំមានសេចក្តីជំនឿដើម្បីអធិស្ឋានដោយក្តី អាណិតអាសូរសម្រាប់ការប្រោសឲ្យ ជាដល់មនុស្សដែលមានជំងឺឈឺក្បាលនេះ។ តាមរយៈព្រះគុណរបស់ព្រះនឹងព្រះបន្ទូលរបស់ទ្រង់ នៅទីបញ្ចប់ខ្ញុំបានអត់ទោសឲ្យឪពុករបស់ខ្ញុំសម្រាប់ការរំលោភបំពានខ្ញុំ ហើយខ្ញុំដឹងជាលើកទីមួយថាវាងាយស្រួលក្នុងការអត់ទោសជាងការពេញទៅដោយសេចក្តីស្អប់ខ្ពើម និងភាពល្វីងជូរចត់។ ខ្ញុំចាប់ផ្តើមព័ន្ធកិច្ចដោយមិនមានអ្វីទាំងអស់ក្រៅពីព្រះនឹងសុបិន្ត ហើយខ្ញុំនៅតែដូច្នេះនៅសែសិបឆ្នាំបន្ទាប់។ ខ្ញុំបានរៀនជាច្រើនដោយបទពិសោធន៍ ប៉ុន្តែវាត្រូវបានចំណាយថ្លៃយ៉ាងខ្ពស់។ ខ្ញុំមានបទពិសោធន៍ មនុស្សជាច្រើនដែលរិះគន់និងរិះគន់ខ្ញុំ ហើយមានអារម្មណ៍ថាខ្ញុំមិនសមរម្យសំរាប់ព័ន្ធកិច្ច សំរាប់ហេតុផលផ្សេងៗជាច្រើន ប៉ុន្តែខ្ញុំក៏មានបទពិសោធន៍នៃជាសុកភាពពីព្រះក្នុងស្ថានភាពទាំងនោះផងដែរ ហើយឥឡូវនេះខ្ញុំអាចធ្វើឲ្យអ្នកដទៃមានជាសុកភាព។ ព្រះបង្រៀនយើងពីព្រះគុណនៃការនាំភាពសុខស្រួលទៅដល់អស់អ្នក ដែលកំពុងរងទុក្ខដោយលើកទឹកចិត្តយើងដោយអង្គទ្រង់ផ្ទាល់នៅពេលដែលយើងឈឺចាប់។

> សូមលើកតម្កើងព្រះជាម្ចាស់ ជាព្រះបិតារបស់ព្រះយេស៊ូ ជាអម្ចាស់នៃយើង។ ព្រះអង្គជាព្រះបិតាប្រកបដោយព្រះហឫទ័យមេត្តាករុណា និងជាព្រះដែលជួយសំរាលទុក្ខគ្រប់បែបយ៉ាងទាំងអស់ ព្រះអង្គសំរាលទុក្ខយើង នៅពេលដែលយើងងមានទុក្ខវេទនាសព្វបែបយ៉ាង ដើម្បីឲ្យយើងអាចសំរាលទុក្ខអស់អ្នកដែលមានទុក្ខវេទនា ព្រោះព្រះជាម្ចាស់ប្រទានឲ្យយើងផ្ទាល់បានធូរស្បើយរួចហើយដែរ។
>
> ២កូរិនថូស ១៖៣-៤(KHSV)

ខ្ញុំតែងតែនឹកឃើញថាវាញឹកញាប់ប៉ុណ្ណា ដែលខ្ញុំតែងតែព្យាយាមចែករំលែកជាមួយនឹងមនុស្សដទៃនូវអ្វីដែលខ្ញុំបានឆ្លងកាត់ ហើយពួកគេពិតជាមិនដឹងថាត្រូវជួយខ្ញុំយ៉ាងណានោះទេ។ ពួកគេអាចនឹងមិនលួងលោមខ្ញុំពីព្រោះពួកគេមិនធ្លាប់ត្រូវការឲ្យព្រះជាម្ចាស់លួងលោមពួកគេ ឬក៏ប្រហែលជាពួកគេត្រូវការការលួងលោម ប៉ុន្តែពួកគេមិនដឹងថាតើគួរសូមនិងទទួលដោយរបៀបណា។ ខ្ញុំតែងតែនិយាយថា យើងមិនអាចឲ្យនូវអ្វីដែលយើងមិនមាននោះទេ។ ដំបូងគឺយើងត្រូវទទួលពីព្រះជាម្ចាស់ ហើយបន្ទាប់មកអ្វីដែលទ្រង់បានប្រទានឲ្យគឺអាចបង្ហូរដល់អ្នកដទៃទៀតតាមរយៈយើង។

នៅពេលដែលមនុស្សមករកយើងជាមួយនឹងបញ្ហារបស់គេ មានជាច្រើនដងដែលពួកគេដឹងរួចជាស្រេចថាយើងមិនអាចដោះស្រាយឲ្យពួកគេបាន។ អ្វីដែលពួកគេត្រូវការយ៉ាងពិតប្រាកដគឺការយល់ ការលួងលោម និងសេចក្តីអាណិតអាសូរ។ នៅជ្រុងមួយទៀតនៃការរងទុក្ខវេទនា យើងអាចក្លាយមកជាមនុស្សមិនរឹងរូស ទន់ភ្លន់ ចាស់ទុំ សុភាពរាបសារហើយមានភាពអាណិតអាសូរច្រើន និងការចេះយល់ចិត្តអ្នកដទៃ។ គុណសម្បត្តិទាំងនេះ ជាចំនួនមួយដែលយើងស្ងើចសសើរនៅក្នុងព្រះរបស់យើង ហើយពួកគេឲ្យឈ្មោះយើងជាបេសកជននៅក្នុងនាមទ្រង់។

ការអភិវឌ្ឍន៍សេចក្តីមេត្តាករុណានិងការយល់ចិត្តអ្នកដទៃ សម្រាប់មនុស្សដទៃទៀតគឺជាចំណែកមួយនៃព្រះពរដែលយើងបញ្ចប់ លើផ្នែកផ្សេងទៀតនៃសេចក្តីរងទុក្ខវេទនា។ អំណោយទាននៃសេចក្តីមេត្តាករុណាគឺមានតម្លៃខ្លាំងណាស់ដល់នរណាម្នាក់ដែលកំពុងឈឺចាប់!

វាមិនមែនជាការឈឺចាប់របស់យើងតែឯងនោះទេ ដែលធ្វើឲ្យយើងមានលក្ខណៈគ្រប់គ្រាន់ដើម្បីព្រះជាម្ចាស់ប្រើប្រាស់សម្រាប់ជួយអ្នកដទៃ។ ជាការពិតណាស់ ព្រះអាចហើយប្រើមនុស្សដែលមានឪពុកម្តាយដ៏អស្ចារ្យ មានកុមារភាពយ៉ាងល្អ មិនមានបញ្ហាផ្នែកហិរញ្ញវត្ថុហើយមានគុណសម្បត្តិផ្សេងៗទៀត។ ទោះជាយ៉ាងណាក៏ដោយ មានមនុស្សមួយចំនួនតូចប៉ុណ្ណោះ ជាធម្មតាពីព្រោះជីវិតកើតឡើងចំពោះយើងរាល់គ្នា ហើយវាមិនជាទីពេញចិត្តគ្រប់ពេលនោះទេ។

## *ទំនាក់ទំនងដ៏ស៊ីជំរៅជាមួយព្រះជាម្ចាស់*

អត្ថប្រយោជន៍មួយ ដែលខ្ញុំបានរកឃើញនៅផ្នែកផ្សេងទៀតនៃសេចក្តីទុក្ខវេទនា គឺ

ការមានទំនាក់ទំនងដ៏ស៊ីជំរៅជាមួយព្រះជាម្ចាស់។ នៅពេលដែលយើងត្រូវបានដាក់ទៅក្នុងទីកន្លែងដែលយើងគ្មាននរណាម្នាក់អាចជួយយើង លើកលែងតែព្រះហើយយើងដាក់សេចក្ដីទុកចិត្តលើទ្រង់ យើងមានបទពិសោធន៍ដ៏អស្ចារ្យថាទ្រង់ជាអ្នកណាហើយទ្រង់ល្អប៉ុណ្ណា។ យើងមានបទពិសោធន៍នឹងសេចក្ដីស្មោះត្រង់របស់ទ្រង់ សេចក្ដីយុត្តិធ៌មរបស់ទ្រង់ សេចក្ដីសប្បុរស ព្រះគុណ ប្រាជ្ញា ហើយនឹងអំណាច ដើម្បីដាក់ឈ្មោះត្រឹមតែពីរបី។ លោកសាវកប៉ុលបាននិយាយថា គោលបំណងរបស់គាត់គឺចង់ស្គាល់ព្រះគ្រីស្ដហើយ ស្គាល់កាន់តែស៊ីជំរៅនិងជិតស្និទ្ធជាមួយនឹងភាពអស្ចារ្យនៃមនុស្សរបស់ទ្រង់។ គាត់បាននិយាយថា គាត់ចង់ស្គាល់អំណាចនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះគ្រីស្ដហើយបន្ទាប់មកលោកនិយាយថា «{នោះខ្ញុំគួរតែចែករំលែក} ព្រមទាំងចូលរួមជាមួយព្រះអង្គដែលរងទុក្ខលំបាក»(ភីលីព ៣៖១០)។

មានចំនុចដ៏មានអនុភាពជាច្រើននៅក្នុងខគម្ពីរនេះ៖

### ១.ប៉ូលបានប្ដេជ្ញាចិត្ត!

ការប្ដេជ្ញាចិត្តគឺត្រូវបានទាមទារប្រសិនបើយើងចង់សម្រេចអ្វីមួយនៅក្នុងជីវិត។ វាគឺមិនមែនជាអ្វី ដែលយើងធ្វើបានត្រឹមត្រូវម្ដងឬពីរដងហើយវានាំទៅរកជ័យជំនះនោះទេ ប៉ុន្តែអ្វីដែលយើងធ្វើត្រឹមត្រូវម្ដងហើយម្ដងទៀតដែលនាំយើងទទួលបានលទ្ធផល

### ២. លោកប៉ូលចង់ស្គាល់ព្រះគ្រីស្ទហើយស្គាល់កាន់តែស៊ីជំរៅនិងជិតស្និទ្ធ

គាត់មិនគ្រាន់តែចង់ដឹង *អំពី* ទ្រង់ប៉ុណ្ណោះទេ គាត់ចង់*ស្គាល់ទ្រង់*! គាត់ចង់មានភាពស្និតស្នាល មានទំនាក់ទំនងផ្ទាល់ខ្លួនជាមួយនឹងទ្រង់។ នេះគឺអាចទៅរួចដែលអ្នកណាម្នាក់ដែលប៉ងប្រាថ្នានឹងមានឆន្ទះស្វែងរកព្រះជាម្ចាស់អស់ពីដួងចិត្តរបស់គេ។

### ៣. លោកប៉ូលចង់ស្គាល់ភាពអស្ចារ្យនៃអង្គព្រះគ្រីស្ទកាន់តែខ្លាំងឡើងនឹងជាក់ច្បាស់

លោកប៉ូលបានស្គាល់ព្រះគ្រីស្ទ។ គាត់មានការជួបប្រទះដ៏អស្ចារ្យមួយជាមួយនឹងទ្រង់នៅតាមផ្លូវទៅឌាម៉ាស់ ហើយគាត់បានស្រាវជ្រាវបន្ថែម។ យើងមិនគួរនឹងស្កប់ស្កល់នោះទេប្រសិនបើយើងនៅមិនទាន់បានលូតលាស់ផ្នែកព្រលឹងវិញ្ញាណ។ មានរឿងជាច្រើនដែលយើងរៀនអំពីថាតើព្រះគ្រីស្ទអស្ចារ្យយ៉ាងណា ហើយយើងនឹងស្គាល់ទ្រង់កាន់តែច្រើនឡើងប្រសិនបើយើងស្វែងរកទ្រង់កាន់តែច្រើននោះ។ ដូចដែលយើងធ្វើដំណើរក្នុងជីវិតជាមួយទ្រង់ យើងឃើញថាទ្រង់គង់ជាមួយយើងក្នុងគ្រប់ស្ថានភាពទាំងអស់។ ទ្រង់មិនដែលចាកចេញឬបោះបង់យើងឡើយ។

៤. លោកប៉ូលចង់មានពិសោធន៍ជាមួយនឹងអំណាចនៃការរស់ឡើងវិញរបស់ព្រះគ្រីស្ទដែលលើកយើងចេញផុតពីសេចក្តីស្លាប់ទោះបីយើងនៅក្នុងរូបកាយក្តី។

នៅពេលដែលយើងស្គាល់ព្រះយេស៊ូស៊ីជំរៅយ៉ាងពិតប្រាកដនិងស្និតស្នាល យើងអាចមានសន្តិភាពនិងអំណរសូម្បីតែនៅក្នុងពេលមានភាពលំបាកក្តី។ យើងទុកចិត្តដែលទ្រង់ធ្វើការល្អៗ ពីអ្វីដែលយើងកំពុងដោះស្រាយមិនថាវាឈឺចាប់ខ្លាំងប៉ុណ្ណានោះទេ។ យើងមិនចាំបាច់ត្រូវរស់នៅក្នុងជីវិតដែលបរាជ័យទេ នៅពេលដែលអំណាចនៃការមានព្រះជន្មរស់ឡើងវិញរបស់ព្រះយេស៊ូអាចទៅបាន។

នៅពេលដែលយើងមានបទពិសោធន៍ជាមួយនឹងអំណាចរបស់ព្រះជាម្ចាស់ នៅក្នុងជីវិតរបស់យើង វានឹងមានភាពងាយស្រួលក្នុងការទុកចិត្តលើទ្រង់នៅពេលក្រោយនៅពេលដែលយើងមានតម្រូវការ។ ព្រះចង់បង្ហាញអំណាចរបស់ទ្រង់នៅក្នុងយើងនិងតាមរយៈយើង។ ទ្រង់មិនគ្រាន់តែចង់រំដោះយើងប៉ុណ្ណោះទេ ប៉ុន្តែទ្រង់ចង់ប្រើយើងជារាជទូតដើម្បីនាំមនុស្សទៅថ្វាយព្រះគ្រីស្ទ។

ប្រសិនអ្នកឬខ្ញុំឆ្លងកាត់ភាពលំបាកដ៏ធ្ងន់ធ្ងរមួយចំនួន ហើយមនុស្សដទៃឃើញថាយើងនៅតែបន្តទុកចិត្តលើព្រះ ហើយប្រកាន់ភ្ជាប់នូវសន្តិភាពនិងឥរិយាបថនៃក្តីអំណរ វាជាទីបន្ទាល់ដល់ពួកគេអំពីការរក្សាអំណាចរបស់ព្រះជាម្ចាស់។ នៅពេលដែលយើងរង់ចាំដោយការអត់ធ្មត់ វាក៏មិនមានបញ្ហាថាវាមានរយៈពេលយូរប៉ុណ្ណានោះទេ វាជាបន្ទាល់ដល់ពួកគេអំពីអំណាចដ៏ស្ថិតស្ថេររបស់ព្រះជាម្ចាស់។ បន្ទាប់ពីនោះពេលដែលយើងបានជួបប្រទះនឹងសេចក្តីប្រោសលោះ ហើយពួកគេឃើញថាព្រះគឺស្មោះត្រង់ វាជាបន្ទាល់ដល់ពួកគេនៃព្រះវត្តមាននិងអំណាចរបស់ទ្រង់ ក៏ដូចជាបំណងព្រះហឫទ័យរបស់ទ្រង់ក្នុងការជួយយើង។ ឧទាហរណ៍ផ្ទាល់ខ្លួនរបស់យើងអាចជាចំណុចដែលនាំឱ្យមនុស្សម្នាក់ថ្វាយជីវិតរបស់គាត់ទៅព្រះគ្រីស្ទ។

*ឧទាហរណ៍ផ្ទាល់ខ្លួនរបស់យើងអាចជាចំណុចដែលនាំឱ្យមនុស្សម្នាក់ថ្វាយគាត់ទៅព្រះគ្រីស្ទ។*

៥. លោកប៉ូលបាននិយាយថា គាត់មានឆន្ទះក្នុងការចែករំលែកនូវការរងទុក្ខក្នុងព្រះគ្រីស្ទ បើសិនជានោះនឹងធ្វើឲ្យគាត់ទៅជាផ្នែកមួយនៃព្រះគ្រីស្ទ

នោះមិនមែនមានន័យថាយើងត្រូវឆ្កាងលើឈើឆ្កាងដូចដែលព្រះយេស៊ូធ្លាប់ធ្វើនោះទេ។ ជាទូទៅវាមានន័យថា យើងគួរមានឆន្ទះក្នុងការឆ្លងកាត់អ្វីដែលយើងត្រូវការ

ដើម្បីក្លាយដូចជាព្រះយេស៊ូ ហើយឃើញសិរីរុងរឿងរបស់ទ្រង់តាមរយៈយើង។

តើមានន័យថាព្រះជាម្ចាស់ប្រទានឲ្យយើងរងទុក្ខវេទនា ហើយនិងការល្បងល់ ដើម្បីឲ្យយើងរៀនពីអ្វីដែលនឹងមានប្រយោជន៍ដល់យើងនៅពេលក្រោយឬ? ទ្រង់មិនមែនជាព្រះដែលនឹងនាំបុត្ររបស់ទ្រង់ទៅរោងដាក់ឧស ដើម្បីផ្តល់ឲ្យគេនូវការវាយដំ ដើម្បីបង្រៀនពួកគេនោះទេ។

ខ្ញុំចូលចិត្តនិយាយថា ពេលមួយយើងមានបញ្ហាឬភាពលំបាក ព្រះជាម្ចាស់អាចប្រើវាធ្វើអោយគោលបំណងរបស់ទ្រង់បានចម្រើនឡើងក្នុងជីវិតរបស់យើង។

*បើយើងធ្វើដំណើរទៅដោយការឈឺចាប់ ហេតុអ្វីបាយើងមិនទាញយកផលប្រយោជន៍ខ្លះៗពីវា?*

ប្រសិនបើយើងធ្វើដំណើរទៅដោយការឈឺចាប់ ហេតុអ្វីបានជាយើងមិនទាញយកផលប្រយោជន៍ខ្លះៗពីវា? ខ្ញុំធ្លាប់មានសេចក្តីឈឺចាប់ដោយមិនមានព្រះ ហើយខ្ញុំក៏បានឈឺចាប់ពេលដែលមានព្រះដែរ ហើយខ្ញុំអាចនិយាយយ៉ាងម៉ឺងម៉ាត់ថា ជាមួយព្រះជាម្ចាស់គឺតែងតែប្រសើរជាង។ ខ្ញុំជឿជាក់ថាព្រះជាម្ចាស់តែងតែមានផែនការណ៍សម្រាប់ការសង្គ្រោះយើង ប៉ុន្តែទ្រង់អាចពន្យារពេលវេលាក្នុងការតម្រូវណាមួយដើម្បីប្រើវាសម្រាប់ការលូតលាស់នឹងអភិវឌ្ឍបុគ្គលិកលក្ខណៈរបស់យើង។ ពេលរបស់ព្រះគឺល្អឥតខ្ចោះក្នុងជីវិតរបស់យើង ហើយកំឡុងពេលដែលយើងរង់ចាំ យើងមានឯកសិទ្ធនៃការជឿទុកចិត្តលើទ្រង់។

## *សម្រាប់អំណរនៃការទទួលបានរង្វាន់*

ព្រះយេស៊ូបានមានបន្ទូលថាទោះបីជាព្រះអង្គស្អប់ខ្ពើមភាពអាម៉ាសនៃឈើឆ្កាង ទ្រង់ក៏បានបញ្ចប់វាសម្រាប់អំណរនៃការទទួលបានរង្វាន់លើផ្នែកដទៃទៀតរបស់វា (ហេព្រើរ១២៖២)។ មនុស្សជាច្រើនបានប្រាប់ខ្ញុំថាពួកគេនឹងមិនផ្លាស់ប្តូរអ្វីដែលពួកគេបានឆ្លងកាត់មកដើម្បីអ្វីមួយនោះទេ ជាធម្មតាដោយសាររបៀបដែលវាផ្លាស់ប្តូរពួកគេនឹងនាំពួកគេចូលទៅជិតព្រះ។

យើងអាចនឹងស្អប់អ្វីដែលយើងឆ្លងកាត់ ខណៈពេលដែលយើងកំពុងឆ្លងកាត់វា។ មិនមានអ្នកណាម្នាក់រីករាយនឹងប្រភេទនៃការឈឺចាប់ ឬទុក្ខវេទនានោះទេ ប៉ុន្តែប្រសិនបើយើងអាចកំណត់ចិត្តគំនិតរបស់យើងលើរង្វាន់ នៅលើផ្នែកផ្សេងទៀតយើងនឹងអាចអត់ទ្រាំដោយអំណរយ៉ាងបរិបូណ៌។ ប្រសិនបើយើងបន្តមានជំនឿថាយើងនឹងឃើញសេចក្តីល្អរបស់ព្រះ នោះមិនមានបញ្ហាទេថា យើងឈឺចាប់អាក្រក់

យ៉ាងណា ឬក៏វាមានរយៈពេលយូរប៉ុណ្ណា យើងនឹងភ្លក្សភាពផ្អែមល្ហែមនៃការវាយយកបាននិងជោគជ័យ។

ខ្ញុំតែងតែនិយាយថាយើងត្រូវតែ «ឆ្លងកាត់» ដើម្បី«សម្រេចបាន»។ កុំភ័យខ្លាចនឹងការលំបាក ពីព្រោះព្រះអង្គនឹងមិនប្រទានឲ្យអ្នកលើសពីអ្វីដែលអ្នកទ្រាំទ្រក្នុងជីវិតរបស់អ្នកជាមួយទ្រង់ក្នុងជីវិតរបស់អ្នកដោយការជួយ និងណែនាំផ្លូវអ្នក។

យើងត្រូវតែ » ដើម្បី «ឆ្លងកាត់» «សម្រេចបាន»។

# ជំពូក ១៣

# ពីមួយថ្ងៃទៅមួយថ្ងៃ

បន្ទាប់នោះមកព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលទៅនឹងម៉ូសេថា មើល អញនឹងបង្អុរភ្លៀងជានំបុ័ងពីលើមេឃមកអោយឯងរាល់គ្នា ត្រូវអោយបណ្តាជនចេញទៅរើសអោយល្មមតែ១ថ្ងៃរាល់ៗថ្ងៃ...

និក្ខមនំ ១៦៖៤(KHOV)

នៅពេលដែលព្រះជាម្ចាស់ប្រទាននំប៉័ងពីស្ថានសួគ៌ឲ្យដល់ជនជាតិអ៊ីស្រាអ៊ែល វាមិនមែនគ្រាន់តែដើម្បីចិញ្ចឹមពួកគេពួកគេប៉ុណ្ណោះទេ ប៉ុន្តែដើម្បីសាកល្បងសេចក្តីទុកចិត្តរបស់ពួកគេលើទ្រង់។ ព្រះអង្គបានបញ្ជាដល់ពួកគេថារើសត្រឹមតែចំនួនដែលគេត្រូវការសម្រាប់មួយថ្ងៃនោះ ហើយទុកចិត្តថាពេលថ្ងៃស្អែកបានមកដល់ ទ្រង់ក៏នឹងប្រទានឲ្យសម្រាប់ថ្ងៃនោះដែរ។ គ្រាន់តែស្រម៉ៃមើលថា តើវាលំបាកប៉ុណ្ណាសម្រាប់ពួកគេជាច្រើននាក់។ ពួកគេបានរស់នៅក្នុងវាលរហោស្ថាននិងមិនមានអាហារហើយក៏មិនមានវិធីណាដែលពួកគេទទួលបានអាហារ។ ខ្ញុំប្រាកដណាស់ថាភាពភ័យខ្លាចរបស់ពួកគេបានឡើងដល់កំពូល។ ខ្ញុំដឹងខ្ញុំអាចនឹងមាន!

នឹងមានពេល ដែលព្រះជាម្ចាស់សាកល្បងយើងនៅក្នុងផ្នែកដើម្បីមើលថា តើយើងនឹងជឿទុកចិត្តលើទ្រង់ឬអត់។ បើជនជាតិអ៊ីស្រាអ៊ែលបានព្យាយាមប្រមូលចំណែកសម្រាប់ថ្ងៃស្អែកនោះវានឹងរលួយហើយចាប់ផ្តើមស្អុយ។ តើញឹកញាប់ប៉ុណ្ណា ដយើងព្យាយាមប្រមូលនៅថ្ងៃនេះនូវអ្វីដែលយើងត្រូវការសម្រាប់ថ្ងៃស្អែកតាមរយៈហេតុផលឬការខ្វល់ខ្វាយ ហើយអ្វីទាំងអស់ដែលវាធ្វើគឺបង្កើតអោយយើងលំបាក។

ថ្មីៗនេះខ្ញុំបានក្រោកឡើងនៅពេលព្រឹក ហើយភ្លាមៗចាប់ផ្តើមគិតអំពីគំរោងនិពន្ធទាំងអស់ ដែលខ្ញុំមានវាបានមកក្នុងពេលតែមួយ។ បន្ថែមលើនេះខ្ញុំមានសិក្ខាសាលាកំពុងកើតមានឡើងដែលខ្ញុំត្រូវការរៀបចំ មានកម្មវិធីទូរទស្សន៍មួយចំនួន ការប្រជុំជាមួយដៃគូរជំនួញ ហើយនឹងការណាត់ជួបជាមួយមនុស្សជាច្រើន! ច្រើនជាងនេះខ្ញុំបានគិតច្រើនអំពីការទាំងអស់ខ្ញុំត្រូវធ្វើច្រើនជាងសាមសិបថ្ងៃ។ ដូច្នេះខ្ញុំមានអារម្មណ៍ថាសម្ពាធនឹងបន្ទុកកាន់តែធ្ងន់មកលើខ្ញុំ។ ព្រះជាម្ចាស់មានបន្ទូលយ៉ាងសា

មញ្ញមកកាន់ដួងចិត្តរបស់ខ្ញុំ រំលឹកខ្ញុំអំពីអ្វីមួយដែលខ្ញុំបានដឹងរួចហើយៈ រស់នៅមួយថ្ងៃសម្រាប់មួយថ្ងៃ។ រំពេចនោះខ្ញុំមានអារម្មណ៍ថា បន្ទុកបានចាកចេញទៅ ពីព្រោះខ្ញុំមានបទពិសោធន៍គ្រប់គ្រាន់ជាមួយព្រះ ដើម្បីដឹងលើសពីការសង្ស័យ ដែលទ្រង់នឹងជួយឲ្យយើងធ្វើអ្វីៗគ្រប់យ៉ាងបាន ទ្រង់ចង់ឲ្យយើងធ្វើប្រសិនបើយើងធ្វើវាមួយថ្ងៃសម្រាប់មួយថ្ងៃ។

នៅពេលយើងប្រើប្រាស់ថ្ងៃនេះព្រួយបារម្ភអំពីថ្ងៃស្អែក យើងធ្លាក់ទៅក្នុងការខ្វះខាយក្នុងថ្ងៃនេះ។ វាឥតប្រយោជន៍!ព្រះយេស៊ូមានបន្ទូលថាកុំឲ្យខ្វល់ខ្វាយពីថ្ងៃស្អែកឡើយព្រោះថ្ងៃស្អែកនឹងមានបញ្ហាគ្រប់គ្រាន់សម្រាប់ថ្ងៃនោះ(ម៉ាថាយ៦៖៣៤)។ ព្រះជួយយើងដូចដែលយើងដាក់សេចក្តីជំនឿរបស់យើងក្នុងទ្រង់ មិនដូចយើងខ្វល់ខ្វាយហើយកើតទុក្ខថា តើយើងនឹងដោះស្រាយបញ្ហារបស់យើងដូចម្តេចនោះទេ។

ក្នុងឆ្នាំ២០១៣ យើងបានបោះពុម្ពការលើកទឹកចិត្តប្រចាំថ្ងៃដែលមានចំណងជើងថា *ចូរទុកចិត្តលើព្រះជារៀងរាល់ថ្ងៃ* ហើយវាជាការលើកទឹកចិត្តដែលពេញនិយមជាងគេបំផុតរបស់យើង។ ហេតុអ្វី? វាជាការពេញនិយម ពីព្រោះវាបរិយាយពីអ្វីដែលយើងមានអារម្មណ៍ថាយើងអាចធ្វើបាន។ សម្លឹងមើលទាំងអស់នៃជីវិតនៅពេលតែមួយ ឬ សូម្បីតែមួយសប្តាហ៍ ឬ មួយខែ គឺជាធម្មតាដែលលើសលប់ ប៉ុន្តែមួយថ្ងៃសម្រាប់មួយថ្ងៃគឺអាចធ្វើបាន។ ពួកអ្នកញៀនស្រាអនាមឹកបានប្រើគោលការណ៍នេះជាមួយនឹងបុរសនិងស្ត្រីដែលមករកពួកគេដើម្បីសុំជំនួយ។ មនុស្សជាញឹកញាប់មានអារម្មណ៍ថាជីវិតរបស់ពួកគេ មិនមានវិធីអាចនឹងទៅសម្រាក ដោយពួកគេមិនផឹកស្រាបាននោះទេ។ ការភ័យខ្លាចនៃការបរាជ័យគឺខ្លាំងក្លាណាស់ដែលពួកគេមិនចង់ចាប់ផ្តើម។ ប៉ុន្តែគំនិតនៃការមិនផឹកមួយថ្ងៃសម្រាប់មួយថ្ងៃហាក់ដូចជាលទ្ធភាពអាចទៅរួច។ គោលដៅរបស់ពួកគេគឺត្រូវនៅដោយមិនស្រវឹងសម្រាប់មួយថ្ងៃ ហើយមួយចំនួនធំនៃពួកគេអាចប្រាប់អ្នកបានដោយជាក់ច្បាស់ថា តើមានប៉ុន្មានថ្ងៃដែលពួកគេមិនស្រវឹង ទោះបីច្រើនឆ្នាំបានកន្លងផុតទៅ ដោយសារពួកគេមានការផឹកជាលើកចុងក្រោយរបស់ពួកគេ។

ដោយសារគោលការណ៍នេះបានមកដោយត្រង់ពីព្រះបន្ទូលរបស់ព្រះ វាធ្វើការនៅក្នុងផ្នែកជាច្រើននៃជីវិត។ យើងអាចចាកចេញពីបំណុល ការធ្វើលំហាត់ប្រាណការស្រកគីឡូ ការទទួលសញ្ញាប័ត្រពីមហាវិទ្យាល័យ តម្រូវការពិសេសបំផុតរបស់ឪពុកម្តាយគឺកូន ឬក៏ជោគជ័យនៅក្នុងអ្វីមួយយើងត្រូវការធ្វើ ប្រសិនបើយើងនឹងដាក់សេចក្តីទុកចិត្តរបស់យើងក្នុងព្រះ ហើយមានជីវិតមួយថ្ងៃម្តងមួយថ្ងៃម្តង។

ខ្ញុំចូលចិត្តសម្រង់មួយដោយមិនស្គាល់ពីប្រភពៈ «ខ្ញុំព្យាយាមរស់នៅមួយថ្ងៃម្តង

មួយថ្ងៃម្តង ប៉ុន្តែពេលខ្លះជាច្រើនថ្ងៃបន្តបន្ទាប់ដែលវាយប្រហារខ្ញុំភ្លាមៗ។»

## *ភាពខុសគ្នារវាងសេចក្តីជំនឿនិងការទុកចិត្ត*

ពាក្យថា «ជំនឿ»និង «ការទុកចិត្ត» គឺជាញឹកញាប់បានប្រើដោយអាចផ្លាស់ប្តូរគ្នាបាន ប៉ុន្តែតើមានអ្វីខុសគ្នា?ក្នុងរបៀបជាច្រើនទាំងពីមានភាពប្រហាក់ប្រហែលគ្នា ពីព្រោះទាំងពីរតម្រូវឲ្យមានទំនុកចិត្តក្នុងព្រះ ប៉ុន្តែ «ជំនឿ»គឺជា*នាម* ហើយដូច្នេះវាជាអ្វីដែលយើងមានខណៈពេល «ការទុកចិត្ត» ជាញឹកញាប់ត្រូវបានប្រើជាកិរិយាស័ព្ទហើយគឺជាអ្វីដែលយើងធ្វើ។

ការទុកចិត្តគឺជំនឿនៅក្នុងសកម្មភាព។

ព្រះប្រទានជំនឿឲ្យយើង។ ព្រះបន្ទូលរបស់ទ្រង់មានបន្ទូលថាគ្រប់មនុស្សទាំងអស់គឺបានប្រទានជំនឿឲ្យតាមខ្នាត(រ៉ូម១២៖៣) ប៉ុន្តែវាគឺស្រេចទៅលើអ្វីដែលបុគ្គលម្នាក់ៗធ្វើជាមួយវា។ វាគឺជំនឿដែលត្រូវឲ្យមានសេរីភាព។ គ្រាន់តែគិតមើលលើអ្វីទាំងអស់ដែលមនុស្សបានដាក់សេចក្តីជំនឿរបស់គេលើពួកវា ជាជាងការលើព្រះ ប្រព័ន្ធហិរញ្ញវត្ថុពិភពលោក រដ្ឋាភិបាល ការអប់រំ មនុស្សដទៃ ប្រាក់ចូលនិវត្តន៍ លើខ្លួនរបស់ពួកគេ និងមានជាបន្តទៀត។ ក្រៅពីអ្វីៗទាំងអស់ដែលមនុស្សដាក់សេចក្តីទុកចិត្តរបស់គេ ព្រះជាម្ចាស់គឺជាប្រភពតែមួយដែលអាចពឹងពាក់បានមួយរយភាគរយ។

ខ្ញុំចង់ឲ្យអ្នករាល់គ្នាយកចិត្តទុក្ខដាក់ទៅនឹងប្រយោគដែលខ្ញុំកំពុងប្រើ «ចូរដាក់សេចក្តីទុកចិត្តរបស់អ្នកលើព្រះ»។ «ដាក់» គឺជាពាក្យសកម្មភាព ពេលយើងដាក់អ្វីមួយទៅកន្លែងណាមួយ វាគឺជាគ្រឹះលើការសម្រេចចិត្តដើម្បីធ្វើការនោះ។ ខ្ញុំអាចដាក់កំព្យូទ័រនេះសាកថ្មឡើងវិញពេលដែលខ្ញុំបានបញ្ចប់ការងារ ដូច្នេះវានឹងមានថ្មពេញហើយរួចរាល់សម្រាប់ការប្រើប្រាស់ពេលបន្ទាប់របស់ខ្ញុំ ឬខ្ញុំអាចទុកវានៅលើគ្រែដេកហើយពេលបន្ទាប់ខ្ញុំត្រូវការវាខ្ញុំនឹងរកឃើញថា វាអស់ថាមពលហើយវាមិនអាចប្រើប្រាស់បានទេសម្រាប់ខ្ញុំ។ ខ្ញុំអាចឆ្លៀតឱកាសប្រើពេលដែលមិនទាន់អស់ថាមពល ប៉ុន្តែប្រសិនបើវាអស់ថាមពល នោះខ្ញុំនឹងធ្លាក់ក្នុងការខកចិត្ត។ នេះស្រដៀងគ្នាទៅនឹងអ្វីដែលយើងធ្វើនៅពេលដែលយើងដាក់សេចក្តីជំនឿរបស់យើងទៅក្នុងអ្វីមួយ ឬលើអ្នកណាម្នាក់ផ្សេងទៀតក្រៅពីព្រះ។ យើងយកឱកាសអ្វីៗដែលដំណើរការទៅបានល្អ ប៉ុន្តែបទពិសោធន៍របស់យើងបង្រៀនយើងថាវាមិនដែលកើតឡើងគ្រប់ពេលនោះទេ។

ជាក់ស្តែងមានអ្វីៗ និង មនុស្សដែលយើងអាចទុកចិត្ត ប៉ុន្តែមិនមានការធានារ៉ាប់

រងថា យើងនឹងពេញចិត្តនូវរាល់លទ្ធផលដែលចេញមកនោះទេ។ ខ្ញុំពិតជាអាចនិយាយបានថាបន្ទាប់ពីដើរជាមួយព្រះរយៈបីត្រីមាសនៃជីវិតរបស់ខ្ញុំ ខ្ញុំពេញចិត្តទាំងស្រុងជាមួយនឹងលទ្ធផលនៃការដាក់ការទុកចិត្តក្នុងទ្រង់។ទោះបីជាអ្វីៗមិនបានចេញមកតាមការដែលខ្ញុំបានគិតថាពួកវាគួរតែកើតឡើង ឬក៏តាមអ្វីដែលខ្ញុំចង់ឲ្យវាកើតឥឡូវនេះខ្ញុំដឹងថាព្រះតែងតែបានធ្វើអ្វីដែលល្អបំផុត។

ប្រសិនបើអ្នកមិនទាន់បានធ្វើដូច្នេះ តើអ្នកនឹងធ្វើការសំរេចចិត្តដើម្បីចាប់ផ្តើមការដាក់សេចក្តីទុកចិត្តរបស់អ្នកក្នុងព្រះក្នុងគ្រប់ស្ថានភាពទាំងអស់ក្នុងជីវិតរបស់អ្នក ឬទេ? គិតអំពីវាជារៀងរាល់ថ្ងៃជាគ្រឹះ ហើយវានឹងហាក់ដូចជាងាយស្រួលក្នុងការធ្វើ។ តើអ្នកអាចទុកចិត្តព្រះសម្រាប់ថ្ងៃនេះឬទេ? តើអ្នកនឹងដាក់សេចក្តីទុកចិត្តរបស់អ្នកក្នុងព្រះអង្គសម្រាប់ថ្ងៃនេះឬទេ? តើក្នុងស្ថានភាពវិវាទអ្វីក៏ដោយដែលអ្នកកំពុងជួបប្រទះនៅថ្ងៃនេះ អ្នកនឹងថ្វាយវាទៅព្រះហើយដាក់សេចក្តីជំនឿរបស់អ្នកក្នុងទ្រង់ទេ?

ព្រះគម្ពីរមានពេញទៅដោយខគម្ពីរអំពីមនុស្សដែលពួកគេនិយាយថានឹង «ដាក់» សេចក្តីទុកចិត្តរបស់ពួកគេក្នុងទ្រង់។ វាជាការសំរេចចិត្តដែលពួកគេបានធ្វើ។ អ្នកនិពន្ធជាញឹកញាប់ប្រើឃ្លា «ខ្ញុំនឹង» នៅពេលដែលនិយាយអំពីការដាក់ទំនុកចិត្តរបស់ពួកគេក្នុងព្រះ។ ការធ្វើការសំរេចចិត្តគឺជាផ្នែកទីមួយ ហើយបន្ទាប់មកយើងអនុវត្តតាម ទោះជាត្រឹមតែមួយម៉ោង ប្រសិននោះជាអ្វីដែលវាចាប់យក។ គោលដៅតូចៗនៅទីបំផុតនឹងជួយយើងឲ្យទៅដល់គោលដៅដែលធំ។

ព្រះគម្ពីរបាននិយាយថា:

> ព្រះអម្ចាស់ជាព្រះនៃទូលបង្គំអើយ! ទូលបង្គំសូមយកព្រះអង្គធ្វើជាទីពឹងជ្រក សូមសង្គ្រោះទូលបង្គំ សូមរំដោះទូលបង្គំ ឲ្យរួចផុតពីអស់អ្នកដែលបៀតបៀនទូលបង្គំផង។
>
> ទំនុកដំកើង ៧៖១

> ឱព្រះជាម្ចាស់អើយនៅថ្ងៃទូលបង្គំភ័យខ្លាច ទូលបង្គំផ្ញើជីវិតលើព្រះអង្គ ខ្ញុំសរសើរតម្កើងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ ខ្ញុំទុកចិត្តលើព្រះជាម្ចាស់ ហើយខ្ញុំនឹងមិនភ័យខ្លាចអ្វីឡើយ តើមនុស្សដែលតែងតែស្លាប់អាចធ្វើអ្វីខ្ញុំកើត?
>
> ទំនុកតម្កើង ៥៦៖៣-៤

ការដាក់សេចក្តីជំនឿរបស់អ្នកក្នុងព្រះនឹងងាយស្រួលនៅពេលដែលជីវិតដំណើរ

ការទៅដោយរលូន ប៉ុន្តែនៅពេលដែលអ្វីៗមិនបានប្រព្រឹត្តដោយប្រសើរ វានឹងមានផលលំបាកកាន់តែច្រើនឡើង។ ប្រសិនបើអ្នកប្រឈមមុខនឹងសេចក្ដីវិនាស ឬសេចក្ដីឈឺចាប់យ៉ាងពិតប្រាកដ វាក៏នឹងពិបាកផងដែរ ប៉ុន្តែយើងគួរចងចាំថាព្រះមិនដែលប្រាប់យើងឲ្យធ្វើអ្វីដែលយើងមិនអាចធ្វើបាននោះទេ។ ខ្ញុំអាចទុកចិត្តព្រះជាម្ចាស់ជារៀងរាល់ថ្ងៃ! សូម្បីតែប្រសិនបើអ្នកមានថ្ងៃដែលនៅពេលខ្លះអ្នកត្រូវនិយាយមួយពាន់ដងក៏ដោយ «ខ្ញុំនឹងដាក់សេចក្ដីទុកចិត្តរបស់ខ្ញុំក្នុងព្រះ» វាមានតំលៃនឹងធ្វើ។ មិនត្រឹមតែលើកកិត្តិយសព្រះប៉ុណ្ណោះទេ ប៉ុន្តែវាបានលើកបន្ទុកចេញពីយើង ដែលយើងមិនត្រូវបានគេដាក់បន្ទុក ក៏ដូចជាមិនរែកពន់វា។

នៅពេលដែលបានរកឃើញថា ខ្ញុំមានជម្ងឺមហារីកដោះក្នុងឆ្នាំ១៩៨៩ វាពិតជារន្ធត់ នឹងការដាស់តឿនចិត្តលើកដំបូងរបស់ខ្ញុំ ភាពព្រួយបារម្ភ។ គំនិតរបស់ខ្ញុំបានពេញទៅដោយ «ចុះបើ..» ប៉ុន្តែព្រះជាម្ចាស់បានសូមឲ្យខ្ញុំនិយាយថា «ព្រះអង្គ នាងខ្ញុំម្ចាស់ទុកចិត្តទ្រង់» ជំនួសឲ្យការនិយាយអំពីការភ័យខ្លាចនិងការព្រួយបារម្ភរបស់ខ្ញុំ។ ថ្ងៃខ្លះខ្ញុំបាននិយាយវាម្ដងហើយម្ដងទៀត ប៉ុន្តែខ្ញុំបានមានៈ។ នៅទីបំផុត ថ្ងៃនៃការបាញ់កាំរស្មីបានមកដល់ ជាមួយនឹងការសាកល្បងដើម្បីមើលដុំមូលរបស់ខ្ញុំ ប្រសិនបើមហារីកវារាលដាល ហើយនោះមានន័យថាការដាក់សេចក្ដីទុកចិត្តលើព្រះជាម្ចាស់រាល់ថ្ងៃ ដូចជាយើងបានរង់ចាំសម្រាប់លទ្ធផលនៃការសាកល្បង វាហាក់ដូចជាវាមានរយៈពេលយូរ ប៉ុន្តែជារៀងរាល់ថ្ងៃខ្ញុំបន្តនិយាយថា «ព្រះជាម្ចាស់នាងខ្ញុំម្ចាស់ជឿលើទ្រង់។» នៅទីបញ្ចប់របាយការណ៍គឺបានចេញមកហើយវាល្អ។ មិនមានមហារីកនៅក្នុងដុំមូលទៀតនោះទេ ប៉ុន្តែក្រុមវេជ្ជបណ្ឌិតមិនប្រាកដទេថានឹងមានតម្រូវការលើការវិនិច្ឆ័យណាមួយផ្សេងទៀត។ មានតែអ្នកវិទ្យាសាស្ត្រខាងដុំពកដែលអាចប្រាប់ការនោះខ្ញុំបាន។ ខ្ញុំបានធ្វើការណាត់ជួបអ្នកវិទ្យាសាស្ត្រខាងដុំពក ប៉ុន្តែវាបានចំណាយពេលមួយដើម្បីបានជួបនឹងគាត់ ដូច្នេះខ្ញុំបានប្រឈមមុខជាច្រើនថ្ងៃនឹងការទុកចិត្តលើព្រះមុនពេលដែលខ្ញុំអាចដឹងថា តើជីវិតរបស់ខ្ញុំនឹងទៅជាយ៉ាងណាក្នុងរយៈពេលពីរបីខែបន្ទាប់។ យើងទាំងអស់គ្នាដឹងពីការពិបាកនៃការចង់បានចំលើយនឹងការដែលត្រូវរង់ចាំសម្រាប់ចំលើយនោះ។

កំឡុងពេលរង់ចាំទាំងនោះ ខ្ញុំមានឱកាសច្រើនដែលអនុញ្ញាតឲ្យចិត្តគំនិតរបស់ខ្ញុំរសាត់ទៅរកសេណារីយ៉ូដែលអាក្រក់បំផុត ប៉ុន្តែព្រះបានរំលឹកខ្ញុំអោយជឿលើទ្រង់។ ទីបំផុតនៅពេលដែលខ្ញុំបានជួបជាមួយអ្នកវិទ្យាសាស្ត្រខាងដុំពក គាត់បាននិយាយថាគាត់បានឃើញថាមិនត្រូវការវិនិច្ឆ័យណាផ្សេងទៀត ព្រោះថាជំងឺមហារីកបានបាត់ទៅទាំងស្រុង។ ខ្ញុំអាចបន្តទៅជាមួយនឹងជីវិតដែលធម្មតា ហើយគ្រាន់តែធ្វើការ

ត្រួតពិនិត្យ ជារៀងរាល់ឆ្នាំប៉ុណ្ណោះ។ តើអ្វីធូរស្បើយយ៉ាងនេះ! ខ្ញុំមានអារម្មណ៍ដូចជាខ្ញុំបានស្រកគីឡូអស់ពីររយគីឡូក្រាម។បន្ទាប់មកជារៀងរាល់ឆ្នាំអស់រយៈពេលជាច្រើនឆ្នាំ នៅពេលដែលការថតពិនិត្យដើមទ្រូងបានមកដល់ ខ្ញុំត្រូវឆ្លងកាត់ដំណើរការម្តងទៀត។ រយៈពេលមួយឆ្នាំដែលអ្នកវិទ្យុវិទ្យាបានគិតថាគាត់បានឃើញថាមានអ្វីមួយនៅលើអេក្រង់ ហើយពួកគេបានចង់អោយខ្ញុំនៅបន្ត ដើម្បីឆ្លុះមើលសរីរាង្គខាងក្នុង ហើយខ្ញុំត្រូវបានរង់ចាំមួយរយៈពេលសម្រាប់កិច្ចការនោះ! *តើនឹងមានអ្វីកើតឡើងប្រសិនបើមហារីកវាត្រឡប់មកវិញ? តើនឹងមានអ្វីកើតឡើងប្រសិនបើវារាលដាលទៅកន្លែងផ្សេង?* សំណួរទាំងនេះនឹងសំណួរដទៃទៀតមានពេលរសាត់ទៅមកក្នុងគំនិតរបស់ខ្ញុំ ខណៈពេលដែលខ្ញុំកំពុងរង់ចាំនោះ ប៉ុន្តែខ្ញុំបាននិយាយថា «ព្រះអម្ចាស់អើយ នាងខ្ញុំម្ចាស់ទុកចិត្តទ្រង់ មិនមានបញ្ហាទេថាលទ្ធផលចេញមកយ៉ាងណានោះ។»

ខ្ញុំត្រូវបានឆ្លុះមើលសរីរាង្គខាងក្នុងហើយលទ្ធផលចេញមក គឺវាពិតជាមិនមានអ្វីទាំងអស់! ម្តងទៀតខ្ញុំប្រកាសថា ខ្ញុំមានសេរីភាពពីជំងឺមហារីក ហើយវាបានបន្តអស់រយៈពេលម្ភៃប្រាំពីរឆ្នាំរហូតមកដល់ឥឡូវនេះ។

ខ្ញុំប្រាប់រឿងនេះអ្នក ក្នុងគោលបំណងអនុញ្ញាតឲ្យអ្នកដឹងថា ខ្ញុំដឹងថាការដាក់សេចក្តីជំនឿរបស់អ្នកក្នុងព្រះជារឿយៗតម្រូវឲ្យអ្នកប្រយុទ្ធ ដោយការប្រយុទ្ធយ៉ាងល្អនៃសេចក្តីជំនឿ ដូចជាលោកប៉ូលបានប្រាប់ដល់ធីម៉ូថេឲ្យធ្វើនៅក្នុង ១ធីម៉ូថេ៦៖១២។ អារក្សជាមេកុហក ហើយវាព្យាយាមគ្រប់បែបយ៉ាងដើម្បីទាញយកអត្ថប្រយោជន៍គ្រប់ស្ថានភាពទាំងអស់ដែលវាអាចបំពេញយើងដោយភាពភ័យខ្លាចប៉ុន្តែយើងអាចរំខានផែនការរបស់វាបាន ដោយសម្រេចជ្រើសរើស «ដាក់» ការទុកចិត្តរបស់យើងក្នុងព្រះ!

ដូចដែលអ្នកបានអាននេះ អ្នកអាចមានអារម្មណ៍ថាអ្នកបានទុកចិត្តព្រះក្នុងអតីតកាល ហើយមិនមានការអ្វីដែលចេញមកក្រៅពីការដែលអ្នកចង់ឲ្យពួកវាកើតឡើងនោះទេ។ ប្រសិនបើដូច្នេះ នោះគឺមិនភ្ញាក់ផ្អើលនោះទេ ព្រោះអ្វីៗមិនធ្លាក់ទៅក្នុងរបៀបដែលយើងបានសម្រេចចិត្តឲ្យវាកើតឡើងគ្រប់ពេលនោះទេ។ ការទុកចិត្តព្រះ ឬ ខ្ញុំគួរតែនិយាយថាការទុកចិត្តទាំងស្រុងលើព្រះ គឺមិនមែនអំពីយើងទេដែលទទួលអ្វីដែលយើងចង់បាន។ នៅពេលដែលយើងសម្រេចចិត្តទុកចិត្តព្រះ យើងបង្កើតការទុកចិត្តទាំងស្រុងលើទ្រង់ដោយមិនមានបញ្ហានឹងលទ្ធផល។ យើងថ្វាយទ្រង់នូវកិត្តិយសនៃការទុកចិត្ត ថាទ្រង់ដឹងប្រសើរបំផុត។

យើងអាចព្យថា ការទុកចិត្តទាំងស្រុងក្នុងករណីរបស់លោកយ៉ូប ដែលគាត់បាននិ

យាយថា «ទោះបីទ្រង់ប្រហារខ្ញុំក្តី ក៏ខ្ញុំនៅតែទុកចិត្តទ្រង់» (យ៉ូប ១៣៖១៥)។ យ៉ូបបានដឹងថាអ្នកប្រោសលោះរបស់គាត់រស់នៅ ហើយនោះនៅទីបញ្ចប់ទ្រង់នឹងគង់នៅលើផែនដី (យ៉ូប ១៩៖២៥)។ ជំនឿដែលទុកចិត្តនិងការជឿជាក់ដែលលោកយ៉ូបបានបង្ហាញនៅក្នុងព្រះគឺជាសារដ៏សំខាន់បំផុតនៅនៅក្នុងសៀវភៅយ៉ូប។ជារឿយៗយើងផ្តោតយ៉ាងខ្លាំងលើមូលហេតុដែលគាត់ទទួលសេចក្តីឈឺចាប់ នោះយើងបាត់បង់នូវមេរៀនផ្សេងទៀតនៅក្នុងសៀវភៅ។ សេចក្តីជំនឿរបស់យ៉ូបបានធ្វើឲ្យខ្ញុំនឹកអស្ចារ្យ ហើយខ្ញុំរកឃើញថាខគម្ពីរទាំងនេះប្រកួតប្រជែង និងពង្រឹងថាមពលឲ្យខ្ញុំទុកចិត្តព្រះមិនមានបញ្ហានោះទេទោះបីខ្ញុំកំពុងឆ្លងកាត់អ្វីក៏ដោយ។

យ៉ូបបានត្អូញត្អែរ ហើយគាត់មិនបានគិតថាគាត់សមនឹងទទួលការឈឺចាប់ដែលគាត់កំពុងនឹងស៊ូទ្រាំនេះទេ តែគាត់មិនដែលឈប់ទុកចិត្តលើព្រះនោះឡើយ។ នៅទីបញ្ចប់ ព្រះបានស្តារគាត់ឡើងវិញមួយជាពីរក្នុងគ្រប់អ្វីៗដែលគាត់បាត់បង់ ហើយខ្ញុំស្រមៃមើលថា នោះជាអារម្មណ៍ដ៏អស្ចារ្យ ខ្ញុំជឿជាក់យ៉ាងមុតមាំថាព្រះប្រទានរង្វាន់ដល់អស់អ្នកដែលបន្តជឿទុកចិត្តលើទ្រង់។

តិចតួចណាស់នៃយើងទាំងអស់គ្នា ដែលអាចឆ្លងកាត់សោកនាថកម្មមួយចំនួនដោយមិនមានការត្អូញត្អែរតិចតួចនោះ ហើយប្រហែលជាយើងមិនបានគិតថាយើងសមនឹងទទួលបញ្ហារបស់យើងច្រើនជាង ដែលយ៉ូបបានទទួលនោះទេ។ ប៉ុន្តែនៅកណ្តាលទាំងអស់ យើងអាចជ្រើសរើសទុកចិត្តព្រះពីមួយថ្ងៃម្តទៀងមួយថ្ងៃម្តង។ ប្រសិនបើយើងមានបំណង នោះយើងអាចបង្កើតវាតាមរយៈអ្វីៗទាំងអស់។

## *តើអនាគតរបស់ខ្ញុំនឹងមើលទៅដូចជាអ្វី?*

យើងទាំងអស់គ្នាគួរនឹងពេញចិត្តចង់ដឹងអំពីអនាគត។ មនុស្សចំណាយប្រាក់រាប់លានដុល្លារនៅលើ fortune-tellers ហើយនឹងចិត្តសាស្ត្រ សង្ឃឹមថានឹងទទួលបានព័ត៌មានខ្លះៗអំពីអនាគតរបស់ពួកគេ។ ព្រះបន្ទូលរបស់ព្រះបានថ្កោលទោសចំពោះការអនុវត្តទាំងនោះ ហើយវាគួរឲ្យចាប់អារម្មណ៍ដែលមនុស្សជាច្រើនចំណាយប្រាក់យ៉ាងច្រើនលើរឿងអស់ទាំងនោះ។ នៅពេលដែលយើងទុកចិត្តព្រះ យើងមិនត្រូវការធ្វើរឿងដូចនោះទេ ព្រោះយើងដឹងថាព្រះនឹងបង្ហាញពីអនាគតរបស់យើងនៅក្នុងពេលរបស់ទ្រង់ ហើយរហូតដល់ពេលទ្រង់ធ្វើការនោះ យើងទុកចិត្តទ្រង់។

អាប្រាហាំ លីនកុន បាននិយាយថា «រឿងល្អបំផុតអំពីអនាគត នោះគឺវាមកដល់នៅថ្ងៃមួយក្នុងពេលមួយ។» តើយើងរួចរាល់នឹងចង់ដឹងអនាគតរបស់យើងឬនៅ? ខ្ញុំ

គិតថាពេលយើងបានដឹង យើងអាចសង្ស័យថាយើងមិនដែលសួរ។ គ្រប់ជីវិតទាំងអស់បានពេញទៅដោយរបស់ល្អហើយក៏ដូចជាមានរបស់មិនល្អដូចគ្នា។ ប្រសិនបើយើងបានឃើញអនាគត យើងអាចនឹងរំភើពអំពីផ្នែករបស់វា ប៉ុន្តែភាពរំភើបញាប់ញ័រនេះនឹងចុះអន់ថយមកវិញ ដូចដែលយើងបានឃើញរឿងទាំងអស់ដែលអាចនឹងលំបាក ឈឺចាប់ ការខកចិត្ត ឬក៏ការប្រណាំងប្រជែង។

ការប្រឈមមុខដែលយើងប្រឈមនឹងថ្ងៃដ៏លំបាកៗម្តងមួយៗ ជួយធ្វើឲ្យយើងធ្វើវាដូច្នេះទៅបានដោយមិនចុះចាញ់។ យើងអាចធ្វើអ្វីៗគ្រប់យ៉ាងបានមួយថ្ងៃម្តងមួយថ្ងៃម្តងដ៏រាបណាយើងដាក់សេចក្តីទុកចិត្តរបស់យើងលើព្រះ ការដឹកនាំនិងការពឹងផ្អែកលើទ្រង់។ ការគិតហួសប្រមានអំពីបញ្ហារបស់យើង បណ្តាលឲ្យយើងទន់ខ្សោយនៅក្នុងគំនិតរបស់យើង ហើយចង់បោះបង់ជីវិតចោល។ ប្រសិនបើយើងបានដឹងអំពីអនាគត យើងអាចនឹងបញ្ឆោតឲ្យគិតនិងបារម្ភអំពីរឿងពិបាកៗទាំងឡាយដែលយើងបានឃើញនៅក្នុងវា ហើយយើងអាចនឹងប្រហែលជារំជើបរំជួលច្រើនជាង។ ខ្ញុំមានអារម្មណ៍ជាក់ច្បាស់ថា ប្រសិនបើព្រះសព្វព្រះហឫទ័យឲ្យយើងដឹងពីអនាគត ទ្រង់ពិតជានឹងបានរៀបចំសម្រាប់យើងធ្វើដូច្នេះ។ អ្វីៗគ្រប់យ៉ាងទ្រង់លាក់បាំងពីយើងគឺសម្រាប់ហេតុផលល្អ ហើយយើងអាចសំរាកក្នុងការដែលដឹងថាទ្រង់នឹងបង្ហាញឲ្យយើងឃើញអ្វីដែលយើងត្រូវការដឹងនៅក្នុងពេលដ៏ត្រឹមត្រូវ។

ជួនកាលយើងទាំងអស់គ្នាខ្វះខាត ហើយនៅពេលផ្សេងទៀតយើងសម្បូណ៌ហូរហៀរ លោកប៉ុលបានលើកទឹកចិត្តយើងឲ្យពេញចិត្តនឹងការទាំងពីរនេះ (ភីលីព៤៖១១-១២)។ ព្រះប្រើការទាំងពីរនេះក្នុងជីវិតរបស់យើង។ មិនមែនក្នុងពេលទាំងអស់វាដូចគ្នានោះទេ ប៉ុន្តែពួកវាធ្វើការជាមួយគ្នា ពួកវាធ្វើឲ្យជីវិតមានសោភណ្ឌភាព។ ពេលដែលយើងអត់ធ្មត់យ៉ាងយូរក្នុងរដូវត្រជាក់ នៅទីបញ្ចប់វានឹងនាំមកនូវរដូវស្លឹកឈើលាស់ហើយនិងផ្កាក្រពុំជាច្រើននៅក្នុងជីវិតរបស់យើង។

ខ្ញុំមិនដឹងអ្វីទាំងអស់ដែលមាននៅក្នុងអនាគតរបស់ខ្ញុំ ប៉ុន្តែខ្ញុំជឿជាក់ថាវានឹងអស្ចារ្យ ហើយខ្ញុំក៏ជឿដែរថារបស់អ្នកក៏នឹងដូចគ្នាដែរ។ ចូរចំណាយពេលមួយថ្ងៃម្តងមួយថ្ងៃម្តងហើយរីករាយនឹងជោគជ័យដែលព្រះជាម្ចាស់ប្រទានឲ្យយើងតាមរយៈការទុកចិត្តទ្រង់ដោយអស់ពីចិត្តនិងពីគំនិតរបស់យើង។ សូមកុំធ្វើកុំហុសដោយខ្ជះខ្ជាយថ្ងៃនេះទៅព្រួយបារម្ភអំពីថ្ងៃស្អែកនោះឡើយ! ព្រះជាម្ចាស់មានអ្នកនៅក្នុងព្រះហស្ថរបស់ទ្រង់ អ្នកគឺនៅក្នុងគំនិតរបស់ទ្រង់ ហើយអ្នកអាចធ្វើអ្វីក៏ដោយដែលអ្នកចង់ធ្វើតាមរយៈទ្រង់ គឺអ្នកដែលជាកំលាំងរបស់អ្នក (ភីលីព ៤៖១៣)។

# ជំពូក ១៤

# ការមិនយល់ដឹង

*ក្នុងពួកឯងរាល់គ្នា តើមានអ្នកណាដែលកោតខ្លាចដល់ព្រះយេហូវ៉ា ដែលស្តាប់តាមសំឡេងរបស់អ្នកបំរើទ្រង់ ឯអ្នកដែលដើរក្នុងសេចក្តីងងឹតឥតមានពន្លឺសោះ ត្រូវឲ្យអ្នកនោះទុកចិត្តដល់ព្រះនាមនៃព្រះយេហូវ៉ា ហើយផ្អែកទៅលើព្រះនៃខ្លួនចុះ។*

*អេសាយ៥០:១០*

មានរឿងមួយដែលយើងអាចទុកចិត្តព្រះជាម្ចាស់បាន គឺនៅពេលដែលយើងគិតថាយើងពិតជាដឹងអំពីអ្វីដែលកើតឡើងនៅក្នុងជីវិតរបស់យើង ឬនៅពេលដែលយើងគិតថាយើងអាចដោះស្រាយរឿងគ្រប់យ៉ាង ហើយគំរោងរបស់យើងនៅចំកន្លែងដែលព្រះជាម្ចាស់នឹងបើកទ្វាឲ្យយើងទទួលអ្វីដែលយើងចង់បាន។ ទោះជាយ៉ាងណាក៏ដោយមានរឿងមួយទៀតដែលអាចកើតឡើង គឺនៅពេលដែលយើងគ្មានពន្លឺដោយសារតែកាលៈទេសៈ ឬអនាគតរបស់យើង។

លោក ឆាល ស្ព័រគែនបាននិយាយថា «ការទុកចិត្តព្រះជាម្ចាស់នៅក្នុងពន្លឺ គឺគ្មានអ្វីទាំងអស់ ប៉ុន្តែការទុកចិត្តព្រះអង្គក្នុងភាពងងឹតទើបជាជំនឿ»។ មនុស្សប្រុសមានបំណងប្រាថ្នាចង់ដឹងរឿងផ្សេងៗស្ទើរតែមិនចេះស្កប់ស្កល់។គាត់ចង់បានព័ត៌មានគ្រប់ជ្រុងជ្រោយ ព្រោះគាត់ជឿថាវាអាចឲ្យគាត់គ្រប់គ្រងជីវិតរបស់គាត់បាន។ ប៉ុន្តែនៅពេលដែលយើងមានទំនាក់ទំនងជាមួយព្រះជាម្ចាស់ យើងត្រូវបោះបង់គំនិតនេះចោល ហើយយើងត្រូវទុកចិត្តព្រះអង្គ ទុកឲ្យទ្រង់តម្រង់ផ្លូវរបស់យើង។ មនុស្សយើងភាគច្រើនមិនបានធ្វើអញ្ចឹងឡើយ រហូតទាល់តែមានជំនួយពីព្រះជាម្ចាស់។ដូច្នេះគឺព្រះអង្គទេដែលបានជួយយើង! ព្រះអង្គអនុញ្ញាតិឲ្យយើងចូលទៅក្នុងស្ថានភាពដែលយើងមិនអាចដោះស្រាយបាន ហើយនៅពេលដែលយើងត្រូវការចម្លើយ ព្រះអង្គជ្រើសរើសមិនផ្តល់ចម្លើយនោះដល់យើងឡើយ។ ជីវិតគឺពោរពេញទៅដោយអាថ៌កំបាំង ហើយជម្រើសរបស់យើងក្នុងការដោះស្រាយបញ្ហានោះគឺមានកំរិត។ យើងអាចនឹងមានអារម្មណ៍ឈឺចាប់ និងមានការភ័ន្តច្រឡំដោយសារយើងព្យាយាមបង្កើនការយល់ដឹងតាមរយៈរឿងផ្សេងៗដែលលាក់នៅក្នុងព្រះហឫទ័យរបស់ព្រះជាម្ចាស់

តែមួយអង្គប៉ុណ្ណោះ ឬយើងអាចស្វែងយល់គំនិតរបស់មនុស្ស និងសួរការយល់ឃើញរបស់ពួកគេអំពីអ្វីដែលមាននៅក្នុងជីវិតរបស់យើង។ ទោះបីជាវាអាចជួយយើងខ្លះក៏ដោយ តែវាក៏ធ្វើឲ្យយើងកាន់តែភ័ន្តច្រឡំ។ ផ្លូវដែលនាំយើងទៅកាន់សន្តិភាពលឿនបំផុត គឺការរៀនទុកចិត្តព្រះជាម្ចាស់។ខ្ញុំជឿថាការទុកចិត្តព្រះជាម្ចាស់គឺជាវិធីមួយដែលយើងគោរពព្រះអង្គ។ វាបានបង្ហាញការគោរព និងប្រកាសថាយើងជឿលើព្រះបន្ទូល ហើយទុកចិត្តលើព្រះបន្ទូលរបស់ព្រះអង្គ។

> ផ្លូវដែលនាំយើងទៅកាន់សន្តិភាពលឿនបំផុត គឺការរៀនទុកចិត្តព្រះជាម្ចាស់។

វិញ្ញាណនៃការភ័យខ្លាច គឺជាឫសគល់នៃបំណងប្រាថ្នាដែលមិនចេះស្កប់ស្កល់ចង់ដឹងគ្រប់ចម្លើយទាំងអស់អំពីជីវិត។ យើងចង់ដឹងថាតើមានអ្វីនឹងកើតឡើងបន្តបន្ទាប់ទៀត ហើយចង់ដឹងថាតើមានអ្វីកើតឡើយចំពោះយើងនៅថ្ងៃអនាគត។ យើងមិនចង់បានការភ្ញាក់ផ្អើលណាមួយឡើយ យ៉ាងហោចណាស់ចង់ដឹងពីអ្វីដែលធ្វើឲ្យយើងមិនមានអំណរ។

ទោះបីជាមានរឿងជាច្រើនដែលព្រះជាម្ចាស់ពិតជាបានបើកសំដែងដល់យើង តែព្រះអង្គមិនធ្វើដូច្នេះគ្រប់ពេលនោះទេ ហើយនៅពេលដែលព្រះអង្គមិនបើកសំដែងដល់យើងក៏ដោយក៏យើងត្រូវតែទុកចិត្តថាយើងពិតជាអាចពឹងផ្អែកលើព្រះអង្គបាន។ នៅពេលដែលយើងទុកចិត្តព្រះអង្គ ហើយយើងមានភាពអត់ធ្មត់ យើងនឹងឃើញថាព្រះអង្គនឹងមិនដែលធ្វើឲ្យយើងដួលឡើយ។

ខ្ញុំសំគាល់ឃើញថាការដែលមិនដឹងនឹងធ្វើឲ្យមានការខ្វល់ខ្វាយ និងបណ្តាលឲ្យមានការថប់អារម្មណ៍។ គំនិតរបស់យើងប្តូរពីរឿងមួយទៅរឿងមួយយ៉ាងលឿន ព្យាយាមរកអ្វីដែលសមហេតុផល ហើយទោះបីជានៅពេលដែលយើងបានគិតថាយើងបានដោះស្រាយគ្រប់បញ្ហាក៏ដោយ តែយើងនៅតែអាចនឹងធ្វើខុស។ យើងចង់ឲ្យអ្វីៗគ្រប់យ៉ាងមានរបៀបរៀបរយនៅកន្លែងដ៏តូចមួយនៅក្នុងជីវិតរបស់យើង ប៉ុន្តែមានពេលខ្លះជីវិតរបស់យើងរញ៉េរញ៉ៃជាជាងមានសណ្តាប់ធ្នាប់។ គ្មាននរណាម្នាក់ទាល់តែសោះដែលនឹងធ្វើអ្វីដែលយើងចង់បានរួមទាំព្រះជាម្ចាស់ផង ហើយអ្វីដែលយើងមានអារម្មណ៍ គឺការឈឺចាប់។ មានពេលជាច្រើននៅក្នុងជីវិតរបស់ខ្ញុំ ដែលខ្ញុំបានដាក់ការរំពឹងទុកទៅលើអ្វីដែលខ្ញុំគិតថាវានឹងកើតឡើង ហើយបន្ទាប់មកធ្វើឲ្យខ្ញុំរវើរវាយនៅពេលដែលរឿងនោះមិនបានដូចការរំពឹងទុក។

ស្ថានភាពទាំងនេះអាចជាមេរៀនសម្រាប់យើង ប៉ុន្តែដើម្បីឲ្យរឿងនេះកើតឡើង

យើងត្រូវតែបន្ទាបខ្លួន និងសុំឲ្យព្រះជាម្ចាស់បង្ហាញយើងថា តើយើងគិតខុសត្រង់ណា។ សម្រាប់ខ្ញុំផ្ទាល់ ខ្ញុំតែងតែរៀបផែនការតាមអ្វីដែលខ្ញុំចង់បាន ហើយពេលខ្លះខ្ញុំមិនបានទាំងផ្តោតអារម្មណ៍ទៅលើអ្វីដែលព្រះជាម្ចាស់សព្វព្រះទ័យផង។

ជំហ៊ានននៃជំនឿដ៏សាមញ្ញបំផុតដែលយើងប្រើក្នុងស្ថានភាពនៃជីវិតរបស់យើង គឺនិយាយថា «ព្រះអម្ចាស់ នេះជាអ្វីដែលទូលបង្គំចង់ឃើញថាវានឹងកើតឡើងក្នុង ជីវិតទូលបង្គំតែកុំឲ្យតាមបំណងចិត្តកូនឡើយ គឺតាមបំណងព្រះហឫទ័យព្រះអង្គវិញ»!

នៅពេលដំបូងដែលខ្ញុំចាប់ផ្តើមព័ន្ធកិច្ចរបស់ខ្ញុំ ខ្ញុំបានជ្រើសរើសមិត្តភ័ក្តមួយក្រុមដែលខ្ញុំគិតថាពួកគេអាចធ្វើការជាមួយខ្ញុំបាន និងជួយខ្ញុំដើម្បីបង្កើតអ្វីដែលព្រះជាម្ចាស់បានបើកសំដែងដល់ខ្ញុំ ដែលខ្ញុំនឹងធ្វើជាគ្រូបង្រៀនព្រះបន្ទូលរបស់ព្រះអង្គ។ ចូរដឹងថាខ្ញុំនិយាយបែបនោះហើយ ខ្ញុំក៏បានជ្រើសរើសពួកគេមែន។ ខ្ញុំបានសម្រេចចិត្តដោយមិនបានទាំងអធិស្ឋាន និងមិនបានគិតពីព្រះជាម្ចាស់នៅក្នុងរឿងនេះទេ។ នៅពេលដែលព្រះយេស៊ូជ្រើសរើសសាវ័ករបស់ព្រះអង្គ (អស់អ្នកដែលនឹងធ្វើការជាមួយព្រះអង្គ) ព្រះអង្គបានអធិស្ឋានពេញមួយយប់មុនពេលជ្រើសរើសពួកគេ (សូមមើលនៅក្នុងគម្ពីរ លូកា ៦:១២-១៣)។

មនុស្សដែលខ្ញុំបានជ្រើសរើសមិនមែនជាជម្រើសរបស់ព្រះជាម្ចាស់ឡើយ ហើយវាក្លាយជាមហន្តរាយ ដែលធ្វើឲ្យខ្ញុំបែរជាមានការឈឺចាប់យ៉ាងខ្លាំងនៅក្នុងអារម្មណ៍របស់ខ្ញុំទៅវិញ។ ពួកគេនិយាយដើមខ្ញុំ កុហក ធ្វើការចោទប្រកាន់មិនត្រឹមត្រូវ ហើយធ្វើឲ្យខ្ញុំស្ទើរតែខ្ចាតចេញពីការបម្រើ មុនពេលដែលខ្ញុំចាប់ផ្តើមសារជាថ្មីក្នុងការបន្តគោលដៅរបស់ខ្ញុំ។

ជម្រើសសំខាន់បំផុត ដែលយើងជ្រើសរើស គឺទាក់ទងទៅនឹងអ្នកដែលយើងមានទំនាក់ទំនងជាមួយ ជាពិសេសនៅពេលដែលយើងមាននឹមជាមួយពួកគេដោយផ្ទាល់។ ជារឿយៗសាតាំងបានប្រើប្រាស់មនុស្ស ទាំងគ្រិស្តបរិស័ទដូចគ្នាផង ដើម្បីធ្វើឲ្យយើងមានរបួសនិងចុះខ្សោយ។ មនុស្សអាចស្មោះត្រង់និងក៏អាចមានកំហុសដែរ ។ ក្រុមមនុស្សទាំងនេះបានគិតថាពួកគេបានឮព្រះសូរសៀងរបស់ព្រះជាម្ចាស់អំពីខ្ញុំ តែតាមពិតទៅវាមិនពិតទាល់តែសោះហើយអំណួតរបស់ពួកគេបានបំផ្លាញពួកគេទៅ។

> ការអធិស្ឋាន អាននឹងនាំទៅរកគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់យើង។

តាមរយៈការឆ្លងកាត់ស្ថានភាពជាច្រើននៅក្នុងជីវិត ខ្ញុំបានរៀនយ៉ាងលំបាកថាការអធិស្ឋាន អាចនឹងនាំទៅរកគ្រប់ការសម្រេចចិត្តសំខាន់ៗរបស់យើង។ ការសន្មត់ និងការសន្និដ្ឋានរបស់យើងមិនបានគាប់ព្រះទ័យព្រះជាម្ចាស់ឡើយ។ កុំឲ្យបង្កើតកំហុសដោយការរៀបចំផែនការ រួចទើបអធិស្ឋាន

សូមឲ្យព្រះជាម្ចាស់ធ្វើឲ្យផែនការនោះបានសម្រេចឡើយ។ ជាដំបូងត្រូវអធិស្ឋាន ហើយអនុញ្ញាតិឲ្យព្រះវិញ្ញាណដឹកនាំអ្នកទៅកាន់បំណងប្រាថ្នាល្អទាំងអស់របស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើង។

## *ស្កប់ស្កល់នឹងការដែលមិនដឹង*

លោកសាវ័កប៉ូលជាមនុស្សដែលមានការអប់រំខ្ពស់ ហើយមកដល់ចំណុចមួយនៃជីវិតរបស់គាត់ គឺជាពេលដែលគាត់និយាយថា«*ដ្បិតខ្ញុំបានផ្តាច់ចិត្តថា នៅក្នុងពួកអ្នករាល់គ្នា នោះខ្ញុំមិនព្រមស្គាល់រឿងអ្វីទៀត ក្រៅពីព្រះយេស៊ូវគ្រីស្ទទេ ហើយគឺដែលទ្រង់ត្រូវឆ្កាងផង*»(១កូរិនថូស២:២)។ នៅពេលដែលគាត់ប្រកាស់ដំណឹងល្អដល់បណ្តាជន គាត់បានប្រាប់ពួកគេថា ការសង្គ្រោះតាមរយៈព្រះយេស៊ូធ្លាប់ជាអាថ៌កំបាំង កាលពីមុន និងជាអាថ៌កំបាំងរបស់ព្រះជាម្ចាស់ ប៉ុន្តែគាត់ជ្រើសរើសជឿជាជាងការព្យាយាមយល់។ មានមនុស្សរាប់មិនអស់ទេ ដែលបដិសេធអំណរជាប្រយោជន៍ដែលបានមកពីភាពសាមញ្ញនៃជំនឿបែបកូនក្មេងនេះ។ ពួកគេចង់យល់ក្នុងគំនិតគ្រប់ទាំងអាថ៌កំបាំងនៃឈើឆ្កាងរបស់ព្រះគ្រិស្ត និងការសង្គ្រោះរបស់ព្រះអង្គ ប៉ុន្តែមនុស្សអាចយល់ការនេះបាន តាមរយៈដួងចិត្តប៉ុណ្ណោះ មិនមែនតាមរយៈគំនិតឡើយ។

បើយើងមិនមានសំណួរដែលគ្មានចម្លើយនៅក្នុងជីវិតយើងទេ ដូច្នេះយើងមិនត្រូវការជំនឿឡើយ។ យើងអាចនិយាយបានថាជំនឿជំនួសឲ្យចម្លើយ! យើងគួរតែរៀនឲ្យស្គាល់ព្រះបន្ទូលរបស់ព្រះអង្គចង់ដឹងពីព្រះអង្គផ្ទាល់និងដឹងពីបំណងព្រះហឫទ័យរបស់ព្រះអង្គវិញជាជាងការស្វែងយល់ចម្លើយដែលទាក់ទងនឹងស្ថានភាពរបស់យើងដោយឥតឈប់ឈរ។ នៅពេលដែលមានមនុស្សសួរថាបើអ្នកជួបនឹងបញ្ហាតើអ្នកនឹងធ្វើដូចម្តេច នោះអ្នកអាចឆ្លើយយ៉ាងសាមញ្ញថា«ខ្ញុំមិនដឹងទេ»។ ប្រាប់អ្នកទាំងនោះថាអ្នកកំពុងអធិស្ឋានអំពីរឿងគ្រប់យ៉ាង ហើយអ្នកច្បាស់ក្នុងចិត្តថាព្រះជាម្ចាស់នឹងប្រាប់ទិសដៅដល់អ្នកនៅពេលវេលាសមស្របមួយ។ ទោះអ្នកហាក់បីដូចជាមានទំនុកចិត្តជាងអ្វីដែលអ្នកមានពិតប្រាកដក៏ដោយ វានៅតែជាការល្អដែលអ្នកប្រកាសជំនឿរបស់អ្នក។ បើយើងជ្រើសរើសទុកចិត្តព្រះជាម្ចាស់ នោះអារម្មណ៍របស់យើងនឹងភ្ជាប់ជាមួយការសម្រេចចិត្តរបស់យើងមិនខាន។ តាមពិតទៅការស្វែងរកចម្លើយនៃអាថ៌កំបាំងនៅក្នុងជីវិតរបស់យើងគ្មានអ្វីខុសទេ ប៉ុន្តែនៅពេលដែលយើងបែរជាច្របូកច្របល់ និងបែរជាមានបញ្ហាជាសញ្ញាដែលបញ្ជាក់ថាយើងទៅហួសដែកំណត់របស់យើងហើយ។

មនុស្សមានបទពិសោធន៍ជាមួយការយល់ច្រឡំជាច្រើននៅក្នុងជីវិត ហើយខ្ញុំជឿ

ថាវាមកពីការគ្មានលំនឹងដោយគេចង់ដឹងរឿងគ្រប់យ៉ាង។ តើអ្នកអាចមានជំនឿទេនៅពេលដែលអ្នកស្ថិតក្នុងភាពងងឹត និងមិនយល់ពីអ្វីដែលកំពុងកើតឡើង ជាមួយអ្នកក្នុងពេលបច្ចុប្បន្ននេះ? នេះជាប្រភេទនៃជំនឿដែលព្រះជាម្ចាស់ស្វែងរក។ ព្រះអង្គចង់ឲ្យយើងទុកចិត្តព្រះអង្គ ជាពិសេសនៅពេលដែលយើងស្ថិតក្នុងភាពងងឹត ឬនៅពេលដែលជីវិតស្ថិតក្នុងភាពអាថ៌កំបាំង ហើយយើងមិនឃើញថាព្រះអង្គកំពុងតែធ្វើការ ឬយើងមិនមានអារម្មណ៍ថាមានព្រះវត្តមានរបស់ព្រះអង្គ។ ស្ថានភាពទាំងនេះពិតជាល្អសម្រាប់យើង ពីព្រោះវានឹងជួយយើងឲ្យមានជំនឿ។ ព្រះគម្ពីរបាននិយាយអំពីជំនឿតូចនិងជំនឿធំ តើហេតុអ្វីបានជាយើងស្កប់ស្កល់ជាមួយជំនឿតូចដែលយើងអាចអភិវឌ្ឍន៍ក្លាយជាជំនឿធំតាមរយៈការទុកចិត្តព្រះជាម្ចាស់ក្នុងពេលលំបាក?

## ត្រូវតែដឹង

ពេលថ្មីៗនេះខ្ញុំបានមើលកុនមួយរឿង ដែលទាក់ទងទៅនឹងភ្នាក់ងាស៊ើបការFBIពីរនាក់ដែលមានកំរិតភាពច្បាស់លាស់ផ្សេងពីគ្នា។ ម្នាក់ហាក់បីដូចជាចូលរួមជាមួយនឹងរឿងក្តីនោះ ខណៈពេលដែលម្នាក់ទៀតមិនខ្វាយខ្វល់ ហើយនៅពេលដែលគាត់សុំព័ត៌មាន ហើយគេបានប្រាប់គាត់ថា អ្នកនឹងទទួលចម្លើយនៅពេលអ្នកមានមូលដ្ឋាន«ត្រូវតែដឹង»។ ពាក្យមួយទៀតអាចនិយាយថា មានតែអ្នកដែលពិតជាចង់ដឹងប៉ុណ្ណោះដែលគេនឹងប្រាប់ព័ត៌មានលំអិតដល់អ្នកនោះ។

ខ្ញុំគិតថាព្រះជាម្ចាស់អនុវត្តន៍មូលដ្ឋាននេះជាមួយយើងដូចគ្នា។ បើយើងចង់ដឹងអ្វីមួយ យើងអាចប្រាកដក្នុងចិត្តថា ព្រះអង្គនឹងប្រាប់យើង តែបើយើងមិនចង់ដឹងទេ ឬបើយើងមិនដឹងល្អជាង នោះព្រះអង្គមិនប្រាប់យើងឡើយ ហើយយើងអាច និងគួរតែរៀនស្កប់ស្កល់ជាមួយរឿងទាំងអស់នេះ។

ចំណេះដឹងអំពីអ្វីមួយអាចជាបន្ទុកដល់ព្រលឹងរបស់យើង ហើយបណ្តាលឲ្យយើងព្រួយនិងអន្ទះសារ ហើយគ្មាននរណាម្នាក់ត្រូវការរឿងទាំងនេះទេ! នៅពេលនោះ ការដែលមិនដឹងអាចជាសន្តិភាពយ៉ាងល្អទៅវិញទេ! នៅសប្តាហ៍មុនខ្ញុំបាននិយាយទូរស័ព្ទជាមួយមនុស្សម្នាក់ យើងបានលើករឿងដែលយើងមិនឯកភាពគ្នាមួយមកនិយាយដែលទាក់ទងទៅនឹងសីលធម៌ក្នុងជីវិតរបស់មនុស្សម្នាក់ទៀតដែលយើងទាំងពីរនាក់ស្គាល់។ យើងបានជជែកគ្នា ប៉ុន្តែយើងក៏ប្រយ័ត្នដែរដើម្បីកុំឲ្យយើងនិយាយដើមអ្នកនោះ ឬក៏និយាយអ្វីដែលមិនបានការ។ មិត្តភ័ក្តិរបស់ខ្ញុំបានសួរសំណួរមួយទាក់ទងនឹងស្ថានភាពនេះ ហើយមុនពេលទាំងដែលខ្ញុំសម្រេចចិត្តថាឆ្លើយ ឬអត់ផងនាងក៏និយាយថា « មិនអីទេ ខ្ញុំមិនចង់ដឹងរឿងនេះទេ»។

ខ្ញុំបានគិតថា តាមរយៈពាក្យសំដីនេះអាចបញ្ជាក់បានថា នាងមានវិញ្ញាណដែលចាស់ទុំ និងអាចជាគំរូមួយសម្រាប់យើងរាល់គ្នា។ មានភាពខុសគ្នារវាងការចង់ដឹងអ្វីមួយដោយគ្រាន់តែចង់ដឹង ឬការចង់គ្រប់គ្រងស្ថានការណ៍ និងចង់ដឹងអ្វីដែលយើងពិតជាចង់ដឹងពិតមែន។ ជាជាងការយល់ច្រឡំ និង ខកចិត្តក្នុងការព្យាយាមរកហេតុផល និងសួរសំណួរអំពីរឿងនៅក្នុងជីវិត តើហេតុអ្វីបានជាយើងមិនគ្រាន់តែទុកចិត្តព្រះជាម្ចាស់ ទុកឲ្យព្រះអង្គធ្វើការជាមួយយើងលើមូលដ្ឋាននៃពាក្យថា«ត្រូវតែដឹង»។

មានស្ថានភាពខ្លះនៅក្នុងគម្ពីរដែលមនុស្សរកហេតុផលជាមួយព្រះជាម្ចាស់ ប៉ុន្តែមិនសំដៅទៅលើការស្វែងរកអ្វី ដែលព្រះជាម្ចាស់មិនទាន់រួចរាល់ក្នុងការបើកសំដែងដល់គេឡើយ។ នេះជាឧទាហរណ៍ពីរនៅក្នុងគម្ពីរដែលបង្ហាញភាពខុសគ្នារវាងហេតុផលដែលស្រប និងមិនស្របបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់។

*ព្រះយេហូវ៉ាទ្រង់មានព្រះបន្ទូលថា មកចុះ យើងនឹងពិភាក្សាជាមួយគ្នា ទោះបើអំពើបាបរបស់ឯងដូចជាពណ៌ក្រហមទែងក៏ដោយ គង់តែនឹងបានសដូចហិមៈ ទោះបើក្រហមឆ្អៅក៏ដោយ គង់តែនឹងបានដូចជារោមចៀមវិញ។*

*អេសាយ ១:១៨*

*ចូរទីពឹងដល់ព្រះយេហូវ៉ាឲ្យអស់អំពីចិត្ត កុំឲ្យពឹងផ្អែកលើយោបល់របស់ខ្លួនឡើយ។*

*សុភាសិត ៣:៥*

ជាថ្មីម្តងទៀតខ្ញុំចង់បញ្ជាក់ឲ្យច្បាស់ថាការសួរសំណួរព្រះជាម្ចាស់វាមិនខុសនោះទេ។ ព្រះអង្គតែងតែចង់ផ្តល់ហេតុផលដល់យើង។ តែកុំអនុញ្ញាតឲ្យហេតុផលត្រឹមត្រូវ ក្លាយជាហេតុផលមិនត្រឹមត្រូវ ឬមិនស្របតាមបំណងព្រះហឫទ័យរបស់ព្រះជាអង្គឡើយ។ ចូរឲ្យសន្តិភាពត្រួតត្រានៅក្នុងជីវិតរបស់អ្នក(កូឡុស៣:១៥)។ ឬយើងអាចនិយាយថាចូរឲ្យសន្តិភាពជាកត្តាក្នុងការសម្រេចចិត្ត ទោះបីជាព្រះជាម្ចាស់សព្វព្រះហឫទ័យនឹងសំណួររបស់អ្នកឬអត់ក៏ដោយ។

## *នៅពេលដែលហាក់បីដូចជាគ្មានផ្លូវ*

ការភ័យក្លាចនឹងយកឈ្នះយើង នៅពេលដែលយើងគិតថាបញ្ហារបស់យើងគ្មានដំណោះស្រាយ។ តើយើងធ្លាប់និយាយឬ លឺអ្នកដទៃនិយាយញឹកញាប់ដែរទេថា«គ្មានផ្លូវដែលអាចដោះស្រាយរឿងនេះបានឡើយ»? បើយើងមិនស្គាល់ផ្លូវ មិនមានន័យ

ថាគ្មានផ្លូវនោះទេ។ ព្រះយេស៊ូមានបន្ទូលពីព្រះអង្គផ្ទាល់ថា «ខ្ញុំគឺជាផ្លូវ» (យ៉ូហាន ១៤:៦)។ លោក អេសាយបាននិយាយថា «ព្រះជាម្ចាស់នឹងដឹកនាំមនុស្សខ្វាក់តាមផ្លូវដែលគេមិនស្គាល់» (អេសាយ៤២:១៦)។ ព្រះជាម្ចាស់អាចដឹកនាំយើងនៅក្នុងភាពងងឹត ព្រោះសម្រាប់ព្រះអង្គភាពងងឹតក៏ដូចជាពន្លឺដែរ។ យើងអាចនៅក្នុងភាពងងឹតជាមួយអ្វីដែលកើតឡើង ប៉ុន្តែព្រះជាម្ចាស់ គឺជាពន្លឺព្រះអង្គមិនដែលគង់នៅក្នុងភាពងងឹតសោះឡើយ។ ទំនុកតម្កើងរបស់ស្តេចដាវីឌ នៅក្នុងជំពូកមួយដ៏អស្ចារ្យនៅក្នុងគម្ពីរបានសរសេរពីការទុកចិត្តព្រះជាម្ចាស់ថា៖

បើយើងមិនស្គាល់ផ្លូវ មិនមានន័យថាគ្មានផ្លូវនោះទេ។

*ទោះបើទូលបង្គំនឹង យកស្លាបនៃបច្ចូសកាលហោះ ទៅនៅឯទីបំផុតនៃសមុទ្រ គង់តែព្រះហស្តទ្រង់នឹងនាំទូលបង្គំនៅទីនោះហើយព្រះហស្តស្តាំទ្រង់នឹងក្តាប់ទូលបង្គំដែរ បើទូលបង្គំថា សេចក្តីងងឹតនឹងគ្របបាំងទូលបង្គំជាប្រាកដ ហើយពន្លឺដែលនៅជុំវិញទូលបង្គំនឹង ត្រឡប់ទៅជាយប់វិញ ដូច្នេះទាំងសេចក្តីងងឹតនោះឯង មិនលាក់ពីទ្រង់ឡើយទោះទាំងយប់ក៏ភ្លឺដូចជាពេលថ្ងៃដែរ ឯសេចក្តីងងឹត និងពន្លឺភ្លឺ នោះស្មើគ្នានៅចំពោះទ្រង់។*

*ទំនុកតម្កើង១៣៩:៩-១២*

នៅពេលដែលយើងឆ្លងកាត់ការល្បងលរយៈពេលយូរ ឬនៅពេលដែលយើងជួបប្រទះអ្វីដែលលំបាកខ្លាំង នោះគ្មានអ្វីចម្លែកទេដែលយើងទៅជាបាក់ទឹកចិត្ត និងចាប់ផ្តើមគិតថារឿននេះនឹងនៅជាប់ក្នុងជីវិតរបស់យើងជាប់រហូត។ យើងគិតអំពីរឿងផ្សេងៗបែបដូច្នេះថា៖ *រឿងនេះនឹងមិនចប់ឡើយ។ ខ្ញុំបានធ្វើអ្វីដែលខ្ញុំអាចធ្វើបានរួចហើយ ប៉ុន្តែវាមិនបានការសោះ។ វាហាក់បីដូចជាគ្មានច្រកចេញសោះ!* ប៉ុន្តែព្រះជាម្ចាស់មានសាច់រឿងផ្សេងដើម្បីប្រាប់យើងរាល់គ្នា។ ព្រះអង្គមានបន្ទូលថា៖

*កុំឲ្យឯងរាល់គ្នានឹងចាំពីការទាំងប៉ុន្មានដែលកន្លងទៅហើយ ឬរិះគិតពីអស់ទាំងការពីចាស់បុរាណនោះឡើយ មើល អញនឹងធ្វើការ១ថ្មីវិញ ការនោះនឹងលេចឡើងឥឡូវ តើឯងរាល់គ្នានឹងមិនស្គាល់ទេឬ អញនឹងធ្វើផ្លូវ១នៅទីរហោស្ថាន ហើយទន្លេនៅសមុទ្រខ្សាច់។*

*អេសាយ ៤៣:១៨-១៩*

បទគម្ពីរនេះបានលើកទឹកចិត្តខ្ញុំជាច្រើនដងក្នុងពេលផ្សេងៗគ្នានៅក្នុងជីវិតរបស់ខ្ញុំ ហើយខ្ញុំសូមអធិស្ឋានឲ្យវាកើតឡើងសម្រាប់អ្នកដែរ។ នៅពេលដែលអ្នកឈឺចាប់ សូមចាំថាព្រះជាម្ចាស់នឹងបង្ហាញផ្លូវដល់អ្នក!

សូមគិតមើលពីពេលមួយនៅក្នុងជីវិតរបស់អ្នកដែលព្រះអង្គបានបង្ហាញផ្លូវដល់អ្នក នៅពេលដែលអ្នកហាក់បីដូចជាគ្មានច្រកចេញ ចូរចាំថាព្រះជាម្ចាស់នឹងធ្វើការនេះម្តងទៀត! ផ្លូវរបស់ព្រះអង្គមិនមែនជាផ្លូវរបស់យើងទេ ប៉ុន្តែដូចដែលលោក អេសាយបាននិយាយ ព្រះជាម្ចាស់អាចបង្កើតផ្លូវនោះ ទោះបីជានៅទីរហោស្ថានក៏ដោយ ហើយព្រះអង្គក៏អាចនឹងនាំទន្លេមកក្នុងពេលដែលជីវិតរបស់យើងដែលកំពុងតែហួតហែងដែរ។

ទោះបីជានៅពេលដែលយើងសម្រេចចិត្តជឿថាព្រះជាម្ចាស់នឹងធ្វើផ្លូវឲ្យយើង តែវានឹងនាំយើងឲ្យសួរសំណួរមួយទៀតថា៖ «តើព្រះអង្គនឹងធ្វើនៅពេលណា»? មានតែព្រះអង្គទេដែលដឹងពិតប្រាកដ ហើយស្ទើរតែគ្រប់ពេលនៅពេលដែលយើងសួរព្រះអង្គ ព្រះអង្គហាក់ដូចជាមិនចាប់អារម្មណ៍ក្នុងការផ្តល់ចម្លើយដល់យើងឡើយ។ នេះដោយសារតែព្រះអង្គចង់ឲ្យយើងទុកចិត្តទ្រង់។

# ជំពូក ១៥

# នៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់
## (ផ្នែកទី១)

*វីរៈបុរសដែលមានអំណាចបំផុតពីរនាក់ គឺភាពអត់ធ្មត់ និងពេលវេលា។*
*លោក លេអូ តុលស្តយ*

បើអ្នកដូចខ្ញុំ ការរៀនអត់ធ្មត់ គឺជាការប្រឈមខ្លាំងបំផុតមួយនៅក្នុងជីវិត។ តើអ្នកធ្លាប់ស្ថិតនៅក្នុងបន្ទប់រង់ចាំ ជាកន្លែងដែលក្រុមគ្រួសារ និងមិត្តភ័ក្តិរង់ចាំដំណឹងពីគ្រូពេទ្យដែលនឹងប្រាប់ដំណឹងដល់ពួកគេពីអ្នកដែលគេស្រឡាញ់ដែលទើបតែធ្វើការវះកាត់រួចដែរឬទេ? មនុស្សភាគច្រើនដែលរង់ចាំហាក់បីដូចជាមានការអន្ទះសារបន្តិច ហើយមើលទៅមុខរបស់ពួកគេហាក់បីដូចជាតក់ស្លុតនិងបង្ហាញការព្រួយបារម្ភ។ ពួកគេរង់ចាំស្តាប់លទ្ធផល ប៉ុន្តែឥឡូវនេះពួកគេមិនដឹងអ្វីទាំងអស់។ ពួកគេរង់ចាំ រង់ចាំ និងរង់ចាំ។ តើដំណឹងនោះ ជាដំណឹងល្អ ឬដំណឹងអាក្រក់? បើការរង់ចាំលើសការគ្រោងទុកបីបួនម៉ោង ធ្វើឲ្យអ្នករង់ចាំទាំងនោះកាន់តែអន្ទះសារ។ គំនិតរបស់ពួកគេប្រហែលជាកាន់តែខ្មៅងងឹងទៅៗ និងកាន់តែអវិជ្ជមាន ហើយនៅក្នុងពិភពខាងសាច់ឈាមយើងអាចយល់ពីរឿងនេះបានយ៉ាងច្បាស់។

សំណួរដ៏សំខាន់មួយ គឺថាតើយើងនឹងទៅជាយ៉ាងណានៅពេលដែលយើងស្ថិតនៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់? តើយើងអន្ទះសារ ច្របូកច្របល់ និងមានការព្រួយបារម្ភ ឬយើងរង់ចាំដោយអត់ធ្មត់ និងរំពឹងដំណឹងល្អ? បើការរង់ចាំយូរជាងអ្វីដែលយើងគិត តើយើងនៅតែវិជ្ជមាន និងមានក្តីសង្ឃឹមដែរឬទេ? យើងតែងតែនិយាយថាយើងទុកចិត្តព្រះជាម្ចាស់ប៉ុន្តែតើយើងបានបង្ហាញពីផលនៃការទុកចិត្តព្រះដែរឬទេ?

### *ព្រះជាម្ចាស់ដោះស្រាយចេញជារៀងរហូត*

ព្រះជាម្ចាស់មិនដែលប្រញាប់ប្រញាល់ពេកចំពោះរឿងអ្វីមួយឡើយ ប៉ុន្តែគឺយើងទេដែលតែងតែប្រញាប់ប្រញាល់គ្រប់រឿងទាំងអស់! យើងមិនស្តប់ចិត្តឡើយ ទោះបី

យើងដឹងថាព្រះជាម្ចាស់នឹងធ្វើការ តែយើងចង់ដឹងថាតើពេលណាទើបព្រះអង្គធ្វើការនោះ។ បទគម្ពីរបានសន្យាជាមួយយើងថានៅពេលវេលាកំណត់ ព្រះជាម្ចាស់នឹងធ្វើអ្វីដែលព្រះអង្គត្រូវធ្វើ ប៉ុន្តែតើពេលណាជាពេលកំណត់? វាគឺជាពេលវេលាដែលព្រះជាម្ចាស់កំណត់ថាជាពេលវេលាត្រឹមត្រូវ ហើយព្រះអង្គកម្រប្រាប់យើងថាតើត្រូវចំណាយពេលយូរប៉ុណ្ណាណាស់។ យ៉ាងណាមិញយើងអាចប្រាកដយ៉ាងច្បាស់ថាវាមិនយូរពេកទេ។ ព្រះជាម្ចាស់ពិតជាដឹងថាតើយើងអាចទ្រាំទ្រជាមួយអ្វីបាន ហើយព្រះអង្គមិនដែលរុញយើងហួសព្រំដែនកំណត់ឡើយ!

អ្វីដែលយើងគិតថាជាពេលវេលាដ៏យូរ គឺគ្រាន់តែជាពេលវេលាខ្លីមួយប៉ុណ្ណោះក្នុងផ្លូវរបស់ព្រះជាម្ចាស់ដែលមើលលើរឿងនោះ៖

> *តែពួកស្ងួនភ្ងាអើយ កុំឲ្យភ្លេចសេចក្តី១នេះឡើយ គឺថា នៅចំពោះព្រះអម្ចាស់១ថ្ងៃទុកដូចជា១ពាន់ឆ្នាំ ហើយ១ពាន់ឆ្នាំក៏ទុកដូចជា១ថ្ងៃដែរ។*
>
> *២ពេត្រុស៣:៨*

ព្រះអង្គមើលឃើញរឿងផ្សេងៗនៅក្នុងពន្លឺនៃភាពអស់កល្បជានិច្ច ទោះជាយ៉ាងណាក៏ព្រះអង្គមិនប្រញាប់ពេកដែរ។ព្រះអង្គឃើញទីបញ្ចប់តាំងពីពេលចាប់ផ្តើមម្ល៉េះ។ ព្រះអង្គធ្លាប់ទៅកន្លែងដែលយើងកំពុងទៅ ហើយព្រះអង្គដឹងយ៉ាងច្បាស់ថាតើនឹងមានរឿងអ្វីកើតឡើង! ព្រះអង្គតែងតែមានហេតុផលល្អចំពោះអ្វីដែលព្រះអង្គបានធ្វើ ហើយព្រះអង្គជួយយើងឲ្យទុកចិត្តទ្រង់ទោះបីជាការរង់ចាំរបស់យើងខ្លីឬវែងក៏ដោយ

យើងតែងតែចង់បានអ្វីដែលយើងមិនទាន់ចាស់ទុំគ្រប់គ្រាន់ក្នុងការចាត់ចែងវាឲ្យបានល្អនៅឡើយ ប៉ុន្តែព្រះជាម្ចាស់ដឹងពីពេលវេលាល្អឥតខ្ចោះ ហើយខ្ញុំចង់ប្រាប់អ្នកថាព្រះអង្គមិនឲ្យអ្វីដល់អ្នកឡើយបើមិនទាន់ដល់ពេលត្រឹមត្រូវ។ ប្រហែលជាព្រះជាម្ចាស់មានបន្ទូលថា «ចូរចាំសិន» ឬព្រះអង្គមានបន្ទូលថា«ទេ» ប៉ុន្តែអ្វីក៏ដោយដែលព្រះអង្គសម្រេចចិត្ត នឹងក្លាយជារបស់ដែលល្អឥតខ្ចោះ ក្នុងពេលវេលាល្អឥតខ្ចោះមិនខាន។ អ្វីដែលព្រះជាម្ចាស់ធ្វើទាក់ទងនឹងជីវិត និងទំនាក់ទំនងរបស់យើងជាមួយព្រះអង្គ គឺដើម្បីឲ្យយើងទទួលបានការល្អ!

ក្នុងនាមយើងជាបុត្ររបស់ព្រះជាម្ចាស់ យើងមានផលនៃការអត់ធ្មត់នៅក្នុងយើងដែលសរសេរនៅក្នុងគម្ពីរ កាឡាទី ៥:២២ ប៉ុន្តែជាធម្មតាវាត្រូវប្រើពេលបីបួនឆ្នាំក្នុងការដើរជាមួយព្រះអង្គមុនពេលដែលយើងអាចឃើញវាកាន់តែជាក់ស្តែង។ គ្រាប់ពូជនេះនៅក្នុងយើងរួចហើយ ប៉ុន្តែវាត្រូវការពេលវេលា និងបទពិសោធន៍ ដើម្បីឲ្យវាអាច

លូតលាស់ និងរឹងមាំបាន។

ពាក្យដើមជាភាសាក្រិចបានបកប្រែពាក្យ «អត់ធ្មត់» ថា «ការស៊ូទ្រាំ» ឬពាក្យមួយទៀតថាការនៅជាប់ជាមួយអ្វីមួយទោះបីជាយើងមិនចូលចិត្ត ឬក៏ធ្វើឲ្យយើងឈឺចាប់ក៏ដោយ។ វាមានន័យថាការមើលឃើញតាំងពីដើមរហូតដល់ចប់។ មនុស្សយើងភាគច្រើនចង់រត់គេចពីរឿងដែលធ្វើឲ្យយើងមានទុក្ខលំបាក។ គំនិតដែលគិតថាការលំបាកនៅតែបន្តមាន ដោយមិនដឹងថាតើយើងនឹងត្រូវទ្រាំទ្រអស់រយៈពេលប៉ុន្មានជារឿងមិនសប្បាយចិត្តខ្លាំងណាស់។ព្រះជាម្ចាស់មិនផ្តល់ចម្លើយនូវអ្វីដែលយើងប្រាថ្នាគ្រប់ពេលឡើយ ជាធម្មតាដោយព្រោះព្រះអង្គចង់ឲ្យវិញ្ញាណរបស់យើងលូតលាស់ ហើយព្រះអង្គជ្រាបថាវាមានសារៈសំខាន់ជាងការដែលយើងគេចផុតពីអ្វីដែលយើងឆ្លងកាត់។

មុនពេលដែលខ្ញុំបានដឹងច្រើនពីការទុកចិត្តព្រះជាម្ចាស់ វាពិតជាធ្វើឲ្យខ្ញុំខកចិត្តនៅពេលដែលខ្ញុំត្រូវការព្រះអង្គឲ្យធ្វើអ្វីមួយទាំងខ្ញុំដឹងថា ជាការងាយស្រួលសម្រាប់ទ្រង់ ប៉ុន្តែព្រះអង្គហាក់បីដូចជាមិនធ្វើអ្វីទាំងអស់។ ឥឡូវនេះខ្ញុំដឹងថាទោះបីជាគ្មានអ្វីផ្លាស់ប្តូរនៅក្នុងកាលៈទេសៈរបស់ខ្ញុំក៏ដោយ ក៏ព្រះជាម្ចាស់ធ្វើការក្នុងខ្ញុំដែរ។ ព្រះអង្គបានកែតម្រង់សេចក្តីជំនឿរបស់ខ្ញុំ ហើយតាមរយៈការនេះ ព្រះអង្គបង្កើន និងធ្វើឲ្យសេចក្តីជំនឿរបស់ខ្ញុំរឹងមាំឡើង។ ដោយសារតែខ្ញុំមិនដឹងពីរបៀបទុកចិត្តព្រះជាម្ចាស់ ខ្ញុំបានរង់ទុក្ខនៅពេលដែលខ្ញុំត្រូវរង់ចាំ ហើយខ្ញុំជឿថាការរង់ចាំរបស់ខ្ញុំ យូរជាងការដែលខ្ញុំត្រូវរៀនទុកចិត្តព្រះអង្គ។

ជីវិតនឹងកាន់តែងាយស្រួល នៅពេលដែលយើងមានបទពិសោធន៍ជាមួយព្រះជាម្ចាស់កាន់តែច្រើន។ យើងត្រូវដឹងថាទោះបីជាព្រះអង្គមិនប្រញាប់ក៏ដោយ គឺតាមពិតទៅព្រះអង្គមិនដែលយឺតឡើយ យ៉ាងហោចណាស់គឺមិនទៅតាមកាលវិភាគរបស់ព្រះអង្គឡើយ។ ការអត់ធ្មត់មិនមែនវាស់ទៅលើសមត្ថភាពក្នុងការរង់ចាំប៉ុណ្ណោះទេ តែវាអាស្រ័យលើឥរិយាបថរបស់យើងក្នុងពេលដែលយើងរង់ចាំផងដែរ។ យើងទាំងអស់គ្នានឹងរង់ចាំរឿងជាច្រើននៅក្នុងជីវិត ប៉ុន្តែការ «រង់ចាំដោយអត់ធ្មត់» គឺជាគោលដៅដែលព្រះជាម្ចាស់មានសម្រាប់យើង។ ការរង់ចាំដោយអត់ធ្មត់ គឺមិនអាចទៅរួចទេ លុះត្រាតែយើងជឿថាចរិតលក្ខណៈរបស់ព្រះជាម្ចាស់គ្មានកំហុសទាល់តែសោះ និងជឿថាព្រះអង្គល្អ និងជឿថាព្រះអង្គប្រទានការល្អរបស់ព្រះអង្គដល់យើងក្នុងពេលដែលយើងមានជីវិតនៅឡើយ។ របស់មួយធ្វើឲ្យខ្ញុំមាន «អារម្មណ៍» មិនល្អមិនមានន័យថាវាមិនល្អនោះទេ។ ខ្ញុំប្រហែលជាអាចឃើញពីអ្វីដែលខ្ញុំគិតថាមិនល្អយូរៗទៅវាជាការល្អសម្រាប់ខ្ញុំទៅវិញ។

## *វាមិនដែលយឺតពេលទាល់តែសោះ*

ម៉ាថា និងមារីបានជូនដំណឹងទៅព្រះយេស៊ូ ឲ្យព្រះអង្គជ្រាបថា ឡាសាជាប្អូនរបស់ពួកគេមានជម្ងឺ។ ព្រះគម្ពីរបានចែងថា ព្រះយេស៊ូស្រឡាញ់ ម៉ាថា ម៉ារី និងឡាសា ហើយពួកគេជាមិត្តសំឡាញ់របស់ព្រះអង្គទៀតផង។ គម្ពីរបានបន្តទៀតថា ទោះបីជាព្រះអង្គដឹងថាឡាសាមានជម្ងឺក៏ដោយ ក៏ព្រះអង្គគង់នៅកន្លែងនោះពីរថ្ងៃទៀតមុនពេលព្រះអង្គទៅមើលគាត់(មើលគម្ពីរយ៉ូហាន១១:៣-៦)។ នៅពេលដែលព្រះយេស៊ូយាងទៅដល់ ឡាសាបានស្លាប់ និងត្រូវបានគេបញ្ចុះនៅក្នុងផ្នូរអស់រយៈពេលបួនថ្ងៃទៅហើយ។ គេអាចសួរសំណួរថា «បើព្រះយេស៊ូស្រឡាញ់គេដល់ម្ល៉េះ ហេតុអ្វីបានជាព្រះអង្គពន្យារពេលសិនមុននឹងព្រះអង្គទៅជួយពួកគេ»?

បានជាព្រះអង្គរង់ចាំ ព្រោះព្រះអង្គចង់ឲ្យស្ថានការណ៍នោះហាក់បីដូចជាអ្វីដែលមិនអាចប៉ះប៉ូវបាននៅពេលដែលព្រះអង្គទៅដល់។ នៅពេលដែលព្រះអង្គទៅដល់ទីនោះ ម៉ាថានិយាយទៅកាន់ព្រះអង្គថា «បើព្រះអង្គគង់នៅទីនេះ នោះប្អូនប្រុសរបស់នាងខ្ញុំមិនស្លាប់ទេ»(យ៉ូហាន១១:២១)។ យើងតែងតែគិត ឬនិយាយពាក្យដូចគ្នាទាក់ទងទៅនឹងកាលៈទេសៈរបស់យើងផ្ទាល់៖ «ព្រះយេស៊ូអើយ បើព្រះអង្គសព្វព្រះហឫទ័យ ព្រះអង្គអាចធ្វើកុំឲ្យរឿងនេះកើតឡើងបាន»។ តាមពិតទៅយើងបាក់ទឹកចិត្ត និងមិនយល់ពីមូលហេតុដែលព្រះជាម្ចាស់អនុញ្ញាតិឲ្យរឿងឈឺចាប់ដែលព្រះអង្គអាចបញ្ចៀសបានកើតឡើងដូចជានាងម៉ាថាដែរ។ បើអ្នកមានរឿងស្រដៀងនឹងសាច់រឿងរបស់ឡាសា នោះអ្នកនឹងដឹងថាព្រះយេស៊ូមិនបានមើលពីការពិតដែលឡាសាបានស្លាប់អស់រយៈពេលបួនថ្ងៃថាជាឧបស័គ្គដែលមិនអាចឈ្នះបានឡើយ។ តាមពិតទៅព្រះអង្គចង់ឲ្យស្ថានភាពនោះមើលទៅហាក់បីដូចជាទៅមិនរួច ដែលធ្វើឲ្យសាច់ញ្ញាតិ និងមិត្តភ័ក្តិរបស់ឡាសា ក៏ដូចជាយើងរាល់គ្នាអាចរៀនបានថាចំពោះព្រះជាម្ចាស់អ្វីទាំងអស់អាចទៅរួច ហើយអ្វីៗទាំអស់មិនដែលយឺតពេលសម្រាប់ព្រះអង្គក្នុងការធ្វើអ្វីដែលព្រះអង្គត្រូវធ្វើឡើយ។ ព្រះយេស៊ូបានប្រោសឡាសាឲ្យរស់ឡើងវិញ ហើយខ្ញុំជឿថាក្រោយពេលដែលព្រះអង្គបង្ហាញការអស្ចារ្យ គ្រប់គ្នាបានរីករាយនឹងអ្វីដែលបានកើតឡើង។ ទោះបីជាខ្ញុំផ្ទាល់មិនដែលបានឃើញនរណាម្នាក់រស់ពីស្លាប់ឡើងវិញក៏ដោយ ក៏ខ្ញុំធ្លាប់បានឃើញព្រះជាម្ចាស់បានប្រទានជីវិតដល់អ្នកដែលស្ថិតក្នុងកាលៈទេសៈ និងស្ថានភាពនៃសេចក្តីស្លាប់ដែរ។ ខ្ញុំគិតថារឿងនេះអាចជាគំរូនៃសេចក្តីពិត គឺព្រះជាម្ចាស់មិនដែលយឺតពេលក្នុងការធ្វើការអស្ចារ្យនៅក្នុងជី

វិតរបស់យើងឡើយ។

ផ្ទុយពីការចង់ឲ្យព្រះជាម្ចាស់ធ្វើតាមចិត្តរបស់យើង យើងអាចចាំថាផ្លូវរបស់ព្រះអង្គតែងតែល្អជាងផ្លូវរបស់យើងជានិច្ចបើគិតក្នុងរយៈពេលយូរ។ មានអាថ៌កំបាំងជាច្រើនដែលលាក់នៅក្នុងប្រាជ្ញារបស់ព្រះជាម្ចាស់។ យើងមិនមែនសុទ្ធតែយល់ពីអ្វីដែលបានកើតឡើងឡើយ ប៉ុន្តែយើងមានអភ័យឯកសិទ្ធិក្នុងការទុកចិត្តព្រះអង្គ ដែលធ្វើឲ្យយើងអាចទ្រាំទ្រការឈឺចាប់របស់យើងបាន។

## *ការអត់ធ្មត់គឺជាអំណាច*

ការអត់ធ្មត់ធ្វើឲ្យយើងមានអំណាចដែលនាំទៅកាន់អំណរនៅក្នុងជីវិត ខណៈពេលដែលយើងរង់ចាំអ្វីដែលយើងប្រាថ្នាចង់បាន។ ពេលវេលាភាគច្រើនក្នុងជីវិតរបស់យើង គឺចំណាយក្នុងការកើតទុក្ខឥតប្រយោជន៍លើរឿង ដែលយើងមិនអាចផ្លាស់ប្តូរបាន។ បើយើងអាចផ្លាស់ប្តូរអ្វីដែលយើងមិនសប្បាយចិត្តបាន នោះយើងគួរតែធ្វើ ប៉ុន្តែបើយើងមិនអាចធ្វើបានទេនោះយើងគួរតែទុកចិត្តព្រះជាម្ចាស់ហើយសម្រេចចិត្តថាយើងមិនកើតទុក្ខឡើយខណៈពេលដែលយើងរង់ចាំអ្វីដែលព្រះអង្គនឹងធ្វើ។ អ្វីដែលយើងខ្ជះខ្ជាយរៀងរាល់ថ្ងៃ យើងមិនអាចយកវាត្រឡប់មកវិញឡើយ ហើយមនុស្សមានប្រាជ្ញា និងអ្នកដែលប្រុងប្រយ័ត្នមិនខ្ជះខ្ជាយពេលវេលាដែលព្រះជាម្ចាស់ប្រទានដល់ពួកគេនៅលើផែនដីនេះឡើយ។ ការខកចិត្ត ការបាក់ទឹកចិត្ត និងទុក្ខលំបាកមិនដែលធ្វើឲ្យស្ថានការអាក្រក់ប្រែជាល្អឡើងវិញបានឡើយ ប៉ុន្តែវាធ្វើឲ្យមានជម្ងឺ ធ្វើឲ្យអាយុខ្លីនិងធ្វើឲ្យបាត់បង់ទំនាក់ទំនងល្អទៅវិញទេ។ លោកសាវ័ក យ៉ាកុបបាននិយាយពីមនុស្សដែលមានការអត់ធ្មត់ថា «គ្រប់លក្ខណ៍ និងពេញខ្នាត...នឹងមិនខ្វះអ្វីឡើយ»។ វ៉ាវ! ខ្ញុំពេញចិត្តពាក្យនេះណាស់ ហើយខ្ញុំគិតថាអ្នកក៏ពេញចិត្តដែរ។ នៅពេលដែលខ្ញុំអានបទគម្ពីរនេះ *ខ្ញុំតែងតែប្រាថ្នាក្នុងការគិតថា ខ្ញុំជាមនុស្សអត់ធ្មត់ហើយ ប៉ុន្តែខ្ញុំមិនទាន់អាចធ្វើបាននៅឡើយទេ*។ យ៉ាងណាក៏ដោយយើងអាចរួចពីភាពមិនចេះអត់ធ្មត់បាន។ មានវិធីមួយ វិធីនោះគឺការគិតដ៏ត្រឹមត្រូវ។

> ពេលវេលាភាគច្រើនក្នុងជីវិតរបស់យើង គឺចំណាយក្នុងការកើតទុក្ខឥតប្រយោជន៍លើរឿង ដែលយើងមិនអាចផ្លាស់ប្តូរបាន។

បើខ្ញុំគិតថាខ្ញុំត្រូវតែមានអ្វីដែលខ្ញុំចង់បានទើបខ្ញុំអាចរីករាយបាន នោះគំនិតរបស់ខ្ញុំផ្ទាល់ គឺធ្វើឲ្យខ្ញុំកើតទុក្ខទៅវិញ។ តែបើខ្ញុំប្តូរការគិតរបស់ខ្ញុំទៅជា *ខ្ញុំទុកចិត្តព្រះអង្គ ហើយខ្ញុំដឹងថាពេលវេលារបស់ព្រះអង្គគ្រប់លក្ខ័ណ ខ្ញុំនឹងចូលទៅកាន់ទីសំរាករបស់*

*ព្រះអង្គ ហើយខ្ញុំអាចរីករាយនឹងជីវិតរបស់ខ្ញុំក្នុងពេលដែលខ្ញុំរង់ចាំបាន* ដូច្នេះខ្ញុំនឹងមិនខ្វះអ្វីឡើយបើខ្ញុំគ្មានការព្រួយបារម្ភណ៍។ ទោះបីជាព្រះជាម្ចាស់នឹងធ្វើអ្វីជាមួយបញ្ហាដែលយើងកំពុងជួបប្រទះក៏ដោយក៏ព្រះអង្គមិនប្រញាប់ពេកដោយសារការមិនចេះអត់ធ្មត់របស់យើងដែរ។ មានរឿងមួយដែលច្បាស់ គឺទោះបីជាយើងត្រូវរង់ចាំឲ្យព្រះអង្គធ្វើការសម្រាប់យើងយូរយ៉ាងណា ការអត់ធ្មត់មានអំណាចធ្វើឲ្យយើងនៅតែមានអំណរជានិច្ចក្នុងពេលដែលយើងរង់ចាំ!

តែងតែមានរឿងកើតឡើងជានិច្ច ទោះបីជាយើងគិតថាគ្មានរឿងអ្វីកើតឡើងក៏ដោយ។ ចូរយើងមើលពីការលូតលាស់របស់ដើមឈើ។ យើងមិនអាចឃើញវាលូតលាស់បានឡើយ ប៉ុន្តែវាកំពុងលូតលាស់។ វាខ្ពស់ជាងមុននិងមែករបស់វាធំជាងមុន។ មនុស្សជាច្រើននិយាយថា ដើមឈើដែលលូតលាស់យឺតផ្តល់ផលផ្លែច្រើន ហើយខ្ញុំជឿថាវាក៏កើតឡើងចំពោះមនុស្សដូចគ្នា។ យើងមិនដែលឃើញមែករបស់យើងលូតលាស់ឡើយ ប៉ុន្តែឫសរបស់យើងចាក់កាន់តែជ្រៅជាងមុន។ ថ្ងៃណាមួយយើងនឹងបង្កើតផលល្អ ព្រមទាំងដឹងថាយើងបានលូតលាស់ក្នុងពេលដែលយើងរង់ចាំ។

## *បំភ្លេចវាចោល*!

បើយើងមើលអ្វីមួយជិតខ្លាំងពេក យើងមិនអាចឃើញការលូតលាស់របស់វាឡើយ តែបើយើងនៅឆ្ងាយពីវាមួយរយៈសិនរួចត្រឡប់មកវិញ នោះវានឹងធ្វើឲ្យយើងអស្ចារ្យក្នុងចិត្ត។ គ្រួសាររបស់ខ្ញុំមានទ្រព្យសម្បត្តិមួយដែលយើងត្រូវលក់ ហើយទោះបីយើងដាក់វានៅទីផ្សារអស់រយៈពេលបីឆ្នាំហើយក៏ដោយ តែគ្មានអ្វីកើតឡើងទាំងអស់។ យើងមិនត្រឹមតែមិនអាចលក់វាបានទេ ប៉ុន្តែគ្មាននរណាសូម្បីតែម្នាក់មើលវាសោះ! គ្មាននរណាម្នាក់តថ្លៃ សោះក្នុងរយៈពេលបីឆ្នាំនេះ ទោះបីជាអតិថិជនមិនល្អម្នាក់ក៏គ្មានដែរ! ខ្ញុំពិតជាមានអារម្មណ៍ខកចិត្ត ព្រោះខ្ញុំពិតជាចង់លក់វាខ្លាំណាស់។ ខ្ញុំបានអធិស្ឋានពីការនេះជាច្រើនដង ហើយខ្ញុំបានប្រកាសជំនឿរបស់ខ្ញុំថាវានឹងលក់ដាច់។ រាល់ថ្ងៃនៅពេលដែលលក់មិនទាន់ដាច់ ខ្ញុំតែងមានអារម្មណ៍ខកចិត្តពេលខ្ញុំគិតដល់រឿងនេះ។ នៅព្រឹកមួយខ្ញុំបានចាប់ផ្តើមអធិស្ឋានម្តងទៀត ពេលនោះព្រះជាម្ចាស់មានព្រះបន្ទូលមកកាន់ដួងចិត្តរបស់ខ្ញុំថា អ្នកត្រូវតែបំភ្លេចទ្រព្យសម្បត្តិដ៏តូចមួយនេះទៅ ហើយទុកឲ្យយើងថែរក្សាវាចុះ។ ខ្ញុំបានដឹងយ៉ាងច្បាស់ថា ខ្ញុំបានចំណាយពេលយ៉ាងច្រើនផ្តោតទៅលើអ្វីមួយ ហើយព្រះជាម្ចាស់ចង់ឲ្យខ្ញុំយកវាចេញពីគំនិតរបស់ខ្ញុំនិងគ្រាន់តែទុកចិត្តថាព្រះអង្គកំពុងធ្វើការ។

គ្រប់ពេលដែលខ្ញុំគិតពីការលក់ទ្រព្យនេះ ខ្ញុំបានគិតថាព្រះជាម្ចាស់ជាអ្នកធ្វើការនេះ! ចុងក្រោយបំផុតខ្ញុំបានសម្រាកក្នុងព្រះអង្គទាក់ទងនឹងរឿងនេះ ហើយពីរសប្តាហ៍ក្រោយមកទ្រព្យនោះក៏បានលក់ដាច់! ខ្ញុំចង់និយាយថាខ្ញុំបានអត់ធ្មត់ក្នុងពេលដែលខ្ញុំរង់ចាំអស់រយៈពេលបីឆ្នាំនេះ ប៉ុន្តែការពិត គឺខ្ញុំមិនបានអត់ធ្មត់ទេ ហើយការមិនអត់ធ្មត់របស់ខ្ញុំអាចបណ្តាលមកពីការរង់ចាំយូរពេក ។ យើងតែងតែគិតថាយើងរង់ចាំព្រះជាម្ចាស់ ប៉ុន្តែតាមពិតទៅ គឺព្រះអង្គទេដែលរង់ចាំយើង!

យើងតែងតែគិតថាយើងរង់ចាំព្រះជាម្ចាស់ ប៉ុន្តែតាមពិតទៅ គឺព្រះអង្គទេដែលរង់ចាំយើង!

ការភ័យខ្លាច មិនបានអ្វីដូចដែលយើងចង់បាន ជាមូលហេតុមួយនៃការមិនចេះអត់ធ្មត់របស់យើង ប៉ុន្តែខ្ញុំចង់និយាយម្តងទៀតថាយើងអាចប្តូរការគិតរបស់យើងបាន ហើយវានឹងជួយយើងយ៉ាងធំធេង។ ជំនួសឲ្យការគិតថាគ្មានអ្វីនឹងកើតឡើងឡើយ យើងអាចគិតយ៉ាងដូច្នេះវិញថា ខ្ញុំមិនបានឃើញអ្វីកើតឡើងទេ ប៉ុន្តែខ្ញុំជឿថាព្រះជាម្ចាស់កំពុងតែធ្វើការ!

ព្រះជាម្ចាស់ទ្រង់ជ្រាបអ្វីៗទាំងអស់ដែលបានកើតឡើងពីអតីតកាល អ្វីដែលកើតឡើងឥឡូវនេះ និងអ្វីដែលនឹងកើតឡើងនៅថ្ងៃអនាគត ព្រះអង្គកំពុងគ្រប់គ្រង់ការនេះ។ ព្រះអង្គមិនអន្ទះសារ ឬមិនចេះអត់ធ្មត់ឡើយ។ ការមិនចេះអត់ធ្មត់របស់យើងបណ្តាលមកពីការពិតថាយើងមិនដឹងពីរបៀប ឬពេលណាដែលយើងនឹងបានទទួលចម្លើយ។ ព័ត៌មានកាន់តែតិច នឹងធ្វើឲ្យយើងកាន់តែងាយក្នុងការមិនចេះអត់ធ្មត់ក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ ប៉ុន្តែព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងបទពិសោធន៍ជាមួយព្រះអង្គ បានប្រាប់យើងថាពេលវេលារបស់ព្រះអង្គល្អឥតខ្ចោះ ហើយការរង់ចាំដែលយើងពិតជាមិនចូលចិត្ត តាមពិតទៅគឺកំពុងធ្វើការល្អនៅក្នុងយើង។

យើងបានអានសាច់រឿងនៅក្នុងព្រះគម្ពីរ គឺសាច់រឿងអស់អ្នកដែលយើងចាត់ទុកថាជាបុរស និងស្ត្រីដ៏អស្ចារ្យរបស់ព្រះជាម្ចាស់ ហើយយើងរាល់គ្នាបានប្រាថ្នាយ៉ាងសំងាត់ថាទីបន្ទាល់របស់ពួកគេអាចជារបស់យើងដែរ។ យ៉ាងហោចណាស់យើងចង់ឲ្យគេសរសើរយើងដូចជាពួកគេដែរ ទោះជាយ៉ាងណាក៏ដោយយើងប្រហែលជាមិនប្រាថ្នាចង់មានបទពិសោធរបស់ពួកគេឡើយ។ តាមពិតទៅពួកគេអស្ចារ្យ ប៉ុន្តែសូមឲ្យខ្ញុំរំឮកអ្នកថាពួកគេសុទ្ធតែធ្លាប់ស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់។ លោក ម៉ូសេ រង់ចាំអស់រយៈពេល៤០ឆ្នាំនៅក្នុងវាលរហោស្ថាន។ ដាវីឌរង់ចាំអស់រយៈពេល២០ឆ្នាំ ដើម្បីក្លាយជាស្តេច ហើយគាត់ត្រូវលាក់ខ្លួននៅក្នុងរូងភ្នំអស់១៥ឆ្នាំ ដើម្បី

គេចពីការតាមសំលាប់របស់ស្តេច សូល។ លោកយ៉ូសែបរង់ចាំអស់រយៈពេល១៣ឆ្នាំ ដើម្បីមានសេរីភាពហើយគាត់ចំណាយ១០ឆ្នាំនៅក្នុងគុក។ លោកអ័ប្រាហាំរង់ចាំអស់រយៈពេល២០ឆ្នាំមុនពេលលោកមានកូន ដែលព្រះជាម្ចាស់បានសន្យាជាមួយគាត់។ បើអ្នកនិងខ្ញុំស្ថិតនៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ នៅថ្ងៃណាមួយយើងនឹងអាចមានទីបន្ទាល់ដ៏អស្ចារ្យដែលនឹងមានអ្នកអាននិងកើតសរសើរមិនខាន។

# ជំពូក ១៦

## នៅក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់
## (ផ្នែកទី ២)

*ចូររង់ចាំព្រះយេហូវ៉ាចុះ ចូរមានកំឡាំង ហើយឲ្យចិត្តក្លាហានឡើង អើ គួររង់ចាំព្រះយេហូវ៉ាទៅ។*

*ទំនុកតម្កើង ២៧:១៤*

វាជារឿងស្មុគស្មាញខ្លាំងណាស់សម្រាប់មនុស្សក្នុងការយល់ថាតើតាមពិតទៅការរង់ចាំព្រះជាម្ចាស់មានន័យដូចម្ដេច។ យើងអាចឃើញថាការរង់ចាំគឺជាការអសកម្ម មានពេលវេលាដែលគ្មានសកម្មភាព នៅពេលដែលជីវិតរបស់យើងនៅទ្រឹង។ មនុស្សយើងភាគច្រើនមានពេលវេលាដែលលំបាក ដែលយើងមិនធ្វើអ្វីទាំងអស់ ហើយបើយើងរង់ចាំព្រះជាម្ចាស់ដោយរបៀបមិនត្រឹមត្រូវ នោះយើងនឹងឃើញថាការយល់ច្រឡំរបស់យើងធ្វើឲ្យយើងពិការមិនខាននៅពេលដែលវាពិតជាកើតឡើងមែន។

ការសិក្សាស៊ីជម្រៅលើភាសាដើមដែលយើងបានទទួលអត្ថន័យនៃពាក្យ «រង់ចាំ» ពីការបើកសំដែងថាការរង់ចាំព្រះជាម្ចាស់ គឺត្រូវតែសកម្មខាងវិញ្ញាណមែនទែន។ ទោះបីជាព្រះជាម្ចាស់សុំឲ្យ យើងនៅស្ងៀមនៅពេលដែលយើងព្យាយាមផ្លាស់ប្ដូរស្ថានភាពដែលយើងជួបប្រទះក៏ដោយ ក៏ព្រះអង្គមិនបានឲ្យយើងមិនធ្វើអ្វីទាំងអស់ឡើយ។ព្រះអង្គចង់ឲ្យយើងមានឥរិយាបថរង់ចាំដោយមានក្ដីរំពឹងទាក់ទងនឹងអ្វីដែលព្រះជាម្ចាស់កំពុងធ្វើ ហើយព្រះអង្គចង់ឲ្យយើងមានពេញដោយក្ដីសង្ឃឹម និងរំពឹងថាព្រះអង្គនឹងធ្វើការយ៉ាងអស្ចារ្យនៅក្នុងជីវិតរបស់យើង។ ព្រះអង្គចង់ឲ្យយើងអរព្រះគុណព្រះអង្គសម្រាប់អ្វីដែលព្រះអង្គកំពុងធ្វើ ទោះបីជាយើងមិនទាន់បានឃើញវាដោយភ្នែករបស់យើងផ្ទាល់ក៏ដោយ។

គំនិត និងឥរិយាបថរបស់យើងអាចធ្វើឲ្យយើងនៅតែមានអំណរយ៉ាងខ្លាំង នៅពេលដែលយើងស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ បើយើងចាត់ចែងវាបានត្រឹមត្រូវ។ ចូរមើលគំនិតពីរប្រភេទនេះ ហើយមើលថាតើអ្នកនឹងជឿលើគំនិតមួយណា

ដែលនឹងអាចបង្កើតអំណរបាន៖

មានគំនិតប្រភេទនេះ៖

- ខ្ញុំបានចាំអស់រយៈពេលយ៉ាងយូរ ខ្ញុំគិតថាខ្ញុំមិនអាចរង់ចាំបានទៀតទេ។
- គ្មានអ្វីកើតឡើងទាំងអស់!
- ខ្ញុំមានអារម្មណ៍ដូចជាព្រះបានភ្លេចខ្ញុំទាំងស្រុងហើយ។
- ខ្ញុំក្លាចថាគ្មានចម្លើយចំពោះបញ្ហារបស់ខ្ញុំ។
- ខ្ញុំប្រហែលជាអាចបោះបង់ចោល។

ហើយក៏មានប្រភេទគំនិតទាំងនេះដែរថា៖

- ខ្ញុំមានអំណរមែនទែនដែលឃើញអ្វីដែលព្រះជាម្ចាស់នឹងធ្វើ។
- ខ្ញុំជឿថាព្រះជាម្ចាស់កំពុងធ្វើការទោះបីជាខ្ញុំមិនទាន់ឃើញមានអ្វីផ្លាស់ប្តូរនៅឡើយក្តី។
- ព្រះអង្គស្រឡាញ់ខ្ញុំ និងខ្ញុំដឹងថាព្រះអង្គនឹងជួយដោះស្រាយបញ្ហារបស់ខ្ញុំ។
- គម្ពីរទំនុកតម្កើងជំពូក១៣៩ បានចែងថាព្រះជាម្ចាស់បានគិតពីខ្ញុំគ្រប់ពេលវេលា ដូច្នេះខ្ញុំដឹងថាព្រះអង្គមិនបំភ្លេចខ្ញុំចោលឡើយ។
- ខ្ញុំនឹងមិនរស់នៅភ័យក្លាចទេ ហើយខ្ញុំនឹងមិនបោះបង់ចោលឡើយ!

វាពិតជាមានសារៈសំខាន់ណាស់ ដែលយើងត្រូវជ្រើសរើសយកគំនិតណាមួយដើម្បីឲ្យមានអំណរបំផុត។ មានករណីមួយគឺថា តើហេតុអ្វីបានជាយើងត្រូវមានគំនិតឬឥរិយាបថអវិជ្ជាមាន? គំនិតខាងសាច់ឈាមដែលលោក ប៉ូលបាននិយាយនៅក្នុងគម្ពីររ៉ូម៨:៦ " *ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្តីស្លាប់ទេ ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត និងសេចក្តីសុខសាន្តវិញ"។* ផ្អែកទៅលើហេតុផល និងការពិតដែលនាំទៅរកអំពើបាប ទោះជាយ៉ាងណាក៏ដោយ បើយើងធ្វើតាម នោះយើងគ្មានជម្រើសឡើយ តែយើងត្រូវតែសម្រេចចិត្តផ្អែកលើអ្វីដែលបានកើតឡើងក្នុងស្ថានភាពរបស់យើង។ តែបើយើងគិតដោយគំនិតខាងវិញ្ញាណរបស់យើង ដែលបានចែងនៅក្នុងខគម្ពីរខាងលើនេះ យើងនឹងទទួលបានជីវិត និងសន្តិភាពនៅក្នុងព្រលឹងរបស់យើងមិនខាន។ ជាមួយគំនិតខាវិញ្ញាណ យើងអាចគិតដូចព្រះជាម្ចាស់ ហើយគំនិតរបស់យើងនឹងពេញដោយក្តីសង្ឃឹមទោះបីជាមានរឿងអ្វីកើតឡើងក៏ដោយ។

## តើយើងស្វែងរកអ្វី?

យើងអាចគិតជាមួយគំនិតខាងសាច់ឈាម ឬមួយគំនិតខាងវិញ្ញាណ ហើយជម្រើសជារបស់យើង។ ជាអកុសលមនុស្សជាច្រើនរស់នៅពេញមួយជីវិត ពួកគេគំរគិតពីអ្វីដែលចូលទៅក្នុងគំនិតរបស់ពួកគេណាស់ ពួកគេមិនដែលបានដឹងថាសាតាំដែលជាសត្រូវរបស់ពួកគេជាប្រភពនៃគំនិតអវិជ្ជមាន ការអស់សង្ឃឹម ភាពភ័យក្លាច និងគំនិតពេញដោយចម្ងល់ឡើយ។ ពួកគេមិនដែលបានដឹងថា ពួកគេអាចគិតដោយខ្លួនឯងបើគេជ្រើសរើសបោះបង់ចោលគំនិត ខុសឆ្គងដែលមិនស្របតាមព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងដាក់មកវិញនូវអ្វីដែលស្របតាមព្រះបន្ទូល។

នៅក្នុងគម្ពីរ ២កូរិនថូស ជំពូក៤ លោកប៉ុលបានរៀបរាប់ពីពេលមួយដែលលោក និង អ្នកជឿផ្សេងទៀតក្នុងព្រះគ្រីស្ទមានបទពិសោធជាមួយនឹងកាលៈទេសៈដ៏លំបាក។ លោកបាននិយាយថាៈ

> *ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ។*
>
> ២កូរិនថូល ៤:១៨

ទាំងលោក ប៉ូល និងមនុស្សដែលដើរជាមួយលោកបានជួបស្ថានភាពដ៏អាក្រក់ ហើយខ្ញុំដឹងយ៉ាងច្បាស់ថាពួកគេបានឃើញបញ្ហាទាំងអស់នោះ ប៉ុន្តែពួកគេក៏សម្លឹងមើលអ្វីផ្សេងទៀតដែរ។ ពួកគេបានឃើញព្រះយេស៊ូ និង ព្រះបន្ទូលសន្យានៃការប្រោសលោះ និងជ័យជំនះរបស់ព្រះអង្គ។ ពួកគេមិនត្រឹមតែមើលនឹងភ្នែកខាងសាច់ឈាមនោះទេ ប៉ុន្តែពួកគេមើលនឹងភ្នែកខាងវិញ្ញាណដែរ។ ពួកគេប្រើដួងចិត្តរបស់ពួកគេមើល អ្វីដែលពួកគេមើលមិនឃើញដោយភ្នែកទទេ ទោះជាយ៉ាងណាក្តីពួកគេជឿថាអ្វីកើតឡើង គឺពិតប្រាកដ។

យើងជឿលើព្រះជាម្ចាស់ទោះបីជាយើងមិនអាចឃើញព្រះអង្គនឹងភ្នែកក៏ដោយ។ យើងជឿថាមានទេវតា យើងជឿថាមានទំនាញផែនដី ហើយជឿថាមានពពក ទោះបីជាយើងមើលមិនឃើញវាក៏ដោយ យើងជឿថាព្រះអាទិត្យនៅទីកន្លែងរបស់វា។ មានរបស់ជាច្រើនដែលយើងពិតជាជឿថាមានមែន ទោះបីជាយើងមើលមិនឃើញក៏ដោយ ដូច្នេះតើហេតុអ្វីបានជាយើងមិនជឿថាព្រះជាម្ចាស់កំពុងធ្វើការនៅពេលដែល

យើងរង់ចាំ ទោះបីជាយើងមិនឃើញភស្តុតាងនៅឡើយក្តី។ ជាធម្មតាយើងមិនបាន លុតជំខ្លួនក្នុងការធ្វើបែបនេះទេ ប៉ុន្តែយើងអាចផ្លាស់ប្តូរបាន។

ជីវិតពិតរបស់យើងគឺនៅជាមួយយើង។អ្វីដែលកំពុងមាននៅក្នុងយើង(ទាំងគំនិត និងឥរិយាបថរបស់យើង) គឺសំខាន់ជាងស្ថានភាពរបស់យើងទៅទៀត។ មិនថាស្ថាន ភាពនៅជុំវិញយើងលំបាកប៉ុណ្ណាទេ បើយើងនៅតែមានឥរិយាបថល្អ ហើយនៅតែ មានគំនិតវិជ្ជមានដែលផ្អែកលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងនឹងអាចមានបទ ពិសោធន៍ជាមួយសន្តិភាពនិងអំណរមិនខាន។ ខ្ញុំជឿថាមនុស្សជាប់ពន្ធនាគារដែល រៀនក្នុងការគិតវិជ្ជមាន និងមានឥរិយាបថល្អអាចមានសេរីភាពជាងមនុស្សដែលរស់ នៅក្នុងសង្គមខាងក្រៅប៉ុន្តែគាត់ពេញទៅដោយសំអប់ ភាពល្វីងជូរចត់ និងឥរិយា បថអវិជ្ជមាន។ មនុស្សអាចលើកកំពស់គុណភាពនៃជីវិតរបស់ខ្លួនបានភ្លាមៗដោយ គ្រាន់តែគិតទៅលើអ្វីដែលល្អ និងថែរក្សាឥរិយាបថនៃក្តីសង្ឃឹម។

យើងអាចមានស្ថានភាពល្អ មានលុយច្រើន មានការងារល្អ និងមានគ្រួសារល្អ តែ នៅតែមានជីវិតដ៏សែនវេទនា បើសិនជាយើងមិនចេះអរគុណ កំណាញ់ និងប្រហែល ជាខឹងនឹងអស់អ្នកដែលធ្វើទុក្ខយើង។ ប៉ុន្តែយើងក៏អាចមានស្ថានភាពលំបាក រស់នៅ តែម្នាក់ឯង និងខ្វះខាតលុយកាក់ តែនៅតែមានសន្តិភាព និងអំណរបើយើងចេះ អគុណ និងចំណាយពេលរបស់យើងព្យាយាមធ្វើជាព្រះពរដល់អ្នកដទៃ។

ឥរិយាបថ និងការគិត គឺជារបស់អ្នកហើយ គ្មាននរណាម្នាក់ធ្វើឲ្យអ្នកមានគំនិតអាក្រក់ បានឡើយ បើអ្នកមិនចង់គិតអាក្រក់!

ឥរិយាបថនិងការគិតគឺជារបស់អ្នក ហើយ គ្មាននរណាម្នាក់ធ្វើឲ្យអ្នកមានគំ និតអាក្រក់បានឡើយ បើអ្នកមិនចង់គិត អាក្រក់!

គ្មានភ័ស្តុតាងនៅក្នុងគម្ពីរដែលថា លោកយ៉ូសែប មានអ្វីផ្សេងក្រៅពីសេចក្តី សង្ឃឹម និងឥរិយាបថល្អក្នុងពេលដែលគាត់ត្រូវរង់ចាំព្រះជាម្ចាស់អស់រយៈពេល១៣ ឆ្នាំ ដើម្បីឲ្យព្រះជាម្ចាស់សង្គ្រោះគាត់ឡើយ។ គាត់មានសុបិនសម្រាប់ជីវិតរបស់គាត់ ហើយគាត់មិនបោះបង់ចោលឡើយ ទោះបីជាកាលៈទេសៈរបស់គាត់ហាក់បីដូចជាវា មិនអាចក្លាយជាការពិតក៏ដោយ។ (អ្នកអាចអានសាច់រឿងរបស់លោក យ៉ូសែបនៅ ក្នុងគម្ពីរ លោកុប្បត្តិ ៣៧-៥០)។

លោក អ័ប្រាហាំរង់ចាំអស់រយៈពេល២០ឆ្នាំ ដើម្បីឲ្យព្រះបន្ទូលសន្យាដែលព្រះ ជាម្ចាស់ប្រទានដល់គាត់បានសម្រេចជារូបរាងឡើង ដែលថាគាត់នឹងមានកូនមួយ។ រយៈពេល២០ឆ្នាំពិតជាយូរណាស់ក្នុងការស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់។

ខ្ញុំគិតថាគាត់មានឱកាស ក្នុងការបោះបង់ចោលច្រើនណាស់ ប៉ុន្តែគាត់បានរក

ឃើញនៅក្នុងព្រះគម្ពីរថា ទោះបីជាគាត់គ្មានមូលហេតុនឹងសង្ឃឹមក៏ដោយ គាត់នឹងសង្ឃឹមដោយជំនឿថាក្តីសុបិនរបស់គាត់នឹងក្លាយជាការពិត ហើយគាត់នឹងបានឃើញព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់សម្រេចរូបរាងឡើង។ ទោះបីជានៅពេលដែលគាត់រំពឹងទុក(មើល ហើយគិតអំពី) អសមត្ថភាពនៃរូបកាយរបស់គាត់ផ្ទាល់ និងការដែលផ្ទៃរបស់សារ៉ាមិនអាចមានកូនក៏ដោយ ក៏មិនមានការគ្មានជំនឿ ឬការមិនទុកចិត្តធ្វើឲ្យគាត់ព្រួយបារម្ភអំពីព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់ឡើយ។ គាត់បានរឹងមាំឡើងតាមរយៈការសរសើរតម្កើង និងផ្តល់សិរីរុងរឿងដល់ព្រះជាម្ចាស់។ ការសរសើរតម្កើង ជារឿងនិទាន ឬជាដំណាលអំពីការល្អរបស់ព្រះជាម្ចាស់ ដូច្នេះហើយលោក អ័ប្រាហាំច្បាស់ជាបានគិតអំពីរឿងផ្សេងៗដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់គាត់។ ការថ្វាយសិរីល្អ គឺជាការបង្ហាញពីភាពល្អឥតខ្ចោះរបស់ព្រះជាម្ចាស់ ដូច្នេះហើយអ័ប្រាហាំពិតជាសញ្ជឹង និងរិះគិតគ្រប់ទាំងការអស្ចារ្យដែលព្រះជាម្ចាស់បានធ្វើក្នុងអតីតកាល។ ជម្រើសរបស់គាត់ គឺចង់ចាំ និងគិតលើការល្អដែលបានធ្វើឲ្យគាត់រឹងមាំនៅពេលដែលគាត់ស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ (មើលនៅក្នុងគម្ពីរ រ៉ូម ៤:១៨-២១)។

នៅក្នុងជីវិតរបស់អ្នក តើឥឡូវនេះអ្នកស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ដែរឬទេ? តើអ្នកធ្លាប់ស្ថិតក្នុងស្ថានភាពនោះក្នុងរយៈពេលយ៉ាងយូរដែរឬទេ? តើវាពិតជាយូរជាងអ្វីដែលអ្នកបានរំពឹងទុកមែនទេ? តើអ្នករង់ចាំបានល្អប៉ុណ្ណា? តើអ្នកគិតអ្វីហើយតើអ្នកមានឥរិយាបថបែបណា? ខ្ញុំសុំឲ្យអ្នកជ្រើសរើសគំនិត និងឥរិយាបថដែលអាចឲ្យអ្នករង់ចាំបានយ៉ាងអត់ធ្មត់ចំពោះព្រះជាម្ចាស់ដែលអាចធ្វើរឿងផ្សេងៗយ៉ាងល្អបំផុត។

## *ការរង់ចាំជាមួយក្តីសង្ឃឹម*

អរគុណព្រះអង្គ ដែលសេចក្តីសង្ឃឹមមិនមែនជាអ្វីដែលយើងរង់ចាំបង្កើតអារម្មណ៍ដើម្បីឲ្យមានក្តីសង្ឃឹមឡើយ។ វាគឺជាអ្វីដែលយើងអាចសម្រេចចិត្តឲ្យមានក្តីសង្ឃឹមនោះ មិនថាយើងមានស្ថានភាពលំបាកខ្លាំងប៉ុណ្ណាឡើយ។ ព្រះជាម្ចាស់បានសន្យាថាបើយើងសុខចិត្តជាប់នៅក្នុងសេចក្តីសង្ឃឹម នោះព្រះអង្គនឹងស្តារព្រះពរដែលយើងមានពីមុនធ្វើពីរដងដល់យើង។ (សូមមើលនៅក្នុងគម្ពីរ សាការី ៩:១២)។ យើងអាចនិយាយម្យ៉ាងទៀតថា បើអ្នកមានបំណងនៅជាប់ជាមួយក្តីសង្ឃឹម ដើម្បីចង្អុលបង្ហាញពីកន្លែងដែលអ្នកមានពេញដោយក្តីសង្ឃឹម ទាំងទោះបីជាមានរឿងអ្វីកើត

ឡើងក៏ដោយក៏អ្នកនឹងមិនអស់សង្ឃឹមមែន នោះព្រះជាម្ចាស់នឹងស្តារអ្វីដែលអ្នកបានបាត់បង់នៅក្នុងជីវិតរបស់អ្នកឡើយវិញ ហើយផ្តល់ព្រះពរទ្វេដងដល់អ្នកមិនខាន។

សេចក្តីសង្ឃឹមមិនគ្រាន់តែជាការប្រាថ្នាឲ្យអ្វីៗបានប្រសើរឡើងឡើយ តែវាជាកំលាំងជំរុញដែលបង្កើតជាច្រកចេញនៅពេលយើងព្យាយាមរក្សាក្តីសង្ឃឹមនោះបាន។ នៅពេលដែលយើងកំពុងរង់ចាំនៅឡើយ រឿងមួយក្នុងចំណោមរឿងដែលអាចជួយយើងឲ្យនៅតែមានជំនឿរឹងមាំ និងពេញដោយក្តីសង្ឃឹម គឺការព្យាយាមសិក្សា និងសញ្ជឹងគិតលើព្រះបន្ទូលរបស់ព្រះជាម្ចាស់(សេចក្តីសន្យារបស់ព្រះអង្គ)។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់មានអំណាច ដែលអាចលើកទឹកចិត្ត និងផ្តល់កំលាំងដល់អស់អ្នកដែលដាក់សេចក្តីសង្ឃឹមលើព្រះអង្គ។

គម្ពីរទំនុកតម្កើងរបស់ដាវីឌ ជាក្មេងម្នាក់ដែលបានរង់ចាំព្រះជាម្ចាស់អស់២០ឆ្នាំដើម្បីបានឃើញព្រះបន្ទូលសន្យារបស់ព្រះលេចរូបរាងឡើងលោកបាននិយាយថា៖

*ទូលបង្គំរង់ចាំព្រះយេហូវ៉ា គឺព្រលឹងទូលបង្គំរង់ចាំទ្រង់ ទូលបង្គំសង្ឃឹមដល់ព្រះបន្ទូលនៃទ្រង់។*

ទំនុកតម្កើង១៣០:៥

សេចក្តីសង្ឃឹមត្រូវការគ្រឹះ។ ត្រូវតែមានមូលហេតុដែលត្រូវសង្ឃឹម ហើយដាវីឌបាននិយាយថាមូលហេតុរបស់គាត់ គឺព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ដាវីឌគ្រាន់តែដាក់ការទុកចិត្តរបស់គាត់នៅក្នុងសេចក្តីស្មោះត្រង់របស់ព្រះជាម្ចាស់ដើម្បីឲ្យព្រះអង្គសម្រេចតាមព្រះបន្ទូលសន្យារបស់ទ្រង់។

ហេតុអ្វីបានជាការសិក្សានិងការសញ្ជឹងគិតលើព្រះបន្ទូលរបស់ព្រះជាម្ចាស់មានក្តីសង្ឃឹមម្ល៉េះ? វាគឺជាគ្រាប់ពូជ ហើយគ្រាប់ពូជតែងតែបង្កើតផល។ នៅពេលដែលព្រះបន្ទូលត្រូវបានសាបព្រោះនៅក្នុងដួងចិត្តដែលមានដីល្អ (ដីផុស និងមិនរឹង) វាគ្មានអ្វីផ្សេងក្រៅពីបង្កើតផលឡើយ។ យើងឃើញមូលដ្ឋានគ្រឹះនេះតាមរយៈព្រះបន្ទូលរបស់ព្រះជាម្ចាស់ ប៉ុន្តែនៅក្នុងគម្ពីរម៉ាកុសជំពូក៤ ផ្តល់ការបើកសំដែងដល់យើងអំពីការទុកចិត្តនេះ។ ការនិយាយអំពីគ្រាប់ពូជ គឺមានដូចខាងក្រោម៖

*ឯពួកអ្នកដែលទទួលពូជក្នុងដីល្អ គឺអស់អ្នកដែលបានឮព្រះបន្ទូល ហើយទទួល រួចបង្កើតផល ម្នាក់បាន៣០ ម្នាក់បាន៦០ ម្នាក់ទៀតបាន១រយ។*

ម៉ាកុស៤:២០

ខ្ញុំពិតជាសុំអ្នកឲ្យអាន សិក្សា ស្តាប់ និងសញ្ជឹងគិតលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ឲ្យបានច្រើនដែលអាចធ្វើទៅបាន ហើយត្រូវធ្វើដោយចិត្តជឿ ដូចជាដីផុស (សុភាព និងចិត្តល្អ)។ លោក យ៉ាកុបបានប្រាប់យើងថាព្រះបន្ទូល «បានដុះ និងចាក់ឫសនៅក្នុងដួងចិត្តរបស់យើង វាមានអំណាចសង្គ្រោះព្រលឹងរបស់យើង (សូមមើលក្នុងគម្ពីរ យ៉ាកុប១:២១)។ ព្រះបន្ទូលបំផ្លាស់បំប្រែយើង ហើយអាចឲ្យយើងក្លាយទៅជាអ្វីដែលព្រះចង់ឲ្យយើងក្លាយទៅជា និងធ្វើអ្វីដែលព្រះអង្គចង់ឲ្យយើងធ្វើ។ នៅពេលដែលយើងស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះអង្គ នោះព្រះអង្គមិនចង់ឲ្យយើងបោះបង់ចោលឡើយ ហើយព្រះបន្ទូលរបស់ព្រះអង្គនឹងផ្តល់អំណាច ដើម្បីឲ្យយើងអាចឈររឹងមាំរហូតដល់ពេលវេលាដែលព្រះអង្គកំណត់មកដល់សម្រាប់ជាច្រកចេញដល់យើង។

សូមដាក់សេចក្តីសង្ឃឹមរបស់អ្នកនៅក្នុងព្រះអង្គ និងនៅក្នុងព្រះបន្ទូលរបស់ព្រះអង្គ! ចូររំពឹងថានឹងបានឮដំណឹងល្អនៅខណៈពេលណាមួយ! នៅពេលដែលយើងរស់នៅក្នុងសេចក្តីសង្ឃឹម យើងនឹងអាចឃើញដំណោះស្រាយសម្រាប់បញ្ហាទាំងឡាយរបស់យើង ហើយយើងអាចរីករាយជាមួយនឹងដំណើរជីវិតរបស់យើងបាន។

## *ត្រូវតែស្តាប់បង្គាប់នៅពេលដែលអ្នករង់ចាំ*

*ចូររង់ចាំព្រះយេហូវ៉ា ហើយកាន់តាមផ្លូវទ្រង់ចុះនោះទ្រង់នឹងដំកើងអ្នក ឲ្យបានផែនដីជាមរដកនៅគ្រាដែលមនុស្សអាក្រក់ត្រូវកាត់ចេញនោះអ្នកនឹងបានឃើញហើយ។*

ទំនុកតម្កើត ៣៧:៣៤

ការរង់ចាំ ជាមួយក្តីសង្ឃឹម ជាចំណុចជោគជ័យក្នុងការឃើញជ័យជំនះក្នុងជីវិតរបស់យើង ប៉ុន្តែការរង់ចាំ និងការរក្សាផ្លូវរបស់ព្រះអង្គ គឺជាចំណុចមួយទៀតដែលយើងត្រូវតែគិត។ ខ្ញុំសង្ឃឹមថាយើងទាំងអស់គ្នាបានដឹងពីសារៈសំខាន់នៃការស្តាប់បង្គាប់ ប៉ុន្តែយើងក៏គួរដឹងដែរថាបើវាអាចមានការលំបាកខ្លាំង ក្នុងពេលវេលាល្អ នោះវានឹងរឹតតែលំបាកខ្លាំងជាងនេះទៀត នៅពេលដែលយើងស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ គឺស្ថានភាពលំបាកដែលមានជាបន្តបន្ទាប់ ហើយយើងមិនឃើញមានអ្វីផ្លាស់ប្តូរអស់រយៈពេលយូរ។ ក្នុងអំឡុងពេលនោះ យើងមិនមានអារម្មណ៍ថាយើងធ្វើការត្រឹមត្រូវឡើយ ដូចជាការមានចិត្តសប្បុរស និងស្រឡាញ់អ្នកដទៃ ឬការបម្រើ និងការថ្វាយជាដើម។

ការបង្ហាញផលផ្លែខាងវិញ្ញាណ គឺមានការលំបាកយ៉ាងខ្លាំងនៅពេលដែលយើងមានការថប់បារម្ភនិងសំពាធនៅក្នុងជីវិតរបស់យើង។ វាអាចលំបាកទាំងការអធិស្ឋាន និងការសិក្សាព្រះបន្ទូលរបស់ព្រះជាម្ចាស់ ទោះជាយ៉ាងណាក៏ដោយការទាំងនេះសំខាន់បំផុត។ ការធ្វើការត្រឹមត្រូវនៅពេលដែលការត្រឹមត្រូវមិនកើតមានដល់យើងគឺអាចជារឿងដែលអស្ចារ្យបំផុតដែលយើងអាចធ្វើបាន។ លោកប៉ូលបានប្រាប់យើងថាកុំឲ្យណាយចិត្តក្នុងការធ្វើការត្រឹមត្រូវឡើយ ដល់ថ្ងៃកំណត់យើងនឹងច្រូតបានមិនខានបើយើងមិនជំពប់ដួល(មើលក្នុងគម្ពីរ កាឡាទី៦:៩)។ ខ្ញុំចង់ចំណាយពេល លើកទឹកចិត្តអ្នកឲ្យរក្សាធ្វើរឿងដែល ត្រឹមត្រូវក្នុងពេលដែលយើងស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់! ធ្វើរឿងត្រឹមត្រូវដោយសារអ្នកស្រឡាញ់ព្រះអង្គ និងដោយសារអ្នកកោតសរសើរនូវអ្វីដែល ព្រះអង្គបានធ្វើ ហើយព្រះអង្គក៏កំពុងតែធ្វើសម្រាប់អ្នកឥឡូវនេះដែរ។

> ការធ្វើការត្រឹមត្រូវនៅពេលដែលការត្រឹមត្រូវមិនកើតមានដល់យើង គឺអាចជារឿងដែលអស្ចារ្យបំផុតដែលយើងអាចធ្វើបាន។

ព្រះអង្គចង់ឲ្យយើងដើរដោយជំនឿ ហើយការដើរដោយជំនឿមានន័យថាយើងមិនដើរដោយការមើលឃើញ ឬដោយសារអារម្មណ៍របស់យើងឡើយ តែដោយសារយើងដឹងថាវាត្រឹមត្រូវ។ ការធ្វើការត្រឹមត្រូវ គឺដោយសារការត្រឹមត្រូវ គឺជាអ្វីដែលអស្ចារ្យ។ វាបានប្រកាសយ៉ាងច្បាស់ថា យើងទុកចិត្តព្រះជាម្ចាស់ ហើយយើងផ្តូរផ្តាច់ក្នុងការគោរពព្រះអង្គជាមួយសកម្មភាពរបស់យើង ទោះបីជាយើងមានស្ថានភាពយ៉ាងណាក៏ដោយ។

នៅពេលដែលយើងមិនប្រែប្រួល និងនៅនឹងមួយកន្លែង ហើយជាប់ជាមួយកិច្ចការរបស់ព្រះជាម្ចាស់ យើងនឹងបានទទួលការសន្យាថាកិច្ចការរបស់យើងមិនខូចបង់ឡើយ (មើលក្នុងគម្ពីរ ១កូរិនថូស១៥:៥៨)។ ព្រះជាម្ចាស់តែងតែឃើញភាពស្មោះត្រង់ ទោះបីជាគ្មាននរណាស្មោះត្រង់ក៏ដោយ។ ហើយអស់អ្នកដែលមិនប្រែប្រួលនៅពេលល្បងលនឹងទទួលមកុដជ័យជំនះនៃជីវិត (មើលក្នុងគម្ពីរយ៉ាកុប១:១២)។

ចូរឲ្យយើងទុកចិត្តព្រះជាម្ចាស់ និងសម្លឹងទៅរង្វាន់របស់យើង ទោះបីជាយើងកំពុងស្ថិតក្នុងបន្ទប់រង់ចាំរបស់ព្រះជាម្ចាស់ក៏ដោយ។ចូរយើងរំពឹងរឿងល្អដែលនឹងកើតឡើងដល់យើងនិងចូរឲ្យយើងមានអំណរនៅក្នុងសេចក្តីសង្ឃឹមដែលគ្មានអ្វីដែលព្រះជាម្ចាស់ធ្វើមិនកើតឡើយ!

# ជំពូក ១៧

# នៅពេលព្រះជាម្ចាស់ស្ងៀមស្ងាត់

....

*ឱព្រះជាម្ចាស់អើយ សូមកុំនៅសំងំស្ងៀមឡើយ! ឱព្រះជាម្ចាស់អើយ សូមកុំនៅ ស្ងៀមស្ងាត់ ឥតកំរើកយ៉ាងនេះ!*

ទំនុកដំកើង ៨៣៖១(KHSV)

ខ្ញុំបានគិតជាច្រើនដង *ខ្ញុំរំពឹងថាព្រះជាម្ចាស់នឹងយាងមកហើយគង់នៅទីនេះជាមួយខ្ញុំនឹងគ្រាន់តែប្រាប់ខ្ញុំពីអ្វីដែលព្រះអង្គចង់ឲ្យខ្ញុំធ្វើ!* ខ្ញុំប្រាកដថាអ្នកក៏ធ្លាប់បានគិតប្រហាក់ប្រហែលគ្នានឹងខ្ញុំក្នុងជីវិតរបស់អ្នកដែរ។ វាដូចគ្នានឹងខ្ញុំ ដែលវាអាចនឹងធ្វើឲ្យរឿងងាយស្រួលកាន់តែច្រើនឡើង។ ប៉ុន្តែវាបានបង្ហាញមកថាព្រះគឺមានគំនិតផ្សេងប៉ុន្តែនោះមិនមែនជាអ្វីដែលព្រះជ្រើសរើសធ្វើនោះទេ។ ប្រសិនបើទ្រង់មិនសព្វព្រះហឫទ័យនឹងធ្វើការក្នុងរបៀបរបស់យើង ដូច្នេះយើងនឹងត្រូវការរៀនធ្វើការទាំងនោះក្នុងរបៀបរបស់ទ្រង់។ ទ្រង់ចង់ឲ្យយើងទុកចិត្តទ្រង់ទោះជានៅពេលដែលទ្រង់ស្ងៀមស្ងាត់ក៏ដោយ!

> *តើអ្នកមិនធ្លាប់មានអារម្មណ៍ថាព្រះបានរៀបចំ ប្តូរចេញទៅឆ្ងាយ ហើយបានចាកចេញទៅដោយមិនមានការបញ្ជូនបន្តសារទេឬ?*

តើអ្នកមិនធ្លាប់មានអារម្មណ៍ថាព្រះបានរៀបចំប្តូរចេញទៅឆ្ងាយ ហើយបានចាកចេញទៅដោយមិនមានការបញ្ជូនបន្តសារទេឬ? ពេលដែលយើងមិនបានឃើញព្រះជាម្ចាស់ធ្វើអ្វីមួយក្នុងជីវិតរបស់យើង ហើយយើងក៏មិនបានឮទ្រង់មានព្រះបន្ទូលអ្វីមួយទេនោះ យើងប្រហែលជាមានអារម្មណ៍ហាក់ដូចជាយើងកំពុងរាវទៅមកក្នុងភាពងងឹត ស្វែងរកផ្លូវរបស់យើងតាមរយៈផ្លូវខ្វាត់ខ្វែង។ ទោះបីជាពេលវេលាទាំងនេះមានការប្រឆាំងគ្នានឹងសេចក្តីជំនឿរបស់យើងក៏ដោយ ពួកវាអាចបង្រៀនយើងតាមរយៈមេរៀនដ៏សំខាន់មួយ៖ ទុកចិត្តព្រះជាម្ចាស់ទោះបីនៅពេលដែលទ្រង់ស្ងាត់ស្ងៀមក៏ដោយ។ ដោយព្រោះទ្រង់ស្ងៀមស្ងាត់នោះមិនមានន័យ

ថាទ្រង់មិនធ្វើអ្វីនោះទេ។

ព្រះជាម្ចាស់បានស្ងាត់ស្ងៀមអស់រយៈពេលបួនរយឆ្នាំ រវាងការបញ្ចប់នៃសម្ព័ន្ធមេត្រីចាស់និងការបើកសម្ព័ន្ធមេត្រីថ្មី ប៉ុន្តែមានរឿងជាច្រើនបានកើតឡើងកំឡុងពេលនោះ ជាក់ស្តែងគឺបានរៀបចំមនុស្សសម្រាប់ការយាងមកនៃព្រះមេស៊ី។ ព្រះគម្ពីរបាននិយាយថា ពេលកំណត់មកដល់ព្រះយេស៊ូបានប្រសូត្រ (កាឡាទី៤៖៤)។ ព្រះតែងតែមានពេលវេលាដ៏សមរម្យសម្រាប់រឿងទាំងអស់។ ពេលទ្រង់រួចរាល់ហើយ ទ្រង់នឹងមានព្រះបន្ទូល ហើយរហូតដល់ទ្រង់ធ្វើវា វាគឺជាកិច្ចការរបស់យើងដើម្បីនៅតែស្តាប់និងនៅតែរង់ចាំជាមួយនឹងការជឿជាក់។

សូមពិចារណាអ្វីដែលព្រះបន្ទូលព្រះប្រាប់យើងអំពីអេលីយ៉ាក្នុងគម្ពីរ ១ពង្សាវតាក្សត្រ១៧៖១។ អេលីយ៉ាបានប្រកាសទំនាយទៅកាន់មនុស្ស ថានឹងមិនមានភ្លៀងធ្លាក់ជាច្រើនឆ្នាំ ហើយពិតប្រាកដណាស់ វាមិនមានភ្លៀងធ្លាក់រយៈពេលបីឆ្នាំនិងប្រាំមួយខែ។ មនុស្សបានទទួលការរងទុក្ខដោយសារភាពរាំងស្ងួតដ៏ធ្ងន់ធ្ងរនេះ ហើយវាទំនងដូចជាអេលីយ៉ាមិនមានប្រជាប្រិយភាពទេក្នុងកុំឡុងពេលនោះ។ ខ្ញុំអាចនឹងប៉ាន់ប្រម៉ាណបានថាគាត់ចង់ឮអ្វីដែលថ្មីពីព្រះជាម្ចាស់អំពីការរាំងស្ងួតនេះ ប៉ុន្តែយោងតាមព្រះគម្ពីរ ១ពង្សាវតាក្សត្រ១៨៖១ «ជាច្រើនថ្ងៃកន្លងទៅ គឺនៅថ្ងៃទីបីនៃភាពរាំងស្ងួត ព្រះជាម្ចាស់មានបន្ទូលមកកាន់អេលីយ៉ា» ប្រទានឲ្យគាត់នូវការអប់រំដទៃទៀត។ ពេលនេះគាត់បានប្រកាសថាភ្លៀងនឹងធ្លាក់ហើយវាក៏បានធ្លាក់មក។

មានឧទាហរណ៍ដទៃទៀតដែលព្រះជាម្ចាស់បានចាប់ផ្តើមស្ងៀមស្ងាត់ជាមួយនឹងអស់អ្នកដែលទុកចិត្តទ្រង់។ ទ្រង់បានស្ងៀមស្ងាត់ជាមួយនឹងការងារនឹងជាមួយអ័ប្រាហាំ។ ការអានសៀវភៅយ៉ូប ជំពូក ២៣ ផ្តល់នូវការយល់ដឹងច្បាស់លាស់ទៅក្នុងការអស់សង្ឃឹមដែលយ៉ូបមានអារម្មណ៍ថាមិនអាចរកឃើញព្រះឬឮពីទ្រង់។ សូមមើលខគម្ពីរពីរបីនេះ៖

> *បើខ្ញុំដឹងថា ព្រះអង្គនៅទីណា បើខ្ញុំអាចទៅដល់កន្លែងដែលព្រះអង្គគង់នៅ*
>
> (យ៉ូប ២៣៖៣)(KHOV)
>
> *តែមើល ខ្ញុំដើរទៅខាងមុខ តែទ្រង់មិនមែននៅទីនោះក៏ថយទៅក្រោយតែរកសំគាល់ទ្រង់មិនបាន។*
>
> *ក៏ទៅខាងឆ្វេង (ហើយទៅខាងជើង) ក្នុងកាលដែលទ្រង់ប្រកបកិច្ចការ*

*តែខ្ញុំមើលទ្រង់មិនឃើញ ហើយទ្រង់ប្រកបកិច្ចការ តែខ្ញុំមើលទ្រង់មិនឃើញ ហើយទ្រង់ពួននៅខាងស្តាំ (ហើយទៅខាងត្បូង) មិនអោយខ្ញុំមើលឃើញឡើយ។*

(យ៉ូប ២៣៖៨.៩) (KHOV)

ឥឡូវនេះស្តាប់សេចក្តីជំនឿរបស់យ៉ូបនិយាយនៅកណ្តាលភាពស្ងៀមស្ងាត់ដ៏គួរអោយភ័យខ្លាចនេះមកពីព្រះ៖

*ប៉ុន្តែ ទ្រង់ស្គាល់ផ្លូវដើររបស់ខ្ញុំ{ទ្រង់ខ្វល់ខ្វាយពីវា លើកសរសើរ និង យកចិត្តទុកដាក់ពីវា} ហើយកាលណាទ្រង់បានសាកល្បងខ្ញុំស្រេចហើយ នោះខ្ញុំនឹងចេញមកដូចជាមាស(បរិសុទ្ធ ហើយមានពន្លឺ)។*

(យ៉ូប ២៣៖១០) (KHOV)

ទោះបីជាយ៉ូបមិនអាចមើលឃើញព្រះឬឮព្រះបន្ទូលទ្រង់ គាត់បាននិយាយថាព្រះកំពុងតែសម្លឹងមកគាត់នឹងព្រួយបារម្ភពីគាត់។ គាត់បាននិយាយថា «កាលណា» ព្រះនឹងដោះលែងគាត់ មិនមែន «ប្រសិនបើ» ព្រះជាម្ចាស់នឹងដោះលែងគាត់នោះទេ!

អ័ប្រាហាំបានដោះស្រាយ ជាមួយនឹងភាពស្ងៀមស្ងាត់របស់ព្រះដោយការថ្វាយកូនប្រុសតែមួយរបស់គាត់ អ៊ីសាក់។ ព្រះបានបង្គាប់អ័ប្រាហាំអោយថ្វាយកូនប្រុសរបស់គាត់ជារបៀបមួយនៃការសាកល្បងសេចក្តីស្មោះត្រង់ និងការស្តាប់បង្គាប់របស់គាត់ ហើយទ្រង់រង់ចាំរហូតដល់លទ្ធភាពចុងក្រោយទីពីរនិយាយទៅកាន់អ័ប្រាហាំប្រាប់គាត់កុំអោយប៉ះពាល់ដល់អ៊ីសាក់។ ប៉ុន្តែរហូតដល់ពេលនោះ អ័ប្រាហាំគ្រាន់តែមានជំនឿនៅតែប៉ុណ្ណោះ។ គាត់ជឿជាក់លើភាពស្មោះត្រង់របស់ព្រះ គាត់មានអារម្មណ៍ថា បើទោះជាគាត់សម្លាប់អ៊ីសាក់ ព្រះជាម្ចាស់នឹងប្រោសគាត់ពីសេចក្តីស្លាប់ (លោកុប្បត្តិ ២២៖១.១២)។

ខ្ញុំមិនបានឆ្លងកាត់រឿងដ៏ធ្ងន់ធ្ងរដូចជាអ្វីដែលយ៉ូប និង អ័ប្រាហាំបានបរិយាយនោះទេ ប៉ុន្តែខ្ញុំបានទទួលពេលវេលានៃភាពស្ងៀមស្ងាត់យ៉ាងយូររវាងពេលនៃការបានឮពីព្រះ។ មានពេលដ៏ពិបាកនៅពេលដែលយើងត្រូវបានបញ្ឆោតថាព្រះជាម្ចាស់មិននៅជាមួយយើងឬថាព្រះមិនខ្វល់ខ្វាយអំពីយើង។ យើងក៏អាចគិតដែរថា យើងបានបាត់បង់សមត្ថភាពនៃការស្តាប់ឮពីព្រះជាម្ចាស់របស់យើង។

ខ្ញុំរុញច្រានខ្លួនខ្ញុំអស់រយៈពេលជាច្រើនឆ្នាំ ទទួលយកការទទួលខុសត្រូវក្នុង«ការព្យាយាម» ស្តាប់ពីព្រះ ប៉ុន្តែនៅទីបញ្ចប់ខ្ញុំបានដឹងថាប្រសិនបើព្រះចង់មានបន្ទូលអ្វី

មួយមកកាន់ខ្ញុំ ទ្រង់មានវិធីច្រើនយ៉ាងដែលអាចអោយប្រកដថាខ្ញុំបានដឹងអ្វីដែលទ្រង់បានមានបន្ទូល។ ជំនួសអោយការ*ព្យាយាម* ស្តាប់ពីព្រះហើយនឹងអារម្មណ៍ខកចិត្តនៅពេលអ្នកមិនឮ ជឿទុកចិត្តថានៅពេលដែលព្រះចង់មានបន្ទូលទៅកាន់អ្នក ទ្រង់នឹងធ្វើឲ្យស្គាល់អង្គទ្រង់យ៉ាងច្បាស់។

ជំនួយឲ្យការភ័យខ្លាចថាអ្នកមិនឮពីព្រះ ចូរជឿថាអ្នកនឹងឮពីទ្រង់។ ប្រសិនបើព្រះដឹងថាអ្នកពិតជាចង់ឮព្រះសូរសៀងរបស់ទ្រង់ហើយអ្នករៀបចំរួចជាស្រេចក្នុងការធ្វើតាម នោះទ្រង់នឹងមិនខកខានមានបន្ទូលនោះទេនៅពេលដែលពេលវេលាត្រឹមត្រូវ ។ នៅពេលដែលពេលកំណត់មកដល់ ព្រះជាម្ចាស់បានមានបន្ទូលទៅកាន់អេលីយ៉ាម្តងទៀត ហើយទ្រង់ក៏នឹងមានបន្ទូលទៅកាន់អ្នកម្តងទៀត!

## *កិច្ចការប្រាំមួយយ៉ាងត្រូវធ្វើនៅពេលដែលព្រះជាម្ចាស់ស្ងៀមស្ងាត់*

### *១. នៅពេលដែលព្រះជាម្ចាស់ស្ងៀមស្ងាត់ ចូររក្សាធ្វើអ្វីដែលទ្រង់បានប្រាប់អ្នកឲ្យធ្វើនៅពេលចុងក្រោយដែលអ្នកជឿថាអ្នកបានពីឮទ្រង់*

លោកប៉ូលបានបង្រៀនអ្នកជឿឲ្យឈរនៅក្នុងសេរីភាព ដែលពួកគេត្រូវបានផ្តល់ឲ្យ ហើយមិនត្រូវជាប់អន្ទាក់ម្តងទៀតក្នុងនឹមនៃទាសភាព(កាឡាទី៥៖១)។ ប្រកាន់ភ្ជាប់នូវអ្វីដែលអ្នកមាន ហើយកុំអនុញ្ញាតឲ្យពេលវេលានៃភាពស្ងៀមស្ងាត់ពីព្រះធ្វើឲ្យអ្នកបាក់ទឹកចិត្តនិងធ្វើឲ្យសេចក្តីជំនឿរបស់អ្នកចុះខ្សោយឡើយ។

នេះជាកិច្ចព្រមព្រៀងដ៏អស្ចារ្យដែលខ្ញុំមិនបានដឹង ប៉ុន្តែក៏មានកិច្ចព្រមព្រៀងដ៏អស្ចារ្យដែលខ្ញុំមិនបានដឹងដែរ ហើយខ្ញុំធ្វើការទាំងអស់ដោយសកម្មដែលខ្ញុំអាចធ្វើវាបាននៅក្នុងជីវិតដ៏ខ្លីរបស់ខ្ញុំ។ ខ្ញុំតែងតែសួរជាញឹកញាប់ថា «តើអ្វីជាកិច្ចការបន្ទាប់សម្រាប់ព័ន្ធកិច្ចរបស់អ្នក?» ចាប់ពីខ្ញុំមិនទាយទុកមុនពីអនាគត ជាធម្មតាខ្ញុំមិនដឹងពីចំលើយសម្រាប់សំណួរនោះទេ។ ប្រសិនបើយើងបានធ្វើផែនការណ៍អ្វីមួយ ខ្ញុំអាចរាយការណ៍ពីការនោះ ប៉ុន្តែភាគច្រើនជាងនោះ ខ្ញុំគ្រាន់តែធ្វើអ្វីដែលយើងភាគច្រើនធ្វើ នោះគឺការរស់នៅជារៀងរាល់ថ្ងៃពេលដែលវាមកហើយទុកចិត្តលើព្រះ។ អ្វីជារឿងបន្ទាប់ទៀតដែលនឹងក្លាយជាការភ្ញាក់ផ្អើលចំពោះខ្ញុំក៏ដូចជាអ្នកដទៃទៀតដែរ។

សំណួរដទៃទៀត ខ្ញុំត្រូវបានសួរដោយមនុស្សជាច្រើនគឺ «តើព្រះជាម្ចាស់មានបន្ទូលអ្វីទៅកាន់អ្នក?»។ខ្ញុំត្រូវបានគេសួរសំណួរនោះនៅគ្រាដំបូងនៃឆ្នាំនីមួយៗ ដូចជាថាប្រសិនបើទំព័រត្រូវបានត្រឡប់នៅលើប្រតិទិន ឥឡូវនេះខ្ញុំគួរតែទទួលការបើកសម្តែងពីព្រះជាម្ចាស់។ ទោះបីជាខែ មករា ថ្ងៃទីមួយ ខ្ញុំអាចនឹងបានចាត់ទុកថាជា

ឱកាសមួយនៃការនិយាយអំពីការធ្វើកិច្ចការថ្មី ព្រះជាម្ចាស់មិនមែនជានិច្ចកាលមានព្រះបន្ទូលថ្មី ដោយព្រោះតែវាគឺជាថ្ងៃទីមួយនៃឆ្នាំនោះទេ។ ព្រះជាម្ចាស់មិនមែនជាម៉ាស៊ីនចាក់ថាសភ្លេង ដែលពេញទៅដោយជំរើសដែលយើងអាចស្នើសុំពីទ្រង់នៅពេលវេលាដ៏ទៀងទាត់នោះទេ។ទ្រង់មានបន្ទូលនៅពេលដែលទ្រង់ជ្រើសរើសហើយដូចគ្នាទ្រង់ជ្រើសរើស នឹងពេលដែលទ្រង់ស្ងៀមស្ងាត់ យើងបន្តធ្វើអ្វីដែលយើងអាចធ្វើបាន។

ដេវនិងខ្ញុំយើងបានអស់សំណើចជាមួយនឹងមិត្តភ័ក្តិថ្មីៗនេះ ពីព្រោះស្ត្រីបាននិយាយថា នៅពេលដែលនាងនឹងប្តីរបស់នាងរៀបការជាលើកដំបូង ប្តីរបស់គាត់ជាមនុស្សខាងវិញ្ញាណហួសហេតុ ហើយគាត់បានកំណត់ឲ្យនាងអានព្រះគម្ពីរក្នុងចំនួនជាក់ស្តែងមួយជារៀងរាល់ថ្ងៃ។ ពេលដែលគាត់ត្រឡប់មកពីកន្លែងធ្វើការវិញ គឺដូចជាជំនួយការគ្រូគង្វាលក្នុងព្រះវិហារតាមតំបន់អញ្ចឹងកិច្ចការទីមួយដែលគាត់និយាយទៅកាន់នាងនោះគឺ «តើថ្ងៃនេះព្រះបានបង្ហាញអ្វីដល់អ្នក?» ខ្ញុំគ្រាន់តែអាចស្រមៃមើលពីប្រភេទនៃសម្ពាធដែលដាក់លើនាង ហើយតើនាងត្រូវមានអារម្មណ៍ធ្លាក់ចុះយ៉ាងដូចម្តេចប្រសិនបើនាងនិយាយថា«មិនមានទេ»។ វាជារឿងកំប្លែង ឥឡូវនេះ ប៉ុន្តែខ្ញុំសង្ស័យថាវាពិតជាកំប្លែងណាស់ពេលនោះ។ សូមកុំដាក់សម្ពាធលើខ្លួនរបស់អ្នក ឬក៏អ្នកដទៃ ចូរនឹករកមើលជាមួយនឹង «ពាក្យពីព្រះ» លុះត្រាតែអ្នកចង់បើកទ្វារសម្រាប់វិញ្ញាណអាក្រក់បញ្ឆោតអ្នក។

## *២. ភាពស្ងៀមស្ងាត់របស់ព្រះអាចជាពាក្យសរសើរដល់អ្នក*

ប្រហែលជាទ្រង់មិនប្រទានឲ្យអ្នកនូវការណែនាំជាក់លាក់ណាមួយទេ ព្រោះទ្រង់ជឿជាក់ថាអ្នកធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ។ វាគឺជាការភាន់ច្រឡំដែលជឿថាព្រះនឹងប្រាប់យើងពីការផ្លាស់ប្តូរដែលយើងធ្វើ។ ទំនាក់ទំនងប្រភេទនោះគឺសម្រាប់ឪពុកម្តាយនឹងកូនង៉ែត មិនមែនសម្រាប់កូនប្រុសស្រីដែលពេញវ័យនោះទេ។ កូនប្រុសម្នាក់របស់ខ្ញុំបាននិយាយនៅព្រឹកនេះថា «ខ្ញុំនឹងមកលេងនៅពេលថ្ងៃនេះ ម៉ាក់។» ខ្ញុំមិនបានផ្ញើបញ្ជីនៃការណែនាំឲ្យច្បាស់អំពីរបៀបដែលខ្ញុំរំពឹងថា គាត់នឹងប្រព្រឹត្តនៅពេលចូលមកក្នុងផ្ទះ។ ខ្ញុំជឿជាក់គាត់ហើយខ្ញុំជឿជាក់ថាគាត់ដឹងពីចិត្តរបស់ខ្ញុំ ហើយនឹងធ្វើតាម។ សម្រាប់ឧទាហរណ៍ គាត់នឹងមិនទុកឲ្យទ្វារចំហពីក្រោយគាត់នោះទេ។ គាត់នឹងមិនចតឡានរបស់គាត់នៅកន្លែងដែលនឹងរាំងស្ទះអ្នកណាម្នាក់មិនឲ្យគេយកឡាន របស់គេចេញពីរោងឡាននោះទេ។ គាត់នឹងមិននាំអ្នកណាម្នាក់ដែលខ្ញុំមិនស្គាល់មកក្នុងផ្ទះនោះទេ។ ខ្ញុំមិនត្រូវការប្រាប់ គាត់នូវរឿងទាំង

អស់នោះទេពីព្រោះគាត់ពិតជាដឹងពីចិត្តរបស់ខ្ញុំ។

ព្រះប្រទានសេរីភាពឲ្យយើងធ្វើការសម្រេចចិត្តតាមព្រះបន្ទូលរបស់ទ្រង់ ហើយអ្វីដែលយើងដឹងពីព្រះហប្ញទ័យនឹងលក្ខណៈរបស់ទ្រង់។ ថ្មីៗនេះខ្ញុំបានឮពីមនុស្សដ៏ល្បីល្បាញម្នាក់របស់ព្រះនិយាយថា ព្រះមិនដែលប្រទានឲ្យគាត់នូវការណែនាំជាក់លាក់ណាមួយ នូវចំណុចប្រសព្វដ៏សំខាន់ណាមួយនៅក្នុងជីវិតរបស់គាត់នោះទេ។ គាត់បានរកឃើញថា នៅពេលដែលគាត់បានរួចរាល់ក្នុងការសម្រេចចិត្តដ៏សំខាន់ គឺគាត់បានអធិស្ឋានសម្រាប់ការនាំផ្លូវរបស់ព្រះ គាត់ត្រូវបានដឹកនាំឱ្យបោះជំហាននិងព្យាយាមធ្វើរឿងជាច្រើនរហូតដល់គាត់មានសន្តិភាពអំពីរឿងត្រឹមត្រូវ។ យើងត្រូវតែចងចាំថា ទោះបីព្រះជាម្ចាស់អាចនិងហាក់ដូចជាស្ងៀមស្ងាត់មកកាន់យើង ទ្រង់តែងតែមានការទំនាក់ទំនងជាមួយយើងនៅក្នុងវិធីខុសៗគ្នា - តាមរយៈព្រះបន្ទូលរបស់ទ្រង់ សេចក្តីសុខសាន្ត ប្រាជ្ញា បទពិសោធន៍របស់យើងពីអតីតកាល ហើយនឹងរឿងផ្សេងទៀត។

> *ប្រសិនបើព្រះជាម្ចាស់មិនប្រាប់យើងជាក់លាក់ពីអ្វីដែលយើងគួរនឹងធ្វើ ដូច្នេះត្រូវជឿជាក់ថាទ្រង់ទុកចិត្តអ្នកក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ!*

ប្រសិនបើព្រះជាម្ចាស់មិនប្រាប់យើងជាក់លាក់ពីអ្វីដែលយើងគួរនឹងធ្វើដូច្នេះ ត្រូវជឿជាក់ថាទ្រង់ទុកចិត្តអ្នកក្នុងការធ្វើការសម្រេចចិត្តដ៏ត្រឹមត្រូវ! វាមិនអាចទៅរួចទេក្នុងការបើកបររថយន្តដែលចត ដូច្នេះមានពេលវេលាដែលយើងត្រូវដាក់ជីវិតរបស់យើងក្នុងការបើកបរហើយចាប់ផ្តើមធ្វើឲ្យទៅមុខយឺតៗមុនពេលដែលយើងរកឃើញថាតើយើងនឹងទៅតាមទិសដៅត្រឹមត្រូវឬអត់។

### *៣. កុំប្រៀបធៀបខ្លួនរបស់អ្នកជាមួយនឹងអ្នកដទៃ!*

យើងតែងតែឮមនុស្សជាច្រើន និយាយអំពីរបៀបដែលព្រះធ្វើការជាមួយនឹងពួកគេ ហើយនឹងសន្មត់ថាព្រះគួរនឹងធ្វើជាមួយយើងដូចគ្នាដែរ ប៉ុន្តែទ្រង់គឺមិនដូច្នោះទេ។ ខ្ញុំបានអានសៀវភៅជាច្រើនអំពីមនុស្សដែល *ធ្វើសម្លេងដូចជាថាព្រះជាម្ចាស់* គង់នៅលើគែមគ្រែរបស់ពួកគេ ផ្តល់ឲ្យពួកគេនូវការណែនាំប្រចាំថ្ងៃលើអ្វីដែលពួកគេធ្វើ។ « ព្រះជាម្ចាស់មានព្រះបន្ទូលថា» ហើយ «ព្រះជាម្ចាស់បានប្រាប់ខ្ញុំ» គឺជាពាក្យដែលពួកគេចូលចិត្ត។ ខ្ញុំក៏ប្រើពាក្យទាំងនោះដែរ ហើយប្រហែលជាច្រើនជាងដែលខ្ញុំគួរនឹងអាចធ្វើបាន ពីព្រោះមានពេលដែលមនុស្សយល់ខុសអំពីអ្វីដែលយើងចង់មានន័យ។ យើងអាចនៅតែបន្តទទួលការដឹកនាំនិងណែនាំពីព្រះ ប៉ុន្តែនោះមិនមានន័យដូចដែលយើងកំពុងទទួលការបង្ហាញពីប្រព័ន្ធផ្សព្វផ្សាយនូវ អ្វីដែលយើងត្រូវធ្វើពេញ

មួយថ្ងៃជារៀងរាល់ថ្ងៃទេ។

ខ្ញុំស្គាល់មនុស្សដែលហាក់ដូចជាបានឮព័ត៌មាន ជាក់លាក់ជាច្រើនពីព្រះជាងខ្ញុំដែលបានធ្វើ ប៉ុន្តែខ្ញុំបានរៀនពីការមិនប្រៀបធៀបខ្លួនរបស់ខ្ញុំជាមួយនឹងអ្នកណាម្នាក់ផ្សេង។ ប្រសិនបើយើងប្រៀបធៀបខ្លួនរបស់យើង ដូច្នោះយើងមិនអាចស្កប់ស្កល់នឹងទំនាក់ទំនងផ្ទាល់ខ្លួនរបស់យើងជាមួយនឹងព្រះជាម្ចាស់ឡើយ។ យើងមានភាពឯករាជ្យ ហើយព្រះជាម្ចាស់ធ្វើការជាមួយយើងក្នុងមធ្យោបាយខុសៗគ្នាក្នុងហេតុផលផ្សេងៗគ្នា ហើយយើងអាចទុកចិត្តការនោះបាន។ នៅពេលដែលយើងមានផាសុកភាពជាមួយមនុស្សម្នាក់ វាគឺអាចទៅរួចដែលអង្គុយនៅក្នុងបន្ទប់មួយហើយមិននិយាយអ្វីសោះ។ ថ្ងៃខ្លះវាគ្រប់គ្រាន់សម្រាប់យើងដោយគ្រាន់តែជឿថាព្រះជាម្ចាស់គង់ជាមួយយើង!

*៤. ចូរបន្តនិយាយទៅកាន់ព្រះ ទោះបីបើអ្នកមិនគិតថាទ្រង់នឹងឆ្លើយតបក៏ដោយ*

យើងត្រូវការបង្ហាញពីខ្លួនរបស់យើង ហើយព្រះចង់ធានាដល់យើងថាយើងអាចនិយាយទៅកាន់ទ្រង់ពីគ្រប់អ្វីៗទាំងអស់រាល់ពេលដែលយើងចង់និងត្រូវការ។ ដាវីឌជាអ្នកតែងទំនុកតម្កើងពិតជាបានថ្វាយដួងចិត្តរបស់គាត់ទៅព្រះជាម្ចាស់ ហើយគាត់បានធ្វើដូច្នេះដោយសេចក្តីស្មោះត្រង់បំផុត។ ភាគច្រើននៃយើងមានពេលដែលគ្រាន់តែចង់ឲ្យនរណាម្នាក់និយាយជាមួយ។ អ្នកប្រហែលជាមិនសូវខ្វល់ខ្វាយលើអ្វីដែលពួកគេនិយាយឡើយ អ្នកគ្រាន់តែចង់ឲ្យនរណាម្នាក់ស្តាប់នឹងរក្សាការសំងាត់ ហើយព្រះជាម្ចាស់គឺតែងតែល្អបំផុតក្នុងរឿងនោះ។

*៥. ចូរបន្តការស្តាប់ទោះបីជាអ្នកមានភាពហួតហែងនៃការមិនស្តាប់អ្វីមួយជាយូរ*

បន្តស្តាប់ អនុញ្ញាតឲ្យព្រះដឹងថា អ្នកបើកដួងចិត្តរបស់អ្នកសម្រាប់ទ្រង់ ហើយថាអ្នករង់ចាំទ្រង់។ ខ្ញុំសួរព្រះជាម្ចាស់ជាញឹកញាប់ ប្រសិនបើទ្រង់មានអ្វីដែលទ្រង់ចង់មានបន្ទូលមកកាន់ខ្ញុំនិងខ្ញុំគ្រាន់តែចំណាយពេលស្ងៀមស្ងាត់ពីរបីនាទី។ វាជារបៀបរបស់ខ្ញុំដែលគោរពអ្វីដែលព្រះជាម្ចាស់មានបន្ទូលមកកាន់យើងនៅក្នុងគម្ពីរសុភាសិតៈ

> *ចូរនឹកដល់ ព្រះអង្គម្ចាស់ក្នុងគ្រប់កិច្ចការដែលកូនធ្វើ នោះព្រះអង្គនឹងត្រួសត្រាយផ្លូវរបស់កូន។*
>
> សុភាសិត ៣៖៦(KHSV)

ទោះបីជាខ្ញុំមិនឮអ្វីសោះនៅពេលដែលខ្ញុំសួរសំណួររនោះ ខ្ញុំនៅតែជឿថាការស្ដាប់របស់ខ្ញុំគឺមានតម្លៃ។ ខ្ញុំបានរកឃើញថា ព្រះជាម្ចាស់អាចនឹងស្ងៀមស្ងាត់នៅពេលដែលខ្ញុំសួរសំណួរ ប៉ុន្តែបន្ទាប់ពីនោះទ្រង់នឹងដឹកនាំស្ថានភាពរបស់ខ្ញុំក្នុងរបៀបផ្សេងៗដែលវាច្បាស់លាស់សម្រាប់ខ្ញុំ ដែលទ្រង់បានចូលរួមក្នុងការដឹកនាំស្ថានភាពរបស់ខ្ញុំ។

*៦. ចូរសូមព្រះជាម្ចាស់ដើម្បីពិនិត្យមើលអ្នក*

ពេលខ្លះ ដាវីឌ បានសូមព្រះដើម្បីពិនិត្យគាត់ ដើម្បីមើលប្រសិនបើមានអ្វីមួយមិនត្រឹមត្រូវក្នុងដួងចិត្តរបស់គាត់(ទំនុកដម្កើង២៦៖២, ១៣៩៖២៣-២៤)។ នេះគឺជាជំហានដ៏អង់អាច ប៉ុន្តែមួយដែលបញ្ជាក់យ៉ាងច្បាស់ថាតើអ្នកណាម្នាក់ពិតជាចង់បានឆន្ទៈរបស់ព្រះ មិនមានបញ្ហាថាវាជាអ្វីនោះទេ។

តើវាអាចទៅរួចឬទេ ដែលមានអ្វីមួយមកបិទបាំងយើងមិនឲ្យឮព្រះបន្ទូលបានច្បាស់លាស់? អំពើបាប អាកប្បកិរិយាខុសឆ្គង ឬការយល់ច្រឡំលើរបៀបដែលបានឮពីព្រះអាចនឹងបិទបាំងយើង។ យើងមិនត្រូវភ័យខ្លាចដោយការដឹងការពិតនោះទេ ពីព្រោះវានាំឲ្យយើងមានសេរីភាព។ នៅពេលដែលព្រះជាម្ចាស់ស្ងៀមស្ងាត់ យើងអាចនឹងមិនធ្វើអ្វីខុស ប៉ុន្តែមិនមានគ្រោះថ្នាក់ក្នុងការស្វែងរកទេ។

ទោះបីជាព្រះជាម្ចាស់បានស្ងៀមស្ងាត់ជាមួយលោកយ៉ូបអស់ពេលជាយូរ នៅទីបញ្ចប់ទ្រង់បានឆ្លើយតបនឹងគាត់ ប៉ុន្តែនៅពេលដែលទ្រង់ឆ្លើយតប ទ្រង់មានរឿងខ្លះមានព្រះបន្ទូលដែលយ៉ូបមិនបានរំពឹងទុក។ ក្រៅពីការខកចិត្ត ចុងបញ្ចប់យ៉ូបទូលទៅព្រះជាម្ចាស់ថា គាត់មិនបានត្រៀមសម្រាប់ហេតុការណ៍ដែលគាត់បានទទួលនោះទេ ហើយច្រើនឬតិចទាមទារឲ្យមានចំលើយខ្លះ។ យ៉ូបបានបង្ហាញថាគាត់បានគិតថាព្រះអយុត្តិធម៌ក្នុងការប្រព្រឹត្តចំពោះគាត់។ គាត់មិនបានដឹងពីសង្គ្រាមខាងវិញ្ញាណដែលកំពុងកើតឡើងនៅពីក្រោយឆាកនោះទេ ដូចដែលយើងមិនដែលបានដឹងថាមានអ្វីដែលកំពុងកើតឡើងនៅខាងក្រោយឆាកនោះដែរ។ ព្រះគម្ពីរបាននិយាយថាយ៉ូបបានដឹងកំហុស ដូច្នេះជាក់ស្តែងគាត់បានធ្វើបាប។

ទោះបីជាគាត់ជាមនុស្សសុចរិតគ្រប់ពេលក៏ដោយ ក៏ពេលដែលសេចក្ដីល្បងល៍ចាប់ផ្ដើម នៅទីបញ្ចប់យ៉ូបសន្មត់ថាព្រះបានធ្វើមិនត្រឹមត្រូវជាមួយគាត់ (យ៉ូប៤២៖៣-៦)។ សេចក្ដីសុចរិតរបស់គាត់បានក្លាយមកជាការសុចរិតតែខ្លួនឯងដែលមានគ្រោះថ្នាក់ដល់អស់អ្នកណាដែលមានលក្ខណៈបែបនេះក្នុងចំណោមយើង។ លោកយ៉ូបជាក់ស្តែងបានឆ្លងកាត់គ្រប់ទាំងពេលវេលាដ៏អាក្រក់ (ពិតជាច្រើនជាងអ្នកដែល

យើងស្គាល់) ប៉ុន្តែនៅទីបញ្ចប់ គាត់និយាយថា ឥឡូវនេះគាត់ដឹងថាព្រះជាម្ចាស់ពិតជាប្រសើរជាងកាលដែលគាត់បានឮ (យ៉ូប ៤២៖៥)។ ដូចគ្នាដែរ ព្រះជាម្ចាស់បានប្រទានគាត់វិញទ្វេដងនូវរាល់អ្វីដែលគាត់បានបាត់បង់ នឹងបានប្រទានពរដល់គាត់យ៉ាងសម្បើម (យ៉ូប ៤២៖១០-១៧)។

ការធ្វើដំណើរគឺលំបាក ប៉ុន្តែនៅទីបញ្ចប់វាចេញលទ្ធផលមកយ៉ាងល្អ! នេះគឺជារឿងដូចគ្នាដែលយើងអាចរំពឹងទុកជាមុន។ ចូរចងចាំថា៖**សាតាំង**មានគឺន័យសម្រាប់គ្រោះថ្នាក់ ព្រះជាម្ចាស់តាំងព្រះទ័យគឺសម្រាប់ ការល្អ (លោកុប្បត្តិ ៥០៖២០) ។

# ជំពូក ១៨

# ការទុកចិត្តព្រះជាម្ចាស់កំឡុងពេលនៃការផ្លាស់ប្តូរ

*អស់អ្នកដែលមិនអាចផ្លាស់ប្តូរគំនិតរបស់ពួកគេ មិនអាចផ្លាស់ប្តូរអ្វីបានទាំងអស់*

George Bernard Shaw

មនុស្សជាច្រើនមិនចង់ផ្លាស់ប្តូរហើយតស៊ូផ្លូវផ្តាច់ជាមួយវា។ ប៉ុន្តែរឿងជាច្រើននៅក្នុងលោកនេះតែងតែមានការផ្លាស់ប្តូរ ទោះបីជាយើងចង់ឬមិនចង់អោយវាកើតឡើងក៏ដោយ ដូច្នេះការបដិសេធមិនទទួលយកវាគឺគ្មានប្រយោជន៍។ អ្វីដែលយើងត្រូវធ្វើគឺផ្លាស់ប្តូរគំនិតរបស់យើងអំពីរបៀបដែលយើងគិតអំពីការផ្លាស់ប្តូរ ពីព្រោះពេលដែលកើតឡើង ជីវិតគឺងាយស្រួលក្នុងការដោះស្រាយ។ សូមពិនិត្យអ្វីដែលមនុស្សមួយចំនួនគិតអំពីការផ្លាស់ប្តូរនិងហេតុអ្វី។

មនុស្សមួយចំនួននិយាយយ៉ាងដាច់អហង្ការថា «ខ្ញុំស្អប់ការផ្លាស់ប្តូរ!» ពួកគេអាចនឹងមានអារម្មណ៍បែបនោះ ពីព្រោះពួកគេមិនចូលចិត្តការចាកចេញពីការគ្រប់គ្រង ឬក៏ពីព្រោះពួកគេគ្មានសន្តិភាពហើយភ័យខ្លាចចំពោះរឿងថ្មីឬសូម្បីតែដោយសារពួកគេមានទំលាប់នៃការគិត ថាពួកគេមិនចូលចិត្តការផ្លាស់ប្តូរ។ ជាក់ស្តែងប្រភេទនៃការគិតអាចជាទំលាប់ដែល យើងបានទទួលយកពីមនុស្សដែលមានឥទ្ធិពលលើយើងតាំងពីកុមារភាពរបស់យើងមក ឬ ពួកវាអាចគ្រាន់តែជាទីតាំងរឹងមាំដែលសាតាំងបង្កើតក្នុងគំនិតរបស់យើងដើម្បីបង្ខាំងយើងពីការមានជីវិតដ៏ល្អ ដែលព្រះយេស៊ូចង់ឲ្យយើងមាន។

ការផ្លាស់ប្តូរគឺជានិរន្តរ៍ភាពនៅក្នុងជីវិតរបស់យើង ហើយដើម្បីទប់ទល់វាគឺដូចជាការតស៊ូនឹងខ្យល់នៅពេលដែលវាសម្រេចចិត្តបក់បោក។ ខ្ញុំមានចៅស្រីម្នាក់ដែល ជាអ្នករៀបចំផែនការ ហើយស្ទើរតែគ្រប់ពេលមានការផ្លាស់ប្តូរផែនការដែលនាងបានធ្វើ វាគឺពិបាកសម្រាប់នាងដើម្បីកែតម្រូវ វាអាចធ្វើអោយនាងរសាប់រសល់។

> *ការផ្លាស់ប្តូរគឺជានិរន្តរ៍ភាព នៅក្នុងជីវិតរបស់យើង យើង ហើយដើម្បីទប់ទល់វាគឺដូចជាការតស៊ូរនឹងខ្យល់នៅពេលដែលវាសម្រេចចិត្តបក់បោក។*

ប៉ុន្តែមិនមានអ្វីដែលយើងធ្វើនឹងរក្សាការផ្លាស់ប្តូរពីការដែលកំពុងកើតឡើងឡើយ វាលើកលែងតែក្នុងករណីខ្លះប៉ុណ្ណោះ។ ប្រហែលជាមានការផ្លាស់ប្តូរខ្លះដែលយើងអាចគ្រប់គ្រងបាន ប៉ុន្តែយើងក៏អាចគ្រប់គ្រងរឿងល្អៗដែលព្រះជាម្ចាស់បានរៀបចំ! យើងមិនអាចទទួលបានពីកន្លែងមួយទៅកន្លែងមួយដែលយើងចង់ទៅ ដោយមិនមានការផ្លាស់ប្តូរប្រភេទខ្លះនោះទេ។ វាមិនអាចទៅរួចនោះទេដែលយើងនៅតែបន្តធ្វើអ្វីដែលតែងតែធ្វើហើយទទួលលទ្ធផលផ្សេងនោះ។ មនុស្សមួយចំនួនចង់ទទួលបានលទ្ធផលផ្សេងជាងអ្វីដែលពួកគេធ្លាប់មានបទពិសោធន៍ ទាំងដែលពួកគេតស៊ូប្រឆាំងនឹងការផ្លាស់ប្តូរ។

## *ផ្លាស់ប្តូរគំនិតរបស់អ្នកអំពីការផ្លាស់ប្តូរ*

ប្រសិនបើអ្នកមិនចូលចិត្តការផ្លាស់ប្តូរ ចូរសួរខ្លួនរបស់អ្នកថាហេតុអ្វី។ អ្នកអាចរកឃើញថាទោះបីជាអ្នកមិនយល់ពីមូលហេតុដែលនៅពីក្រោយអាកប្បកិរិយារបស់អ្នកហើយជាធម្មតាការផ្លាស់ប្តូរ ការគិតរបស់អ្នកនឹងផ្តល់ឲ្យអ្នកនូវទស្សនៈថ្មីដ៏ពេញលេញមួយលើការផ្លាស់ប្តូរ។

ទីនេះជាផ្លូវដែលនាំឲ្យវិនាសមួយចំនួនយើងអាចគិតពីការផ្លាស់ប្តូរ ដែលវាមិនមានអ្វីច្រើនជាងធ្វើឲ្យយើងមានការយល់ច្រឡំ:

- *ខ្ញុំស្អប់ការផ្លាស់ប្តូរ*
- *ខ្ញុំខ្លាចការផ្លាស់ប្តូរ*
- *ខ្ញុំចូលចិត្តអ្វីៗដែលកើតឡើងក្នុងជីវិតរបស់ខ្ញុំនៅក្នុងការគ្រប់គ្រង*
- *ខ្ញុំចូលចិត្តអ្វីៗដែលមាននៅពេលឥឡូវនេះហើយខ្ញុំមិនចង់ឲ្យវាផ្លាស់ប្តូរទេ*

ទីនេះគឺជាវិធីស្ថាបនាមួយចំនួន ដែលយើងអាចគិតពីការផ្លាស់ប្តូរដែលនឹងជួយយើងក្នុងការទំលុះទំលាយវាដោយក្តីអំណរ:

- *ខ្ញុំចូលចិត្តការផ្លាស់ប្តូរ*
- *ខ្ញុំជឿថាការផ្លាស់ប្តូរក្នុងជីវិតរបស់ខ្ញុំនឹងធ្វើឲ្យអ្វីៗមានការប្រសើរឡើង*
- *ខ្ញុំរីករាយពីការឃើញពីលទ្ធផលនៃការផ្លាស់ប្តូរនេះ*
- *ខ្ញុំចង់ក្លាយជាអ្វីដែលខ្ញុំអាចធ្វើបានហើយខ្ញុំដឹងថាការផ្លាស់ប្តូរគឺជាផ្នែកមួយនៃដំណើរការ។*

- *ខ្ញុំចង់នៅកន្លែងដែលព្រះជាម្ចាស់ចង់អោយខ្ញុំនៅហើយនោះប្រហែលជាតម្រូវការនៃការផ្លាស់ប្តូរ។*

យើងអាចធ្វើឲ្យគំនិតរបស់យើងថ្មីទាំងអស់ដោយការជ្រើសរើសដើម្បីគិត នូវគំនិតដែលស្របតាមព្រះបន្ទូលនិងព្រះហប្ញទ័យរបស់ព្រះជាម្ចាស់។ ទ្រង់បានធ្វើវាយ៉ាងច្បាស់លាស់នៅក្នុខគម្ពីរ ដែលមានតែទ្រង់តែប៉ុណ្ណោះដែលមិនដែលផ្លាស់ប្តូរ ហើយទោះជាវត្ថុគ្រប់យ៉ាងនៅក្រោមអំណាចនៃការផ្លាស់ប្តូរក៏ដោយ (ម៉ាឡាគី ៣៖៦, ហេព្រឺ ១២៖២៧) ។

នៅពេលអ្វីមួយផ្លាស់ប្តូរ វាមិនមែនដាច់ខាតមានន័យថា អ្វីដែលបានធ្វើពីមុនខុសនោះទេ។ វាអាចមានន័យថាអ្វីដែលប្រសើរជាងកំពុងនឹងមក! ថ្មីៗនេះយើងមានបុគ្គលិកដែលលាលែងពីដំណែងរបស់គាត់ ដែលផ្តល់ឲ្យយើងនូវការជូនដំណឹងត្រឹមតែពីរសប្តាហ៍ ហើយយើងមិនមានអ្នកណាម្នាក់ជំនួសកន្លែងរបស់គាត់នោះទេ។ ការងាររបស់គាត់គឺសំខាន់ហើយនឹងមិនងាយស្រួលក្នុងការស្វែងរកអ្នកណាម្នាក់មកជំនួសកន្លែងរបស់គាត់នោះទេ។ ខ្ញុំអាចនឹងមានអារម្មណ៍ស្មុគស្មាញ ប៉ុន្តែខ្ញុំបន្តទុកចិត្តលើព្រះដើម្បីផ្តល់នឹងធ្វើអោយយើងខ្ពស់ឡើងតាមរយៈការផ្លាស់ប្តូរនេះ ដើម្បីធ្វើអោយស្ថានភាពថ្មីកាន់តែប្រសើរឡើងជាងស្ថានភាពដែលធ្លាប់មាន។

ដូចដែលបានចេញមក យើងបញ្ចប់ដោយមិនត្រូវការដើម្បីជំនួសបុគ្គលិកទៀតទេ ពីព្រោះមនុស្សពីរនាក់ផ្សេងទៀតនៅក្នុងក្រុមរបស់គាត់បានក្រោកឡើង នឹងនិយាយថា «យើងជឿថាយើងអាចទទួលខុសត្រូវកាន់តែច្រើនឡើងនិងធ្វើការងារជាមួយមនុស្សតិចជាងមុន។» វាបានប្រព្រឹត្តទៅយ៉ាងអស្ចារ្យ ហើយយើងអាចនឹងមិនរីករាយជាមួយនឹងការផ្លាស់ប្តូរនោះទេ។ ដូច្នេះអ្វីមួយដែលយើងតស៊ូតទល់ជាដំបូងហើយមិនចង់អោយបញ្ចប់ជាព្រះពរនៅក្នុងរបៀបដ៏អស្ចារ្យជាងអ្វីដែលយើងបានរំពឹងទុក។

ចំពោះអ្វីៗទាំងអស់គឺមានពេល មានរដូវកាល ហើយអ្វីៗទាំងអស់គឺវាស្រស់ស្អាតក្នុងពេលរបស់វា (ដានីញ៉ែល២៖២១ សាស្តា៣៖១,១១។ នៅក្នុងព្រះគម្ពីរយើងឃើញថាជាយូរមកហើយផែនដីនៅតែមាន នឹងមានការផ្លាស់ប្តូររដូវកាល (លោកុប្បត្តិ៨៖២២)។ រដូវរងារនាំទៅរករដូវផ្ការីក ហើយដូវផ្ការីកនាំទៅកាន់រដូវក្តៅ ហើយរដូវក្តៅនាំទៅរដូវស្លឹកឈើជ្រុះ រដូវស្លឹកឈើជ្រុះទៅកាន់ដូវរងារ។ អាកាសធាតុ ល្បឿនខ្យល់ ហើយនឹងការផ្លាស់ប្តូរសំណើមប្រចាំថ្ងៃ។ យើងរំពឹងថានឹងមានការផ្លាស់ប្តូរពេលដែលរដូវកាលវាមកដល់ ប៉ុន្តែយើងក៏ត្រូវតែរំពឹងទុកអំពីការផ្លាស់ប្តូរនៅក្នុងផ្នែកផ្សេងទៀតនៃជីវិតរបស់យើងផងដែរ ពីព្រោះវាតែងតែកើតឡើង។ យើងផ្លាស់ប្តូរនៅ

ក្នុងរបៀបជាច្រើន ដូចដែលយើងបានទទួលវ័យចំណាស់។ មនុស្សជុំវិញខ្លួនយើងផ្លាស់ប្តូរ ការប្តេជ្ញាចិត្តរបស់ពួកគេអាចនឹងផ្លាស់ប្តូរ ហើយនៅពេលដែលអ្វីៗផ្លាស់ប្តូរក្នុងជីវិតរបស់ពួកគេ វាអាចប្រហែលជាត្រូវការការផ្លាស់ប្តូរក្នុងទំនាក់ទំនងរបស់យើងជាមួយនឹងពួកគេ។

នៅពេលដែលកូនៗរបស់យើងធំឡើងហើយចាកចេញពីផ្ទះ ទំនាក់ទំនងរបស់យើងជាមួយនឹងពួកគេនឹងផ្លាស់ប្តូរ ប៉ុន្តែពួកគេមិនត្រូវមានតិចជាងអ្វីដែលយើងចង់បាននោះទេ ពួកគេគ្រាន់តែត្រូវការភាពខុសគ្នាហើយពួកគេអាចប្រសើរជាងដែលមិនធ្លាប់មាន។

កូនស្រីរបស់ខ្ញុំបានទំលាក់អ្វីមួយនៅផ្ទះនៅថ្ងៃផ្សេងទៀត ហើយខ្ញុំបាននៅក្នុងតវិយាបថសម្រាប់ក្រុមហ៊ុន ហើយក្មេងស្រីជជែកគ្នា ដូច្នេះនាងបានចាប់ផ្តើមនឹងចាកចេញបន្ទាប់ពីនាងបានមកដល់ត្រឹមតែប៉ុន្មាននាទីប៉ុណ្ណោះ ខ្ញុំបាននិយាយថា«ហេតុអ្វីបានជាឯងប្រញាប់ប្រញាល់ដូច្នេះ? ចូលមកហើយអង្គុយមួយភ្លែតសិន។» នាងបានឆ្លើយតប «ម៉ាក់ ខ្ញុំមានគ្រួសារនៅឯផ្ទះ ខ្ញុំចង់ត្រឡប់ទៅផ្ទះ។» ខ្ញុំចាប់ផ្តើមរសាត់ទៅតាមទិសដៅនៃការទទួលអារម្មណ៍ឈឺចាប់របស់ខ្ញុំ ប៉ុន្តែដូចដែលខ្ញុំបានសូមព្រះជាម្ចាស់ឲ្យជួយខ្ញុំ ខ្ញុំបានដឹងថានាងមានទំនួលខុសត្រូវដទៃទៀតជាច្រើនក្នុងជីវិតរបស់នាងក្រៅពីការមកសួរសុខទុក្ខខ្ញុំ ហើយខ្ញុំមិនគួរនឹងធ្វើឲ្យមានការលំបាកដល់នាងដោយមានការអាក់អន់ចិត្តនោះទេ។ខ្ញុំពិតជាចង់ឲ្យនាងមានភាពរស់នៅសម្រាប់ជីវិតរបស់នាងបានតាមអ្វីដែលនាងត្រូវការដោយមិនមានសម្ពាធពីខ្ញុំ។ នាងចំណាយពេលជាច្រើនជាមួយខ្ញុំ ហើយធ្វើកិច្ចការជាច្រើនសម្រាប់ខ្ញុំ ដូច្នេះសម្រាប់ខ្ញុំការដាក់សម្ពាធលើនាងជាឱកាសពេល ដែលនាងរវល់ជាមួយក្រុមគ្រួសាររបស់នាងវានឹងជាភាពអាត្មានិយម ហើយអាចមានឥទ្ធិពលប៉ះពាល់យ៉ាងខ្លាំងដល់ទំនាក់ទំនងល្អរបស់យើង។ យើងត្រូវអនុញ្ញាតឲ្យកូនៗរបស់យើងធំធាត់ ហើយមានការសម្រេចចិត្តដោយខ្លួនឯង។ ហើយទោះបីជាយើងអាចមិនចូលចិត្តជំរើសទាំងអស់របស់ពួកគេក្តី ក៏ពួកគេមានសិទ្ធិធ្វើវាហើយយើងគួររំពឹងការទាំងនោះ។

ដូច្នេះហើយជាញឹកញាប់ មនុស្សពិតជាកំសត់បន្ទាប់ពីកូនៗរបស់ពួកគេចាកចេញពីផ្ទះ។ វាហាក់ដូចជាពិបាកជាពិសេសសម្រាប់ *ម៉ាក់* ។ គាត់បានចំណាយជីវិតរបស់គាត់បង្ហូរក្តីស្រឡាញ់របស់គាត់ និងយកចិត្តទុកដាក់ចំពោះកូនរបស់គាត់ ប្រហែលជាវាច្រើនលើសលប់សម្រាប់ជីវិតរបស់គាត់ ហើយឥឡូវនេះកូនគឺកំពុងចេញឆ្ងាយធ្វើរឿងថ្មីហើយម៉ាក់គឺព្យាយាមតែម្នាក់ឯងក្នុងការស្វែងរកទិសដៅថ្មី។ ការឆ្លើយតបមួយគឺគាត់អាចមាន គឺរក្សាសម្ពាធលើកូនដើម្បីចំណាយពេលជាមួយនឹងគាត់

ហើយបំផ្លាញទំនាក់ទំនងរបស់គាត់ជាមួយនឹងពួកគេ ឬដាក់ពួកគេទៅក្នុងស្ថានភាពដែលពួកគេមានអារម្មណ៍ត្រូវបានបោកបញ្ឆោត ដូច្នេះអ្វីៗដែលពួកគេធ្វើដើម្បីគាត់វាមិនមែនធ្វើចេញពីការស្ម័គ្រចិត្តធ្វើ ប៉ុន្តែវាដូចជាករណីកិច្ចដែលមិនមានក្តីអំណរក្នុងការធ្វើវា។ ការឆ្លើយតបដ៏ប្រសើរបំផុត គឺអនុញ្ញាតឲ្យកូនៗទៅ ធ្វើឲ្យកើនឡើងនូវទំនាក់ទំនងថ្មីជាមួយនឹងពួកគេ ដែលជាគ្រឹះដ៏ធំធេងលើថាមពលនៃមិត្តភាពម្តាយនិងកូន។ បន្ទាប់ពីការទទួលថាអ្វីៗកំពុងផ្លាស់ប្តូរនិងកំពុងចាប់ផ្តើមគិតទៅក្នុងផ្លូវថ្មី គាត់នឹងរកឃើញថាព្រះមិនដែលបិទផ្លូវមួយដោយមិនបើកផ្លូវផ្សេងទៀតនោះទេ ផ្លូវមួយដែលស្រស់ស្អាតក្នុងពេលរបស់វាដូចផ្លូវមួយដែលបានមានកន្លងទៅ។

នារីម្នាក់ដែលខ្ញុំស្គាល់ថ្មីៗនេះបាននិយាយថា «កូនម្នាក់ដែលខ្ញុំមិនដែលគិតថាធ្វើឲ្យខ្ញុំខូចចិត្ត គេបានធ្វើវា តែកូនម្នាក់ដែលខ្ញុំបានគិតថាគេនឹងធ្វើនោះ គេបែរជាមិនបានធ្វើទៅវិញ!»។ មនុស្សតែងតែមិនធ្វើនូវអ្វីដែលយើងគិតថាគឺនឹងធ្វើ ហើយនៅពេលដែលការនោះកើតឡើង វាជាពេលមួយដ៏ល្អបំផុតដើម្បីជឿទុកចិត្តលើព្រះ។ មនុស្សអាចនឹងផ្លាស់ប្តូរក្នុងរបៀបដែលពិបាកសម្រាប់យើង ប៉ុន្តែពេលវេលាទាំងនោះអាចកើតមានដើម្បីជាប្រយោជន៍ ប្រសិនបើយើងរក្សាឥរិយាបថវិជ្ជមាននិងបន្តទុកចិត្តព្រះ។ ជាការពិតណាស់ ការទុកចិត្តព្រះជាកូនសោរសម្រាប់គ្រប់យ៉ាងទាំងអស់។ វាអនុញ្ញាតឲ្យយើងចូលទៅក្នុងការសម្រាករបស់ព្រះហើយអត់ធន់ដោយក្តីស្ងប់សុខក្នុងកំឡុងពេលនៃការផ្លាស់ប្តូរក្នុងការរស់នៅរបស់យើង។

ព្រះជាម្ចាស់ដឹងគ្រប់យ៉ាងដែលបានកើតឡើងក្នុងអតីតកាល អ្វីៗដែលកំពុងកើតមានក្នុងបច្ចុប្បន្ន ហើយនិងអ្វីដែលនឹងកើតឡើងក្នុងអនាគតកាល ហើយទ្រង់ស្ថិតក្នុងការគ្រប់គ្រងអ្វីទាំងអស់នោះ។ ដូច្នេះហើយទ្រង់មិនខ្វល់ខ្វាយឬអន្ទះអន្ទែងនោះទេ។ ភាពអន្ទះអន្ទែងនឹងក្តីព្រួយបារម្ភរបស់យើងគឺមកពីហេតុការណ៍ដែលយើងមិនបានដឹងនូវរឿងជាច្រើនដែលយើងគួរនឹងដឹង ជាពិសេសនៅកំឡុងពេលនៃការផ្លាស់ប្តូរ ហើយវាធ្វើឲ្យយើងមានអារម្មណ៍មិនងាយស្រួល។ ជាការពិតណាស់ ព្រះអាចឲ្យយើងដឹងគ្រប់យ៉ាងដែលកំពុងនឹងកើតឡើងក្នុងអនាគតកាល ហើយឲ្យយើងដឹងពីរបៀបផ្លាស់ប្តូរក្នុងជីវិតរបស់យើងនឹងកើតឡើង ប៉ុន្តែទ្រង់មិនធ្វើវា។ នោះពីព្រោះទ្រង់រំពឹងថាយើងទុកចិត្តទ្រង់។ វាជាឯកសិទ្ធិរបស់យើងដើម្បីជឿទ្រង់!

នៅពេលដែលយើងមិនបានរំពឹងការផ្លាស់ប្តូរនៅក្នុងជីវិតរបស់យើង ឬសូម្បីផែនការផ្លាស់ប្តូរ ជាញឹកញាប់វាបន្សល់ទុកឲ្យយើងនូវសំណួរជាច្រើនដែលមានតែព្រះជាម្ចាស់ប៉ុណ្ណោះដែលអាចឆ្លើយបាន។ ជាការពិតណាស់ យើងចង់ដឹងពីគំរូប្លង់ទាំងស្រុងនៃជីវិតរបស់យើងឥឡូវនេះ ប៉ុន្តែជឿជាក់ថា ប្រសិនបើយើងបានដឹងគ្រប់

យ៉ាងដែលគួរនឹងដឹងក្នុងពេលអនាគត ជីវិតនឹងគួរឲ្យធុញទ្រាន់ដូចដែលយើងរស់ពីមួយថ្ងៃទៅមួយថ្ងៃ ឬក៏គួរឲ្យភ័យខ្លាចជាងការដែលមិនដឹង។

ព្រះជាម្ចាស់ទ្រង់ល្អ ហើយវាឈរដើម្បីហេតុផលថា ប្រសិនការដឹងអ្វីដែលកំពុងនឹងកើតឡើងមុនពេលវាកើតឡើងជារឿងក៏ល្អបំផុតសម្រាប់យើង នោះព្រះជាម្ចាស់នឹងរៀបចំឲ្យវាកើតឡើងតាមរបៀបនោះ។ ប្រសិនបើទ្រង់មិនធ្វើដូច្នោះ យើងអាចសន្មតដោយសុវត្ថិភាពថាការរង់ចាំ និងការភ្ញាក់ផ្អើលអាចជារឿងល្អបំផុតសម្រាប់យើង។ ការទុកចិត្តព្រះជាម្ចាស់មានន័យថា យើងទុកចិត្តលើវិធីរបស់ទ្រង់។ យើងមិនគួរគ្រាន់តែទុកចិត្តទ្រង់ដើម្បីផ្តល់ឲ្យយើងនូវអ្វី*ដែលយើងចង់បាន* ទេ យើងត្រូវតែទុកចិត្តទ្រង់សម្រាប់ការល្អបំផុត*របស់ទ្រង់* ក្នុងជីវិតរបស់យើង ហើយដែលផ្អែកលើការចាត់វេលារបស់ទ្រង់និងរបៀបដែលទ្រង់ធ្វើជាមួយយើង។

ប្រសិនបើអ្នកជាមនុស្សដែលមិនចូលចិត្តការផ្លាស់ប្តូរ ខ្ញុំសូមផ្តាំផ្ញើថាអ្នកត្រូវផ្លាស់ប្តូរគំនិតរបស់អ្នកអំពីការផ្លាស់ប្តូរ ពីព្រោះជារឿយៗវាបង្កើតនូវអ្វីដែលវិជ្ជមានបំផុតនៅក្នុងជីវិតរបស់យើង។

## *ជ្រោះហួតអស់*

យើងអាចចង់បានជីវិតរបស់យើងតាមរបៀបនោះ ប៉ុន្តែតើមានអ្វីកើតឡើងបើព្រះជាម្ចាស់សម្រេចចិត្តថាវាជាពេលសម្រាប់ផ្លាស់ប្តូរ។ ហើយមានអ្វីកើតឡើងបើសិនជាអ្វីដែលទ្រង់ដឹកនាំយើងហាក់ដូចជាមិនល្អដូចជាអ្វីដែលយើងបានចាកចេញមកនោះ? វាហាក់ដូចជាកើតឡើងចំពោះអេលីយ៉ា ប៉ុន្តែមិនមានការកត់សំគាល់ណាមួយពីគាត់ថាមិនចូលចិត្តឬត្អូញត្អែរអំពីវានោះទេ។

លោក អេលីយ៉ា បានរស់នៅក្នុងភាពរាំងស្ងួតជាយូរ ប៉ុន្តែព្រះជាម្ចាស់បានផ្គត់ផ្គង់លោកដោយការអស្ចារ្យ។ លោកបានរស់នៅក្បែរជ្រោះដែលមានទឹកហូរនិងសត្វក្អែកដែលនាំអាហារឲ្យលោកជារៀងរាល់ថ្ងៃ។ ប៉ុន្តែនៅទីបញ្ចប់ជ្រោះបានរីងទឹក (១ ពង្សាវតាក្សត្រ១៧៖៧)។ ព្រះជាម្ចាស់បានប្រាប់អេលីយ៉ាឲ្យទៅទីក្រុងមួយផ្សេងទៀតដែលស្ត្រីមេម៉ាយអាចផ្គត់ផ្គង់គាត់។ ពេលដែលទៅដល់ទីនោះ គាត់បានឃើញថាស្ត្រីបានមកដល់អាហារពេលចុងក្រោយរបស់គាត់ ហើយគាត់មានគំរោងសម្រាប់គាត់និងកូនប្រុសរបស់គាត់ថាពួកគេនឹងបរិភោគវាហើយនឹងស្លាប់ទៅ។ វាជាស្ថានភាពដ៏គួរឲ្យសង្វេក ប្រសិនបើអ្នកសួរខ្ញុំ ហើយជាការពិតមិនមានអ្នកណាម្នាក់នឹងរំភើបពីការនេះ ប៉ុន្តែដូចដែលខ្ញុំបាននិយាយថា មិនមានការកត់ត្រាណាមួយពីការ

ត្អូញត្អែរពីលោកអេលីយ៉ានោះទេ។ គាត់បានប្រាប់ទៅស្ត្រីមេម៉ាយថា ប្រសិនបើនាងផ្តល់អាហារដល់លោកទីមួយ ធាតុផ្សំនៃអាហាររបស់នាងនឹងមិនរីងស្ងួតតាមការរាំងស្ងួតនោះឡើយ។ ស្ត្រីបានធ្វើដូចដែលលោកបានប្រាប់ ហើយប្រាកដណាស់វាគ្រប់គ្រាន់ ពួកគេមានយ៉ាងបរិបូរណ៍ (១ពង្សាវតាក្សត្រ ១៧៖៨.១៦)។

ការផ្លាស់ប្តូរក្នុងជីវិតអេលីយ៉ានេះមិនមានអត្ថប្រយោជន៍ចាំបាច់ណាមួយសម្រាប់ជីវិតគាត់នោះទេ ប៉ុន្តែវាបានធ្វើប្រយោជន៍ទៅស្ត្រីមេម៉ាយ។ មានពេលខ្លះនៅក្នុងជីវិតរបស់ខ្ញុំ ហើយក៏នឹងមាននៅក្នុងជីវិតរបស់អ្នក នៅពេលព្រះផ្លាស់ប្តូរអ្វីមួយក្នុងការរស់នៅរបស់អ្នកដើម្បីជួយអ្នកណាម្នាក់ផ្សេងទៀត។ វាអាចនឹងមិនដូចជាជួយយើង ឬយើងអាចហាក់ដូចជាត្រូវតែឈានមួយឬពីរជំហ៊ានថយក្រោយសម្រាប់រដូវកាលមួយ ប៉ុន្តែទ្រង់ប្រើយើងដូចជាភ្នាក់ងាររបស់ព្រះអង្គនៃការផ្លាស់ប្តូរនៅក្នុងជីវិតរបស់មនុស្សដទៃផ្សេងទៀត។ នៅពេលដែលយើងបានបញ្ចប់កិច្ចការរបស់យើង យើងអាចទុកចិត្តថាព្រះនឹងលើកយើង ឡើងទៅកន្លែងដែលប្រសើរជាងកន្លែងមួយដែលយើងបានចាកចេញមក។

ខ្ញុំច្បាស់ណាស់ថា ព្រះយេស៊ូពិតជាចូលចិត្តពេលដែលទ្រង់គង់ជាមួយព្រះបិតារបស់ទ្រង់នៅឯស្ថានសួគ៌ មុនពេលដែលទ្រង់យាងមកផែនដីដើម្បីបង់ថ្លៃសម្រាប់អំពើបាបរបស់យើងជាង ដែលទ្រង់បានធ្វើពេលដែលទ្រង់បានជាប់លើឈើឆ្កាង ការរងទុក្ខវេទនានិងការសុគតសម្រាប់យើង។ យ៉ាងណាក៏ដោយ ទ្រង់បានរីករាយទទួលកិច្ចការនេះ ពីព្រោះសេចក្តីល្អដែលបម្រុងនឹងធ្វើសម្រាប់អ្នកដទៃ។ ប្រសិនបើយើងចង់ឲ្យព្រះជាម្ចាស់ប្រើប្រាស់យើងការផ្លាស់ប្តូរមួយចំនួនដែលយើងមិនត្រូវខ្វល់ខ្វាយដោយប្រហែលជាចាំបាច់យូរៗម្តង។

ប្រសិនបើជ្រោះរបស់អ្នករីងស្ងួត ចូរកុំខ្វល់ខ្វាយហួសហេតុពេក។ ខ្ញុំអាចធានាអះអាងចំពោះអ្នកថាព្រះមានផែនការថ្មី។ ឧទាហរណ៍ថា ប្រសិនបើមនុស្សម្នាក់បាត់បង់ការងាររបស់គាត់ដោយសារក្រុមហ៊ុនកាត់បន្ថយបុគ្គលិក ដែលគាត់មិនបានរំពឹងទុកជាមុន គាត់អាចនឹងមានអារម្មណ៍រន្ធត់ដោយការផ្លាស់ប្តូរដែលកើតមានលើខ្លួនរបស់គាត់។ នេះគឺអាចយល់បាន ប៉ុន្តែការបន្តទុកចិត្តព្រះជាម្ចាស់កំឡុងពេលនៃការផ្លាស់ប្តូរជាកូនសោរមួយក្នុងសោរទាំងឡាយ ដើម្បីអនុញ្ញាតឲ្យការផ្លាស់ប្តូររុញគាត់ទៅមុខ។

ការទុកចិត្តព្រះជាម្ចាស់នៅក្នុងស្ថានភាពណាមួយឬគ្រប់ស្ថានភាពគឺជាគ្រឿងផ្សំចំបងដើម្បីរៀនរស់ក្នុងជីវិតដែលសុខសាន្ត មានអំណរ និងជ័យជំនះ។

## ចូររង់ចាំផល់អស់ព្យុះ

ជាងសាមសិបឆ្នាំមុន ខ្ញុំបានចាកចេញពីតួនាទីនៃព័ន្ធកិច្ចនៃក្រុមជំនុំប្រចាំតំបន់មួយ ដើម្បីតាមអ្វីដែលខ្ញុំបានគិតថាជាការដឹកនាំរបស់ព្រះជាម្ចាស់។ ខ្ញុំធ្លាប់មានឱកាសធ្វើព័ន្ធកិច្ចដ៏ល្អក្នុងក្រុមជំនុំ ប៉ុន្តែខ្ញុំធ្លាប់មានអារម្មណ៍ថាខ្ញុំនឹងមានឱកាសច្រើនជាងនេះក្នុងស្ថានភាពផ្សេងទៀត។ សម្រាប់ការស្មៀមស្ងាត់មួយខណៈ វាហាក់ដូចជា ប្រសិនបើការផ្លាស់ប្តូរដែលខ្ញុំបានធ្វើវាមិនឲ្យផលដូចជាអ្វីដែលខ្ញុំបានបោះបង់ចោល។ ជាការពិត វាហាក់ដូចជាប្រសិនបើខ្ញុំបានឈានមួយជំហានថយក្រោយជំនួសឲ្យការឈានទៅមុខ។

នៅទីបញ្ចប់អ្វីៗបានផ្លាស់ប្តូរ បង្ហាញឲ្យឃើញថាខ្ញុំបានបង្កើតការសម្រេចចិត្តដ៏ត្រឹមត្រូវ ប៉ុន្តែវាបានចំណាយពេលច្រើនជាងការដែលខ្ញុំបានគិតថាវាគួរនឹងកើត។ ប្រសិនបើអ្នកនៅក្នុងពេលវេលានៃការផ្លាស់ប្តូរ ហើយវាហាក់ដូចជាអ្វីៗមិនដំណើរការ អ្នកគ្រាន់តែអត់ធ្មត់ហើយបន្តស្មោះត្រង់ធ្វើអ្វីដែលអ្នកមានអារម្មណ៍ថាព្រះដឹកនាំអ្នកឲ្យធ្វើវា។ វានឹងគួរឲ្យខ្មាស់ណាស់ប្រសិនបើអ្នកបោះបង់សិទ្ធិរបស់អ្នកមុនពេលការចាញ់របស់អ្នកមកដល់នោះ។ ចូរគិតវាតាមវិធីនេះ៖ នៅពេលមានព្យុះនៅខាងក្រៅ ជារឿយៗយើងត្រូវតែបន្តនៅខាងក្នុងហើយគ្រាន់តែរង់ចាំមុនពេលចាប់ផ្តើមជាមួយនឹងផែនការរបស់យើង។

ការផ្លាស់ប្តូរមួយចំនួនក្នុងជីវិតរបស់យើងអាចហាក់ដូចជាព្យុះ។ ពួកវាមកភ្លាមៗ នឹងមិនមានការរំពឹងទុក ហើយអាចនឹងលាក់យើងពីការធ្វើអ្វីដែលយើងបានគ្រោងនឹងធ្វើ។ មិនមែនព្យុះទាំងអស់ស្ថិតក្នុងការព្យាករណ៍អាកាសធាតុទេ! ការរំជួលចិត្តកញ្ជ្រោលឡើងក្នុងកំឡុងពេលនៃការផ្លាស់ប្តូរ ហើយយើងត្រូវរង់ចាំឲ្យពួកវាស្ងប់ស្ងាត់មុនពេលបង្កើតការសម្រេចចិត្តណាមួយ។ ខ្ញុំមិនគិតថាវាជាប្រាជ្ញាដើម្បីធ្វើការសម្រេចចិត្តកំឡុងពេលដែលការរំជួលចិត្តមានកំរិតខ្ពស់ពេកឬទាបពេកនោះទេ។ យើងត្រូវការពេលវេលាដើម្បីកែសម្រួលការផ្លាស់ប្តូរពេលដើម្បីគិត ហើយពេលដើម្បីស្តាប់ពីព្រះជាម្ចាស់។ មុនពេលអ្នកបង្កើតការសម្រេចចិត្តដ៏សំខាន់អ្វីមួយក្នុងកំឡុងពេលនៃការផ្លាស់ប្តូរ ខ្ញុំសូមផ្តល់ដំបូន្មានថាអ្នកត្រូវរង់ចាំ។ សូមផ្តល់ឲ្យខ្លួនរបស់អ្នកនូវពេលវេលាដើម្បីធ្វើឲ្យធ្លាប់ទៅនឹងវិធីថ្មីនៃការធ្វើអ្វីមួយឬទំនួលខុសត្រូវថ្មី ឬមនុស្សថ្មីនៅក្នុងជីវិត

> *មុនពេលអ្នកបង្កើតការសម្រេចចិត្តដ៏សំខាន់អ្វីមួយក្នុងកំឡុងពេលនៃការផ្លាស់ប្តូរ ខ្ញុំសូមផ្តល់ដំបូន្មានថាអ្នកត្រូវរង់ចាំ។*

របស់អ្នក។ ខណៈពេលអ្នកកំពុងរង់ចាំ ចូរដាក់គំនិតរបស់អ្នកទៅក្នុងទិសដៅវិជ្ជមាន។ ចូរជឿថាអ្វីៗដែលល្អកំពុងនឹងកើតឡើង ហើយចូររក្សាឥរិយាបថល្អ!

អ្វីៗហាក់ដូចជាស្វែងរកទីកន្លែងតាំងលំនៅក្នុងជិវិតរបស់យើង ប្រសិនបើយើងផ្តល់ពេលឲ្យពួកវា។ ខ្ញុំនៅចាំបានថា ពេលមួយ ពេលដែលអ្នកដឹកនាំសំខាន់ៗមួយចំនួនរបស់យើងក្នុងព័ន្ធកិច្ចចង់ ធ្វើការផ្លាស់ប្តូរមួយដែលខ្ញុំមិនរីករាយជាខ្លាំងពីការនោះ ប៉ុន្តែខ្ញុំបានសម្រេចចិត្ត ដោយការគោរពសម្រាប់ពួកគេ ដោយស្របជាមួយនឹងវា។ ខ្ញុំពិតជាមិនចូលចិត្តវា សម្រាប់ការស្មៀមស្ងាត់ពេលខ្លះ នឹងជួនកាលវាពិបាកក្នុងការទប់ទល់នឹងភាពអវិជ្ជមាន ហើយនឹងអារម្មណ៍ចោទប្រកាន់ដែលខ្ញុំបានដឹងថាព្រះជាម្ចាស់មិនបានអនុញ្ញាតឲ្យ។ ខ្ញុំបានចំណាយពេលបីបួនខែ ទីបំផុតខ្ញុំបានដោះស្រាយជាមួយនឹងការផ្លាស់ប្តូរ។ ខ្ញុំអាចនឹងធ្វើតាមអារម្មណ៍របស់ខ្ញុំ ហើយទទូចថាយើងបោះបង់ចោលការផ្លាស់ប្តូរ ពីព្រោះខ្ញុំគ្រាន់តែមិនចូលចិត្តវា ហើយខ្ញុំមានសិទ្ធិនឹងធ្វើការនោះ។ ប៉ុន្តែនៅក្នុងទីជំរៅ ខ្ញុំបានដឹងថាមិនមានផ្លូវណាចូលទៅបាននោះទេ ដូច្នេះខ្ញុំបានរង់ចាំ! ព្យុះនៅខាងក្នុងខ្ញុំបានបញ្ចប់ ហើយអ្វីៗមានសន្តិភាពម្តងទៀត។ វាបានប្រែក្លាយថាការផ្លាស់ប្តូរនេះគឺល្អខ្លាំងណាស់ ហើយក្នុងទីបញ្ចប់ខ្ញុំបានរីករាយដែលខ្ញុំបានធ្វើតាមដំបូន្មានរបស់អ្នករួមការងាររបស់ខ្ញុំ។

ប្រហែលជាអ្នកមិនចូលចិត្តការផ្លាស់ប្តូរនៅកន្លែងធ្វើការ ដែលអ្នកមិនអាចធ្វើអ្វីបាន ឬការផ្លាស់ប្តូរក្នុងកាលៈទេសៈផ្សេងទៀត ឬបុគ្គលណាម្នាក់នៅក្នុងជីវិតរបស់អ្នក។ ប៉ុន្តែប្រសិនបើអ្នកសម្រេចចិត្តធ្វើវាឲ្យបានល្អបំផុត នៅទីបញ្ចប់អ្នកក៏ប្រហែលជារកឃើញថាស្ថានភាពថ្មីគឺប្រសើរជាងមុនទាំងអស់។

ថ្មីៗនេះខ្ញុំបានកាត់សក់របស់ខ្ញុំខ្លីជាងមុនដែលមិនធ្លាប់ ហើយពេលដំបូងខ្ញុំមិនចូលចិត្តវាទេ ប៉ុន្តែឥឡូវនេះខ្ញុំស្រលាញ់វា។ ខ្ញុំគិតថាវាធ្វើឲ្យខ្ញុំមើលទៅក្មេងជាងមុន ហើយវាពិតជាងាយស្រួលក្នុងការថែរក្សា! ដេវ បានទុកពុកមាត់អស់រយៈពេល៤០ឆ្នាំ ហើយថ្ងៃមួយគាត់បានចេញពីបន្ទប់ទឹកមកដោយកោរវាចេញ។ សម្រាប់ខ្ញុំវាមើលទៅដូចជាបបូរមាត់របស់គាត់បានបាត់ហើយអស់រយៈពេលជាយូរដែលខ្ញុំពិតជាមិនចូលចិត្តវា។ ប៉ុន្តែឥឡូវនេះខ្ញុំស្រលាញ់វាហើយគិតថាគាត់ក្មេងជាងមុនតាមវិធីនេះ ហើយខ្ញុំមិនចង់ឲ្យគាត់ទុកពុកមាត់ទៀតនោះទេ។ ចំណុចដែលខ្ញុំព្យាយាមធ្វើគឺថាយើងត្រូវផ្តល់ឲ្យនូវពេលវេលា ហើយនៅពេលដែលយើងធ្វើ ជារឿយៗយើងនឹងសម្របខ្លួនយើងទៅតាមនឹងពិតប្រាកដ និងចូលចិត្តការផ្លាស់ប្តូរនៃជីវិត។

# ជំពូក ១៩

# ខ្ញុំពិតជាចង់ផ្លាស់ប្តូរមែន

*មនុស្សគ្រប់គ្នាគិតពីការផ្លាស់ប្តូរពិភពលោក ប៉ុន្តែគ្មាននរណាម្នាក់គិតពីការផ្លាស់ប្តូរខ្លួនឯងឡើយ។*

លោក លេអូ តុលស្តូយ

មានរឿងខ្លះនៅក្នុងជីវិតដែលយើងចង់ផ្លាស់ប្តូរ ហើយយើងនឹងមានអំណរយ៉ាងខ្លាំង បើព្រះជាម្ចាស់សំរេចផ្លាស់ប្តូររឿងទាំងនោះ។ ប៉ុន្តែវាទៅជាយ៉ាងណាទៅវិញ បើយើងជាម្នាក់ដែលត្រូវផ្លាស់ប្តូរ?

ខ្ញុំបានខ្ជះខ្ជាយពេលវេលាជាច្រើនឆ្នាំគិតថាលុះត្រាតែស្ថានភាព និងមនុស្សនៅជុំវិញខ្ញុំហ្នឹងផ្លាស់ប្តូរ ទើបខ្ញុំនឹងមានអំណរជាងនេះ។ ខ្ញុំព្យាយាមផ្លាស់ប្តូរពួកគេ ខ្ញុំអធិស្ឋានទៅព្រះជាម្ចាស់ដើម្បីឲ្យព្រះអង្គផ្លាស់ប្តូរពួកគេ តែក្រោយមកទើបខ្ញុំដឹងថាព្រះជាម្ចាស់ចង់ផ្លាស់ប្តូរខ្ញុំទៅវិញទេ។ រហូតមកដល់ចំណុចនេះ ខ្ញុំមិនដែលបានដឹងសោះថាខ្ញុំត្រូវតែផ្លាស់ប្តូរ ដែលនេះហើយជាដំណោះស្រាយសម្រាប់ការមិនសប្បាយចិត្ត និងការមិនពេញចិត្តខ្លះៗនៅក្នុងជីវិតរបស់យើង។ ចុងក្រោយនៅពេលដែលខ្ញុំមើលមកខ្លួនឯងយ៉ាងស្មោះត្រង់បំផុត ទើបខ្ញុំដឹងថាគ្មានអ្វីមួយ និងគ្មាននរណាម្នាក់អាចធ្វើឲ្យខ្ញុំសប្បាយចិត្តបានឡើយលុះត្រាតែខ្ញុំសប្បាយចិត្តដោយខ្លួនឯង។ ខ្ញុំពិតជាមិនបានចូលចិត្តខ្លួនឯងកាលពីមុនឡើយ ប៉ុន្តែខ្ញុំបានចំណាយពេលយ៉ាងច្រើនព្យាយាមដាក់ការគួញគ្នែរពីការមិនសប្បាយចិត្តរបស់ខ្ញុំទៅលើមនុស្សនិងរឿងផ្សេងទៀតដែលខ្ញុំមិនបានយល់ពីសេចក្តីពិតទាំងស្រុង។

សាតាំងចង់ឲ្យយើងផ្តោតទៅលើអ្វីដែលខុសជាមួយអ្នកដទៃ ពីព្រោះវិធីនេះហើយដែលយើងមិនដែលមើលឃើញថាតើយើងមានកំហុសអ្វី។ ការចោលទោសរបស់យើងទៅលើពួកគេធ្វើឲ្យយើងមើលមិនឃើញកំហុសរបស់ខ្លួនឯង។ ការនេះពិតជាបានជួយខ្ញុំឲ្យដឹងថាពេលវេលារបស់ខ្ញុំនៅលើផែនដីនេះ គឺកើនឡើង ខ្ញុំនឹងឈរនៅចំពោះព្រះជាម្ចាស់ និង ត្រូវរាប់រៀបទូលថ្វាយព្រះអង្គពីដំណើររបស់ខ្លួនខ្ញុំផ្ទាល់ (មើល រ៉ូម ១៤:១២)។ ព្រះអង្គមិនបានសួរខ្ញុំពីនរណាម្នាក់ផ្សេងទៀតឡើយ ប៉ុន្តែព្រះ

អង្គបានសួរពីខ្ញុំផ្ទាល់។ ដូច្នេះ ខ្ញុំគួរតែផ្តោត លើការអនុញ្ញាតិឲ្យព្រះជាម្ចាស់ធ្វើអ្វីដែលព្រះអង្គចង់ធ្វើនៅក្នុងខ្ញុំ ជាជាងព្យាយាមឲ្យព្រះអង្គផ្លាស់ប្តូរនរណាម្នាក់ ឬអ្វីមួយ។

នៅពេលដែលព្រះជាម្ចាស់វែកញែកជាមួយយើងអំពីអាកប្បកិរិយា និងឥរិយាបថដែលព្រះអង្គមិនសព្វព្រះហឫទ័យ គឺអាចជាការយល់ច្រឡំយ៉ាងខ្លាំង។ ព្រះបន្ទូលរបស់ព្រះជាម្ចាស់ដែលទាក់ទងនឹងរឿងនេះជា «ការដាស់តឿន» ហើយនេះជាកិច្ចការរបស់ព្រះវិញ្ញាណដ៏វិសុទ្ធ។ យើងអាចមានអារម្មណ៍យ៉ាងសាមញ្ញថា «មានអ្វីមួយខុសប្រក្រតី» ប៉ុន្តែយើងមិនដឹងថាជាអ្វីទេ។ ជាជាងការព្យាយាមស្វែងរកថាតើវាជាអ្វី ខ្ញុំសូមលើកទឹកចិត្តថាចូរទុកចិត្តព្រះជាម្ចាស់! បើយើងស្ថិតនៅក្នុងសមរភូមិនៃគំនិតកាន់តែច្រើន យើងនឹងកាន់តែពិបាកក្នុងការដឹង និងយល់ច្បាស់ពីអ្វីដែលព្រះជាម្ចាស់ចង់បង្ហាញដល់យើង។

ឧបមាថាខ្ញុំបានប្រកែកជាមួយដេវពីរឿងអ្វីមួយ ហើយទោះបីជាខ្ញុំមានអារម្មណ៍មិនស្ងប់នៅក្នុងព្រលឹងរបស់ខ្ញុំក៏ដោយ វាមិនបានកើតឡើងចំពោះខ្ញុំថាព្រះវិញ្ញាណដ៏វិសុទ្ធព្យាយាមដាស់តឿនខ្ញុំពីអាកប្បកិរិយាខុសឆ្គង ដោយសារតែខ្ញុំទទួលការដាស់តឿនគ្រប់ពេលវេលាដែលថាគំនិតរបស់ខ្ញុំត្រឹមត្រូវនិងគំនិតរបស់ដេវខុសនោះទេ។

ប្រហែលជាយើងបង្អាក់កិច្ចការរបស់ព្រះវិញ្ញាណ ហើយយើងក៏មិនដឹងថាយើងកំពុងធ្វើអ្វីដែររហូតដល់យើងរៀនកត់ចំណាំអារម្មណ៍ទាំងនោះបានយ៉ាងត្រឹមត្រូវថាតើគំនិតទាំងនោះជាអ្វី។ ប៉ុន្តែយើងទុកចិត្តថាព្រះជាម្ចាស់នឹងបង្ហាញសេចក្តីពិតដល់យើង យើងនឹងរៀន ហើយសេចក្តីពិតដោះយើងឲ្យរួច។ ខ្ញុំជឿថា ជាការល្អបើយើងអធិស្ឋានបានទៀងទាត់ ដែលមិនមានអ្វីមួយបោកប្រាស់យើងនៅក្នុងផ្នែកណាមួយនៅក្នុងជីវិតរបស់យើង ហើយព្រះជាម្ចាស់នឹងប្តូរ និងបំផ្លាស់ប្រែយើងឲ្យបានដូចរូបអង្គព្រះគ្រិស្ត(មើល ៨:២៩-៣០)។

## *តើអ្នកឆន្ទះដើម្បីផ្លាស់ប្តូរ?*

ខ្ញុំជឿលើគោលដៅ ប៉ុន្តែខ្ញុំមិនគិតថាវាបានមកដោយឯងៗ ដែលជាអ្វីដែលគ្រប់គ្រងដោយព្រះជាម្ចាស់ ហើយយើងមិនមានចំណែកអ្វីនោះឡើយ។ ព្រះជាម្ចាស់មានកិច្ចការសម្រាប់យើងម្នាក់ៗ ប៉ុន្តែយើងត្រូវតែបានទទួលការផ្លាស់ប្រែជាមុន មុនពេលដែលព្រះអង្គអាចប្រើប្រាស់យើងក្នុងផ្លូវដែលព្រះអង្គចង់បាន។ ខ្ញុំពិតជារំភើបណាស់អំពីការត្រាស់ហៅនៅក្នុងជីវិតរបស់ខ្ញុំ ដើម្បីឲ្យខ្ញុំបង្រៀនព្រះបន្ទូលរបស់ព្រះអង្គ ប៉ុន្តែ

ជាដំបូងខ្ញុំមិនបានដឹងថាតើព្រះអង្គនឹងត្រូវធ្វើការនៅក្នុងខ្ញុំខ្លាំងប៉ុណ្ណាឡើយមុនពេលដែលព្រះអង្គអាចធ្វើការតាមរយៈខ្ញុំបាន។

ព្រះជាម្ចាស់មានផែនការល្អសម្រាប់យើងម្នាក់ៗ ប៉ុន្តែមានពេលដែលយើងវង្វេងហើយដើរក្នុងផ្លូវខុស។ អរព្រះគុណព្រះជាម្ចាស់ដោយសារជំនួយពីព្រះអង្គយើងអាចដើរនៅក្នុងផ្លូវត្រឹមត្រូវបាន។ យើងអាចទាំងឃើញកំហុសរបស់យើងក្លាយទៅជាព្រះពរ ដោយសារយើងដើរតាមការណែនាំរបស់ព្រះអង្គ។ បុរសពីរនាក់នៅក្នុងព្រះគម្ពីរដែលបានដើរនៅក្នុងផ្លូវខុស គឺយ៉ាកុប និងប៉ូល។ ប៉ុន្តែនៅពេលដែលព្រះជាម្ចាស់ធ្វើការនៅក្នុងជីវិតរបស់ពួកគេ ពួកគេទាំងពីរនាក់បានផ្លាស់ប្រែ ហើយទោះបីជាពួកគេបានប្រព្រឹត្តកំហុសដ៏ធ្ងន់ធ្ងរច្រើនយ៉ាងណាក៏ដោយ ក៏ជីវិតរបស់ពួកគេបញ្ចប់ដោយអស្ចារ្យបំផុត។

លោក យ៉ាកុប ធ្លាប់ជាមនុស្សបោកប្រាស់ បានក្លាយជាមនុស្សដ៏អស្ចារ្យរបស់ព្រះជាម្ចាស់(មើលនៅក្នុងលោកុប្បត្តិ ៣២:២២-២៨)។ លោកប៉ូលជាអ្នកបៀតបៀនដល់គ្រិស្តបរិស័ទ បានក្លាយទៅជាសាវ័កដ៏អស្ចារ្យម្នាក់(មើលក្នុងគម្ពីរកិច្ចការ៧:៥៨ ៨:១-៣,៩:១,៤,៧,២២)។ មិនដែលយឺតពេលក្នុងការផ្លាស់ប្តូរ និងឃើញគោលដៅរបស់យើងបានសម្រេចឡើយ។

មិនយឺតពេលក្នុងការផ្លាស់ប្តូរ និងឃើញគោលដៅរបស់យើងបានសម្រេចឡើយ។

ជាច្រើនដង ដើម្បីមានបទពិសោធន៍ពីការផ្លាស់ប្តូរដែលយើងចង់បាននៅក្នុងកាលៈទេសៈរបស់យើង យើងត្រូវតែមានបំណងក្នុងការផ្លាស់ប្តូរជាមុន។ ទាំងលោកយ៉ាកុប និង លោកប៉ូលមិនត្រឹមតែមានបទពិសោធន៍ក្នុងការផ្លាស់ប្រែនៅក្នុងកាលៈទេសៈរបស់ពួកគាត់ប៉ុណ្ណោះទេ តែពួកគាត់ប្រកាន់ខ្ជាប់ការផ្លាស់ប្រែដែលពួកគេត្រូវតែធ្វើនៅក្នុងខ្លួនរបស់ពួកគេផ្ទាល់។ ខ្ញុំចង់ផ្តល់យោបល់ថា ប្រសិនជាអ្នកមិនរីករាយជាមួយអ្វីដែលបានកើតឡើងនៅក្នុងជីវិតរបស់អ្នកទេ នោះមុនពេលដែលអ្នកសុំឲ្យព្រះជាម្ចាស់ផ្លាស់ប្តូរជីវិតរបស់អ្នក ចូរសុំឲ្យព្រះជាម្ចាស់ផ្លាស់ប្តូរអ្វីៗនៅក្នុងអ្នកដែលត្រូវផ្លាស់ប្តូរជាមុនសិន។ ចូរឲ្យយើងក្លាយទៅជាមនុស្សដែលព្រះជាម្ចាស់ចង់ឲ្យយើងទៅជា ហើយមិនយូរប៉ុន្មានយើងនឹងធ្វើអ្វីដែលព្រះអង្គចង់ឲ្យយើងធ្វើមិនខាន ហើយយើងនឹងមានអ្វីដែលព្រះជាម្ចាស់ចង់ឲ្យយើងមានដែរ។ ការផ្លាស់ប្រែដើម្បីឲ្យបានដូចជារូបអង្គព្រះគ្រិស្ត អាចជាការធ្វើដំណើរយ៉ាងវែង និងពេញដោយការឈឺចាប់ ប៉ុន្តែតាមពិតទៅវាអាចទៅបានយ៉ាងរលូន និងយ៉ាងរហ័សផងបើយើងសហការជាមួយព្រះវិញ្ញាណដ៏វិសុទ្ធដែលព្រះអង្គធ្វើការនៅក្នុងយើង។

ពេលខ្លះ នៅក្នុងការធ្វើដំណើររបស់យើង វាអាចមានអារម្មណ៍ ដូចអ្នកជាមនុស្ស

ម្នាក់គត់ដែលត្រូវការការផ្លាស់ប្ដូរ។ ជាពិសេសវាមានការលំបាកសម្រាប់ខ្ញុំនៅពេលខ្ញុំមានអារម្មណ៍ថាខ្ញុំជាមនុស្សតែម្នាក់ដែលព្រះជាម្ចាស់ពាក់ព័ន្ធជាមួយ។ មានពេលមួយនៅពេលដែលខ្ញុំត្អូញត្អែរទៅកាន់ព្រះអង្គពីរឿងនេះ ព្រះអង្គបានខ្សឹបនៅក្នុងដួងចិត្តរបស់ខ្ញុំថា «ចយ័អ្នកបានសុំពីខ្ញុំយ៉ាងច្រើន តើអ្នកចង់បានវា ឬក៏អត់»។ តាមពិតទៅព្រះអង្គបានធ្វើការជាមួយយើងទាំងអស់គ្នា ឬយ៉ាងហោចណាស់ព្រះអង្គមានបំណងនឹងធ្វើការ ប៉ុន្តែមិនមែនយើងស្ដាប់ និងកាន់ខ្ជាប់ការផ្លាស់ប្ដូរដែលព្រះអង្គចង់ធ្វើការនៅក្នុងយើងទាំងអស់គ្នាឡើយ។ ខ្ញុំពិតជាចង់លើកទឹកចិត្តអ្នកថា កុំព្រួយបារម្ភអំពីអ្វីដែលព្រះអម្ចាស់ធ្វើ ឬមិនធ្វើនៅក្នុងជីវិតរបស់អ្នកដទៃខ្លាំងពេក ប៉ុន្តែត្រូវទទួលអ្វីដែលព្រះអង្គកំពុងធ្វើនៅក្នុងជីវិតរបស់អ្នកវិញ។

បើព្រះជាម្ចាស់កំពុងធ្វើការក្នុងជីវិតរបស់អ្នកនៅពេលនេះ វាហាក់បីដូចជាអ្នកមិនមែនជាមនុស្សដូចពីមុនឡើយ ប៉ុន្តែអ្នកក៏មិនទាន់ក្លាយជាមនុស្សម្នាក់ដែលអ្នកត្រូវក្លាយជានៅឡើយដែរ ហើយអ្នកមានអារម្មណ៍ដូចជាអ្នកកំពុងជាប់គាំង! អ្នកមិនអាចត្រឡប់ក្រោយ ហើយអ្នកក៏មិនអាចបន្តទៅមុខទៀតដោយគ្មានជំនួយពីព្រះអម្ចាស់បានដែរ ហើយព្រះអង្គហាក់បីដូចជាកំពុងផ្ទំលក់។ ពេលនេះមិនមែនជាពេលដែលត្រូវបោះបង់ចោលឡើយ ចូរបន្តទុកចិត្តព្រះជាម្ចាស់! ការទុកចិត្តព្រះជាម្ចាស់មិនមែនគ្រាន់តែមួយពេលប៉ុណ្ណោះទេ មិនមែនជារឿងប្រាំវិនាទីទេ ប៉ុន្តែគឺជាដំណើរចេញចូលរាល់ថ្ងៃ។ ព្រះជាម្ចាស់ផ្លាស់ប្ដូរយើងបន្តិចម្ដងៗ។ពេលខ្លះយើងក៏មិនអាចដឹងពីការផ្លាស់ប្ដូរនេះបានដែរ លុះត្រាតែយើងមើលត្រឡប់ក្រោយយ៉ាងវែង ហើយយើងនឹងឃើញថាយើងពិតជាខុសប្លែកពីមុនមែន។ ខ្ញុំតែងតែនិយាយថា«ខ្ញុំមិនទាន់ក្លាយជាម្នាក់ដែលខ្ញុំត្រូវក្លាយទៅជានៅឡើយ ប៉ុន្តែអរព្រះគុណព្រះអង្គដែលខ្ញុំមិនដូចពីមុន»!

ខ្ញុំធ្លាប់មានជំងឺផ្លូវចិត្តធ្ងន់ធ្ងរក្រោយពេលត្រូវបានរំលោភបំពានដោយឪពុករបស់ខ្ញុំ ហើយទោះបីជាក្រោយពេលដែលខ្ញុំសារភាព និងចង់ផ្លាស់ប្រែ ក៏វាត្រូវការចំណាយពេលវេលាយ៉ាងយូរដែរ។ កុំបាក់ទឹកចិត្តដោយសារតែដំណើរការរបស់អ្នកហាក់បីដូចជាយឺតយ៉ាវ គ្រាន់តែជឿថាព្រះជាម្ចាស់ដឹងពីអ្វីដែលព្រះអង្គកំពុងធ្វើ ហើយអ្នកត្រូវរីករាយជាមួយខ្លួនឯងក្នុងពេលដែលអ្នកកំពុងផ្លាស់ប្ដូរ។ ចូរចាំថា ការពិបាកចិត្តមិនបានធ្វើឲ្យការផ្លាស់ប្ដូរទៅលឿនជាងមុនឡើយ!

ក្នុងដំណើរដើម្បីឲ្យយើងមានភាពចាស់ទុំខាងវិញ្ញាណ យើងត្រូវតែទុកចិត្តពេលវេលារបស់ព្រះជាម្ចាស់ និងទុកចិត្តផ្លូវរបស់ព្រះអង្គ ទោះបីជាទាំងផ្លូវ និងពេលវេលាមិនមែនជាអ្វីដែលយើងជ្រើសរើសក្ដី។ ទោះជាយ៉ាងណាក៏ដោយ ជាច្រើនឆ្នាំទៅមុខ

ទៀត នៅពេលដែលអ្នកមើលពីជីវិតរបស់អ្នក ត្រឡប់ក្រោយ អ្នកនឹងចាប់អារម្មណ៍ថា វាពិតជាបានគ្រប់ល័ក្ខណ!

ការផ្លាស់ប្តូរឲ្យបាន ដូចជារូបអង្គរបស់ព្រះគ្រិស្ត គឺជាការផ្លាស់ប្តូរដ៏អស្ចារ្យបំផុត ហើយត្រូវឆ្លងកាត់ដំណាក់កាលជាច្រើននៅក្នុងជីវិតរបស់យើង ប៉ុន្តែដំណាក់កាលនិមួយៗពិតជាស្រស់ស្អាតក្នុងពេលវេលារបស់វា។ ព្រះជាម្ចាស់មានគំរោងការជាពិសេសសម្រាប់យើងម្នាក់ៗ។ ដូច្នេះ យើងត្រូវរីករាយក្នុងដំណាក់និមួយៗ រីករាយជាមួយព្រះជាម្ចាស់ និងរីករាយជាមួយខ្លួនឯងនៅពេលដែលអ្នកធ្វើដំណើរក្នុងជីវិត!

> ការផ្លាស់ប្តូរឲ្យបានដូចជារូបអង្គរបស់ព្រះគ្រិស្ត គឺជាការផ្លាស់ប្តូរដ៏អស្ចារ្យបំផុត។

## *ការរៀនដើម្បីធ្វើការឲ្យខុសប្លែក*

ពេលដែលខ្ញុំសញ្ជឹងគិតពីការផ្លាស់ប្តូរដ៏អស្ចារ្យដែលព្រះជាម្ចាស់បានធ្វើនៅក្នុងជីវិតរបស់ខ្ញុំអស់ជាច្រើនឆ្នាំកន្លងមកនេះ ខ្ញុំដឹងថាការផ្លាស់ប្តូរនីមួយៗតម្រូវឲ្យខ្ញុំរៀនក្នុងការធ្វើរឿងផ្សេងៗឲ្យខុសប្លែក ឬក៏ត្រូវឆ្លើយតមទៅនឹងស្ថានភាពបែបផ្សេងខុសពីអ្វីដែលខ្ញុំធ្លាប់ធ្វើពីមុន។

ឧទាហរណ៍ថា ខ្ញុំធ្លាប់ជាមនុស្សកំណាញ់ ប៉ុន្តែមានពេលមួយព្រះជាម្ចាស់បានបើកសំដែងដល់ខ្ញុំពីជម្រៅនៃភាពកំណាញ់របស់ខ្ញុំ ហើយថាតើមានបញ្ហាប៉ុន្មានដែលធ្លាប់កើតមានក្នុងជីវិតរបស់ខ្ញុំបណ្តាលមកពីការនេះ ខ្ញុំពិតជាចង់ផ្លាស់ប្តូរខ្លាំងណាស់។ ប៉ុន្តែ«ឆន្ទៈរបស់ខ្ញុំ»បានស្លាប់បន្តិចម្តងៗ ហើយវាតែងតែធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង។ វាបានធ្វើឲ្យខ្ញុំចំណាយពេលយ៉ាងយូរដើម្បីគ្រាន់តែឃើញពីជម្រៅនៃភាពកំណាញ់របស់ខ្ញុំ ហើយប្រើពេលយូរជាងនេះទៅទៀតដើម្បីរៀនឲ្យចេះសប្បាយចិត្ត និងចេះរក្សាឥរិយាបថល្អនៅពេលមានអ្វីកើតឡើងមិនដូចបំណងរបស់ខ្ញុំ។ នៅពេលដែលខ្ញុំរៀនទុកចិត្តព្រះជាម្ចាស់កាន់តែច្រើន នោះខ្ញុំក៏កាន់តែងាយស្រួលដែរ ប៉ុន្តែខ្ញុំប្រាកដណាស់ថាវាមិនកើតឡើងក្នុងរយៈពេលមួយយប់នោះឡើយ។

ខ្ញុំរៀនបានថា៖ ដើម្បីយើងអាចមានអំណរជាមួយសន្តិភាពបាន ខ្ញុំត្រូវតែសម្របខ្លួនរបស់ខ្ញុំជាមួយមនុស្ស និងរឿងផ្សេងៗ ជាជាងរំពឹងថាគេនឹងសម្របតាមខ្ញុំ (មើលរ៉ូម១២:១៦)។ ខ្ញុំត្រូវចំណាយពេលពីរបីឆ្នាំទើបខ្ញុំដឹងច្បាស់ថា ការមានសន្តិភាពពិតជាប្រសើរជាងការដែលខ្ញុំដើរតាមផ្លូវរបស់ខ្ញុំគ្រប់ពេលវេលា។ សន្តិភាព គឺជារបស់មានតំលៃបំផុតដែលយើងអាចមាន ហើយយើងគួរតែមានប្រាជ្ញាដើម្បីលើកតម្លៃ

របស់វា។ តើអ្នកចង់បានសន្តិភាពគ្រប់គ្រាន់ដើម្បីធ្វើយ៉ាងណាផ្លាស់ប្តូរអ្នកឲ្យអ្នកអាចមានសន្តិភាពដែរឬទេ?

ខ្ញុំក៏គិតដែរថាការគិតថាខ្លួនត្រូវ គឺជាការគិតហួស ហើយបើខ្ញុំបាត់បង់សន្តិភាពដោយព្រោះព្យាយាមបង្ហាញថា ខ្ញុំត្រូវនៅពេលដែលខ្ញុំមិនយល់ស្របជាមួយនរណាម្នាក់ ជាធម្មតាវាគ្មានតម្លៃអ្វីឡើយ។ យើងអាចទុកចិត្តព្រះជាម្ចាស់ដែលនឹងបង្ហាញថាយើងត្រឹមត្រូវ បើវាពិតជាអ្វីដែលព្រះអង្គត្រូវតែធ្វើមែន តែបើមិនមែនទេ យើងក៏អាចជ្រើសរើសពេញចិត្តនូវអ្វីដែលបានកើតឡើង ទោះជាទៅជាយ៉ាងណាក៏ដោយ។

តំណើរការនៃការរៀនសូត្រមិនចេះចប់ឡើយ។យើងនឹងបន្តរៀនក្នុងផ្នែកជាច្រើនពេញមួយជីវិត របស់យើង ហើយការរៀនទុកចិត្តផ្លូវរបស់ព្រះជាម្ចាស់ក៏មិនខុសគ្នាដែរ។ សព្វថ្ងៃនេះខ្ញុំក៏នៅតែរៀនពីទំនាក់ទំនងរបស់ខ្ញុំជាមួយនឹងព្រះអង្គដែរ ហើយខ្ញុំគិតថាអ្នកក៏ដូចគ្នា។

## *ដំណើរការនៃការផ្លាស់ប្តូរ*

នៅពេលមួយដែលយើងសម្រេចចិត្តថាយើងចង់ផ្លាស់ប្តូរ ហើយយើងមានបំណងអនុញ្ញាតិឲ្យព្រះវិញ្ញាណធ្វើការនៅក្នុងជីវិតរបស់យើង មានមេរៀនដ៏សំខាន់មួយដែលយើងទាំងអស់គ្នាត្រូវតែរៀន៖ យើងមិនអាចផ្លាស់ប្តូរខ្លួនឯងដោយខ្លួនឯងបានឡើយ ហើយការផ្លាស់ប្តូរពិតប្រាកដតម្រូវឲ្យមានការទុកចិត្តព្រះ ជាម្ចាស់ឲ្យធ្វើការនៅក្នុងយើងឲ្យបានសម្រេច។ មនុស្សយើងភាគច្រើនតែងតែជាប់គាំង និងបញ្ចប់ដោយការបាក់ទឹកចិត្តនិងកាខកចិត្តដោយសារតែយើងព្យាយាមផ្លាស់ប្តូរតែយើងនៅតែបរាជ័យ។ យើងបានប្រសើរឡើងតិចតួចប៉ុណ្ណោះ តែបន្ទាប់មកយើងហាក់បីដូចជាធ្លាក់ទៅក្នុងទំលាប់ចាស់វិញ។ ដូច្នេះយើងសម្រេចចិត្តថាយើងនឹងព្យាយាមខ្លាំងជាងមុន ឬក៏យើងរៀបផែនការ និងរូបមន្តថ្មីដែលអាចឲ្យយើងផ្លាស់ប្តូរបាន ប៉ុន្តែយើងនៅតែមិនអាចបានជោគជ័យ។

បើយើងចង់ផ្លាស់ប្តូរ ហើយយើងព្យាយាមផ្លាស់ប្តូរ តើហេតុអ្វីបានជាយើងមិនអាចផ្លាស់ប្តូរបាន? តើហេតុអ្វីបានជាយើងមិនអាចឈប់ធ្វើអ្វីដែលយើងមិនចង់ធ្វើ? ឧទាហរណ៍ថា៖ បើខ្ញុំជាមនុស្សដែលនិយាយដោយមិនបានគិត ហើយវាបណ្តាលឲ្យមានបញ្ហាជាច្រើននៅក្នុងទំនាក់ទំនងរបស់ខ្ញុំ ដូច្នេះខ្ញុំចង់ផ្លាស់ប្តូរនិស្ស័យដែលនៅក្នុងខ្ញុំ តើហេតុអ្វីបានជាខ្ញុំធ្វើមិនបាន? ចម្លើយយ៉ាងសាមញ្ញគឺ យើងមិនអាចមានភាពជោគជ័យដោយគ្មានព្រះជាម្ចាស់បានឡើយ។ ព្រះអង្គចង់ឲ្យយើងសុំពីទ្រង់ ហើយ

ទទួលជំនួយពីព្រះអង្គក្នុងគ្រប់អ្វីទាំងអស់ដែលយើងធ្វើ។ មានតែព្រះជាម្ចាស់ទេដែលពិតជាអាចជួយយើង ព្រោះរឿងនេះជាការងារដែលនៅខាងក្នុង។

បើយើងព្យាយាមយ៉ាងអស់ពីសមត្ថភាពនៅស្ងៀមស្ងាត់ និងមិនបង្កបញ្ហាដោយនិយាយរឿងខុសយើងនឹងជោគជ័យមួយរយៈ ប៉ុន្តែនៅខណៈពេលដែលយើងធ្វេសប្រហែសនឹងមានបញ្ហាម្តងទៀត។ ប៉ុន្តែបើយើងរៀនទុកចិត្តព្រះជាម្ចាស់ក្នុងការជួយយើងក្នុងទំនាក់ទំនងទាំងអស់របស់យើង យើងនឹងបានជោគជ័យបន្តិចម្តងៗ គឺព្រះអង្គផ្លាស់ប្តូរយើង។ នៅថ្ងៃមួយយើងនឹងដឹងថាបញ្ហាចាស់មិនមែនជាបញ្ហាទៀតទេ ហើយយើងមិនអាចធ្វើអ្វីផ្សេងក្រៅពីអរគុណព្រះជាម្ចាស់ឡើយព្រោះយើងដឹងថាព្រះអង្គជាអ្នកធ្វើគ្រប់យ៉ាង។ មានតែអ្នកនៅជាប់នឹងព្រះគ្រិស្តទេដែលមានបទពិសោធន៍ពីការផ្លាស់ដ៏ប្តូរពិតប្រាកដ! គំរោងការរបស់ព្រះជាម្ចាស់គឺថា៖«?យ៉ូហាន១៥:៥)។

វាជាធម្មជាតិរបស់មនុស្សដែលចង់ធ្វើរឿងផ្សេងៗដោយខ្លួនឯង ដែលធ្វើឲ្យយើងមានមោទនភាពលើខ្លួនឯង ប៉ុន្តែព្រះជាម្ចាស់ចង់ឲ្យយើងទុកចិត្តលើព្រះអង្គក្នុងគ្រប់រឿងទាំងអស់ ហើយបន្ទាប់មកអរព្រះគុណព្រះអង្គសម្រាប់អ្វីដែលព្រះអង្គបានធ្វើ។

តើអ្នកមានឧបស័គ្គជាមួយខ្លួនរបស់អ្នកដែរឬទេ?តើអ្នកកំពុងតែព្យាយាមផ្លាស់ប្តូររឿងផ្សេងៗដែលអ្នកមិនចូលចិត្ត ឬក៏រឿងដែលអ្នកដឹងថាវាមិនស្របនឹងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ដែរឬទេ? ប្រហែលជាអ្នកព្រួយបារម្ភ តែអ្នកព្យាយាមមិនព្រួយ ឬមួយអ្នកខឹងនរណាម្នាក់ ហើយអ្នកព្យាយាមអត់ទោសឲ្យគេ។ អាចមានរឿងផ្សេងៗរាប់ពាន់ ប៉ុន្តែមានរឿងមួយដែលយើងត្រូវរៀន គឺថាយើងមិនអាចផ្លាស់ប្តូរដោយគ្រាន់តែព្យាយាមដោយខ្លួនឯងបានឡើយ ប៉ុន្តែយើងត្រូវការជំនួយពីព្រះ។

អរព្រះគុណព្រះជាម្ចាស់ យើងអាចអធិស្ឋាន ដាក់ការទុកចិត្ត និងមានទំនុកចិត្តលើព្រះជាម្ចាស់ឲ្យព្រះអង្គធ្វើអ្វីដែលត្រូវសម្រេចនៅក្នុងយើង។គ្រប់ការខិតខំប្រឹងប្រែងដែលយើងមានគួរតែធ្វើនៅពេលដែលយើងពឹងផ្អែកលើព្រះអង្គ មិនមែននៅពេលយើងនៅដាច់ឆ្ងាយពីព្រះអង្គឡើយ។ វាហាក់បីដូចជាធម្មតា ប៉ុន្តែវាជារឿងដែលលំបាកបំផុតសម្រាប់ឲ្យយើងរៀនធ្វើការនេះ ដោយសារតែសាច់ឈាមរបស់មនុស្សមានភាពឯករាជ្យ។ យើងត្រូវតែប្តូរឯករាជ្យភាពរបស់យើង ទៅជាការពឹងផ្អែកលើព្រះយេស៊ូ បើយើងពិតជាចង់បានជ័យជំនះពិតប្រាកដមែន។ រៀនក្នុងការពឹងផ្អែក! រៀនក្នុងការទុកចិត្ត!

យើងត្រូវតែប្តូរឯករាជភាពរបស់យើង ទៅជាការពឹងផ្អែកលើព្រះយេស៊ូ បើយើងពិតជាចង់បានជ័យជំនះពិតប្រាកដមែន។

លោកសាវ័ក ប៉ូលបានចែកចាយជាមួយយើង នៅក្នុងគម្ពីររ៉ូម១៧:១៥-២៥ ថា

គាត់បានព្យាយាម តែត្រូវបរាជ័យរហូតដល់គាត់ដឹងថាមានតែព្រះជាម្ចាស់ទេដែលអាចរំដោះគាត់បាន ហើយគាត់អាចធ្វើគ្រប់ទាំងអស់បានតាមរយៈព្រះគ្រិស្ត។ ពេលដែលពិតជាមានឧបសគ្គដែលលោក ប៉ូលបានជួបប្រទះដោយផ្ទាល់នៅពេលដែលលោកព្យាយាមធ្វើរឿងត្រឹមត្រូវ ហើយនៅតែបន្តបរាជ័យ លោកមានប្រសាសថា៖

*វេទនាណាស់ខ្ញុំ តើអ្នកណានឹងជួយឲ្យ ខ្ញុំរួចពីតួសេចក្តីស្លាប់នេះទៅបាន អរព្រះគុណដល់ព្រះអង្គ គឺដោយសារព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់នៃយើងរាល់គ្នា ដូច្នេះ ខ្លួនខ្ញុំគោរពប្រតិបត្តិតាមក្រឹត្យវិន័យរបស់ព្រះ ដោយគំនិតខ្ញុំ តែខាងសាច់ឈាមខ្ញុំ នោះតាមច្បាប់របស់អំពើបាបវិញ។*

រ៉ូម ៧:២៤-២៥

វាហាក់បីដូចជាបង្ហាញដល់ខ្ញុំយ៉ាងច្បាស់អំពីភាសានិងវណ្ណយុត្តដែលយើងឃើញនៅក្នុងខគម្ពីរដែលលោកប៉ូលបានបញ្ជាក់ ហើយលោកប្រាកដណាស់ថា នៅចុងក្រោយបំផុតលោកបានរកឃើញចម្លើយ។ មានតែព្រះជាម្ចាស់ទេដែលអាចធ្វើអ្វីដែលត្រូវសម្រេចក្នុងជីវិតរបស់លោក ហើយមានតែព្រះជាម្ចាស់ទេដែលអាចធ្វើអ្វីៗដែលត្រូវសម្រេចនៅក្នុងជីវិតរបស់យើងដូចគ្នា។

## *ចូរសុំ និង ចូរទទួល*

បើអ្នកចង់ផ្លាស់ប្តូរ នោះព្រះជាម្ចាស់នឹងឃើញ ហើយព្រះអង្គសព្វព្រះហឫទ័យឲ្យអ្នកផ្លាស់ប្តូរ! ជំហានបន្ទាប់ គឺការទុកចិត្តព្រះអង្គក្នុងការធ្វើអ្វីដែលត្រូវសម្រេច និងផ្តល់កំលាំងដល់អស់អ្នកដែលត្រូវការផ្លាស់ប្តូរពិតប្រាកដ។ ជារឿយៗ នៅពេលដែលយើងចង់ផ្លាស់ប្តូរ យើងព្យាយាមធ្វើវានៅពេលដែលយើងនៅឆ្ងាយពីព្រះជាម្ចាស់។ វាមិនអាចទៅរួចទេ! វាមិនអាចទៅរួចទេសម្រាប់លោកសាវ័ក ប៉ូល ហើយវាក៏មិនអាចទៅរួចសម្រាប់យើងដែរ។ ខ្សែបន្ទាត់ក្រោមបំផុតនៅទីនេះ គឺយើងត្រូវតែទុកចិត្តព្រះជាម្ចាស់ឲ្យធ្វើតាមបំណងព្រះហឫទ័យរបស់ព្រះអង្គនៅក្នុងយើង ជាជាងការព្យាយាមធ្វើដោយខ្លួនឯង។

គម្ពីរយ៉ាកុប៤:៦បានលើកឡើងថា ព្រះជាម្ចាស់ «តែទ្រង់ផ្តល់ព្រះគុណមកកាន់តែខ្លាំងឡើង ហេតុនោះបានជាទ្រង់មានព្រះបន្ទូលថា (ព្រះទ្រង់ទាស់ទទឹងនឹងពួកមានឫកធំ តែទ្រង់ផ្តល់ព្រះគុណមកពួករាបសាវិញ)»។ ព្រះគុណ គឺជាព្រះទ័យមេត្តារបស់ព្រះជាម្ចាស់ និងជាអំណាច ហើយមានការហូរឥតឈប់ឈរនៅក្នុងជីវិតរបស់

យើង។ យើងនឹងបញ្ចប់ដោយបាក់ទឹកចិត្ត និងអស់កំលាំង។

ខ្ញុំនឹកចាំពីភាពរីករាយដែលខ្ញុំមាននៅពេលដែលខ្ញុំរកឃើញសេចក្ដីពិត។ ខ្ញុំព្យាយាមយ៉ាងខ្លាំងដើម្បីក្លាយជាមនុស្សម្នាក់ដែលព្រះជាម្ចាស់ចង់ឲ្យខ្ញុំក្លាយទៅជា ប៉ុន្តែខ្ញុំបរាជ័យជាបន្តបន្ទាប់ ហើយច្របូកច្របល់ និងបាក់ទឹកចិត្តទៀតផង។ ខ្ញុំបានព្យាយាម ហើយបរាជ័យរាប់ពាន់ដង។ ខ្ញុំនិយាយថាខ្ញុំបានបោះបង់ចោល ប៉ុន្តែក្រោយមកខ្ញុំធ្វើការប្ដេជ្ញាម្ដងទៀត ហើយព្យាយាម តែនៅតែបរាជ័យជាច្រើនដងទៀត។ ចុងក្រោយបំផុត នៅពេលដែលខ្ញុំដឹងថាខ្ញុំខ្វះព្រះគុណរបស់ព្រះជាម្ចាស់ជាគ្រឿងផ្សំនៅក្នុងគំរោងការរបស់ខ្ញុំ ខ្ញុំចាប់ផ្ដើមទុកចិត្តឲ្យព្រះអង្គផ្លាស់ប្ដូរខ្ញុំ នោះខ្ញុំចាប់ផ្ដើមមានជ័យជំនះ។

ដូចជាបទចម្រៀងដែលសរសេរថា«ព្រះគុណអស្ចារ្យ! សំឡេងដ៏ផ្អែមល្ហែម!» ប៉ុន្តែយើងត្រូវតែសុំព្រះជាម្ចាស់ឲ្យផ្ដល់ព្រះគុណមកក្នុងជីវិតរបស់យើង។ ព្រះគម្ពីរយ៉ាកុប ៤:២ បានសរសេរថា៖ *...តែមិនបានអ្វីសោះ ពីព្រោះមិនសូម* ។ វាគឺសាមញ្ញបំផុត! សុំ! សុំ នោះនឹងបានទទួល (យ៉ូហាន ១៦:២៤)។ នៅពេលដែលខ្ញុំមានឧបស័គ្គក្នុងការផ្លាស់ប្ដូរ ខ្ញុំបានព្យាយាម ប៉ុន្តែខ្ញុំមិនបានសុំឡើយ ខ្ញុំមិនបានទុកចិត្តឡើយ។ ការទុកចិត្តព្រះជាម្ចាស់ជាធម្មតាជាគ្រឿងផ្សំដែលមិនអាចខ្វះបាននៅក្នុងជោគជ័យរបស់យើង។ បើយើងបោះបង់ចោលនូវគំនិតខាងសាច់ឈាមរបស់យើង ដោយព្យាយាមទុកចិត្តព្រះជាម្ចាស់បន្ថែមទៀត យើងនឹងមានការភ្ញាក់ផ្អើលនឹងលទ្ធផលមិនខាន។

## *តើចំណែករបស់យើងជាអ្វី?*

យើងត្រូវបានទទួលសេចក្ដីបង្រៀនពីព្រះបន្ទូលរបស់ព្រះជាម្ចាស់ថា បើយើងសំឡឹងយ៉ាងខ្ជាប់ខ្ជួនលើព្រះបន្ទូលរបស់ព្រះជាម្ចាស់ យើងនឹងផ្លាស់ប្ដូរទៅដូចជារូបអង្គរបស់ព្រះគ្រិស្តពីសិរីល្អមួយទៅកាន់សិរីល្អមួយមិនខាន (មើល ២កូរិនថូស ៣:១៨)។ ចំណែករបស់យើង គឺត្រូវរៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ ហើយជឿថាព្រះបន្ទូលមានអំណាចក្នុងការផ្លាស់ប្ដូរយើង។ យកព្រះបន្ទូលដាក់នៅក្នុងចិត្តរបស់យើងដូចជាថ្នាំពេទ្យ ហើយទុកចិត្តឲ្យព្រះបន្ទូលនឹងធ្វើការ។ លោក យ៉ាកុបនិយាយថា ព្រះបន្ទូលមានអំណាចសង្គ្រោះព្រលឹងរបស់យើងបាន(មើល យ៉ាកុប ១:២១)។

ទុកចិត្តលើព្រះបន្ទូលស្មើនឹងទុកចិត្តព្រះជាម្ចាស់! កុំអានព្រះបន្ទូលដោយគ្រាន់តែបំពេញការតព្វកិច្ចបែបសាសនារាល់ថ្ងៃឡើយ ប៉ុន្តែយើងត្រូវអានដោយគោរព ត្រូវយល់ថាព្រះបន្ទូលមានពេញដោយអំណាច។ ត្រូវទទួលយកព្រះបន្ទូលដូចជាអាហារ

ប្រចាំថ្ងៃរបស់អ្នក ព្រោះព្រះបន្ទូលជាអាហារដែលយើងត្រូវការសម្រាប់ផ្តល់កំលាំងដល់ព្រលឹងរបស់យើង។ ត្រូវជឿថាព្រះបន្ទូលនឹងធ្វើការនៅក្នុងអ្នក។ ប្រៀបដូចជាយើងទុកចិត្តថ្នាំដែលបានសរសេរនៅក្នុងវេជ្ជបញ្ជាថានឹងព្យាបាលរូបកាយរបស់យើងបាន យើងអាចទុកចិត្តថ្នាំពេទ្យ (អំណាចនៃការប្រោសឲ្យជា) ដែលនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ក្នុងការព្យាបាលព្រលឹងរបស់យើងបានដូចគ្នា។

ខ្ញុំចង់ផ្តល់យោបល់ថាចូរឲ្យយកអ្វីដែលអ្នកកំពុងអានទៅជាការអធិស្ឋានវិញ។ ឧទាហរណ៍នៅពេលដែលអ្នកអានការណែនាំពីការស្រឡាញ់អ្នកដទៃ កុំគ្រាន់តែអានឡើយ ប៉ុន្តែសុំព្រះជាម្ចាស់ឲ្យស្រឡាញ់អ្នកដទៃផង។ នៅពេលដែលអ្នកអានពីសារៈសំខាន់នៃការអត់ទោសដល់សត្រូវរបស់អ្នក ចូរយកការនោះអធិស្ឋានផង។ សុំឲ្យព្រះជាម្ចាស់ជួយអ្នកឲ្យអត់ទោសឲ្យបានលឿន និងមានសេចក្តីសប្បុរសក្នុងសេចក្តីមេត្តា។ ដោយធ្វើការនេះ យើងមិនត្រឹមតែអានព្រះបន្ទូលទេ ប៉ុន្តែយើងសុំព្រះជាម្ចាស់ធ្វើឲ្យវាកើតឡើងនៅក្នុងជីវិតរបស់យើង។

ត្រូវតែចងចាំថា រឿងដែលអស្ចារ្យបំផុតដែលយើងអាចធ្វើបានគឺការពឹងផ្អែក និងដាក់ការទុកចិត្តរបស់យើងនៅក្នុងព្រះជាម្ចាស់!

# ជំពូក ២០

## ការទុកចិត្តព្រះជាម្ចាស់ដើម្បីផ្លាស់ប្តូរមនុស្ស

*ចូររៀនផ្តល់តម្លៃមនុស្សជាទីដែលពួកគេជា មិនមែនទីដែលអ្នកចង់ឲ្យពួកគេក្លាយទៅជានោះទេ។*

*លោក ចន ម៉ាកស្វែល*

ខ្ញុំគិតថារឿងមួយដែលងាយស្រួលបំផុតនៅក្នុងពិភពលោកសម្រាប់មនុស្សជាតិធ្វើ គឺការស្វែងរកកំហុសគ្នាទៅវិញទៅមក តែវាក៏ជារឿងមួយក្រៀមក្រំបំផុតដែរ! យើងទាំងអស់គ្នាតែងមានកំហុស ហើយនៅពេលដែលយើងព្យាយាមផ្លាស់ប្តូរអ្នកដទៃបែរជាធ្វើឲ្យយើងមិនដឹងថាខ្លួនយើងត្រូវផ្លាស់ប្តូរទៅវិញ។

មានតែព្រះជាម្ចាស់ទេដែលផ្លាស់ប្តូរមនុស្សបានដោយពិតប្រាកដនិងមានប្រសិទ្ធភាព ព្រោះការផ្លាស់ប្តូរ គឺជាអ្វីមួយដែលត្រូវតែសម្រេចពីក្នុងចេញមកក្រៅ។ ត្រូវផ្លាស់ប្តូរដួងចិត្តជាមុន ដើម្បីអាចឲ្យអាកប្បកិរិយារបស់មនុស្សផ្លាស់ប្តូរបានដោយពិតប្រាកដ ហើយមានតែព្រះជាម្ចាស់ទេដែលអាចផ្តល់ដួងចិត្តថ្មីដល់យើង។ នៅក្នុងគម្ពីរអេសេគាល៣៦:២៦ បានសរសេរថា៖« *អញនឹងឲ្យឯងមានចិត្តថ្មី ហើយនឹងដាក់វិញ្ញាណថ្មីនៅក្នុងឯងដែរ អញនឹងដកចិត្តដែលរឹងដូចថ្ម ពីរូបសាច់ឯងចេញ រួចនឹងឲ្យមានចិត្តជាសាច់វិញ*» ។ នោះមានន័យយ៉ាងសាមញ្ញថា ព្រះជាម្ចាស់នឹងផ្តល់ដួងចិត្តនិងវិញ្ញាណថ្មីដល់យើង និងយកដួងចិត្តរឹងរូស រឹងដូចថ្មចេញពីយើង ហើយផ្តល់មកវិញនូវដួងចិត្តដែលឆ្លើយតបទៅនឹងបំណងព្រះហឫទ័យ និងការប៉ះពាល់របស់ព្រះអង្គ។ បើគ្មានការផ្លាស់ប្តូរនេះទេ នឹងមិនមានក្តីសង្ឃឹមច្រើនសម្រាប់មនុស្សក្នុងការស្រឡាញ់គ្នាទៅវិញទៅមក និងការរស់នៅជាមួយគ្នាដោយសន្តិភាពឡើយ។

ប្រហែលជានៅក្នុងជីវិតរបស់អ្នក អ្នកមាននរណាម្នាក់ ជាមនុស្សដែលអ្នកចង់ឲ្យគេផ្លាស់ប្តូរ។ អាចជាប្តី ឬប្រពន្ធ ជាកូន ជាឪពុកម្តាយ ជាសាច់ញាតិ ជាមិត្តភ័ក្តិ ឬជាអ្នកធ្វើការជាមួយអ្នក។ មនុស្សនឹងមិនផ្លាស់ប្តូរទេបើគេមិនចង់ផ្លាស់ប្តូរ។ ដូច្នេះជំហានដំបូង គឺត្រូវអធិស្ឋានឲ្យពួកគេ សុំឲ្យព្រះជាម្ចាស់ផ្តល់ឲ្យពួកគេប្រឈមមុខនឹងសេចក្តីពិតអំពីអាកប្បកិរិយារបស់ពួកគេ និងមានបំណងក្នុងការផ្លាស់ប្តូរ។ រឿងមួយ

ទៀតដែលអ្នកអាចធ្វើបាន ក្រោយពីនោះ គឺធ្វើជាគំរូល្អសម្រាប់ពួកគេ និងសំឡឹងលើនិស្ស័យល្អរបស់ពួកគេជាជាងនិស្ស័យដែលអ្នកមិនចូលចិត្ត។

## *អធិស្ឋានដោយបន្ទាបខ្លួន*

ការអធិស្ឋានដើម្បីឲ្យអ្នកដទៃផ្លាស់ប្តូរត្រូវធ្វើដោយការបន្ទាបខ្លួន បើមិនដូច្នោះទេ យើងអាចធ្លាក់ទៅក្នុងអន្ទាក់ដូចអ្នកដែលយើងគិតថាគេកំពុងមានបញ្ហា។១កូរិនថូស ១០:១២ *«បានជាអ្នកណាដែលស្មានថាខ្លួនឈរនោះត្រូវប្រយ័ត្នក្រែងលោដួល»*។ ខ្ញុំតែងតែអធិស្ឋានថា៖

> «ព្រះវរបិតាអើយខ្ញុំសូមឲ្យព្រះអង្គផ្លាស់ប្តូរ__________បើគេពិតជាត្រូវការការផ្លាស់ប្តូរមែន។ បើគេមិនត្រូវការការផ្លាស់ប្តូរទេ សូមព្រះអង្គផ្លាស់ប្តូរដួងចិត្តរបស់ខ្ញុំ ហើយសូមឲ្យខ្ញុំឃើញពីបញ្ហារបស់ខ្ញុំវិញ ដែលគិតថាគេមានបញ្ហា។ ទូលបង្គំក៏សុំឲ្យព្រះអង្គផ្លាស់ប្តូរទូលបង្គំនូវអ្វីដែលទូលបង្គំត្រូវផ្លាស់ប្តូរដែរ។ អាម៉ែន!»

មានរឿងជាច្រើនដែលយើងគិតថាជាអំពើបាប ព្រោះព្រះបន្ទូលបានសរសេរយ៉ាងច្បាស់ ប៉ុន្តែមានរឿងផ្សេងទៀតជាច្រើនដែលមាននៅក្នុងមនុស្ស ហើយយើងមិនចូលចិត្តដោយគ្មានមូលហេតុ។ នៅពេលដែលនរណាម្នាក់មិនដូចយើង ឬមានគំនិតខុសពីយើង នោះយើងងាយក្នុងការឃើញកំហុសនៅក្នុងពួកគេណាស់ ប៉ុន្តែបើយើងបើកចិត្តឲ្យទូលាយវាប្រសើរជាង ត្រូវដឹងមនុស្សគ្រប់គ្នាពិតជាមានតំលៃ បើយើងស្វែងរកតំលៃរបស់អ្នកនោះ។

ឧបសគ្គមួយដ៏ធំបំផុតនៅក្នុងជីវិតរបស់យើងគឺការស៊ាំជាមួយមនុស្ស និងរឿងដែលយើងមិនចូលចិត្តពួកគេ! យើងចង់ឲ្យពួកគេផ្លាស់ប្តូរ ដើម្បីជាប្រយោជន៍របស់យើង ប៉ុន្តែយើងកម្រដឹងថាតើអ្វីទៅការពិតនៃឥរិយាបថអាត្មានិយម យ៉ាងហោចណាស់ខ្ញុំក៏ធ្លាប់ជាមនុស្សបែបនោះដែរ។ នៅក្នុងអំណួតរបស់យើង យើងសន្មតថាផ្លូវនិងអំពើរបស់យើងតែងតែត្រឹមត្រូវ ហើយឲ្យមនុស្សទាំងអស់នៅក្នុងសកលលោកនេះធ្វើតាមរបៀបរបស់យើង។ នេះជាឥរិយាបថដែលបណ្តាលឲ្យមានការលែងលះ និងបរាជ័យក្នុងទំនាក់ទំនងរបស់គ្រួសារជាច្រើន ក៏ដូចជានៅក្នុងជីវិតមនុស្សទូទៅ។

ជំហានដំបូងក្នុងការបន្ទាបខ្លួន គឺគ្រប់គ្នាគួរតែទទួលស្គាល់ថា ប្រហែលជាយើងមានកំហុសច្រើនជាងអ្នកដែលយើងកំពុងថ្កោលទោសផង។ យើងមើលមិនឃើញ

កំហុសរបស់ខ្លួនឯង ពេលខ្លះដោយសារយើងវឹកវរខ្លាំងជាមួយនឹងគំនិតដែលយើងគិតថាអ្នកដទៃមានកំហុស។ យើងក៏ប៉ុនប៉ងដោះសារខ្លួន នៅពេលដែលអាកប្បកិរិយារបស់យើងខុសឆ្គងប៉ុន្តែយើងមិនបានផ្តល់ក្តីមេត្តាដូចគ្នានេះដល់អ្នកដ៏ទៃឡើយ។

ក្តីរន្ធត់ដ៏ធំមួយនៅក្នុងជីវិតរបស់ខ្ញុំកើតឡើង នៅពេលដែលព្រះជាម្ចាស់ណែនាំខ្ញុំឲ្យស្គាល់ខ្លួនឯង! នៅពេលដែលខ្ញុំកំពុងអធិស្ឋានឲ្យ ដេវ ផ្លាស់ប្តូរពេលនោះព្រះជាម្ចាស់បានបង្អាក់សេចក្តីអធិស្ឋានរបស់ខ្ញុំ។ តើអ្នកអាចស្រមៃចេញទេ នៅពេលខ្ញុំបានព្យាយាមអធិស្ឋានហើយព្រះជាម្ចាស់បានបង្អាក់ខ្ញុំ! ឥឡូវនេះពេលខ្ញុំគិតឡើងវិញ ខ្ញុំខ្មាសអៀនពីភាពល្ងីល្ងើដែលខ្ញុំធ្លាប់មាន ប៉ុន្តែនៅពេលនោះខ្ញុំមិនដឹងអ្វីសោះ។ ព្រះជាម្ចាស់បានបង្អាក់ខ្ញុំនៅពេលដែលខ្ញុំព្យាយាមអធិស្ឋានឲ្យ ដេវ ហើយព្រះអង្គបានប្រាប់ខ្ញុំថា ដេវមិនមែនជាបញ្ហានៅក្នុងទំនាក់ទំនងរបស់យើងឡើយ តែជាខ្ញុំទៅវិញទេ។ ធ្វើឲ្យខ្ញុំរន្ធត់មែនទែន! នៅក្នុងវគ្គបីថ្ងៃបន្ទាប់ព្រះជាម្ចាស់បានធ្វើឲ្យខ្ញុំប្រឈមមុខជាមួយនឹងសេចក្តីពិតដែលធ្លាប់នៅជាប់ជាមួយខ្ញុំកន្លងមក។ ព្រះអង្គបានបើកសំដែងពីភាពអាត្មានិយមនិងការយកតែចិត្តខ្លួនឯង ដែលខ្ញុំធ្លាប់មានពីមុនមកថាតើខ្ញុំជាមនុស្សដែលពិបាករស់នៅជាមួយខ្លាំងប៉ុណ្ណា និងពីរបៀបដែលខ្ញុំអាចរីករាយបាននៅពេលដែលខ្ញុំធ្វើអ្វីដែលខ្ញុំចង់ធ្វើ។ ក្នុងរយៈពេលបីថ្ងៃនោះ ខ្ញុំយំស្ទើរតែគ្រប់ពេល ប៉ុន្តែវាជាការចាប់ផ្តើមក្នុងការផ្លាស់ប្តូរដ៏ល្អខ្លះនៅក្នុងជីវិតរបស់ខ្ញុំ។

ក្តីរន្ធត់ដ៏ធំមួយនៅក្នុងជីវិតរបស់ខ្ញុំកើតឡើងនៅពេលដែលព្រះជាម្ចាស់ណែនាំខ្ញុំឲ្យស្គាល់ខ្លួនឯង!

## *អំណាចនៃសេចក្តីមេត្តាករុណា*

សេចក្តីមេត្តាករុណាតែងតែយកឈ្នះលើការថ្កោលទោស (មើល យ៉ាកុប២:១៣)។ ពាក្យមួយទៀតអាចនិយាយថា សេចក្តីមេត្តាករុណា គឺជាការមួយអស្ចារ្យជាងការថ្កោលទោស។ ខ្ញុំឆ្ងល់ថា មនុស្សយើងភាគច្រើន អាចផ្តល់ក្តីមេត្តាករុណាដល់ខ្លួនឯងច្រើន ទោះបីយើងដឹងថាយើងមានគុណវិបត្តិ មានភាពកំសោយ និងកំហុសជាច្រើនក៏ដោយ។ នៅពេលដែលយើងដឹងថាព្រះជាម្ចាស់ផ្តល់ក្តីមេត្តាករុណាយ៉ាងច្រើនជារៀងរាល់ថ្ងៃដល់យើង នោះយើងមានចិត្តសប្បុរសក្នុងការផ្តល់ក្តីមេត្តាដល់អ្នកដទៃ។ នេះជារឿងព្រេង ដ៏ល្អអំពីស្តេចដែលមិនចង់យល់អំពីព្រះគុណ ចំពោះអ្នកថែសួនដែលបានធ្វើ៖

មានស្តេចមួយអង្គមានចំការផ្លែឈើដ៏ធំមួយ។ គាត់បានដាំដើមឈើហូបផ្លែជា

ច្រើនមុខនៅទីនោះ។ គាត់បានជួលអ្នកថៃសួនជំនាញម្នាក់ឲ្យថែរក្សាដើមឈើទនោះ

រាល់ថ្ងៃគាត់អាចបេះផ្លែទុំ និងផ្លែទុំជោរពីដើមឈើផ្សេងៗ ហើយប្រមូលដាក់នៅក្នុងកន្ត្រក។ រៀងរាល់ព្រឹកអ្នកថៃសួនអាចឲ្យផ្លែឈើទាំងនោះទៅដល់ស្តេចនៅពេលដែលស្តេចបើកសាវនាការ។

ថ្ងៃមួយអ្នកថៃសួនបានបេះផ្លែផៃរី ហើយបានយកទៅថ្វាយស្តេច។ នៅពេលនោះស្តេចកំពុងមានអារម្មណ៍មិនល្អ។ នៅពេលដែលទ្រង់រើសផ្លែផៃរីទៅភ្លក្ស វាមានរស់ជាតិជូរ។ ដូច្នេះទ្រង់បានជះកំហឹងទៅលើអ្នកថៃសួន។ ទ្រង់បានជះផ្លែផៃរីនោះទៅលើអ្នកថៃសួនទាំងកំហឹង។ វាបានត្រូវក្បាលរបស់អ្នកថៃសួន ប៉ុន្តែអ្នកថៃសួនបាននិយាយថា «ព្រះជាម្ចាស់ពេញដោយព្រះទ័យមេត្តាករុណា»។

ស្តេចបានសួរថា «អ្នកច្បាស់ជាឈឺចាប់និងខឹង តើហេតុអ្វីបានជាអ្នកនិយាយថា «ព្រះជាម្ចាស់ពេញដោយព្រះទ័យមេត្តាករុណា» ទៅវិញ?

អ្នថៃសួនបាននិយាយថា៖ «បពិតព្រះករុណា ទូលបង្គំចង់យកម្នាស់មកថ្វាយព្រះអង្គនៅថ្ងៃនេះ ប៉ុន្តែទូលបង្គំបានប្តូរគំនិត។ បើព្រះករុណាគប់ម្នាស់មកទូលបង្គំវិញទូលបង្គំប្រហែលជារបួសធ្ងន់ហើយមើលទៅ។ ព្រះជាម្ចាស់ពេញដោយព្រះហឫទ័យមេត្តាករុណា ដែលបានផ្លាស់ប្តូរគំនិតរបស់ទូលបង្គំ»។

អ្នកថៃសួនបានរៀនទុកចិត្តព្រះជាម្ចាស់ ទោះបីជាមានរឿងហាក់បីដូចជាមិនយុត្តិធម៌ចំពោះគាត់ក៏ដោយ។ រឿងអាចកើតឡើងអាក្រក់ជាងអ្វីដែលបានកើតឡើងទៅទៀងបើគ្មានសេចក្តីមេត្តាករុណាពីព្រះជាម្ចាស់ទេ!

យើងគ្មានមូលហេតុណាផ្សេងក្នុងការផ្តល់ក្តីមេត្តាករុណាដល់អ្នកដទៃ ក្រៅពីការពិតដែលព្រះជាម្ចាស់បានធ្វើ និងបានបង្ហាញក្តីមេត្តាករុណាដល់យើងឡើយ។ ព្រះអង្គរំពឹងថាយើងនឹងផ្តល់ដល់អ្នកដទៃនូវអ្វីដែលព្រះអង្គបានផ្តល់ដល់យើងដោយព្រះទ័យសប្បុរស។ ព្រះអង្គអត់ទោសដល់យើងហើយរំពឹងថាយើងនឹងអត់ទោសដល់អ្នកដទៃ ព្រះអង្គស្រឡាញ់យើងដោយគ្មានលក្ខខ័ណ្ឌ ហើយព្រះអង្គរំពឹងថាយើងនឹងស្រឡាញ់អ្នកដទៃដូចគ្នា ព្រះអង្គផ្តល់ព្រះគុណចំពោះបរាជ័យរបស់យើង ហើយព្រះអង្គក៏រំពឹងថាយើងនឹងផ្តល់ក្តីមេត្តាដល់អ្នកដទៃដែរ។ ព្រះអង្គម្ចាស់មិនរំពឹងឲ្យយើងថ្វាយនូវអ្វីដែលយើងមិនមាននោះឡើយ ដូច្នេះព្រះអង្គបំពេញដល់យើងនូវរបស់ល្អគ្រប់យ៉ាងដែលយើងត្រូវការ ធ្វើឲ្យយើងអាចរីករាយជាមួយជីវិតរបស់យើង និងដំណាងឲ្យព្រះអង្គយ៉ាងល្អ។ ខ្ញុំអាចស្រមៃថាស្តេចដែលគ្មានក្តីមេត្តាបានគិតអស់រយៈពេលយ៉ាងយូរ ពីឥរិយាបថពេញដោយក្តីមេត្តាដែលអ្នកថៃសួនមាន! នៅពេលដែលយើងផ្តល់ក្តីមេត្តាដល់មនុស្ស ពួកគេនឹងមានការអស្ចារ្យនៅក្នុងចិត្ត ជាពិសេស គឺនៅ

ពេលដែលពួកគេដឹងច្បាស់ថាពួកគេត្រូវទទួលពិន័យ។

ខ្ញុំចង់សុំឲ្យអ្នកចំណាយពេលពីរបីនាទី ហើយសញ្ជឹងគិតថា តើនៅក្នុងជីវិតរបស់អ្នកមានអ្នកណាដែលអ្នកត្រូវតែផ្តល់ក្តីមេត្តាឲ្យឬទេ។ ក្តីមេត្តា គឺជាអំណោយ។ វាមិនអាចសន្សំ ឬជាការដែលមនុស្សសមនឹងទទួលឡើយ ប៉ុន្តែនៅពេលដែលគេបានទទួលដោយឥតគិតថ្លៃ គេនឹងមានបទពិសោធន៍ជាមួយនឹងអំណាចនៃក្តីស្រឡាញ់របស់ព្រះជាម្ចាស់នៅក្នុងការអនុវត្តជាក់ស្តែងដែលនឹងផ្លាស់ប្តូរពួកគេ។

ព្រះជាម្ចាស់បានផ្តល់ព្រះគុណដល់ ដេវ ហើយនិងខ្ញុំក្នុងការអត់ទោសដល់ឪពុករបស់ខ្ញុំដែលគាត់បានរំលោភបំពានដល់ខ្ញុំកាលពីខ្ញុំនៅក្មេង ហើយយើងផ្តល់ក្តីមេត្តាដល់គាត់ក្នុងពេលគាត់ចាស់ និងថែរក្សាគាត់រហូតដល់គាត់លាចាកលោកនេះទៅ។ ខ្ញុំចាំពីអ្វីដែលគាត់បាននិយាយមកកាន់យើងថា «មនុស្សភាគច្រើនប្រហែលជាចង់សំឡាប់ប៉ាដោយសារតែអំពើដែលប៉ាប្រព្រឹត្ត ប៉ុន្តែកូនៗបែរជាធ្វើល្អចំពោះប៉ាទៅវិញ»! គាត់ពិតជាបានទទួលព្រះយេស៊ូបីឆ្នាំមុនគាត់ស្លាប់ ហើយខ្ញុំពិតជាអរព្រះគុណព្រះជាម្ចាស់ចំពោះរឿងនេះ។ ព្រះអង្គបានបង្ហាញក្តីមេត្តាដល់គាត់តាមរយៈយើង។ ព្រះអង្គធ្វើការតាមរយៈ និងចាប់ដៃគូរជាមួយមនុស្ស ហើយ ព្រះអង្គចង់ប្រើប្រាស់យើងរាល់គ្នាដោយរបៀបសាមញ្ញ។ មានមនុស្សជាច្រើននៅក្នុងពិភពលោកដែលបានបាត់បង់ និងមានការឈឺចាប់។ ពួកគេអាចសាកល្បងជាមួយសាសនាមួយចំនួន និងមានការបាក់ទឹកចិត្ត ប៉ុន្តែបើពួកគេជួបព្រះយេស៊ូ ពួកគេនឹងមិននៅដដែលឡើយ។ ប្រហែលជាព្រះអង្គអាចជួបជាមួយនរណាម្នាក់នៅក្នុងជីវិតរបស់អ្នកតាមរយៈគំរូជីវិតអ្នក។ ចូរប្តូរផ្តាច់បង្ហាញដល់មនុស្សអំពីព្រះយេស៊ូថាព្រះអង្គជាអ្នកណា ជាជាងគ្រាន់តែព្យាយាមប្រាប់ពួកគេ។ ពាក្យសំដីអាចអស់តម្លៃ និងគ្មានអំណាចបើគ្មានសកម្មភាពដើម្បីជាការស្តារឡើងវិញ។

អស់រយៈពេលជាច្រើនឆ្នាំ ដែលខ្ញុំបានឃើញមនុស្សទាំងឡាយព្យាយាមប្រាប់ឪពុករបស់ខ្ញុំឲ្យគាត់ផ្លាស់ប្តូរអាកប្បកិរិយារបស់គាត់ ព្រោះគាត់អាត្មានិយម និងពោលពាក្យកំរោលស្ទើរតែពេញមួយជីវិតរបស់គាត់ ប៉ុន្តែទោះបីជាមាននរណានិយាយទៅកាន់គាត់ច្រើនយ៉ាងណាក្តី ក៏មិនមានកើតផលល្អឡើយ។ ទោះជាយ៉ាងណាក៏ដោយ នៅពេលដែលគាត់មានបទពិសោធជាមួយក្តីមេត្តារបស់ព្រះជាម្ចាស់ ដួងចិត្តរឹងរូសរបស់គាត់ចាប់ផ្តើមរលាយ ហើយព្រះជាម្ចាស់អាចផ្លាស់ប្តូរគាត់បាន។ ក្រោយពេលដែលគាត់បានទទួលព្រះយេស៊ូជាព្រះសង្គ្រោះរបស់គាត់ គាត់ក៏បានជ្រមុជទឹក ហើយគាត់ក៏បានផ្លាស់ប្តូរយ៉ាងពិតប្រាកដ។ គាត់អាចរស់នៅបានតែបីឆ្នាំទៀតប៉ុណ្ណោះ ប៉ុន្តែអរព្រះគុណព្រះជាម្ចាស់ឥឡូវនេះគាត់នៅឯស្ថានសួគ៌។

## *សេរីភាពក្នុងការជ្រើសរើស*

ព្រះជាម្ចាស់មិនបានបង្ខំមនុស្សឲ្យធ្វើអ្វីដែលប្រឆាំងនឹងបំណងរបស់ពួកគេទេ ហើយយើងក៏មិនគួរព្យាយាមធ្វើវាដែរ។ វាមិនខុសទេក្នុងការព្យាយាមនិយាយទៅនរណាម្នាក់អំពីឥរិយាបថខុសឆ្គងរបស់ពួកគេដែលធ្វើឲ្យគេឲ្យអ្នក ឬក៏អ្នកដទៃទៀតឈឺចាប់ តែបើគេបដិសេធពាក្យសំដីរបស់យើង នោះយើងខ្ជះខ្ជាយពេលវេលារបស់យើង បើយើងនៅតែព្យាយាមបញ្ចុះបញ្ចូលគេឲ្យផ្លាស់ប្តូរ។ ខ្ញុំធ្លាប់បានឃើញការផ្លាស់ប្តូរដ៏អស្ចារ្យនៅក្នុងមនុស្សអស់រយៈពេលជាច្រើនឆ្នាំ ប៉ុន្តែមិនមែនដោយសារតែខ្ញុំនិយាយទៅពួកគេឲ្យគេផ្លាស់ប្តូរនោះទេ។ ព្រះជាម្ចាស់ធ្វើការផ្លាស់ប្តូរមនុស្សនៅពេលដែលយើងអធិស្ឋានឲ្យគេ!

ព្រះបន្ទូលរបស់ព្រះអង្គចែងថា បើស្ត្រីម្នាក់មានប្តីដែលមិនជឿ នាងអាចយកឈ្នះគាត់បានដោយអាកប្បកិរិយាល្អ តែមិនមែនដោយពាក្យសំដីរបស់នាងឡើយ (មើល ១ពេត្រុស៣:១)។ ខ្ញុំច្បាស់ណាស់ថានៅពេលដែលស្ត្រីនោះព្យាយាមបញ្ចុះបញ្ចូលប្តីនាងឲ្យផ្លាស់ប្តូរ គាត់នឹងកាន់តែមិនចង់ផ្លាស់ប្តូរ! ព្រះជាម្ចាស់ពូកែរបញ្ចុះបញ្ចូលមនុស្សឲ្យគេធ្វើ ឬមិនឲ្យគេធ្វើរឿងផ្សេងៗជាងយើងរាល់គ្នា។

ត្រូវតែមានការប្តូរផ្តាច់ក្នុងការអធិស្ឋាន ជាជាងព្យាយាមផ្លាស់ប្តូរមនុស្ស ហើយអ្នកនឹងឃើញលទ្ធផលល្អប្រសើរច្រើនជាង។

## *ការស្មាន*

អំពើបាបនៃការស្មាន គឺជាអំពើបាបដែលយើងកំរបានឮ ប៉ុន្តែយើងត្រូវតែឮពីវាឲ្យបានច្រើន។ ការស្មាន(ការសន្និដ្ឋាន) កើតចេញពីដួងចិត្តអំណួត ហើយមាននរណាម្នាក់ស្មានអ្វីមួយ គេនឹងធ្វើការសម្រេចចិត្តទាំងពួកគេគ្មានសិទ្ធិក្នុងការសម្រេច និងធ្វើអ្វីមួយដែលគេមិនបានទទួលការអនុញ្ញាតិឲ្យធ្វើ។

បុគ្គលិកដែលពូកែស្មានកំរបានឡើងឋានៈណាស់ កូនដែលពូកែស្មាននឹងបញ្ចប់ដោយបាត់បង់អភ័យឯកសិទ្ធហើយបុត្ររបស់ព្រះជាម្ចាស់ដែលពូកែស្មានត្រូវតែមានការផ្លាស់ប្រែមុននឹងពួកគេអាចធ្វើការឲ្យព្រះជាម្ចាស់ដោយមានប្រសិទ្ធភាព។ ការធ្វើការសម្រេចចិត្តដោយខ្លួនយើង ដោយមិនយល់ដល់ព្រះជាម្ចាស់ គឺជាការស្មាន។

*ឥឡូវនេះ ឯពួកអ្នកដែលថា ថ្ងៃនេះ ឬថ្ងៃស្អែកយើងនឹងទៅឯក្រុងណា*

*មួយ ហើយនិងនៅស្រុកនោះអស់១ឆ្នាំ ដើម្បីនឹងរកស៊ីឲ្យបានចំណេញ អ្នករាល់គ្នាមិនដឹងជានឹងកើតមានយ៉ាងណាដល់ថ្ងៃស្អែកទេ ដ្បិតជីវិតអ្នករាល់គ្នាជាអ្វី គឺជាចំហាយទឹកទេតើ ដែលឃើញតែ១ភ្លែត រួចបាត់ទៅ គួរតែបាននិយាយដូច្នេះវិញថា បើយើងរស់នៅ ហើយព្រះអម្ចាស់ទ្រង់សព្វព្រះហឫទ័យ នោះយើងនឹងធ្វើការនេះ ឬការនោះ តែឥឡូវនេះ អ្នករាល់គ្នាមានសេចក្តីអំនួត អំពីពាក្យអួតអាងរបស់ខ្លួនដូច្នោះ ហើយគ្រប់ទាំងសេចក្តីអំនួតយ៉ាងនោះ សុទ្ធតែអាក្រក់ទាំងអស់។*

យ៉ាកុប ៤:១៣-១៦

ការធ្វើសកម្មភាពដោយមិនបានគិតពីព្រះជាម្ចាស់ មិនបានអធិស្ឋាន និងមិនបានទុកចិត្តផ្លូវរបស់ព្រះអង្គ គឺមិនមែនជាអ្វីមួយដែលស្ពានសួគ៌អបអរសាទរជាមួយឡើយ។ វាបង្ហាញពីអរិយាបថនៃអំណួតដែលយើងត្រូវតែផ្លាស់ប្តូរ។

ការសម្រេចចិត្តថា មនុស្សម្នាក់ត្រូវផ្លាស់ប្តូរ ហើយព្យាយាមធ្វើការផ្លាស់ប្តូរពួកគេ គឺជាការស្មាន។ ដូច្នេះហើយបានជាខ្ញុំទទូចថា ទោះបីជាពេលយើងអធិស្ឋានឲ្យនរណាម្នាក់ផ្លាស់ប្តូរ យើងត្រូវតែធ្វើដោយឥរិយាបថបន្ទាបខ្លួន ដោយដឹងថាយើងក៏មានចំណុចជាច្រើនដែលត្រូវផ្លាស់ប្តូរដែរ។

ខ្ញុំពិតជាមានអំណរណាស់នៅពេលដែលព្រះជាម្ចាស់អត់ធ្មត់ជាមួយខ្ញុំ ប៉ុន្តែជាច្រើនដងខ្ញុំបានសុំឲ្យព្រះអង្គអត់ធ្មត់ជាមួយអ្នកដទៃ។ យើងមិនអាចយល់គ្រប់ពេលបានទេថា តើហេតុអ្វីបានជាព្រះជាម្ចាស់មិនផ្លាស់ប្តូរមនុស្សដែលប្រព្រឹត្តជាមួយយើងដោយមិនប្រក្រតី។ បើតាមសំដីលោក ប៉ូល ព្រះជាម្ចាស់បានបង្ហាញសេចក្តីសប្បុរស និងពន្យារពេលនៃការកាត់ទោសដើម្បីឲ្យមនុស្សប្រែចិត្ត(មើល រ៉ូម២:៤)។ បើព្រះជាម្ចាស់អាចបង្ហាញក្តីមេត្តា និងទុកឲ្យមនុស្សមានឥរិយាបថមិនល្អអាចប្រែចិត្តបាន ប្រហែលជាយើងក៏គួរតែធ្វើតាមព្រះអង្គដែរ។

ខ្ញុំធ្លាប់មានថៅហ្វាយម្នាក់ ដែលគាត់ប្រព្រឹត្តជាមួយបុគ្គលិកដោយមិនប្រក្រតីដែរ។ គាត់មិនបានកោតសរសើរចំពោះការខិតខំប្រឹងប្រែងធ្វើការរបស់បុគ្គលិកទេ មិនបានបង់ប្រាក់ដល់ពួកគេឲ្យបានត្រឹមត្រូវឡើយគាត់ឆាប់ស្តីបន្ទោសចំពោះកំហុសតិចតួច ហើយមិនចេះគោរពអ្នកដទៃទៀតផង។ គាត់ជាគ្រិស្តបរិស័ទ ហើយគាត់គួរតែដឹងច្រើនជាងនេះ ហើយខ្ញុំត្រូវតែទទួលស្គាល់ថាខ្ញុំធ្លាប់សួរព្រះជាម្ចាស់ថាតើហេតុអ្វីបានជាព្រះអង្គអនុញ្ញាតឲ្យគាត់នៅតែមានឥរិយាបថមិនល្អ ហើយហេតុអ្វីបានជាព្រះអង្គមិនធ្វើអ្វីមួយដើម្បីបញ្ឈប់គាត់។ មានតែមនុស្សដែលពូកែស្មានប៉ុណ្ណោះ

ដែលសួរព្រះជាម្ចាស់! ប្រហែលជាខ្ញុំអាចអធិស្ឋានល្អជាងនេះថា «ព្រះអង្គម្ចាស់អើយ ទូលបង្គំដឹងថាព្រះអង្គកំពុងធ្វើអ្វីហើយទូលបង្គំសូមអធិស្ឋានថាគាត់នឹងស្តាប់ព្រះអង្គ និងធ្វើអ្វីៗដែលត្រឹមត្រូវ។ គាត់បានធ្វើឲ្យទូលបង្គំឈឺចាប់ តែទូលបង្គំដឹងថាអាកប្បកិរិយារបស់គាត់ធ្វើឲ្យព្រះអង្គឈឺចាប់ខ្លាំងជាងទូលបង្គំទៅទៀត។ អរគុណព្រះអង្គសម្រាប់ការអត់ធ្មត់ដ៏អស្ចារ្យដែលព្រះអង្គមានសម្រាប់យើងរាល់គ្នា»។

ជារឿងក្រៀមក្រំមួយ ដែលបុរសនោះមិនផ្លាស់ប្តូរឡើយរហូតដល់ព្រះជាម្ចាស់បានដកគាត់យកទៅ។ ជាលទ្ធផលជីវិតរបស់គាត់មិនបានផ្លាស់ប្តូរតាមអ្វីដែលគាត់គួរស្តាប់ និងចុះចូលជាមួយព្រះជាម្ចាស់ទេ។ រឿងនេះធ្វើឲ្យខ្ញុំក្រៀមក្រំនៅពេលដែលខ្ញុំគិតពីវា ឥឡូវនេះខ្ញុំពិតជាប្រាថ្នាថា នៅពេលនោះខ្ញុំគួរតែចំណាយពេលច្រើនជាងនេះក្នុងការអធិស្ឋានសម្រាប់បុរសនោះជាជាងការមិនសប្បាយចិត្តជាមួយគាត់ និងព្រួយបារម្ភអំពីអ្វីដែលគាត់បានធ្វើដាក់ខ្ញុំ។

នៅពេលដែលមនុស្សនៅក្នុងជីវិតរបស់អ្នកមិនរស់នៅតាមតែអ្វី ដែលពួកគេគួររស់នៅ ហើយអាកប្បកិរិយារបស់ពួកគេធ្វើឲ្យយើង និងអ្នកដទៃទៀតឈឺចាប់ យើងត្រូវតែអធិស្ឋានដោយចិត្តព្យាយាមសម្រាប់ពួកគេ។ អធិស្ឋានដើម្បីឲ្យពួកគេស្តាប់ព្រះជាម្ចាស់មុនពេលអ្វីៗយឺតពេល។ ប្រភេទនៃឥរិយាបថប្រកបដោយក្តីមេត្តានេះ គឺប្រសើរជាងការថ្កោលទោសច្រើនណាស់! លោក ដេតរិច បុនហូហ្វ័របាននិយាយថា «ដោយសារតែការថ្កោលទោសអ្នកដទៃ ធ្វើឲ្យយើងមើលមិនឃើញពីភាពអាក្រក់របស់ខ្លួនឯង ហើយការគិតពីអំពើល្អរបស់អ្នកដទៃក៏ដូចជាបង្ហាញថាយើងជាមនុស្សបែបនោះដែរ»!

យើងនឹងមានអំណរជាមួយនឹងសន្តិភាពច្រើននៅក្នុងជីវិតរបស់យើង បើយើងអធិស្ឋានសម្រាប់អ្នកដទៃជាជាងព្យាយាមផ្លាស់ប្តូរពួកគេ ហើយព្រះជាម្ចាស់នឹងធ្វើអ្វីដែលព្រះអង្គអាចធ្វើបាន។ នៅពេលដែលយើងរង់ចាំការផ្លាស់ប្តូរដែលយើងប្រាថ្នាកើតឡើងនៅក្នុងជីវិត ត្រូវឲ្យប្រាកដថា យើងនៅតែស្មោះត្រង់ចំពោះអ្វីៗគ្រប់យ៉ាងដែលព្រះជាម្ចាស់ឲ្យយើងធ្វើ។ ចូរឲ្យយើងធ្វើជាមនុស្សចេះបត់បែន និងជាមនុស្សដែលអាចឲ្យព្រះហស្តរបស់ព្រះអង្គសូនបាន ហើយសុំឲ្យព្រះអង្គធ្វើឲ្យយើងក្លាយជាមនុស្សដែលសាកសមឲ្យព្រះអង្គប្រើ។

# ជំពូក ២១

# ការដោះស្រាយជាមួយការសង្ស័យ

*ចូរកុំដកកប់ក្នុងការសង្ស័យអ្វីដែលអ្នកបានដាំក្នុងសេចក្តីជំនឿទៅ ។*
អេលីស្សាប៊ែត អេលីអូត

វាអាចជាការងាយស្រួលក្នុងការទុកចិត្តព្រះជាម្ចាស់ ប្រសិនបើការសង្ស័យមិនបានចូលមកសួរសុខទុក្ខយើង ប៉ុន្តែវាមិនអាចទៅរួចនោះទេ ដូច្នេះយើងត្រូវរៀបចំដំណោះស្រាយជាមួយវា។ វាជាការងាយស្រួលដើម្បីចង់បានសម្រាប់ការមិនមានការប្រឆាំងណាមួយ ប៉ុន្តែវាមិនមែនជាការប្រាកដនិយមនោះទេ។ ប្រសិនបើមិនមានការល្បួង។ ប្រសិនបើមិនមានការភ័យខ្លាច។ ប្រសិនបើការសង្ស័យមិនបានចេញមក! ប៉ុន្តែពួកវាកំពុងដំណើរការទៅហើយ ពួកវានៅមិនទាន់មានបញ្ហា ជាញឹកញាប់យើងជាអ្នកអនុញ្ញាតឲ្យពួកវាកើតឡើង។ ព្រះជាម្ចាស់បានប្រាប់យើងថាឲ្យមានជំនឿនិងកុំមានការសង្ស័យឡើយ ហើយទ្រង់ក៏មិនដែលប្រាប់ទេថា ការសង្ស័យនឹងមិនមកសោះ មកសួរសុខទុក្ខយើងម្តងម្កាលនោះ។ ហេតុផលទាំងមូលដែលព្រះជាម្ចាស់ប្រាប់យើងមិនឲ្យសង្ស័យ គឺពីព្រោះទ្រង់ដឹងថាវានឹងមក ហើយទ្រង់ចង់ឲ្យយើងរួចរាល់ជាស្រេចដើម្បីដោះស្រាយជាមួយវាយ៉ាងរហ័សហើយត្រឹមត្រូវនៅពេលដែលវាកើតឡើង។

ថ្មីៗនេះខ្ញុំបានចាប់ផ្តើមធ្វើកម្មវិធីទូរទស្សន៍មួយទៅលើអ្វី ដែលខ្ញុំឆ្លើយទៅនឹងសំណួររបស់អ្នកទស្សនាអំពីការទុកចិត្ត។ ស្ត្រីម្នាក់បានផ្ញើសំណួរតាមរយៈវេបសាយរ៍របស់យើងអំពីការសង្ស័យ។ នាងបាននិយាយថា នាងព្យាយាមទុកចិត្តព្រះ នាងចង់ទុកចិត្តព្រះ ប៉ុន្តែនាងហាក់ដូចជាមិនអាចបំបាត់ការសង្ស័យដែលធ្វើឲ្យនាងឈឺចាប់នោះទេ ហើយនាងបានសួរខ្ញុំពីអ្វីដែលនាងអាចនឹងធ្វើបាន។

> *យើងអាចរៀនសង្ស័យការសង្ស័យរបស់យើង។*

ប្រហែលជាអ្នកមានសំណួរដូចគ្នាដែរ ខ្ញុំដឹងថា ខ្ញុំបានធ្វើវានៅពេលមួយ។ សេចក្តីទុកចិត្ត គឺថា យើងមិនអាចរក្សាការមកដល់នៃសេចក្តីសង្ស័យនិងការព្យាយាម

ដើម្បីលួចសេចក្តីជំនឿនិងទំនុកចិត្តរបស់យើងលើព្រះជាម្ចាស់បាននោះទេ។ ប៉ុន្តែ នៅពេលដែលការសង្ស័យមកដល់ យើងអាចជ្រើសរើសការមិនអនុញ្ញាតឲ្យវាមាន ឥទ្ធិពលមកលើយើងបាន។ យើងអាចរៀនសង្ស័យលើការសង្ស័យរបស់យើង!

នៅពេលដែលព្រះជាម្ចាស់ប្រាប់យើងមិនឲ្យធ្វើអ្វីមួយ ទ្រង់គឺមិនមែនប្រាប់យើង ថា យើងនឹងមិនទទួលការល្បួងឲ្យធ្វើវានោះទេ ឬ នឹងមិន*មានអារម្មណ៍* ដូចជាកំពុង ធ្វើវា ឬ ត្រូវការបដិសេធការធ្វើវានោះទេ។ ជាក់ស្តែងទ្រង់កំពុងប្រាប់យើងផ្ទុយមក វិញ។ ហេតុអ្វីប្រាប់យើងថា «កុំភ័យខ្លាច» ដែលយើងមានឱកាសនឹងភ័យខ្លាចនោះ? ហេតុអ្វីប្រាប់យើងថាមិនត្រូវចូលទៅក្នុងការល្បួង ទាំងដែលយើងកំពុងនឹងត្រូវបាន ល្បួង? ហេតុអ្វីប្រាប់យើងកុំឲ្យ សង្ស័យទាំងដែលយើងកំពុងនឹងមានឱកាសនឹង សង្ស័យនោះ?

ការមន្ទិលសង្ស័យនឹងមក ប៉ុន្តែយើងមិនត្រូវការ អនុញ្ញាតឲ្យវាធ្វើឲ្យយើងវង្វេងពី ទំនាក់ទំនងជានឹងព្រះបន្ទូលសន្យារបស់ព្រះជាម្ចាស់នោះទេ។

## *ឧទាហរណ៍ពីព្រះគម្ពីរ*

លោកអ័ប្រាហាំគឺជាឧទាហរណ៍ដ៏ល្អបំផុតមួយដែលខ្ញុំដឹង នៅពេលដែលយើងចង់ រៀនអំពីរបៀបដែលមនុស្សម្នាក់ នៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ដោះស្រាយ ការមន្ទិលសង្ស័យ។ លោកអ័ប្រាហាំបានទទួលសេចក្តីសន្យាពីព្រះជាម្ចាស់ដែល គាត់នឹងសារ៉ានឹងមានកូន។ តាមស្ថានភាពតាមធម្មជាតិរបស់គាត់គឺវាមិនអាចទៅរួច នោះទេ ពីព្រោះតាមអាយុកាលរបស់ពួកគេទាំងពីរនាក់វាបានកន្លងហួសពីការដែល អាចមានកូនបានទៅហើយ។ យោងតាមខគម្ពីរ លោកអ័ប្រាហាំមិនមានហេតុផលអ្វី ទាំងអស់នឹងសង្ឃឹម ប៉ុន្តែគាត់បានសង្ឃឹមក្នុងសេចក្តីជំនឿ (រ៉ូម ៤៖១៨)។

នៅពេលដែលគាត់ពិចារណាពីការបាត់បង់ចំណង់នៃរាងកាយរបស់គាត់ ហើយ និងការដែលមិនអាចមានកូនបាននៃរាងកាយរបស់សារ៉ានោះ សេចក្តីជំនឿរបស់អ័រ ប្រាហាំនៅតែមិនចុះអន់ថយ(រ៉ូម៤៖១៩)។ ការគ្មានជំនឿនិងមិនមានទំនុកចិត្តមិន បានធ្វើឲ្យគាត់រេរា(ដែលមានមន្ទិលសង្ស័យ) ទាក់ទងនឹងសេចក្តីសន្យារបស់ព្រះ នោះទេ ពីព្រោះគាត់បានទទួលកំលាំងដោយសារការសរសើរតម្កើងព្រះជាម្ចាស់ (រ៉ូម ៤៖២០)។ ព្រះបន្ទូលសន្យារបស់ព្រះចំពោះលោកអ័ប្រាហាំនឹងសារ៉ាបានកើតឡើង ទោះបីជាវាបានចំណាយពេលយូរជាងអ្វីដែលពួកគេបានគិតវាពីដំបូង។

ខ្ញុំអាចស្រមៃមើលពីរបៀបដែលការសង្ស័យព្យាយាមបង្ខាំងមនុស្ស ដែលយើង

បានអានអំពីព្រះគម្ពីរអំពីការផ្លាស់ប្តូរជាមួយព្រះ។ ព្រះគម្ពីរពោពេញទៅដោយឧទាហរណ៍នៃមនុស្សដែលទុកចិត្តព្រះជាម្ចាស់ ទោះបីជាពួកគេធ្លាប់មានបទពិសោធន៍ពីភាពផ្ទុយគ្នាដ៏អស្ចារ្យ សេចក្តីលំបាកវេទនា ហើយនឹងពេលដែលវិនិច្ឆ័យដោយភាពអយុត្តិធម៌។ ជាការពិតណាស់ភាពមន្ទិលសង្ស័យបានមកសួរសុខទុក្ខយ៉ូសែប កំឡុងពេលដែលគាត់ជាប់គុកសម្រាប់បទឧក្រិដ្ឋដែលគាត់មិនបានប្រព្រឹត្ត... ហើយអ៊ីស្ធើរដូចដែលនាងបានរៀបចំទៅមុខស្តេចដោយមិនបានទទួលការអញ្ជើញ ទោះបីវាជាទោសឧក្រិដ្ឋដែលត្រូវផ្តន្ទាទោសដោយសេចក្តីស្លាប់ក្តី... ហើយលោកប៉ូលដូចដែលលោកបានធ្វើដំណើរនាំដំណឹងល្អនៃព្រះគ្រិស្ត មានតែការប្រឈមមុខជាមួយនឹងបញ្ហាការធ្វើទុក្ខបុកម្នេញ គុក ការវាយដំ ការអត់ឃ្លាន ហើយនឹងសេចក្តីលំបាកវេទនាផ្សេងៗក្តី។ ប៉ុន្តែមនុស្សទាំងនេះពួកគេម្នាក់ៗបានឃើញភាពស្មោះត្រង់នៃព្រះ ហើយពួកគេតតាំងសម្រាប់ការប្រយុទ្ធយ៉ាងល្អនៃសេចក្តីជំនឿ។

## *ការយល់ដឹងអំពីការប្រឆាំង*

ថ្មីៗនេះខ្ញុំបានដឹងថាការធ្វើឲ្យមានសេរីភាពពីអ្វីមួយតាមរយៈព្រះគុណរបស់ព្រះ មិនមែនតែងតែមានន័យថា ជាការបាត់ទៅទាំងស្រុងនៃវត្ថុនោះ នោះទេ។ យើងមានសេរីភាពពីការឈឺចាប់នៃអតីតកាលរបស់យើង ប៉ុន្តែពេលខ្លះវានៅតែអាចមកសួរសុខទុក្ខយើងបាន។ យើងមានសេរីភាពពីភាពភ័យខ្លាច ប៉ុន្តែវាបង្ហាញខ្លួននៅក្នុងពេលវេលាដែលមិនសមស្របណាមួយ ដោយគ្រាន់តែឃើញថា ប្រសិនបើវានឹងចូលមកក្នុងជីវិតរបស់យើងជាថ្មីម្តងទៀត។

នៅក្នុងព្រះគម្ពីរលូកាជំពូកបួន យើងឃើញពីករណីរបស់ព្រះយេស៊ូដែលបានចាប់ផ្តើមដឹកនាំដោយព្រះវិញ្ញាណបរិសុទ្ធទៅក្នុងទីរហោឋានដើម្បីទទួលការល្បួងពីវិញ្ញាណអាក្រក់។ ក្នុងពេលសែសិបថ្ងៃដែលទ្រង់បានគង់នៅទីនោះ ទ្រង់បានស៊ូទ្រាំនឹងសេចក្តីល្បួងផ្សេងៗគ្នា ដោយទទួលបានជ័យជំនះលើការស៊ូទ្រាំនិមួយៗ។ ព្រះគម្ពីរបានចែងថា នៅពេលការបោកបញ្ឆោតគ្រប់យ៉ាងបានបញ្ចប់ វិញ្ញាណអាក្រក់ក៏បានចេញឆ្ងាយទៅ ដើម្បីរង់ចាំឱកាសផ្សេងៗទៀត (លូកា៤៖១៣)។ ក្នុងពាក្យផ្សេងទៀត ព្រះយេស៊ូបានឈ្នះការប្រយុទ្ធ ប៉ុន្តែការប្រយុទ្ធដទៃទៀតនឹងមក។ ការប្រឆាំងនឹងមក!

យើងមានបទពិសោធន៍នឹង ការប្រកួតប្រជែងដែលសាកល្បងសេចក្តីជំនឿរបស់យើងក្នុងព្រះ។ វាជាការព្យាយាមនៅក្នុងចង្រ្កាននៃសេចក្តីទុក្ខព្រួយ ហើយសេចក្តី

សង្ឃឹមនឹងចេញមកដោយភាពរឹងមាំ និងភាពឋិតថេរ។ មន្ទិលសង្ស័យ ភាពភ័យខ្លាច និងការព្រួយបារម្ភគឺជាផ្នែកនៃការប្រឆាំង។ ជាមួយនឹងឱកាសការប្រឆាំងវានឹងមក (១កូរិនថូស១៦៖៩)។ លោកប៉ូលបាននិយាយថា នៅពេលដែលគាត់ចង់ធ្វើការល្អ ការអាក្រក់តែងតែបានមក(រ៉ូម៧៖២១)។ យើងមិនត្រូវការអនុញ្ញាតឲ្យវាឈ្នះសេចក្តីជំនឿរបស់យើងបានទេ ប៉ុន្តែវានឹងមក!

ការប្រឆាំងវានឹងមកក្នុងទំរង់ជាច្រើន ប៉ុន្តែភាពឆ្វេសប្រហែសនៃរបៀបដែលវាមកចេតនារបស់វាគឺដើម្បីធ្វើឲ្យយើងបោះបង់ចោលសេចក្តីសង្ឃឹម នៃការទទួលបានអ្វីដែលព្រះជាម្ចាស់បានសន្យាជាមួយយើង។

*មនុស្សដែលប្រឆាំងនឹងយើង:*

ខណៈពេលដែលយើងកំពុងស្វែងរកដើម្បីធ្វើតាមព្រះហឫទ័យរបស់ព្រះ យើងអាចរកឃើញមនុស្សដែលប្រឆាំងនឹងយើង។ ពួកសាវកបានដោះស្រាយជាមួយការប្រឆាំងពីពួកអ្នកដឹកនាំសាសនា ហើយនឹងពួកទាហានរ៉ូម៉ាំងនៅលើមូលដ្ឋានធម្មតា។ ជាក់ស្តែងព្រះយេស៊ូបានដោះស្រាយជាមួយនឹង ការប្រឆាំងពីមនុស្សដែលបានបដិសេធនឹងស្អប់ទ្រង់។ ពួកគេបានចោទប្រកាន់ទ្រង់ដោយមិនមែនជាការពិត ពួកគេបានទិតៀននិងបន្ទាបបន្ថោកទ្រង់ ប៉ុន្តែទ្រង់នៅតែបានយកចិត្តទុកដាក់ទៅលើការប្រព្រឹត្តតាមព្រះហឫទ័យព្រះបិតារបស់ព្រះអង្គ។ ជួនកាល មនុស្សដែលប្រឆាំងនឹងយើងគឺជាអ្នកដែលយើងពឹងផ្អែកលើគេក្នុងការលើកទឹកចិត្តយើង ហើយប្រសិនបើការនោះកើតឡើង វាអាចជាភាពឈឺចាប់ដ៏ខ្លាំងក្លាមួយ។ បងប្អូនបង្កើតប្រុសៗរបស់ព្រះយេស៊ូបានគិតថា ទ្រង់បានធ្វើវា ហើយវាគួរឲ្យខ្មាសអៀនដែលនៅជាមួយទ្រង់។

*កាលៈទេសៈដែលប្រឆាំងនឹងយើង:*

យើងទាំងអស់គ្នាស៊ាំថ្មីកជាមួយកាលៈទេសៈដែលស្ថិតនៅក្នុងការប្រឆាំងជាមួយនឹងយើងនិងធ្វើឲ្យវាលំបាកសម្រាប់យើងដើម្បីសម្រេចគោលដៅរបស់យើង។ សម្រាប់រយៈពេលមួយខ្ញុំធ្លាប់បានរក្សាទុកតារាង នៃកិច្ចការនានាដែលបានកើតឡើងនៅក្នុងជីវិតពិតប្រចាំថ្ងៃដែលមិនបានរំពឹងទុក ការខកចិត្ត ហើយការបានចំណាយពេលនឹងថាមពល។ នៅក្នុងកុំឡុងពេលនោះ ខ្ញុំបានព្យាយាមដើម្បីបញ្ចប់សៀវភៅអានមួយក្បាល ការរៀបចំសិក្ខាសាលាដែលនឹងមកដល់ កម្មវិធីសម្រាប់ទូរទស្សន៍ ហើយនិងការធ្វើដំណើរដើម្បីចែកចាយដំណឹងល្អរបស់ព្រះគ្រិស្ត។ នៅចុងបញ្ចប់នៃថ្ងៃទីសាម

សិប ខ្ញុំមានបញ្ជីយ៉ាងវែងនៃកាលៈទេសៈនៃការប្រឆាំងចាប់តាំងពីការផឹកវីតាមីនក្រហមនៅលើគ្រែព័ណស រហូតដល់ការធ្លាក់លើជណ្តើរ។

រឿងប្រភេទនេះគឺជាការរំខានបំផុត ប៉ុន្តែកាលៈទេសៈខ្លះវាធ្ងន់ធ្ងរជាងហើយតម្រូវឲ្យយើងយកចិត្តទុកដាក់ច្រើនលើវាជាង។ នៅពេលដែលរឿងមួយចំនួនប្រឆាំងនឹងយើង វាស្ថិតនៅក្នុងរបៀបដែលយើងធ្វើអ្វីដែលយើងតាំងចិត្តធ្វើ។ យើងអាចទទួលរ៉ាប់រងបានទាំងអស់ថា នៅពេលដែលយើងព្យាយាមអស់ពីកំលាំងចិត្តធ្វើតាមព្រះជាម្ចាស់ សាតាំងនឹងរកមធ្យោបាយដើម្បីប្រឆាំងនឹងយើង។

*អារម្មណ៍និងគំនិតដែលប្រឆាំងនឹងយើង:*

ក៏ដូចជាការណ៍ជាក់ស្តែងដែលខ្ញុំបានលើកឡើង ជារឿយៗយើងត្រូវបានជំទាស់ដោយគំនិតនិងអារម្មណ៍ដែលធ្វើឲ្យសេចក្តីជំនឿរបស់យើងក្នុងព្រះចុះខ្សោយ។ សេចក្តីសង្ស័យគឺជាបញ្ហាតែមួយក្នុងចំណោមនោះ។ វាក៏មាន ការភ័យខ្លាច ការថប់បារម្ភ ការខ្លាចក្រែង ការអស់សង្ឃឹម ការព្រួយបារម្ភ ហើយនឹងបញ្ហាដទៃទៀត។ ទោះជាយ៉ាងណាក៏ដោយយើងអាចត្រូវបានលើកទឹកចិត្តឲ្យដឹងថា មានបុរសនិងស្ត្រីនៃព្រះជាច្រើននាក់ដែលបានទៅមុនយើង ពេលដែលពួកគេបានទំលុះទំលាយនិងបំពេញតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់ ហើយជាមួយនឹងព្រះគុណនៃព្រះអម្ចាស់ព្រះយេស៊ូគ្រិស្តនៃយើង ដូច្នេះយើងក៏អាចនិងធ្វើដូចគ្នាបានដែរ។

យើងគួរតែ «មើលនិងអធិស្ឋាន» ដូចជាយើងត្រូវបានបំផុសគំនិតក្នុងព្រះបន្ទូលរបស់ព្រះដើម្បីធ្វើ(ម៉ាថាយ២៦៖៤០-៤១, ១ពេត្រុស៤៖៧)។ ចូរយកចិត្តទុកដាក់ទៅលើអ្វីៗដែលប្រឆាំងនឹងសេចក្តីជំនឿរបស់អ្នក ហើយនិងព្យាយាមរារាំងអ្នកពីការស្តាប់បង្គាប់ព្រះជាម្ចាស់។ចូរទទួលស្គាល់ពួកវា និងអ្វីដែលជាពួកវា(ការរារាំង) ហើយមិនត្រូវអនុញ្ញាតឲ្យពួកវាប្លន់យកទ្រព្យសម្បត្តិរបស់អ្នកពីព្រះជាម្ចាស់ឡើយ។

ទាក់ទងនឹងការសង្ស័យ ចូរចាំថាការមានអារម្មណ៍សង្ស័យមិនមែនមានន័យថាអ្នកមិនមានសេចក្តីជំនឿនិងមិនមានទំនុកចិត្តលើព្រះជាម្ចាស់នោះទេ។ វាមានន័យថាសាតាំងកំពុងនឹងនាំការល្បួងដើម្បីបញ្ឈប់យើងពីការទុកចិត្តទ្រង់ ប៉ុន្តែយើងអាចពិចារណាអំពីប្រភពនៃការល្បួងហើយយើងដឹងថាយើងមិនគួរជឿវា។

សម្រាប់ឧទាហរណ៍ សូមនិយាយថា ខ្ញុំបានឮថា អ្នកណាម្នាក់បាននិយាយអ្វីមួយរិះគន់ខ្ញុំ ប៉ុន្តែវាគឺជាអ្នកណាម្នាក់ដែលបានរិះគន់មនុស្សជាច្រើនហើយ ពួកគេពិតជាមិនបានដឹងពីខ្ញុំនោះទេ។ ខ្ញុំនឹងមិនទទួលការខកចិត្តដោយសារតែការរិះគន់របស់ពួកគេនោះទេ ពីព្រោះខ្ញុំពិចារណាអំពីប្រភព។ យើងគួរធ្វើរឿងដូចគ្នានៅពេលអារម្មណ៍

និងការគិតមិនគោរពព្រះមកហើយល្បួងយើងមិនឲ្យទុកចិត្តព្រះជាម្ចាស់។ព្រះយេស៊ូបានប្រាប់ទៅពួកសិស្សរបស់ទ្រង់ឲ្យពួកគេអធិស្ឋានដើម្បីកុំឲ្យធ្លាក់ទៅក្នុងការល្បួង (លូកា២២៖៤០)។ ការល្បួងនឹងមក ប៉ុន្តែពួកគេមានជំរើសថាតើគួរទទួលយកឬមិនគួរទទួលយក។

សម្រាប់ខ្ញុំផ្ទាល់ វាមានអត្ថប្រយោជន៍ណាស់ក្នុងការយល់ថាវាគ្រាន់តែពីព្រោះខ្ញុំមានអារម្មណ៍ភ័យខ្លាច វាមិនមានន័យថាខ្ញុំគឺជាមនុស្សកំសាកម្នាក់នោះទេ ហើយថាគ្រាន់តែពីព្រោះខ្ញុំមានអារម្មណ៍សង្ស័យ វាមិនមានន័យថា ខ្ញុំទុកចិត្តព្រះតទៅទៀតមិនបាននោះទេ។ យើងមិនអាចឈ្នះសត្រូវរបស់យើងបានទេ ប្រសិនបើយើងមិនស្គាល់ពួកគេ! ការសង្ស័យគឺជាមិត្តសម្លាញ់នៃការភ័យខ្លាច ហើយពួកវាទាំងពីរនេះគឺជាសត្រូវរបស់យើង!

## ការបិទការរំខាន

តើអ្នកធ្លាប់ប្រឈមមុខនឹងសម្លេងដែលធ្វើឲ្យខឹងហើយអ្នកបានបើកវិទ្យុ ឬ ទូរទស្សន៍របស់អ្នកដើម្បីកុំឲ្យឮសម្លេងទាំងនោះដែរឬទេ? ខ្ញុំរស់នៅក្នុងខុនដូរដែលជាធម្មតាពេលខ្លះគឺវាស្ងាត់ខ្លាំងណាស់ ប៉ុន្តែនៅសប្តាហ៍មួយក្នុងពេលល្ងាច ភោជនីដ្ឋានរង្គសាលតាមផ្លូវមានក្រុមតន្ត្រីដែលប្រគំតន្ត្រីយ៉ាងឮដែលខ្ញុំមិនចូលចិត្ត ហើយវារំខានខ្ញុំខ្លាំងណាស់។ ពួកវាមានជញ្ជាំងចល័តដែលរអិលបើកបិទ ដូច្នេះតន្ត្រីផ្ទុះឡើងនៅខាងក្រៅក៏ដូចជានៅខាងក្នុង។ ខ្ញុំបានរៀនថា ប្រសិនបើខ្ញុំបើកទូរទស្សន៍របស់ខ្ញុំឲ្យឮបន្តិចនោះវានឹងបន្ថយសម្លេងតន្ត្រី។

ខ្ញុំគិតថាអ្វីដែលអ័ប្រាហាំបានធ្វើនៅពេលដែលគាត់ ឈ្នះលើសេចក្តីសង្ស័យនិងការមិនមានជំនឿ គឺតាមរយៈការអធិស្ឋានទៅកាន់ព្រះជាម្ចាស់ គឺជាឧទាហរណ៍ដែលខុសគ្នានៃបញ្ហាដូចគ្នា។គាត់បានឮសម្លេងហើយមានអារម្មណ៍មានការសង្ស័យ ប៉ុន្តែសម្លេងរំខានដែលចេញមកពីសាតាំងបានគ្របដណ្តប់ដោយសារការសរសើរតម្កើង

ខ្ញុំបានឮថា ផ្នែកនៃការសរសើរតម្កើងគឺជាការប្រាប់អំពីរឿងនិទានឬរឿងរ៉ាវដែលជាកិច្ចល្អដែលព្រះបានធ្វើ។ប្រហែលជាពេលដែលអ័ប្រាហាំបានយល់ពីការសង្ស័យគាត់បានចាប់ផ្តើមសួរ សារ៉ា ប្រសិនបើនាងចងចាំពេលវេលា នៅពេលដែលពួកគេបានចាកចេញពីផ្ទះរបស់ពួកគេនៅ ហារ៉ាន ដើម្បីតាមព្រះជាម្ចាស់ ទាំងដែលគេមិនបានដឹងសោះថាកន្លែងណាដែលទ្រង់ចង់ឲ្យពួកគេទៅ។ ព្រះបានដឹកនាំពួកគេពីមួយជំហានទៅមួយជំហាន ហើយខ្ញុំប្រាកដណាស់ថាមានរឿងជាច្រើនទៀតអំពីការល្អនៃ

ព្រះដែលពួកគេអាចរាប់ឡើងវិញនិងនិយាយអំពីវា។

ដេវ និងខ្ញុំ ធ្វើរឿងដូចគ្នាជាញឹកញាប់។ យើងរីករាយក្នុងការនិយាយអំពីថ្ងៃនៃការចាប់ផ្តើមព័ន្ធកិច្ចរបស់ពួកយើង ហើយនឹងការប្រឈមទាំងអស់ដែលយើងបានប្រឈមនឹងរបៀបដែលព្រះជាម្ចាស់បានស្មោះត្រង់។ នៅពេលដែលខ្ញុំចងចាំពេលវេលាទាំងនោះ ខ្ញុំឃើញថាវាពិបាកនឹងសង្ស័យព្រះ។ នោះមិនមែនមានន័យថាខ្ញុំមិនមានអារម្មណ៍សង្ស័យនោះទេ ប៉ុន្តែខ្ញុំបិទវាហើយគិតពីប្រភព!

ព្រះជាម្ចាស់អាចនឹងមិនប្រទានឲ្យ យើងនូវការណែនាំណាមួយនៅក្នុងព្រះបន្ទូលរបស់ទ្រង់មិនឲ្យសង្ស័យ បើទ្រង់ដឹងថាវានឹងមកវាយប្រហារជំនឿរបស់យើង។ ការសង្ស័យគឺជាឧបករណ៍របស់ពួកវិញ្ញាណអាក្រក់ ដែលបង្វាំងយើងពីការធ្វើកិច្ចការដែលព្រះជាម្ចាស់ចង់ឲ្យយើងធ្វើ និងមានអ្វីដែលទ្រង់ចង់ឲ្យយើងធ្វើ។

នៅពេលដែលព្រះយេស៊ូនៅលើផ្លូវរបស់ទ្រង់ ដើម្បីព្យាបាលកូនស្រីបុរសម្នាក់ដែលមានជំងឺយ៉ាងធ្ងន់ធ្ងរ អ្នកផ្សេងទៀតក៏បញ្ឈប់ទ្រង់ហើយសូមឲ្យទ្រង់ព្យាបាលពួកគេ។ ទ្រង់បានឈប់ហើយជួយពួកគេ ហើយឱកាសមួយ កំឡុងពេលដែលទ្រង់ធ្វើដំណើរទៅកាន់មនុស្សដែលឈឺ អ្នកបំរើរបស់បុរសនោះបានមក ប្រាប់ពួកគេមិនចាំបាច់បន្តដំណើររបស់ពួកគេទៀតទេ ពីព្រោះក្មេងស្រីបានស្លាប់បាត់ទៅហើយ។ ខគម្ពីរបានចែងថា ព្រះយេស៊ូបានឮពួកគេ ប៉ុន្តែមិនបានអើពើនឹងពួកគេនោះទេ ហើយបានប្រាប់ទៅបុរសនោះដើម្បីបន្តជឿ(ម៉ាកុស៥៖២២-៤៣)។ អ្នកឃើញថាទោះបីជាព្រះយេស៊ូមិនបានចាប់អារម្មណ៍នឹងព័តមាន ដែល បានមានចេតនានាំការសង្ស័យ ទ្រង់ត្រូវបានល្បួងក្នុងរបៀបតែមួយជាមួយនឹងយើង ប៉ុន្តែទ្រង់មិនបានធ្វើអំពើបាបសោះ (ហេប្រឺ ៤៖១៥)។

## *មិនធ្លាប់ដែលគ្មានផ្លូវទេ*

នៅក្នុងវេចនានុក្រមVine′sExpositoryនៃព្រះបន្ទូលសម្ព័ន្ធមេត្រីថ្មី«សេចក្តីសង្ស័យ» គឺត្រូវបានគេសន្មតថា «នឹងមិនមានផ្លូវ» ឮ «នឹងមិនមានប្រភព»។ យើងមិនដែលមិនមានផ្លូវនោះទេ ពីព្រោះព្រះយេស៊ូគឺជា *ផ្លូវ* (យ៉ូហាន១៤៖៦)។ យើងអាចមើលមិនឃើញផ្លូវ ប៉ុន្តែនោះគឺវាជាក់ច្បាស់ណាស់ ពេលដែលយើងត្រូវការទុកចិត្តព្រះជាម្ចាស់។ ជំនឿនិងការទុកចិត្តសម្រាប់ពេលវេលានៅក្នុងជីវិតពេលដែលយើងមិនដឹងថាអ្វីត្រូវធ្វើឬមិនមានធនធានផ្ទាល់ខ្លួនរបស់យើង។ ព្រះយេស៊ូមិនមែនគ្រាន់តែជាផ្លូវប៉ុណ្ណោះទេ ទ្រង់ក៏ជាប្រភពធនធានរបស់យើងដែរ! មិនមានអ្វីមួយដែលយើងម្នាក់ៗ

ត្រូវការដែលទ្រង់មិនអាចផ្តល់ឲ្យយើងបាននោះទេ។

មនុស្សអាចនឹងប្រាប់អ្នកថា «វាមិនមានផ្លូវនោះទេ» ហើយវិញ្ញាណអាក្រក់អាចនឹងខ្សឹបថា «វាមិនមានផ្លូវនោះទេ» ប៉ុន្តែអ្នកអាចចងចាំថា «ផ្លូវ» គឺរស់នៅក្នុងអ្នក ហើយទ្រង់គង់នៅជាមួយអ្នក! តើអ្នកនឹងទុកចិត្តទ្រង់ក្នុងគ្រប់ផ្លូវតាមរយៈការទទួលជ័យជំនះឬទេ?

សែសិបឆ្នាំកន្លងមក ពេលដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំដើម្បីបង្រៀនព្រះបន្ទូលរបស់ទ្រង់ ខ្ញុំបានកំពុងធ្វើការសែសិបម៉ោងក្នុងមួយសប្តាហ៍ បន្ថែមលើនេះខ្ញុំបានក្លាយជាប្រពន្ធនិងម្តាយ។ កាលវិភាគដ៏មមាញឹករបស់ខ្ញុំ បានធ្វើអោយខ្ញុំមិនមានពេលវេលាគ្រប់គ្រាន់ដើម្បីសិក្សាព្រះគម្ពីរអោយបានត្រឹមត្រូវដើម្បីរៀបចំការបង្រៀនដែលខ្ញុំបានដឹកនាំឲ្យធ្វើនៅឯការសិក្សាព្រះគម្ពីរប្រចាំសប្តាហ៍របស់យើងនោះទេ។

ខ្ញុំមានអារម្មណ៍ថា មានកំលាំងនៅក្នុងដួងចិត្តរបស់ខ្ញុំ ដែលខ្ញុំអាចនឹងឈានជំហាន យ៉ាងធំនៃសេចក្តីជំនឿហើយជំរុញការងាររបស់ខ្ញុំដើម្បីចំណាយពេលបន្ថែមទៀតក្នុងការសិក្សាព្រះបន្ទូលរបស់ព្រះ។ ដេវ បានយល់ស្របហើយខ្ញុំបានចាកចេញពីការងារនឹងចំណូលរបស់ខ្ញុំ។ វិក័យប័ត្ររបស់យើងមានចំនួនតិចតួចក្នុងមួយខែៗជាងប្រាក់ខែរបស់ដេវ ហើយខ្ញុំចាំបានពីការសង្ស័យនិងភាពភ័យខ្លាចដែលអាចនឹងប៉ះពាល់ខ្ញុំ ការប្រាប់ខ្ញុំថាព្រះនឹងមិនប្រទានហើយថាខ្ញុំបានធ្វើការសម្រេចចិត្តមិនល្អដើម្បីបោះបង់ការងាររបស់ខ្ញុំ។

នៅក្នុងដួងចិត្តរបស់ខ្ញុំ ខ្ញុំមានអារម្មណ៍ថាខ្ញុំបានធ្វើការដ៏ត្រឹមត្រូវ ប៉ុន្តែគំនិតរបស់ខ្ញុំនៅតែបន្តជជែកវែកញែកជាមួយខ្ញុំ។ ខ្ញុំត្រូវបានគេធ្វើបាបរហូតដល់ចំណុចដែលគួរឲ្យអាណិតអាសូរ។ បន្ទាប់ពីនោះនៅព្រឹកមួយខណៈពេលដែលខ្ញុំកំពុងដើរកាត់ផ្ទះ ព្រះជាម្ចាស់បានមានបន្ទូលមកកាន់ដួងចិត្តរបស់ខ្ញុំហើយមានបន្ទូលថា «អ្នកអាចព្យាយាមទាំងយកចិត្តទុកដាក់នឹងខ្លួនរបស់អ្នក ហើយរស់នៅក្នុងសេចក្តីភ័យខ្លាចនឹងការសង្ស័យ ឬអ្នកអាចទុកចិត្តខ្ញុំដើម្បីផ្តល់ឲ្យសម្រាប់អ្នកក្នុងផ្លូវដ៏អស្ចារ្យ។» ខ្ញុំបានឆ្លងកាត់ផ្លូវខ្វែងក្នុងសេចក្តីជំនឿរបស់ខ្ញុំ ខ្ញុំត្រូវការបញ្ឈប់គំនិតសង្ស័យ ហើយសម្រេចចិត្តប្រសិនខ្ញុំនឹងទុកចិត្តព្រះជាម្ចាស់ឬអត់។

ព្រះជាម្ចាស់បានប្រទានឲ្យខ្ញុំនូវព្រះគុណដើម្បីទុកចិត្តនិងសម្រាប់រយៈពេលប្រាំមួយឆ្នាំយើងបានមើលព្រះជាម្ចាស់ប្រទានពីមួយខែទៅមួយខែក្នុងរបៀបដ៏អស្ចារ្យ។ កំឡុងពេលឆ្នាំទាំងនោះ សេចក្តីជំនឿរបស់ខ្ញុំបានធំធាត់ហើយខ្ញុំបានរៀនដោយបទពិសោធន៍ថាព្រះជាម្ចាស់ស្មោះត្រង់។ ខ្ញុំនៅតែមើលទៅក្រោយហើយចងចាំអំពីឆ្នាំទាំងនោះ ហើយ ខ្ញុំពិតជារីករាយដែលខ្ញុំមានពួកវា ពីព្រោះពួកវាបាននាំខ្ញុំចូលទៅ

កាន់តែគៀកព្រះជាម្ចាស់ជាងពេលមុន។

ប្រសិនបើអ្នកមានអារម្មណ៍ថាព្រះជាម្ចាស់កំពុងដឹកនាំអ្នកធ្វើកិច្ចការអ្វីមួយ ប៉ុន្តែភ្លាមៗអ្នកឈានជើងចេញទៅដោយសេចក្តីជំនឿដោយការសង្ស័យ សូមកុំភ្ញាក់ផ្អើល។ សេចក្តីជំនឿរបស់អ្នកបានទទួលការសាកល្បង ហើយទោះបីជាវាអាចនឹងជាឧបសគ្គ វាគឺជារឿងល្អ។ អ្នកកាន់តែរៀនទុកចិត្តព្រះជាម្ចាស់ច្រើនតាមរយៈបទពិសោធន៍ភាពងាយស្រួលវានឹងមកធ្វើការនោះ។ អ្នកនឹងមានបទពិសោធន៍អំពីសេចក្តីស្មោះត្រង់របស់ទ្រង់នៅក្នុងរបៀបថ្មី ហើយពេលផ្សេងទៀតដែលអ្នកធ្វើ វានឹងធ្វើឲ្យអ្នករឹងមាំឡើង។

ពេលមួយ ខ្ញុំបានឮថា សេចក្តីសង្ស័យសម្លាប់សុបិន្តច្រើនជាងបរាជ័យ។ កុំអនុញ្ញាតឲ្យការសង្ស័យផ្អាកជំនឿរបស់អ្នក។ ទទួលស្គាល់វាថាវាគឺជាអ្វី ហើយផ្លាស់ប្តូរអតីតកាលវាក្នុងសេចក្តីជំនឿ!

# ជំពូក ២២

## តើអ្នកមានបទពិសោធន៍ច្រើនប៉ុណ្ណា?

*សប្បាយហើយ (មានពរ សំណាង គួរឲ្យច្រណែន) អស់អ្នកណាដែលរកបានប្រាជ្ញា ហើយអ្នកណាដែលខំប្រឹងទាល់តែបានយោបល់។*

សុភាសិត ៣:១៣

ប្រសិនបើអ្នកធ្លាប់ដាក់ពាក្យធ្វើការ មានសំណួរមួយដែលអ្នកសម្ភាសន៍អាចនឹងសួរអ្នកគឺ «តើអ្នកធ្លាប់មានបទពិសោធន៍ទេ?» បើអ្នកឆ្លើយថា ធ្លាប់មានបទពិសោធន៍ នោះសំណួរបន្ទាប់ប្រហែលជា «តើអ្នកមានបទពិសោ*ធន៍*ច្រើនប៉ុណ្ណា?»ទោះបីជាអ្នកអាចមានជំនាញថ្នាក់មហាវិទ្យាល័យពិតប្រាកដ ដែលអ្នកប្រាថ្នាធ្វើ ការតាមជំនាញនេះក៏ដោយ តែចំណេះដឹងតែម្យ៉ាងមិនគ្រប់គ្រាន់សំរាប់ឲ្យយើងធ្វើការនោះទេ។ មិនថាយើងគិតថា យើងចេះដឹងច្រើនប៉ុណ្ណាទេ លុះត្រាតែចំណេះដឹងរបស់យើងធ្លាប់បានសាកល្បង ហើយក៏គ្មានភស្តុតាងពីការ ដែលយើងធ្លាប់ធ្វើការ នោះទេ។

ព្រះជាម្ចាស់ក៏ត្រូវការបែបដូចនេះដែរ ពេលដែលទ្រង់ចង់ប្រើយើងសម្រាប់ ថ្វាយសិរីល្អ និងគោលបំណងនៅលើផែនដីនេះដល់ទ្រង់។ នៅពេលលោកម៉ូសេ ត្រូវការជំនួយក្នុងការដឹកនាំរាស្ត្រអ៊ីស្រាអែលតាមការបង្គាញរបស់ព្រះជាម្ចាស់ លោក ក៏បានឲ្យការ*ណែនាំ*ការនេះដល់មនុស្សដែរ។

*ចូរឲ្យឯងរាល់គ្នារើសយកមនុស្សដែលមានប្រាជ្ញា មានយោបល់ ហើយមានឈ្មោះក្នុងពូជអំបូរឯងរាល់គ្នាមក នោះអញនឹងតាំងគេឲ្យធ្វើជាមេលើឯងរាល់គ្នា។*

ចោទិយកថា១:១៣

អ្នកប្រហែលជាកត់សំគាល់ថា សេចក្តីត្រូវការក្នុងបញ្ជីមិនបានផ្តោតទៅ លើទេព្យកោសល្យនោះទេ! មនុស្សអាចមានទេពកោសល្យតាមការខ្លះតាំងពីកំណើត ប៉ុន្តែដើម្បីឲ្យក្លាយជាវត្ថុមានតម្លៃ ពួកគេត្រូវការប្រាជ្ញា យោបល់ និងបទពិ សោធន៍។

លោកម៉ូសេបានស្វែងរកមនុស្សដែលមានបទពិសោធន៍មុនពេលដាក់ ពួកគេទៅក្នុងតួនាទីដឹកនាំណាមួយ។

នៅពេលយើងចាប់ផ្ដើមបង្កើតព័ន្ធកិច្ចដែលព្រះជាម្ចាស់បានត្រាស់ហៅ យើងឲ្យបង្កើត យើងក៏ត្រូវការមនុស្សមកជួយយើងដែរ។ នៅពេលដែលខ្ញុំកំពុងតែ ជជែកជាមួយគ្រូគង្វាលរបស់ខ្ញុំអំពីចក្ដីត្រូវការខ្លះៗ គាត់បាននិយាយថា «ចយស៍ ត្រូវតែចាំគ្រប់ពេលថា អ្នកនឹងមិនស្គាល់អ្នកណាម្នាក់ច្បាស់នោះទេ បើ អ្នកមិនបានឃើញគេនៅក្នុងគ្រប់ស្ថានភាពណាមួយនោះ។» ហេតុអ្វី? ពីព្រោះ គ្មានអ្នកណាម្នាក់ដឹងថាអ្នកនោះនឹងប្រព្រឹត្តបែបណាទេ ទាល់តែចរិកលក្ខណៈនិង ចំណេះដឹងស្ថិតក្នុងការសាកល្បងសិន។ យើងក៏មិនដឹងនូវអ្វីដែលយើងនឹងធ្វើសំរាប់ខ្លួនយើងដែរ លុះត្រាតែយើងធ្លាប់មានបទពិសោធន៍ឆ្លងកាត់ខុសៗគ្នានៅក្នុងជីវិត។

វាគឺជាការងាយទេក្នុងការគិតឬនិយាយថាយើងទុកចិត្តព្រះជាម្ចាស់ ប៉ុន្ដែ តើយើងពិតជាទុកចិត្តព្រះមែនទេពេលដែលយើងត្រូវការ? ក្នុងពេលខ្ញុំកំពុងតែ សរសេរសៀវភៅពីការទុកចិត្តព្រះជាម្ចាស់នេះ ខ្ញុំបានអត់ធ្មត់នឹងបញ្ហាដែលមាន ការឈឺចាប់ខ្លាំងហើយរយៈពេលយូរទៀត។ ក្នុងកំឡុងពេលនោះ ខ្ញុំអាចទុកចិត្ត ព្រះជាម្ចាស់ក្នុងការធ្វើការនោះ ពីព្រោះខ្ញុំធ្លាប់មានបទពិសោធន៍ជាច្រើនឆ្នាំជាមួយទ្រង់ ហើយខ្ញុំក៏បានឃើញពេលវេលានៃភាពស្មោះត្រង់របស់ទ្រង់ម្តងហើយម្តងទៀតដែរ។

យើងអាចអានសៀវភៅពីការទុកចិត្តព្រះជាម្ចាស់ ប៉ុន្ដែយើងក៏នឹងត្រូវការបទពិសោធន៍ដើម្បីឲ្យកាន់តែមានបទពិសោធន៍ល្អជាងនេះទៀតដែរ។ ក្នុងនាមជាអ្នកបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់ខ្ញុំព្យាយាមចែកចាយទៅបងប្អូនថាការឮ និងការអានគឺជាផ្នែកមួយនៃអ្វីដែលជាតំរូវការ។ យើងក៏ត្រូវតែ«ធ្វើ»នូវអ្វីដែល យើងកំពុងតែរៀនដែរ ហើយក្នុងការធ្វើនេះ យើងត្រូវរៀនឲ្យបានច្រើន បើរៀនមិនបានច្រើនទេ យើងអាចធ្វើតាមរយៈចំណេះដឹងក៏បាន នោះយើងនឹងលូតលាស់តាមរយៈការសិក្សានោះ។

## *ព្រះយេស៊ូវបានមានបទពិសោធន៍*

ព្រះគម្ពីរហេព្រើរ៥:៨-៩ប្រកាសថា ហើយទោះបើទ្រង់ជាព្រះរាជបុត្រាក៏ដោយ

> គង់តែទ្រង់បានរៀនស្តាប់បង្គាប់ ដោយសារការដែលទ្រង់រងទុក្ខលំបាកទាំងប៉ុន្មាននោះដែរ [៩] រួចកាលទ្រង់បានគ្រប់លក្ខណ៍ហើយ នោះទ្រង់បានត្រឡប់ជាមេបង្កើត នៃសេចក្ដីសង្គ្រោះដ៏នៅអស់កល្បជានិច្ច ដល់អស់អ្នក

ណាដែលស្តាប់បង្គាប់ទ្រង់។

សូម្បីតែព្រះយេស៊ូក៏ត្រូវបានប្រដាប់ដើម្បីធ្វើកិច្ចការដែលព្រះអម្ចាស់ចង់ឲ្យ ទ្រង់ធ្វើ ដោយឆ្លងកាត់ការងារជាច្រើន ដើម្បីឲ្យមានបទពិសោធន៍កាន់តែច្រើនដែរ។ ខ្ញុំមិនដឹងពីបងប្អូននោះទេ ប៉ុន្តែការនោះបានលើកទឹកចិត្តខ្ញុំ! ការនោះជួយខ្ញុំឲ្យយល់ថា បទពិសោធន៍បានបង្រៀនយើង ហើយយើងនិយាយពីបទសោធន៍នោះ។ យើងប្រហែលជាពិបាកខ្លាំងជាគ្រីស្ទបរិស័ទក្មេងខ្ចីក្នុងការ ទុកចិត្តព្រះជាម្ចាស់ ប៉ុន្តែពេលវេលាយូរៗទៅ ជំនឿរបស់យើងត្រូវបានសាកល្បងរួចជាស្រេច នោះយើងនឹងដឹង ថាព្រះជាម្ចាស់អាចទុកចិត្តបាន។ មូលដ្ឋានការយល់ដឹងលើចំណេះដឹងខួរក្បាលគឺជាកំរិតមួយនៃការចេះដឹង ប៉ុន្តែការចេះដឹងដោយមានបទពិសោធន៍គឺវាកាន់តែស៊ីជំរៅជាងទៅទៀត។

មូលដ្ឋានការយល់ដឹងលើចំណេះដឹងខួរក្បាលគឺជាកំរិតមួយនៃការចេះដឹង ប៉ុន្តែការចេះដឹងដោយមានបទពិសោធន៍គឺវាកាន់តែស៊ីជំរៅជាងទៅទៀត។

យើងត្រូវការការសិក្សាអប់រំ(ព្រះបន្ទូលព្រះ) ប៉ុន្តែយើងក៏ត្រូវការការបើក សម្តែងដែរ។ ខ្ញុំជឿថា តាមរយៈពេលវេលា ចំណេះដឹងរបស់យើងបានទទួល ការសាកល្បង ហើយយើងក៏កាន់តែមានបទពិសោធន៍ក្នុងការមើលឃើញពីការល្អនិងការស្មោះត្រង់របស់ព្រះជាម្ចាស់នៅក្នុងស្ថានភាពផ្ទាល់ខ្លួនរបស់យើងដែរ។

ខណៈពេលលោកសាវកប៉ូលកំពុងបង្រៀន និងលើកទឹកចិត្តក្រុមជំនុំនៅកូរិនថូសថា ដ្បិតគ្មានសេចក្តីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្តីល្បួង ដែលត្រូវខាងមនុស្សលោកទេ រីឯព្រះទ្រង់ក៏ស្មោះត្រង់ដែរ ទ្រង់មិនឲ្យកើតមានសេចក្តីល្បួងហួសកំឡាំងអ្នករាល់គ្នាឡើយ(១កូរិនថូល១០:១៣)។ ខ្ញុំជឿថា លោកប៉ូល និយាយចេញមកពីបទពិសោធន៍។ លោកបានឆ្លងកាត់ការលំបាកជាច្រើននៅក្នុង ពេលទុកចិត្តព្រះជាម្ចាស់ ហើយពីមួយពេលទៅមួយពេល លោកបានឃើញព្រះជា ម្ចាស់ដឹកនាំលោក ហើយប្រទានកម្លាំងឲ្យលោកឆ្លងផុតទាំងអស់ដោយឥរិយាបថជោគជ័យ។

ថ្មីៗនេះ ក្នុងពេលវគ្គចំណួរនិងចម្លើយ គឺខ្ញុំបានទុកចិត្តព្រះជាម្ចាស់ទាំងស្រុង ហើយមានស្ត្រីម្នាក់សួរថា តើខ្ញុំអាចទុកចិត្តព្រះជាម្ចាស់យ៉ាងម៉េចទៅ បើពេលខ្ញុំទុកចិត្តទ្រង់កាលពីមុនទ្រង់មិនបានធ្វើការអ្វីដល់ខ្ញុំសោះ?» ម្ភៃឆ្នាំមុន ខ្ញុំអាចពិបាកនឹងផ្តល់ចម្លើយដល់នាង ប៉ុន្តែបន្ទាប់ពីមានបទពិសោធន៍ជាមួយព្រះ ជាម្ចាស់សែសិបឆ្នាំមកនេះខ្ញុំបានដឹងចម្លើយ។ ខ្ញុំបាននិយាយថា«បើអ្នកបានទុកចិត្តព្រះជាម្ចាស់សំរាប់អ្វីមួយ ហើយមិនបានសម្រេច អញ្ចឹង អ្នកបានទុកចិត្ត ព្រះសម្រាប់អ្វីមួយដែលអ្នក

ចង់បាន ហើយវាមិនមែនជាអ្វីដែលស្ថិតនៅក្នុងផែនការរបស់ព្រះជាម្ចាស់សម្រាប់អ្នកឡើយ»។ អ្នកដែលមានជំនឿចាស់ទុំ អាចទុកចិត្តព្រះជាម្ចាស់សម្រាប់អ្វីមួយ តែបើគេមិនបានការនោះទេ នោះពួកគេក៏នៅតែទុកចិត្តព្រះជាម្ចាស់ដដែល។ ពួកគេជឿថា បើអ្វីដែលពួកគេបានសុំត្រូវតាមបំណងព្រះហឫទ័យព្រះជាម្ចាស់ នោះព្រះនឹងប្រទានដល់ពួកគេ ហើយពួកគេយល់ថា បើអ្វីដែលគេពួកចង់បានមិនត្រូវតាមបំណងព្រះហឫទ័យព្រះទេ នោះពួកគេមិនបានវាល្អជាង។ ជាការពិត ពួកគេអាចរៀនអរគុណព្រះជាម្ចាស់ចំពោះអ្វីដែលពួកគេចង់បានតែមិនបាន! ពួកគេមិនគួរគ្រាន់តែទុកចិត្តព្រះជាម្ចាស់សម្រាប់តែអ្វីដែលគេចង់បាននោះទេ ប៉ុន្តែពួកគេត្រូវតែទុកចិត្តព្រះជាម្ចាស់គ្រប់ជំហានទៅកាន់អ្វីដែលពួកគេចង់បាន។

លោកសាវក ប៉ូល បាននិយាយដូចនេះ៖

> តែយើងខ្ញុំចង់ឲ្យអ្នករាល់គ្នានិមួយៗ បានសំដែងចេញជាចិត្តឧស្សាហ៍ដូចគ្នាទាំងអស់ ប្រយោជន៍ឲ្យបានសេចក្ដីជំនឿដ៏ពេញលេញរបស់សេចក្ដីសង្ឃឹមដរាប ដល់ចុងបំផុត។
>
> ហេព្រើរ ៦:១១

យើងទុកចិត្តលើព្រះជាម្ចាស់គ្រប់ពេល ទោះបីយើងឆ្លងកាត់ក្នុងស្ថានភាពលំបាកក៏ដោយឬពេលដែលយើងត្រូវការ នោះវានឹងកាន់តែងាយក្នុងការធ្វើនៅពេលក្រោយទៀត។ បន្តិចម្ដងៗ (ពេលខ្លះកាន់តែតិចៗម្ដងៗ) យើងរៀនទុកចិត្តព្រះជាម្ចាស់ ដូច្នេះ សូមកុំបាក់ទឹកចិត្តបើសិនជាអ្នកមានអារម្មណ៍ថា អ្នកមិនបានជោគជ័យលើការមួយឥឡូវនេះដូចដែលអ្នកចង់បាន។

## *សាលារៀនជីវិត*

យើងគ្រប់គ្នាស្ថិតនៅក្នុងសាលារៀននៃជីវិតជាក់ស្ដែង ហើយយើងរៀនហើយរៀនទៀតតាមតែដំណើរជីវិតរបស់យើង។ ស្ដេចដាវីឌមានបន្ទូលជាញឹកញាប់ពីអ្នក មានបទពិសោធន៍ជាមួយព្រះជាម្ចាស់។ ឯអស់អ្នកដែលស្គាល់ព្រះនាមទ្រង់គេនឹងទុកចិត្តដល់ទ្រង់ ដ្បិតឱព្រះយេហូវ៉ាអើយ ទ្រង់មិនបានបោះបង់ចោលពួកអ្នកដែលស្វែងរកទ្រង់ឡើយ(ទំនុកដំកើង៩:១០)។តាមបទពិសោធន៍ដែលយើងធ្លាប់មាន ពីការល្អ ចិត្តប្រណី ក្តីមេត្តា ក្តីស្រឡាញ់ដ៏លើសលប់ និងក្តីសប្បុរសរបស់ព្រះជាម្ចាស់ គឺការនោះផ្តល់ឲ្យយើងនូវទំនុកចិត្តដែលយើងអាចទុកចិត្តព្រះជាម្ចាស់បាន គ្រប់ស្ថានការទាំង

អស់។ ទោះបីជាទ្រង់មិនបានប្រទានឲ្យយើងនូវអ្វីដែលយើង សង្ឃឹមថាបានក្តី ក៏យើងនឹងឃើញថា ទ្រង់តែងតែប្រទាននូវអ្វីដែលល្អបំផុតដល់យើង។ គ្រាន់តែយើងមិនបានដឹងពីហេតុផលរបស់ព្រះជាម្ចាស់ដែលទ្រង់ធ្វើតាមវិធីរបស់ទ្រង់ មិនមែនមានន័យថា វិធីរបស់ទ្រង់មិនត្រឹមត្រូវនោះទេ។ យើងគួរតែ យល់ឲ្យច្បាស់ ទោះបីជាពេលខ្លះ ត្រូវចំណាយពេលក្នុងជីវិតយើងដើម្បីធ្វើការនោះក៏ដោយ។

ជារឿយៗមនុស្សនិយាយថា «ខ្ញុំប្រាថ្នានៅក្មេងម្តងទៀត ហើយដឹងនូវអ្វីដែលខ្ញុំបានដឹងដូចពេលឥឡូវនេះ» ប៉ុន្តែការនោះមិនអាចទៅរួចទេ។ យើងត្រឹមតែដឹងនូវអ្វីដែលយើងដឹងពេលនេះ ពីព្រោះយើងបានឆ្លងកាត់សាលារៀននៃជីវិតជាក់ស្តែង។

ខ្ញុំមិនបានអាចដាក់ឲ្យជីវិតរបស់ខ្ញុំនៅមួយកន្លែង ហើយអត់ធ្វើអ្វីសោះដើម្បីទៅរៀននៅសាលាព្រះគម្ពីរនៅ ពេលដែលព្រះជាម្ចាស់បានត្រាស់ហៅខ្ញុំឲ្យបង្រៀនព្រះបន្ទូលរបស់ទ្រង់នោះទេ ប៉ុន្តែខ្ញុំនៅតែបានរៀន ហើយក៏នៅតែមានសាលារៀននៃជីវិតជាក់ស្តែងដែរ ហើយខ្ញុំបានរៀន ពីការជាច្រើនដែលខ្ញុំមិនដែលបានរៀនកាលពីនៅសាលា។

ស្តេចដាវីឌបាននិយាយពីអ្វីដែលទ្រង់បានហៅថា «បទពិសោធន៍នៃការលះបង់» (ទំនុកដំកើង១១៩:៧)។ ខ្ញុំស្រឡាញ់ការគិតបែបនោះណាស់! បទពិសោធន៍ខ្លះដែលយើងមាន ប្រហែលជាមិនមែនជាការជ្រើសរើសរបស់យើងទេ ដ្បិតនៅក្នុងព្រះជាម្ចាស់ប្រាជ្ញាគឺជា «ការលះបង់» ពាក្យផ្សេងទៀតគឺ បទពិសោធន៍ស្អាតស្អំដែលធ្លាប់ជួយយើងឲ្យស្គាល់ព្រះពិត និងអំណាចនៃការរស់ឡើងវិញរបស់ព្រះជាម្ចាស់។

ក្នុងកំឡុងពេល៦ឆ្នាំ ដែលព្រះជាម្ចាស់បានសាកល្បងសេចក្តីជំនឿរបស់យើងបន្ទាប់ពីខ្ញុំឈប់ពីការងាររបស់ខ្ញុំ ហើយយើងបានពឹងផ្អែកលើទ្រង់ទាំងស្រុង ខ្ញុំបានលូតលាស់ខាងព្រលឹងវិញ្ញាណក្នុងផ្លូវដ៏អស្ចារ្យមួយ។ វាមិនមែនជាផ្លូវដែលខ្ញុំបានជ្រើសរើសទេ ប៉ុន្តែវាជាផ្លូវដ៏ត្រឹមត្រូវមួយរយភាគរយ!

ខ្ញុំរីករាយនឹងការសញ្ជឹងគិតពីការយកចិត្តទុកដាក់របស់ព្រះជាម្ចាស់ទៅលើរាស្ត្រអ៊ីស្រាអែលនៅពេលដែលពួកគេធ្វើដំណើរឆ្លងកាត់វាលរហោស្ថានដើម្បី ចូលទៅក្នុងសាលារៀននៃជីវិតជាក់ស្តែ។ ព្រះជាម្ចាស់បានផ្គត់ផ្គង់នំម៉ាណាដល់ពួកគេ (អាហារមកពីព្រះជាម្ចាស់) ហើយពួកគេក៏មិនដឹងថានំនោះមកពីណាដែរ លើកលែងតែជាការសន្យារបស់ព្រះជាម្ចាស់ ដែលនំម៉ាណាអាចមានទៀតនៅថ្ងៃ បន្ទាប់ហើយបន្ទាប់ទៀត។ ពួកគេបានទុក

> ពេលខ្លះ មានផ្លូវតែមួយ យើងនឹងរៀនធ្វើអ្វីមួយ គឺនៅពេលយើងគ្មានជំរើសផ្សេងទៀត។

ចិត្តព្រះជាម្ចាស់មួយថ្ងៃម្តង។ ពេលខ្លះមានតែ វិធីតែមួយគត់ដែលយើងនឹងរៀនធ្វើអ្វីមួយគឺពេលដែលយើងគ្មានជំរើសផ្សេង។

សំលៀកបំពាក់ឯងមិនបានសឹកនៅលើខ្លួនសោះ ហើយជើងឯងក៏មិនបានពុះពងនៅរវាង៤០ឆ្នាំនេះផង(ចោទិយកថា៨:៤)។ ពួកគេមិនដែលបានទទួលខោអាវថ្មីអ្វីទេ ប៉ុន្តែខោអាវដែលពួកគេស្លៀកពាក់ គឺអស្ចារ្យហើយមានរយៈពេលយូរ។ ព្រះជាម្ចាស់បានមានបន្ទូលថា នឹងល្បងលឯងឲ្យដឹងជាសេចក្តីណា ដែលនៅក្នុងចិត្តឯង គឺបើនឹងកាន់តាមបញ្ញត្តទ្រង់ឬទេ។ បងប្អូនឃើញទេ គ្មានភស្តុតាងពីការទុកចិត្តដោយគ្មានការសាកល្បងនោះទេ! គោលបំណងរបស់ទ្រង់គឺ ជួយពួកគេឲ្យស្ថិតក្នុងកាលៈទេសៈដែលប្រសើរ ប៉ុន្តែដំបូងទ្រង់ត្រូវតែបង្រៀនពួកគេឲ្យពឹកផ្អែកលើទ្រង់ ក្រែងលោហ៍ពួកគេភ្លេចទ្រង់ បន្ទាប់ពីឆ្លងកាត់បទពិសោធន៍ជាច្រើនជាមួយទ្រង់ (ចោទិយកថា៨:២,៧,១១)។

នៅក្នុងសាលានៃជីវិតជាក់ស្តែង ខ្ញុំធ្លាប់ត្រូវអ្នកដែលខ្ញុំបានគិតថាជាមិត្តល្អក្បត់ ហើយសមាជិកគ្រួសារ និង មិត្តភ័ក្តិបដិសេធនៅពេលដែលពួកគេមិនគាំ ទ្រជំរើសរបស់ខ្ញុំសម្រាប់ជីវិតរបស់ខ្ញុំ មានទាំងការយល់ច្រឡំ ការចោទប្រកាន់ និងការបៀតបៀន ហើយនិងការឈឺចាប់ផ្សេងៗទៀត។ ប៉ុន្តែ ខ្ញុំក៏រៀនបានពីការសំខាន់មួយគឺការអត់ទោសដល់អ្នកដែលធ្វើឲ្យខ្ញុំឈឺចាប់ ហើយនិងការបដិសេធដែលធ្វើឲ្យមានភាពល្ងីងជូរចត់ និងខឹងសម្បារ។ ខ្ញុំក៏បានរៀនពីភាពស្មោះត្រង់ ឧត្តម្ភាព សន្តិភាពអត់ធ្មត់ ការគ្រប់គ្រងខ្លួនឯង ពីរបៀបជ្រើសរើសមិត្តល្អ ពីការយកព្រះ ជាទីមួយនៅក្នុងជីវិតរបស់ខ្ញុំ ពីការឲ្យតម្លៃអ្នកដទៃ និងពីការអានសៀវភៅរាប់ពាន់ ក្បាលពីមេរៀនជីវិតរបស់អ្នកផ្សេងៗទៀត។ ជីវិតរបស់ពួកគេមិនមែនជាការងាយ ស្រួលដើម្បីរៀនតាមនោះទេ ពីព្រោះពួកគេត្រូវការការសាកល្បងដែលការនោះ ក្លាយជាបទពិសោធន៍ជាក់ស្តែង ដែលធ្វើមិនឲ្យខ្ញុំទុកចិត្តព្រះជាម្ចាស់អស់ពីចិត្តនោះទេជាច្រើនឆ្នាំមកនេះ។

## *វាកាន់តែងាយស្រួល*

ខ្ញុំជឿ ហើយខ្ញុំអាចនិយាយដោយប្រាកដថា ការទុកចិត្តព្រះជាម្ចាស់គឺងាយស្រួល បើផ្ញើជីវិតជាមួយទ្រង់។ តាមដែលយើងជ្រើសរើស «ដាក់» ការទុកចិត្តរបស់យើង ទៅលើទ្រង់ជំនួសឲ្យការដាក់ទៅលើការដទៃទៀត។ នោះយើងនឹងរៀន ហើយលូតលាស់ក្នុងសមត្ថភាពរបស់យើងដើម្បីធ្វើការនោះ។ ខ្ញុំបានមើលពីជីវិតរបស់ដេវនូវអ្វី

ដែលខ្ញុំហៅថា «ការបន្ធូរបន្ថយដ៏វិសុទ្ធ» ក្នុងកំឡុងពេលស្ទើរតែជាងហាសិបឆ្នាំ ដែលយើងបានរៀបការជាមួយគ្នាមកនេះ។ នៅពេលមួយធ្វើឲ្យខ្ញុំក្តៅក្រហាយថា ជីវិតហាក់បីដូចជាស្រួលពេកសម្រាប់គាត់និងវាពិបាកសម្រាប់ខ្ញុំ បន្ទាប់មកខ្ញុំក៏បានរៀនថា ជីវិតយើងគ្រប់ៗគ្នាគឺមិនងាយស្រួលនោះទេ ប៉ុន្តែយើងអាចរស់នៅក្នុងជីវិតការបន្ធូរបន្ថយដ៏វិសុទ្ធដោយការទុកចិត្តព្រះជាម្ចាស់គ្រប់ពេលវេលាគ្រប់ការទាំងអស់។

ដេវហាក់បីដូចជារៀនលឿនជាងខ្ញុំ ខ្ញុំហាក់បីដូចពិបាកបន្តិច ហើយជាធម្មតាត្រូវតែមានការមួយចំនួនទៀត«បទពិសោធន៍នៃការលះបង់»ដែលគាត់បានធ្វើមុន ហើយខ្ញុំទទួលបានចុងក្រោយ។ គាត់រៀនតាំងពីដំបូងក្នុងជីវិតក្នុងការផ្ទង់ការយកចិត្តទុកដាក់របស់គាត់ចំពោះព្រះ ហើយអនុញ្ញាតឲ្យព្រះជាម្ចាស់យកចិត្តទុកដាក់ ចំពោះគាត់វិញ។ ខ្ញុំបានរំលឹកពីអាពាហ៍ពិពាហ៍កាលពីដើមឆ្នាំដំបូងរបស់ យើងឡើងមកវិញពេលដែលយើងឆ្លងកាត់ការលំបាកដែលគាត់បានព្យាយាមប្រាប់ខ្ញុំថា ការព្រួយបារម្ភរបស់ខ្ញុំ និងការពិបាកចិត្តរបស់ខ្ញុំ គឺមិនផ្លាស់ប្តូរអ្វីទាំងអស់ ហើយខ្ញុំគួរតែទុក ចិត្តព្រះជាម្ចាស់វិញ។ ខ្ញុំចង់ធ្វើអញ្ចឹងដែរ ប៉ុន្តែខ្ញុំពិតជាមិនដឹងថាធ្វើយ៉ាងម៉េច។ បើសិនជាអ្នកកំពុងតែមានពេលពិបាកក្នុងការទុកចិត្តព្រះជាម្ចាស់។ ខ្ញុំសូមបញ្ជាក់ជាមួយបងប្អូនថា ខ្ញុំដឹងពីអារម្មណ៍បងប្អូនយ៉ាងម៉េច ប៉ុន្តែតាមរយៈបទពិសោធន៍ ខ្ញុំដឹងថាបើអ្នកបន្តដំណើររបស់អ្នកទៅមុខនោះអ្នកនឹងរៀនបាន។ កុំបាក់ទឹកចិត្តនឹងខ្លួនឯងឡើយ ទោះបើពេលខ្លះអ្នកហាក់ដូចជាមានសេចក្តីជំនឿតិចតួចបំផុត គ្រាន់តែចាំថាពេលណាអ្នកប្រើជំនឿតិចបំផុតនោះ វាក្លាយទៅជាសេចក្តីជំនឿដ៏ធំគ្រប់ពេល។

ព្រះយេស៊ូបានមានព្រះបន្ទូលទៅសិស្សថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម្ល៉េះ ម្តេចក៏គ្មានសេចក្តីជំនឿ(ម៉ាកុស៤:៤០)។ ប៉ុន្មានឆ្នាំក្រោយមក យើងឃើញសិស្សទាំងនោះអនុវត្តសេចក្តីជំនឿដោយចេញទៅចែកចាយដំណឹងល្អរបស់ ព្រះគ្រីស្តនៅពេលដែលមានការបៀតបៀនកើតឡើង។ សេចក្តីជំនឿដ៏តូចរបស់ពួកគេបានលូតលាស់ទៅជាធំបំផុត ហើយសេចក្តីជំនឿរបស់យើងក៏អាចបែបនោះដែរ។ ពួកគេមិនបានរៀនឲ្យមានជំនឿធំដោយផ្អែកទៅលើថ្ងៃណាល្អនោះទេ ពួកគេបានរៀនពីការនោះក្នុងពេលខ្យល់ព្យុះប្រភេទហារីខេន! ពួកគេបានបរាជ័យក្នុងការទុកចិត្តព្រះជាម្ចាស់នៅពេលមានព្យុះ ប៉ុន្តែជាការពិតពួកគេបានរៀនទុកចិត្តព្រះជាម្ចាស់គ្រប់ពេលវេលា និងគ្រប់ការទាំងអស់។ មនុស្សបែបនេះប្រឈមនឹងការស្លាប់ រាល់ថ្ងៃហើយពួកគេនៅតែបន្តបែបនេះដដែល ពីព្រោះទោះបីជាមានជីវិត ឬស្លាប់ក្តី ក៏ពួកគេនៅតែដឹងថា ពួកគេអាចទុកចិត្តព្រះជាម្ចាស់បាន!

នៅពេលដែលព្រះយេស៊ូ កំពុងតែឈឺចាប់នៅលើឈើឆ្កាង ហើយជិតផុតដង្ហើម

បន្ទូលរបស់ទ្រង់ចុងក្រោយគឺ ពាក្យទុកចិត្ត។ នោះព្រះយេស៊ូវ ស្រែកឡើងជាខ្លាំងថា «ឱព្រះវរបិតាអើយ ទូលបង្គំសូមប្រគល់វិញ្ញាណដល់ព្រះហស្តទ្រង់វិញ!» (ព្រះគម្ពីរ លូកា២៣:៤៦)។

ខ្ញុំសូមអធិស្ឋានឲ្យយើងរៀនទុកចិត្តព្រះជាម្ចាស់រហូតដល់ដង្ហើមចុងក្រោយរបស់យើង! ការរស់នៅក្នុងជីវិតនៃការទុកចិត្តព្រះជាម្ចាស់អាចធ្វើឲ្យជីវិតជួបទុក្ខលំបាក និងរីករាយ។ ការទុកចិត្តគឺជាអំណោយដ៏អស្ចារ្យដែលព្រះជាម្ចាស់ បានប្រទានដល់យើង ដូច្នេះចូរកុំរុំអំណោយនេះទុក ចូរប្រើវាគ្រប់ពេលវេលាទាំងអស់ និងគ្រប់ទាំងផ្លូវរបស់យើង។

# ជំពូក ២៣

# ការប្តូរផ្តាច់គ្រប់យ៉ាងថ្វាយព្រះជាម្ចាស់

*ពិភពលោកមិនទាន់បានឃើញអ្វី ដែលព្រះជាម្ចាស់ធ្វើតាមរយៈមនុស្ស ដែល ពិតជាប្តូរផ្តាច់ចំពោះព្រះអង្គនៅឡើយ។*

*លោក ឌី អែល មូឌី*

មនុស្សហាក់បីដូចជាតែងតែមានរឿងដែលត្រូវព្រួយបារម្ភ ប៉ុន្តែមានរឿងបីដែលព័ន្ធកិច្ចរបស់យើងបានទទួលការស្នើសុំឲ្យយើងអធិស្ឋានឲ្យច្រើនជាងគេគឺៈ អធិស្ឋានសម្រាប់កូនៗ និងមនុស្សជាទីស្រឡាញ់របស់ពួកគេ អធិស្ឋានសម្រាប់ហិរញ្ញវត្ថុ និងអធិស្ឋានសម្រាប់សុខភាព និងការប្រោសឲ្យជា។

ការព្រួយបារម្ភ គឺជាសត្រូវនឹងការទុកចិត្តព្រះជាម្ចាស់ ហើយវាបន្តលួចជំនឿរបស់យើង និងធ្វើឲ្យយើងស្ថិតនៅក្នុងភាពភ័យខ្លាច។ គ្មានមនុស្សណាម្នាក់អាចទទួលអ្វីដែលគេចង់បានពីព្រះជាម្ចាស់តាមរយៈការភ័យក្លាចឡើយ។ មានតែតាមរយៈជំនឿ និងការទុកចិត្តព្រះជាម្ចាស់ប៉ុណ្ណោះ ដែលយើងអាចរស់នៅក្នុងជីវិតដែលយើងពិតជាចង់រស់នៅជាមួយ និងជីវិតដែលមានសន្តិភាព និងអំណរដែលយើងប្រាថ្នាបាន។ ចូរមើលចំណុចនៃការព្រួយបារម្ភទាំងបីនេះ ដោយដឹងថាយើងអាចប្រើគោលការណ៍ដែលយើងឃើញនៅទីនេះទៅក្នុងជីវិតរបស់យើងបាន។

## ១. *ការព្រួយបារម្ភពីកូនៗរបស់យើង*

តើពួកគេនឹងធំធាត់ឡើងយ៉ាងដូចម្តេច? តើយើងជាឪពុកម្តាយល្អឬទេ? តើយើងអាចកែរតម្រង់ពួកគេយ៉ាងដូចម្តេចនៅពេលដែលពួកគេត្រូវការការកែរតម្រង់? តើយើងតឹងតែងពេក ឬយើងធូររលុងពេក? នៅពេលដែលយើងឃើញកូនៗរបស់យើងជាប់គាំងនៅក្នុងជីវិតរបស់ពួកគេក្នុងពេលដែលពួកគេស្ថិតក្នុងវ័យជំទង់ ឬយុវវ័យ យើងតែងតែឆ្ងល់ថា តើឫសគល់នៃបញ្ហារបស់ពួកគេជាកំហុសរបស់យើង ឬយ៉ាងណា។ អារក្សចង់ដាក់បន្ទុកដល់ឪពុកម្តាយ ជាមួយការចោទប្រកាន់ខុសឆ្គង ដែលឥតប្រយោជន៍និងខាតកំលាំង។

ដេវ និងខ្ញុំមានកូនបួននាក់ និងចៅ១១នាក់ ហើយយើងបានឃើញពួកគេជាប់គាំងជាមួយបញ្ហាផ្សេងៗជាច្រើន។ ព្រះជាម្ចាស់បានបង្រៀនខ្ញុំថា ការអធិស្ឋានជាមិត្តដ៏អស្ចារ្យបំផុតរបស់ខ្ញុំ និងជាអ្នកជំនួយដ៏មានប្រសិទ្ធភាពបំផុត ដែលបានជួយកូនចៅរបស់ខ្ញុំនៅពេលដែលពួកគេជួបឧបសគ្គ។ ការព្រួយបារម្ភរបស់ខ្ញុំចំពោះការព្រួយបារម្ភរបស់ពួកគេមិនអាចជួយពួកគេ ឬជួយខ្ញុំបានឡើយ។

យើងអាចឃើញកូនៗរបស់យើង ឬអ្នកផ្សេងទៀតដែលយើងស្រឡាញ់ ធ្វើការសម្រេចចិត្តមិនល្អ ហើយយើងពិតជាចង់ជំរុញពួកគេឲ្យផ្លាស់ប្តូរខ្លាំងណាស់។ ទោះជាយ៉ាងណាក៏ដោយ ភាគច្រើន ទោះបីជាយើងដឹងច្បាស់ពីចម្លើយសម្រាប់បញ្ហារបស់អ្នកដទៃក៏ដោយ ក៏គេនឹងមិនស្តាប់យើងដែរ។ ជាពិសេសយុវវ័យ និងយុវជនក្មេងខ្ចី ហាក់បីដូចជាពួកគេត្រូវតែធ្វើកំហុសរបស់ពួកគេ ហើយពួកគេនឹងដឹងដោយខ្លួនឯងថា តើអ្វីមានប្រយោជន៍ និងអ្វីដែលគ្មានប្រយោជន៍សម្រាប់ពួកគេ។

ដោយសារតែដេវ និងខ្ញុំមានចៅច្រើន ឥឡូវនេះយើងមានចៅគ្រប់លំដាប់អាយុ ហើយយើងក៏មានចៅពីរនាក់ដែលស្ថិតក្នុងយុវវ័យ ដែលអ្នកទាំងពីរកំពុងជាប់គាំងនៅក្នុងផ្នែកផ្សេងគ្នា។ មានម្នាក់ជាប់គាំងជាមួយនឹងអសុវត្ថិភាពដែលជាក់ស្តែងជាប់គាំងជាមួយរឿងជាច្រើន ខណៈពេលដែលម្នាក់ទៀតមានភាពអន្ទះសារនៅក្នុងជីវិតរបស់នាងដោយសារមូលហេតុហួសហេតុ និង ឥតប្រែប្រួលនិងអារម្មណ៍ក្នុងការទទួលខុសត្រូវខុសរឿង។

ក្នុងវ័យរបស់ខ្ញុំ វាងាយស្រួលសម្រាប់ខ្ញុំទេ ហើយក្នុងបទពិសោធន៍ដែលខ្ញុំមានក្នុងការមើលទៅពួកគេទាំងពីរនោះខ្ញុំអាចមើលឃើញពីឫសគល់នៃបញ្ហារបស់ពួកគេ ប៉ុន្តែវាមិនងាយស្រួលសម្រាប់ពួកគេទេ ជាធម្មតាដោយសារពួកគេទាំងពីរនាក់កំពុងធ្វើដំណើរនៅក្នុងជីវិតរបស់ខ្លួន។ ពួកគេព្យាយាមយល់ពីខ្លួនរបស់ពួកគេ និងតយុទ្ធសម្រាប់ឯករាជ្យភាពរបស់ពួកគេ នៅពេលខ្លះពួកគេទាំងពីរនាក់ស្ពាយមកជាមួយនូវភាពក្មេងខ្ចី និងរបៀបរបស់យុវវ័យនៅឡើយ។

យើងក៏មើលឃើញចៅផ្សេងទៀតដែលជាប់គាំងជាមួយបញ្ហារបស់ពួកគេ តែពួកគេបាននៅកន្លែងដែលមានសុវត្ថិភាព ឥឡូវនេះពួកគេរស់នៅគាប់ព្រះហឫទ័យព្រះជាម្ចាស់ ជាជីវិតដែលបង្កើតផលផ្លែ។ មានម្នាក់ជាប់គាំងជាមួយកំហឹង ម្នាក់ទៀតជាមួយថ្នាំញៀន ម្នាក់ទៀតជាមួយការបះបោរ ហើយនៅពេលដែលខ្ញុំគិតថយក្រោយ

> ការអធិស្ឋានបើកទ្វារឲ្យព្រះជាម្ចាស់ធ្វើការ។

ខ្ញុំឃើញថាការអធិស្ឋានដោយអស់ពីចិត្តរបស់ខ្ញុំសម្រាប់ពួកគេ បង្កើតលទ្ធផលយ៉ាង

អស្ចារ្យគ្រប់ពេល។ ការអធិស្ឋានមិនគួរជាជម្រើសចុងក្រោយទេ តែផ្ទុយទៅវិញគួរតែជាជម្រើសទីមួយ ដែលយើងគួរធ្វើក្នុងគ្រប់ការលំបាកទាំង អស់។ ការអធិស្ឋានបើកទ្វារឲ្យព្រះជាម្ចាស់ធ្វើការ ហើយទ្វារនោះនៅតែបន្តបើក ដែលយើងនៅតែបន្តអធិស្ឋាន ហើយអរព្រះគុណព្រះអង្គ និងអរព្រះគុណព្រះអង្គ ដែលព្រះអង្គថែរក្សារបស់របរ និងមនុស្សដែលយើងថ្វាយទៅព្រះអង្គ។

កូនទាំងបួននាក់របស់យើងម្នាក់ៗធ្លាប់បានខ្វាយខ្វល់ដោយសារកូនៗ របស់ពួកគេ ប៉ុន្តែឥឡូវនេះពួកគេបានលូតលាស់ក្លាយជាបុរសនិងស្ត្រីហើយ ទាំងអស់គ្នាកំពុងបម្រើព្រះជាម្ចាស់ ហើយយើងមានអំណរជាមួយទំនាក់ទំនងដ៏ល្អជាមួយពួកគេ និងមានមោទនភាពចំពោះពួកគេណាស់។ អ្នកអាចឆ្លងកាត់រឿងអ្វីមួយជាមួយកូនណាម្នាក់របស់អ្នក ឬកូនៗទាំងអស់របស់អ្នក ហើយអ្នកមានការព្រួយបារម្ភ ដោយសារតែមានបញ្ហាធ្ងន់ធ្ងរ ដែលពិតជាត្រូវការការយកចិត្តទុកដាក់ពីព្រះជាម្ចាស់។ ការព្រួយបារម្ភ គឺជាការល្បួងដល់ឪពុកម្ដាយ។ យើងចង់ជួយកូនៗរបស់យើង! យើងចង់រំដោះពួកគេ! យើងសុខចិត្តទទួលការឈឺចាប់របស់ពួកគេដាក់លើខ្លួនយើង ហើយអាចឃើញពួកគេឆ្លងកាត់ទុកលំបាកទាំងឡាយ។ នេះហើយ គឺជាសេចក្ដីស្រឡាញ់ដែលព្រះជាម្ចាស់បានធ្វើចំពោះស្ថានភាពនៃអំពើបាបរបស់យើង និងផលនៃអំពើទាំងនោះ ហើយវាជាធម្មតាទេសម្រាប់យើងជាឪពុកម្ដាយដែលមានអារម្មណ៍ដូចគ្នានេះ។ ទោះជាយ៉ាងណាក៏ដោយ ក៏យើងមិនអាចរំដោះកូនៗរបស់យើងពីទុក្ខលំបាកទាំងអស់នៅក្នុងជីវិតបាននោះទេ ហើយយើងត្រូវតែបង្ហាញក្ដីស្រឡាញ់ពិតប្រាកដដល់ពួកគេ ដោយទុកឲ្យពួកគេរងទុក្ខនូវចំណែកដែលជាផលនៃអ្វីដែលពួកគេបានសាបព្រោះ។ យើង អាចមានទំនុកចិត្តនៅក្នុងគម្ពីរសុភាសិត ដែលបានបង្រៀនយើងឲ្យបង្រៀនកូនៗរបស់យើងក្នុងផ្លូវដែលពួកគេគួរដើរ ហើយនៅពេលដែលពួកគេលូតលាស់ឡើងពួកគេនឹងមិនងាកចេញឆ្ងាយពីផ្លូវនោះឡើយ (សុភាសិត ២២:៦)។

ទោះបីជាកូនៗអាចវង្វេងផ្លូវមួយរយៈពេលក្តី ពួកគេនឹងវិលត្រឡប់មកធ្វើរឿងត្រឹមត្រូវវិញបើយើងបន្តអធិស្ឋាន និងធ្វើជាគំរូល្អសម្រាប់ពួកគេ។

## *តើជាកំហុសរបស់អ្នកណា?*

បើអ្នកមានកូនដែលមានបញ្ហា ឬមានភាពបាក់បែកនៅក្នុងជីវិតរបស់ពួកគេ តើជាកំហុសរបស់អ្នកណា? តើជាកំហុសរបស់អ្នកឬ ដែលបណ្ដាលឲ្យពួកគេមានបញ្ហា ឬក៏គ្រាន់តែជាជម្រើសមិនត្រឹមត្រូវដែលពួកគេជ្រើសរើស?តើដោយសារតែមិត្តភ័ក្តិដែល

ពួកគេជ្រើសរើស ឬក៏ដោយសារតែសង្គមដែលពួកគេកំពុងរស់នៅសព្វថ្ងៃ?

ខ្ញុំគិតថាយើងប្រើពេលច្រើនពេកហើយក្នុងការត្អូញត្អែរ ហើយគ្មានពេលគ្រប់គ្រាន់ក្នុងការសំគាល់ថាទោះបីជាកំហុសរបស់អ្នកណាក៏ដោយ ក៏ព្រះជាម្ចាស់នៅតែជាចម្លើយដែរ! ខ្ញុំពិតជាធ្លាប់ប្រព្រឹត្តខុសជាមួយកូនៗរបស់ខ្ញុំ ហើយខ្ញុំក៏មានការភ្ញាក់ផ្អើលដែរ ដែលខ្ញុំធ្លាប់ជាអាណាព្យាបាលដ៏ល្អ។ ខ្ញុំបានចិញ្ចឹមកូននៅក្នុងផ្ទះដែលពេញដោយភាពរឹករវ ពេញដោយគំរូអាក្រក់ដល់គ្នាទៅវិញទៅមក តែអរព្រះគុណព្រះជាម្ចាស់ដែលព្រះអង្គផ្តល់ព្រះគុណដើម្បីឲ្យខ្ញុំចិញ្ចឹមកូនៗ របស់ខ្ញុំបានល្អជាងអ្វីដែលខ្ញុំធ្លាប់ស្រម៉ៃ។ កូនស្រីទាំងពីររបស់ខ្ញុំបាននិយាយថា «ម៉ាក់! បើគិតពីអ្វីដែលម៉ាក់ធ្លាប់ទទួលការបីបាច់ និងពីការរំលោភបំពានដែលម៉ាក់ធ្លាប់ទទួល នោះម៉ាក់បានចិញ្ចឹមយើងបានយ៉ាងល្អបំផុត»!

យើងត្រូវតែចាំថា ទោះបីជាយើងមិនមែនជាឪពុកម្តាយគ្រប់ល័ក្ខណ៍ក៏ដោយ ក៏ព្រះជាម្ចាស់អាចយកឈ្នះ និងប៉ះប៉ូវលទ្ធផលនៃកំហុសដែលយើងធ្លាប់ធ្វើបានដែរ។ អ្វីដែលព្រះអង្គត្រូវការពីយើង គឺការប្រែចិត្តពិតប្រាកដ និងការអធិស្ឋានយ៉ាងស្មោះត្រង់ថ្វាយបញ្ហាទាំងអស់ដល់ព្រះអង្គ ដូច្នេះព្រះអង្គនឹងធ្វើការលើរឿងទាំងអស់នេះ។

ខ្ញុំទទូចអ្នកឲ្យតយុទ្ធជាមួយការល្បួង អំពីការព្រួយបារម្ភពីកូនៗរបស់អ្នក ហើយផ្ទុយមកវិញត្រូវទុកចិត្តព្រះជាម្ចាស់ថាព្រះអង្គនឹងធ្វើការនៅក្នុងពួកគេ ចំពោះអ្វីដែលអ្នកមិនអាចធ្វើបាន។ មានតែព្រះជាម្ចាស់ទេដែលអាចផ្លាស់ប្តូរមនុស្សបាន! ខ្ញុំដឹងថានៅពេលដែលខ្ញុំនិយាយថា «កុំព្រួយបារម្ភពីកូនៗរបស់អ្នក» វាស្រួលជាងការធ្វើ ប៉ុន្តែខ្ញុំអាចសន្យាជាមួយអ្នកបានថា ព្រះជាម្ចាស់ទ្រង់ស្មោះត្រង់ ហើយទោះបីជាយើងមិនអាចគ្រប់គ្រងនូវជម្រើសដែលអ្នកដទៃជ្រើសរើសក៏ដោយ ក៏ការអធិស្ឋានរបស់យើងអាចបើកទ្វារសម្រាប់ព្រះជាម្ចាស់ឲ្យធ្វើការនៅក្នុងជីវិតរបស់ពួកគេបានដែរ។ គ្មានបញ្ហាអ្វីដែលធំពេកសម្រាប់ព្រះជាម្ចាស់ទេ។

យើងអាចថ្វាយកូនៗរបស់យើងទៅព្រះជាម្ចាស់ ហើយព្រះអង្គនឹងដឹកនាំយើងក្នុងការចិញ្ចឹមបីបាច់កូនៗរបស់យើង ហើយព្រះអង្គនឹងធ្វើការនៅក្នុងជីវិតរបស់ពួកគេ ដើម្បីឲ្យពួកគេនៅតែដើរនៅក្នុងផ្លូវចង្អៀតដែលនាំទៅរកជីវិត ឬក៏យើងអាចព្រួយបារម្ភពីពួកគេ ហើយខ្លាចថាពួកគេនឹងត្រូវឈឺចាប់ ឬជ្រើសរើសខុស។

ខ្ញុំធ្លាប់សាកល្បងទាំងពីរ ហើយខ្ញុំអាចឆ្លើយជាមួយអ្នកថា ការថ្វាយពួកគេទៅព្រះជាម្ចាស់ គឺជាជម្រើសដ៏ល្អបំផុត។ ជំនឿ និងការទុកចិត្តរបស់យើង គឺកើតផលឡើងតាមរយៈការអធិស្ឋាន និងការប្រកាសព្រះបន្ទូល។ អធិស្ឋានសម្រាប់កូនៗរបស់អ្នក

កុំឲ្យកំណត់ពេលលើការទុកចិត្តឡើយ!

ហើយប្រកាសអ្វីដែលអ្នកអធិស្ឋាន។ នៅពេលដែលអ្នកធ្វើការជ្រើសរើសខុសពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ ចូរបន្តទុកចិត្តព្រះអង្គ។ កុំឲ្យធ្វើការកំណត់ពេលលើការទុកចិត្តឡើយ!

យើងអាចអធិស្ឋានឲ្យកូនៗរបស់យើង និងអ្នកដទៃទៀតដែលយើងស្រឡាញ់ និងជាអ្នកដែលយើងយកចិត្តទុកដាក់ជាមួយ ដូចដែល លោកសាវ័កប៉ូលបានអធិស្ឋានសម្រាប់អ្នកដែលលោកស្រឡាញ់ និងអ្នកដែលលោកបម្រើដែរ។ ចូរប្រើបទគម្ពីរនេះជាគំរូពីរបៀបថ្វាយមនុស្សទៅព្រះជាម្ចាស់។

> *ឥឡូវនេះ ខ្ញុំផ្ញើអ្នករាល់គ្នាទុកនឹងព្រះ ហើយនិងព្រះបន្ទូលនៃព្រះគុណទ្រង់ ដែលអាចនឹងស្អាងចិត្ត ហើយនិងឲ្យអ្នករាល់គ្នាមានកេរ្តិ៍អាករនៅក្នុងពួកនៃអស់អ្នកដែលបានញែកជាបរិសុទ្ធ។*
>
> កិច្ចការ ២០:៣២

នេះជាគំរូមួយពីរបៀបអធិស្ឋាននៅក្នុងបទគម្ពីរនេះ ហើយធ្វើឲ្យយើងអាចយកគំរូតាម។ ចូរនិយាយថាមនុស្សដែលអ្នកចង់អធិស្ឋានឲ្យមានឈ្មោះថា សែម ហើយជាជាងការបារម្ភពី សែម និងការព្យាយាមផ្លាស់ប្តូរគាត់ អ្នកត្រូវតែថ្វាយគាត់ទៅព្រះជាម្ចាស់។ អ្នកអាចធ្វើបែបនេះជាមួយនឹងពាក្យថា៖

> «បិតាអើយ ទូលបង្គំសូមថ្វាយ សែមទៅព្រះអង្គ។ ទូលបង្គំដាក់គាត់នៅក្នុងការគ្រប់គ្រងរបស់ព្រះអង្គ ហើយទុកចិត្តលើព្រះបន្ទូលនៃព្រះគុណរបស់ព្រះអង្គ។ ទូលបង្គំទុកចិត្តថាព្រះអង្គនឹងថែរក្សា សែម ឲ្យមានសុវត្ថិភាពហើយធ្វើឲ្យគាត់មានទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះអង្គ»។

ឥឡូវនេះនៅពេលដែលអ្នករៀបនឹងបារម្ភពី សែម ចូរប្តូរពីការបារម្ភទៅជាការអធិស្ឋាននៃការអរព្រះគុណ ថាព្រះជាម្ចាស់បានធ្វើការនៅក្នុងជីវិតរបស់ សែម។

ខ្ញុំធ្លាប់បានឃើញរឿងអស្ចារ្យកើតឡើងនៅក្នុងជីវិតកូនៗរបស់ខ្ញុំ ដោយខ្លួនខ្ញុំផ្ទាល់ជ្រើសរើសធ្វើតាមរបៀបនេះឯង។ នៅពេលដែលខ្ញុំបានអធិស្ឋានដោយលើកយកព្រះបន្ទូលចំៗក្នុងករណីកូនៗរបស់ខ្ញុំអស់រយៈពេលជាច្រើនខែ ហើយខ្ញុំមានការអស្ចារ្យពីការដែលព្រះជាម្ចាស់ធ្វើការ។ ការព្រួយបារម្ភ និងការភ័យខ្លាចមិនអាចឲ្យព្រះហស្តរបស់ព្រះជាម្ចាស់ធ្វើការបានទេ មានតែការទុកចិត្ត និងការប្តេជ្ញាចិត្តប៉ុណ្ណោះទើបជាដំណោះស្រាយ។

## ២. ការព្រួយបារម្ភអំពីហិរញ្ញវត្ថុ

យើងត្រូវការលុយដើម្បីប្រើប្រាស់ក្នុងជីវិត ហើយវាហាក់បីដូចជាមានប៉ុន្មានក៏ដោយ ក៏មិនចេះគ្រប់គ្រាន់ឡើយ!យ៉ាងណាមិញការព្រួយបារម្ភអំពីបញ្ហាមិនមែនជាដំណោះស្រាយទេ។ ព្រះជាម្ចាស់បង្គាប់យើងឲ្យយកដង្វាយ ១ភាគ១០ និងដង្វាយស្ម័គ្រចិត្តទៅកាន់ឃ្លាំងរបស់ព្រះអង្គ (ព្រះរាជរបស់ព្រះអង្គធ្វើការ) ហើយព្រះអង្គនឹងបើកទ្វារស្ថានសួគ៌ និងចាក់បង្ហូរព្រះពរដល់យើង។ ព្រះអង្គក៏នឹងស្ដីបន្ទោសសត្វដែលស៊ីបំផ្លាញជំនួសអ្នកដែរ(ម៉ាឡាគី៣:១០-១១)។ យើងមិនអាចរំពឹងថាបានច្រូតកាត់ឡើយ បើយើងមិនបានសាបព្រោះ ដូច្នេះចំណុចដំបូងបំផុតនៃពានិជ្ជកម្ម គឺអ្នកត្រូវប្រាកដថាអ្នកពិតជាស្មោះត្រង់ក្នុងការថ្វាយ ហើយបើអ្នកបានធ្វើការនេះរួចហើយ នោះអ្នកនឹងមានទំនុកចិត្តក្នុងការឈរនៅចំពោះព្រះជាម្ចាស់ និងអធិស្ឋានដោយបន្ទាបខ្លួន ដោយរំពឹងថាតម្រូវការរបស់អ្នកនឹងបានទទួលអាស្រ័យលើភាពសំបូរសប្បាយរបស់ព្រះជាម្ចាស់(ភីលីព៤:១៩)។ យើងក៏ត្រូវតែប្រើប្រាជ្ញាជាមួយលុយកាក់ដែលយើងមានដែរ។

ព្រះជាម្ចាស់មិនបានសន្យាថានឹងប្រទានអ្វីដែលយើងចង់បានឡើយ ប៉ុន្តែព្រះអង្គបានសន្យាថានឹងបំពេញតម្រូវការរបស់យើង។ អ្នកអាចសុំអ្វីៗគ្រប់យ៉ាងដែលអ្នកត្រូវការដោយសេរី ហើយព្រះអង្គសន្យាថានឹងប្រទានដល់យើងនូវអ្វីដែលចិត្តយើងប្រាថ្នា (មើលទំនុកតម្កើង ៣៧:៤) ប៉ុន្តែការប្រាថ្នាទាំងនេះមិនមែនជាការប្រាថ្នាដែលគ្មាន ប្រយោជន៍ដល់ព្រលឹងយើងឡើយ។

ខ្ញុំបានឃើញថាការដែលព្រះជាម្ចាស់ផ្គត់ផ្គងដល់យើងអស់ជាច្រើនឆ្នាំ ហើយការផ្គត់ផ្គង់របស់ទ្រង់តែងតែកើនឡើងរាល់ឆ្នាំ តែខ្ញុំពិតជាអាចនិយាយថាយើងពឹងផ្អែកព្រះអង្គជាច្រើនឆ្នាំ។ ព្រះជាម្ចាស់មិនចង់ឲ្យយើងផ្ដោតទៅលើសំភារៈជ្រុលពេកឡើយ ដោយសារប្រាជ្ញារបស់ព្រះអង្គ ព្រះអង្គតែងតែបង្អកអ្វីដែលយើងចង់បាននៅពេលឥឡូវនេះ ព្រោះព្រះអង្គមានអ្វីដែលប្រសើរជាងនៅក្នុងគំនិតរបស់ព្រះអង្គ ជាជាងគ្រាន់តែផ្ដល់អ្វីដែលយើងចង់បានដល់យើង។ ត្រូវចងចាំថាការពន្យារពេលមិនមែនជាការបដិសេធទេ ហើយយើងគួរតែទុកចិត្តពេលវេលារបស់ព្រះអង្គ។ ព្រះអង្គអាច បង្អកអ្វីដែលអ្នកគិតថាចង់បាន ពីព្រោះព្រះអង្គមានអ្វីដែលប្រសើរជាងសម្រាប់អ្នកដែលអ្នកគ្មានប្រាជ្ញាគ្រប់គ្រាន់ក្នុងការសុំនាពេលបច្ចុប្បន្ននេះ។

ត្រូវកាត់បន្ថយការព្រួយបារម្ភអំពីហិរញ្ញវត្ថុរបស់យើង ហើយត្រូវមានប្រាជ្ញាក្នុងការប្រើប្រាស់វាលើតម្រូវការចាំបាច់ក្នុងជីវិតរបស់យើង។ ការដើរដោយប្រាជ្ញា គឺធ្វើ

អ្វីៗនៅពេលឥឡូវនេះដែលអាចឲ្យយើងស្កប់ចិត្តនៅក្នុងជីវិតពេលទៅមុខទៀត តែសង្គមរបស់យើងបានរុញយើងឲ្យយើងមានបំណុលដូចភ្នំ តាមរយៈការផ្តល់ឲ្យយើងនូវរបៀបជាច្រើនក្នុងការទិញរបស់ផ្សេងៗនិងត្រូវចំណាយរហូតនៅពេលខាងមុខ។ វាគឺជាបំណុល ហើយបើយើងមានវាកាន់តែច្រើន នោះយើងក៏បង្កើតបញ្ហាហិរញ្ញវត្ថុកាន់តែច្រើនដែរ។ នៅពេលដែលយើងប្រើកាតឥនទានដែលយើងមិនអាចរត់រួច នោះយើងកំពុងតែចំណាយអ្វីដែលយើងត្រូវចំណាយនៅថ្ងៃស្អែក ហើយនៅពេលថ្ងៃស្អែកមកដល់ យើងនឹងគ្មានអ្វីក្រៅពីទុក្ខព្រួយឡើយ។

ខ្ញុំពិតជាចង់ទទូចដល់អ្នកដោយក្តីស្រឡាញ់ឲ្យអ្នកមានការអត់ធ្មត់ច្រើន ក្នុងការរង់ចាំសម្រាប់អ្វីទាំងអស់ ជាជាងស្វែងរកផ្លូវដើម្បីបានអ្វីដែលអ្នកចង់បានក្នុងពេលឥឡូវនេះ ទោះបីវាសំខាន់យ៉ាងណាសម្រាប់អនាគតរបស់អ្នកក៏ដោយ។ ការសន្សំប្រាក់ដើម្បីទិញអ្វីដែលយើងចង់បាន នៅតែជាជម្រើសដ៏ល្អដែលមនុស្សគួរពិចារណា តែមានមនុស្សតិចណាស់ដែលធ្វើបែបនេះ។

សន្តិភាពមានតម្លៃជាងសំភារៈ! នៅពេលដែលយើងមានបំណុលរំកោះ វានឹងលួចសន្តិភាពរបស់យើង ហើយអាចធ្វើឲ្យទំនាក់ទំនងរបស់យើងមានបញ្ហាទៀតផង។ នៅកន្លែងណាដែលខ្វះខាតថវិកា កន្លែងនោះតែងតែមានស្ត្រេស និងសំពាធ ហើយជា ញយដងវាតែងតែបង្កើតអាកប្បកិរិយាមិនល្អ ដែលបង្កើតបញ្ហានៅក្នុងទំនាក់ទំនង។ បើអ្នកជុំនៅក្នុងបំណុលរួចហើយ ខ្ញុំមិនមានចម្លើយសម្រាប់ដោះស្រាយបញ្ហាបានលឿនឲ្យអ្នកទេ ប៉ុន្តែខ្ញុំអាចសន្យាថាបើអ្នក ថ្វាយទៅព្រះជាម្ចាស់ជាមុនដោយចេញពីចិត្ត ហើយចាប់ផ្តើមដោះបំណុលរបស់អ្នកបណ្តើរៗ ស្របពេលជាមួយគ្នា អ្នកត្រូវដាក់វិន័យខ្លួនឯងក្នុងការមិនទិញអ្វីដែលអ្នកពិតជាមិនត្រូវការ នៅពេលណាមួយអ្នកនឹងរួចពីបំណុល ហើយនឹងមានអំណរពីការរួចពីបំណុលហិរញ្ញវត្ថុមិនខាន។

> សន្តិភាពមានតម្លៃជាងសំភារៈ!

អ្វីៗទាំងអស់តែងតែមានករណីលើកលែង ប៉ុន្តែបញ្ហាភាគច្រើនរបស់យើងមិនមែនដោយសារយើង គ្មានលុយគ្រប់គ្រាន់ទេ តែដោយសារតែយើងចាយលើសអ្វីដែលយើងមាន! កុំក្លាយទៅជាមនុស្សដែលមានអារម្មណ៍ទៅលើរបស់ដែលអ្នកមិនបានធ្វើការនិងសន្សំដើម្បីវាឡើយ។ ត្រូវទុកចិត្តព្រះជាម្ចាស់ថាព្រះអង្គនឹងផ្គត់ផ្គង់អ្វីគ្រប់យ៉ាងដែលអ្នកចង់បាននៅពេលវេលាសមរម្យណាមួយ។

> បញ្ហាភាគច្រើនរបស់យើងមិនមែនដោយសារយើងគ្មានលុយគ្រប់គ្រាន់ទេ តែដោយសារតែយើងចំណាយលើសអ្វីដែលយើងមាន!

## ៣. ការព្រួយបារម្ភពីខ្លួនឯង និងពីអ្វីៗដែលទាក់ទងជាមួយយើង

រឿងនេះ ប្រហែលជាការព្រួយបារម្ភលេខមួយហើយមើលទៅ នៅក្នុងពិភពលោកយើងនេះ។ យើងព្រួយពីរឿងរាប់រយដែលទាក់ទងនឹងយើង។ យើងព្រួយពីសុខភាពរបស់យើង។ បើយើងបានទទួលរបាយការណ៍មិនល្អពីវេជ្ជបណ្ឌិត គំនិតរបស់យើងអាចគិតពីអ្វីដែលនឹងកើតឡើងទៅមុខទៀតជាមួយយើង។ តើយើងនឹងរងទុក្ខទេ? តើយើងនឹងស្លាប់ទេ? ទោះបីជាព្រះជាម្ចាស់ផ្តល់សមត្ថភាពខាងផ្នែកវេជ្ជសាស្ត្រដល់មនុស្សយ៉ាងណាក្តី ក៏យើងត្រូវចាំថា ព្រះយេស៊ូ គឺជាព្រះនៃការប្រោសឲ្យជារបស់យើង! ព្រះអង្គចង់ឲ្យយើងទុកចិត្តព្រះអង្គ និងដើរតាមដំបូន្មានរបស់ព្រះអង្គក្នុងរឿងដែលទាក់ទងទៅនឹងសុខភាពរបស់យើងផងដែរ។

ពេលខ្ញុំកាន់តែចាស់ ខ្ញុំកាន់តែមានសុខភាពល្អ ព្រោះខ្ញុំបានបន្តរៀនពីរបៀបគោរពរូបកាយរបស់ព្រះគ្រិស្តដែលបានប្រទានមកខ្ញុំដោយព្រះគុណដ៏អស្ចារ្យ។

យើងមានអភ័យឯកសិទ្ធិក្នុងការទុកចិត្ត ថាព្រះជាម្ចាស់នឹងរក្សាយើងឲ្យនៅតែមានសុខភាពល្អ ជាជាងគ្រាន់តែប្រោសយើងឲ្យជានៅពេលដែលយើងឈឺ។

ឧទាហរណ៍៖ យើងមិនអាចបន្តរស់នៅក្រោមការថប់បារម្ភ ហើយរំពឹងថាមានសុខភាពល្អឡើយ។ ពេលខ្ញុំស្ថិតនៅក្នុងវ័យ៣០ឆ្នាំ ខ្ញុំតែងតែមានអារម្មណ៍មិនល្អ តែឥឡូវពេលដែលខ្ញុំស្ថិតក្នុងវ័យ៧០ឆ្នាំ ខ្ញុំមានអារម្មណ៍ល្អស្ទើរតែគ្រប់ពេល!ខ្ញុំកំណត់ការផ្លាស់ប្តូរ ស្ទើរតែទាំងអស់ គឺបង្កើតទំលាប់បរិភោគឲ្យបានទៀងទាត់ ធ្វើលំហាត់ប្រាណ ហើយរៀនរស់ជាមួយនឹងការថប់បារម្ភតិចបំផុត ហើយខ្ញុំក៏ទុកចិត្តព្រះយេស៊ូឲ្យព្រះអង្គប្រើអំណាច នៃការប្រោសឲ្យជារបស់ព្រះអង្គនៅក្នុងខ្ញុំគ្រប់ពេលវេលា។ យើងមិនត្រូវចាំទាល់តែយើងឈឺទើបយើងសុំការប្រោសឲ្យជានោះទេ! យើងមានអភ័យឯកសិទ្ធិក្នុងការទុកចិត្តថាព្រះជាម្ចាស់នឹងរក្សាយើងឲ្យនៅតែមានសុខភាពល្អ ជាជាងគ្រាន់តែប្រោសយើងឲ្យជានៅពេលដែលយើងឈឺ។

ព្រះអង្គរីករាយក្នុងការមើលថៃយើង។ ព្រះបន្ទូលរបស់ព្រះអង្គចែងថាព្រះជាម្ចាស់ចាប់អារម្មណ៍លើអ្វីគ្រប់យ៉ាងដែលទាក់ទងជាមួយយើង៖

*ព្រះយេហូវ៉ាទ្រង់នឹងធ្វើឲ្យជំនឿនរបស់ទូលបង្គំបានពេញខ្នាតឡើងឱព្រះយេហូវ៉ាអើយ សេចក្តីសប្បុរសរបស់ទ្រង់ស្ថិតស្ថេរនៅជាដរាបសូមទ្រង់កុំបោះបង់ចោលអស់ទាំងស្នាដៃនៃព្រះហស្តទ្រង់ឡើយ។*

ទំនុកតម្កើង ១៣៨:៨

យើងជាស្នាព្រះហស្តរបស់ព្រះអង្គ ជាបុត្ររបស់ព្រះអង្គ ហើយព្រះអង្គប្តូរផ្តាច់ក្នុងការថែរក្សាយើងបើយើងអនុញ្ញាតឲ្យព្រះអង្គធ្វើបែបនេះ។ ខគម្ពីរដែលខ្ញុំចូលចិត្តទាក់ទងទៅនឹងការទុកចិត្តព្រះជាម្ចាស់ គឺនៅក្នុងគម្ពីរ១ពេត្រុស។ចូរអានខគម្ពីរនេះដោយប្រុងប្រយ័ត្ន។

*កាលគេបានជេរប្រមាថដល់ទ្រង់ នោះទ្រង់មិនបានជេរតបវិញទេខណៈដែលទ្រង់រងទុក្ខ នោះក៏មិនបានគំហកកំហែងដល់គេដែរ គឺបានប្រគល់ព្រះអង្គទ្រង់ទៅព្រះ ដែលជំនុំជំរះដោយសុចរិតវិញ។*

១ពេត្រុស ២:២៣

ខគម្ពីរមួយខនេះសរុបអ្វីគ្រប់យ៉ាងដែលខ្ញុំចង់និយាយនៅក្នុងសៀវភៅនេះ។ យើងអាចទុកចិត្តព្រះជាម្ចាស់គ្រប់ពេលវេលា ក្នុងគ្រប់របៀប ដោយខ្លួនយើងផ្ទាល់ និងជាមួយអ្វីៗគ្រប់យ៉ាង។ គ្មានអ្វីដែលយើងថ្វាយទៅព្រះអង្គដែលព្រះអង្គមិនអាចគ្រប់គ្រងបាននោះឡើយ។ ទោះបីជាមនុស្សប្រព្រឹត្តចំពោះព្រះយេស៊ូយ៉ាងណាក៏ដោយ ក៏ព្រះអង្គមិនព្យាយាមថែរក្សាអង្គទ្រង់ទេ តែផ្ទុយទៅវិញព្រះអង្គទុកចិត្តព្រះបិតារបស់ព្រះអង្គក្នុងការធ្វើការនេះ។

តើមានការថប់បារម្ភ និងការមិនសប្បាយចិត្តប៉ុន្មានដែលយើងបង្កើតនៅក្នុងជីវិតរបស់យើងដោយខ្លួនឯង ដើម្បីបញ្ជាក់ថាយើងបានធ្វើត្រឹមត្រូវ និងគ្មាននរណាម្នាក់កេងចំណេញពីយើងបាន? ខ្ញុំជឿថាវាលើសពីអ្វីដែលយើងអាចស្រមៃ។ ដោយសារយើងមកដល់ចុងបញ្ចប់នៃសៀវភៅនេះហើយ ខ្ញុំចង់សួរអ្នកថា តើអ្នកមកដល់ចំណុចមួយនៅក្នុងជីវិតដែលអ្នកចង់ថ្វាយខ្លួនរបស់អ្នក និងអ្វីៗគ្រប់បែបយ៉ាងដែលអ្នកមានទៅព្រះយេស៊ូឬទេ។ តើអ្នកនឹងប្រគល់ខ្លួនរបស់អ្នកទៅព្រះអង្គ និងប្តូរផ្តាច់ក្នុងការស្តាប់បង្គាប់ព្រះអង្គក្នុងគ្រប់អ្វីដែលព្រះអង្គសុំឲ្យអ្នកធ្វើ ដោយអ្នកទុកចិត្តថា ព្រះអង្គនឹងថែរក្សាអ្នកដែរឬទេ?

## *តើអ្នកមាន «ខ្លួនអ្នក» ច្រើនប៉ុណ្ណានៅក្នុង«គំនិតរបស់អ្នក»?*

យើងបារម្ភថា តើអ្នកណានឹងមើថែយើងនិងថា តើគេនឹងមើលថែយើងបានល្អដែរឬយ៉ាងណា? បើយើងអាចពឹងលើអ្នកដទៃ តើគេនឹងធ្វើយ៉ាងណា? យើងបារម្ភពីការដែលអ្នកដទៃគិតពីយើង ហើយថាតើគេចូលចិត្តយើងដែរឬទេ។ តើយើងធ្វើឲ្យពួកគេសប្បាយចិត្តឬទេ? តើនៅក្នុងពិភពលោកនឹងមានរឿងអ្វីកើតឡើងហើយថា តើវា

មានឥទ្ធិពលយ៉ាងដូចម្ដេចចំពោះយើង? តើយើងនឹងបាត់បង់ការងារដែរឬទេ បើមានវិបត្តិសេដ្ឋកិច្ច?

«តើនឹងមានអ្វីកើតឡើងជាមួយខ្ញុំ»? គឺជាការភ័យខ្លាចដ៏ធំបំផុតដែលយើងមាន ប៉ុន្តែដំណឹងល្អគឺថា យើងអាចកាត់បន្ថយការព្រួយបារម្ភណ៍របស់យើងនៅថ្ងៃនេះ និងដឹងថាព្រះជាម្ចាស់នឹងថែរក្សាយើង។

សុំឲ្យព្រះជាម្ចាស់ជួយអ្នកឲ្យដក*ខ្លួនអ្នក*ចេញពីគំនិតរបស់អ្នក ពីព្រោះបើអ្នកគិតពីខ្លួនឯងកាន់តែតិច អ្នកនឹងមានអំណរកាន់តែច្រើន។ ក្នុងពេលដែលអ្នកទុកចិត្តថាព្រះអង្គនឹងមើលថែអ្នក ត្រូវប្រាកដថា អ្នកបានព្រោះពូជល្អដោយជួយដល់អ្នកដទៃ។ គ្រប់ពេលដែលអ្នកជួយមនុស្សដែលខ្វះខាត នោះអ្នកកំពុងតែសាបព្រោះពូជសម្រាប់ការច្រូតកាត់មកវិញជាជំនួយពីព្រះជាម្ចាស់នៅក្នុងជីវិតរបស់អ្នកផ្ទាល់។

កាលពីច្រើនឆ្នាំកន្លងទៅខ្ញុំបានមកដល់ចំណុចមួយនៅក្នុងជីវិតរបស់ខ្ញុំ នៅពេលដែលខ្ញុំមានការមិនសប្បាយចិត្តខ្លាំង ខ្ញុំចង់ឃើញអ្វីមួយដែលព្រះជាម្ចាស់ចង់បង្ហាញខ្ញុំដើម្បីឲ្យខ្ញុំអាចរីករាយបាន។ វាជាសាច់រឿងយ៉ាងវែង តែសរុបសេចក្ដីមកព្រះអង្គបានបង្ហាញខ្ញុំថា ខ្ញុំមិនសប្បាយចិត្តមកពីខ្ញុំអត្តានិយម។ ខ្ញុំគិតពីខ្លួនឯងស្ទើរតែគ្រប់ពេលវេលា ហើយតាមរយៈការប្រឹងប្រែងជ្រុលហួសរបស់ខ្ញុំ ដើម្បីព្យាយាមបង្ហាញថាខ្ញុំពិតជាបានទទួលការថែទាំមែន ខ្ញុំបែរជារារាំងព្រះអង្គក្នុងការថែទាំខ្ញុំទៅវិញ។ ព្រះជាម្ចាស់ចង់មើលថែយើង ប៉ុន្តែយើងត្រូវថ្វាយខ្លួនរបស់យើងទៅព្រះអង្គ។

## *ចូរប្ដូរផ្ដាច់អ្វីៗទាំងអស់ថ្វាយព្រះជាម្ចាស់*

នៅពេលដែលយើងផ្ញើខ្លួនរបស់យើងលើនរណាម្នាក់ ឬលើអ្វីមួយ មានន័យថាយើងប្រគល់ខ្លួនរបស់យើងទៅអ្នកនោះ ឬរបស់នោះទាំងស្រុង។ យើងអាចប្ដូរផ្ដាច់ចំពោះនរណាម្នាក់ ឬចំពោះការងារ។ យើងប្ដូរផ្ដាច់ ចំពោះគ្រួសារ ឬមិត្តភ័ក្តិ។ ខ្ញុំប្ដូរផ្ដាច់ចំពោះការត្រាស់ហៅនៅក្នុងជីវិតរបស់ខ្ញុំ ដើម្បីបង្រៀនព្រះបន្ទូលរបស់ព្រះជាម្ចាស់។ ប៉ុន្តែក្រៅពីការប្ដូរផ្ដាច់ទាំងនេះ យើងគួរតែថ្វាយខ្លួនរបស់យើងទាំងស្រុង និងទាំងអស់ទៅព្រះជាម្ចាស់ ដើម្បីសុំឲ្យព្រះហឫទ័យរបស់ព្រះអង្គសម្រេចនៅក្នុងជីវិតរបស់យើង។ ការប្ដូរផ្ដាច់ពិតប្រាកដមិនដែលផុតកំណត់ឡើយ។ ខ្ញុំស្នើរឲ្យអ្នកអធិស្ឋានប្រចាំថ្ងៃដូចខាងក្រោមនេះ៖

«ព្រះវរបិតាអើយ ទូលបង្គំសូមថ្វាយខ្លួនរបស់ទូលបង្គំជាថ្មីម្ដងទៀតទៅក្នុងព្រះហស្តរបស់ព្រះអង្គ។ ទូលបង្គំទុកចិត្តថាព្រះអង្គនឹងមើលថែទូល

បង្គំក្នុងគ្រប់កិច្ចការទាំងអស់ និងគ្រប់ទាំងផ្លូវរបស់ទូលបង្គំផង។ សូមដឹកនាំទូលបង្គំ និងផ្តល់ព្រះគុណដល់ទូលបង្គំក្នុងការដើរតាមព្រះអង្គជារៀងរហូត។ បើទូលបង្គំមានការឈឺចាប់ ទូលបង្គំទុកចិត្តថាព្រះអង្គនឹងកំសាន្តចិត្តទូលបង្គំ។ បើទូលបង្គំមានជម្ងឺ ទូលបង្គំទុកចិត្តថា ព្រះអង្គនឹងប្រោសទូលបង្គំឲ្យបានជា។ បើទូលបង្គំត្រូវការអ្វី ទូលបង្គំជឿថាព្រះអង្គនឹងបំពេញ។ បើទូលបង្គំមិនដឹងថាទូលបង្គំត្រូវធ្វើអ្វី ទូលបង្គំទុកចិត្តថាព្រះអង្គនឹងបង្ហាញផ្លូវដល់ទូលបង្គំ។ ទូលបង្គំជារបស់ព្រះអង្គ ព្រះអង្គជារបស់ទូលបង្គំ ហើយទូលបង្គំទុកចិត្តព្រះអង្គ! នៅក្នុងព្រះនាមព្រះអម្ចាស់ព្រះយេស៊ូគ្រិស្ត អាមែន»!

តើយើងអាចថ្វាយអ្វីផ្សេងៗទៀត ដែលទាក់ទងនឹងយើងទៅព្រះជាម្ចាស់បានយ៉ាងដូចម្តេច ដើម្បីឲ្យយើងអាចថ្វាយខ្លួនយើងទាំងស្រុងទៅព្រះជាម្ចាស់បាន? ប្រហែលជាអ្នកក្លាយជាគ្រិស្តបរិស័ទដោយទទួលព្រះយេស៊ូជាព្រះសង្គ្រោះ ប៉ុន្តែតើអ្នកធ្លាប់ថ្វាយខ្លួនរបស់អ្នកទាំងស្រុង ដើម្បីឲ្យព្រះអង្គមើលថែនិងថែរក្សាដែរឬទេ? ខ្ញុំជឿថា នេះជាអ្វីដែលយើងត្រូវការបំផុត!

ជីវិតដ៏ល្អរបស់អ្នកអាចចាប់ផ្តើមក្នុពេលឥឡូវនេះ បើអ្នកមានឆន្ទៈក្នុងការថ្វាយខ្លួនរបស់អ្នកឲ្យព្រះយេស៊ូថែរក្សា និងអនុញ្ញាតិឲ្យព្រះអង្គមើលថែអ្នក!

*ហើយចូរផ្ទេរគ្រប់ទាំងសេចក្តីទុក្ខព្រួយរបស់អ្នករាល់គ្នាទៅលើទ្រង់ ដ្បិតទ្រង់តែងយកព្រះទ័យទុកដាក់នឹងអ្នករាល់គ្នា។*

១ ពេត្រុស ៥:៧

ខ្ញុំមានអំណរក្នុងការសរសេរសៀវភៅនេះ ខ្ញុំមិនត្រឹមតែអធិស្ឋានឲ្យអ្នករីករាយក្នុងការអានសៀវភៅនេះប៉ុណ្ណោះទេ ប៉ុន្តែក៏សូមឲ្យសៀវភៅនេះជាសៀវភៅដែលធ្វើឲ្យអ្នកបានស្តារការប្តូរផ្តាច់របស់អ្នកចំពោះការទុកចិត្តព្រះជាម្ចាស់ក្នុងគ្រប់អ្វីៗ និងគ្រប់ពេលវេលាទាំងអស់!

# NOTES


1. “Trust,” Webster’s Dictionary 1828---Online Edition, http://Webstersdictionary1838.com/Dictionary/trust.
2. “Trust,” Merriam-Webster.com, www.merriamwebster.com/dictionary/trust.
3. Dr. Erwin W. Lutzer, “Who Can You Trust?,” Moody Church Media, 2002 www.moodymedia.org/articles/who-can-you-trust/.
4. “Charles Dickens Quotes, ”Goodreads, www.goodreads.com/quotes/18876-no-one-is-useless-in-this-world-who-lightens-the.
5. “John Bunyan Quotes,” Goodreads, www.goodreads.com/quotes/41980-you-have-not-lived-todaty-until-you-have-done-something.
6. “Saint Augustine Quotes,” BrainyQuote, www.brainyquote.com/quotes/quotes/s/saintaugus108487.html.
7. Lee Strobel, “Why Dose God allow Tragedy and Suffering?,” CT Pastors, http/:www.christianitytoday.com/pastor/2012/july-online-ony/dosegodallowtragedy.html.
8. “C.S. Lewis Quotes About Conscince,” AZ Quotes, www.azquote.com/author/8805-C_S_Lewis/tag?conscience.
9. “Abraham Lincoln Quotes,” Goodreads, www.goodreads.com/quote/24046-the-best-thing-about-the-future-is-that-it-comess.
10. “Charles Spurgeon Quotes,”AZ Quotes, www.azquotes.com/quote/1411293.
11. “Dietrich Bonhoeffer Quotes,” Goodreads, www.goodreads.com/quotes/328974-judging-others-makes-us-blind-whereas-love-is-illuminating-by.

# តើអ្នកមានទំនាក់ទំនងពិតប្រាកដជាមួយព្រះយេស៊ូដែរឬទេ?

ព្រះជាម្ចាស់ស្រឡាញ់អ្នក! ព្រះអង្គបានបង្កើតអ្នកមកជាមនុស្សពិសេស ដោយឡែក តែមួយគត់ ហើយព្រះអង្គមានគោលបំណងនិងផែនការច្បាស់លាស់សម្រាប់ជីវិតរបស់អ្នក។តាមរយៈទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះអាទិករ និងជាព្រះជាម្ចាស់របស់អ្នក អ្នកអាចស្វែងរកផ្លូវនៃជីវិតដែលពិតជាធ្វើឲ្យព្រលឹងរបស់អ្នកស្កប់ស្កល់។

មិនថាអ្នកជាអ្នកណាទេតើអ្នកបានធ្វើអ្វីទេ ឬថាតើឥឡូវនេះអ្នកដើរដល់ចំណុចណានៅក្នុងជីវិតរបស់អ្នកទេ ព្រះយេស៊ូពិតជាមានបំណងលះបង់ព្រះជន្មរបស់ព្រះអង្គដើម្បីឲ្យអ្នកអាចទទួលការអត់ទោសពីព្រះជាម្ចាស់ និងមានជីវិតថ្មីនៅក្នុងព្រះអង្គ។ ព្រះអង្គកំពុងរង់ចាំឲ្យអ្នកអញ្ជើញព្រះអង្គឲ្យធ្វើជាព្រះសង្គ្រោះ និងជាព្រះជាម្ចាស់របស់អ្នក។

បើអ្នករួចរាល់ដើម្បីថ្វាយជីវិតរបស់អ្នកដល់ព្រះយេស៊ូនិងដើរតាមព្រះអង្គហើយ អ្វីដែលអ្នកត្រូវធ្វើគឺគ្រាន់តែសុំព្រះអង្គឲ្យអត់ទោសបាបដល់អ្នក និងផ្តល់ការចាប់ផ្តើមថ្មីនៅក្នុងជីវិតរស់នៅថ្មីដ៏មានន័យរបស់អ្នក។ សូមចាប់ផ្តើមដោយការអធិស្ឋានបែបនេះថា៖

*ព្រះអម្ចាស់យេស៊ូ អរព្រះគុណព្រះអង្គដែលបូជាជីវិតរបស់ព្រះអង្គសម្រាប់ទូលបង្គំ ហើយអត់ទោសបាបដល់ទូលបង្គំ ដែលអាចធ្វើឲ្យទូលបង្គំមានទំនាក់ទំនងដោយផ្ទាល់ជាមួយព្រះអង្គ។ ទូលបង្គំពិតជាសោកស្តាយសម្រាប់កំហុសដែលទូលបង្គំបានប្រព្រឹត្ត ហើយទូលបង្គំដឹងថាទូលបង្គំត្រូវការព្រះអង្គជួយទូលបង្គំឲ្យរស់នៅក្នុងផ្លូវត្រឹមត្រូវ។*

*ព្រះបន្ទូលរបស់ព្រះអង្គចែងនៅក្នុងគម្ពីររ៉ូម១០:១៩ថា «បើមាត់អ្នកទទួលថ្លែងប្រាប់ពីព្រះអម្ចាស់យេស៊ូ ហើយអ្នកជឿក្នុងចិត្តថាព្រះបានប្រោសឲ្យទ្រង់រស់ពីស្លាប់ឡើងវិញនោះអ្នកនឹងបានសង្គ្រោះពិត។ ទូលបង្គំជឿថាព្រះអង្គជាព្រះរាជបុត្រារបស់ព្រះជាមច្ចាស់ ហើយប្រកាសថាព្រះអង្គជាព្រះសង្គ្រោះ និងជាព្រះអម្ចាស់ របស់ទូលបង្គំ។ សូមទទួលយកទូលបង្គំ ហើយធ្វើការនៅក្នុងចិត្តរបស់ទូលបង្គំ សូមច្នៃទូលបង្គំឲ្យបានទៅជាមនុស្សដែលព្រះអង្គសព្វព្រះទ័យ។ ព្រះយេស៊ូអើយ! ទូលបង្គំចង់រស់នៅសម្រាប់ព្រះអង្គ ហើយទូលបង្គំពិតជាអរព្រះគុណដែលព្រះអង្គប្រទានឲ្យទូលបង្គំនូវការចាប់ផ្តើមថ្មីនៅក្នុងជីវិតថ្មីរបស់ទូលបង្គំជាមួយព្រះអង្គនៅថ្ងៃនេះ។*

*ព្រះយេស៊ូ! ទូលបង្គំស្រឡាញ់ព្រះអង្គ!*

វាជាការអស្ចារ្យដែលយើងដឹងថាព្រះជាម្ចាស់ស្រឡាញ់យើងខ្លាំងណាស់! ព្រះអង្គចង់មានទំនាក់ទំនងស៊ីជម្រៅ និងជិតស្និតជាមួយយើង ដែលជាទំនាក់ទំនងដែលប្រសើរឡើងរាល់ថ្ងៃនៅពេលដែលយើងចំណាយពេលជាមួយព្រះអង្គដោយការអធិស្ឋាន និងការសិក្សាព្រះគម្ពីរ។ យើងចង់លើកទឹកចិត្តអ្នកក្នុងជីវិតថ្មីរបស់អ្នកជាមួយព្រះគ្រិស្ត។

សូមស្វែងរកតាមរយៈ joycemeyer.org/salvation ដើម្បីស្នើសុំសៀវភៅរបស់អ្នកស្រីចយ៍ គឺសៀវភៅ A New Way of Living ដែលជាអំណោយរបស់ពួកយើងដល់អ្នក។ យើងក៏មានប្រភពឥតគិតថ្លៃផ្សេងទៀតនៅលើអ៊ីនធ័រណេត ដើម្បីជួយអ្នកឲ្យទទួលបានអ្វីគ្រប់យ៉ាងដែលព្រះជាម្ចាស់ត្រៀមសម្រាប់អ្នក។

សូមអបអរសាទរលើការចាប់ផ្ដើមថ្មីក្នុងជីវិតរបស់អ្នកក្នុងព្រះគ្រិស្ត! យើងសង្ឃឹមថាយើងនឹងបានទទួលដំណឹងពីអ្នកឆាប់ៗនេះ។

# អំពីអ្នកនិពន្ធ

អ្នកស្រី ចយស៍ ម៉ៃយ័រ ជាអ្នកបង្រៀនព្រះបន្ទូលនាំមុខគេម្នាក់នៅលើពិភពលោក នេះ។ ការផ្សាយតាមទូរទស្សន៍ប្រចាំថ្ងៃ *ជីវិតរីករាយប្រចាំថ្ងៃ* ត្រូវបានផ្សព្វផ្សាយលើ បណ្តាញរាប់រយប៉ុស្តទូរទស្សន៍ និង តាមស្ថានីយ៍វិទ្យុពេញពិភពលោក។

អ្នកស្រី ចយស៍ ម៉ៃយ័រ បានសរសេរសៀវភៅជាងមួយរយបំផុសខាងវិញ្ញាណ។ សៀវភៅរបស់អ្នកស្រីដែលលក់ដាច់បំផុតរួមមាន *អំណាចនៃការគិត, ភាពជឿជាក់នៃស្ត្រី, មើលល្អ អារម្មណ៍ល្អ, ការចាប់ផ្តើមថ្ងៃរបស់អ្នកត្រឹមត្រូវ, បញ្ចប់ថ្ងៃរបស់ អ្នកត្រឹមត្រូវ, ព្រះគម្ពីរជាជីវិតប្រចាំថ្ងៃ, ការយល់ព្រមការញៀន, ឮព្រះសូរ សៀងព្រះជាម្ចាស់ដូចម្តេច, ភ្លូងលំអរជំនួសផេះ និងសមរភូមិនៃគំនិត*។

អ្នកស្រី ចយស៍ ម៉ៃយ័រ ធ្វើដំណើរយ៉ាងខ្លាំង រៀបចំការប្រជុំធំៗពេញមួយឆ្នាំ និង ចែកចាយរាប់ពាន់ដងជុំវិញពិភពលោក។

# JOYCE MEYER MINISTRIES ADDRESS

សូមចូលទៅកាន់គេហទំព័រ tv.joycemeyer.org ដើម្បីទស្សនា សាររបស់អ្នកស្រី ចយស៍នៅក្នុងភាសារផ្សេងៗ


**Joyce Meyer Ministries**
P.O. Box 655
Fenton, MO 63026
USA
(636) 349-0303

**Joyce Meyer Ministries--Canada**
P.O. Box 7700
Vancouver, BC V6B 4E2
Canada
(800) 868-1002

**Joyce Meyer Ministries--Australia**
Locked Bag 77
Mansfield Delivery Centre
Queensland 4122
Australia
(07) 3349 1200

**Joyce Meyer Ministries--England**
P.O. Box 1549
Windsor SL4 1GT
United Kingdom
01753 831102

**Joyce Meyer Ministries—South Africa**
P.O. Box 5
Cape Town 8000
South Africa
(27) 21-701-1056

## OTHER BOOKS BY JOYCE MEYER

*100 Ways to Simplify Your Life*
*21 Ways to Finding Peace and Happiness*
*Any Minute*
*Approval Addiction*
*The Approval Fix**
*The Battle Belongs to the Lord*
*Battlefield of the Mind**
*Battlefield of the Mind for Kids*
*Battlefield of the Mind for Teens*
*Battlefield of the Mind Devotional*
*Be Anxious for Nothing**
*Being the Person God Made You to Be*
*Beauty for Ashes*
*Change Your Words, Change Your Life**
*The Confident Mom**
*The Confident Woman*
*Do Yourself a Favor…Forgive**
*Eat the Cookie … Buy the Shoes**
*Eight Ways to Keep the Devil Under Your Feet*
*Ending Your Day Right*
*Enjoying Where You Are on the Way to Where You Are Going*
*The Everyday Life Bible*
*Filled with the Spirit*
*Get Your Hopes Up!**
*Good Health, Good Life**
*Hearing From God Each Morning*
*How to Hear from God**
*How to Succeed at Being Yourself*
*I Dare You*
*If Not for the Grace of God**
*In Pursuit of Peace*
*The Joy of Believing Prayer*
*Knowing God Intimately*
*A Leader in the Making*
*Life in the world*
*Living Beyond Your Feeling**
*Living Courageously**
*Look Great, Feel Great*
*Love Out Loud*
*The Love Revolution**
*Making Good Habits, Breaking Bad Habits**
*Making Good Habits, Breaking Bad Habits*
*Making Marriage Work (previously published as Help Me-I'm Married)*
*Me and My Big Mouth!**
*The Mind Connection**
*Never Give Up!*

*Never Lose Heart*
*New Day, New You*
*Overload*
*The Penny*
*Perfect Love (Previously published as God Is Not Mad at You )**
*The Power of Being Positive*
*The Power of Being Thankful*
*The Power of Determination*
*The Power of Forgiveness*
*The Power of Simple Prayer*
*Power Thoughts**
*Power Thoughts Devotional*
*Reduce Me to Love*
*The Secret Power of Speaking God's Word*
*The Secrets of Spiritual Power*
*The Secret to True Happiness*
*Seven Things that Steal Your Joy*
*Start Your New Life Today*
*Starting Your Day Right*
*Straight Talk*
*Teenagers Are People Too!*
*Trusting God Day by Day*
*The Word, the Name, the Blood*
*Women to Woman*
*You Can Begin Again**

## Joyce Meyer Spanish Titles

Belleza en Lugar de Cenizas (Beauty for Ashes)
Buena Salud, Buena Vida (Good Health, Good Life)
Cambia Tus Palabras, Cambia Tu Vida (Change Your Words, Change Your Life)
El Campo de Batalla de la Mente (Battlefield of the Mind)
Como Formar Buenos Habitos y Romper Malos Habitos (Making Good Habits, Breaking Bad Habits)
La Conexion de la Mente (The Mind Connection)
Dios No Esta Enojado Contigo (God Is Not Mad at You)
La Dosis de Aprobacion (The Approval Fix)
Empezando Tu Dia Bien (Starting Your Day Right)
Hazte un Favor a Ti Mismo…Perdona (Do Yourself a Favor…Forgive)
Madre Segura de Si Misma (The Confident Mom)
Pensamientos de Poder (Power Thoughts)
Sobrecarga (Overload)*
Termina Bien Tu Dia (Ending Your Day Right)
Usted Puede Comenzar de Nuevo (You Can Begin Again)
Viva Valientemente (Living Courageously)

*Study Guide available for this title

Books By Dave Meyer
Life Lines

**នៅពេលយើងដាក់ចំណែកនៃការទុកចិត្តព្រះជាម្ចាស់ដ៏ត្រឹមត្រូវ ចូលក្នុងគ្រប់កិច្ចការដែលយើងធ្វើ នោះនឹងនាំឲ្យយើងរស់នៅដោយគ្មានការខ្វល់ខ្វាយ ការថប់បារម្ភ ការភ័យខ្លាច ការដោះសារ ឬការតានតឹងដែលនាំឲ្យល្ហិតល្ហៃ...**

តាំងពីមនុស្សម្នាក់ៗចង់ពឹងផ្អែកលើខ្លួនឯង និងចង់បានឯករាជ្យមក ធ្វើឲ្យយើងត្រូវចំណាយពេល ដើម្បីរៀនពីរបៀបទុកចិត្តព្រះជាម្ចាស់។ ចំណុចពិបាកដែលកើតចេញពីបទពិសោធន៍មិនគាប់ចិត្តរបស់យើង បានបង្រៀនយើងថា យើងមិនអាចទុកចិត្តមនុស្សគ្រប់ពេលបានទេ។ ក៏ប៉ុន្តែ ផ្លូវរបស់ព្រះជាម្ចាស់វិញខុសពីផ្លូវរបស់មនុស្សឆ្ងាយណាស់ ហើយព្រះបន្ទូលរបស់ព្រះអង្គក៏បង្រៀនយើងដែរថា បុគ្គលិកលក្ខណៈរបស់ព្រះអង្គ គឺមិនអាចកុហក ឬមិនអាចបោកបញ្ឆោតឡើយ។

នៅក្នុងសៀវភៅនេះ ខ្ញុំសង្ឃឹមថា ខ្ញុំអាចចែករំលែកជាមួយអ្នករាល់គ្នា ថាអ្នករាល់គ្នាអាចរៀនទុកចិត្តដោយឥតព្រំដែន ហើយមានសេចក្ដីជំនឿលើសពីភាពសមហេតុសមផល។ ការទុកចិត្តលើព្រះជាម្ចាស់ទាំងស្រុង គួរតែជាគោលដៅរបស់យើង គឺមិនមែនគ្រាន់តែដោយព្រោះ ការទុកចិត្តព្រះជាម្ចាស់ជាការគោរពដល់ព្រះអង្គប៉ុណ្ណោះទេ ក៏ប៉ុន្តែដោយសារការទុកចិត្តនេះផ្ដល់អត្ថប្រយោជន៍ដ៏សម្បើមដល់យើង។

ណែនាំដោយ អ្នកស្រី **ចយស៍ ម៉ៃយ័រ**

ការរស់នៅរបស់គ្រិស្តបរិស័ទ